# មហា

# សតិប្បដ្ឋានភាវនា

## ព្រះពុទ្ធដីកា

## អដ្ឋកថា និង មហាដីកា

សតិប្បដ្ឋាន

ជាផ្លូវមូលតែមួយប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ

រៀបរៀងដោយខ្ញុំបាទ អ៊ឹម រ៉ៃយ៉ា

ព.ស. ២៥៥២

# មហា

# សតិប្បដ្ឋានភាវនា

## ព្រះពុទ្ធដីកា

## អដ្ឋកថា និង មហាដីកា



សតិប្បដ្ឋាន

ជាផ្លូវមូលតែមួយប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ

រៀបរៀងដោយខ្ញុំបាទ អ៊ុម វ៉ៃយ៉ា

ព.ស. ២៥៥២

# សំវេជនីយធម៌

## " មហាបរិនិព្វានសូត្រ "

ម្នាលអានន្ទ ក្រែងតថាគតប្រាប់អ្នកជាមុនហើយ យ៉ាងនេះថា សេចក្តីព្រាត់ប្រាស សេចក្តីវិនាស សេចក្តីប្រែប្រួល ចាកសត្វនិងសង្ខារជាទីស្រឡាញ់ជាទីពេញចិត្តទាំងអស់ តែងមានជាធម្មតា ម្នាលអានន្ទ ព្រោះហេតុនោះបុគ្គលគប្បីបាននូវសេចក្តីទៀងទាត់ មិនព្រាត់ប្រាស ក្នុងខន្ធប្រវត្តិនេះ អំពីទីណា ធម្មជាតិណា កើតឡើងហើយ មានហើយ សង្ខារតាក់តែងហើយ តែងមានសេចក្តីវិនាសទៅជាធម្មតា ធម្មជាតិនោះឯង បុគ្គលនឹងពោលថា កុំវិនាសដូច្នេះ ហេតុនោះ មិនមានឡើយ ។ ម្នាលអានន្ទ មួយទៀត ធម្មជាតិណា ដែលតថាគតទាត់ចោលហើយ ខ្ជាក់ចោលហើយ ជម្រុះចោលហើយ លះបង់ចោលហើយ បន្សាត់ចោលហើយ អាយុសង្ខារតថាគតដាក់ចុះហើយ វាចាតថាគតពោលដោយពិតថា បរិនិព្វាននៃតថាគតមិនយូរឡើយ កន្លង ៣ ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ តថាគតនឹងត្រឡប់មកកាន់ធម្មជាតិនេះវិញទៀត ព្រោះហេតុនៃជីវិតប៉ុណ្ណោះ ហេតុនុ៎ះ មិនមានឡើយ ម្នាលអានន្ទមកយើងនឹងទៅកាន់កូដាគារសាលា នាមហាវ័ន ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏ស្តេចចូលទៅកាន់ កូដាគារសាលា នាមហាវ័ន មួយអន្លើដោយព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថាម្នាលអានន្ទ អ្នកចូរទៅឱ្យពួកភិក្ខុទាំងប៉ុន្មាន ដែលអាស្រ័យនៅក្នុងក្រុងវេសាលី

ទាំងអស់នោះ មកជួបជុំក្នុងឧបដ្ឋានសាលា ។ ព្រះអានន្ទមានអាយុ ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏ឱ្យភិក្ខុទាំងប៉ុន្មានដែលអាស្រ័យនៅក្នុងក្រុងវេសាលី ទាំងអស់នោះ មកប្រជុំគ្នា ក្នុងឧបដ្ឋានសាលា ហើយចូលទៅគាល់ព្រះមានព្រះភាគហើយ ឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ ឋិតនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃប្រជុំគ្នាហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គ ទ្រង់សម្គាល់កាលគួរ ក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ ទ្រង់គង់ស្រេចហើយ ក៏បានត្រាស់នឹងភិក្ខុទាំងឡាយថា សាសនព្រហ្មចរិយៈនេះ គប្បីតាំងនៅអស់កាលជាអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្តែងហើយ ដោយបញ្ញាដ៏ឧត្តម ធម៌ទាំងឡាយនោះ អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយ ៗ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សាសនព្រហ្មចរិយធម៌ គប្បីតាំងនៅអស់កាលជាអង្វែង គប្បីតម្កល់នៅអស់កាលដ៏យូរ មួយទៀត សាសនព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក

ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្ដែងហើយដោយបញ្ញាដ៏ឧត្ដម អ្នកទាំងឡាយ គប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ តើដូចម្ដេច , អ្វីខ្លះ , គឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលភិក្ខុទាំងឡាយ សាសន-ព្រហ្មចរិយៈនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ដោយប្រការណា ធម៌ទាំងឡាយណា ដែលតថាគតសម្ដែងហើយ ដោយបញ្ញាដ៏ឧត្ដម អ្នកទាំងឡាយគប្បីរៀនដោយប្រពៃ ហើយសេព ចម្រើន ធ្វើរឿយ ៗ ដោយប្រការដូច្នោះ ធម៌ទាំងឡាយនោះ យ៉ាងនេះឯង ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតនឹងដាស់តឿនអ្នកទាំងឡាយ សង្ខារទាំងឡាយ មានសេចក្ដីវិនាសទៅជាធម្មតា អ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ បរិនិព្វាននឹងមានដល់តថាគតមិនយូរឡើយ កន្លង៣ខែ អំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ព្រះសុគតជាសាស្ដា លុះទ្រង់មានព្រះបន្ទូលដូច្នេះហើយ ក៏ទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា ពួកជនណា ៗ ទោះបីក្មេងក្ដី ចាស់ក្ដី ពាលក្ដី បណ្ឌិតក្ដី អ្នកមានក្ដី អ្នកក្រក្ដី ជនទាំងអស់នោះ តែងមានសេចក្ដីស្លាប់នៅពីខាងមុខ ។

ភាជន៍ដី ដែលស្មូនផ្នាំងធ្វើហើយ ទោះបីតូចក្តី ធំក្តី ឆ្អិនក្តី ឆៅក្តី ភាជន៍ទាំងអស់នោះ មានកិរិយាបែកធ្លាយជាទីបំផុត យ៉ាងណា ជីវិតរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។ ព្រះសាស្តាទ្រង់មានព្រះបន្ទូលដូច្នេះ តទៅទៀតថា វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគត មានប្រមាណតិច តថាគតនឹងលះបង់អ្នកទាំងឡាយ ហើយទៅ ឯទីពឹងចំពោះខ្លួន តថាគតបានធ្វើទុកហើយ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរកុំប្រមាទ ត្រូវមានស្មារតី មានសីលល្អមានតម្រិះតម្កល់នឹងល្អ ចូររក្សាចិត្តរបស់ខ្លួន ឱ្យរឿយៗចុះ ភិក្ខុណាមិនប្រមាទហើយនៅក្នុងធម្មវិន័យនេះ នឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវព្រះនិព្វានជាទីបំផុតនៃកងទុក្ខបានមិនខានឡើយ ។

( ភាណវារៈមួយទៀត ) ម្នាលអានន្ទ បុគ្គលណាមួយ ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ បុគ្គលនោះ ឈ្មោះថា ធ្វើសក្ការៈគោរពរាប់អាន បូជាតថាគត ដោយគ្រឿងបូជាដ៏ឧត្តម ម្នាលអានន្ទ ព្រោះហេតុនោះ បរិស័ទក្នុងសាសនានេះ គប្បីសិក្សាថា យើងទាំងឡាយនឹងប្រព្រឹត្តនូវធម៌ សមគួរដល់ធម៌ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

អថខោ ភគវា ភិក្ខូ អាមន្តេសិ ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថាតិ ។ អយំ តថា-គតស្ស បច្ឆិមា វាចា ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ណ្ហើយចុះ ឥឡូវនេះ តថាគតប្រាប់អ្នកទាំងឡាយឱ្យបានដឹង សង្ខារ

ទាំងឡាយ មានសេចក្ដីសាបសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្ដីមិនប្រមាទចុះ ។ នេះជា បច្ឆិមវាចា របស់ព្រះតថាគត ។

# និទានវចនៈ

ព្រះពោធិសត្វ ទូន្មានតាបសកុមារជាបុត្រ ដែលធុញទ្រាន់ក្នុងការនៅព្រៃ ចង់ទៅនៅក្នុងស្ថានទីនៃមនុស្ស ថា :

បុគ្គលណា មិនមានអំពើអាក្រក់ដោយ កាយ វាចា និង ចិត្ត , បាចេញអំពីព្រៃនេះទៅហើយ ចូរតាំងខ្លួនឱ្យដូចជាកូន ដែលកើតអំពីទ្រូង ហើយគប្បីសេពគប់រកនូវបុគ្គលនោះចុះ ។

មួយទៀត បុគ្គលណា ប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន កូនចេញអំពីព្រៃនេះហើយ ចូរសេពគប់នូវបុគ្គលដែលជាអ្នកធ្វើនូវអំពើដ៏បរិសុទ្ធ ប្រកបដោយបញ្ញានោះចុះ ។

នៃបា ! បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់ល្មៀត មានចិត្តដូចជាសត្វស្វា ត្រេកអរហើយ បែរជាមិនត្រេកអរវិញ ( គឺ ស្រឡាញ់ហើយស្អប់ទៅវិញ ក្នុងខណៈនោះភ្លាមៗ ក្រេវក្រោធ ឆេវឆាវ មានចិត្តរំពៃចាប់កំហុសអ្នកដទៃ ) បើទុកជាផ្ទៃនៃជម្ពូទ្វីបទាំងមូលនេះ មិនមានមនុស្សសោះក៏ដោយកូនចូរកុំសេពគប់នូវបុរសបែបនោះឡើយ កូនចូរចៀសវាងអ្នកនោះអំពីចម្ងាយឱ្យដូចជាបុគ្គលអ្នកភ័យខ្លាច ចៀសវាងអសិរពិស ដ៏កាចសាហាវ អំពីចម្ងាយឬដូចបុគ្គលឆ្អើមលាមក ចៀសវាងនូវផ្លូវធំដែលប្រឡាក់ដោយលាមក ឬ ដូចបុគ្គលអ្នកទៅដោយយាន ចៀសវាងនូវផ្លូវដែលមិនរាបស្មើដូច្នោះ នៃបា អំពើដែលមិនជាប្រយោជន៍ទាំងឡាយ រមែងចម្រើនដល់បុគ្គលដែលសេពគប់នូវបុគ្គលពាលជ្រុលពេក កូនចូរកុំគប់រកជាមួយបុគ្គលពាលឡើយ ព្រោះការនៅរួមជាមួយនឹងបុគ្គលពាល ជាហេតុនាំសេចក្ដីទុក្ខមកឱ្យ ប្រៀបដូចជាការនៅរួម

ជាមួយនឹងសត្រូវសព្វ ៗ កាល ។

នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរកូន ចូរកូនធ្វើតាមពាក្យរបស់យើង ចូរកូនកុំសេពគប់ជាមួយបុគ្គលពាលឡើយ ព្រោះការនៅរួមជាមួយជនពាលទាំងឡាយ រមែងនាំសេចក្តីទុក្ខមកឱ្យ ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តី ចំពោះព្រះរតនត្រៃ អនុមោទនានូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

ខ្ញុំបាទសូមឧទ្ទិសកុសលជូនមាតាបិតាជាព្រះអរហន្តបច្ចុប្បន្ន ព្រមទាំងអតីតកាលផង ពួកញាតិក្នុងសង្សារវដ្តផង និង សព្វសត្វក្នុងត្រៃលោកផង លោកគ្រូបណ្ឌិតទាំងពីរ គឺ :

លោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស ផង

លោកគ្រូ បណ្ឌិតធម្មាចារ្យ រស់ សុជាត ផង

ដែលលោកទាំងពីរជាអាចារ្យរបស់ខ្ញុំ ជាអ្នកមានសីល មានចរិយាល្អបរិសុទ្ធ , ខ្ញុំអាស្រ័យលោកគ្រូទាំងពីរហើយ ទើបបានសិក្សានូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ក្នុងបដិបទាដ៏ត្រង់តែមួយគត់ គឺ សតិប្បដ្ឋាន ៤ ប្រព្រឹត្តទៅដើម្បីវិសុទ្ធិ គឺ **ព្រះនិព្វាន** ។

បាត់ដំបង , ថ្ងៃ ១៥ កើត ខែ មិគសិរ ព.ស ២៥៥២

រៀបរៀងដោយខ្ញុំបាទ អ៊ុម វ៉ៃយ៉ា

# សន្លឹកប្រាប់មាតិកា

មាតិកា លេខទំព័រ


បុព្វភាគនៃសតិប្បដ្ឋាន........................ ០៩

អានិសង្សនៃសតិប្បដ្ឋាន...................... ១១

កាយានុបស្សនាសតិប្បដ្ឋាន ១៦

**១. អានាបានបព្វ:**............................................ ២៩

- ការកំណត់ខ្យល់អស្សាសបស្សាស:..................... ៣២

- បាលីវិភង្គអំពីអានាបា.................................. ៤០

- ខ្យល់អានាបាសមថន័យ.............................. ៤៣

- ខ្យល់អានាបាវិបស្សនាន័យ.......................... ៤៤

**២. ឥរិយាបថបព្វ:**............................................ ៤៥

- ឥរិយាបថខាងក្នុង-ខាងក្រៅ.......................... ៤៩

**៣. សម្បជញ្ញបព្វ:**............................................ ៥១

- សាត្ថកសម្បជញ្ញ:............................................ ៥៣

- សប្បាយសម្បជញ្ញ:.......................................... ៥៤

- គោចរសម្បជញ្ញ:............................................ ៥៥

- អសម្មោហសម្បជញ្ញ:..................................... ៥៩

**៤. បដិកូលមនសិការបព្វ:**................................ ៦៩

**៥. ធាតុមនសិការបព្វៈ**.............................. ៧២

- បរិញ្ញា ៣...................................... ៩៣
- ភូមិរបស់បរិញ្ញា.................................. ៩៥

**៦. នវសីវថិកាបព្វៈ**.............................. ១០១

វេទនានុបស្សនាសតិប្បដ្ឋាន ១០៧

- លក្ខណៈនៃវេទនា ៥.............................. ១១០
- វេទនាជាអរូបកម្មដ្ឋាន............................. ១១៤

ចិត្តានុបស្សនាសតិប្បដ្ឋាន ១២១

- ចិត្តក្នុង-ចិត្តក្រៅ.................................. ១២៤

ធម្មានុបស្សនាសតិប្បដ្ឋាន ១៣៤

**១. នីវរណបព្វៈ**.................................. ១៣៤

- ហេតុឱ្យកើតកាមច្ឆន្ទៈ.............................. ១៣៨
- ធម៌សម្រាប់លះកាមច្ឆន្ទៈ............................ ១៣៩
- ហេតុឱ្យកើតព្យាបាទ............................... ១៤០
- ធម៌សម្រាប់លះព្យាបាទ.............................. ១៤១
- ហេតុឱ្យកើតថីនមិទ្ធៈ............................... ១៤៣
- ធម៌សម្រាប់លះថីនមិទ្ធៈ............................. ១៤៤
- ហេតុឱ្យកើតឧទ្ធច្ចកុក្កុច្ចៈ........................... ១៤៥
- ធម៌សម្រាប់លះឧទ្ធច្ចកុក្កុច្ចៈ......................... ១៤៦

- ហេតុឱ្យកើតវិចិកិច្ឆា............................... ១៤៧
- ធម៌សម្រាប់លះវិចិកិច្ឆា............................. ១៤៨
**២. ខន្ធបញ្ហ:**............................................... ១៥០
- សច្ចៈប្រាកដ........................................ ១៥៦
**៣. អាយតនបញ្ហ:**........................................... ១៥៨
- ហេតុឱ្យកើតសំយោជនៈ............................ ១៦២
- ការដឹងហេតុលះបង់សំយោជនៈ...................... ១៦៣
- អាយតនស័ព្ទ........................................ ១៦៦
**៤. ពោជ្ឈង្គបញ្ហ:**.......................................... ១៨៥
- សតិសម្ពោជ្ឈង្គ...................................... ១៨៧
- ធម្មវិចយសម្ពោជ្ឈង្គ................................. ១៨៨
- វីរិយសម្ពោជ្ឈង្គ..................................... ១៩៣
- បីតិសម្ពោជ្ឈង្គ...................................... ១៩៩
- បស្សទ្ធិសម្ពោជ្ឈង្គ.................................. ២០០
- សមាធិសម្ពោជ្ឈង្គ.................................... ២០២
- ឧបេក្ខាសម្ពោជ្ឈង្គ................................... ២០៤
**៥. សច្ចបញ្ហ:**............................................... ២០៨
- អត្ថរបស់សច្ចៈ....................................... ២២៧
- ទុក្ខអរិយសច្ចៈ...................................... ២៤៧
- សមុទយអរិយសច្ចៈ.................................. ២៧៨

- និរោធអរិយសច្ចៈ........................................ ២៨៥
- បញ្ហាកម្មដ្ឋ៏រិញរឿងព្រះនិព្វាន.......................... ៣១០
- ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ..................... ៣២៣
ទិដ្ឋិកថា................................................ ៣៣៧
ទិដ្ឋិវិសុទ្ធិ.............................................. ៣៥១
- ការកំណត់នាមរូប..................................... ៣៥៥
- អរូបធម៌ប្រាកដដោយអាការ ៣ យ៉ាង................. ៣៨០
មហាវិបស្សនា ១៨ ................................ ៤១២
- ឃនៈ ៤ ប្រការ........................................ ៤១៤

# សតិប្បដ្ឋាន
# ជាបុព្វភាគនៃវិបស្សនា មគ្គ ផល

សតិប្បដ្ឋាន គឺជាបុព្វភាគបដិបទា ក្នុងការចម្រើននូវលោកិយមគ្គដែលជាហេតុនៃលោកុត្តរមគ្គ ។

**វគ្គមួយ ក្នុងអដ្ឋកថា មហាសតិប្បដ្ឋានសូត្រ :**

ព្រះចុឡនាគត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ជាសិស្ស ពោលថា សតិប្បដ្ឋានជាមគ្គដើម ( បុព្វភាគ ) ។

ចំណែកព្រះចុឡសុមនត្ថេរ ទ្រទ្រង់ព្រះត្រៃបិដក ជាអាចារ្យពោលថា ជាមគ្គផ្សំ ( មិស្សកៈ ) ។ សិស្សពោលថា ជាខាងដើមទាន ។ អាចារ្យពោលថា ជាមគ្គផ្សំ អាវុសោ ។ តែពេលដែលអាចារ្យនិយាយរឿយ ៗ សិស្សក៏នៅស្ងៀម ទាំងសិស្ស ទាំងអាចារ្យ មិនស្របបញ្ហាគ្នា ក៏ផ្អាកទៅ ។ ពេលក្រោយមក ព្រះថេរៈជាអាចារ្យដើរទៅកាន់កន្លែងស្រង់ទឹក គិតពិចារណាថា យើងពោលថា ជាមគ្គផ្សំ ចំណែកចុឡនាគប្រកាន់ ពោលថា ជាបុព្វភាគ សេចក្តីវិនិច្ឆ័យក្នុងប្រការនេះយ៉ាងណាហ្ន៎ ! ក៏បានស្វាធ្យាយ មហាសតិប្បដ្ឋានសូត្រតាំងពីដើម ក៏កំណត់បាននូវវគ្គមួយថា " **ម្នាលភិក្ខុទាំងឡាយ អ្នកណាមួយ ចម្រើនសតិប្បដ្ឋាន ៤ នេះ រហូតដល់ទៅ ៧ ឆ្នាំ** " ក៏ដឹងថា លោកុត្តរមគ្គកើតឡើងហើយ ឈ្មោះថា តាំងនៅដល់ទៅ ៧ ឆ្នាំ មិនមាន ដែលយើងពោលថា ជាមគ្គផ្សំមិនបាន ។ ចំណែកចុឡនាគពោលថា ជាមគ្គខាងដើម ត្រឹមត្រូវ ក្រោយមក ពេលគេប្រកាសការស្តាប់ធម៌នៅថ្ងៃ ៨ រោច លោកក៏និមន្តទៅ ។

បានឮមកថា ព្រះថេរៈចាស់ ៧ ជាអ្នកពេញចិត្តក្នុងការស្តាប់ធម៌ កាលបានឮការប្រកាសស្តាប់ធម៌ ក៏គិតថា នឹងទៅមុន នឹងទៅមុន ។

ថ្ងៃនោះ ជាវារៈរបស់ព្រះចុឡនាគ លោកគង់លើធម្មាសនៈ ចាប់ផ្តិតពោលគាថាជាដើម ព្រះថេរៈជាអាចារ្យគង់ខាងក្រោយ បាំង៧ នៅស្ងៀម ។

ពិតហើយ ព្រះថេរៈចាស់ ៧ មិនច្រណែនគ្នា មិនលើកយកការពេញចិត្តរបស់ខ្លួនធ្វើជាភារៈ ដូចរែកបាច់អំពៅនោះទេ កាន់យកតែហេតុដែលគួរប៉ុណ្ណោះ ដែលមិនគួរ បោះចោល ។ ព្រោះដូច្នោះ ព្រះចុឡសុមនត្ថេរ ក៏ហៅព្រះចុឡនាគតិច ៗ , ព្រះចុឡនាគ បានឮដូចជាសំឡេងអាចារ្យហៅ ទើបផ្អាកធម្មកថា ឆ្លើយ មានការអ្វីទាន ។ អាចារ្យពោលនឹងព្រះចុឡនាគថា យើងពោលថា ជាមគ្គផ្សំនោះមិនត្រូវទេ ដែលអ្នកបានពោលថា សតិប្បដ្ឋានជាបុព្វ-ភាគនោះ ត្រូវហើយ ។

ព្រះចុឡនាគត្ថេរគិតថា អាចារ្យរបស់យើង ទ្រទ្រង់ព្រះបរិយត្តិធម៌ទាំងអស់ ជាសុតពុទ្ធនៃព្រះត្រៃបិដក ភិក្ខុយ៉ាងនេះហើយ គង់នៅវិលវល់ជាមួយបញ្ហាច្រើន តទៅមុខ ធម្មកថិកទាំងឡាយ នឹងវិលវល់ជាមួយបញ្ហាបែបនេះ ដូច្នេះ យើងនឹងកាន់យកព្រះសូត្រជាគោល ធ្វើបញ្ហានេះ មិនឱ្យស្មុគស្មាញតទៅ ។

**អដ្ឋកថា វិភង្គសូត្រ** : ការរៀន ការសាកសួរ ការចងចាំ និង ការពិចារណានៅក្នុងបដ្ឋាន គឺអារម្មណ៍របស់សតិ ជាបុព្វភាគនៃសតិប្បដ្ឋានភាវនា ។

# ព្រះពុទ្ធដីកា

## " អានិសង្សនៃការចម្រើនសតិប្បដ្ឋាន "

ម្នាលភិក្ខុទាំងឡាយ នរណាមួយបានចម្រើននូវសតិប្បដ្ឋាន ៤ រហូតអស់រយៈពេល ៧ ឆ្នាំ អ្នកនោះ គប្បីសង្ឃឹមផល ២ យ៉ាង ណាមួយ គឺ នឹងសម្រេចព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬ បើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៧ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៦ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផល ក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៦ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៥ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬ បើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៥ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៤ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៤ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៣ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២

ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៣ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ២ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ២ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ១ ឆ្នាំ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬ បើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ១ ឆ្នាំ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៧ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬ បើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៧ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៦ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៦ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៥ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២

ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៥ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៤ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៤ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៣ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ៣ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ២ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ២ ខែ លើកទុកចុះ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ១ ខែ អ្នកនោះ នឹងសង្ឃឹមផលទាំង ២ ផលណាមួយ គឺ ព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬបើឧបាទិនៅសល់ នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ ១ ខែ លើកទុកចុះ ។ល។ អ្នកណាមួយ បានចម្រើនសតិប្បដ្ឋានទាំង ៤ នោះ រយៈពេល ៧ ថ្ងៃ តាមលំដាប់នៃភាវនាដែល

តថាគតបានពោលមកហើយយ៉ាងនេះ បណ្ដាផលទាំង ២ ផលណាមួយ គឺ នឹងសង្ឃឹមបាននូវព្រះអរហត្តផលក្នុងបច្ចុប្បន្នជាតិនេះ ១ ឬ បើឧបាទិនៅសល់នឹងបានជាព្រះអនាគាមី ១ ។

ម្នាលភិក្ខុទាំងឡាយ នេះជាផ្លូវមូលតែមួយដើម្បីសេចក្ដីបរិសុទ្ធិវិសេសនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោក និងសេចក្ដីខ្សឹកខ្សួល ដើម្បីរំលត់បង់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ពាក្យណា ដែលតថាគត បានពោលហើយថា " **សាសនារបស់តថាគត ជាគុណសម្រាប់ស្រោចស្រង់សត្វ** " ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរ គឺ សតិប្បដ្ឋាន ៤ នេះឯង ។

## អដ្ឋកថា

### " អានិសង្សនៃការចម្រើនសតិប្បដ្ឋាន "

ពាក្យថា **យោ ហិ កោចិ ភិក្ខវេ** មានន័យថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ មិនថា ភិក្ខុ ភិក្ខុនី ឧបាសក ឬ ឧបាសិកា ។ ពាក្យថា **ឯវំ ភាវេយ្យ** មានន័យថា បានចម្រើនតាមលំដាប់ភាវនា ដែលតថាគតបានពោលហើយតាំងពីដើម ។ ពាក្យថា **បដិកង្ខំ** មានន័យថា គប្បីសង្ឃឹមបាន គឺ គប្បីប្រាថ្នា បានយ៉ាងពិត ។ បទថា **អញ្ញា** សំដៅដល់ ព្រះអរហត្ត ។ ពាក្យថា **សតិ វា ឧបាទិសេស** មានន័យថា បើឧបាទិសេសវិបាកខន្ធ ដែលកិលេស មានតណ្ហាជាដើមប្រកាន់ទុក នៅសល់ មិនទាន់អស់ទៅ ។ ពាក្យថា **អនាគាមិតា**

ប្រែថា ភាពជាព្រះអនាគាមី ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងព្រះឱវាទ ជាធម៌នាំអ្នកបដិបត្តិចេញចាកទុក្ខ ក្នុងរយៈ ៧ ឆ្នាំ យ៉ាងនេះហើយ កាលនឹងទ្រង់សម្តែងវេលាបដិបត្តិ ដែលខ្លីជាងនោះ ទើបត្រាស់ថា **តិដ្ឋន្តុ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ៧ ឆ្នាំ លើកទុកសិនចុះ ។

ពាក្យនោះទាំងអស់ ទ្រង់ត្រាស់ដោយវេនេយ្យសត្វថ្នាក់កណ្តាល ។ តែទ្រង់ត្រាស់ថា បុគ្គលទទួលពាក្យប្រៀនប្រដៅក្នុងពេលព្រឹក នឹងសម្រេចគុណវិសេសក្នុងពេលល្ងាច ទទួលពាក្យប្រៀនប្រដៅពេលល្ងាច នឹងសម្រេចពេលព្រឹកដូច្នេះ ទ្រង់សំដៅដល់បុគ្គលដែលមានបញ្ញាចាស់ក្លា ។

ព្រះមានព្រះភាគ ទ្រង់សម្តែងថា ពាក្យប្រៀនប្រដៅរបស់តថាគត នាំអ្នកបដិបត្តិចេញចាកទុក្ខ យ៉ាងនេះហើយ កាលនឹងទ្រង់ញ៉ាំងព្រះធម៌ទេសនាដែលទ្រង់សម្តែងដល់ធម៌កំពូល គឺ ព្រះអរហត្ត ឱ្យចុះក្នុងឋានៈ ២១ ប្រការ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវមូលតែមួយ ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោកៈ និងបរិទេវៈ ដើម្បីរំលត់ទុក្ខ និងទោមនស្ស ដើម្បីសម្រេចបាននូវអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន នោះ គឺ សតិប្បដ្ឋាន ៤ , ពាក្យណា ដែលតថាគតសម្តែងហើយ ពាក្យនោះ តថាគតពោល ព្រោះអាស្រ័យផ្លូវមូលតែមួយនេះឯង ។

# ឱវាទព្រះសាស្តា

## " ពោលអំពី សតិប្បដ្ឋានភាវនា "

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគមរបស់អ្នកកុរុ ក្នុងដែនកុរុ ។ កាលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគមនោះឯង បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន , ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺ **សតិប្បដ្ឋានទាំង ៤** នេះ ជាផ្លូវមូលតែមួយ ( ប្រព្រឹត្តទៅ ) ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

សតិប្បដ្ឋានទាំង ៤ តើអ្វីខ្លះ ?

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោកចេញ ១ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ១ ពិចារណាឃើញនូវចិត្តក្នុងចិត្តទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជា

អ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោកចេញ ១ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោកចេញ ១ ។

( ចប់ ឧទ្ទេសវារកថា )

# អដ្ឋកថា

## " កាយានុបស្សនាសតិប្បដ្ឋាន "

**ក្នុងបដិសម្ភិទាមគ្គ :** បទថា **ឧបដ្ឋានតោ** មានការចូលទៅតាំងទុកជាអត្ថ គឺ មានសភាវធម៌ជាអត្ថ អធិប្បាយថា មានសតិនាំចេញចាកសេចក្ដីប្រកាន់ ។

បទថា **ឧបដ្ឋានំ សតិ - សតិប្រាកដ** ឈ្មោះថា សតិប្រាកដ ព្រោះសតិកំណត់អារម្មណ៍នោះ តាំងទុក ។

បទថា **អនុបស្សនាញាណំ** សតិជាអនុបស្សនាញាណ មានន័យថា កាយានុបស្សនា ជានិមិត្ត ដោយអំណាចសមថានុបស្សនា គឺ **នាមកាយ រូបកាយ** , ជាញាណដោយអំណាចសមថវិបស្សនា ។

បទថា **កាយោឧបដ្ឋានំ - កាយប្រាកដ** គឺ ឈ្មោះថា ប្រាកដ ព្រោះកាយ មានសតិចូលទៅតម្កល់ ។

បទថា **នោ សតិ - មិនមែនសតិ** មានន័យថា កាយនោះមិនមែនសតិ ។

បទថា **តំ កាយំ អនុបស្សតិ - សតិពិចារណាឃើញកាយនោះ** គឺ តាមរលឹកនូវកាយតាមដែលបានពោលហើយ ដោយអំណាចនៃសមថវិបស្សនាជាក់ច្បាស់ដោយញាណដែលសម្បយុត្តដោយឈាន ឬ ដោយវិបស្សនាញាណ។

ពាក្យថា **កាយេ កាយានុបស្សនា សតិប្បដ្ឋាន ភាវនា** សតិប្បដ្ឋាន-ភាវនា គឺ ការពិចារណាឃើញកាយក្នុងកាយ ។

ន័យម្យ៉ាងទៀត លោកអធិប្បាយថា ការពិចារណាឃើញ កាយក្នុងកាយ គឺ មិនមែនពិចារណាឃើញធម៌ដទៃក្នុងកាយឡើយ មិនមែនពិចារណា

ឃើញ ថាទៀង ថាសុខ ថាអត្តា ថាស្អាត នៅក្នុងកាយដែលមិនទៀង ជាទុក្ខ ជាអនត្តា មិនស្អាតឡើយ , អធិប្បាយថា ពិចារណាឃើញកាយ ត្រឹមតែជាកាយ ព្រោះមិនមាននរណា១ គួរនឹងប្រកាន់ក្នុងកាយ **ថាជាយើង ថារបស់យើង ថាស្រី ឬ ប្រុស** ។

ក្នុង ៣ បទ មានជាដើមថា **វេទនាសុវេទនានុបស្សនា** ជាដើម ក៏មានន័យ ដូច្នេះដូចគ្នា ។

សតិនោះឯងប្រាកដ ឈ្មោះថា **សតិប្បដ្ឋាន** និងដែលសម្បយុត្តដោយកាយានុបស្សនា ឈ្មោះថា **កាយានុបស្សនាសតិប្បដ្ឋាន** ការចម្រើនកាយា-នុបស្សនាសតិប្បដ្ឋាននោះឯង ឈ្មោះថា កាយានុបស្សនាសតិប្បដ្ឋានភាវនា ។

បទថា **តំ កាយំ** ទ្រង់ពោលពាក្យសំដៅយកកាយនោះ ទ្រង់សង្គ្រោះយកពាក្យថា **កាយ** សព្ទ គឺ **នាមកាយ** និង **រូបកាយ** ស្ងួម្បីមិនទាន់បានសម្តែងទុក ដោយអនិច្ចានុបស្សនាជាដើម ក៏សំដៅយក **នាមកាយ** ( **នាមធម៌** ) និង **រូបកាយ** ( **រូបធម៌** ) នោះឯង មិនបានសំដៅយក **កាយនិមិត្ត** ( បញ្ញត្តិ ) នោះឡើយ , គឺ ទ្រង់សំដៅយកអនុបស្សនា និង ភាវនា ។

### អដ្ឋកថា សុមង្គលវិលាសិនី មហាវគ្គ សតិប្បដ្ឋាន :

ព្រះអង្គទ្រង់ត្រាស់សម្តែងថា សតិប្បដ្ឋានជាផ្លូវមូលតែ១ ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្តីសោក និង សេចក្តីខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខនិងទោមនស្ស ដើម្បីបាននូវអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ក្នុងពាក្យថា **មគ្គ** ព្រោះអត្ថថា ដូចម្តេច - ព្រោះអត្ថថា ជាផ្លូវនាំទៅកាន់ព្រះនិព្វានម្យ៉ាង ព្រោះអត្ថថា អ្នកត្រូវការព្រះនិព្វាន គប្បីស្វែងរកម្យ៉ាង ។

ពាក្យថា **ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ** មានន័យថា ដើម្បីប្រយោជន៍ដល់សេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ដែលជាអ្នកមានចិត្តសៅហ្មងព្រោះមន្ទិលទាំងឡាយ មានរាគៈជាដើម និងព្រោះឧបក្កិលេសទាំងឡាយ មានអភិជ្ឈាវិសមលោភៈជាដើម តាមពិត សត្វទាំងឡាយនោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយជាច្រើន តាំងពីព្រះពុទ្ធជាម្ចាស់ ព្រះនាមថា **តណ្ហង្ករ មេធង្ករ សរណង្ករ ទីបង្ករ** ដែលបរិនិព្វានក្នុងកប្បតែមួយ ក្នុងរយៈពេល ៤ អសង្ខេយ្យ រាប់ពីកប្បនេះថយក្រោយទៅ រហូតមកដល់ព្រះពុទ្ធ ជាម្ចាស់សាក្យមុនីជាទីបំផុត ព្រះបច្ចេកពុទ្ធច្រើនរយអង្គ និងព្រះអរិយសាវ័កទាំងឡាយរាប់មិនអស់ រមែងលះបង់មន្ទិលផ្លូវចិត្តទាំងអស់ ដល់នូវភាពបរិសុទ្ធិវិសេសដោយផ្លូវនេះឯង ការបញ្ញត្តិភាពសៅហ្មងដោយរូប មិនមានឡើយ ។

**ក្នុងសំយុត្តនិកាយ ខន្ធវារវគ្គ :**

**" ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយសៅហ្មង ព្រោះចិត្តសៅហ្មង សត្វទាំងឡាយបរិសុទ្ធ ព្រោះចិត្តបរិសុទ្ធ "**

សេចក្តីបរិសុទ្ធិនៃចិត្តនោះ រមែងមានដោយ **មគ្គ** គឺ សតិប្បដ្ឋាននេះ , ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ** ។

ពាក្យថា **ដើម្បីឈានកន្លងសេចក្តីសោក និង បរិទេវៈ** សំដៅយក

ដើម្បីឈានកន្លង គឺ លះបង់នូវសេចក្ដីសោក និង បរិទេវៈ ។ ពិតហើយ មគ្គនេះ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីឈានកន្លងសោកៈ និង បរិទេវៈ ដូចជាសោកៈរបស់សន្តតិមហាមាត្យជាដើម ( ព្រោះភរិយាស្លាប់ ) ។

ពាក្យថា **ដើម្បីរំលត់ទុក្ខ និង ទោមនស្ស** មានន័យថា ដើម្បីការតាំងនៅមិនបាន គឺ រំលត់ទាំង ២ , ទាំងទុក្ខផ្លូវកាយ និង ទុក្ខផ្លូវចិត្ត ។

មគ្គប្រកបដោយអង្គ ៨ នេះ ជាអរិយៈ ហៅថា ញេយ្យធម៌ ក្នុងសេចក្ដីថា **ញាយស្ស អធិគមាយ** ដើម្បីសម្រេចនូវញេយ្យធម៌ អធិប្បាយថា ដើម្បីបានសម្រេច គឺ ដើម្បីញេយ្យធម៌នោះ ។ ពិតហើយ **មគ្គ** គឺ សតិប្បដ្ឋានដែលជាលោកិយ ដែលបុគ្គលចម្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបានសម្រេចនូវមគ្គជាលោកុត្តរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងថា **ដើម្បីសម្រេចនូវញេយ្យធម៌** ។

ក្នុងពាក្យថា **ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន** អធិប្បាយថា ដើម្បីធ្វើឱ្យជាក់ច្បាស់ គឺ ដើម្បីធ្វើឱ្យប្រចក្សដោយខ្លួនឯង នូវអមតធម៌ដែលបានឈ្មោះថា **និព្វាន** ព្រោះប្រាសចាកតណ្ហា ដែលជាគ្រឿងរួបរឹត ។ ពិតហើយ មគ្គនេះ កាលបុគ្គលចម្រើនហើយ រមែងធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ឱ្យសម្រេចតាមលំដាប់ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបទ្រង់ត្រាស់ថា ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់សតិប្បដ្ឋានមាន **៤** មិនច្រើនជាងនោះ ?

ឆ្លើយថា ព្រោះទ្រង់ឱ្យជាប្រយោជន៍ដ៏ក្រៃលែង ដល់វេនេយ្យសត្វ ។

ពិតហើយ ក្នុងពពួកវេនេយ្យសត្វ ដែលមានបញ្ញាទន់ខ្សោយ និង បញ្ញាចាស់ក្លានោះ :

- **កាយានុបស្សនាសតិប្បដ្ឋាន** មាននិមិត្ត ដែលគប្បីសម្រេចបាន ដោយមិនលំបាក គឺ ជាផ្លូវបរិសុទ្ធ សម្រាប់វេនេយ្យសត្វ ដែលជាសមថយានិក មានបញ្ញាទន់ខ្សោយ ។
- **វេទនានុបស្សនាសតិប្បដ្ឋាន** មានអារម្មណ៍ ដ៏ល្អិតសុខុម ជាផ្លូវបរិសុទ្ធ សម្រាប់វេនេយ្យសត្វ ដែលជាសមថយានិក មានបញ្ញាចាស់ក្លា ។
- **ចិត្តានុបស្សនាសតិប្បដ្ឋាន** មានអារម្មណ៍ចែកចេញ មិនសូវច្រើន ជាផ្លូវបរិសុទ្ធសម្រាប់វេនេយ្យសត្វ ដែលជាវិបស្សនាយានិក មានបញ្ញាទន់ខ្សោយ ។
- **ធម្មានុបស្សនាសតិប្បដ្ឋាន** មានអារម្មណ៍ ចែកចេញច្រើន ជាផ្លូវបរិសុទ្ធ សម្រាប់វេនេយ្យសត្វ ដែលជាវិបស្សនាយានិក មានបញ្ញាចាស់ក្លា ។

ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា សតិប្បដ្ឋានមាន ៤ មិនច្រើនជាងនោះ ។

ក្នុងអដ្ឋកថាពោលថា **សតិប្បដ្ឋាន** មានតែ ១ ប៉ុណ្ណោះ ព្រោះមានការរលឹក , មាន ៤ ដោយអំណាចនៃអារម្មណ៍ ។

ប្រៀបដូចព្រះនគរមានទ្វារ ៤ បុគ្គលដែលចូលមកតាមទ្វារ ទិសខាងកើត បុគ្គលដែលចូលមកតាមទ្វារទិសខាងត្បូង បុគ្គលដែលចូលមកតាមទ្វារ

ទិសខាងលិច ក៏ដូចគ្នានឹងបុគ្គលដែលចូលមកតាមទ្វារទិសខាងជើង នាំយកវត្ថុផ្សេងៗចូលមក តាមទ្វារទិសណាមួយ ចូលមកក្នុងព្រះនគរ យ៉ាងណា សេចក្តីឧបមេយ្យនេះ ក៏ដូច្នោះ ។ ពិតហើយ ព្រះនិព្វាន ប្រៀបដូចជាព្រះនគរ , លោកុត្តរធម៌ មានអង្គ ៨ ប្រៀបដូចជាទ្វារព្រះនគរ សតិប្បដ្ឋាន មានកាយជាដើម ប្រៀបដូចជាទិសទាំងឡាយ មានទិសខាងកើតជាដើម ។

បុគ្គលមកពីទិសខាងកើត នាំវត្ថុផ្សេងៗ មកពីទិសខាងកើត ចូលមកកាន់ព្រះនគរតាមទ្វារទិសខាងកើត យ៉ាងណា អ្នកបដិបត្តិតាមរយៈកាយានុ-បស្សនា ចម្រើនកាយានុបស្សនា ១៤ វិធី រមែងចូលទៅកាន់ព្រះនិព្វានដោយអរិយមគ្គ ដែលកើតចាកអានុភាពនៃការចម្រើនកាយានុបស្សនា ក៏ដូច្នោះ ។

បុគ្គលដែលមកពីទិសខាងត្បូង នាំវត្ថុមកពីទិសខាងត្បូង ចូលមកកាន់ព្រះនគរតាមទ្វារទិសខាងត្បូង យ៉ាងណា អ្នកបដិបត្តិ តាមរយៈនៃវេទនានុប-ស្សនា ចម្រើនវេទនានុបស្សនា ៩ វិធី រមែងចូលទៅកាន់ព្រះនិព្វាន ដោយអរិយមគ្គ ដែលកើតចាកអានុភាពនៃការចម្រើនវេទនានុបស្សនា ក៏ដូច្នោះ ។

បុគ្គលមកពីទិសខាងលិច នាំវត្ថុចូលមកតាមទ្វារទិសខាងលិច រមែងចូលមកកាន់ព្រះនគរតាមទ្វារទិសខាងលិច យ៉ាងណា អ្នកបដិបត្តិតាមរយៈចិត្តានុបស្សនា ចម្រើនចិត្តានុបស្សនា ១៦ វិធី រមែងចូលមកកាន់ព្រះនិព្វានដោយអរិយមគ្គដែលកើតចាកអានុភាពនៃការចម្រើនចិត្តានុបស្សនាក៏ដូច្នោះ ។

បុគ្គលមកពីទិសខាងជើង នាំវត្ថុមកពីទិសខាងជើង ក៏ចូលមកកាន់ព្រះនគរតាមទ្វារទិសខាងជើងយ៉ាងណា អ្នកបដិបត្តិតាមរយៈធម្មានុបស្សនា ចម្រើន

ធម្មានុបស្សនា **៥** វិធី ក៏ចូលមកកាន់ព្រះនិព្វានដោយអរិយមគ្គ ដែលកើតចាកពីអានុភាពនៃការចម្រើនធម្មានុបស្សនា ក៏ដូច្នោះ ។

បណ្ឌិតគប្បីជ្រាបថា ដែលព្រះអង្គទ្រង់ត្រាស់ថា សតិប្បដ្ឋានមានតែ **១** ក៏ដោយអានុភាពនៃការរលឹកបានម្យ៉ាង ឬ ដោយអានុភាពដែលមានការចូលមកប្រជុំចុះក្នុងទីតែមួយ ( ព្រះនិព្វាន ) ម្យ៉ាង , សតិប្បដ្ឋានមាន **៤** ដោយការកំណត់តាមអារម្មណ៍ ។

ពាក្យថា **ពិចារណាឃើញកាយ** មានន័យថា មានប្រក្រតីពិចារណាឃើញកាយ ឬ ពិចារណាឃើញកាយ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា **ក្នុងកាយ** បណ្ឌិតគប្បីជ្រាបថា ទ្រង់ធ្វើសព្ទថា **កាយ** ពាក្យទី **២** ពិចារណាឃើញកាយ មួយលើកទៀត ដើម្បីទ្រង់សម្ដែងការកំណត់ និង ការចែកឱ្យដាច់ពីគ្នាមិនឱ្យប្រជុំគ្នា , ភិក្ខុ មិនមែនពិចារណាឃើញវេទនាក្នុងកាយ ឬចិត្តក្នុងកាយ ឬធម៌ក្នុងកាយនោះទេ ដែលពិត ពិចារណាឃើញ កាយក្នុងកាយ ទើបទ្រង់សម្ដែងការកំណត់ឱ្យដាច់ដោយឡែកពីគ្នា ដោយទ្រង់សម្ដែងអាការពិចារណាឃើញកាយ ( រូបធម៌ ) ក្នុងវត្ថុដែលសម្មតិថា កាយ ។ មិនមែនពិចារណាឃើញធម៌ដទៃ ដែលផុតចាកអវយវៈតូចធំក្នុងកាយ ទាំងមិនពិចារណាឃើញបុរស ឬ ស្ត្រី ដែលផុតចាកសក់ជាដើម ។

ពិតហើយ ក្នុងទីនេះ **កាយ** ដែលរាប់ថា ជាទីប្រជុំចុះនៃមហាភូតរូប និង ឧបាទាយរូប ដែលសន្មតថា ជាសក់ជាដើម មិនមែនពិចារណាឃើញធម៌ដទៃណាក្រៅពី **ភូតរូប** និង **ឧបាទាយរូប** ឡើយ សេចក្ដីពិត ពិចារណាឃើញកាយដែលជាទីប្រជុំចុះនៃអវយវៈតូចធំក្នុងកាយនោះ ដូចនឹង ពិចារណាឃើញ

អង្គប្រកបនៃរថដូច្នោះ ពិចារណាឃើញកាយដែលជាទីប្រជុំចុះនៃសក់ ក្រចកជាដើម ដូចជាពិចារណាឃើញ ចំណែកតូចធំនៃព្រះនគរ គឺ ពិចារណាឃើញកាយដែលជាទីប្រជុំចុះនៃ **ភូតរូប** និង **ឧបាទាយរូប** ។

( ដែលបានវោហារថា សក់ ឬ ក្រចក ព្រោះ ភូតរូប និង ឧបាទាយរូបប្រជុំគ្នា មិនមានសត្វបុគ្គល ក្នុងសក់ ឬ ក្រចកនោះឡើយ ) ។

ដូច្នេះហើយ ទើបទ្រង់សម្តែងនូវការចែកដាច់ពីគ្នា ដោយទ្រង់សម្តែងនូវវត្ថុដែលបានវោហារថា **កាយ** គ្រាន់តែជាទីប្រជុំ ដោយអាការផ្សេង ៗ ប៉ុណ្ណោះឯង ។ បុរស ឬ ស្ត្រី មិនមាន , មានត្រឹមតែកាយនេះប៉ុណ្ណោះ ។ **ភូតរូប** និង **ឧបាទាយរូប** ប្រជុំគ្នា ទើបហៅថា **កាយ** តែសត្វទាំងឡាយប្រកាន់ខុសដោយប្រការនោះៗ ក្នុងកាយដែលគ្រាន់តែជាទីប្រជុំនៃធម៌នោះៗ ដូចដែលពោលហើយ គឺ **ភូតរូប** និង **ឧបាទាយរូប** ។ ព្រោះហេតុនោះ ព្រះបុរាណាចារ្យ ទើបពោលថា :

*យំ បស្សតិ ន តំ ទិដ្ឋំ   យំ ទិដ្ឋំ តំ ន បស្សតិ*
*អបស្សំ ពជ្ឈតេ មូឡ្ហោ   ពជ្ឈមានោ  ន មុច្ចតិ.*

**ប្រែថា** បុគ្គលមើលវត្ថុណា មិនបានឃើញវត្ថុនោះ បែរជាឃើញវត្ថុមិនបានមើល បុគ្គលវង្វេង កាលដែលឃើញរបស់ដែលមិនបានមើល រមែងជាប់ជំពាក់ កាលបើជាប់ជំពាក់ ក៏មិនរួចផុត ។

លោកសំដែងពាក្យនេះ ដើម្បីសម្តែងនូវការចែកឱ្យដាច់ពីគ្នានូវ **ឃនៈ** ជាដើម ។

ភិក្ខុនេះ ពិចារណាឃើញកាយក្នុងកាយប៉ុណ្ណោះ អធិប្បាយថា មិនមែនពិចារណាឃើញធម៌ដទៃឡើយ ។ បុគ្គលទាំងឡាយ ឃើញទឹកក្នុងថ្ងៃបណ្ដើរកូន សេចក្ដីពិត ទឹកមិនមាន យ៉ាងណា ភិក្ខុពិចារណាឃើញកាយ នេះថា ជារបស់មិនទៀង ជាទុក្ខ មិនមែនតួខ្លួន មិនស្អាត ថាជា របស់ទៀង ជាសុខ ជាតួខ្លួន ថាស្អាតមិនបានឡើយ សេចក្ដីពិត ពិចារណាឃើញកាយនេះ អធិប្បាយថា ពិចារណាឃើញកាយដែលជាទីប្រជុំចុះ នៃអាការនោះ ៗ គឺ មិនទៀង ជាទុក្ខ មិនមែនខ្លួន មិនស្អាតនោះ វិញទេ ។

**កាយនេះ** ព្រះសារីបុត្តពោលទុកក្នុងបដិសម្ភិទាមគ្គថា :

ភិក្ខុរូបខ្លះ ក្នុងធម្មវិន័យនេះ ពិចារណាឃើញកាយ គឺ ដី , កាយ គឺ ទឹក , កាយ គឺ ភ្លើង , កាយ គឺ ខ្យល់ , កាយ គឺ រោម សក់ ក្រចក ធ្មេញ ស្បែក ឆ្អឹង .... មានន័យថា ជារបស់មិនទៀង ដូច្នេះបណ្ឌិតគប្បីជ្រាបនូវអត្ថនៃកាយទាំងអស់ យ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ គឺ ពិចារណាឃើញនូវកាយនេះ ប៉ុណ្ណោះ ។

**ក្នុងបដិសម្ភិទាមគ្គ** : ឈ្មោះថា **ភិក្ខុ** បានដល់ អ្នកឃើញភ័យក្នុងសង្សារវដ្ដ ។

ម្យ៉ាងទៀត គប្បីជ្រាបថា **ពិចារណាឃើញកាយ** គឺ ពិចារណាឃើញធម៌ទាំងឡាយដែលប្រជុំគ្នា សន្មតបានថា ជាសក់ជាដើម មិនមែនពិចារណាឃើញត្រង់ចំណែកណាមួយ ដែលសន្មតថា ជាយើង ថាជា របស់យើងក្នុងកាយនោះទេ តែពិចារណាឃើញកាយនោះៗ ជាទីប្រជុំនៃធម៌ផ្សេងៗ ដែលសន្មតថា សក់ ក្រចក ជាដើម ។

ម្យ៉ាងទៀត **ការពិចារណាឃើញកាយក្នុងកាយ** បានដល់ ពិចារណាឃើញកាយជាទីប្រជុំនៃអាការផ្សេងៗ មានលក្ខណៈមិនទៀងជាដើម ដែលមានន័យមកតាមលំដាប់ ក្នុងបដិសម្ភិទាមគ្គថា ពិចារណាឃើញកាយក្នុងកាយនេះ ដោយជារបស់មិនទៀង មិនមែនឃើញថា ទៀង នោះទេ ។

ពិតហើយ អ្នកបដិបត្តិបដិបទា គឺ ពិចារណាឃើញកាយ ក្នុងទីនេះ រមែងពិចារណាឃើញកាយជារបស់មិនទៀង មិនមែនឃើញថា ជារបស់ទៀង ពិចារណាឃើញថាជាទុក្ខ មិនឃើញថាជាសុខ ពិចារណាឃើញថាជាអនត្តា មិនឃើញថា ជាអត្តា ដោយអំណាចអនុបស្សនា ៧ មានអនិច្ចានុបស្សនា ទុក្ខានុបស្សនា អនត្តានុបស្សនា និព្វិទានុបស្សនា វិរាគានុបស្សនា និរោធានុបស្សនា និងបដិនិស្សគ្គានុបស្សនា គឺពិចារណាឃើញសេចក្ដីមិនទៀងជាដើម រមែងនឿយណាយ មិនរីករាយ រមែងលះបង់តម្រេក មិនមែនត្រេកអរ , រមែងរំលត់ទុក្ខ មិនមែនបង្កនូវទុក្ខ , រមែងលះបង់ មិនមែនប្រកាន់មាំ ។

ភិក្ខុនោះ កាលណាពិចារណាឃើញកាយនេះ ដោយជារបស់មិនទៀង រមែងលះបង់នូវនិច្ចសញ្ញា ការសម្គាល់ថា ទៀង ចេញបាន កាលពិចារណាឃើញនូវទុក្ខ រមែងលះបង់នូវសុខសញ្ញា ការសម្គាល់ថាជាសុខចេញបាន កាលពិចារណាឃើញនូវរបស់មិនមែនជាតួខ្លួន រមែងលះបង់អត្តសញ្ញា ការសម្គាល់ថាជាតួខ្លួនចេញបាន កាលបើនឿយណាយ រមែងលះបង់នូវសេចក្ដីត្រេកអរ កាលបើលះបង់នូវសេចក្ដីត្រេកអរបាន រមែងកម្ចាត់នូវសមុទយៈ កាលបើទុក្ខរលត់ ក៏ព្រោះការលះបង់នូវហេតុដែលនាំឱ្យកើតទុក្ខ កាលបើលះបង់បានហើយ រមែងមិនប្រកាន់មាំ ( នេះអនុបស្សនា ៧ ) ។

ពាក្យថា **មានសេចក្ដីព្យាយាម** មានអត្ថថា សភាវៈណា រមែងដុតកម្ដៅកិលេសទាំងឡាយក្នុងភព ៣ ហេតុនោះ សភាវៈនោះ ឈ្មោះថា **អាតាប - ដុតកម្ដៅកិលេស** ពាក្យនេះ ជាឈ្មោះនៃសេចក្ដីព្យាយាម សេចក្ដីព្យាយាមនៃបុគ្គលនោះ មានហើយ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **អាតាបី** គឺ អ្នកមានសេចក្ដីព្យាយាម ។

ពាក្យថា **មានសម្បជញ្ញៈ** គឺ អ្នកប្រកបហើយដោយការដឹងខ្លួនដែលហៅថា សម្បជញ្ញៈ ។

ពាក្យថា **មានសតិ** គឺ ប្រកបហើយដោយសតិ ដែលមានក្នុងកាយ ។

ភិក្ខុរូបនេះ កំណត់ដឹងអារម្មណ៍ដោយសតិហើយ ពិចារណាឃើញច្បាស់ដោយបញ្ញា ធម្មតាថា បញ្ញាអាចពិចារណាឃើញច្បាស់ទៅបាន បើវៀរចាកសតិហើយ មិនអាចប្រព្រឹត្តទៅបានឡើយ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ទុកក្នុង សំយុត្តនិកាយ មហាវគ្គ ថា :

**ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា សតិ គប្បីមានក្នុងទីទាំងពួង** ព្រោះដូច្នោះ ក្នុងទីនេះ ទើបទ្រង់ត្រាស់ថា រមែងពិចារណាឃើញកាយក្នុងកាយ ។ កាយានុបស្សនាសតិប្បដ្ឋាន ទ្រង់បានសម្ដែងទុកដោយប្រការដូច្នេះឯង ។

( ចប់ អដ្ឋកថា ឧទ្ទេសវារៈ )

## ១ - អានាបានបព្វៈ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង សាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយ ពែនភ្នែន តាំងកាយឱ្យត្រង់ តាំងសតិឱ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។ ភិក្ខុនោះ មានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល កាលដកដង្ហើម ចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូល វែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង , កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬ កាលដកដង្ហើមចូលខ្លី ក៏ដឹង ច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី , ( ភិក្ខុ ) សិក្សាថា អាត្មាអញនឹងកំណត់ ដឹងច្បាស់នូវកាយ គឺ ខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញកំណត់ដឹងច្បាស់នូវកាយ គឺ ខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់កាយសង្ខារ ( អស្សាសបស្សាសៈ ) ហើយដក ដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរម្ងាប់កាយសង្ខារ ដកដង្ហើមចូល ។

ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងក្តី កូនសិស្សនៃជាងក្រឡឹងក្តី ដែល ប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែ ក្រឡឹងវែង ឬ កាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញទាញខ្សែ ក្រឡឹងខ្លី មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដកដង្ហើម ចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូល វែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹង

ច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី , ( ភិក្ខុ ) សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺ ខ្យល់ចេញទាំងពួង ហើយដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់នូវកាយ គឺ ខ្យល់ចូលទាំងពួង ហើយដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ សិក្សាថា អាត្មា អញនឹងរម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល មានឧបមេយ្យដូច្នោះឯង ។

ភិក្ខុពិចារណា ឃើញនូវកាយក្នុងកាយ ជាខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ នេះផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ដែលប្រជុំកើតឡើងក្នុងកាយ ទាំងធម៌ដែលសូន្យទៅក្នុងកាយ គ្រប់ឥរិយាបថទាំង ៤ ផង ។

មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន " តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម " គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតី ប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយ តណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះ ឯង ។

## អដ្ឋកថា

ពាក្យថា **ភិក្ខុចូលទៅកាន់ព្រៃ ចូលទៅកាន់គល់ឈើ ចូលទៅកាន់ផ្ទះស្ងាត់** នេះ ទ្រង់សម្ដែងកំណត់នូវសេនាសនៈ ដែលសមគួរដល់ការចម្រើនសតិប្បដ្ឋានរបស់ភិក្ខុអង្គនោះ ។ ព្រោះចិត្តរបស់លោកត្រាច់ទៅក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើមមកយូរហើយ រមែងមិនប្រាថ្នានឹងឡើងកាន់វិថីនៃកម្មដ្ឋាន គិតតែនឹងបម្រាសចេញក្រៅផ្លូវតែម្យ៉ាង ប្រៀបដូចរទេះ ដែលទឹមដោយគោកោងដូច្នោះ ព្រោះដូច្នោះ ភិក្ខុដែលនឹងចម្រើននូវសតិប្បដ្ឋាននេះ បំណងនឹងទូន្មានចិត្តដែលកាច ដែលច្រើនដោយការក្រេបរស មានរូបារម្មណ៍ជាដើមមកយូរហើយ គប្បីពង្រាត់ចេញចាករូបារម្មណ៍ជាដើម ហើយចូលទៅកាន់ព្រៃក្តី គល់ឈើក្តី ផ្ទះស្ងាត់ក្តី គប្បីអាស្រ័យខ្សែ គឺ សតិ ចងទុកក្នុងបង្គោល គឺ អារម្មណ៍របស់សតិប្បដ្ឋាននោះ ។ ចិត្តរបស់លោកនោះ រមែងរសាប់រសល់ទៅផ្លូវនោះផ្លូវនេះ កាលមិនបានអារម្មណ៍ ដែលធ្លាប់សេពមកក្នុងកាលមុន ទាំងមិនអាចផ្ដាច់ខ្សែ គឺ សតិ ឱ្យដាច់ដើម្បីនឹងគេចទៅ ក៏នៅអែបស្អិទ្ធនឹងអារម្មណ៍នោះទៅ គឺ ដោយសារអំណាចនៃឧបចារភាវនា និងអប្បនាភាវនា ( ភាវនាទាំង ២ នេះ មានពិស្តារក្នុងវិសុទ្ធិមគ្គ-សមាធិនិទ្ទេសហើយ បណ្ឌិតគប្បីសិក្សាចុះ ) ។ ប្រៀបដូចកូនគោ ដែលគេពង្រាត់ចេញពីមេគោ យកទៅចងទុកជាប់នឹងបង្គោលស្ទឹង ដើម្បីបង្វឹកដូច្នោះ ។

សេនាសនៈនេះ រមែងសមគួរដល់ការចម្រើនសតិប្បដ្ឋាន របស់ភិក្ខុអង្គនោះ ដែលចម្រើនសតិប្បដ្ឋានដោយប្រការដូច្នេះ។ ព្រោះដូច្នោះ ទើបខ្ញុំម្ចាស់ពោលថា **ពាក្យនេះ** ជាការសម្តែងដល់សេនាសនៈដែលសមគួរដល់ការចម្រើន

សតិប្បដ្ឋានរបស់ភិក្ខុអង្គនោះ ។

## ការកំណត់ខ្យល់អស្សាសបស្សាសៈ

ពាក្យថា **ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាងក្រឡឹង ឬ កូនសិស្សនៃជាងក្រឡឹងដែលឆ្លាត** នេះ ត្រឹមតែជាពាក្យឧបមាប៉ុណ្ណោះ ។

ពាក្យថា **ក្នុងកាយខាងក្នុង** នេះគឺ ជាអប្បនាប៉ុណ្ណោះ តែអប្បនានោះក៏មិនមកដោយពាក្យនោះ មកតែឧបចារកម្មដ្ឋានដ៏សេស ។ ពាក្យថា **អ្នកឆ្លាត** គឺ អ្នកជំនាញ ។ ពាក្យថា **ទាញខ្សែក្រឡឹងវែងក្តី** មានន័យថា សន្ធឹងដៃ សន្ធឹងជើងទាញខ្សែវែង នៅពេលក្រឡឹងធ្វើពិណជាដើម ដែលជារបស់ធំ ។ ពាក្យថា **ទាញខ្សែក្រឡឹងខ្លីក្តី** មានន័យថា ទាញខ្លីៗ ក្នុងពេលក្រឡឹងរបស់តូចៗ ដូចជាភ្លុកនិងរនុកទ្វារជាដើម ។ ពាក្យថា **ដូច្នោះដូចគ្នា** មានន័យថា សូម្បីភិក្ខុនេះក៏ដូច្នោះ កាលដកដង្ហើមចូលវែងដោយខ្យល់អស្សាសៈ និងបស្សាសៈដែលវែងនិងខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើមចូលវែង ។ ល ។ ក៏ពិចារណាថា យើងដកដង្ហើមចូលវែង ។ ពេលដែលលោកពិចារណាយ៉ាងនេះ ឈាន ៤ រមែងកើតក្នុងនិមិត្តនៃខ្យល់អស្សាសបស្សាសៈ លោកចេញចាកឈានហើយ ក៏កំណត់ដឹងនូវខ្យល់អាស្សាសបស្សាសៈ ឬ ក៏កំណត់អង្គឈាន ។

ក្នុងការកំណត់ខ្យល់អស្សាសបស្សាសៈនោះ ភិក្ខុប្រកបកម្មដ្ឋានក្នុងខ្យល់អស្សាសបស្សាសៈ រមែងកំណត់ដឹងនូវរូប យ៉ាងនេះថា ខ្យល់អស្សាស-បស្សាសៈទាំងនេះ អាស្រ័យអ្វី - អាស្រ័យវត្ថុ , **ករជកាយ** ឈ្មោះថា វត្ថុ , មហាភូតរូប ៤ និង ឧបាទាយរូប ឈ្មោះថា **ករជកាយ** , បន្ទាប់ពីនោះ ទើប

កំណត់ក្នុងនាមធម៌ ដែលមានផស្សៈជាទី ៥ ( វេទនា សញ្ញា ចេតនា វិញ្ញាណ ផស្សៈ ) មានរូបនោះជាអារម្មណ៍ ។ កាលកំណត់នាមរូបនោះ យ៉ាងនេះ ដោយប្រការដូច្នេះ ហើយក៏គិតរកបច្ច័យនៃនាមរូបនោះ កាលបើឃើញបដិច្ចសមុប្បាទ មានអវិជ្ជាជាដើមហើយ ក៏ឆ្លងផុតនូវសេចក្ដីសង្ស័យបានថា នេះត្រឹមតែបច្ច័យ និងធម៌ដែលកើតព្រោះបច្ច័យប៉ុណ្ណោះ មិនមែនសត្វ ឬបុគ្គល ទើបកំណត់ដឹងនាមរូបព្រមទាំងបច្ច័យដែលស្ថិតនៅក្នុងសាមញ្ញលក្ខណៈ ចម្រើនវិបស្សនា ក៏នឹងសម្រេចនូវព្រះអរហត្តតាមលំដាប់ នេះជាផ្លូវចេញចាកទុក្ខ សម្រេចរហូតដល់អរហត្តរបស់ភិក្ខុមួយរូប ។

ភិក្ខុចម្រើនឈានកម្មដ្ឋាន កំណត់នាមរូបថា អង្គឈាន ទាំងឡាយនេះ អាស្រ័យអ្វី - អាស្រ័យវត្ថុរូប , **ករជកាយ** ឈ្មោះថា **វត្ថុរូប** , អង្គឈានជានាមធម៌ ករជកាយជារូបធម៌ កាលនឹងគិតរកបច្ច័យនៃនាមរូបនោះ ក៏ឃើញបច្ចយាការ មានអវិជ្ជាជាដើម ទើបឆ្លងនូវសេចក្ដីសង្ស័យបានថា នេះត្រឹមតែបច្ច័យនិងធម៌អាស្រ័យបច្ច័យកើតឡើង មិនមែនសត្វ ឬបុគ្គល ទើបកំណត់នូវត្រៃលក្ខណ៍នៃនាមរូប ព្រមទាំងបច្ច័យ ចម្រើនវិបស្សនា សម្រេចអរហត្តតាមលំដាប់ នេះជាផ្លូវនៃការផុតចាកទុក្ខរបស់ភិក្ខុមួយរូប ។

ពាក្យថា **ឥតិ អជ្ឈត្តំ វា** - ក្នុងកាយខាងក្នុង មានន័យថា ពិចារណាឃើញកាយក្នុងកាយ គឺ ខ្យល់អស្សាសបស្សាសៈរបស់ខ្លួន ។ ពាក្យថា **ឬ ខាងក្រៅ** មានន័យថា ពិចារណាឃើញកាយក្នុងកាយ គឺ ខ្យល់អស្សាសបស្សាសៈរបស់អ្នកដទៃ ។ ពាក្យថា **ទាំងខាងក្នុងទាំងខាងក្រៅ** មានន័យថា ឬ ក្នុងកាយ គឺ ខ្យល់អស្សាសបស្សាសៈរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយ

ពាក្យនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ កាលភិក្ខុនោះមិនដាក់ចុះនូវកម្មដ្ឋាន ដែលស្ទាត់ជំនាញ ឱ្យកាយ គឺ ខ្យល់អស្សាសបស្សាសៈសញ្ចរទៅមក ក៏កិច្ចទាំង ២ នេះ មិនមានក្នុងខណៈតែមួយនោះទេ ។

**បបញ្ចសូទនី អដ្ឋកថា អានាបានស្សតិសូត្រ :**

បទថា **កាយញ្ញតរំ** មានន័យថា តថាគតពោលនូវកាយមួយប្រភេទ ក្នុងបណ្តាកាយ ៤ មានបឋវីកាយជាដើម អធិប្បាយថា តថាគតពោលថា **ខ្យល់** ជាកាយ ។ម្យ៉ាងទៀត កោដ្ឋាស ( ចំណែក )នៃរូប **២៥** គឺ រូបាយតនៈ ។ ល ។ កវឡិង្ការាហារ ឈ្មោះថា **រូបកាយ** បណ្តាកោដ្ឋាសនៃរូប ២៥ នោះ **អានាបាន** ( ខ្យល់ដង្ហើមចេញចូល ) ជាកាយមួយប្រភេទ សង្គ្រោះចូលក្នុង **ផោដ្ឋព្វា-យតនៈ** ព្រោះហេតុនោះ ទើបទ្រង់ត្រាស់យ៉ាងនោះ ។ បទថា **តស្មាតិហ** មានន័យថា ព្រោះហេតុដែលភិក្ខុតាមកំណត់ដឹងនូវ **វាយោកាយ** ជាកាយមួយប្រភេទ ក្នុងកាយទាំង ៤ ឬ តាមឃើញ **អនាបាន** ជាកាយមួយប្រភេទ ក្នុងចំណែកនៃរូប **២៥** ដែលជារូបកាយ ព្រោះហេតុនោះ ទើបជាអ្នកពិចារណាឃើញកាយក្នុងកាយ ។

បទថា **បហានំ** ទ្រង់សម្តែងយកញាណជាគ្រឿងលះបង់ យ៉ាងនេះថា លះបង់និច្ចសញ្ញា " ការឃើញថាទៀង " ដោយអនិច្ចានុបស្សនា " ការតាមឃើញថា មិនទៀង " ។ បទថា **តំ បញ្ញាយ ទិស្វា** ទ្រង់សម្តែងដល់វិបស្សនា ដែលបន្តគ្នា គឺ សម្តែង **បហានញាណ** ពោលគឺ អនិច្ចញាណ , វិរាគញាណ និរោធញាណ បដិនិស្សគ្គញាណ ដោយវិបស្សនាបញ្ញាដទៃទៀត ។ បទថា **អជ្ឈុបេក្ខិតា ហោតិ** មានន័យថា សម្លឹងមើលក្នុងចំណែកទាំង ២ គឺ ការសម្លឹង

មើលនៃអ្នកបដិបត្តិសមថៈ និង ការសម្លឹងមើលការប្រាកដរួមគ្នា ។ ក្នុងការសម្លឹងមើល ២ យ៉ាងនោះ ការសម្លឹងមើលសហជាតធម៌ ក៏មាន , ការសម្លឹងមើលអារម្មណ៍ ក៏មាន ទីនេះសំដៅយកការសម្លឹងអារម្មណ៍ ។ បទថា **អជ្ឈុបេ-ក្ខិតា ហោតិ** មានន័យថា ជាអ្នកសម្លឹងមើលនូវសហជាតធម៌ ។

ពាក្យថា **ពិចារណាឃើញធម៌** គឺ ហេតុកើតឡើង គឺ អាស្រ័យស្នប់របស់ជាងទង ១ ស្បែកស្នប់ ១ , ការព្យាយាម កើតពីស្បែកស្នប់សម្រាប់រុញខ្យល់ ទើបនឹងសញ្ចរទៅមកបាន យ៉ាងណា **កាយ** គឺ ខ្យល់អស្សាសបស្សាសៈ អាស្រ័យ ករជកាយ១ រន្ធច្រមុះ១ ចិត្ត១ របស់ភិក្ខុ ទើបសញ្ចរទៅមកបាន ដូច្នោះដែរ ។ ភិក្ខុឃើញធម៌ មានកាយជាដើម ដែលមានការកើតឡើងជាធម្មតា ទ្រង់ហៅថា ពិចារណាឃើញធម៌ដែលប្រជុំកើតឡើងក្នុងកាយ ។ ពាក្យថា **ពិចារណាឃើញធម៌** គឺ ការរលត់ មានន័យថា កាលស្បែកស្នប់ត្រូវនាំចេញមកហើយ កាលស្បែកខូចហើយ កាលសេចក្តីព្យាយាមដែលកើតពីស្បែកនោះ មិនមាន ខ្យល់នោះ រមែងប្រព្រឹត្តទៅមិនបាន យ៉ាងណា កាលកាយបែកធ្លាយហើយ កាលរន្ធច្រមុះត្រូវកម្ចាត់ចោលហើយ និងកាលចិត្តរលត់ហើយ ឈ្មោះថា **កាយ** គឺ ខ្យល់អស្សាសបស្សាសៈ ក៏រមែងប្រព្រឹត្តទៅមិនបានដូច្នោះដូចគ្នា ។ ភិក្ខុឃើញយ៉ាងនេះថា ខ្យល់អស្សាសបស្សាសៈរលត់ ព្រោះកាយជាដើមរលត់ ដូច្នេះ ទ្រង់ហៅថា ពិចារណាឃើញធម៌ គឺ ការរលត់នៃកាយ ។

ពាក្យថា **ពិចារណាឃើញធម៌ គឺ ការកើតនិងការរលត់** មានន័យថា ពិចារណាឃើញការកើត និង ការរលត់តាមកាល ។

ពាក្យថា **សតិរបស់លោកប្រាកដច្បាស់ថា កាយមានមែន** មានន័យថា

សតិរបស់ភិក្ខុនោះ ចូលទៅតម្កល់ចំពោះយ៉ាងនេះថា កាយនេះមានមែន តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុស មិនមែនខ្លួន មិនមែនរបស់ខ្លួន មិនមែនយើង មិនមែនរបស់យើង មិនមែនគេ មិនមែនរបស់គេ ។

ពាក្យថា **ត្រឹមប៉ុណ្ណោះ** នេះជាគ្រឿងកំណត់នូវដែននៃប្រយោជន៍ ។ លោកអធិប្បាយថា សតិចូលទៅតាំងមាំនោះ មិនមែនដើម្បីប្រយោជន៍យ៉ាងដទៃនោះទេ ដែលពិតនោះ ដើម្បីប្រយោជន៍ គឺ ការដឹង គឺប្រមាណនៃការដឹងដ៏ប្រពៃក្រៃលែងឡើង និងប្រមាណនៃសតិប៉ុណ្ណោះ អធិប្បាយថា ដើម្បីចម្រើននូវសតិសម្បជញ្ញៈ ។ ពាក្យថា **មានចិត្តមិនអាស្រ័យ** មានន័យថា មិនត្រូវកិលេសអាស្រ័យ ដោយអំណាចនៃកិលេស គឺ តណ្ហា និង ទិដ្ឋិ ។ ពាក្យថា **មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក** មានន័យថា មិនប្រកាន់អ្វី ៗ ក្នុងលោក គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ថា នេះជាខ្លួនរបស់យើង នេះមាននៅក្នុងខ្លួនរបស់យើង ។

ម្យ៉ាងទៀត ការរួញរាខាងក្នុង រមែងធ្វើអន្តរាយដល់អ្នកដែលមិនមានសេចក្តីព្យាយាម មិនមានសម្បជញ្ញៈ ជាអ្នកមានសេចក្តីវង្វេងក្នុងបដិបទា ជាអ្នកដែលប្រព្រឹត្តទៅក្នុងវត្ថុមិនមែនជាឧបាយ អ្នកនៅប្រាសចាកសតិ រមែងមិនអាចជាអ្នកមានការកំណត់ដឹងនូវបដិបទាបានទេ ព្រោះហេតុនោះ កម្មដ្ឋាននោះរបស់ភិក្ខុនោះ រមែងមិនសម្រេច ដូច្នោះហើយ កម្មដ្ឋាននោះ កាលបើនឹងសម្រេចដោយអានុភាពនៃធម៌ណា កាលទ្រង់សម្តែងនូវធម៌ទាំងឡាយនោះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ថា មានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ ។

ទ្រង់សម្តែង កាយានុបស្សនាសតិប្បដ្ឋាន ព្រមទាំងអង្គនៃសម្បយោគ ដើម្បីនឹងទ្រង់សម្តែងនូវអង្គនៃការលះបង់ ទើបត្រាស់ថា កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោក ។

ពាក្យថា **កម្ចាត់បង់** មានន័យថា នាំចេញដោយការកម្ចាត់ចោលជាខណៈៗ ឬដោយការគ្របសង្កត់ ។ ពាក្យថា **ក្នុងលោក** គឺ ក្នុងកាយនោះឯង ។ ពិតហើយ **កាយនេះ** ទ្រង់ត្រាស់ថា **លោក** ព្រោះអត្ថថា ទ្រុឌទ្រោម ។

អភិជ្ឈា និង ទោមនស្ស មិនមែនព្រះយោគាវចរនោះ លះបង់បានក្នុងអារម្មណ៍ ត្រឹមកាយនេះប៉ុណ្ណោះទេ សូម្បីក្នុងវេទនាជាដើម ក៏លះបង់បានដូចគ្នា ព្រោះដូច្នោះ ទើបទ្រង់ពោលទុកក្នុងសតិប្បដ្ឋានវិភង្គថា ឧបាទានក្ខន្ធ ៥ ក៏ហៅថា **លោក** ។

ពាក្យនោះ ទ្រង់ពោលទុក តាមន័យនៃការអធិប្បាយសេចក្តី ព្រោះធម៌ទាំងឡាយនោះ រាប់បានថាជា **លោក** ។

តែទ្រង់ពោលពាក្យណាទុកថា លោកដូចម្តេច **លោក** គឺ កាយនោះឯង ក្នុងពាក្យនោះ មានដូច្នេះឯង ។ គប្បីឃើញការភ្ជាប់សេចក្តីដូច្នេះថា កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកនោះ ។

ក្នុងទីនេះ **កាមច្ឆន្ទ** រួមចូលនឹងសព្ទថា **អភិជ្ឈា** , **ព្យាបាទ** រួមចូលនឹងសព្ទថា **ទោមនស្ស** ដូច្នោះ ទើបគួរជ្រាបថា ទ្រង់អធិប្បាយការលះនីវរណៈ ដោយទ្រង់សម្តែងជាគូ ដែលមានកម្លាំងទាក់ទងនឹងនីវរណៈ ។

តែដោយពិសេស ក្នុងទីនេះ ទ្រង់ត្រាស់នូវសេចក្តីត្រេកអរ ដែលមានកាយសម្បត្តិជាមូល ដោយការកម្ចាត់បង់នូវអភិជ្ឈា ទ្រង់ត្រាស់ដល់សេចក្តីមិន

ត្រេកអរ ដែលមានកាយវិបត្តិជាមូល ដោយការកម្ចាត់បង់នូវទោមនស្ស ត្រាស់នូវតម្រេកក្នុងកាយ ដោយការកម្ចាត់បង់នូវអភិជ្ឈា ត្រាស់ដល់ការមិនត្រេកអរក្នុងការចម្រើនកាយានុបស្សនា ដោយការកម្ចាត់បង់នូវទោមនស្ស ត្រាស់ការលះបង់កាយ ដែលសម្គាល់ថា ជាភាវៈស្អាត ជាសុខជាដើម ដែលមិនមានពិតក្នុងកាយ ដោយការកម្ចាត់បង់អភិជ្ឈា និងត្រាស់ដល់ការលះបង់នូវភាវៈដែលមិនស្អាត ជាទុក្ខជាដើម ដែលមានពិតនៅក្នុងកាយ ដោយការកម្ចាត់បង់នូវទោមនស្ស ។

ដោយព្រះតម្រាស់នេះ ទ្រង់សម្តែងដល់អានុភាពនៃសេចក្តីព្យាយាម និង ជាអ្នកអាចក្នុងការប្រកបនូវសេចក្តីព្យាយាមរបស់ព្រះយោគាវចរនោះ ។ ពិតហើយ អានុភាពនៃសេចក្តីព្យាយាមនោះ គឺ នឹងជាអ្នករួចផុតចាកសេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរ និងវៀរចាកស្រឡះនូវវត្ថុដែលមិនមានតាមសេចក្តីពិត នាំចេញមកនូវវត្ថុដែលមានតាមសេចក្តីពិត ។

ព្រះយោគាវចរនោះ ជាអ្នករួចផុតចាកនូវសេចក្តីរីករាយ និង មិនរីករាយ ជាអ្នកគ្របសង្កត់នូវសេចក្តីរីករាយនិងមិនរីករាយ មិនប្រមូលមកនូវវត្ថុដែលមិនមានតាមសេចក្តីពិត មិនលះចោលនូវវត្ថុដែលមានតាមសេចក្តីពិត ទើបឈ្មោះថា ជាអ្នកអាចក្នុងការប្រកបសេចក្តីព្យាយាមដោយប្រការនោះ ៗ ។

ម្យ៉ាងទៀត ទ្រង់ត្រាស់កម្មដ្ឋានដោយអនុបស្សនា ក្នុងពាក្យថា **កាយេ កាយានុបស្សី** ពិចារណាឃើញកាយក្នុងកាយ ។ ត្រាស់ដល់ការរក្សាកាយរបស់ព្រះយោគាវចរដោយការបំពេញកម្មដ្ឋាន ដោយវិហារធម៌ដែលពោលទុកហើយក្នុងពាក្យថា **វិហរតិ** ។

ក្នុងពាក្យខាងដើមថា **អាតាបី** មានសេចក្ដីព្យាយាម គប្បីជ្រាបថា ទ្រង់ត្រាស់ដល់សម្មាវាយាមៈ ដោយអាតាបៈ , សេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ទ្រង់ត្រាស់ដល់កម្មដ្ឋានដែលឱ្យសម្រេចនូវប្រយោជន៍ទូទៅ ឬឧបាយជាគ្រឿងរក្សាកម្មដ្ឋានដោយសតិសម្បជញ្ញៈ ឬ ត្រាស់សមថៈដែលបានមកដោយអំណាចនៃកាយានុបស្សនា ត្រាស់វិបស្សនាដោយសម្បជញ្ញៈ ត្រាស់ដល់ផលនៃភាវនា ដោយការកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ។

# បាលីវិភង្គ

ចំណែកក្នុងបាលីវិភង្គ បានពោលនូវអត្ថនៃបទទាំងឡាយនោះ ទុកថា បទថា **អនុបស្សី** មានន័យថា អនុបស្សនា ក្នុងពាក្យនោះ តើដូចម្តេច ? ការដឹងដោយជុំវិញ ការដឹងទូទៅ ។ ល ។ ការឃើញត្រូវ នេះហៅថា **អនុបស្សនា** បុគ្គលបានប្រកបហើយ ប្រកបព្រមហើយ ចូលទៅហើយ ចូលទៅព្រមហើយ ចូលដល់ហើយ ចូលដល់ព្រមហើយ មកតាមព្រមហើយ ដោយអនុបស្សនានេះ ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **អនុបស្សី** ។ បទថា **វិហរតិ** ប្រែថា រស់នៅ ប្រព្រឹត្តទៅ រក្សា ដំណើរទៅ ឱ្យអត្តភាពដំណើរទៅ ត្រាច់ទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **វិហរតិ** ។

បទថា **អាតាបី** ជាអ្នកមានសេចក្តីព្យាយាម ប្រែថា **អាតាប** សេចក្តីព្យាយាមក្នុងពាក្យនោះ ដូចម្តេច ការប្រារព្ធសេចក្តីព្យាយាមតាមផ្លូវចិត្ត ។ ល ។ សម្មាវាយាមៈណា នេះហៅថា **អាតាប** បុគ្គលប្រកបដោយ **អាតាប** ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **អាតាបី** ។ បទថា **សម្បជានោ** មានន័យថា សម្បជញ្ញៈ ក្នុងពាក្យនោះ តើដូចម្តេច ? ការដឹងត្រូវ ការដឹងទូទៅ ។ ល ។ ការឃើញត្រូវ នេះហៅថា **សម្បជញ្ញ** បុគ្គលណាប្រកបហើយ ។ ល ។ មកតាមព្រមហើយ ដោយសម្បជញ្ញៈនេះ ព្រោះហេតុនោះ បុគ្គលនោះ ឈ្មោះថា **សម្បជានោ** ។ បទថា **សតិមា** មានន័យថា សតិ ក្នុងពាក្យនោះ តើដូចម្តេច ? ការរលឹក ការរលឹកដល់ ។ ល ។ ការរលឹកត្រូវ នេះហៅថា **សតិ** បុគ្គលណាប្រកបហើយ ។ ល ។ មកតាមព្រមហើយ ដោយសតិនេះ ព្រោះហេតុនោះ បុគ្គលនោះ ហៅថា **សតិមា** ។ សេចក្តីថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ**

មានន័យថា **លោក** ក្នុងពាក្យនោះ តើដូចម្ដេច ?
កាយនោះឯង ហៅថា **លោក** , ឧបាទានក្ខន្ធ **៥** ក៏ហៅថា **លោក** នេះហៅថា **លោក** ។

**អភិជ្ឈា** ក្នុងពាក្យនោះ តើដូចម្ដេច ?

សេចក្ដីត្រេកអរ ត្រេកអរខ្លាំង ការសប្បាយចិត្ត ការរីករាយ តម្រេក សេចក្ដីត្រេកអរដោយអំណាចនៃតម្រេកខ្លាំង សេចក្ដីត្រេកត្រអាលនៃចិត្ត នេះហៅថា **អភិជ្ឈា** ។ **ទោមនស្ស** ក្នុងពាក្យនោះ តើដូចម្ដេច ? ការមិនសប្បាយផ្លូវចិត្ត ទុក្ខផ្លូវចិត្ត ។ ល ។ វេទនាមិនសុខ ជាទុក្ខដែលកើតពីសម្ផស្សផ្លូវចិត្ត នេះហៅថា **ទោមនស្ស** ។

អភិជ្ឈា និង ទោមនស្សនេះ ដែលព្រះយោគាវចរកម្ចាត់ហើយ នាំចេញហើយ រលត់ហើយ ឱ្យស្ងប់ហើយ ឱ្យរំងាប់ហើយ ឱ្យដល់នូវការតាំងនៅមិនបានហើយ ឱ្យដល់នូវការសាបសូន្យហើយ ឱ្យដល់នូវការមិនមានហើយ ឱ្យដល់នូវការវិនាសហើយ ហួតហែងហើយ ឱ្យស្ងួតអស់ហើយ ធ្វើឱ្យដល់នូវទីបំផុតហើយ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ន័យនេះមកក្នុងអត្ថដូច្នេះ ក្នុងបាលីវិភង្គ បណ្ឌិតគប្បីជ្រាបដោយប្រការដូច្នេះចុះ ។

**១ - សតិ** ក្នុងកាយរបស់ភិក្ខុនោះ ដោយការកំណត់ក្នុងអាការយ៉ាងនេះ ជា **សតិសម្ពោជ្ឈង្គៈ** ។

**២ - ញាណ** ដែលសម្បយុត្តដោយសតិជា **ធម្មវិចយសម្ពោជ្ឈង្គៈ** ។

**៣ - វីរិយៈ** តាមផ្លូវកាយ និងចិត្តដែលសម្បយុត្តដោយធម្មវិចយសម្ពោជ្ឈង្គ

នោះជា **វិរិយសម្ពោជ្ឈង្គៈ** ។

**៤ - បីតិ** បីតិប្រាសចាកអាមិសរបស់ភិក្ខុ ដែលមានសេចក្ដីព្យាយាមហើយ ជា **បីតិសម្ពោជ្ឈង្គៈ** ។

**៥ - បស្សទ្ធិ** ក្នុងសម័យណា កាយ និង ចិត្ត របស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ស្ងប់រម្ងាប់ក្នុងសម័យនោះ នេះជា **បស្សទ្ធិសម្ពោ-ជ្ឈង្គៈ** ។

**៦-សមាធិ** សម័យណាចិត្តរបស់ភិក្ខុអ្នកមានកាយស្ងប់ហើយ មានសេចក្ដីសុខ ក៏រមែងតាំងមាំ ជា **សមាធិសម្ពោជ្ឈង្គៈ** ។

**៧-ឧបេក្ខា** ពោលគឺ សម្ពោជ្ឈង្គៈ **៦** ប្រការ ដូចបានពោលមកនេះ មិនតឹងពេក មិនធូរពេក ជា **ឧបេក្ខាសម្ពោជ្ឈង្គៈ** ។

ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ដែលភិក្ខុចម្រើនយ៉ាងនេះហើយ ធ្វើឱ្យច្រើនហើយ ឈ្មោះថាធ្វើ **ពោជ្ឈង្គៈ ៧** ឱ្យពេញបរិបូរណ៍ ។

ដោយហេតុមានប្រមាណត្រឹមប៉ុណ្ណេះ ទ្រង់សម្ដែងដល់វិបស្សនា ព្រមដោយលក្ខណៈផ្សេង១ ក្នុងជួរខណៈចិត្ត១ ថាជា **សម្ពោជ្ឈង្គៈ** ។

លោកិយសតិប្បដ្ឋាន ធ្វើលោកិយសម្ពោជ្ឈង្គៈឱ្យបរិបូរណ៍ លោកិយសម្ពោជ្ឈង្គៈធ្វើ វិជ្ជា វិមុត្តិ ផល និង និព្វានដែលជាលោកុត្តរឱ្យបរិបូរណ៍ ។

# ខ្យល់អានាបានសមថន័យ

វិសុទ្ធិមគ្គ : សូម្បីក្នុងប្រភេទនៃការកំណត់កាយសង្ខារ នៅគ្រោតគ្រោត , ក្នុងថ្នាក់ឧបចារសមាធិនៃបឋមជ្ឈាន ទើបល្អិត , ក្នុងថ្នាក់ឧបចារនៃបឋមជ្ឈានទាំងឡាយនោះ នៅគ្រោតគ្រោត ក្នុងថ្នាក់នៃបឋមជ្ឈានទើបល្អិត , ក្នុងថ្នាក់បឋមជ្ឈាន និងឧបចារនៃទុតិយជ្ឈាននៅគ្រោតគ្រោត ក្នុងថ្នាក់ទុតិយ-ជ្ឈានទើបល្អិត , ក្នុងថ្នាក់ទុតិយជ្ឈាននិងឧបចារនៃតតិយជ្ឈាននៅគ្រោតគ្រោត ក្នុងថ្នាក់នៃតតិយជ្ឈានទើបល្អិត , ក្នុងថ្នាក់តតិយជ្ឈាននិងឧបចារនៃចតុត្ថជ្ឈាន នៅគ្រោតគ្រោត ក្នុងថ្នាក់ចតុត្ថជ្ឈានទើបល្អិត រហូតដល់ការមិនកើតឡើងតែម្តង " ពាក្យដែលពោលមកនេះ ជាមតិរបស់ព្រះទីឃភាណកៈ ( អ្នកពោលគម្ពីរទីឃនិកាយ ) និង ព្រះសំយុត្តភាណកៈ ( អ្នកពោលគម្ពីរសំយុត្តនិកាយ ) រីឯ ព្រះមជ្ឈិមភាណកៈទាំងឡាយបំណងយក សូម្បីក្នុងឧបចារនៃឈានជាន់លើ ក៏ល្អិតជាងឈានជាន់ក្រោម ដូចជា " ក្នុងបឋមជ្ឈាននៅគ្រោតគ្រោត ក្នុងឧបចារជ្ឈាន នៃទុតិយជ្ឈានល្អិត " ដូច្នេះ ជាឧទាហរណ៍ , តែថា ដោយមតិរបស់អាចារ្យទាំងអស់នោះ មានន័យថា កាយសង្ខារដែលកើតឡើងក្នុងពេលមិនទាន់បានកំណត់ជា ( ព្រះកម្មដ្ឋាន ) នឹងស្ងប់នៅក្នុងពេលកំណត់ជា ( ព្រះកម្មដ្ឋាន ) , កាយសង្ខារដែលកើតឡើងក្នុងពេលកំណត់ ( ព្រះកម្មដ្ឋាន ) នឹងស្ងប់ក្នុងឧបចារនៃបឋមជ្ឈាន ។ ល ។ កាយសង្ខារដែលកើតឡើងក្នុងឧបចារនៃចតុត្ថជ្ឈាន នឹងស្ងប់ក្នុងចតុត្ថជ្ឈាន ដូច្នេះឯង នេះជាន័យតាមផ្លូវសមថៈ ។

# ខ្យល់អានាបាវិបស្សនាន័យ

វីឯ ក្នុងផ្លូវវិបស្សនា កាយសង្ខារដែលមិនទាន់បានកំណត់ នៅគ្រោត គ្រោត ក្នុងពេលធ្វើការកំណត់មហាភូតរូប ទើបល្អិត សូម្បីកាយសង្ខារក្នុងពេល កំណត់មហាភូតរូបនោះ ក៏នៅគ្រោតគ្រោត តែពេលកំណត់ឧបាទាយរូបទើប ល្អិត កាយសង្ខារក្នុងពេលកំណត់ឧបាទាយរូបនោះ នៅគ្រោតគ្រោត តែក្នុង ពេលកំណត់សកលរូប ទើបល្អិត កាយសង្ខារក្នុងពេលដែលកំណត់សកលរូប នោះ នៅគ្រោតគ្រោត ក្នុងពេលកំណត់អរូប ទើបល្អិត កាយសង្ខារក្នុងពេល កំណត់អរូបនោះនៅគ្រោតគ្រោត តែពេលកំណត់ទាំងរូបទាំងអរូប ទើបល្អិត សូម្បីកាយសង្ខារពេលកំណត់ទាំងរូបទាំងអរូបនោះ ក៏នៅគ្រោតគ្រោត តែក្នុង ពេលដែលកំណត់បច្ច័យ ( របស់នាមរូប ) ទើបល្អិត កាយសង្ខារក្នុងពេល កំណត់បច្ច័យនោះនៅគ្រោតគ្រោត តែក្នុងពេលឃើញនាមរូបព្រមទាំងបច្ច័យ ទើបល្អិត កាយសង្ខារក្នុងពេលឃើញនាមរូបព្រមទាំងបច្ច័យ នៅគ្រោតគ្រោត តែពេលដែលវិបស្សនាមាន ( សាមញ្ញ )លក្ខណៈជាអារម្មណ៍ ទើបល្អិត ក្នុង ទុព្វលវិបស្សនា ( វិបស្សនាទន់ខ្សោយ ) នៅគ្រោតគ្រោត ក្នុងពលវវិបស្សនា ទើប ល្អិត ។

ក្នុងវិបស្សនានោះ ការរម្ងាប់កាយសង្ខារ ប្រព្រឹត្តទៅជាខាងដើម ដំបូង១ រហូតទៅដល់ចុង តាមលំដាប់ បណ្ឌិតគប្បីជ្រាបតាមន័យដូចដែល ពោលមកដូច្នេះចុះ ។

( ចប់ អានាបានបព្វៈ )

# ២ - ឥរិយាបថបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុកាលដើរក្តី ក៏ដឹងច្បាស់ថា អាត្មាអញដើរ កាលឈរក្តី ក៏ដឹងច្បាស់ថា អាត្មាអញឈរ កាលអង្គុយក្តី ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ កាលដេកក្តី ក៏ដឹងច្បាស់ថា អាត្មាអញដេក ។

ម្យ៉ាងទៀត ភិក្ខុនោះ បានតាំងនូវកាយដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយនោះ ដោយអាការយ៉ាងនោះ ៗ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងយ៉ាងនេះ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្រៅ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុងនិងខាងក្រៅគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ដែលកើតឡើង និង ធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។

មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយ តណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់ អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណា ឃើញកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាង នេះឯង ។

## អដ្ឋកថា

ព្រះមានព្រះភាគ កាលទ្រង់ចែក កាយានុបស្សនាតាមរយៈខ្យល់ អស្សា-សបស្សាសៈយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ចែកតាមរយៈនៃឥរិយាបថ ទើបត្រាស់ថា **បុន បចរំ** ម្យ៉ាងទៀត ដូច្នេះជាដើម ។

ក្នុងឥរិយាបថទាំងនោះ គប្បីជ្រាបថា សត្វតិរច្ឆាន ដូចជាឆ្កែស្រុក ឬ ឆ្កែចចកជាដើម កាលដើរ ក៏ដឹងថាខ្លួនដើរ ពិតមែន តែក្នុងឥរិយាបថនោះ ទ្រង់មិនបានត្រាស់សំដៅយកការដឹងក្នុងទីនេះទេ ព្រោះការដឹងដូច្នោះ មិនអាចលះបង់នូវសេចក្ដីប្រកាន់ថាសត្វបាន ដកចេញនូវការឃើញថាជាសត្វមិនបាន មិនមែនជាកម្មដ្ឋាន ឬ សតិប្បដ្ឋានភាវនាឡើយ ។ ចំណែកការដឹងរបស់ភិក្ខុ ( អ្នកចម្រើនកាយានុបស្សនាសតិប្បដ្ឋាន ) រមែងលះបង់នូវការឃើញថាជាសត្វ ដកនូវការប្រកាន់ថាជាសត្វបាន ជាកម្មដ្ឋាន និងជាសតិប្បដ្ឋានភាវនា ។ ពាក្យដែលទ្រង់ត្រាស់ សំដៅដល់ការឃើញច្បាស់យ៉ាងនេះថា **នរណាដើរ ការដើររបស់នរណា ដើរបានព្រោះអ្វី** ។ សូម្បីក្នុងឥរិយាបថដទៃ មានការឈរជាដើម ក៏មានន័យដូច្នេះ ។

នឹងវិនិច្ឆ័យ ក្នុងបញ្ហាទាំងឡាយនោះថា **នរណាដើរ** មានន័យថា មិនមែនសត្វ ឬ បុគ្គលណា១ ដើរឡើយ ។ ពាក្យថា **ការដើររបស់នរណា** មានន័យថា មិនមែនការដើររបស់សត្វ ឬ បុគ្គលណា ១ ឡើយ ។ ពាក្យថា **ដើរបានព្រោះអ្វី** មានន័យថា ដើរបានព្រោះការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ។ ព្រោះដូច្នោះ ភិក្ខុនោះ រមែងដឹងច្បាស់យ៉ាងនេះថា គឺ ចិត្ត

កើតឡើងថា **យើងនឹងដើរ** ចិត្តនោះ ក៏ធ្វើឱ្យកើតវាយោធាតុ វាយោធាតុក៏ធ្វើឱ្យកើតវិញ្ញត្តិ គឺ ការកម្រើក ការនាំសកលកាយឱ្យឈានទៅខាងមុខ ដោយការកម្រើកនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ហៅថា **ដើរ** ។

សូម្បីក្នុងឥរិយាបថដទៃ មានការឈរជាដើម ក៏មានន័យដូចគ្នា ។

ក្នុងឥរិយាបថឈរជាដើមនោះ ចិត្តកើតឡើងថា **យើងនឹងឈរ** ចិត្តនោះធ្វើឱ្យកើតវាយោធាតុ វាយោធាតុធ្វើឱ្យកើតវិញ្ញត្តិ គឺ ការកម្រើក ការជ្រោងសកលកាយ ឱ្យតាំងឡើងមកតាំងពីបាតជើងជាទីបំផុត ដោយការកម្រើកនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ហៅថា **ឈរ** ។

ចិត្តកើតឡើងថា **យើងនឹងអង្គុយ** ចិត្តនោះ ក៏ធ្វើឱ្យកើតវាយោធាតុ វាយោធាតុធ្វើឱ្យកើតវិញ្ញត្តិ គឺ ការកម្រើក ការបត់កាយ ផ្នែកខាងក្រោយចុះ ជ្រោងកាយខាងលើឡើង ដោយការកម្រើកនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ហៅថា **អង្គុយ** ។

ចិត្តកើតឡើងថា **យើងនឹងដេក** ចិត្តនោះ ក៏ធ្វើឱ្យកើតវាយោធាតុ វាយោធាតុធ្វើឱ្យកើតវិញ្ញត្តិ គឺ ការកម្រើក ការសណ្ដូកកាយ ដោយអាការដេក ដោយការកម្រើកនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត នេះហៅថា **ដេក** ។

ភិក្ខុនោះដឹងច្បាស់យ៉ាងនេះ រមែងមានការគិតឃើញយ៉ាងនេះថា គេពោលថា សត្វដើរ សត្វឈរ សត្វអង្គុយ សត្វដេក តែដោយអត្ថហើយ សត្វណា១ ដើរ ឈរ មិនមាន ដូចពាក្យដែលពោលថា រទេះទៅមុខ រទេះឈប់ តែដោយពិត រទេះមិនបានទៅ មិនបានឈប់ ដោយខ្លួនឯងឡើយ តែពេលនាយសារថីដែលឆ្លាតទឹមគោរ ៤ ក្បាល ហើយបរទៅ រទេះទើបទៅ ទើបឈប់

ព្រោះដូច្នោះ ពាក្យនោះគ្រាន់តែបញ្ញត្តិដែលសន្មតគ្នា យ៉ាងណា **កាយ** ប្រៀបដូចរទេះ ព្រោះអត្ថថា មិនដឹង ខ្យល់ដែលកើតពីចិត្ត ប្រៀបដូចគោ ចិត្តប្រៀបដូចសារថី កាលចិត្តកើតឡើងគិតថា **យើងនឹងដើរ យើងនឹងឈរ** វាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ក៏កំរើកឡើង ឥរិយាបថ មានដើរ ជាដើម រមែងប្រព្រឹត្តទៅ ព្រោះការកំរើកនៃវាយោធាតុដែលកើតពីកិរិយារបស់ចិត្ត បន្ទាប់ពីនោះទៅ សត្វក៏ដើរ សត្វក៏ឈរ យើងក៏ដើរ យើងក៏ឈរ ព្រោះហេតុនោះពាក្យនោះ គ្រាន់តែជាការបញ្ញត្តិ សន្មតគ្នា ដូច្នោះដូចគ្នា ។

ទើបព្រះបុរាណាចារ្យពោលថា :

**នាវា មាលុតវេគេន ជិយាវេគេន តេជនំ យថា យាតិ តថា កយោយាតិ វាតាហតោ អយំ យន្តំ សុត្តវសេនេវ ចិត្តសុត្តវសេនិទំ បយុត្តំ កាយយន្តម្បិ យាតិ ឋាតិ និសីទតិ កោ នាម ឯត្ថ សោ សត្តោ យោ វិនា ហេតុប្បច្ចយោ អត្តនោ អានុភាវេន តិដ្ឋេ វា យទិ វា វជេ ។**

ប្រែថា : ទូកស្ទុះទៅដោយកម្លាំងខ្យល់ គ្រាប់ព្រួញស្ទុះទៅដោយកម្លាំងខ្សែធ្នូ យ៉ាងណា កាយនេះត្រូវខ្យល់នាំទៅ ទើបដើរទៅបាន ក៏ដូច្នោះ ស្ទូម្បីសរីរយន្ត គឺ កាយនេះត្រូវបច្ច័យប្រកបហើយ ដើរ ឈរ និងអង្គុយបានដោយអំណាចខ្សែ គឺ ចិត្ត ដូចជាគ្រឿងយន្តវិលទៅ ដោយអំណាចខ្សែទាញដូច្នោះ , ក្នុងលោកនេះ សត្វណា ៗ វៀរហេតុបច្ច័យចេញហើយ ឈរបានដើរបាន ដោយអានុភាពរបស់ខ្លួន សត្វនោះ ឈ្មោះអ្វីទៅ ។

ព្រោះដូច្នោះ គប្បីជ្រាបថា ភិក្ខុនេះកំណត់ឥរិយាបថ មានដើរជាដើមដែលប្រព្រឹត្តទៅបាន ដោយអំណាចហេតុ-បច្ច័យ ប៉ុណ្ណោះយ៉ាងនេះ ពេលដើរ

ក៏ដឹងថាយើងដើរ ពេលឈរ ក៏ដឹងថាយើងឈរ ពេលអង្គុយ ក៏ដឹងថាយើងអង្គុយ ពេលដេក ក៏ដឹងថាយើងដេក ។ ពាក្យថា **ឬថា កាយរបស់លោកតាំងនៅដោយអាការណា១ ក៏ដឹងនូវកាយនោះ ដោយអាការនោះ១** នេះជាការពោលរួមដល់ឥរិយាបថទាំងអស់ ។

មានពាក្យអធិប្បាយថា ឬ កាយរបស់លោកតាំងនៅដោយអាការណា ១ ក៏ដឹងច្បាស់នូវកាយនោះ ដោយអាការនោះ ១ គឺ កាយនោះតាំងនៅដោយអាការដើរ តាំងនៅដោយអាការឈរ អង្គុយ ដេក ក៏ដឹងច្បាស់ថា យើងឈរ យើងអង្គុយ យើងដេក ។

## ឥរិយាបថខាងក្នុង-ខាងក្រៅ

ពាក្យថា **ខាងក្នុង** មានន័យថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ៤ របស់ខ្លួនយ៉ាងនេះ ។ ពាក្យថា **ឬខាងក្រៅ** គឺ ដោយការកំណត់ឥរិយាបថ ៤ របស់អ្នកដទៃ ។ បទថា **ទាំងខាងក្នុង ទាំងខាងក្រៅ** មានន័យថា ពិចារណាឃើញកាយក្នុងកាយ ដោយការកំណត់ឥរិយាបថ ៤ របស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ។ ក្នុងបាលីជាដើមថា **ពិចារណាឃើញធម៌ គឺ ការកើតឡើង** គឺ ត្រូវនាំការកើត និងការរលត់នៃរូបក្ខន្ធឡើងសម្តែងក្នុងអាការទាំង ៥ តាមន័យ បាលីជាដើមថា រូបកើត ព្រោះអវិជ្ជាកើត ដូច្នេះ ។

ព្រះមានព្រះភាគទ្រង់សំដៅយក ការកើត និង ការរលត់ នោះឯង ទើបត្រាស់ថា គឺ ការកើតដូច្នេះជាដើម ។ បាលីជាដើមថា សតិរបស់លោក ក៏

ប្រាកដច្បាស់ថា **កាយមានមែន** ដូច្នេះ ក៏មានសេចក្តីដូចគ្នា តាមដែលពោល ហើយ ។

( ចប់ ឥរិយាបថបព្វៈ )

# ៣ – សម្បជញ្ញបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុធ្វើនូវសម្បជញ្ញៈ គឺ សេចក្តីដឹងខ្លួនក្នុងការដើរទៅមុខ ឬ ថយក្រោយ ធ្វើនូវសេចក្តីដឹងខ្លួនក្នុងការមើលទៅមុខ ឬ ប្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបត់ដៃជើង ឬ លាដៃជើង ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងការបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយៈ ជញ្ជប់ ( នូវភេសជ្ជៈមានសប្បិជាដើម ) ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលបន្ទោបង់ឧច្ចារៈបស្សាវៈ ធ្វើនូវសេចក្តីដឹងខ្លួន ក្នុងកាលដែលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយ ស្ងៀម ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្រៅ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយខាងក្នុង និងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ដែលប្រជុំកើតឡើងក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនបញ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យដោយ ( តណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះ ឯង ។

## អដ្ឋកថា

ព្រះមានព្រះភាគ កាលទ្រង់ចែកកាយនុបស្សនា ដោយឥរិយាបថ **៤** យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយសម្បជញ្ញៈ **៤** ទើបត្រាស់ថា សេចក្ដីដទៃនៅមានទៀត ។

ក្នុងសម្បជញ្ញបព្វៈនោះ ពាក្យថា **ឈានទៅមុខ** ជាដើម បានពណ៌នាទុកហើយក្នុង **សាមញ្ញផលសូត្រ** មានសេចក្ដីថា :

អធិប្បាយក្នុងព្រះបាលីថា **អភិក្កន្តេ បដិក្កន្តេ** ជាមុនសិន :

**ការទៅ** ហៅថា **អភិក្កន្ត** ការដើរទៅមុខ ។

**ការត្រឡប់** ហៅថា **បដិក្កន្ត** ការថយក្រោយ ។

ទាំង **២** យ៉ាងនេះ រមែងមានក្នុងឥរិយាបថទាំង **៤** ។

ក្នុងការដើរទៅមុខ កាលនាំកាយឆ្ពោះទៅមុខ ឈ្មោះថា **ដើរទៅមុខ** ពេលដែលត្រឡប់ក្រោយ ឈ្មោះថា **ថយក្រោយ** ។

សូម្បីក្នុងការឈរ អ្នកឈរនោះឯង ឱនកាយទៅមុខ ឈ្មោះថា **ឈានទៅមុខ** ពេលងើបឡើងវិញ ឈ្មោះថា **ថយក្រោយ** ។

សូម្បីក្នុងការអង្គុយ អ្នកដែលអង្គុយនោះ ឈ្ងោកទៅខាងមុខអាសនៈ ឈ្មោះថា **ឈានទៅមុខ** ពេលងើបមកវិញ ឈ្មោះថា **ថយក្រោយ** ។ សូម្បីក្នុងការដេក ក៏មានន័យដូច្នេះដែរ ។

បទថា **សម្បជានការី ហោតិ** មានន័យថា ធ្វើកិច្ចទាំងពួងដោយសម្បជញ្ញៈ ឬ មានសម្បជញ្ញៈនោះឯង ។ គឺថា ភិក្ខុនោះ រមែងមានសម្បជញ្ញៈក្នុងការឈានទៅជាដើម មិនបានប្រាសចាកសម្បជញ្ញៈក្នុងកាលណាមួយឡើយ។

សម្បជញ្ញៈក្នុងព្រះបាលី មាន ៤ យ៉ាង គឺ :

**១ - សាត្ថកសម្បជញ្ញៈ** **២ - សប្បាយសម្បជញ្ញៈ**

**៣ - គោចរសម្បជញ្ញៈ** **៤ - អសម្មោហសម្បជញ្ញៈ**

## សាត្ថកសម្បជញ្ញៈ

កាលចិត្តគិតនឹងទៅកើតឡើង តែមិនទាន់បានទៅ គ្រាន់តែគិតមុន ពិចារណាដល់ប្រយោជន៍ និង មិនមែនប្រយោជន៍ ថា ការទៅនោះ មាន ប្រយោជន៍ដល់យើង ឬ មិនមាន , ហើយប្រាថ្នានូវប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ** ។

ពាក្យថា **ប្រយោជន៍** ក្នុងបទថា សាត្ថកសម្បជញ្ញៈនោះ គឺ ការចម្រើន ដោយធម៌ កាលបានឃើញនូវព្រះចេតិយ បានឃើញព្រះស្រីមហាពោធិ៍ ឃើញ ព្រះសង្ឃ ឃើញព្រះថេរៈ និង ឃើញអសុភជាដើម ។ គឺថា ភិក្ខុនោះ ញុាំងបីតិ ដែលមានព្រះពុទ្ធជាអារម្មណ៍ឱ្យកើតឡើង សូម្បីការឃើញព្រះចេតិយ ឬ ការ ឃើញព្រះស្រីមហាពោធិ៍ ញុាំងបីតិដែលមានព្រះសង្ឃជាអារម្មណ៍ ឱ្យកើត ឡើង ព្រោះឃើញព្រះសង្ឃ ពិចារណាបីតិនោះឯងជារបស់អស់ទៅ សូន្យទៅ រមែងសម្រេចព្រះអរហត្ត ឃើញព្រះថេរៈទាំងឡាយ តាំងនៅក្នុងឱវាទរបស់ ព្រះថេរៈទាំងឡាយនោះ , ឃើញអសុភ ក៏ញុាំងឈានឱ្យកើតឡើងក្នុងអសុភ នោះ ពិចារណាអសុភនោះ ជារបស់អស់ទៅសូន្យទៅ រមែងសម្រេចព្រះ អរហត្ត ព្រោះហេតុនោះ ទើបទ្រង់ហៅថា ការឃើញវត្ថុនោះ **មានប្រយោជន៍**។

អាចារ្យពួកខ្លះពោលថា ការចម្រើនដោយអាមិសៈ ក៏មានប្រយោជន៍

ដូចគ្នា ព្រោះអាស្រ័យអាមិសៈនោះ បដិបត្តិដើម្បីអនុគ្រោះដល់ព្រហ្មចរិយធម៌ ។

## សប្បាយសម្បជញ្ញៈ

ចំណែកការទៅនោះ កាលពិចារណាដល់សប្បាយ និង អសប្បាយ ហើយគិតដល់នូវសប្បាយ ឈ្មោះថា **សប្បាយសម្បជញ្ញៈ** សេចក្តីនេះ យ៉ាងណា បើមនុស្សទាំងឡាយប្រជុំគ្នា ១០ យោជន៍ ១២ យោជន៍ ដើម្បីបូជាព្រះចេតិយ ទាំងស្រី ទាំងប្រុសប្រដាប់តាក់តែងកាយ សមគួរដល់សម្បត្តិរបស់ខ្លួន ដូចជារូបគំនូរ នាំគ្នាដើរទៅកាន់ទីនោះ លោភៈរមែងកើតឡើងដល់ភិក្ខុនោះ ព្រោះអារម្មណ៍ដែលគួរប្រាថ្នា បដិឃៈរមែងកើតឡើង ព្រោះអារម្មណ៍មិនជាទីប្រាថ្នា មោហៈរមែងកើតឡើង ព្រោះមិនពិចារណា រមែងត្រូវអាបត្តិព្រោះកាយសំសគ្គៈក៏មាន រមែងជាអន្តរាយដល់ជីវិត និងព្រហ្មចារ្យក៏មាន ។ តាមហេតុផលដូចពោលមកនេះ ទីនោះជាអសប្បាយ បើមិនមានអន្តរាយដូចដែលពោលហើយ នោះជាសប្បាយ ។ ក្នុងការឃើញព្រះស្រីមហាពោធិ៍ ក៏ដូចគ្នា។ សូម្បីការឃើញព្រះសង្ឃ ក៏មានប្រយោជន៍ បើមនុស្សទាំងឡាយសាងមណ្ឌបធំ នៅក្នុងស្រុក ពពួកជននាំគ្នាស្តាប់ព្រះធម៌ទាំងយប់ តែងមានទាំងប្រជុំជនទាំងអន្តរាយ ដូចដែលបានពោលហើយ ។ តាមហេតុផលមកនេះ នោះជាអសប្បាយ បើមិនមានអន្តរាយ នោះជាសប្បាយ ។

សូម្បីក្នុងការឃើញព្រះថេរៈ ដែលមានបរិវារច្រើន ក៏មានប្រយោជន៍ ការឃើញអសុភក៏មានប្រយោជន៍ ប៉ុន្តែអសុភស្រីជាអសប្បាយដល់បុរស អសុភប្រុសជាអសប្បាយដល់ស្ត្រី អសុភដែលជាសភាគៈគ្នាប៉ុណ្ណោះ ជាសប្បាយ ។

ការពិចារណានូវសប្បាយ យ៉ាងនេះឯង បានឈ្មោះថា **សប្បាយសម្បជញ្ញៈ** ។

## គោចរសម្បជញ្ញៈ

ការជ្រើសរើសអារម្មណ៍ ពោលគឺ កម្មដ្ឋាន ដែលខ្លួនពេញចិត្ត ក្នុងបណ្តាកម្មដ្ឋាន **៣៨** ហើយក៏កំណត់អារម្មណ៍នោះប៉ុណ្ណោះ ទៅក្នុងទីភិក្ខាចារនៃភិក្ខុដែលពិចារណាដល់ប្រយោជន៍ និងសប្បាយ យ៉ាងនេះ ឈ្មោះថា **គោចរ-សម្បជញ្ញៈ** ។

ដើម្បីជាការប្រាកដច្បាស់ក្នុងគោចរសម្បជញ្ញៈ បណ្ឌិត គប្បីជ្រាបក្នុងចតុក្កៈនេះ ដូចតទៅ :

***ភិក្ខុរូបខ្លះក្នុងសាសនានេះ នាំទៅតែមិននាំមក រូបខ្លះមិននាំទៅតែនាំមក រូបខ្លះមិននាំទៅ ទាំងមិននាំមក រូបខ្លះនាំទៅផង នាំមកផង ។***

ក្នុងបណ្តាភិក្ខុ ៤ ចំពូកនោះ ភិក្ខុណាជម្រះចិត្តចាកធម៌ ដែលជាគ្រឿងរារាំង ដោយការចង្រ្កម និង ដោយការអង្គុយក្នុងពេលថ្ងៃ ក្នុងបឋមយាម ក្នុងពេលជិតកណ្តាលយប់ ក៏បដិបត្តិយ៉ាងនោះ សឹងក្នុងមជ្ឈិមយាម ភ្ញាក់ក្នុងបច្ឆិមយាមញុំាងកាល ឱ្យកន្លងទៅ ដោយការអង្គុយ និងការចង្រ្កម ធ្វើវត្តនៅលានព្រះចេតិយ និងលានព្រះស្រីមហាពោធិ៍ ស្រោចទឹកនៅគល់ព្រះស្រីមហាពោធិ៍ តម្កល់ទឹកឆាន់ ទឹកប្រើប្រាស់ និង ប្រព្រឹត្តសមាទានខន្ធកវត្តគ្រប់យ៉ាងមានអាចរិយវត្ត និងឧបជ្ឈាយ៍វត្តជាដើម ភិក្ខុនោះធ្វើសរីរៈបរិកម្មហើយ ចូលទៅកាន់សេនាសនៈ ឱ្យរាងកាយបានទទួលភាពកក់ក្តៅ ហើយប្រកបរឿយៗនូវកម្មដ្ឋាន កាលដល់ពេលភិក្ខាចារ គ្រងចីវរ និង យកបាត្រ កំណត់កម្មដ្ឋានជា

គោល ហើយចេញចាកអាសនៈ ប្រកបចិត្តក្នុងកម្មដ្ឋានយ៉ាងនោះ ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចម្រើនពុទ្ធានុស្សតិកម្មដ្ឋាន គប្បីចម្រើននូវពុទ្ធា-នុស្សតិកម្មដ្ឋាននោះ ទៅរឿយ ៗ មិនលះកម្មដ្ឋាននោះ ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចម្រើនកម្មដ្ឋានដទៃ ផ្អាកកម្មដ្ឋាននោះចុះ , ដូចការដាក់ចុះនូវរបស់ដែលកាន់ ទុកត្រង់ជើងជណ្តើរ , កាន់យកបីតិ មានព្រះពុទ្ធជាអារម្មណ៍ ចូលទៅកាន់លានព្រះចេតិយ ប្រសិនបើចេតិយធំ ធ្វើប្រទក្សិណ ៣ ជុំ ហើយថ្វាយបង្គំក្នុងទិសទាំង ៤ ប្រសិនបើចេតិយតូច គប្បីធ្វើប្រទក្សិណយ៉ាងនោះ ហើយថ្វាយបង្គំក្នុងទិសទាំង ៨ កាលថ្វាយបង្គំព្រះចេតិយហើយចូលទៅកាន់លានព្រះស្រីមហាពោធិ៍ សម្តែងនូវសេចក្តីគោរព ថ្វាយបង្គំព្រះស្រីមហាពោធិ៍ ដូចនៅចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគ ដូច្នោះ ។ ភិក្ខុនោះថ្វាយបង្គំលានព្រះចេតិយ និងព្រះស្រីមហាពោធិ៍ យ៉ាងនេះហើយ កាន់យកកម្មដ្ឋាន ដែលខ្លួនបានដាក់ចុះនោះ ដូចបុគ្គលដែលបានរើសយកវត្ថុដែលបានដាក់ចុះ កាន់យកឡើងវិញដូច្នោះ កាលចូលទៅកាន់ស្រុក ឃ្លុំចីវរ កំណត់កម្មដ្ឋាននោះជាគោល ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។

គ្រានោះពួកមនុស្សទាំងឡាយ ឃើញភិក្ខុនោះ ក៏ចេញមកទទួលដោយសេចក្តីរីករាយថា លោកម្ចាស់របស់ពួកយើងមកដល់ហើយ ទទួលបាត្រ និមន្តឱ្យគង់ក្នុងរោងឆាន់ ថ្វាយយាគូ កាលភត្តមិនទាន់សម្រេច ក៏នាំគ្នាសួរបញ្ហាខ្លះ ស្តាប់ធម៌ខ្លះ ។

ព្រះអដ្ឋកថាចារ្យពោលថា សូម្បីគេមិនសូមឱ្យសម្តែងធម៌ ក៏គប្បីសម្តែងធម៌ ដើម្បីអនុគ្រោះប្រជាជន ។

ភិក្ខុនិងសាមណេរទាំងឡាយសួរថា លោកដ៏ចម្រើន មនុស្សទាំងនោះត្រូវអ្វីនឹងលោក ភិក្ខុអង្គនោះពោលថា លោកសួរព្រោះឃើញអ្វី ភិក្ខុនិងសាមណេរទាំងនោះពោលថា ឃើញពួកគេស្រឡាញ់លោកខ្លាំងណាស់ ។ ភិក្ខុនោះក៏សរសើរអ្នកស្រុកនោះថា អ្នកដ៏មានអាយុទាំងឡាយ កិច្ចណា ដែលមាតាបិតាធ្វើបានដោយលំបាក កិច្ចនោះពួកគេធ្វើដល់យើង សូម្បីចីវររបស់ពួកយើង ក៏ជារបស់គេ ពេលមានភ័យក៏ឱ្យយើងផុតភ័យ ពេលឃ្លានក៏ឱ្យឆ្អែត អ្នកដែលជាឧបការដល់យើងដូច្នេះ មិនមានទៀតឡើយ ។ នេះហៅថា **នាំទៅ មិននាំមក** ។

ចំណែកភិក្ខុធ្វើវត្តបដិបត្តិ ដូចដែលបានពោលហើយ ភ្លើងធាតុដែលរំលាយអាហារថ្មីអស់ហើយ ក៏ដុតសាច់ក្រពះ ញើសក៏ហូរជោកខ្លួន កម្មដ្ឋានមិនឡើងកាន់វិថី ភិក្ខុនោះគ្រងចីវរ កាន់បាត្រ ថ្វាយបង្គំព្រះចេតិយ យ៉ាងរហ័ស ចូលទៅកាន់ស្រុកដើម្បីយាគូ តាំងពីព្រលឹម ភិក្ខុទើបតែឆាន់យាគូបាន ២-៣ ម៉ាត់ តេជោធាតុកើតពីកម្ម ក៏ឈប់ដុតសាច់ក្រពះ បែរមកដុតអាហារថ្មី ភិក្ខុនោះ ក៏បានរំលត់នូវសេចក្តីស្រេកឃ្លាន ដូចស្រោចទឹក ១០០ ក្អម ក៏ឆាន់យាគូ ផ្តើមការកំណត់កម្មដ្ឋានជាគោល លាងបាត្រ និងខ្ពុរមាត់ហើយ ចម្រើនកម្មដ្ឋានរឿយៗទៅ ក្នុងចន្លោះពេលដែលមិនទាន់បានឆាន់ភត្តាហារ និមន្តទៅបិណ្ឌបាតក្នុងកន្លែងដែលមិនទាន់បានទៅ ឆាន់អាហារដោយការកំណត់កម្មដ្ឋាននោះជាគោល បន្ទាប់ពីនោះមក ក៏បានកាន់យកកម្មដ្ឋានដែលបានកំណត់ហើយនោះ និមន្តមកវិញ ។ នេះហៅថា **មិននាំទៅ តែនាំមក** ។

ភិក្ខុទាំងឡាយឆាន់យាគូហើយ ផ្តើមចម្រើនវិបស្សនា បានសម្រេចព្រះអរហត្ត ក្នុងព្រះពុទ្ធសាសនានេះរាប់មិនអស់ , នៅកោះសីហឡទ្វីប ក្នុងរោង

ឆាន់របស់អ្នកស្រុកនោះៗ មិនមានអាសនៈណាមួយ ដែលភិក្ខុឆាន់យាគូហើយ មិនបានសម្រេចអរហត្តឡើយ ។

ចំណែកភិក្ខុមានសេចក្តីប្រមាទ លះបង់នូវធុរៈ ទម្លាយវត្តដែលគប្បីធ្វើ មានចិត្តក្រាស់ដោយចេតោខីលធម៌ **៥** យ៉ាង ( ធម៌ឱ្យវិនាស គឺ សេចក្តីសង្ស័យ **១**-ក្នុងព្រះពុទ្ធ **២**-ក្នុងព្រះធម៌ **៣**-ក្នុងព្រះសង្ឃ **៤**-ក្នុងសិក្ខា **៥**-សេចក្តីក្រោធក្នុងសព្រហ្មចារី ) មិនខ្វល់ក្នុងកម្មដ្ឋាន ចូលទៅកាន់ស្រុកបិណ្ឌបាត ដើរស្និទ្ធស្នាលទៅជាមួយគ្រហស្ថ បរិភោគរួមជាមួយគ្រហស្ថ ដែលមិនសមគួរជាអ្នកចេញទៅទទេ នេះហៅថា **មិននាំទៅ ទាំងមិននាំមក** ។

ចំណែកភិក្ខុ ដែលបានពោលហើយ **នាំទៅផង ទាំងនាំមកផង** គឺ ទៅក៏ចម្រើនកម្មដ្ឋាន ពេលត្រឡប់មក ក៏ចម្រើនកម្មដ្ឋាន ។

ពិតហើយ កុលបុត្តទាំងឡាយ ដែលប្រាថ្នាប្រយោជន៍ បួសក្នុងព្រះសាសនានេះហើយ ១០រូបខ្លះ ២០រូបខ្លះ ... ១០០រូបខ្លះ ក៏ធ្វើកត្តិកាគ្នាថា អាវុសោទាំងឡាយយើងបួស មិនមែនព្រោះគេចម្ចាស់បំណុល មិនមែនបួសព្រោះគេចភ័យ មិនមែនបួសដើម្បីអាជីព តែដើម្បីផុតទុក្ខ ទើបបួសក្នុងព្រះសាសនានេះ ។ ព្រោះដូច្នោះ បើកិលេសកើតឡើងក្នុងខណៈដើរ ចូរគ្របសង្កត់ក្នុងខណៈដើរ បើកិលេសកើតឡើងក្នុងខណៈឈរ ចូរគ្របសង្កត់ក្នុងខណៈឈរ បើកិលេសកើតឡើងក្នុងខណៈអង្គុយ ចូរគ្របសង្កត់ក្នុងខណៈអង្គុយ បើកិលេសកើតឡើងក្នុងខណៈដេក ចូរគ្របសង្កត់ក្នុងខណៈដេកចុះ ។ ភិក្ខុទាំងឡាយនោះ កាលព្រមព្រៀងគ្នាយ៉ាងនេះហើយ ពេលចូលស្រុកដើម្បីភិក្ខាចារ ក៏មនសិការកម្មដ្ឋានរឿយ ៗ ទៅ ។ ភិក្ខុនោះ មិនឈានជើងដោយ

ចិត្តប្រាសចាកកម្មដ្ឋានឡើយ សូម្បីឈានទៅមុខ ឬ ឈានថយក្រោយ ។ ចម្រើនវិបស្សនា ចុះកាន់អរិយភូមិ បើមិនអាចយ៉ាងនោះ ក៏គ្របសង្កត់កិលេសនោះទៅ នេះឈ្មោះថា **ទាំងនាំទៅ និងនាំមក** ។

ក្នុងការបដិបត្តិ ៤ យ៉ាងនេះ ភិក្ខុណា **នាំទៅ និង ទាំងនាំមក** គោចរសម្បជញ្ញៈរបស់ភិក្ខុនោះ រមែងដល់នូវកំពូលនៃការបដិបត្តិ នេះហៅថា **គោចរសម្បជញ្ញៈ** ។

## អសម្មោហសម្បជញ្ញៈ

ការមិនវង្វេងក្នុងការឈានទៅជាដើម ឈ្មោះថា **អសម្មោហសម្បជញ្ញៈ** អសម្មោហសម្បជញ្ញៈនោះ គប្បីជ្រាបដូច្នេះ :

បុថុជ្ជនជាអន្ធពាល កាលដើរទៅជាដើម ក៏វង្វេងគិតថា ខ្លួនដើរទៅ ការដើរទៅនោះ ខ្លួនធ្វើឱ្យកើតឡើង អញដើរទៅ ការដើរទៅនោះ អញធ្វើឱ្យកើតឡើង យ៉ាងណា ភិក្ខុក្នុងព្រះសាសនានេះ មិនវង្វេងដូច្នោះទេ កាលចិត្តគិតថា អញនឹងដើរទៅ វាយោធាតុក៏កើតពីចិត្ត ញ៉ាំងវិញ្ញត្តិឱ្យកើតឡើង រមែងកើតឡើងដោយចិត្តនោះឯង ដូច្នោះរាងឆ្អឹងដែលសន្មតថា កាយនេះ រមែងឈានទៅ ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត យ៉ាងនេះឯង ។ កាលរាងឆ្អឹងនោះ ឈានទៅយ៉ាងនេះ កាលលើកជើងតែម្ខាងឡើង ធាតុ ២ គឺ បឋវីធាតុ អាបោធាតុ មានកម្លាំងខ្សោយចុះ , ធាតុ ២ ទៀត វាយោធាតុ តេជោធាតុ មានកម្លាំងខ្លាំងឡើង ។ ក្នុងខណៈដែលដាក់ជើងចុះ ធាតុ ២ គឺ **វាយោធាតុ តេជោធាតុ** មានកម្លាំងខ្សោយចុះ ធាតុ

**២** ក្រៅពីនេះ មានកម្លាំងខ្លាំងឡើង ។

***រូបធម៌*** និង ***អរូបធម៌*** ក្នុងខណៈដែលលើកជើងឡើង មិននៅដល់ខណៈដែលបោះជើងទៅមុខទេ ***រូបធម៌*** និង**នាមធម៌** ក្នុងខណៈបោះជើងទៅនោះ មិននៅដល់ខណៈដែលដាក់ជើងចុះ នោះដូចគ្នា ដែលប្រព្រឹត្តទៅក្នុងខណៈឈានទៅមុខ ក៏មិននៅដល់ខណៈដាក់ជើងចុះ ក្នុងខណៈដែលដាក់ជើងចុះ ក៏មិននៅដល់ខណៈដែលជាន់លើផែនដី ក៏មិននៅដល់ខណៈដែលជាន់ស៊ប់ពេញបាតជើង ***រូបធម៌*** និង **នាមធម៌** រមែងរលត់ទៅជារយៈៗ ជាខណៈៗ ក្នុងឥរិយាបថនោះឯង ។

ក្នុងការដើរទៅមុខជាដើមនោះ នរណាមួយឈានទៅ ឬ ការឈានទៅរបស់អ្នកណា ដោយបរមត្ថ ធាតុទាំងឡាយនោះប៉ុណ្ណោះដើរ ធាតុទាំង-ឡាយនោះប៉ុណ្ណោះឈរ ធាតុទាំងឡាយនោះប៉ុណ្ណោះអង្គុយ ធាតុទាំងឡាយប៉ុណ្ណោះដេក ក្នុងចំណែកនៃឥរិយាបថនោះ ៗ ចិត្តដួងដទៃកើតឡើង ចិត្តដួងដទៃរលត់ទៅ ព្រមជាមួយនឹងរូប ប្រព្រឹត្តទៅដូចជាក្រសែទឹកហូរដែលមិនដាច់ដូច្នោះ ការមិនវង្វេងក្នុងការដើរទៅយ៉ាងនេះ ឈ្មោះថា **អសម្មោហសម្ប-ជញ្ញៈ** ។

| | | | |
|---|---|---|---|
| ការមើលទៅមុខ | ឈ្មោះថា | **អាលោកិត** | ។ |
| ការមើលទៅទិសឆៀង | ឈ្មោះថា | **វិលោកិត** | ។ |

ក្នុងការមើលទាំង **២** នេះ កាលចិត្តគិតថា យើងនឹងមើលទៅមុខដោយអំណាចការសម្លឹងមើល ដើម្បីប្រយោជន៍ ឈ្មោះថា **សាត្ថកសម្បជញ្ញៈ**។ ដូច្នេះគប្បីជ្រាបថា ការមើលទៅតាមទិសជា **សាត្ថកសម្បជញ្ញៈ** និង **សប្បាយ-**

**សម្បជញ្ញៈ** ដោយការមើលព្រះចេតិយជាដើម ដូចដែលបានពោលហើយ ។

ចំណែក **គោចរសម្បជញ្ញៈ** គឺ ការមិនលះបង់កម្មដ្ឋាននោះឯង ដូច្នោះ ការមើលទៅមុខ និងការមើលទៅតាមទិស , ក្នុងព្រះបាលី ភិក្ខុដែលចម្រើនវិបស្សនាកម្មដ្ឋាន ក៏កំណត់ **ខន្ធ ធាតុ អាយតនៈ** ជាអារម្មណ៍ ចំណែកភិក្ខុដែលចម្រើនសមថកម្មដ្ឋាន កំណត់កសិណជាដើម ជាអារម្មណ៍ គប្បីធ្វើការកំណត់កម្មដ្ឋានជាគោលចុះ ។ ឈ្មោះថាខ្លួននៅក្នុងរូបកាយ ជាអ្នកមើលទៅមុខ និងមើលទៅទិសផ្សេង មិនមាន ។ កាលកើតការគិតថា យើងនឹងមើលទៅមុខ វាយោធាតុដែលមានចិត្តជាសមុដ្ឋាន ព្រមដោយចិត្តដូងនោះ ក៏ញុំាងវិញ្ញត្តិឱ្យកើត ធ្វើឱ្យបើកត្របកភ្នែកឡើង ដោយអំណាចការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត យ៉ាងនេះឯង ។ នឹងមាននរណាទៅដែលជាអ្នកមើលទៅមុខនោះ ។ ការពិត ចក្ខុវិញ្ញាណ ញុំាងទស្សនកិច្ច ឱ្យសម្រេច កើតឡើងប៉ុណ្ណោះ ។ ការដឹងច្បាស់យ៉ាងនេះ ឈ្មោះថា **អសម្មោហ-សម្បជញ្ញៈ** ក្នុងព្រះបាលីនេះ ។

រីឯ វិថីចិត្តក្នុងការសម្រេចកិច្ច នៃការដឹងអារម្មណ៍ មានដូច្នេះ :

**១ - ភវង្គចិត្ត** ញុំាងភវង្គកិច្ច ជាអង្គនៃឧប្បត្តិភព ឱ្យសម្រេចកើតឡើង ។

**២ - កិរិយាមនោធាតុ** រំពឹងដល់អារម្មណ៍បន្ទាប់ពីភវង្គចិត្តនោះ ញុំាងអាវជ្ជនកិច្ចឱ្យកើតឡើងហើយ ។

**៣ - ចក្ខុវិញ្ញាណ** ញុំាងទស្សនកិច្ចឱ្យសម្រេច បន្ទាប់ពីកិរិយាមនោធាតុនោះរលត់ទៅ ។

**៤ - វិបាកមនោធាតុ** ញុំាំងសម្បដិច្ឆន្នកិច្ច ( កិច្ចទទួលអារម្មណ៍ ) ឱ្យសម្រេចបន្ទាប់ពីចក្ខុវិញ្ញាណរលត់ទៅ ។

**៥ - វិបាកមនោវិញ្ញាណធាតុ** ញុំាំងសន្តីរណកិច្ច ( កិច្ច គឺ ការពិចារណាអារម្មណ៍ ) ឱ្យសម្រេចកើតឡើង បន្ទាប់ពីវិបាកមនោធាតុរលត់ទៅ ។

**៦ - កិរិយាមនោវិញ្ញាណធាតុ** ញុំាំងវោដ្ឋវនកិច្ច( កិច្ច គឺការកំណត់អារម្មណ៍ក្នុងបញ្ចទ្វារ ) ឱ្យសម្រេចកើតឡើង បន្ទាប់ពីវិបាកមនោវិញ្ញាណធាតុរលត់ទៅ ។

**៧ - ជវនចិត្ត** រមែងស្ទុះទៅ **៧** ខណៈបន្ទាប់ពីកិរិយាមនោ-វិញ្ញាណធាតុរលត់ទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចក្ខុទ្វារដូច្នេះ កាលរូបារម្មណ៍មកប្រាកដ កាត់ភវង្គចិត្តហើយ វិថីចិត្តមានអាវជ្ជនចិត្តជាដើមកើតឡើងហើយរលត់ទៅ ដោយអំណាចការធ្វើកិច្ចរបស់ខ្លួនឱ្យសម្រេច ក្នុងទីបំផុត ជវនចិត្ត រមែងកើតឡើង ជវនចិត្តនោះ ដូចជាបុរសដែលចូលមកក្នុងចក្ខុទ្វារ ។

ចិត្តទាំងឡាយ មានវោដ្ឋវនចិត្តជាទីបំផុតនេះ រមែងកើតឡើងក្នុងចក្ខុទ្វារ ចិត្តទាំងនោះ រមែងរលត់ទៅក្នុងទីនោះឯង ព្រមជាមួយនឹងសម្បយុត្តធម៌ រមែងមិនឃើញនូវគ្នានិងគ្នាឡើយ ។

ម្យ៉ាងទៀត អសម្មោហសម្បជញ្ញៈនេះ គប្បីជ្រាបដោយការពិចារណានូវ ខន្ធ អាយតនៈ ធាតុ និង បច្ច័យ , ក្នុងអធិការនេះ ចក្ខុនិងរូបជារូបក្ខន្ធ ទស្សនៈជាវិញ្ញាណក្ខន្ធ វេទនាដែលសម្បយុត្តជាមួយនឹងវិញ្ញាណ ជាវេទនាខន្ធ

សញ្ញាជាសញ្ញាខន្ធ សម្បយុត្តធម៌ មានផស្សៈជាដើម ជាសង្ខារក្ខន្ធ ។ ការមើលទៅមុខ និងការមើលទៅកាន់ទិសផ្សេង រមែងប្រាកដ ព្រោះខន្ធទាំង ៥ នេះ ប្រជុំរួមគ្នាប៉ុណ្ណោះ ក្នុងការមើលទាំងនោះ មាននរណាមួយមើលទៅមុខ មាននរណាមួយមើលទៅ កាន់ទិសផ្សេង ៗ នោះ ។ ចក្ខុជាចក្ខាយតនៈ រូបជារូបាយតនៈ ទស្សនៈជាមនាយតនៈ សម្បយុត្តធម៌ទាំងឡាយ មានវេទនាជាដើម ជាធម្មាយតនៈ ការមើលទៅមុខ និងការមើលទៅកាន់ទិសផ្សេង រមែងសម្រេចបាន ព្រោះអាយតនៈទាំង ៤ នេះ ប្រជុំគ្នាប៉ុណ្ណោះ មិនមាននរណាមួយមើលទៅមុខ មិនមាននរណាមួយមើលទៅកាន់ទិសផ្សេងឡើយ ។ ចក្ខុជាចក្ខុធាតុ រូបជារូបធាតុ ទស្សនៈជាចក្ខុវិញ្ញាណធាតុ ធម៌ទាំងឡាយ មានវេទនាជាដើម ដែលសម្បយុត្តជាមួយនឹងចក្ខុវិញ្ញាណធាតុនោះ ជាធម្មធាតុ , ការមើលទៅមុខ ការមើលទៅតាមទិស រមែងប្រាកដព្រោះធាតុ ៤ នេះ ប្រជុំគ្នាប៉ុណ្ណោះ មិនមាននរណាមួយ មើលទៅមុខ មិនមាននរណាមួយមើលទៅតាមទិសផ្សេងឡើយ ។ ចក្ខុជានិស្សយបច្ច័យ រូបជាអារម្មណបច្ច័យ អាវជ្ជនចិត្តជាអនន្តរបច្ច័យ សមនន្តរបច្ច័យ ឧបនិស្សយបច្ច័យ នត្ថិបច្ច័យ វិគតបច្ច័យ អាលោកៈជាឧបនិស្សយបច្ច័យ វេទនាជាដើមជាសហជាតបច្ច័យ ការមើលទៅមុខ ការមើលទៅតាមទិសរមែងប្រាកដ ព្រោះបច្ច័យទាំងនេះ ប្រជុំគ្នាប៉ុណ្ណោះ មិនមាននរណាមើលទៅមុខ មិនមាននរណាមើលទៅតាមទិសផ្សេងឡើយ ។

មិនមាននរណា ៗ ដែលថា ជាខ្លួនក្នុងខាងក្នុង ជាអ្នកលាតដៃចេញ បត់ដៃចូលនោះទេ មានតែការបត់ចូល និងលាតចេញ ព្រោះការផ្សាយទៅនៃ

វាយោធាតុដែលកើតពីកិរិយារបស់ចិត្ត ដូចនឹងមនុស្សយន្តដែលកម្រើកដៃជើងបាន ព្រោះការទាញខ្សែប៉ុណ្ណោះ ការកំណត់ដឹងយ៉ាងនេះ នេះជា **អសម្មោហ-សម្បជញ្ញៈ** ។

មិនមាននរណា១ ដែលថា ជាខ្លួនក្នុងខាងក្នុង ជាអ្នកគ្រងចីវរនោះឡើយ មានតែការគ្រងចីវរដែលជាការផ្សាយទៅនៃវាយោធាតុ កើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ ។ ក្នុងចីវរ និងកាយនោះ ចីវរក៏មិនមានចេតនា កាយក៏មិនមានចេតនា ចីវរក៏មិនដឹងថាអញគ្របកាយ កាយក៏មិនដឹងថា អញត្រូវចីវរគ្រប ព្រោះដូច្នោះ ភិក្ខុបានចីវរល្អក៏មិនគួររីករាយ បានចីវរមិនល្អក៏មិនគួរអន់ចិត្ត ដូចដំបូក ចេតិយ ដើមឈើ ដែលគេបូជា បុគ្គលខ្លះបូជាដោយផ្កាឈើធូបក្រអូប សំពត់ជាដើម បុគ្គលខ្លះមិនបូជាទេ ក៏បន្ទោបង់មូត្រលាមកជាដើម ខ្លះប្រហារដោយដុំដី ឬ សស្ត្រាជាដើម តែដំបូក ដើមឈើជាដើម រមែងមិនរីករាយ ឬ ទាស់ចិត្តក្នុងការបូជា និងមិនបូជានេះឡើយ ។

គប្បីជ្រាបការប្រើប្រាស សង្ឃាដី ចីវរ ដោយ អសម្មោហសម្បជញ្ញៈដោយការពិចារណា ដូច្នេះចុះ ។

ក្នុងការកាន់បាត្រនោះ បាត្រក៏មិនមានចេតនា ដៃក៏មិនមានចេតនា ។ បាត្រមិនដឹងថា អញត្រូវដៃកាន់ ដៃក៏មិនដឹងថាអញកាន់បាត្រ ធាតុទាំងឡាយប៉ុណ្ណោះកាន់ពួកធាតុ ។

មិនមាននរណាមួយ ដែលឈ្មោះថា ខ្លួនក្នុងខាងក្នុងជា អ្នកបរិភោគឡើយ , ការកាន់បាត្ររមែងមាន ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ដូចដែលពោលហើយ , ការលូកដៃចុះក្នុងបាត្រ រមែងមាន

ដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ការពូតដុំបាយ ការលើកដុំបាយឡើង និង ការបើកមាត់ រមែងមានដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្តប៉ុណ្ណោះ មិនមាននរណាជាអ្នកបញ្ឆាគ្រោងឆ្អឹងនេះឡើយ ។ ការយកដុំបាយដាក់ចូលក្នុងមាត់ ធ្មេញលើធ្វើនាទីដូចអង្រែ ធ្មេញក្រោមធ្វើនាទីដូចត្បាល់ អណ្ដាតធ្វើនាទីដូចដៃ រមែងមានដោយការផ្សាយទៅនៃវាយោធាតុ ដែលកើតពីកិរិយារបស់ចិត្ត ការបរិភោគនោះមានទឹកមាត់ចេញពីចុងអណ្ដាតខ្លះ មានទឹកមាត់ចេញពីគល់អណ្ដាតខ្លះ លាយច្របល់គ្នា របស់ដែលទំពានោះ ត្រូវត្រឡប់ចុះឡើងដោយដៃ គឺ អណ្ដាត ចុះក្នុងត្បាល់ គឺ ធ្មេញក្រោម មានទឹកមាត់ធ្វើឱ្យសើម បុកឱ្យខ្ទេចដោយអង្រែ គឺ ធ្មេញលើ , មិនមាននរណាមកដួសដាក់ចូលទៅខាងក្នុងពោះ ដោយស្លាបព្រា ឬ សម្ភារៈអ្វីមួយឡើយ ចូលទៅដោយវាយោធាតុប៉ុណ្ណោះ ។ អាហារដែលចូលទៅតាមបំពង់កនោះ មិនមាននរណាយកវត្ថុអ្វីមួយ មកចាំត្រងឡើយ រមែងតាំងនៅដោយអំណាចនៃវាយោធាតុប៉ុណ្ណោះ អាហារដែលតាំងនៅនោះ មិនមាននរណាដុតភ្លើងចំហុយឱ្យរលួយឡើយ រមែងរលួយដោយតេជោធាតុនោះឯង អាហារដែលរលួយហើយ មិនមាននរណាប្រើកំណាត់ឈើ ឬ មែកឈើកៀរចេញក្រៅឡើយ វាយោធាតុនោះឯងនាំចេញ ( បន្ទោបង់លាមក ) ។

ដោយប្រការដូច្នេះ វាយោធាតុរមែងនាំអាហារចូល ផ្លាស់ប្ដូរ ទ្រទ្រង់ ត្រឡប់ចុះឡើង ធ្វើឱ្យល្អិត ធ្វើឱ្យស្ងួតដើម្បីនាំចេញ , បឋវីធាតុទ្រទ្រង់ទុក ត្រឡប់ចុះឡើង ធ្វើឱ្យល្អិត និងធ្វើឱ្យស្ងួត , អាបោធាតុធ្វើឱ្យស្អិត តាមរក្សានូវសំណើម , តេជោធាតុធ្វើអាហារដែលចូលទៅនោះឱ្យរលួយ អាកាសធាតុចែក

ឱ្យជាដុំៗ , វិញ្ញាណធាតុចាត់ចែងឱ្យធាតុផ្សេងៗ ធ្វើនាទីឱ្យត្រូវក្នុងរឿងនោះ ៗ គប្បីជ្រាបអសម្មោហសម្បជញ្ញៈ ដោយការបរិភោគយ៉ាងនេះចុះ ។

បទថា **ឧច្ចារបស្សាវកម្មេ** បានដល់ ការបន្ទោបង់ឧច្ចារបស្សាវៈ ។ មិនមានខ្លួនជាខាងក្នុង ក្នុងការបន្ទោបង់នូវឧច្ចារបស្សាវៈនោះទេ មានត្រឹមតែការបន្ទោបង់ឧច្ចារបស្សាវៈ ដោយការផ្សាយទៅនៃវាយោធាតុប៉ុណ្ណោះ ។ ឬថា បូសបែកធ្លាយនៅពេលដែលបូសនោះវាទុំ ខ្ទុះនិងឈាមក៏ហូរចេញ ដោយមិនមាននរណាត្រូវការ យ៉ាងណា ភាជនៈដែលពេញដោយទឹក ក៏រមែងហូរចេញដោយគេមិនត្រូវការ យ៉ាងណា ឧច្ចារបស្សាវៈដែលសន្សំទុកនៅក្នុងពោះវៀនធំ និង តម្រងបស្សាវៈ ត្រូវកម្លាំងខ្យល់សង្កត់ហើយ ក៏រមែងហូរចេញដោយគ្មានអ្នកត្រូវការ ក៏យ៉ាងនោះដែរ ។ ឧច្ចារបស្សាវៈនេះ កាលបើហូរចេញមកក្រៅយ៉ាងនេះ រមែងមិនជារបស់ខ្លួន ហើយក៏មិនជារបស់អ្នកដទៃដែរ គ្រាន់តែជាអាហារដែលហូរចេញចាករាងកាយប៉ុណ្ណោះ ។

សូម្បី ការដើរ ការឈរ ការអង្គុយ ការដេក ការភ្ញាក់ ការនិយាយ ការនៅស្ងៀមនោះ ក៏គប្បីមានការដឹងខ្លួនដោយ អសម្មោហសម្បជញ្ញៈចុះ ។

ព្រះមហាសិវត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា ភិក្ខុណាដើរ ឬចង្ក្រម ក្រោយមកឈរស្ងៀម កាលពិចារណាឃើញថា រូបធម៌ និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងវេលាចង្ក្រម រលត់ទៅក្នុងខណៈដែលឈរស្ងៀមនោះឯង ភិក្ខុនេះ ឈ្មោះថា ជាអ្នកធ្វើនូវសេចក្ដីដឹងខ្លួនក្នុងការដើរ ។

ភិក្ខុណាសូត្រធម៌ក្ដី វិសជ្ជនាបញ្ហាក្ដី មនសិការកម្មដ្ឋានក្ដី ឈរក្ដី ក្រោយមកអង្គុយចុះ ក៏ពិចារណាឃើញថា រូបធម៌ និង អរូបធម៌ ដែលប្រព្រឹត្ត

ទៅក្នុងពេលឈរ រលត់ទៅក្នុងខណៈអង្គុយនោះឯង ភិក្ខុនេះឈ្មោះថា ជាអ្នកធ្វើនូវសេចក្ដីដឹងខ្លួនក្នុងខណៈឈរ ។

ភិក្ខុណាអង្គុយយូរ ធ្វើការស្វាធ្យាយធម៌ជាដើម ក្រោយមកក្រោកឡើង ក៏ពិចារណាឃើញថា រូបធម៌ និងអរូបធម៌ក្នុងពេលអង្គុយនោះ រលត់ទៅក្នុងខណៈក្រោកឡើងនេះឯង នេះឈ្មោះថា ភិក្ខុធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងខណៈអង្គុយ ។

ភិក្ខុណាដេកសូត្រធម៌ក្ដី មនសិការកម្មដ្ឋានក្ដី ក៏លក់ទៅ ពេលភ្ញាក់ឡើង ក៏ពិចារណាឃើញថា រូបធម៌ និងអរូបធម៌ ក្នុងពេលដេករលត់ទៅក្នុងខណៈដែលភ្ញាក់ឡើងនោះឯង ភិក្ខុនេះ ឈ្មោះថា ជាអ្នកធ្វើនូវការដឹងខ្លួនក្នុងពេលដេក និងពេលភ្ញាក់ឡើង ។ ចិត្តដែលមិនធ្វើការងារ ឈ្មោះថា **លក់** ដែលធ្វើការងារ ឈ្មោះថា **ភ្ញាក់** ។

ភិក្ខុកាលកំពុងនិយាយ មានសតិសម្បជញ្ញៈថា សំឡេងនេះកើតឡើងព្រោះអាស្រ័យនូវ បបូរមាត់ អណ្ដាត ធ្មេញ ក្រអូមមាត់ និងសេចក្ដីព្យាយាមរបស់ចិត្ត ដែលសមគួរដល់រឿងនោះ ៗ ទើបនិយាយ ឬថា ទន្ទេញធម៌ក៏ដោយ សម្ដែងធម៌ក៏ដោយ ចម្រើនកម្មដ្ឋានក៏ដោយ វិសជ្ជនាបញ្ហាក៏ដោយ យ៉ាងយូរ ក្រោយមកនៅស្ងៀម ក៏ពិចារណាឃើញថា រូបធម៌ និងអរូបធម៌ ក្នុងពេលនិយាយ រលត់ទៅក្នុងពេលនៅស្ងៀមនេះ ភិក្ខុនេះ ឈ្មោះថា ធ្វើនូវការដឹងខ្លួនក្នុងការនិយាយ ។

ភិក្ខុណានៅស្ងៀម ហើយធ្វើនូវការមនសិការព្រះធម៌ ឬ កម្មដ្ឋានយ៉ាងយូរ ក្រោយមកពិចារណាឃើញដូច្នេះថា រូបធម៌ និង អរូបធម៌ ដែល

ប្រព្រឹត្តទៅក្នុងកាលនៅស្ងៀម រលត់ទៅក្នុងពេលនៅស្ងៀមនេះឯង ព្រោះថា ពេលឧបាទាយរូបកើត ទើបឈ្មោះថា **និយាយ** , ពេលមិនកើត ឈ្មោះថា **ស្ងៀម** ភិក្ខុនេះ ឈ្មោះថា ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងការនៅស្ងៀម ដូច្នេះឯង ។

បណ្ឌិត គប្បីជ្រាបអំពីការធ្វើនូវសេចក្ដីដឹងខ្លួន ដោយអំណាចសម្ប-ជញ្ញៈ **៤** ដោយប្រការដូច្នេះចុះ ។

( ចប់ សម្បជញ្ញបព្វៈ )

# ៤ - បដិក្កូលមនសិការបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេង ៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ថៃដែលមានមាត់ទាំង ២ ខាង ពេញដោយធញ្ញជាត មានប្រការផ្សេង ៗ ធញ្ញជាតទាំងនោះ គឺ ស្រូវខ្សាយ-ស ស្រូវខ្សាយក្រហម សណ្ដែកបាយ សណ្ដែករាជមាស ល្ង អង្ករ បុរសដែលមានចក្ខុ គប្បីស្រាយនូវថៃនោះ ហើយពនិត្យមើលដូច្នេះថា នេះស្រូវខ្សាយ-ស នេះស្រូវខ្សាយក្រហម នេះសណ្ដែកបាយ នេះសណ្ដែករាជមាស នេះល្ង នេះ អង្ករ មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើ តាំងអំពីបាតជើងឡើងទៅ ខាងក្រោម តាំងអំពីចុងសក់ចុះមក ដែលមានស្បែក បិទបាំងជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេង ៗ ដូច្នេះថា ក្នុងកាយនេះ មានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ មានឧបមេយ្យដូច្នេះ

ឯង ។ ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការកើតឡើងនៃកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការរលត់សូន្យទៅនៃកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ ទាំងការកើត ទាំងការរលត់នៃកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ (ដោយតណ្ហា-ទិដ្ឋិ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អាការ ៣២

## ជាកាយគតាសតិកម្មដ្ឋាន

ក្នុងបបញ្ចសូទនី អដ្ឋកថា កាយគតាសិសូត្រ :

ម្នាលភិក្ខុទាំងឡាយ **កាយគតាសតិ** ដែលភិក្ខុចម្រើនហើយ ធ្វើឱ្យច្រើនហើយ តែងមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញកាយនេះឯង ខាងក្រោម តាំងពីបាតជើងឡើងទៅ ខាងលើតាំងពីចុងសក់ចុះមក មានស្បែកព័ទ្ធជុំវិញ ពេញដោយរបស់មិនស្អាត ដែល

មាននៅក្នុងកាយនេះ មាន សក់ រោម..... ជាដើម ។

## អដ្ឋកថា

បទថា **កាយគតាសតិ** បានដល់ សតិសម្លឹងកាយខ្លះ មានកាយជាអារម្មណ៍ខ្លះ ។ កាលពោលថា **សម្លឹងកាយ** គឺ ពោលដល់សមថៈ ។ កាលពោលថា **មានកាយជាអារម្មណ៍** គឺ ពោលដល់វិបស្សនា , ទីនេះជាការពោលដល់សមថៈ និង វិបស្សនា ដោយបទទាំង **២** ។

កាយដែលប្រកបដោយមហាភូតរូប **៤** គប្បីជ្រាបថា ដូចជាថៃដែលមានមាត់ទាំង **២** ខាង , អាការ **៣២** មានសក់ជាដើម ប្រៀបដូចធញ្ញជាតផ្សេង ៗ ដែលគេដាក់លាយគ្នានៅក្នុងថៃនោះ ព្រះយោគាវចរប្រៀបដូចបុរសមានចក្ខុ អាការប្រាកដច្បាស់នៃអាការ **៣២** របស់ព្រះយោគាវចរ ប្រៀបដូចអាការដែលធញ្ញជាតផ្សេង ៗ ប្រាកដដល់បុរសអ្នកស្រាយថៃនោះចេញ ហើយពិចារណាមើល ។

ពាក្យថា **ខាងក្នុងក្តី** មានន័យថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ឬ ក្នុងកាយរបស់អ្នកដទៃ ឬ ក្នុងកាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់អាការ **៣២** មានសក់ជាដើមយ៉ាងនេះឯង ។

វិសុទ្ធិមគ្គ : អាការ **៣២** ទ្រង់ត្រាស់ជា **វត្ថុបដិកូល** ជាសមថៈ , ត្រាស់ជា **ធាតុ** ជាវិបស្សនា ( កាយគតាសតិ )។

( ចប់ បដិកូលមនសិការបព្វៈ )

## ៤-ធាតុមនសិការបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះផង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅយ៉ាងណា ដោយកំណត់ថា គ្រាន់តែជាធាតុថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ គប្បីពិឃាតគោហើយ ពន្លះជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំ បែកជា ៤ មាន ឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះផង ដែលឋិតនៅយ៉ាងណា ដែលតាំងនៅ យ៉ាងណា ដោយការកំណត់ថា គ្រាន់តែជាធាតុ ដូច្នេះថា ក្នុងកាយនេះ មានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ មានឧបមេយ្យដូច្នោះឯង ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុង ( ដោយការកំណត់ថា ជាធាតុ ) ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

### អដ្ឋកថា

ក្នុងធាតុមនសិការបព្វៈនោះ ការពណ៌នានូវអត្ថ ព្រមទាំងសេចក្តីឧបមាមានដូចតទៅនេះ :

បុគ្គលអ្នកសម្លាប់គោពួកខ្លះ ឬ កូនសិស្សនៃអ្នកសម្លាប់គោ កាលគេនៅចិញ្ចឹមគោដើម្បីអាហារក្តី សម្លាប់គោហើយ ក៏ពន្លះសាច់ចេញជាចំណែក១ ហើយយកទៅអង្គុយលក់នៅផ្លូវបែកជា ៤ គឺ ជាផ្លូវដែលខ្វែងគ្នា បែកទៅក្នុងទិសទាំង ៤ យ៉ាងណា ភិក្ខុ ( ជាអ្នកបំពេញធាតុកម្មដ្ឋាន ) ក៏ដូច្នោះដែរ រមែង

ពិចារណាកាយ សូម្បីតាំងនៅដោយអាការណា គឺ ឋិតនៅដោយអាការយ៉ាងណាមួយ ក្នុងឥរិយាបថទាំង ៤ , ដែលថា ឋិតនៅដោយអាការណា គឺថា ក្នុងកាយនេះ មាន បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ។

អធិប្បាយថា កាលអ្នកពិឃាតគោ នៅចិញ្ចឹមគោនៅឡើយក្តី នាំគោទៅកាន់ទីពិឃាតក្តី នាំគោទៅចងទុកនៅក្នុងទីពិឃាតក្តី កំពុងសម្លាប់គោក្តី សម្លឹងមើលគោដែលស្លាប់ហើយក្តី ការសម្គាល់ថាគោនៅមាននៅឡើយ ដរាបណាគេមិនទាន់ពន្លះសាច់គោទៅជាចំណែក ៗ តែពេលគេពន្លះសាច់គោចេញទៅជាចំណែកៗហើយ ការសម្គាល់ថាជាគោក៏អស់ទៅ គេក៏ត្រឡប់ជាសម្គាល់ថា សាច់គោវិញ គេមិនបានគិតថា យើងលក់គោនោះទេ មនុស្សអ្នកទិញក៏គិតថា យើងទិញសាច់គោ មនុស្សទាំងឡាយនេះជួញដូរសាច់គោ សេចក្តីប្រៀបនេះ យ៉ាងណា ភិក្ខុនេះ ក៏ដូច្នោះដូចគ្នា កាលបុថុជ្ជនល្ងង់ខ្លៅ គ្រហស្ថក្តី បព្វជិតក្តី មានការសម្គាល់ថា សត្វ ឬ បុគ្គល នៅមានជានិច្ច កាលដែលមិនទាន់បានពិចារណានូវកាយនេះ តាមអាការដែលវាតាំងនៅ ដែលចែកចេញជាចំណែកៗនៃពួកធាតុ , តែកាលបើ លោកពិចារណាជាធាតុហើយ ការសម្គាល់ថាជា សត្វក៏អស់ទៅ ចិត្តក៏តាំងនៅដោយល្អ ក្នុងការប្រាកដនៃធាតុនោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ភិក្ខុពិចារណាឃើញកាយនេះឯងតាមដែលឋិតនៅដោយអាការណាៗ ថាជា **ធាតុ** គឺថា នៅក្នុងកាយនេះមាន បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចជាអ្នកពិឃាតគោ ឬ កូនសិស្សនៃអ្នកពិឃាតគោ ។ ល ។

ព្រះយោគាវចរ ប្រៀបដូចអ្នកពិឃាតគោ ការសម្គាល់ថា **សត្វ** ដូចជា

ការសម្គាល់ថា **គោ** ឥរិយាបថទាំង ៤ ប្រៀបដូចផ្លូវបែកជា ៤ ការពិចារណាជាធាតុ ប្រៀបដូចអ្នកពិឃាតគោ ពន្លះសាច់ចេញជាចំណែក ១ , នេះជាការពណ៌នាបាលី ក្នុងធាតុមនសិការបព្វៈនេះ ។

វិសុទ្ធិមគ្គ : ចតុធាតុវវដ្ឋាន មាន ២ យ៉ាង ដោយសង្ខេប ១ ដោយពិស្ដារ ១ ។ ដោយសង្ខេបទ្រង់សម្ដែងក្នុងសតិប្បដ្ឋានសូត្រ ដោយពិស្ដារទ្រង់សម្ដែងក្នុងមហាហត្ថិបទោបមសូត្រ ។

ក្នុងមហាហត្ថិបទោបមសូត្រនោះ មានសេចក្ដីដូចតទៅ សម្រាប់អ្នកចម្រើនកម្មដ្ឋានដែលមានបញ្ញាទន់ខ្សោយ :

ម្នាលអាវុសោទាំងឡាយ ធាតុដីខាងក្នុង តើដូចម្ដេច ? វត្ថុណាមាននៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់រឹង គ្រោតគ្រាត ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនេះគឺអ្វី វត្ថុនេះ គឺ សក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ខួរក្នុងក្បាល ឬ សូម្បីវត្ថុណាមួយដែលមានក្នុងខ្លួន អាស្រ័យខ្លួន ជារបស់រឹងគ្រោតគ្រាត ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន ម្នាលអាវុសោ នេះហៅថា **ធាតុដីខាងក្នុង** ។

ម្នាលអាវុសោទាំងឡាយ ធាតុទឹកខាងក្នុងតើដូចម្ដេច ? វត្ថុណានៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់សើមជ្រួតជ្រាប ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនេះគឺអ្វី វត្ថុនេះ គឺ ទឹកប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់

ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិស ទឹកមូត្រ ឬ សូម្បីវត្ថុណាមួយ ដែលមាននៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់សើមជ្រួតជ្រាប ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា **ធាតុទឹកខាងក្នុង** ។

ម្នាលអាវុសោទាំងឡាយ ធាតុភ្លើងខាងក្នុងតើដូចម្តេច ? វត្ថុណាមួយ ដែលមានក្នុងខ្លួន អាស្រ័យខ្លួន ជារបស់ក្តៅ ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនេះគឺអ្វី វត្ថុនេះ គឺជាហេតុឱ្យអប់ឧណ្ហកាយ១ ជាហេតុឱ្យកាយទ្រុឌទ្រោម១ ជាហេតុឱ្យកាយរសាប់រសល់១ ជាគ្រឿងរំលាយអាហារដែលបរិភោគចូលទៅ១ ឬថា វត្ថុណាមួយដែលមាននៅក្នុងខ្លួន អាស្រ័យខ្លួន ជារបស់ក្តៅ ដែលបុគ្គលប្រកាន់ថាជា របស់ខ្លួន ម្នាលអាវុសោ នេះហៅថា **ធាតុភ្លើងខាងក្នុង** ។

ម្នាលអាវុសោទាំងឡាយ ធាតុខ្យល់ខាងក្នុងតើដូចម្តេច ? វត្ថុណាមាន នៅក្នុងខ្លួន អាស្រ័យខ្លួន ជាវត្ថុបក់ផាត់នាំទៅមក ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន វត្ថុនេះគឺអ្វី វត្ថុនេះគឺ ខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់នៅក្នុងពោះ ខ្យល់នៅក្នុងពោះវៀន ខ្យល់រត់តាមអវយវៈតូចធំ ខ្យល់ដង្ហើមចេញចូល ដូច្នេះក្តី ឬ វត្ថុណាមួយមាននៅក្នុងខ្លួន អាស្រ័យខ្លួន ដែលបុគ្គលប្រកាន់ថា ជារបស់ខ្លួន ម្នាលអាវុសោទាំងឡាយ នេះហៅថា **ធាតុខ្យល់ខាងក្នុង** ។

**អដ្ឋសាលិនី អដ្ឋកថា ធម្មសង្គណី :**

ពាក្យថា **មហាភូត** នេះ គប្បីជ្រាបភាវៈនៃរូបដែលបាន ឈ្មោះថា **មហាភូត** ព្រោះហេតុ ប្រាកដជារបស់ធំជាដើម ។

ពិតហើយ រូបទាំងនេះ ហៅថា **មហាភូត** ព្រោះប្រាកដ ជារបស់ធំ ១

, **មហាភូត** គឺ ដូចជាអ្នកលេងកល ដែលដូចជាយក្សប្រុស និងយក្សស្រី ១ , ព្រោះត្រូវថែទាំរក្សាច្រើន ១ , មានការប្រែប្រួលច្រើន ១ , ជាវត្ថុធំដែលមានប្រាកដ ១ ។

បណ្ដាហេតុទាំងឡាយនោះ សេចក្ដីថា :

**១ - រូប** ឈ្មោះថា **មហាភូត** ព្រោះប្រាកដជារបស់ធំ មានអធិប្បាយថា រូបទាំងឡាយនេះ ប្រាកដជារបស់ធំ ទាំងក្នុងសន្ដាននៃរូបដែលមិនមានចិត្តគ្រប់គ្រង ទាំងក្នុងសន្ដាននៃរូបដែលមានចិត្តគ្រប់គ្រង , បណ្ដាសន្ដានទាំង **២** នោះ ក្នុងសន្ដាននៃរូបដែលមិនមានចិត្តគ្រប់គ្រង ដូចជា ចក្រវាឡ ផែនដីជាដើម .... , ក្នុងសន្ដាននៃរូបដែលមានចិត្តគ្រប់គ្រង ប្រាកដជារបស់ធំ ដូចជា ត្រី អណ្ដើក ទេពជាដើម... , ( ទំហំចក្រវាឡ ... ត្រីជាដើម មានពិស្ដារក្នុងអដ្ឋកថា អដ្ឋសាលិនីហើយ បណ្ឌិតគប្បីសិក្សាចុះ ) ។

**២ - រូប** ឈ្មោះថា **មហាភូត** ដែលដូចជាអ្នកលេងកល ដូចយក្សប្រុស និងយក្សស្រីនោះ មានអធិប្បាយថា មហាភូតរូបនេះ ដែលដូចជាអ្នកលេងកល ព្រោះសម្ដែងនូវវត្ថុដែលមិនមែនជាកែវមណី ឱ្យទៅជាកែវមណី សម្ដែងដុំដីដែលមិនមែនជាមាស ឱ្យទៅជាមាស យ៉ាងណា ម្យ៉ាងទៀត ខ្លួនឯងមិនមែនជាយក្ស មិនមែនជាបក្សី ក៏សម្ដែងឱ្យទៅជាយក្ស ឱ្យទៅជាបក្សី យ៉ាងណា សេចក្ដីឧបមេយ្យនេះ ក៏ដូចគ្នា **មហាភូតរូប** ខ្លួនឯងមិនមែនជាពណ៌ខៀវ ក៏សម្ដែងឧបាទាយរូបឱ្យប្រាកដជាពណ៌ខៀវ មិនមែនជាពណ៌លឿង ក៏សម្ដែងឧបាទាយរូបឱ្យប្រាកដជាពណ៌លឿង មិនមែនជាពណ៌ក្រហម ក៏សម្ដែងនូវឧបា-ទាយរូបឱ្យប្រាកដជាពណ៌ក្រហម មិនមែនជាពណ៌ស ក៏សម្ដែងឧបាទាយរូបឱ្យ

ប្រាកដជាពណ៌ស ព្រោះដូច្នោះ រូបនេះ ទើបឈ្មោះថា **មហាភូត** គឺ ព្រោះវាដូចនឹងមហាភូត គឺ អ្នកលេងកល ។ ម្យ៉ាងទៀត **មហាភូត** ឧបមាដូចជាយក្សប្រុសជាដើម ចាប់បុគ្គលណាបានហើយ មហាភូតនោះ ក៏ចូលទៅក្នុងខ្លួនបុគ្គលទាំងនោះ ចង់រកវាក៏មិនឃើញ ឬ នៅខាងក្រៅក៏មិនជួប នឹងថាវាមិនពួននៅក្នុងបុគ្គលនោះ ក៏មិនមែន សេចក្ដីនេះ យ៉ាងណា សូម្បីមហាភូតរូបនេះ ក៏ដូច្នោះដូចគ្នា នឹងចូលទៅរកវា ខាងក្នុងនៃគ្នានិងគ្នាក៏មិនជួប នឹងរកមើលនៅខាងក្រៅក៏មិនឃើញ តែថា មហាភូតរូបនេះ មិនអាស្រ័យគ្នា និងគ្នា ក៏មិនមែន ដូច្នោះ រូបនេះ ទើបឈ្មោះថា **មហាភូត** ព្រោះវាដូចជា មហាភូត មានយក្សជាដើម ព្រោះមហាភូតរូបនេះ ជាធម្មជាតិ ឋិតនៅក្នុងឋានៈដែលសាមញ្ញជនគិតមិនដល់ ។

ម្យ៉ាងទៀត មហាភូតនេះ ឧបមាដូចជាយក្សស្រី បិទបាំងភាវៈខ្លួនឯងដែលគួរឱ្យខ្លាច ទុកដោយពណ៌សម្បុរ សណ្ឋានរាងរៅ ភាពឆើតឆាយ ដែលគួរឱ្យពេញចិត្ត បោកបញ្ឆោតសត្វទាំងឡាយយ៉ាងណា មហាភូតរូបនេះ ក៏ដូច្នោះដូចគ្នា បិទបាំងលក្ខណៈរបស់ខ្លួន ទៅតាមសភាពដែលវាជារបស់គ្រោតគ្រាតជាដើម ទុកដោយពណ៌សម្បុរ ដែលគួរឱ្យពេញចិត្ត ដោយទ្រង់ទ្រាយអង្គាវយវៈតូចធំដែលគួរឱ្យពេញចិត្ត និងដោយការលើកដៃជើង ការកម្រើកម្រាមដៃ ការព្រិចភ្នែក ដែលគួរឱ្យពេញចិត្ត នៅក្នុងសរីរៈរបស់ស្ត្រី និង បុរសជាដើម ទុកហើយ លួងលោមបុគ្គលល្ងង់ខ្លៅ មិនឱ្យឃើញសភាវៈរបស់ខ្លួនឡើយ ដូច្នោះ រូបនេះ ទើបឈ្មោះថា **មហាភូត** ព្រោះដូចនឹងមហាភូត មានយក្សស្រីជាដើម ព្រោះអត្ថថា បោកបញ្ឆោត ។

**៣ - រូប** ឈ្មោះថា **មហាភូត** ព្រោះហេតុ ត្រូវថែទាំរក្សាដោយច្រើន គឺ ព្រោះហេតុ ត្រូវថែរក្សាដោយបច្ច័យជាច្រើន អធិប្បាយថា **រូបនេះ** ឈ្មោះថា **មហាភូត** ដោយអត្ថថា ត្រូវឱ្យបរិភោគ ដើម្បីឱ្យរស់ ដោយអាហារគ្រឿងឧបត្ថម្ភជាដើម យ៉ាងច្រើន ព្រោះត្រូវទំនុកបម្រុងរៀងរាល់ថ្ងៃ ម្យ៉ាងទៀត **រូប** ឈ្មោះថា **មហាភូត** ព្រោះត្រូវទំនុកបម្រុងថែរក្សាបានដោយលំបាក ។

**៤ - រូប** ឈ្មោះថា **មហាភូត** ដោយហេតុ មានការប្រែប្រួលច្រើន គឺ ព្រោះរូបនេះត្រូវប្រែប្រួលជាច្រើន ពិតហើយ រូបនេះ ជារូបដែលមានចិត្តគ្រប់គ្រងក៏មាន ជារូបដែលមិនមានចិត្តគ្រប់គ្រងក៏មាន រមែងមានការប្រែប្រួលជាច្រើន ក្នុងរូបទាំង ២ នេះ សម្រាប់រូបដែលមិនមានចិត្តគ្រប់គ្រង ការប្រែប្រួលជាច្រើននេះ រមែងប្រាកដក្នុងពេលដែលវិនាស ឯរូបដែលមានចិត្តគ្រប់គ្រង រមែងប្រាកដការប្រែប្រួល ក្នុងពេលដែលធាតុកម្រើក ។

**៥ - រូប** ឈ្មោះថា **មហាភូត** ដោយហេតុជារបស់ធំ មានប្រាកដ មាន អធិប្បាយថា រូបនេះ ឈ្មោះថា **ជារបស់ធំ** ព្រោះត្រូវកំណត់យកដោយការព្យាយាមធំ , ឈ្មោះថា **មានប្រាកដ** ព្រោះការប្រាកដនោះឯង ដូច្នោះ **រូប** ឈ្មោះថា **មហាភូត** ព្រោះជាវត្ថុធំមានប្រាកដ យ៉ាងនេះឯង ។

## ក្នុងគម្ពីរអភិធម្មត្ថសង្គហៈ

*បឋវីធាតុ* មានវចនត្ថៈថា **បត្ថីនត្តេន បឋវី** ឈ្មោះថា **បឋវី** ព្រោះអត្ថថា **រឹង** ។ ឈ្មោះថា **ធាតុ** ព្រោះអត្ថថា ទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន មានអត្ថថា មិនមែនសត្វ មិនមែនជីវៈ ។ **ធាតុ** គឺ **បឋវី** ឈ្មោះថា **បឋវីធាតុ** ។

កាលណាប្រៀបធៀបនឹងមហាភូតរូប **៣** ដទៃទៀត បឋវីធាតុនេះមាន លក្ខណៈរឹង ។ បើនៅក្នុងវត្ថុណា មានបឋវីធាតុច្រើន ជាប្រធាន លក្ខណៈរឹងនេះ ក៏ប្រាកដច្បាស់ ដូចជា ឥដ្ឋ ថ្ម ដី ដើមឈើ ជាដើម និងបើក្នុងវត្ថុណា មានបឋវីធាតុនេះតិច លក្ខណៈរឹង នោះក៏ប្រាកដមិនច្បាស់ កាលប៉ះត្រូវ ក៏ដឹងថាជាលក្ខណៈទន់ បានសេចក្ដីថា ភាពរឹងនោះមានតិច យ៉ាងនេះ ទើបធ្វើឱ្យដឹងថា **ទន់** ។ ដូច្នេះ ធម្មជាតិដែលមានលក្ខណៈរឹងក្ដី ទន់ក្ដី ក្នុងកាលប៉ះត្រូវហើយ ចាត់ជាបឋវីធាតុទាំងអស់ ព្រោះក្រៅពីបឋវីធាតុហើយ រូបដទៃៗ មិនអាចធ្វើឱ្យដឹងភាពរឹង ឬ ទន់ ប្រាកដដល់ការប៉ះនោះបានឡើយ ដូច្នោះឯង **បឋវីធាតុ** មានលក្ខណៈ **២** យ៉ាង គឺ :

**១- កក្ខឡបឋវី** បឋវីមានភាពរឹង ជាលក្ខណៈ

**២- អថទ្ធបឋវី** បឋវីមានភាពទន់ ជាលក្ខណៈ

**បឋវីធាតុ** ប្រែថា ធម្មជាតិដែលទ្រទ្រង់ ជាទីអាស្រ័យរបស់រូបដែលកើតរួមទាំងឡាយនោះ ឈ្មោះថា **បឋវី** ។

## លក្ខណាទិចតុក្កៈរបស់បឋវី

| | |
|---|---|
| **- កក្ខឡត្ត លក្ខណា** | មានភាពរឹង ជាលក្ខណៈ ។ |
| **- បតិដ្ឋាន រសា** | មានការធ្វើជាទីប្រតិស្ឋាន ជាកិច្ច ។ |
| **- សម្បដិច្ឆន្ន បច្ចុប្បដ្ឋានា** | មានការទទួលទ្រ ជាអាការប្រាកដ ។ |
| **- អវសេសធាតុត្តយ បទដ្ឋានា** | មានធាតុ ៣ ទៀត ជាហេតុជិត ( ទឹក ភ្លើង ខ្យល់ ) ។ |

អាបោធាតុ មានវចនត្ថៈថា **អាបេតិ សហជាតរូបេសុ ព្យាបេត្វា តិដ្ឋតីតិ អាបោ** ធម្មជាតិណា រមែងផ្សាយទៅ ជ្រួតជ្រាបទូទៅ ក្នុងរូបដែលកើតព្រមជាមួយនឹងខ្លួន ហើយតាំងនៅក្នុងរូបនោះ ធម្មជាតិនោះ ឈ្មោះថា **អាបោធាតុ** ។

ន័យម្យ៉ាងទៀត **អប្បាយតិ សហជាត រូបានិ សុដ្ឋុ ព្រូហេតិ វឌ្ឍេតីតិ អាបោ** ធម្មជាតិណា ធ្វើសហជាតរូបទាំងឡាយឱ្យចម្រើនឡើង គឺ ពូនផ្តុំ កកណែន ធម្មជាតិនោះ ឈ្មោះថា **អាបោ** ។

ន័យម្យ៉ាងទៀត **សហជាតរូបានិ អវិប្បកិណ្ណានិ កត្វា ភុសោ បាតិ រក្ខតីតិ អាបោ** ធម្មជាតិណា រមែងគ្រប់គ្រងរក្សាសហជាតរូប យ៉ាងហ្មត់ចត់មិនឱ្យរាត់រាយរតាត់រតាយបាន ធម្មជាតិនោះ ឈ្មោះថា **អាបោ** ។

ដូច្នោះ **អាបោធាតុ** មាន **២** យ៉ាង គឺ :

**១. បគ្ឃរណអាបោ** មានការហូរជ្រាប ជាលក្ខណ:

**២. អពន្ធនអាបោ** មានការកកពូនផ្តុំ ជាលក្ខណ:

អាបោធាតុនេះ បើមានច្រើននៅក្នុងវត្ថុណា តែងធ្វើវត្ថុនោះឱ្យទៅជារាវ ហើយហូរបាន ។ ប៉ុន្តែបើមានចំនួនចិត្តវិញ ក៏ធ្វើឱ្យវត្ថុនោះ ទៅជាកក ពូនផ្តុំជាដុំ ជាផែន ស្អិតល្អួតជាប់គ្នា ជារូបរាងសណ្ឋានផ្សេង ៗ ដូចជាផែនដី ភ្នំ ទំពាំង ភ្លុក ស្នែងជាដើម ។

បើក្នុងវត្ថុណា មានអាបោធាតុច្រើនជាងបឋវីធាតុ ក៏ធ្វើឱ្យបឋវីធាតុនោះ មានអំណាចតិច ទើបជាហេតុឱ្យវត្ថុនោះទន់ជ្រាយ រាវ ហើយហូរទៅបាន ។ ដូច្នោះវត្ថុដែលហូរនោះ គឺបឋវីធាតុនោះឯងដែលហូរ មិនមែនអាបោ-

ធាតុហូរទេ ពីព្រោះ អាបោធាតុ ជាធាតុប៉ះត្រូវដឹងតាមផ្លូវកាយមិនបាន គឺ ដឹងបានតែត្រឹមតាមផ្លូវចិត្តប៉ុណ្ណោះ ។

អាបោធាតុ ដែលមានប្រក្រតីជា **អាពន្ធនលក្ខណៈ** តែកាលណាត្រូវឧណ្ហតេជោហើយ **បគ្ឃរណលក្ខណៈ** នឹងប្រាកដ គឺ ហូរទៅបាន បានដល់អាបោធាតុដែលនៅក្នុង ដែក មាស ក្រមួនជាដើម ។

អាបោធាតុដែលមានប្រក្រតីជា **បគ្ឃរណលក្ខណៈ** តែកាលណាត្រូវសីតតេជោហើយ **អាពន្ធនលក្ខណៈ** នឹងប្រាកដ គឺកកពូនផ្តុំ បានដល់អាបោធាតុដែលនៅក្នុងទឹក ក្នុងប្រេងជាដើម ។

## លក្ខណាទិចតុក្កៈរបស់អាបោ

| | | | |
|---|---|---|---|
| - **បគ្ឃរណ លក្ខណា** | មានការហូរជ្រាប | ជាលក្ខណៈ | ។ |
| **អាពន្ធន លក្ខណា វា** | ឬមានការកកពូនផ្តុំ | ជាលក្ខណៈ | ។ |
| - **ឧបព្យូហន រសា** | មានការចូលទៅកពូន | ជាកិច្ច | ។ |
| - **សង្គហ បច្ចុប្បដ្ឋានា** | មានការប្រមែប្រមូលទុក ជាអាការប្រាកដ | | ។ |
| - **អវសេសធាតុត្តយ បទដ្ឋានា** | មានធាតុដ៏សេស ៣ ទៀត ជាហេតុជិត | | ។ |

តេជោធាតុ មានវចនត្ថៈថា **តេជេតិ បរិបាចេតីតិ តេជោ** ធាតុដែលឈ្មោះថា **តេជោ** ព្រោះអត្ថថា ធ្វើឱ្យក្តៅ ធ្វើឱ្យទុំ ធ្វើឱ្យឆ្អិន ធ្វើឱ្យជោរ ។

វត្ថុផ្សេង ៗ ជាច្រើន ដូចជាអាហារជាដើម ឆ្អិនបានដោយកម្តៅ តែអាហារខ្លះឆ្អិនបានដោយត្រជាក់ដូចគ្នា ។ ដូច្នោះ តេជោធាតុ បានដល់ ធាតុ

ភ្លើង មាន **២** លក្ខណៈ គឺ :

**១- ឧណ្ហតេជោ** មានចំហាយក្តៅ ជាលក្ខណៈ

**២- សីតតេជោ** មានចំហាយត្រជាក់ ជាលក្ខណៈ

## លក្ខណាទិចតុក្កៈរបស់តេជោ

- **ឧណ្ហត្ត លក្ខណា** មានភាពក្តៅ ជាលក្ខណៈ ។
- **បរិបាចនំ រសោ** មានការដុតដាំរោលឆ្អើរ ជាកិច្ច ។
- **មទ្ទវានុប្បទាន បច្ចុប្បដ្ឋានា** មានការធ្វើឱ្យទន់ ជាអាការប្រាកដ ។
- **អវសេសធាតុត្តយ បទដ្ឋានា** មានធាតុសល់ ៣ ជាហេតុជិត ។

វាយោធាតុ មានវចនត្ថៈថា **វាយតិ សហជាតធម្មេ អបតមានេ កត្វា វហតីតិ វាយោ** ប្រែថា ធាតុណា អាចនាំទៅនូវរូបដែលកើតព្រមជាមួយខ្លួន ធ្វើឱ្យតាំងនៅស្ងៀម មិនចល័ត មិនធ្វើចលនា ព្រោះហេតុនោះ ធាតុនោះ ឈ្មោះថា **វាយោ** បានដល់ ខ្យល់ដែលធ្វើឱ្យតឹង ។

ក្នុងរាងកាយរបស់សត្វ ដូចជាការដឹងខ្លួនថា តឹង រួយ ស្រយង់ ស្រពន់ ឈឺពើត ចុកចាប់ ឬពេលប្រឹងដៃប្រឹងជើង ឬ ខណៈដែលភ្នែកសម្លឹងមិនពព្រិច ពេលនោះ វាយោធាតុ ក៏ប្រាកដដោយសេចក្តីព្យាយាមរបស់ខ្លួន ។ ចំពោះនៅខាងក្រៅ រាងកាយសត្វវិញ ដូចពោះវៀនកង់ ឬ បាល់ដែលសប់ខ្យល់ចូលទៅហើយ ឬ ទឹកក្នុងតម្រងទឹកបិទរន្ធ ឬ ខ្យល់ដែលទ្រទឹក ទឹកទ្រផែនដី ។

ន័យម្យ៉ាងទៀត មានវចនត្ថៈថា **វាយតិ ទេសន្តរុប្បត្តិ ហេតុភាវេន**

**ភូតសង្ឃាតំ ចាលេតីតិ វាយោ** ប្រែថា ធាតុណា តែងធ្វើឱ្យពពួកមហាភូតរូប ដែលកើតព្រមជាមួយខ្លួន ចល័តទៅទីដទៃ ដោយជាហេតុឱ្យមានចលនា ពីកន្លែងមួយទៅកន្លែងមួយ ដូច្នោះ ធាតុនោះ ឈ្មោះថា **វាយោ** បានដល់ ខ្យល់ ដែលធ្វើឱ្យកម្រើកញ័រ ។

ដូចជាសត្វទាំងឡាយ ធ្វើនូវឥរិយាបថផ្សេងៗបាន ឬ ព្រិចភ្នែក បត់ដៃ បត់ជើង បន្ទោបង់ឧច្ចារៈ-បស្សាវៈ ធ្វើឱ្យអាហារធ្លាក់ទៅកាន់ក្រពះ ប្រសូត្របុត្តជាដើម ទាំងនេះដែលប្រព្រឹត្តទៅបាន ក៏ដោយអំណាចធាតុខ្យល់ទាំងអស់។ ចំពោះធាតុខ្យល់ខាងក្រៅ ក្រៅរាងកាយសត្វវិញ ធ្វើឱ្យវត្ថុរបស់របរផ្សេង ៗ ចល័ត ញ័រ កម្រើក ចាកទីកន្លែងដើមទៅបាន ។

ដូច្នោះ **វាយោធាតុ** បានដល់ ធាតុខ្យល់ ដែលមាន **២** លក្ខណៈ គឺ :

| | | |
|---|---|---|
| **១- វិត្ថម្ភនវាយោ** | មានភាពតឹង | ជាលក្ខណៈ |
| **២- សមុទីរណវាយោ** | មានភាពកម្រើក ញ័រ | ជាលក្ខណៈ |

## លក្ខណាទិចតុក្កៈរបស់វាយោ

| | | |
|---|---|---|
| **- វិត្ថម្ភន លក្ខណា** | មានភាពតឹង ជាលក្ខណៈ | ។ |
| **- សមុទីរណ រសា** | មានការកម្រើកញ័រ ជាកិច្ច | ។ |
| **- អាភិនីហារ បច្ចុប្បដ្ឋានា** | មានការនាំចេញ ជាអាការប្រាកដ | ។ |
| **- អវសេសធាតុត្តយ បទដ្ឋានា** | មានធាតុសល់ ៣ ជាហេតុជិត | ។ |

**មូលបរិយាយសូត្រ ( បិដក. ២០ )**

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានឃើញនូវព្រះអរិយៈទាំងឡាយ ( មានព្រះពុទ្ធជាដើម ) មិនឈ្លាសក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ គឺមិនមានអរិយធម៌ មិនឃើញពួកសប្បុរស មានព្រះពុទ្ធជាដើម មិនឈ្លាសក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងសម្គាល់នូវផែនដី ថាជាផែនដីពិត លុះសម្គាល់នូវផែនដីថា ជាផែនដីពិតហើយ ក៏រាប់អាននូវផែនដី រាប់អានក្នុងផែនដី រាប់អានថា ផែនដីពិត រាប់អានថា ផែនដីជារបស់អញ ត្រេកអរនឹងផែនដី ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរនៃផែនដីនោះមិនបាន ។

បុថុជ្ជនតែងសម្គាល់នូវទឹកថា ជាទឹកពិត លុះសម្គាល់នូវទឹកថា ជាទឹកពិតហើយ ក៏រាប់អាននូវទឹក រាប់អានក្នុងទឹក រាប់អានថាទឹកពិត រាប់អានថាទឹកជារបស់អញ ត្រេកអរនឹងទឹក ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរទឹកនោះមិនបាន ។

បុថុជ្ជនតែងសម្គាល់នូវភ្លើង ថាជាភ្លើងពិត លុះសម្គាល់នូវភ្លើង ថាជាភ្លើងពិតហើយ ក៏រាប់អាននូវភ្លើង រាប់អានក្នុងភ្លើង រាប់អានថាភ្លើងពិត រាប់អានថាភ្លើងជារបស់អញ ត្រេកអរនឹងភ្លើង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់នូវដំណើរភ្លើងនោះមិនបាន ។

បុថុជ្ជនតែងសម្គាល់នូវខ្យល់ថាជាខ្យល់ពិត លុះសម្គាល់នូវខ្យល់ថាជាខ្យល់ពិតហើយ ក៏រាប់អាននូវខ្យល់ រាប់អានក្នុងខ្យល់ រាប់អានថាខ្យល់ពិត រាប់

អានថា ខ្យល់ជារបស់អញ ត្រេកអរនឹងខ្យល់ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ តថាគតពោលថា ព្រោះបុថុជ្ជននោះ កំណត់ដំណើរខ្យល់នោះមិនបាន ។

អដ្ឋកថា : ពាក្យថា **បឋវី បឋវិតោ** នោះគប្បីជ្រាបថា បឋវីមាន **៤** យ៉ាង គឺ លក្ខណៈបឋវី១ សសម្ភារបឋវី១ អារម្មណបឋវី១ និង សម្មតិបឋវី១ ។

ក្នុងបឋវី **៤** យ៉ាងនោះ **បឋវីធាតុ** ដែលលោកពោលទុកក្នុងប្រយោគថា ម្នាលអាវុសោ បឋវីធាតុខាងក្នុងដូចម្តេច បានដល់ វត្ថុដែលមានលក្ខណៈរឹង ឈ្មោះថា **លក្ខណបឋវី** ។

**បឋវីធាតុ** ដែលលោកពោលទុកក្នុងប្រយោគជាដើមថា ភិក្ខុជីកដោយខ្លួនឯងក្តី ប្រើអ្នកដទៃឱ្យជីកក្តី នូវផែនដី និងវត្ថុខាងក្រៅ មានដែកនិងលោហៈជាដើម ព្រមទាំងគុណសម្បត្តិ មានពណ៌ជាដើម នេះបឋវីខាងក្រៅ ។ បឋវីធាតុ គឺ កោដ្ឋាសៈ ( ចំណែក ) **២០** មានសក់ជាដើម នេះបឋវីខាងក្នុងរួមហៅថា **សសម្ភារបឋវី** ។

**បឋវីធាតុ** មកក្នុងប្រយោគជាដើមថា បុគ្គលដែលកំណត់ដឹងនូវបឋវីកសិណ ហៅថា **អារម្មណបឋវី** ឬ **និមិត្តបឋវី** ។

**បឋវីធាតុ** ក្នុងន័យថា បុគ្គលដែលបានឈាន មានបឋវីកសិណជាអារម្មណ៍ កើតក្នុងទេវលោក បានឈ្មោះថា បឋវីទេវតា ដោយអំណាចបឋវីកសិណជាហេតុនោះ នេះគប្បីជ្រាបថា **សម្មតិបឋវី** ។

ក្នុងអធិការនេះ សំដៅយកបឋវីទាំងអស់នោះ បថុជ្ជនតែងសម្គាល់នូវបឋវីយ៉ាងណាមួយ ក្នុងបណ្តាបឋវីទាំងឡាយនោះថា ជាបឋវី រមែងស្គាល់ថា

ជាបឋវី រមែងរាប់អានក្នុងបឋវី កាលកាន់យកតាមវោហារនៃលោក រមែងសម្គាល់ដោយសញ្ញាវិបល្លាស ថាជាបឋវី ពេលកំណត់ដំណើរនៃបឋវីនោះមិនបាន ក៏សម្គាល់នូវចំណែកនៃបឋវីនោះ ថាជា សត្វ ជារបស់សត្វ ។ ព្រោះបុថុជ្ជននោះ ប្រៀបដូចជាមនុស្សឆ្កួត គេរមែងប្រកាន់វត្ថុណាមួយដោយអាការណាមួយ ។

បទថា **បឋវឹ បឋវិតោ សញ្ញត្វា** មានន័យថា បុថុជ្ជននោះ សម្គាល់នូវផែនដីនោះដោយសញ្ញាដែលវិបរិត យ៉ាងនេះ ហើយបន្ទាប់មក រមែងសម្គាល់ គឺ កំណត់ផ្សេងៗទៀត បានដល់ ប្រកាន់ដោយអាការផ្សេងៗ ដោយប្រការដទៃ គឺ ដោយអំណាចកិលេសជាគ្រឿងយឺតយូរ គឺ តណ្ហា មានះ និង ទិដ្ឋិ ដ៏មានកម្លាំង ។ តាមព្រះបាលីថា កិលេសជាគ្រឿងយឺតយូរនេះ មានសញ្ញាជាតួហេតុ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **បឋវី មញ្ញតិ** ។

ដើម្បីនឹងទ្រង់សម្ដែងនូវការសម្គាល់ទាំងនោះ របស់អ្នកសម្គាល់យ៉ាងនេះ ដោយន័យពិស្ដារ ព្រះមានព្រះភាគ ទើបត្រាស់បឋវី **២០** ប្រភេទ ក្នុងន័យជាដើមថា កេសា លោមា ត្រាស់បឋវីក្នុងគម្ពីរវិភង្គយ៉ាងនេះថា បឋវីធាតុ ២ យ៉ាង បឋវីធាតុខាងក្រៅ តើដូចម្ដេច គឺ វត្ថុខាងក្រៅដែលរឹងគ្រោតគ្រាតមិនមានចិត្តគ្រប់គ្រង ដូចជាដែក លោហៈ សំណ ស្ពាន់ ប្រាក់ មាស មុក្តាកែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រវាឡ កែវទទឹម ពេជ្រភ្នែកឆ្មា ស្មៅ ដើមឈើ ដុំក្រួស ខ្សាច់ ក្បឿង ផែនដី ថ្មភ្នំ និង ត្រាស់និមិត្តផែនដី ក្នុងវត្ថុអារម្មណ៍ខាងក្នុង ទ្រង់សំដៅយកបឋវីនោះៗ ហើយសម្ដែងនូវសេចក្ដីនេះទុក ។

បទថា **បឋវី មញ្ញតិ** មានន័យថា បុថុជ្ជនរមែងសម្គាល់ ថាយើងជាដី

ថាដីរបស់យើង ថាអ្នកដទៃជាដី ថាដីរបស់អ្នកដទៃ ដូច្នេះ ដោយការសម្គាល់ **៣** យ៉ាង និងរមែងសម្គាល់ទាំងដីខាងក្នុងដោយ **តណ្ហា មានះ ទិដ្ឋិ** ។

សម្គាល់ដូចម្តេច ?

ពិតហើយ បុថុជ្ជននេះ កាលញុំាងឆន្ទរាគៈឱ្យកើតឡើង ក្នុងសក់ជាដើម គឺ រីករាយ ត្រេកត្រអាល និយាយដល់រឿយៗ វង្វេងវង្វាន់ ក្នុងសក់ រោម ក្រចក ធ្មេញ ស្បែក ឬ ក៏វត្ថុជាទីតាំងនៃតម្រេក យ៉ាងណាមួយ , បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដោយអំណាចនៃតណ្ហា យ៉ាងនេះ ។ ឬក៏ កើតការប្រាថ្នាក្នុងសក់ជាដើមនោះ ក្នុងន័យថា សក់របស់យើងគួរជាយ៉ាងនេះរហូតទៅ រោមរបស់យើង គួរជាយ៉ាងនេះ រហូតទៅ ឬក៏តាំងចិត្តទុកដើម្បីបាននូវវត្ថុដែលខ្លួនមិនទាន់បាន ក្នុងន័យថា ដោយសីលនេះ ឬ ព្រហ្មចរិយៈនេះ សូមឱ្យយើងមានសក់ខ្មៅស្រិលទន់ល្មើយ យ៉ាងនេះ ។ បុថុជ្ជនរមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដោយអំណាចតណ្ហា ដូចអធិប្បាយមកនេះឯង ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ ឬ វិបត្តិនៃសក់ជាដើមរបស់ខ្លួន ហើយញុំាងមានះឱ្យកើតឡើងថា យើងល្អជាងគេ យើងស្មើនឹងគេ យើងអន់ជាងគេ ដូចដែលពោលមកនេះ ឈ្មោះថា សម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដែលកើតចាកអំពីមានះ ។

ម្យ៉ាងទៀត បថុជ្ជនរមែងប្រកាន់សក់ថាជា ជីវៈ ក្នុងន័យដែលពោលហើយថា ជីវៈនោះ គឺ សរីរៈនោះ ។ ក្នុងរោមជាដើម ក៏មានន័យដូចគ្នា ។ បុថុជ្ជន រមែងសម្គាល់បឋវីខាងក្នុង ដោយការសម្គាល់ដោយអំណាចនៃទិដ្ឋិ

ដូចពោលមក ដូច្នេះឯង ។

ម្យ៉ាងទៀត បុថុជ្ជន រមែងប្រកាន់មាំនូវបឋវីផ្សេងៗ មានសក់ជាដើម ដោយការប្រកាន់ទាស់យ៉ាងនេះថា ម្នាលអាវុសោ បឋវីធាតុខាងក្នុងយ៉ាងណា បឋវីធាតុខាងក្រៅយ៉ាងណា ក៏បឋវីធាតុនោះ ឈ្មោះថា បឋវីធាតុដូចគ្នា ដែលវាមិនមែនជារបស់យើងថា នុ៎ះជាយើង នុ៎ះជារបស់យើង នុ៎ះជាខ្លួនរបស់យើង ឈ្មោះថា រមែងសម្គាល់បឋវីធាតុខាងក្នុង ដោយការសម្គាល់ដែលកើតចាកអំណាចនៃទិដ្ឋិយ៉ាងនេះ ។

បថុជ្ជន រមែងសម្គាល់បឋវីខាងក្រៅ ដូចបឋវីខាងក្នុង តើដូចម្តេច ?

ពិតហើយ បុថុជ្ជននេះ ញុំាំងឆន្ទរាគៈឱ្យកើតឡើង ក្នុងដែក លោហៈជាដើម ត្រេកត្រអាល និយាយដល់រឿយៗ វង្វេងវង្វាន់ ក្នុងដែក លោហៈជាដើម រមែងហួងហែងរក្សា គ្រប់គ្រងដែកជាដើមទុក ក្នុងន័យថា ដែករបស់យើង លោហៈរបស់យើង នេះឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដោយអំណាចនៃតណ្ហា ដោយប្រការដូច្នេះឯង ។ ឬថា បុថុជ្ជនរមែងប្រាថ្នានូវបឋវីធាតុខាងក្រៅថា សូមឱ្យដែក និង លោហៈជាដើមរបស់យើង គប្បីមានយ៉ាងនេះរហូតទៅ ឬ តាំងចិត្តថា ដើម្បីឱ្យបាននូវវត្ថុដែលមិនទាន់បាន ដោយសីល និង ព្រហ្មចរិយៈនេះ សូមឱ្យយើងជាអ្នកមានឧបករណ៍មាន ដែក និង លោហៈជាដើម ឱ្យបានបរិបូរ យ៉ាងនេះ ។ បថុជ្ជន ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតចាកអំណាចតណ្ហា ដោយប្រការយ៉ាងនេះឯង ។

ម្យ៉ាងទៀត បុថុជ្ជនអាស្រ័យសម្បត្តិ ឬវិបត្តិនៃដែក និងលោហៈជាដើម

របស់ខ្លួន កើតមានះថា ដោយឧបករណ៍នេះ យើងប្រសើរជាងគេ យើងស្មើនឹងគេ ឬថា យើងអន់ជាងគេ , បុថុជ្ជន ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតចាកអំណាចនៃមានះ យ៉ាងនេះឯង ។

បុថុជ្ជន រមែងមានការសម្គាល់ក្នុងដែកថា ជីវៈ រមែងប្រកាន់មាំថា នេះជាជីវៈ ន័យក្នុងលោហៈជាដើមក៏ដូច្នេះ ។

បុថុជ្ជន ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ដែលកើតចាកអំណាចនៃទិដ្ឋិ យ៉ាងនេះឯង ។

ប្រការមួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ពិចារណាឃើញបឋវីកសិណថាជា អត្តា គឺថា រមែងប្រកាន់មាំនូវនិមិត្តបឋវី ថា អត្តា តាមន័យដែលលោកពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គ ថា បថុជ្ជន រមែងពិចារណាឃើញសេចក្តីទាំង ២ គឺ បឋវីកសិណ និង អង្គអវយវៈថា បឋវីកសិណ គឺជាយើង យើងគឺ បឋវីកសិណ ដូច្នេះ ឈ្មោះថា រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់កើតចាកអំណាចនៃទិដ្ឋិ យ៉ាងនេះឯង ។

បុថុជ្ជន រមែងសម្គាល់បឋវីខាងក្រៅ ដោយការសម្គាល់ **៣** យ៉ាងដូចដែលអធិប្បាយមក ដូច្នេះឯង ។

ក្នុងពាក្យថា **បឋវី មញ្ញតិ** នេះ គប្បីជ្រាបការសម្គាល់ទាំង **៣** ដូចពណ៌នាមកដូច្នេះជាដំបូង ។ បន្ទាប់ពីនេះទៅ ខ្ញុំម្ចាស់នឹងពោលដោយសង្ខេបប៉ុណ្ណោះ ។ ពាក្យថា **បឋវិយា** នេះ ក្នុងពាក្យថា **បឋវិយា មញ្ញតិ** នេះជាសត្តមីវិភត្តិ , ព្រោះដូច្នោះ ក្នុងពាក្យនេះ មានអធិប្បាយដូច្នេះថា បុថុជ្ជនរមែងសម្គាល់ថា យើងមានក្នុងបឋវី , រមែងសម្គាល់ថា សេចក្តីកង្វល់ស្មុកស្មាញ

របស់យើង មានក្នុងបឋវី រមែងសម្គាល់ថា បុគ្គលដទៃមានក្នុងបឋវី រមែងសម្គាល់ថា សេចក្តីកង្វល់ស្មុកស្មាញរបស់អ្នកដទៃ មានក្នុងបឋវី ។ ម្យ៉ាងទៀត ន័យនៃខ្លឹមសាររបស់សត្តមីវិភត្តិនោះ ទ្រង់បានពោលទុកថា បុថុជ្ជនរមែងពិចារណាឃើញអត្តាក្នុងរូប ដូចម្តេច ? គឺ បុថុជ្ជនពួកខ្លះក្នុងលោកនេះ ពិចារណាឃើញ វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជា អត្តា គេពិចារណាឃើញនូវអត្តាក្នុងរូបយ៉ាងនេះថា នេះឯង ជាអត្តារបស់យើង អត្តារបស់យើងដូច្នេះឯង មាននៅក្នុងរូបនេះ ដោយន័យនោះឯង បុថុជ្ជនទើបប្រកាន់នូវវេទនាធម៌ជាដើម បន្ទាប់មកក៏កំណត់យកបឋវីប្រភេទណាមួយ ក្នុងបណ្តាបឋវីខាងក្នុងនិងខាងក្រៅ ក្នុងភាពជាឱកាសនៃអត្តានោះ សម្គាល់ថា អត្តារបស់យើងនេះឯង មានក្នុងបឋវីនេះ ដូច្នេះ ឈ្មោះថា រមែងសម្គាល់ក្នុងបឋវី ។ នេះឈ្មោះថា ការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបុថុជ្ជននោះ ញ៉ាំងសេចក្តីស្នេហាក្នុងអត្តា និងមានះ ដែលមានអត្តាជាទីតាំងឱ្យកើតឡើងក្នុងរូបនោះ គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចតណ្ហា និង មានះ ។

តែក្នុងកាលណា បុថុជ្ជន សម្គាល់តាមន័យនោះឯងថា អត្តារបស់អ្នកដទៃនោះ មានក្នុងបឋវី ក្នុងកាលនោះ ជាការសម្គាល់ដែលកើតដោយអំណាចនៃទិដ្ឋិ ការសម្គាល់ដទៃក្រៅពីនេះ ក៏ទ្រង់បំណងយកដែរ ។

ពាក្យថា **បឋវិតោ** ក្នុងពាក្យថា **បឋវិតោ មញ្ញតិ** ជាបញ្ចមីវិភត្តិ , ព្រោះដូច្នោះ បុថុជ្ជនកាលសម្គាល់ការកើតឡើង ឬ ការប្រាសទៅនៃបឋវី មានប្រភេទតាមដែលពោលហើយនៃខ្លួន ឬ នៃបុគ្គលដទៃ ព្រមទាំងទ្រព្យសម្បត្តិ

ផ្ទាល់ខ្លួន ឬ សម្គាល់ថា អត្តាដទៃពីបឋវី គប្បីជ្រាបថា ឈ្មោះថា សម្គាល់ក្រៅពីបឋវី ។ នេះឯងជាការសម្គាល់ដោយអំណាចនៃទិដ្ឋិរបស់បុថុជ្ជននោះ ។

កាលបុថុជ្ជននោះ ញ៉ាំងសេចក្តីស្នេហា និង មានះ ឱ្យកើតក្នុងវត្ថុដែលគ្រប់គ្នាសម្គាល់ ដោយការសម្គាល់ ដោយអំណាចនៃទិដ្ឋិនោះឯង គប្បីជ្រាបថា ជាការសម្គាល់ដោយអំណាចនៃតណ្ហា និងមានះ ។ អាចារ្យពួកដទៃពោលថា បុថុជ្ជនចម្រើនបឋវីកសិណ ដែលជាបរិត្តារម្មណ៍ បន្ទាប់ពីនោះ ក៏ប្រកាន់អត្តាដែលមិនមានប្រមាណផ្សេងទៀត ហើយសម្គាល់ថា អត្តារបស់យើងមានសូម្បីក្រៅពីបឋវី យ៉ាងនេះ ឈ្មោះថា រមែងសម្គាល់ក្រៅពីបឋវី ។ ការសម្គាល់ម្យ៉ាង ដែលប្រព្រឹត្តទៅយ៉ាងនេះ គឺ បុថុជ្ជនរមែងប្រកាន់មហាបឋវីតែម្យ៉ាង ។

ក្នុងពាក្យថា **បឋវឹ មេតិ មញ្ញតិ** មានវិនិច្ឆ័យដូចតទៅ នេះ :

ការសម្គាល់ដែលប្រព្រឹត្តទៅក្នុងន័យថា រមែងហួងហែង មហាបឋវីដោយអំណាចនៃតណ្ហាតែប៉ុណ្ណោះ គប្បីជ្រាបថា បានដល់ ការសម្គាល់ដោយអំណាចតណ្ហា ម្យ៉ាងដូចគ្នា ។ ការសម្គាល់ដោយអំណាចតណ្ហានេះ គួរប្រកបចូលក្នុងបឋវីទាំងខាងក្នុង និង ខាងក្រៅ សូម្បីទាំងអស់ មានប្រភេទតាមដែលបានពោលទុកហើយ យ៉ាងនេះថា សក់របស់យើង រោមរបស់យើង ដែករបស់យើង យ៉ាងនេះឯង ។

បទថា **បឋវឹ អភិនន្ទតិ** មានន័យថា បុថុជ្ជន រមែងត្រេកត្រអាល អធិប្បាយថា រីករាយ ជាប់ចិត្តក្នុងបឋវី មានប្រការតាមដែលបានពោលហើយនោះឯង ដោយកិលេស មានតណ្ហាជាដើម ។

បើមានពាក្យសួរថា បើសេចក្តីនេះសម្រេចហើយ ក្នុង២បទនោះថា **បឋវី មញ្ញតិ** ហេតុអ្វី ទើបទ្រង់ពោលទុកយ៉ាងនេះ ?

ឆ្លើយថា ពាក្យនោះ ព្រះបុរាណាចារ្យទាំងឡាយ មិនបានលើកយកមកវិចារណ៍ មតិនេះជាមតិផ្ទាល់ខ្លួន ចាកដំណើរនៃការសម្តែង ឬ ចាកការឃើញទោស ព្រោះលោកដល់ព្រមដោយសីល្បៈនៃការសម្តែងដ៏វិចិត្រដោយន័យផ្សេង ៗ ព្រោះចាក់ផ្ទុះនូវធម្មធាតុណា ធម្មធាតុនោះ ព្រះមានព្រះភាគទ្រង់ចាក់ផ្ទុះហើយដោយប្រពៃ ព្រោះហេតុនោះ កាលទ្រង់សម្តែងការកើតឡើងនៃកិលេស ដោយអំណាចការសម្គាល់ជាខាងដើម ឥឡូវនេះ កាលនឹងសម្តែងដោយអំណាចការរីករាយជាដើម ទើបពោលពាក្យនេះទុក ព្រោះលីលានៃការសម្តែង ។

ន័យម្យ៉ាងទៀត បុថុជ្ជនណា សម្គាល់បឋវី សម្គាល់ក្នុងបឋវី សម្គាល់ចាកបឋវី សម្គាល់ថា បឋវីរបស់យើង បុថុជ្ជននេះ ព្រោះហេតុនៃខ្លួនមិនអាចលះបង់តណ្ហា ឬ ទិដ្ឋិ ដែលអាស្រ័យបឋវីបាន ព្រោះហេតុនោះ ទើបត្រេកអរនឹងបឋវីតែម្យ៉ាង , ម្យ៉ាងទៀត បុថុជ្ជនណា ត្រេកអរនឹងបឋវី បុថុជ្ជននោះរមែងត្រេកអរនឹងទុក្ខ ឯទុក្ខជាទោស ព្រោះដូច្នោះ ទើបទ្រង់ពោលពាក្យនេះទុកថា **ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា នរណាត្រេកអរនឹងបឋវីធាតុ អ្នកនោះត្រេកអរនឹងទុក្ខ នរណាត្រេកអរនឹងទុក្ខ អ្នកនោះរមែងមិនរួចផុតចាកទុក្ខឡើយ ។**

ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សេចក្តីសម្គាល់ និង សេចក្តីត្រេកអរដែលមានបឋវីធាតុជាទីតាំង យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់នាំធាតុដែល

ជាហេតុនៃការសម្គាល់ និង សេចក្ដីត្រេកអររបស់បុថុជ្ជននោះ ទើបត្រាស់ថា **តថាគតពោលថា សេចក្ដីនោះ ព្រោះហេតុអ្វី ព្រោះការមិនដឹង ជាហេតុនៃសេចក្ដីនោះ** ។

ប្រការនោះ មានខ្លឹមសារដូចតទៅនេះ បើមានពាក្យសួរថា បុថុជ្ជននោះ រមែងសម្គាល់នូវបឋវីធាតុនោះ ព្រោះហេតុអ្វី គឺថា ព្រោះហេតុអ្វី ទើបបុថុជ្ជននោះ សម្គាល់ ត្រេកអរ ក្នុងបឋវីធាតុនោះ ? ឆ្លើយថា ព្រះមានព្រះភាគត្រាស់ថា **តថាគតពោលថា សេចក្ដីនោះ ព្រោះបុថុជ្ជននោះកំណត់ដំណើរនោះមិនបាន** មានអធិប្បាយថា ព្រោះហេតុនោះ បុថុជ្ជននោះ មិនបានកំណត់ដឹង ពិតហើយ បុថុជ្ជនណា កាលកំណត់ដឹងនូវបឋវី រមែងកំណត់ដឹងដោយបរិញ្ញា **៣** គឺ **ញាតបរិញ្ញា តីរណបរិញ្ញា** និង **បហានបរិញ្ញា** ។

## បរិញ្ញា ៣

ក្នុងបរិញ្ញា **៣** នោះ **ញាតបរិញ្ញា តីរណបរិញ្ញា បហានបរិញ្ញា** តើដូចម្ដេច ?

**១ - ញាតបរិញ្ញា** គឺ បុថុជ្ជនរមែងកំណត់ដឹងបឋវីធាតុថា បឋវីធាតុនោះ ប្រព្រឹត្តទៅក្នុងខាងក្នុង បឋវីធាតុប្រព្រឹត្តទៅក្នុងខាងក្រៅ នេះជា **លក្ខណៈ** របស់បឋវីធាតុនោះ នេះជា **កិច្ច** នេះជា **បច្ចុប្បដ្ឋាន** ( អាការប្រាកដ ) នេះជា **បទដ្ឋាន** ( ហេតុជិត ) របស់បឋវីធាតុនោះ ដូចពោលមកនេះ ហៅថា **ញាតបរិញ្ញា** ។

**ក្នុងវិសុទ្ធិមគ្គពោលថា** : លោកិយបរិញ្ញាមាន **៣** , ក្នុងបរិញ្ញា **៣** នោះ

បញ្ញាដែលប្រព្រឹត្តទៅ ដោយការកំណត់នូវបច្ចត្តលក្ខណៈ ( លក្ខណៈដោយចំពោះខ្លួន ) នៃធម៌ទាំងឡាយនោះ ក្នុងន័យថា រូបមានការបែកធ្លាយជាលក្ខណៈ វេទនាមានការសោយអារម្មណ៍ ជាលក្ខណៈ ដូច្នេះជាដើម នេះឈ្មោះថា **ញាតបរិញ្ញា** ។

**២. តីរណបរិញ្ញា** គឺ បុថុជ្ជនពិចារណាបឋវីធាតុ ធ្វើឱ្យជាវត្ថុដែលខ្លួនដឹងហើយ យ៉ាងនេះ ដោយអាការ **៤០** ថា មិនទៀង ជាទុក្ខ ជារោគ ជាបូស ជាកូនសរចាក់ដោត ជាវត្ថុអាក្រក់ ជាអាពាធ ជារបស់កន្ទៀត ជារបស់វិនាស ជារបស់ចង្រៃ ជារបស់ឧបទ្រព ជាភ័យ ជាឧបសគ្គ ជារបស់ញាប់ញ័រ ជារបស់បែកធ្លាយ ជារបស់មិនស្ថិតស្ថេរ ជារបស់ពឹងមិនបាន ជារបស់ជ្រកកោនមិនបាន ជាទីស្នាក់អាស្រ័យមិនបាន ជារបស់សង្ឃឹមមិនបាន ជារបស់ទទេ ជារបស់សោះសូន្យ ជារបស់មិនមែនខ្លួន ប្រកបដោយទោស ប្រែប្រួល គ្មានខ្លឹមសារ ជាឫសគល់នៃសេចក្តីលំបាក ជាឃាតក ជារបស់ព្រាត់ប្រាស ប្រកបដោយអាសវៈ ជាសង្ខតៈ ជាមារ ជារបស់មានជាតិជាធម្មតា ជរាជាធម្មតា ព្យាធិជាធម្មតា មរណៈជាធម្មតា សោកជាធម្មតា ខ្សឹកខ្សួលជាធម្មតា ចង្អៀតចង្អល់ជាធម្មតា ជាវត្ថុមានសេចក្តីសៅហ្មងជាធម្មតា ដូចពោលមកនេះ ឈ្មោះថា **តីរណបរិញ្ញា** ។

**ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា** : លក្ខណារម្មណិយវិបស្សនា " វិបស្សនាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ " ដែលប្រព្រឹត្តទៅ ឡើងកាន់សាមញ្ញ-លក្ខណៈនៃធម៌ទាំងឡាយនោះ ក្នុងន័យថា រូបមិនទៀង វេទនាមិនទៀង ជាដើម ឈ្មោះថា **តីរណបរិញ្ញា** ។

៣ - **បហានបរិញ្ញា** គឺ បុគ្គលពិចារណាឃើញយ៉ាងនេះហើយ រមែងលះបង់ឆន្ទរាគៈក្នុងបឋវីធាតុដោយអរហត្តមគ្គ ដូចដែលពោលមកនេះ ឈ្មោះថា **បហានបរិញ្ញា** ។

**ក្នុងគម្ពីរវិសុទ្ធិមគ្គពោលថា** : លក្ខណារម្មណិយវិបស្សនា នោះឯងដែលប្រព្រឹត្តទៅដោយអំណាចការលះបង់វិបល្លាស មានការសម្គាល់ថា ទៀងជាដើម ក្នុងធម៌ទាំងឡាយនោះ នេះឈ្មោះថា **បហានបរិញ្ញា** ។

## ភូមិរបស់បរិញ្ញា

ភូមិរបស់ **ញាតបរិញ្ញា** ចាប់តាំងពីសង្ខារបរិច្ឆេទ " ការកំណត់សង្ខារ គឺ នាមរូប " ទៅរហូតដល់ បច្ចយបរិគ្គហៈ " ការកំណត់បច្ច័យរបស់នាមរូប " ក្នុងរវាងនេះ រមែងមានដោយភាពជាធំ ក្នុងការកំណត់នូវ **បច្ចត្តលក្ខណៈ** ( លក្ខណៈដោយចំពោះ ) នៃធម៌ទាំងឡាយប៉ុណ្ណោះ ។

ភូមិរបស់ **តីរណបរិញ្ញា** ចាប់តាំងពីកលាបសម្មសនៈ ( សម្មសនញាណ ) រហូតដល់ឧទយព្វយានុបស្សនា ( ឃើញទាំងការកើតទាំងការរលត់ ) ក្នុងរវាងនេះ មានភាពជាធំក្នុងការចាក់ធ្លុះនូវ **សាមញ្ញលក្ខណៈ** ប៉ុណ្ណោះ ។

ភូមិរបស់ **បហានបរិញ្ញា** ចាប់ពីភង្គានុបស្សនា ( ឃើញការរលត់ ) ជាដើម កាន់តែច្បាស់ឡើង ត្រឹមពីនេះទៅ ភាពជាធំ រមែងមានដល់អនុបស្សនា **៧** ដែលមានការលះបង់នូវបហាតព្វធម៌ មាននិច្ចសញ្ញាជាដើម ឱ្យសម្រេច ដូច្នេះគឺ ព្រះយោគាវចរ តាមឃើញសង្ខារដោយអាការមិនទៀង រមែងលះបង់នូវនិច្ចសញ្ញាបាន តាមឃើញដោយអាការជាទុក្ខ រមែងលះបង់

នូវ សុខសញ្ញា តាមឃើញដោយអាការជាអនត្តា រមែងលះបង់នូវអត្តសញ្ញា កាលនឿយណាយ រមែងលះបង់នូវនន្ទិ កាលប្រាសចាកនូវសេចក្តីត្រេកអរ រមែងលះបង់នូវរាគៈ ការរំលត់ ( រារាំងហេតុឱ្យកើតឡើងនៃសង្ខារ ) រមែងលះបង់សមុទយៈ ( គឺ ការកើតឡើងនៃសង្ខារ ) ការរលាស់ចោល រមែងលះបង់នូវសេចក្តីប្រកាន់មាំ ។

ក្នុងបរិញ្ញាទាំង ៣ នេះ កាលព្រះយោគាវចរ បានសម្រេចនូវញាត-បរិញ្ញាមួយហើយ បរិញ្ញាក្រៅពីនេះ ក៏ឈ្មោះថា បានសម្រេចផងដែរ ព្រោះសង្ខារបរិច្ឆេទ និង បច្ចយបរិគ្គហៈ នឹងធ្វើឱ្យសម្រេចបាន ព្រោះហេតុនោះខ្ញុំម្ចាស់ទើបពោលថា ហេតុណា កាលតីរណបរិញ្ញាប្រព្រឹត្តទៅ មគ្គាមគ្គញ្ញាណទើបកើតឡើង ហើយតីរណបរិញ្ញានេះ មានក្នុងលំដាប់នៃញាតបរិញ្ញា ព្រោះហេតុនោះ ព្រះយោគាវចរដែលមានបំណងនឹងធ្វើមគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិនោះឱ្យដល់ព្រម ចូរធ្វើសេចក្តីព្យាយាមក្នុងកលាបសម្មសនៈចុះ ។

ម្យ៉ាងទៀត ការកំណត់នាមរូប ឈ្មោះថា **ញាតបរិញ្ញា** , ការកំណត់ដឹង មានការពិចារណាកលាបៈជាដើម រហូតដល់អនុលោមញ្ញាណ ជាទីបំផុត ហៅថា **តីរណបរិញ្ញា** , ញាណក្នុងអរិយមគ្គ ឈ្មោះថា **បហានបរិញ្ញា** ។

ពាក្យថា **បរិញ្ញាបញ្ញា** បានដល់ បញ្ញាជាគ្រឿងកំណត់ដឹង , ពិតហើយ **បញ្ញា** នេះ ទ្រង់ហៅថា **បរិញ្ញា** ។

បុថុជ្ជនណា មានការកំណត់ដឹងបឋវី បុថុជ្ជននោះ រមែងកំណត់ដឹងដោយ **បរិញ្ញា ៣** នេះឯង ។ បើបរិញ្ញាទាំងឡាយនោះ មិនមានដល់បុថុជ្ជននោះ ព្រោះដូច្នោះ បុថុជ្ជននោះ ឈ្មោះថា រមែងសម្គាល់ រមែងរីករាយនឹង

បឋវី ព្រោះមិនបានកំណត់ដឹង ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ មិនបានស្តាប់ ។ ល ។ ...

ពាក្យថា **អាបំ អាបតោ** គប្បីជ្រាបអាបោ ៤ យ៉ាង គឺ លក្ខណអាបោ ១ សសម្ភារអាបោ ១ អារម្មណអាបោ ១ និង សម្មតិអាបោ ១ ។

ក្នុងបណ្តាអាបោ ៤ យ៉ាងនោះ :

**អាបោធាតុ** ដែលពោលទុកក្នុងប្រយោគជាដើមថា បណ្តាអាបោធាតុ **២** យ៉ាងនោះ អាបោធាតុខាងក្នុងដូចម្តេច បានដល់ វត្ថុដែលមានការសើមជ្រួតជ្រាប ប្រមូលផ្តុំ ជាលក្ខណៈចំពោះខ្លួន គឺ អាបោធាតុដែលមានចិត្តគ្រប់គ្រងក្នុងខាងក្នុង ឈ្មោះថា **លក្ខណអាបោ** ។

**អាបោធាតុ** បានដល់ ធាតុទឹកព្រមទាំងគ្រឿងប្រកប មានក្នុងរាងកាយរបស់សត្វ មានទឹកប្រមាត់ជាដើម នេះហៅថា **សសម្ភារអាបោ** ។

**អបោធាតុ** ដែលពោលទុកក្នុងប្រយោគជាដើមថា បុគ្គលរៀនយកអាបោកសិណ រមែងកាន់យកនិមិត្តក្នុងអាបោ នេះឈ្មោះថា **អារម្មណអាបោ** ។

**អាបោធាតុ** បានដល់ ធាតុទឹកដែលសន្មតគ្នាថា ទឹកផឹក ទឹកងូតជាដើម នេះឈ្មោះថា **សម្មតិអាបោ** ។ ពាក្យដ៏សេសទាំងអស់ ដូចគ្នានឹងពាក្យដែលលោកពោលទុកក្នុងបឋវីធាតុនោះឯង ។ តែបើពោលដោយការប្រកបសេចក្តីសុទ្ធៗ អាបោធាតុជាខាងក្នុងមាន **១២** យ៉ាង មានស្លេស្មជាដើម គប្បីជ្រាបថា នេះអាបោធាតុខាងក្នុង ។

អាបោធាតុដែលទ្រង់ពោលទុកថា អាបោធាតុ **២** យ៉ាងនោះ អាបោធាតុខាងក្រៅ ដូចម្តេច គឺ វត្ថុដែលសើម ហូរជ្រួតជ្រាប នៅខាងក្រៅ បានដល់

ការសើម វត្ថុដែលដល់នូវភាពសើម អាបោធាតុដែលមិនមានចិត្តគ្រប់គ្រង ជាខាងក្រៅ គឺ ប្រេង ទឹកសុទ្ធ ទឹកអំពៅ ទឹកឃ្មុំ ទឹកនៅលើផែនដី ទឹកនៅក្នុងអាកាស គប្បីជ្រាបថា ជាអាបោធាតុខាងក្រៅ ។

បទថា **តេជំ តេជតោ** គប្បីជ្រាបតេជោធាតុ ៤ យ៉ាង គឺ លក្ខណ-តេជោ ១ សសម្ភារតេជោ ១ អារម្មណតេជោ ១ សម្មតិតេជោ ១ ។

**តេជោធាតុ** បានដល់ ធាតុភ្លើងដែលជាបរមត្ថ នេះឈ្មោះថា **លក្ខណ-តេជោ** ។

**តេជោធាតុ** បានដល់ ធាតុភ្លើងព្រមទាំងគ្រឿងប្រកប មាននៅក្នុងរាងកាយ មានភ្លើងធ្វើកាយឱ្យកក់ក្តៅ ភ្លើងក្តៅខ្លាំងនាំឱ្យគ្រុន ភ្លើងក្តៅខ្លាំងធ្វើរាងកាយឱ្យរិបរិត ភ្លើងធ្វើរាងកាយឱ្យចាស់ សក់ស្កូវជាដើម ភ្លើងដែលរំលាយអាហារ ។

តេជោធាតុខាងក្រៅ បានដល់ តេជោធាតុដែលមិនមាន ចិត្តគ្រប់គ្រង បានដល់ ភ្លើងព្រៃ ភ្លើងអុស ភ្លើងចំបើង ជាដើម ឬ កម្តៅដែលកើតពីព្រះអាទិត្យ ទាំងនេះជាសសម្ភារតេជោ ។

**តេជោធាតុ** បានដល់ តេជោកសិណ ឬ ភ្លើងដែលជាអារម្មណ៍របស់សមថៈ នេះជា **អារម្មណតេជោ** ។

**តេជោធាតុ** បានដល់ ភ្លើងដែលសន្មតគ្នាថា ភ្លើងអគ្គិសនី ភ្លើងចង្កៀងជាដើម នេះគឺ **សម្មតិតេជោ** ។

បទថា **វាយំ វាយតោ** គប្បីជ្រាបវាយោធាតុ ៤ យ៉ាង បានដល់ លក្ខណវាយោ១ សសម្ភារវាយោ១ អារម្មណវាយោ១ សម្មតិវាយោ១ ។

ក្នុងបណ្តាវាយោធាតុ ៤ យ៉ាងនោះ គឺ **វាយោធាតុ** បានដល់ ធាតុខ្យល់ដែលជាបរមត្ថ នេះគឺ **លក្ខណវាយោ** ។

**វាយោធាតុ** បានដល់ ធាតុខ្យល់ព្រមទាំងគ្រឿងប្រកប មានទាំងខាងក្នុងនិងខាងក្រៅ ។ វាយោធាតុក្នុងរាងកាយសត្វ មានខ្យល់បក់ឡើងលើ ខ្យល់បក់ចុះក្រោម ខ្យល់បក់ក្នុងពោះ ខ្យល់បក់ក្នុងពោះវៀន ខ្យល់បក់តាមអវយវៈតូចធំ ខ្យល់ដង្ហើមចេញចូល ហៅថា **វាយោខាងក្នុង** ។ **វាយោធាតុនៅក្រៅ** គឺ ខ្យល់មកពីទិសខាងត្បូង ខ្យល់ទិសខាងជើង ខ្យល់ព្យុះជាដើម ហៅថា វាយោ-ធាតុខាងក្រៅ នេះគឺ **សសម្ភារវាយោ** ។

**វាយោធាតុ** បានដល់ វាយោកសិណ ឬ ខ្យល់ជាអារម្មណ៍របស់សមថកម្មដ្ឋាន នេះ **អារម្មណវាយោ** ។

**វាយោធាតុ** បានដល់ ខ្យល់បក់ទៅ បក់មកជាធម្មតា នេះហៅថា **សម្មុតិវាយោ** ។

ន័យដែលឈ្មោះថា **លក្ខណៈ** នេះ ក្នុងនេត្តិបករណ៍មានយ៉ាងនេះថា កាលពោលដល់ធម៌សុទ្ធហើយ ដោយធម៌តែម្យ៉ាងហើយ ន័យដែលលោកពោលមកនោះ មានប្រមាណប៉ុណ្ណេះ ព្រោះកាលកាន់យកនូវមហាភូតរូប ៤ ហើយ សូម្បីឧបាទាយរូប ក៏បានកាន់យកផងដែរ ព្រោះឧបាទាយរូបនោះ មិនកន្លងផុតពីលក្ខណរូបឡើយ មហាភូតរូប និង ឧបាទាយរូបនោះ ជារូបក្ខន្ធ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលត្រាស់ថា បុថុជ្ជនដែលមិនបានស្តាប់ រមែងសម្គាល់ បថវី អាបោ តេជោ វាយោ គឺ ទ្រង់ត្រាស់ថា គេរមែងពិចារណាឃើញ រូបជាខ្លួន ខ្លួនមានរូប រូបមានក្នុងខ្លួន ខ្លួនមានក្នុងរូប ។

**ក្នុងន័យនេះ គប្បីជ្រាបភាពផ្សេងគ្នាថា បណ្តាទិដ្ឋិ ៤ ប្រការនោះ ជាឧច្ឆេទទិដ្ឋិ ១ ជាសស្សតទិដ្ឋិ ៣ ។**

( ចប់ ធាតុមនសិការបព្វៈ )

# ៦-នវសីវថិកាបព្វៈ

**១** - ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ទោះស្លាប់អស់ ១ ថ្ងៃក្តី ស្លាប់អស់ ២ ថ្ងៃក្តី ស្លាប់អស់ ៣ ថ្ងៃក្តី ដែលកំពុងហើម មានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ដូចម្តេចមិញ ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈបែបនោះ មិនបានឡើយ ។ ភិក្ខុពិចារណាឃើញនូវ កាយក្នុងកាយ ខាងក្នុង ជាប្រក្រតី ( ដោយការកំណត់នូវអសុភ មានអសុភកំពុងហើមជាដើម ) គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។ បេ ។

**២** - ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលនៅក្នុងព្រៃស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ត្រដក់ គម្រង់ទាំងឡាយកំពុងចឹកស៊ីក្តី ត្មាតទាំងឡាយកំពុងចឹកស៊ីក្តី សត្វស្វានទាំងឡាយកំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី បាណកជាតិ ( សត្វល្អិត ១ មានរុយជាដើម ) ទាំងឡាយផ្សេងៗ កំពុងរូងជញ្ជក់ស៊ីក្តី ដូចម្តេចមិញ ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈនោះ ) មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាវៈដូច្នោះពុំបានឡើយ ។ ភិក្ខុពិចារណា ឃើញនូវកាយក្នុងកាយ ជាខាងក្នុងជាប្រក្រតី ដោយការកំណត់នូវអសុភ មានអសុភដែលពួកសត្វកំពុងចឹកស៊ីជាដើម គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញ

នូវកាយក្នុងកាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុងនិងខាងក្រៅ គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការកើតឡើង និងធម៌ គឺ ការរលត់ទៅនៃកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនបញ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

**៣** - ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែរាងឆ្អឹង ប្រកបដោយសាច់នឹងឈាម មានសរសៃ ជាគ្រឿងចងដូចម្ដេចមិញ ។ បេ ។

**៤** - សរីរៈនៅសល់តែរាងឆ្អឹង ឥតមានសាច់ ប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ។ បេ ។

**៥** - សរីរៈនៅសល់តែរាងឆ្អឹង មិនមានសាច់ និងឈាម មានតែសរសៃជាគ្រឿងចង ។ បេ ។

**៦** - សរីរៈនៅសល់តែរាងឆ្អឹងទទេ មិនមានសរសៃចងរួបរឹត ខ្ទាត់ខ្ទាយ រាត់រាយទៅក្នុងទិសតូចនិងទិសធំ គឺ ឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅ

ដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែកឆ្អឹងទ្រនុងខ្នងទៅដោយឡែក ឆ្អឹងជំនីរទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកំភួនដៃទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កាទៅដោយឡែក ធ្មេញទៅដោយឡែក លលាដ៏ក្បាលទៅដោយឡែក ( ដូចម្ដេចមិញ ) ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោតក៏គង់នឹងមានសភាវៈដូច្នេះ គង់នឹងក្លាយទៅជាដូច្នេះ នឹងកន្លងនូវភាវៈដូច្នេះពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុងជាប្រក្រតី ( ដោយការកំណត់នូវសរីរៈស្លាប់ដែលសល់តែរាងឆ្អឹងជាដើម ) គ្រប់ឥរិយាបថទាំង ៤ យ៉ាង នេះឯង ពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវកាយក្នុងកាយជាខាងក្នុង និង ខាងក្រៅ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ គឺ ការកើតឡើង និងធម៌ គឺ ការរលត់ទៅក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជា

ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

**៧** - ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែរាងឆ្អឹងទទេ មានសម្បុរ-ស ដូចសម្បុរនៃស័ង្ខ ។ បេ ។

**៨** - សរីរៈនៅសល់តែឆ្អឹងទទេ រោយរាយជាពុំនូក ៗ កន្លងហួសទៅមួយឆ្នាំហើយ ។ បេ ។

**៩** - សរីរៈនៅសល់តែឆ្អឹងទទេ ពុកផុយខ្ទេចខ្ទី ជាកម្ទេចតូច កម្ទេចធំផ្សេង ៗ ( ដូចម្ដេចមិញ ) ។ ភិក្ខុនោះ ( ក៏ បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបនឹងកាយនេះឯងថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាវៈដូច្នោះគង់នឹងក្លាយទៅជាយ៉ាងនោះ នឹងកន្លងនូវភាវៈដូច្នោះ ពុំបានឡើយ ។ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវកាយក្នុងកាយ ជាខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណា ឃើញនូវកាយក្នុងកាយ ជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ទាំងពិចារណាឃើញធម៌ដែលសូន្យទៅក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ គឺ ការកើតឡើងនៃកាយ និង ធម៌ គឺ ការរលត់ទៅនៃកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។

មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយនេះមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ

ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង **៤** ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវកាយក្នុងកាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង **៤** យ៉ាងនេះឯង ។

## អដ្ឋកថា

ប្រការថា **សោ ឥមមេវ កាយំ** មានន័យថា ភិក្ខុប្រើញាណបង្អោន នូវកាយរបស់ខ្លួននេះ ទៅប្រៀបធៀបនឹងសាកសព ប្រៀបយ៉ាងណា ប្រៀបថា កាយនេះនឹងមានសភាពយ៉ាងនោះជាធម្មតា គង់ជាដូច្នោះ នឹងកន្លងផុតនូវសភាពបែបនោះ មិនបានឡើយ ។ លោកអធិប្បាយថា កាយនេះដែលនៅឈរ ដើរបានជាដើម ក៏ព្រោះមានធម៌ ៣ ប្រការ គឺ **អាយុ ភ្លើងធាតុ** និង **វិញ្ញាណ** កាលបើធម៌ ៣ ប្រការនេះ ប្រាសទៅហើយ កាយនេះនឹងមានសភាពបែប នោះជាធម្មតា គឺ គង់មានសភាពរលួយស្អុយដូចគ្នា ត្រូវតែដូច្នោះឯង គឺ នឹងទៅជាប្រភេទសាកសពហើមប៉ោងជាដើម យ៉ាងនោះដូចគ្នា មិនកន្លងសភាពបែបនោះបានឡើយ គឺមិនកន្លងភាពជាសាកសពហើមប៉ោង យ៉ាងនោះ បានឡើយ ។

ពាក្យថា **ឬខាងក្នុង** មានន័យថា ពិចារណាឃើញកាយក្នុងកាយរបស់ខ្លួន ក្នុងកាយរបស់អ្នកដទៃ ឬ ក្នុងកាយរបស់ខ្លួនតាមកាល កាយរបស់អ្នកដទៃតាមកាល ដោយការកំណត់ សាកសពដែលហើយប៉ោង ជាដើមយ៉ាងនេះឯង ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងព្រៃខ្មោច ៩ ប្រភេទ ហើយ កាលទ្រង់នឹងបញ្ចប់នូវកាយានុបស្សនា ទើបត្រាស់ថា **ឯវំ ខោ ភិក្ខវេ** យ៉ាងនេះឯងម្នាលភិក្ខុទាំងឡាយជាដើម ។

**បរមត្ថមញ្ជូសាមហាដីកា :** ក្នុង **នវសីវថិកាបព្វៈ** នេះ ទ្រង់សម្ដែងដោយអំណាចវិបស្សនាសុទ្ធ ។

កាយានុបស្សនាមាន **១៤** បព្វៈ គឺ អានាបានបព្វៈ១ ឥរិយាបថបព្វៈ១ ចតុសម្បជញ្ញបព្វៈ១ បដិក្កូលមនសិការបព្វៈ ១ ធាតុមនសិការបព្វៈ១ សីវថិកាបព្វៈ ៩ សេចក្ដីពណ៌នាមានយ៉ាងដូច្នេះឯង ។

( ចប់ កាយានុបស្សនាសតិប្បដ្ឋានភាវនា )

# វេទនានុបស្សនាសតិប្បដ្ឋាន

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងពាក្យថា ភិក្ខុពិចារណាឃើញ វេទនាក្នុងវេទនា ចិត្តក្នុងចិត្ត ធម៌ក្នុងធម៌ទាំងឡាយ ។ ល ។ កម្ចាត់បង់អភិជ្ឈា និងទោមនស្សក្នុងលោក ប្រយោជន៍ក្នុងការពោលដដែល ៗ នៃវេទនាជាដើមក្នុងពាក្យមានជាអាទិថា **វេទនាសុ វេទនានុបស្សី** ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ គប្បីជ្រាបតាមន័យដូចបានពោលហើយ ក្នុងកាយានុបស្សនានោះចុះ ។ ម្យ៉ាងទៀត ប្រការថា ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ពិចារណាឃើញចិត្តក្នុងចិត្ត ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយនេះ មានវិនិច្ឆ័យដូច្នេះ , វេទនា ក៏បានដល់ វេទនា **៣** ( គឺ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ) វេទនា **៣** នោះ ជាលោកិយតែម្យ៉ាង សូម្បីចិត្តក៏ជាលោកិយ ធម៌ទាំងឡាយក៏ជាលោកិយដូចគ្នា ។ ការចែក **វេទនា ចិត្ត ធម៌** នោះនឹងប្រាកដក្នុងនិទ្ទេសវារៈ ។ ចំណែកក្នុងឧទ្ទេសវារៈនេះ ភិក្ខុពិចារណាឃើញវេទនា **៣** នោះ ដោយប្រការដែលខ្លួន គប្បីពិចារណាឃើញ ក៏គួរជ្រាបថា ជាអ្នកពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ ។ សូម្បីក្នុងចិត្តនិងធម៌ ក៏ដូចគ្នា ។

សួរថា ភិក្ខុពិចារណាឃើញវេទនាក្នុងវេទនា តើដូចម្ដេច ?

ឆ្លើយថា ពិចារណាឃើញសុខវេទនា ថាជាទុក្ខ ឃើញទុក្ខវេទនាថាដូចជាកូនសរ ឃើញអទុក្ខមសុខវេទនាថាជា របស់មិនទៀង ។

ដូចដែលទ្រង់ត្រាស់ទុកថា :

**ភិក្ខុណាឃើញសុខវេទនា ថាជាទុក្ខ ឃើញទុក្ខវេទនាថា ដូចជាកូនសរ**

**ឃើញអទុក្ខមសុខវេទនា ថាជារបស់មិនទៀង ភិក្ខុនោះឯង ជាអ្នកឃើញត្រូវ នឹងជាអ្នកស្ងប់ ហើយត្រាច់ទៅ ។**

ម្យ៉ាងទៀត ភិក្ខុពិចារណាឃើញវេទនាទាំងអស់នោះថា ជាទុក្ខផង ដែរ ។ យើងពោលថា វេទនាគ្រប់យ៉ាង ក្នុងបណ្តាវេទនាទាំងនោះ គប្បី ពិចារណាឃើញវេទនាទាំងនោះ ដែលជាសុខ ជាទុក្ខ ( មានការផ្លាស់ប្តូរគ្នា )។ ដូចដែលទ្រង់ត្រាស់ ទុក្ខថា សុខវេទនា ជាសុខពេលកើតឡើង និងតាំងនៅ ជាទុក្ខពេលប្រែប្រួលទៅ ដូច្នេះពាក្យទាំងអស់ អ្នកសិក្សា គប្បីស្វែងយល់ឱ្យ បានទូលំទូលាយចុះ ( ចប់អដ្ឋកថា ឧទ្ទេសវារៈ ) ។

**អភិធម្មាវតា : វេទនាខន្ធ** គឺ សភាវៈយ៉ាងណាមួយ ដែលមានការ សោយនូវអារម្មណ៍ ។

**គម្ពីរវិសុទ្ធិមគ្គ** : ដែលហៅថា **វេទនាខន្ធ** ព្រោះជាធម្មជាតិដែលមាន ការសោយរសនៃអារម្មណ៍ ជាលក្ខណៈគ្រប់យ៉ាង ។

ធម្មជាតិដែលមានការសោយរសនៃអារម្មណ៍ ជាលក្ខណៈ គឺ វេទនានោះ ឯង ។ ដូចព្រះសារីបុត្តត្ថេរពោលនឹងព្រះមហាកោដ្ឋិកត្ថេរថា " **ម្នាលអាវុសោ ព្រោះហេតុដែលធម្មជាតិនោះឯង សោយរសនៃអារម្មណ៍ រមែងដឹងថា ជា សុខ ជាទុក្ខ ព្រោះហេតុនោះ ទើបហៅថា វេទនា** " ។

វេទនានោះឯង កាលបើពោលដោយសភាវៈ គឺ មានតែម្យ៉ាងដោយ លក្ខណៈ គឺ **មានការសោយអារម្មណ៍** , តែបើពោលដោយជាតិ មាន **៣** យ៉ាង គឺ **កុសល អកុសល** និង **អព្យាកតៈ** ក្នុង **៣** យ៉ាងនេះ គប្បីជ្រាបថា វេទនាដែល សម្បយុត្តជាមួយកុសលចិត្ត ដែលពោលទុកថា កាមាវចរកុសលចិត្ត មាន **៨**

ដែលផ្សេងគ្នាដោយ **សោមនស្ស ឧបេក្ខា ញាណ** និង **សង្ខារ** ដូច្នេះជាដើម ចាត់ជាកុសលវេទនា បើសម្បយុត្តជាមួយនឹងអកុសលចិត្ត ចាត់ជាអកុសលវេទនា បើសម្បយុត្តជាមួយអព្យាកតចិត្ត ចាត់ជាអព្យាកតវេទនា ។

ពាក្យថា **វិញ្ញាណ** និង **ចិត្ត** នេះអាចប្រើផ្លាស់ប្តូរគ្នាបាន ខុសគ្នាតែព្យញ្ជនៈ តែអត្ថដូចគ្នា ដូចពាក្យថា **កុសលចិត្ត** ឬ **កុសលវិញ្ញាណ** ។

វេទនានោះ បើពោលតាមសភាវៈ មាន **៥** គឺ សុខវេទនា ទុក្ខវេទនា សោមនស្សវេទនា ទោមនស្សវេទនា និង ឧបេក្ខាវេទនា ក្នុងវេទនា **៥** នោះ :

**១. សុខ** សម្បយុត្តជាមួយកាយវិញ្ញាណដែលជាកុសលវិបាក ។

**២. ទុក្ខ** សម្បយុត្តជាមួយកាយវិញ្ញាណដែលជាអកុសលវិបាក ។

**៣. សោមនស្ស** សម្បយុត្តជាមួយចិត្ត **៦២** ដួង បានដល់ :

**- ក្នុងកាមាវចរចិត្ត ១៨ ដួង មាន :**

| | | | |
|---|---|---|---|
| កុសលចិត្ត | ៤ | សហេតុកវិបាក | ៤ |
| អហេតុកវិបាក | ១ | សហេតុកកិរិយា | ៤ |
| អហេតុកកិរិយា | ១ | អកុសលចិត្ត | ៤ |

**- ក្នុងរូបាវចរចិត្ត ១២ ដួង** ( វៀរបញ្ចមជ្ឈាន ) **មាន :**

កុសល ៤ វិបាក ៤ កិរិយា ៤

**- ក្នុងលោកុត្តរចិត្ត** លោកុត្តរចិត្ត ដែលមិនប្រកបដោយឈាន មិនមាន ហេតុនោះ លោកុត្តរចិត្ត ៨ ក៏បានជា ៤០ ដោយអំណាចនៃឈាន ៥ , ក្នុងលោកុត្តរចិត្ត ៤០ នោះ វៀរចិត្តដែលប្រព្រឹត្តទៅក្នុងបញ្ចមជ្ឈាន ៨ សល់ **៣២** ។

រួមទាំងអស់ **១៨** + **១២** + **៣២** = **៦២** ។

**៤. ទោមនស្ស** សម្បយុត្តជាមួយអកុសលចិត្ត **២** ដួង ។

**៥. ឧបេក្ខា** សម្បយុត្តជាមួយចិត្ត **៥៥** ដួង ដ៏សេស ។

## លក្ខណៈនៃវេទនា ៥

**១-សុខវេទនា** មានការសោយនូវផោដ្ឋព្វៈ គួរជាទីប្រាថ្នា ជាលក្ខណៈ , មានការធ្វើសម្បយុត្តធម៌ឱ្យចម្រើន ជាកិច្ច , មានសេចក្តីសប្បាយកាយ ជាអាការប្រាកដ , មានកាយបសាទ ជាហេតុជិត ។

**២-ទុក្ខវេទនា** មានការសោយផោដ្ឋព្វៈមិនជាទីប្រាថ្នា ជាលក្ខណៈ , មានការធ្វើសម្បយុត្តធម៌ឱ្យខ្សោយចុះ ជាកិច្ច , មានការមិនសប្បាយកាយ ជាអាការប្រាកដ , មានកាយបសាទ ជាហេតុជិត ។

**៣-សោមនស្សវេទនា** មានការសោយអារម្មណ៍ ជាទីគាប់ចិត្ត ជាលក្ខណៈ , មានការប្រសព្វនឹងអាការៈជាទីប្រាថ្នា ជាកិច្ច , មានការសប្បាយចិត្ត ជាអាការប្រាកដ , មានបស្សទ្ធិ ( ការស្ងប់នាមកាយ ) ជាហេតុជិត ។

**៤-ទោមនស្សវេទនា** មានការសោយអារម្មណ៍មិនជាទីគាប់ចិត្ត ជាលក្ខណៈ , មានការប្រសព្វនឹងអាការមិនជាទីគាប់ចិត្ត ជាកិច្ច , មានការមិនសប្បាយផ្លូវចិត្ត ជាអាការប្រាកដ , មានហទយវត្ថុតែម្យ៉ាងប៉ុណ្ណោះ ជាហេតុជិត ។

**៥-ឧបេក្ខាវេទនា** មានការសោយអារម្មណ៍ជាកណ្តាល ជាលក្ខណៈ , មានការរក្សាសម្បយុត្តធម៌មិនឱ្យចម្រើនឡើង មិនឱ្យសៅហ្មង ជាកិច្ច , មាន

ភាពស្ងប់ ជាអាការប្រាកដ , មានចិត្តដែលមិនប្រកបដោយបីតិ ជាហេតុជិត ។

ព្រះយោគី គប្បីពិចារណាឃើញដោយអនុបស្សនា **៧** មានអនិច្ចានុបស្សនាជាដើម ។

## ការពិចារណានូវវេទនា

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយ វិធីដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលទទួលសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា កាលទទួលទុក្ខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា កាលទទួលអទុក្ខមសុខវេទនាក្តី ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា ។

កាលទទួលសុខវេទនាប្រកបដោយអាមិសៈក្តី ( **អដ្ឋកថា** សោមនស្សវេទនា ដែលអាស្រ័យនូវកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារ ៦ គឺ ទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ហៅថា **សាមិសសុខ** ) ក៏ដឹងច្បាស់ថា អត្មាអញទទួលសុខវេទនាប្រកបដោយអាមិសៈ , កាលទទួលសុខវេទនាដែលឥតអាមិសៈក្តី ( **អ.** សោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ " **ដីកា** : នេក្ខម្មៈបានដល់ កុសល " ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ) ក៏ដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនាដោយឥតអាមិសៈ, កាលទទួលទុក្ខវេទនាប្រកបដោយអាមិសៈ ( **អ.** គឺ ទោមនស្សវេទនាដែលអាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ) ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា ប្រកបដោយអាមិសៈ , កាល

ទទួលទុក្ខវេទនាដែលឥតអាមិសៈ ( **អ.** គឺ ទោមនស្សវេទនាដែលអាស្រ័យនេក្ខម្មៈ ) ក៏ដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនាដោយឥតអាមិសៈ , កាលទទួលអទុក្ខមសុខវេទនា ប្រកបដោយអាមិសៈក្តី ( **អ .** គឺ ឧបេក្ខាវេទនាអាស្រ័យកាមគុណ ៥ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ) ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាប្រកបដោយអាមិសៈ , កាលទទួលអទុក្ខមសុខវេទនាឥតអាមិសៈក្តី ( **អ.** គឺ ឧបេក្ខាវេទនាអាស្រ័យនេក្ខម្មៈ ប្រព្រឹត្តទៅក្នុងទ្វារ ៦ ) ក៏ដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនាដោយឥតអាមិសៈ ។

ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជាខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយខាងក្នុង និង ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផងពិចារណាឃើញធម៌ គឺ ការកើតឡើងនៃវេទនា គ្រប់ឥរិយាបថទាំង ៤ ផងពិចារណាឃើញធម៌ គឺ ការរលត់ទៅនៃវេទនា គ្រប់ឥរិយាបថទាំង ៤ ផងពិចារណាឃើញធម៌ គឺ ការកើតឡើង និងធម៌ គឺ ការរលត់ទៅនៃវេទនាទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី ( ដែលជាគ្រឿងកំណត់នូវវេទនា ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា វេទនាទាំងឡាយ មានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោក ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ

ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះ ឯង ។

## អដ្ឋកថា

បទថា **សុខវេទនា** មានន័យថា ភិក្ខុកំពុងសោយវេទនាដែលជាសុខតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី ក៏ដឹងច្បាស់ថា យើងសោយនូវសុខវេទនា ។ សូម្បីទារកដែលនៅក្មេងខ្ចី ក៏មានការសោយនូវសុខវេទនាដែរ នៅពេលបៅដោះ មានការដឹងច្បាស់នូវការសោយសុខវេទនា ក៏ពិត , តែថា សុខវេទនាជាដើមនេះ ទ្រង់មិនបានត្រាស់សំដៅយកការដឹងដូច្នោះទេ ។ ព្រោះការដឹងដូច្នោះ មិនអាចលះបង់ការឃើញថា ជាសត្វបាន មិនអាចដកនូវការសម្គាល់ថា ជាសត្វបាន មិនមែនជាកម្មដ្ឋាន ឬ សតិប្បដ្ឋានភាវនាឡើយ ។ ចំណែកការដឹងច្បាស់របស់ភិក្ខុនេះ លះបង់ការឃើញថាជាសត្វបាន ទាំងជាកម្មដ្ឋាន ទាំងជាសតិប្បដ្ឋានភាវនា ។ ពាក្យនេះទ្រង់ត្រាស់ដល់ការសោយសុខវេទនាប្រកបដោយការដឹងខ្លួន យ៉ាងនេះថា **នរណាសោយ ការសោយរបស់នរណាសោយបានព្រោះអ្វី** ។

ពាក្យថា **នរណាសោយ** គឺ មិនមែនជាសត្វ ឬ បុគ្គលណា ១ សោយឡើយ ។ ពាក្យថា **សោយបានព្រោះអ្វី** ឆ្លើយថា ព្រោះវេទនារបស់ភិក្ខុនោះមានវត្ថុជាអារម្មណ៍ម្យ៉ាង ហេតុនោះ ទើបមានការដឹងយ៉ាងនេះថា សត្វទាំង-ឡាយសោយនូវវេទនា ព្រោះធ្វើវត្ថុឱ្យជាទីតាំងនៃវេទនា មានសុខវេទនាជាដើមនោះ ១ ឱ្យជាអារម្មណ៍ ។ ពាក្យថា **យើងសោយនូវវេទនានោះ** គ្រាន់តែជាសម្មតិវោហារប៉ុណ្ណោះ ព្រោះកាន់យកការប្រព្រឹត្តទៅនៃវេទនានោះ ។

លោកកំណត់ដឹងថា សត្វទាំងឡាយសោយនូវវេទនា ព្រោះធ្វើវត្ថុឱ្យជាអារម្មណ៍ យ៉ាងនេះ គប្បីជ្រាបថា លោករមែងដឹងច្បាស់ថា ត្រឹមតែការសោយនូវសុខវេទនា ។

## វេទនាជាអរូបកម្មដ្ឋាន

ព្រះមានព្រះភាគ ទ្រង់បានត្រាស់រូបកម្មដ្ឋាននោះហើយ ពេលទ្រង់ត្រាស់ដល់អរូបកម្មដ្ឋាន ទ្រង់ក៏ត្រាស់ដល់ការកើតឡើងនៃវេទនាទាំងឡាយ ព្រោះកម្មដ្ឋានរមែងប្រាកដច្បាស់ ដោយអំណាចនៃវេទនា ដូច្នោះហើយ ទើបទ្រង់ត្រាស់នូវអរូបកម្មដ្ឋានដោយអំណាចនៃវេទនា ព្រោះថា បើដោយអំណាចផស្សៈ ឬដោយអំណាចចិត្ត កម្មដ្ឋានមិនអាចប្រាកដច្បាស់បានឡើយ ប្រាកដដូចនៅក្នុងទីងងឹត ។ ទ្រង់បានត្រាស់ទុកក្នុងសក្កបញ្ហសូត្រថា កម្មដ្ឋានមាន **២** យ៉ាង គឺ រូបកម្មដ្ឋាន១ អរូបកម្មដ្ឋាន១ ដូច្នេះឯង ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងវេទនានុបស្សនាសតិប្បដ្ឋាននោះ ក្នុងពាក្យថា **សុខវេទនា** ដូច្នេះជាដើម មានបរិយាយនៃការដឹងច្បាស់ ក្នុងន័យម្យ៉ាងទៀតដូចតទៅនេះ :

សេចក្ដីថា **សុខំ វេទនំ វេទិយាមីតិ បជានាតិ** ដឹងច្បាស់ថា យើងសោយនូវសុខវេទនា មានន័យថា កាលសោយនូវសុខវេទនា ក្នុងខណៈសោយនូវសុខវេទនានោះ ក៏មិនមានទុក្ខវេទនា ទើបដឹងច្បាស់ថា យើងសោយនូវសុខវេទនា ។ ព្រោះដូច្នោះ ទើបឈ្មោះថា វេទនាមិនទៀង មិនស្ថិតស្ថេរ មានសេចក្ដីប្រែប្រួលជាធម្មតា ព្រោះក្នុងខណៈនោះទុក្ខវេទនា ក៏មិនប្រាកដ ហើយ

មុននោះសុខវេទនាក៏មិនទាន់មាន ។ លោកដឹងខ្លួនក្នុងសុខវេទនានោះ យ៉ាងនេះ ។ សមពិត ដូចដែលទ្រង់ត្រាស់ថា ម្នាលអគិវេស្សនៈ សម័យណាសោយសុខវេទនា សម័យនោះមិនមានការសោយនូវទុក្ខវេទនា ទាំងមិនមានការសោយនូវអទុក្ខមសុខវេទនា រមែងសោយនូវសុខវេទនានោះ តែប៉ុណ្ណោះ , សម័យណាសោយនូវទុក្ខវេទនា ។ ល ។ សោយអទុក្ខមសុខវេទនា សម័យនោះមិនមានការសោយនូវសុខវេទនា មិនមានការសោយនូវទុក្ខវេទនា សោយតែអទុក្ខមសុខវេទនាតែប៉ុណ្ណោះ , ម្នាលអគិវេស្សនៈ សូម្បីសុខវេទនាក៏មិនទៀងមានបច្ច័យតាក់តែង អាស្រ័យបច្ច័យកើតឡើង មានសេចក្ដីសាបសូន្យទៅជាធម្មតា មានសេចក្ដីវិនាសទៅជាធម្មតា មានការរលត់ទៅជាធម្មតា សូម្បីទុក្ខ-វេទនា ។ ល ។ សូម្បីអទុក្ខមសុខវេទនា ក៏មិនទៀង ។ ល ។ មានសេចក្ដីរលត់ទៅជាធម្មតា ម្នាលអគិវេស្សនៈ អរិយសាវ័កបានស្ដាប់ហើយ ឃើញយ៉ាងនេះ រមែងនឿយណាយ រមែងប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេកទើបរួចផុត កាលបើរួចផុតហើយ រមែងដឹងច្បាស់ថា រួចផុតហើយ ក៏ដឹងច្បាស់ថាជាតិអស់ហើយ ព្រហ្មចរិយធម៌នៅចប់ហើយ កិច្ចដែលគួរធ្វើ បានធ្វើស្រេចហើយ កិច្ចដទៃដើម្បីជាយ៉ាងនេះ មិនមានទៀតឡើយ ។

## វេទនាក្នុង – វេទនាក្រៅ

សេចក្ដីថា **ឥតិ អជ្ឈត្តំ វា - ឬខាងក្នុង** មានន័យថា ពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយរបស់ខ្លួន ក្នុងវេទនាទាំងឡាយរបស់អ្នកដទៃ ឬក្នុងវេទនាទាំងឡាយរបស់ខ្លួនតាមកាល របស់បុគ្គលដទៃតាមកាល ដោយការ

កំណត់នូវសុខវេទនាជាដើម យ៉ាងនេះ ។ ចំណែកក្នុងសេចក្ដីថា **សមុទយ-ធម្មានុបស្សី វា** ពិចារណាឃើញធម៌ គឺ ការកើតឡើងនៃវេទនាទាំងឡាយនេះ មានវិនិច្ឆ័យថា ភិក្ខុនោះឃើញការកើតឡើង និង ការវិនាសទៅនៃវេទនាទាំងឡាយនោះ ដោយអាការ **៥** យ៉ាង ថា ព្រោះអវិជ្ជាកើត ទើបកើតវេទនាជាដើម ដូច្នេះ ។

ហេតុឱ្យកើតឡើងនៃវេទនា **៥** យ៉ាង គឺ : អវិជ្ជា តណ្ហា ឧបាទាន កម្ម និង អាហារ ( ផស្សៈ ) ។

គប្បីជ្រាបថា លោកពិចារណាឃើញធម៌ គឺ ការកើតឡើងនៃវេទនាទាំងឡាយ និងពិចារណាឃើញធម៌ គឺ ការរលត់ទៅនៃវេទនាទាំងឡាយ ឬ ពិចារណាឃើញធម៌ គឺ ការកើតឡើងនៃវេទនាទាំងឡាយតាមកាល ពិចារណាឃើញធម៌ គឺ ការរលត់ទៅនៃវេទនាទាំងឡាយតាមកាល ។

## អដ្ឋកថា សឡាយតនវិភង្គសូត្រ

ឈ្មោះថា **សោមនស្សដែលអាស្រ័យផ្ទះ** បានដល់ សោមនស្សដែលអាស្រ័យកាមគុណប្រព្រឹត្តទៅក្នុងទ្វារ ៦ គឺ ក្នុងវេទនាទាំងឡាយនោះ សោ-មនស្សដែលអាស្រ័យផ្ទះ ៦ យ៉ាង តើដូចម្ដេច កាលបុគ្គលពិចារណាឃើញនូវការបាននូវរូប ដែលគប្បីដឹងច្បាស់ដោយភ្នែក ជារូបគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត គួររីករាយ ជារបស់ប្រចាំលោក ដោយការបានផ្ទាល់ ឬ ការតាមត្រិះរិះដល់រូបដែលធ្លាប់បានមកក្នុងកាលមុន ដែលកន្លងទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ទើបកើតសោមនស្សឡើង សោមនស្សបែបនេះ

ហៅថា **សោមនស្សអាស្រ័យផ្ទះ** ។

ឈ្មោះថា **សោមនស្សមិនអាស្រ័យផ្ទះ** បានដល់ សោមនស្សដែលកើតឡើងដល់អ្នកដែលមានសោមនស្សថា យើងបានស្វែងយល់ក្នុងវិបស្សនាហើយ ជាអ្នកមានសេចក្ដីត្រេកអរ ក្នុងការផ្ដើមចម្រើននូវវិបស្សនា ដោយអំណាចនៃត្រៃលក្ខណ៍ មានអនិច្ចំជាដើម ក្នុងអារម្មណ៍គួរជាទីពេញចិត្ត ដែលមកកាន់ទ្វារទាំង ៦ យ៉ាងនេះ ជាដើមថា សោមនស្សដែលអាស្រ័យការចេញចាកផ្ទះទាំង ៦ យ៉ាង ដូចម្ដេច កាលបុគ្គលដឹងរូបទាំងឡាយថា មិនទៀង មានការប្រែប្រួល បែកធ្លាយ រលត់ ហើយឃើញនូវរូបនោះ ដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិតថា រូបទាំងឡាយសូម្បីក្នុងអតីត និង បច្ចុប្បន្ន រូបទាំងឡាយនោះ ទាំងអស់ មិនទៀង ទ្រាំនៅមិនបាន មានសេចក្ដីប្រែប្រួលជាធម្មតា ទើបកើតសោមនស្សឡើង សោមនស្សបែបនេះ ឈ្មោះថា សោមនស្សអាស្រ័យការចេញចាកផ្ទះ ដូច្នោះបុគ្គលគប្បីសេពនូវសោមនស្សអាស្រ័យការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយអំណាចការត្រិះរិះដល់ និង ដោយអំណាចឈានជាដើម ។

ក្នុងបទទាំងឡាយនោះ បទថា **បើសោមនស្សប្រកបនឹងវិតក្កវិចារៈ** គឺ សោមនស្សអាស្រ័យការចេញចាកផ្ទះ ( កាមគុណ ) នោះ ក៏ត្រូវដឹងច្បាស់ថា សោមនស្សនេះកើតដោយអំណាចនៃការចេញចាកផ្ទះ ដោយអំណាចវិបស្សនា ដោយការតាមរលឹក និង ដោយអំណាចនៃឈានទី ១ នោះ ជាសោមនស្សដែលនៅមានវិតក្កវិចារៈ បើសោមនស្សណាមិនមានវិតក្កវិចារៈ គឺ សោមនស្សដែលកើតដោយអំណាចឈានទី ២ និង ទី ៣ ក៏ត្រូវដឹងថា ជាសោមនស្សមិន

មានវិតក្កវិចារៈ ។ ពាក្យថា **មិនមានវិតកវិចារៈ ប្រណីតជាង** សូម្បីសោមនស្សទាំង ២ នេះ មានន័យថា សោមនស្សទាំង ២ នេះ សោមនស្សដែលមិនមានវិតក្កៈនិងវិចារៈនោះ ប្រសើរជាង ។ ក្នុងសោមនស្សទាំង ២ នេះ សោមនស្សដែលមិនមានវិតក្កវិចារៈ ប្រសើរជាងសោមនស្សដែលមានវិតក្កវិចារៈ ។ សោមនស្សវិបស្សនាដែលមិនមានវិតក្កវិចារៈ ប្រសើរជាងសោមនស្សវិបស្សនាដែលមានវិតក្កវិចារៈ ។ សោមនស្សសមាបត្តិ ដែលមិនមានវិតក្កវិចារៈនោះ ប្រសើរជាងសោមនស្សសមាបត្តិដែលមានវិតក្កវិចារៈ ។

ឈ្មោះថា **ទោមនស្សអាស្រ័យផ្ទះ** បានដល់ ទោមនស្សអាស្រ័យកាមគុណ ដែលកើតដល់អ្នកតាមត្រិះរិះថា យើងមិនបានសោយ នឹងមិនបានសោយ រមែងមិនបានសោយនូវឥដ្ឋារម្មណ៍ក្នុងទ្វារទាំង ៦ កាលបុគ្គលពិចារណាឃើញការមិនបានចំពោះនូវរូបដែលគួរស្រឡាញ់ គួរប្រាថ្នា គួរពេញចិត្ត ក្នុងលោក ដែលដឹងច្បាស់ដោយភ្នែក ឬ កាលតាមរលឹកដល់រូបដែលមិនធ្លាប់បាន កាលបើវាកន្លងទៅហើយ រលត់ហើយ ប្រែប្រួលទៅហើយ ក៏កើតនូវទោមនស្សឡើង ទោមនស្សបែបនេះ ហៅថា ទោមនស្សអាស្រ័យផ្ទះ។ គប្បីសេពទោមនស្សដែលអាស្រ័យការចេញចាកផ្ទះ ឈ្មោះថា **ទោមនស្សអាស្រ័យការចេញចាកផ្ទះ** បានដល់ ទោមនស្សដែលកើតដល់អ្នកដែលមិនអាចញ៉ាំងចិត្តឱ្យសម្រេចក្នុងធម៌ គឺ អរិយផល តាមសេចក្តីប្រាថ្នាបាន ពោលគឺការរួចផុតដ៏កំពូល ហើយក៏ផ្តើមចម្រើនវិបស្សនាតាមអំណាចត្រៃលក្ខណ៍ មានអនិច្ចំជាដើម ដើម្បីសម្រេចនូវអរិយផលនោះ លោកកើតទុក្ខថា យើងមិនអាចញ៉ាំងចិត្តឱ្យចុះកាន់វិបស្សនា អស់ថ្ងៃ អស់ខែ អស់ឆ្នាំ ហើយសម្រេច

អរិយភូមិ ក្នុងរូបដែលគួរស្រឡាញ់ មកកាន់គន្លងទ្វារទាំង ៦ ។ កាលបុគ្គលដឹងនូវរូបទាំងឡាយថា មិនទៀង ប្រែប្រួល វិនាស រលត់ទៅ ឃើញរូបនោះដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិត យ៉ាងនេះថា រូបទាំងឡាយ សូម្បីក្នុងអតីតក្នុងបច្ចុប្បន្ន រូបទាំងអស់នោះ មិនទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលជាធម្មតា ហើយក៏មានបំណងក្នុងការរួចផុតដ៏កំពូល គិតថា ពេលណាហ្ន៎យើងនឹងចូលដល់អាយតនៈនោះ គឺ អាយតនៈដែលព្រះអរិយៈជាម្ចាស់បានចូលដល់ហើយ ។ កាលលោកមានបំណងដើម្បីបាននូវការរួចផុតយ៉ាងនេះ ដូចដែលពោលមក ទោមនស្សក៏កើតឡើង ព្រោះសេចក្ដីប្រាថ្នាជាបច្ច័យ ទោមនស្សបែបនេះ ហៅថា **ទោមនស្សអាស្រ័យការចេញចាកផ្ទះ** ។

ឈ្មោះថា **ឧបេក្ខាដែលអាស្រ័យផ្ទះ** បានដល់ ឧបេក្ខាដែលអាស្រ័យកាមគុណ ដែលជាប់ជំពាក់ ដែលប្រកៀកកើតឡើងក្នុងកាមគុណនោះឯងប្រព្រឹត្តទៅកន្លងរូបមិនបាន ដូចមេឃ្មុំជាប់ជំពាក់ក្នុងទឹកអំពៅ ក្នុងអារមណ៍គួរជាទីស្រឡាញ់ ដែលមកកាន់គន្លងទ្វារទាំង ៦ , ឧបេក្ខាអាស្រ័យផ្ទះ ក៏កើតឡើងដល់បុគ្គលល្ងង់ បុគ្គលវង្វេង បុគ្គលមានកិលេសក្រាស់ បុគ្គលគិតតែយកឈ្នះមិនមានព្រំដែន យកតែឈ្នះមិនមានផល មានប្រក្រតីមិនឃើញទោសមិនបានទទួលការសិក្សា ជាអន្ធបុថុជ្ជន ឧបេក្ខាបែបនេះ ជាឧបេក្ខាកន្លងរូបមិនបាន ព្រោះហេតុនោះ ទើបហៅថា **ឧបេក្ខាអាស្រ័យផ្ទះ** ។

ឧបេក្ខាដែលអាស្រ័យការចេញចាកផ្ទះ បានដល់ ឧបេក្ខាដែលប្រកបព្រមដោយវិបស្សនាញាណ កើតដល់បុគ្គលដែលមិនរីករាយក្នុងអារម្មណ៍ដែលគួររីករាយ មិនប្រទូសរ៉ាយក្នុងអារមណ៍ដែលមិនជាទីពេញចិត្ត មិនវង្វេងព្រោះ

ការពិចារណាអារម្មណ៍ មានអារម្មណ៍ជាទីស្រឡាញ់ជាដើម ដែលមកកាន់គន្លងទ្វារទាំង ៦ លោករមែងដឹងច្បាស់ក្នុងវេទនាទាំងឡាយនោះ , ឧបេក្ខាអាស្រ័យការចេញចាកផ្ទះ គឺ ឧបេក្ខាដែលកើតឡើងដល់អ្នកដែលដឹងច្បាស់នូវការមិនទៀង ការប្រែប្រួល ការវិនាស ការរលត់របស់រូប ហើយឃើញរូបទាំងឡាយនោះ ដោយបញ្ញាដ៏ប្រពៃតាមពិតថា រូបទាំងឡាយ សូម្បីក្នុងអតីត និង បច្ចុប្បន្ន រូបទាំងឡាយនោះ សុទ្ធតែមិនទៀង ទ្រាំនៅមិនបាន មានការប្រែប្រួលជាធម្មតា ឧបេក្ខានេះ ជាឧបេក្ខាដែលកន្លងរូបបាន ដូច្នោះ ឧបេក្ខានោះ ហៅថា **ឧបេក្ខាអាស្រ័យការចេញចាកផ្ទះ** ។

វេទនានុបស្សនាសតិប្បដ្ឋានភាវនា ៩ វិធី មានសេចក្តីអធិប្បាយមកដូច្នេះឯង ។

( ចប់ វេទនានុបស្សនាសតិប្បដ្ឋានភាវនា )

# ចិត្តានុបស្សនាសតិប្បដ្ឋាន

ម្យ៉ាងទៀត **ចិត្ត** ព្រះយោគាវចរ គប្បីពិចារណាឃើញដោយអំណាចប្រភេទនៃចិត្តផ្សេង ៗ មានអារម្មណចិត្ត អធិបតិចិត្ត សហជាតចិត្ត ភូមិចិត្ត កម្មចិត្ត វិបាកចិត្ត និងកិរិយាចិត្តជាដើម និងដោយអំណាចប្រភេទនៃចិត្ត មានចិត្តដែលប្រកបដោយរាគៈជាដើម ដែលមកក្នុងនិទ្ទេសវារៈនៃអនុបស្សនា ៧ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ក៏ដឹងច្បាស់ថាចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ទោះចិត្តប្រកបដោយទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ទោះចិត្តប្រកបដោយមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ទោះចិត្តរួញរា ក៏ដឹងច្បាស់ថា ចិត្តរួញរា ទោះចិត្តរាយមាយ ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ទោះចិត្តដល់នូវភាវៈជាធំ ( រូបាវចរ និង អរូបាវចរ ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈជាធំ ទោះចិត្តមិនដល់នូវភាវៈជាធំ ( កាមាវចរ ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈជាធំ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង ( នៅជាកាមាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ( ជារូបាវចរនិងអរូបាវចរ ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ទោះចិត្តតម្កល់មាំ ( ជាឧបចារៈសមាធិ និង អប្បនាសមាធិ ) ក៏ដឹងច្បាស់ថា ចិត្តតម្កល់មាំ ទោះចិត្តមិនតម្កល់មាំ

( ប្រាសចាកសមាធិទាំង ២ ) ក៏ដឹងច្បាស់ថា ចិត្តមិនតម្កល់មាំ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ( ចិត្តរួចស្រឡះ បានដល់ វិមុត្តិ **២** ប្រការ គឺ តទង្គវិមុត្តិ និង វិក្ខម្ភនវិមុត្តិ ។ **អនុបស្សនា ៧** មានអនិច្ចានុបស្សនាជាដើម ហៅថា តទង្គវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកនិច្ចសញ្ញា , **សមាបត្តិ ៨** ហៅថា វិក្ខម្ភនវិមុត្តិ ព្រោះជាធម្មជាតិរួចស្រឡះចាកអកុសល មាននីវរណៈជាដើម . " អដ្ឋកថា មហាបទានសូត្រ " ) , ទោះចិត្តមិនទាន់រួចស្រឡះ ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។

ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្តខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវចិត្តក្នុងចិត្ត ខាងក្នុងនិងខាងក្រៅជាប្រក្រត្រី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងចិត្ត គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការរលត់នៃចិត្តគ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ គឺ ហេតុកើតឡើង ទាំងធម៌ គឺ ការរលត់ទៅនៃចិត្តគ្រប់ឥរិយាបថទាំង ៤ ផង ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា ចិត្តមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ( ភិក្ខុមានចិត្តមិនអាស្រ័យដោយតណ្ហា និងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវចិត្តក្នុងចិត្ត ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

បណ្តាបទទាំងឡាយនោះ បទថា **ចិត្តប្រកបដោយរាគៈ** គឺ ចិត្តដែលកើតព្រមនឹងលោភៈ **៨** ដួង ។ បទថា **ចិត្តប្រាសចាករាគៈ** គឺ ចិត្តដែលជា **កុសល** និង **អព្យាកតៈ** ដែលជាលោកិយ ។ ក្នុងសេចក្តីនេះ ជាការពិចារណា មិនមែនជាការរួបរួមធម៌នោះទេ ព្រោះដូច្នោះ នៅក្នុងពាក្យថា **ចិត្តប្រាសចាករាគៈ** ទើបមិនបានសំដៅយកលោកុត្តរចិត្ត សូម្បីតែ ១ បទ ។ អកុសលចិត្ត **៤** ដួង ដ៏សេស ក៏មិនរាប់ចូលក្នុងបទមុន និង បទក្រោយដែរ ។

បទថា **ចិត្តប្រកបដោយទោសៈ** បានដល់ ចិត្ត **២** ដួង ដែលប្រកបនឹងទោមនស្ស ។ បទថា **ចិត្តប្រាសចាកទោសៈ** បានដល់ ចិត្តដែលជា **កុសល** និង **អព្យាកតៈ** ជាលោកិយ ។ អកុសលចិត្ត **១០** ដួង ដ៏សេស មិនបានរាប់ចូលក្នុងបទមុន និង បទក្រោយទេ ។

បទថា **ចិត្តប្រកបដោយមោហៈ** បានដល់ ចិត្ត **២** ដួង ដែលកើតព្រមនឹងវិចិកិច្ឆា ១ ដួង កើតព្រមនឹងឧទ្ធច្ចៈ ១ ដួង តែព្រោះមោហៈ រមែងកើតបានក្នុងអកុសលចិត្តទាំងអស់ ដូច្នោះ សូម្បីក្នុងអកុសលចិត្តដ៏សេស ក៏គួរបានក្នុងបទថា ចិត្តប្រកបដោយមោហៈនេះដែរ ។ ពិតហើយ អកុសលចិត្ត **១២** មាន ( លោភមូល ៨ ទោសមូល ២ មោហមូល ២ ) លោករួមទុកក្នុងទុក្កៈនេះប៉ុណ្ណោះ ។ ពាក្យថា **ចិត្តប្រាសចាកមោហៈ** បានដល់ ចិត្តដែលជា **កុសល** និង **អព្យាកតៈ** ជាលោកិយ ។

បទថា **ចិត្តរួញរា** បានដល់ ចិត្តដែលប្រកបនឹងថីនមិទ្ធៈ , ចិត្តដែលធ្លាក់ចុះក្នុងថីនមិទ្ធៈនោះឯង ឈ្មោះថា **ចិត្តរួញរា** ។ បទថា **ចិត្តរាយមាយ** បានដល់

ចិត្តប្រកបនឹងឧទ្ធច្ចៈ ។ ចិត្តដែលកើតព្រមនឹងឧទ្ធចៈនោះ ឈ្មោះថា **ចិត្តរាយមាយ** ។

បទថា **មហគ្គតំ** - ចិត្តដល់នូវភាវៈជាធំ បានដល់ ចិត្តជារូបាវចរៈ និង អរូបាវចរៈ ។ បទថា **អមហគ្គតំ** - ចិត្តមិនដល់នូវភាវៈជាធំ បានដល់ ចិត្តជាកាមាវចរៈ ។

បទថា **សឧត្តរំ** - ចិត្តនៅមានចិត្តដទៃប្រសើរជាង បានដល់ ចិត្តជាកាមាវចរៈ ។ បទថា **អនុត្តរំ** - ចិត្តមិនមានចិត្តដទៃប្រសើរជាង បានដល់ចិត្តជារូបាវចរៈ និង អរូបាវចរៈ ។ ឬថា ចិត្តទាំងនោះ គឺ ចិត្តឈ្មោះថា **សឧត្តរ** បានដល់ រូបាវចរៈ , **អនុត្តរ** បានដល់ អរូបាវចរៈ ។

បទថា **សមាហិតំ** - ចិត្តតម្កល់មាំ បានដល់ អប្បនាសមាធិ ឬ ឧបចារសមាធិ ។ បទថា **អសមាហិតំ** - ចិត្តមិនតម្កល់មាំ បានដល់ ចិត្តដែលវៀរចាកសមាធិទាំង ២ ។

បទថា **វិមុត្តំ** - ចិត្តរួចផុត បានដល់ ចិត្តដែលរួចស្រឡះដោយតទង្គ-វិមុត្តិ និង វិក្ខម្ភនវិមុត្តិ ។ បទថា **អវិមុត្តំ** - ចិត្តមិនទាន់រួចផុត បានដល់ ចិត្តដែលវៀរចាកវិមុត្តិទាំង ២ ។

ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និង និស្សរណវិមុត្តិ មិនមានឱកាសក្នុងបទនេះឡើយ ។

## ចិត្តក្នុង - ចិត្តក្រៅ

បទថា **ឥតិ អជ្ឈត្តំ វា** - ឬខាងក្នុង មានន័យថា ភិក្ខុយោគាវចរកំណត់

ចិត្តដែលប្រព្រឹត្តទៅក្នុងសម័យណា ៗ ដោយការកំណត់ចិត្តមានរាគៈជាដើម យ៉ាងនេះ ឈ្មោះថា ពិចារណាឃើញចិត្តក្នុងចិត្តរបស់ខ្លួន ឬ ក្នុងចិត្តរបស់បុគ្គលដទៃ ក្នុងចិត្តរបស់ខ្លួនតាមកាល ឬ ក្នុងចិត្តរបស់បុគ្គលដទៃតាមកាល ។

ក្នុងពាក្យថា **ពិចារណាឃើញធម៌** គឺ ហេតុកើតឡើងនេះ គប្បីនាំការកើតឡើងនិងការរលត់ទៅនៃវិញ្ញាណចេញ មកប្រៀបធៀបដោយអាការ១ ជា ៥ យ៉ាង ថា ព្រោះការកើតឡើងនៃអវិជ្ជា វិញ្ញាណទើបកើតឡើងដូច្នេះជាដើម។

វិសុទ្ធិមគ្គ : ធម៌ **៥** ប្រការ ជាហេតុជាបច្ច័យនៃវិញ្ញាណនោះ គឺកើតឡើងយ៉ាងនេះ , ធម៌ **៤** មាន **អវិជ្ជា តណ្ហា ឧបាទាន កម្ម** ជាហេតុព្រោះជាអ្នកធ្វើឱ្យកើត **អាហារ** ជាបច្ច័យ ព្រោះជាអ្នកឧបត្ថម្ភ , ម្យ៉ាងទៀត ក្នុងធម៌ **៥** នោះ ធម៌ **៣** មាន **អវិជ្ជាជាដើម** ជាទីអាស្រ័យកើតឡើងនៃវិញ្ញាណ ដូចមាតាជាទីអាស្រ័យកើតនៃទារក , **កម្ម** ជាអ្នកញ៉ាំងវិញ្ញាណឱ្យកើត ដូចបិតាញ៉ាំងបុត្តឱ្យកើត , **អាហារ** ជាអ្នកឧបត្ថម្ភ ដូចម៉ែដោះ អ្នកចិញ្ចឹមរក្សាទារក ។

ក្នុងគម្ពីរអដ្ឋសាលិនី អដ្ឋកថា ព្រះធម្មសង្គណី បានសម្ដែងថា :

**- ចិន្តេតីតិ ចិត្តំ** ឈ្មោះថា **ចិត្ត** ព្រោះអត្ថថា **គិត** គឺ ដឹងអារម្មណ៍ ។

## លក្ខណាទិចតុក្កៈរបស់ចិត្ត

**- វិជាននលក្ខណំ** មានការដឹងអារម្មណ៍ ជាលក្ខណៈ ។

**- បុព្វង្គមរសំ** មានការកើតមុន និងជាប្រធាននៃធម៌ទាំងពួងជាកិច្ច។

**- សន្ទានបច្ចុប្បដ្ឋានំ** មានការកើតឡើង តជាប់គ្នា មិនដាច់ខ្សែ ជាអាការប្រាកដ ។

**- នាមរូបបទដ្ឋានំ** មាននាមរូប ជាហេតុជិត ។

## ចិត្តប្រកបដោយរាគៈ

" បានដល់ លោភមូលចិត្ត ៨ ដួង "

**លុព្ភតីតិ លោភោ** ឈ្មោះថា **លោភៈ** ព្រោះអត្ថថា ចង់បាន ។

ឈ្មោះថា **លោភៈ** ព្រោះអត្ថថា ជាហេតុឱ្យប្រាថ្នា ឬ ព្រោះអត្ថថា ប្រាថ្នាដោយខ្លួនឯង ឬ ព្រោះអត្ថថា ត្រឹមតែជាសេចក្តីប្រាថ្នាប៉ុណ្ណោះ ។

## លក្ខណាទិចតុក្កៈរបស់លោភៈ

**- អារម្មណគ្គហណលក្ខណោ** មានការប្រកាន់មាំនូវអារម្មណ៍ ជាលក្ខណៈ ដូចស្វាជាប់ជ័រ ។

**- អភិសង្គរសោ** មានការជាប់ស្អិតក្នុងអារម្មណ៍ ជាកិច្ច ដូចសាច់ជាប់លើក្បៀងក្តៅ ។

**- អបរិច្ចាគបច្ចុប្បដ្ឋានោ** មានការមិនបរិច្ចាគជាអាការប្រាកដ ដូចក្អែកមិនលះបង់កន្លែងផ្សំប្រេង ។

**- អយោនិសោមនសិការបទដ្ឋានោ** មានការមិនធ្វើទុកក្នុងចិត្ត ដោយត្រូវទំនងក្នុងអារម្មណ៍ ជាហេតុជិត ។

**លោភៈ** នោះ កាលណាចម្រើនឡើងហើយ ប្រៀបដូចជាស្ទឹង , ឈ្មោះ

ថា **តណ្ហា** គប្បីឃើញថា រមែងហូរទៅកាន់អបាយ តែម្យ៉ាង ដូចជាទន្លេដែលតែងតែហូរទៅកាន់មហាសមុទ្រដូច្នោះ

## លក្ខណាទិចតុក្កៈរបស់តណ្ហា

- **ហេតុលក្ខណា** ជាហេតុនៃទុក្ខទាំងពួង ជាលក្ខណៈ ។
- **អភិនន្ទនរសា** មានសេចក្តីត្រេកអរពេញចិត្ត ក្នុងអារម្មណ៍ ភូមិ និង ភព ជាកិច្ច ។
- **អតិត្តភាវបច្ចុប្បដ្ឋានា** ធ្វើឱ្យសហជាតធម៌ មិនឆ្អែតក្នុងអារម្មណ៍ ៦ ជាអាការប្រាកដ ។
- **វេទនាបទដ្ឋានា** មានវេទនា ជាហេតុជិត ។

**ចិត្ត** ដែលប្រកបដោយលោភៈ ឬ **បុគ្គល** ដែលប្រកបដោយលោភៈ ឈ្មោះថា **លុព្ភិតោ** , ភាវៈនៃចិត្ត ឬ នៃបុគ្គលអ្នកលោភ ឈ្មោះថា **លុព្ភិតត្តំ** គឺ សេចក្តីលោភ ។

**លោភៈ** ដែលជាមូល ( ឫសគល់ ) ហៅថា **លោភៈ** , បើដល់ភាពជាកម្មបទ ហៅថា **អភិជ្ឈា** ។

**ធម្មជាតិ** ឈ្មោះថា **អភិជ្ឈា** មានន័យថា ការសម្លឹងរំពៃចង់បាន អធិប្បាយថា ចង់បានរបស់អ្នកដទៃ ប្រព្រឹត្តបង្អោនទៅក្នុងសម្បត្តិរបស់អ្នកដទៃនោះ ។ **អភិជ្ឈា** នោះឯង មានលក្ខណៈសម្លឹងចង់បានសម្បត្តិរបស់អ្នកដទៃ យ៉ាងនេះថា ធ្វើយ៉ាងណា ទើបបានរបស់គេ មកជារបស់យើង ។

# ចិត្តប្រកបដោយទោសៈ

" បានដល់ ទោសមូលចិត្ត ២ ដួង "

ឈ្មោះថា **ទោសៈ** ព្រោះអត្ថថា គិតប្រទូសរ៉ាយ អាការគិតប្រទូសរ៉ាយ ឈ្មោះថា **ទូសនា** កិរិយាប្រទូសរ៉ាយ ។

ឈ្មោះថា **ព្យាបាទ** ដោយអត្ថថា ជាហេតុឱ្យដល់នូវសេចក្តីវិនាស គឺឱ្យចូលដល់នូវសេចក្តីវិនាសនៃចិត្ត ឬដោយអត្ថថា ញុំាងវិន័យអាចារ រូបសម្បត្តិ និង ប្រយោជន៍សុខជាដើម ឱ្យដល់នូវសេចក្តីវិនាស តែដោយអត្ថន័យ **ព្យាបាទ** នោះ ក៏គឺ **ទោសៈ** នេះឯង ។

## លក្ខណាទិចតុក្កៈរបស់ទោសៈ

- **ចណ្ឌិក្កលក្ខណោ** មានការកាចសាហាវ ជាលក្ខណៈ ។
- **និស្សយទហនរសោ** មានការដុតរោលនូវសម្បយុត្តធម៌ ជាកិច្ច ។
- **ទូស្សនបច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយ ជាអាការប្រាកដ ។
- **អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុ ជាហេតុជិត ។

## អាឃាតវត្ថុ ១០ យ៉ាង

១- អាឃាតគេដោយគិតថា គេបានធ្វើសេចក្តីវិនាសឱ្យដល់យើង ។

២- អាឃាតគេដោយគិតថា គេកំពុងធ្វើសេចក្តីវិនាសឱ្យដល់យើង ។

៣- អាឃាតគេដោយគិតថា គេនឹងធ្វើសេចក្តីវិនាសឱ្យដល់យើង ។

៤- អាឃាតគេដោយគិតថា គេធ្លាប់បានធ្វើនូវសេចក្តីវិនាស ដល់អ្នក

ដែលយើងស្រឡាញ់ ។

**៥.** អាឃាតគេដោយគិតថា គេកំពុងធ្វើនូវសេចក្តី វិនាសដល់អ្នកដែលយើងស្រឡាញ់ ។

**៦.** អាឃាតគេដោយគិតថា គេនឹងធ្វើនូវសេចក្តីវិនាស ដល់បុគ្គលដែលយើងស្រឡាញ់ ។

**៧.** អាឃាតគេដោយគិតថា គេបានធ្វើនូវប្រយោជន៍ ដល់បុគ្គលដែលយើងស្អប់ ។

**៨.** អាឃាតគេដោយគិតថា គេកំពុងធ្វើប្រយោជន៍ ឱ្យដល់បុគ្គលដែលយើងស្អប់ ។

**៩.** អាឃាតគេដោយគិតថា គេនឹងធ្វើប្រយោជន៍ ឱ្យដល់បុគ្គលដែលយើងស្អប់ ។

## ចិត្តប្រកបដោយមោហៈ

" បានដល់ មោហមូលចិត្ត ២ ដួង "

ឈ្មោះថា **មោហៈ** ព្រោះអត្ថថា ជាហេតុធ្វើឱ្យវង្វេង ឬ ព្រោះអត្ថថា ភាវៈនៃខ្លួនឯងវង្វេង ឬ ព្រោះអត្ថថា នោះឯង ត្រឹមតែជាការវង្វេងប៉ុណ្ណោះ ។

## លក្ខណាទិចតុក្កៈរបស់មោហៈ

**-ចិត្តស្ស អន្ធភាវលក្ខណោ** មានការងងឹតនៃចិត្ត ជាលក្ខណៈ ។

**អញ្ញាណលក្ខណោ វា** ឬមានការមិនដឹង ជាលក្ខណៈ ។

**-អសម្បដិវេធរសោ** មានការមិនចាក់ធ្លុះ ជាកិច្ច ។

**អារម្មណសភាវច្ឆាទន** ឬ មានការបិទបាំងសភាវៈនៃអារម្មណ៍ជាកិច្ច។

**រសោ វា**

**-អសម្មាបដិបត្តិ** មានការបដិបត្តិមិនត្រូវ ជាអាការប្រាកដ ។

**បច្ចុប្បដ្ឋានោ**

**អន្ធការបច្ចុប្បដ្ឋានោ វា** ឬ មានភាពងងឹត ជាអាការប្រាកដ ។

**-អយោនិសោមនសិការ** មានការមិនធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវ

**បទដ្ឋានោ** ទំនង ជាហេតុជិត ។

**មោហៈនេះ** គប្បីឃើញថា ជាមូលនៃអកុសលទាំងពួង។

**មោហៈ** គឺ **អវិជ្ជា** បានដល់ ការមិនដឹងតាមសេចក្ដីពិត ។ ក្នុងទីនេះ ទ្រង់សម្ដែងដល់ការមិនដឹងក្នុងធម៌ ៨ ប្រការ គឺ :

**១-ទុក្ខេ អញ្ញាណំ** ការមិនដឹងក្នុងទុក្ខសច្ច ។

**២-ទុក្ខសមុទយេ អញ្ញាណំ** ការមិនដឹងក្នុងទុក្ខសមុទយសច្ច ។

**៣-ទុក្ខនិរោធេ អញ្ញាណំ** ការមិនដឹងក្នុងទុក្ខនិរោធសច្ច ។

**៤-ទុក្ខនិរោធគាមិនីបដិបទាយ អញ្ញាណំ** ការមិនដឹងក្នុងមគ្គសច្ច ។

**៥-បុព្វន្តេ អញ្ញាណំ** ការមិនដឹងក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអតីត ។

**៦-អបរន្តេ អញ្ញាណំ** ការមិនដឹងក្នុង ខន្ធ អាយតនៈ ធាតុ ដែលជាអនាគត ។

**៧-បុព្វន្តាបរន្តេ អញ្ញាណំ** ការមិនដឹងក្នុង ខន្ធ អាយតនៈ ធាតុ

ទាំងអតីត និង ទាំងអនាគត ។

**៨ - ឥទប្បច្ចយតា បដិច្ចសមុប្បន្នេសុ ធម្មេសុ អញ្ញាណំ** ការមិនដឹងក្នុងបដិច្ចសមុប្បាទ គឺ មិនដឹងក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នាកើតឡើង ថាមានធម៌នេះជាបច្ច័យ ។

## ចិត្តប្រកបដោយថីនមិទ្ធៈ

**ចិត្តរួញរា** បានដល់ ចិត្តប្រកបដោយថីនមិទ្ធៈ ក្នុងបណ្តា ថីនមិទ្ធៈនោះ ការរួញរា បានដល់ **ថីនៈ** ។ ការងោកងុយ មិនអាចហ៊ាន ភាពមិនអាចការទម្លាយ ឈ្មោះថា **មិទ្ធៈ** ។

**ថីនៈ** និង **មិទ្ធៈ** ចេតសិកទាំង ២ នេះ ប្រកបនឹងចិត្ត ដែលជាសសង្ខារិកៈ ៥ ដួង គឺ ក្នុងលោភមូលចិត្ត ៤ ដួង និង ទោសមូលចិត្ត ១ ។ ចេតសិកទាំង ២ នេះ កើតរួមគ្នាជានិច្ច **ថីនៈ** ប្រៀបដូចអណ្តាតភ្លើង , **មិទ្ធៈ** ប្រៀបដូចពន្លឺ ។

## លក្ខណាទិចតុក្កៈរបស់ថីនៈ

| | |
|---|---|
| **-អនុស្សាហន លក្ខណំ** | មានការមិនឧស្សាហ៍ ជាលក្ខណៈ ។ |
| **-វិរិយវិនោទន រសំ** | មានការកម្ចាត់បង់នូវវិរិយៈ ជាកិច្ច ។ |
| **-សំសីទន បច្ចុប្បដ្ឋានំ** | មានការរួញរានៃចិត្ត ជាអាការប្រាកដ ។ |
| **-អរតី វិជម្ភិកាទីសុ អយោនិសោមនសិការ** | មានអយោនិសោមនសិការក្នុងការមិនត្រេកអរក្នុងកុសល និង ការងោកងុយជាដើម ជា |

| | |
|---|---|
| **បទដ្ឋានំ** | ហេតុជិត ។ |

## លក្ខណាទិចតុក្កៈរបស់មិទ្ធៈ

| | |
|---|---|
| **-អកម្មញ្ញតា លក្ខណំ** | មានការមិនគួរដល់ការងារ មិនរហ័សរហួន ជាលក្ខណៈ ។ |
| **-ឱនហន រសំ** | មានការបិទបាំងសហជាតធម៌ ជាកិច្ច ។ |
| **-លីនតា បច្ចុប្បដ្ឋានំ** | មានការងោកងក់ ជាអាការប្រាកដ ។ |
| **-អរតី វិជម្ភិកាទីសុ អយោនិសោមនសិការបទដ្ឋានំ** | មានអយោនិសោមនសិការ ក្នុងការមិនត្រេកអរ និង ការងោកងុយជាដើម ជាហេតុជិត ។ |

## ចិត្តប្រកបដោយឧទ្ធច្ចៈ

**ចិត្តរាយមាយ** បានដល់ ចិត្តដែលប្រកបដោយឧទ្ធច្ចៈ ។

ភាវៈនៃចិត្តដែលរាយមាយ ឈ្មោះថា **ឧទ្ធច្ចៈ** ឧទ្ធច្ចៈនេះ មានការឆ្វាទៅឆ្វាមកនៃចិត្តចំពោះអារម្មណ៍ ។

## លក្ខណាទិចតុក្កៈរបស់ឧទ្ធច្ចៈ

| | |
|---|---|
| **-អវូបសមន លក្ខណំ** | មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹកត្រូវខ្យល់ផាត់ ។ |
| **-អនវដ្ឋាន រសំ** | មានការមិនតាំងនៅនឹងក្នុងអារម្មណ៍តែមួយជា |

| | |
|---|---|
| | កិច្ច ដូចទង់ត្រូវខ្យល់ ។ |
| **-ភន្តត្ត បច្ចុប្បដ្ឋានំ** | មានការវីវក់ - ឆ្វាទៅក្នុងអារម្មណ៍ ជាអាការប្រាកដ ដូចពំនូកផេះត្រូវគេគប់នឹងដុំដី ។ |
| **-អយោនិសោមនសិការ បទដ្ឋានំ** | មានការធ្វើទុកក្នុងចិត្តមិនល្អ មិនត្រូវ ជាហេតុជិត ។ |

គូនៃចិត្តដទៃទៀត មានន័យប្រាកដច្បាស់ហើយ បណ្ឌិតគប្បីកំណត់ដឹងចុះ ។

ចិត្តានុបស្សនាសតិប្បដ្ឋានភាវនា **១៦** វិធី មានប្រការ ដូចពោលមកយ៉ាងនេះឯង ។

( ចប់ ចិត្តានុបស្សនាសតិប្បដ្ឋានភាវនា )

# ធម្មានុបស្សនាសតិប្បដ្ឋាន

រីឯ **ធម៌** ព្រះយោគាវចរ គប្បីពិចារណាឃើញដោយអំណាចនៃលក្ខណៈចំពោះខ្លួន និង សាមញ្ញលក្ខណៈ ដោយអំណាចប្រភេទនៃធម៌ ដែលមានសភាពសូន្យ ដែលមកក្នុងនិទ្ទេសវារៈនៃអនុបស្សនា **៧** មានអនិច្ចានុ-បស្សនាជាដើម ។

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធី ដូចម្តេច ?

## ១ - នីវរណបព្វៈ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺ នីវរណៈទាំង **៥** យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺ នីវរណៈទាំង **៥** តើដូចម្តេច ? ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈ មាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះកាមច្ឆន្ទៈដែលមិនទាន់កើតឡើង ហើយកើតឡើងបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កាមច្ឆន្ទៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះព្យាបាទមាននៅ

ក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះព្យាបាទដែលមិនទាន់កើតឡើង ហើយកើតឡើងបានដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវព្យាបាទ ដែលកើតឡើងហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះ ព្យាបាទដែលលះបង់បាន មិនកើតតទៅទៀតដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមាននៅក្នុងសន្តានចិត្តអាត្មាអញ ទោះថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងសន្តានចិត្តអាត្មាអញ ទោះថីនមិទ្ធៈដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវថីនមិទ្ធៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ថីនមិទ្ធៈដែលលះបង់បានហើយ មិនកើតតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះឧទ្ធច្ចកុក្កុច្ចៈ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះវិចិកិច្ឆាមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងសន្តានចិត្ត

របស់អាត្មាអញ ទោះវិចិកិច្ឆាមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆា មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះវិចិកិច្ឆាមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវវិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណា ឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការរលត់ទៅនៃធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការកើតឡើង ទាំងធម៌ គឺ ការរលត់ទៅនៃធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យដោយ ( តណ្ហា និង ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ នីវរណៈទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

# អដ្ឋកថា

ព្រះមានព្រះភាគ ជាម្ចាស់ កាលត្រាស់ចិត្តានុបស្សនាសតិប្បដ្ឋាន **១៦** វិធី យ៉ាងនេះហើយ ឥឡូវនេះកាលនឹងត្រាស់ ធម្មានុបស្សនាសតិប្បដ្ឋាន **៥** វិធី ទើបទ្រង់ត្រាស់ថា **កថញ្ច ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្ដេច ?

ម្យ៉ាងទៀត ព្រះមានព្រះភាគ កាលត្រាស់ការកំណត់រូបកម្មដ្ឋានសុទ្ធ ដោយកាយានុបស្សនា ត្រាស់ការកំណត់អរូបកម្មដ្ឋានសុទ្ធ ដោយវេទនានុប-ស្សនា និងចិត្តានុបស្សនា ឥឡូវនេះកាលត្រាស់ការកំណត់រូបកម្មដ្ឋាននិងអរូបកម្មដ្ឋានរួមគ្នា ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្ដេច ?

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ត្រាស់កំណត់រូបក្ខន្ធ ដោយកាយានុ-បស្សនា ត្រាស់ការកំណត់នូវវេទនាខន្ធ ដោយវេទនានុបស្សនា ត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនា ។ ឥឡូវនេះ កាលត្រាស់ដល់ការកំណត់នូវសញ្ញាខន្ធ និង សង្ខារក្ខន្ធ ទើបត្រាស់ថា **កថញ្ច ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ ធម្មានុបស្សនា តើដូចម្ដេច ?

បណ្ដាបទទាំងឡាយនោះ បទថា **សន្តំ** មានហើយ គឺ ព្រមព្រៀងដោយអំណាចនៃការកើតឡើងរឿយ ៗ ។ បទថា **អសន្តំ** មិនមាន គឺ មិនមានប្រាកដ ព្រោះមិនកើតឡើង ឬ ព្រោះលះបង់បានហើយ ។ បទថា **ដោយហេតុណា** មានន័យថា កាមច្ឆន្ទៈកើតឡើងព្រោះហេតុណា ។ បទថា **តញ្ច បជានាតិ** ក៏ដឹងច្បាស់នូវហេតុនោះ គឺ ជាក់ច្បាស់នូវហេតុនោះ ។ គ្រប់ៗ បទ គប្បីជ្រាប

តាមន័យនេះចុះ ។

## ហេតុកើតឡើងនៃកាមច្ឆន្ទៈ

ក្នុងនិមិត្តទាំង ២ នោះ កាមច្ឆន្ទៈ រមែងកើតឡើងព្រោះ មនសិការដែលមិនត្រូវទំនងក្នុងសុភនិមិត្ត ។ វត្ថុដែលស្អាតក្តី អារម្មណ៍ដែលល្អក្តី ឈ្មោះថា សុភនិមិត្ត ។ ការធ្វើទុកក្នុងចិត្ត មិនដោយឧបាយ ការដាក់ចិត្តក្រៅផ្លូវ ការដាក់ចិត្តក្នុងវត្ថុដែលមិនទៀងថាទៀង ក្នុងវត្ថុដែលជាទុក្ខថាសុខ ក្នុងវត្ថុដែលមិនមែនខ្លួន ថាជាតួខ្លួន ឬ ក្នុងវត្ថុដែលមិនស្អាតថាស្អាត ឈ្មោះថា **អយោនិសោមនសិការ** ការធ្វើទុកក្នុងចិត្តមិនត្រូវទំនង ។ កាលភិក្ខុធ្វើអយោនិសោមនសិការនោះ ឱ្យកាន់តែច្រើនឡើង ក្នុងសុភនិមិត្តនោះ កាមច្ឆន្ទៈរមែងកើតឡើង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តមានហើយ កាលធ្វើឱ្យច្រើននូវអយោនិសោមនសិការ ក្នុងសុភនិមិត្តនោះ នេះជាអាហារដើម្បីការកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើង ឬ ដើម្បីការធ្វើកាមច្ឆន្ទៈដែលកើតឡើងហើយ ឱ្យកាន់តែកម្រើកក្រៃលែងឡើង** ។

## ហេតុលះបង់កាមច្ឆន្ទៈ

ចំណែកកាមច្ឆន្ទៈនោះ នឹងលះបង់បានដោយយោនិសោមនសិការ ការធ្វើទុកក្នុងចិត្តដោយត្រឹមត្រូវ ក្នុងអសុភនិមិត្ត ។ វត្ថុដែលមិនស្អាតក្តី អារម្មណ៍ដែលមិនល្អក្តី ឈ្មោះថា **អសុភនិមិត្ត** ។ ការធ្វើទុកក្នុងចិត្តដោយឧបាយ ការធ្វើទុកក្នុងចិត្តដោយត្រឹមត្រូវ ការធ្វើទុកក្នុងចិត្តក្នុងវត្ថុដែលមិនទៀង ថា មិនទៀង

ក្នុងវត្ថុដែលជាទុក្ខ ថាជាទុក្ខ ក្នុងវត្ថុដែលមិនមែនខ្លួនថា មិនមែនខ្លួន ឬក្នុងវត្ថុដែលមិនស្អាត ថាមិនស្អាត ឈ្មោះថា **យោនិសោមនសិការ** ។ កាលភិក្ខុធ្វើយោនិសោមនសិការនោះឯង ឱ្យប្រព្រឹត្តទៅកាន់តែច្រើនឡើងក្នុងអសុភនិមិត្តនោះ រមែងលះបង់នូវកាមច្ឆន្ទៈចេញបាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ កាលអសុភនិមិត្តមានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងអសុភនិមិត្តនោះ នេះជាអាហារដើម្បីការមិនកើតឡើងនៃកាមច្ឆន្ទៈ ដែលនៅមិនទាន់កើតឡើង ឬ ដើម្បីលះបង់នូវកាមច្ឆន្ទៈ ដែលកើតឡើងហើយ** ។

## ធម៌សម្រាប់លះបង់កាមច្ឆន្ទៈ

ម្យ៉ាងទៀត ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវកាមច្ឆន្ទៈ គឺ **១** - ការកាន់យកនូវអសុភនិមិត្តជាអារម្មណ៍ **២** - ការប្រកបរឿយៗនូវអសុភភាវនា **៣** - ការរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ **៤** - ការដឹងប្រមាណក្នុងភោជន **៥** - ការមានកល្យាណមិត្ត **៦** - និយាយតែរឿងដែលជាទីសប្បាយ ។

ពិតហើយ កាលភិក្ខុកំណត់អសុភនិមិត្ត **១០** យ៉ាង ក៏អាចលះបង់កាមច្ឆន្ទៈបាន ។ កាលចម្រើនអុភនិមិត្តក្តី កាលបិទទ្វារក្នុងឥន្ទ្រិយទាំងឡាយក្តី ដឹងប្រមាណក្នុងភោជន ព្រោះកាលមានឱកាសបរិភោគសល់ត្រឹម ៤ - ៥ ដុំទៀតឆ្អែត ក៏ផឹកទឹក គ្រាន់តែញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅបាន រមែងលះបង់នូវកាមច្ឆន្ទៈបាន ព្រោះហេតុនោះ ទ្រង់ទើបពោលទុក ក្នុងខុទ្ទកនិកាយ ថេរគាថាថា :

**ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ**
**អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ**

ភិក្ខុគប្បីវៀរដុំបាយ ៤ - ៥ ពុំនូត ហើយឆាន់ទឹក នេះជា ឧបដិបត្តិដែលសមគួររបស់ភិក្ខុដែលមានខ្លួនបញ្ជូនទៅហើយ ។

សូម្បីភិក្ខុដែលសេពគប់កល្យាណមិត្ត ដែលជាអ្នកត្រេកអរ ក្នុងការចម្រើនអសុភ ដូចព្រះតិស្សត្ថេរ អ្នកចម្រើនអសុភកម្មដ្ឋាន ក៏រមែងលះបង់នូវកាមច្ឆន្ទៈបាន សូម្បីដោយការចរចា ក្នុងរឿងជាទីសប្បាយ អាស្រ័យអសុភ ១០ ក្នុងឥរិយាបថ ឈរ ឬ អង្គុយជាដើម ក៏រមែងលះបង់នូវកាមច្ឆន្ទៈបាន ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះបង់នូវកាមច្ឆន្ទៈ ដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា កាមច្ឆន្ទៈនេះលះបង់បានហើយដោយធម៌ **៦** ប្រការ រមែងមិនកើតឡើងតទៅទៀតដោយអរហត្តមគ្គ ។

## ហេតុកើតឡើងនៃព្យាបាទ

ចំណែកព្យាបាទ រមែងកើតឡើង ព្រោះអយោនិសោមនសិការក្នុងបដិឃនិមិត្ត ។ បដិឃៈក្តី អារម្មណ៍ដែលជួយឱ្យបដិឃៈកើតឡើងក្តី ឈ្មោះថា **បដិឃនិមិត្ត** ក្នុងពាក្យថា បដិឃនិមិត្តជាដើមនោះ ។ អយោនិសោមនសិការមានលក្ខណៈតែម្យ៉ាងដូចគ្នា ក្នុងធម៌ទាំងពួង ។ កាលភិក្ខុធ្វើអយោនិសោម-នសិការនោះ ឱ្យកាន់តែច្រើនឡើងក្នុងនិមិត្តនោះ ព្យាបាទ រមែងកើតឡើង ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្តមានហើយ ការមិនធ្វើឱ្យច្រើនឡើងនូវយោនិសោមនសិការ ក្នុងបដិឃនិមិត្ត**

**នោះ នេះជាអាហារដើម្បីការកើតឡើងនៃព្យាបាទ ដែលនៅមិនទាន់កើតឡើង ឬដើម្បីធ្វើឱ្យព្យាបាទដែលកើតឡើងហើយ កម្រើកកាន់តែខ្លាំងឡើង ។**

## ហេតុលះបង់ព្យាបាទ

តែព្យាបាទនោះ នឹងលះបង់បានដោយការធ្វើទុកក្នុងចិត្ត ឱ្យបានត្រឹមត្រូវ ក្នុងមេត្តាចេតោវិមុត្តិ , កាលនិយាយដល់មេត្តា រមែងគួរទាំងអប្បនាទាំងឧបចារៈ ។

បទថា **មេត្តាចេតោវិមុត្តិ** បានដល់ អប្បនាយោនិសោមនសិការ មានលក្ខណៈដូចពោលហើយ ។ កាលភិក្ខុធ្វើយោនិសោមនសិការឱ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងមេត្តាចេតោវិមុត្តិនោះ រមែងលះបង់នូវព្យាបាទបាន ។

ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិមានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការ ក្នុងមេត្តាចេតោវិមុត្តិនោះ នេះជាអាហារដើម្បីការមិនកើតឡើងនៃព្យាបាទដែលមិនទាន់កើតឡើង ឬ ដើម្បីលះបង់នូវព្យាបាទដែលកើតឡើងហើយ ។**

## ធម៌សម្រាប់លះបង់ព្យាបាទ

ម្យ៉ាងទៀត ធម៌ **៦** ប្រការ ប្រព្រឹត្តទៅដើម្បីលះបង់នូវព្យាបាទ គឺ **១**-ការកំណត់និមិត្តក្នុងមេត្តាជាអារម្មណ៍ **២**-ការប្រកបរឿយ ៗ នូវមេត្តាភាវនា **៣** - ការពិចារណាដល់សត្វមានកម្មជារបស់ខ្លួន **៤** - ការធ្វើឱ្យច្រើននូវការ

ពិចារណា **៥**-ការមាននូវកល្យាណមិត្ត **៦**-ការនិយាយក្នុងរឿងជាទីសប្បាយ ។

ពិតហើយ កាលភិក្ខុកំណត់មេត្តាកម្មដ្ឋាន ដោយការផ្សាយមេត្តាទៅកាន់ទិសទាំងពួងដោយចំពោះ ឬ ដោយមិនចំពោះ យ៉ាងណាមួយ រមែងលះបង់ព្យាបាទបាន ។ កាលភិក្ខុចម្រើនមេត្តា ផ្សាយទៅកាន់ទិសដោយចំពោះក្តី មិនចំពោះក្តី កាលពិចារណានូវខ្លួនឯង និងអ្នកដទៃ មានកម្មជារបស់ខ្លួនយ៉ាងនេះហើយ យើងក្រោធនឹងបុគ្គលនោះ ធ្វើអ្វីគេកើត យើងអាចធ្វើសីលជាដើមរបស់គេឱ្យវិនាសបានដែរឬ គេមកហើយដោយកម្មរបស់គេ ទៅវិញ ក៏ដោយកម្មរបស់គេដែរ ដែលពិតការក្រោធនឹងអ្នកដទៃ ប្រៀបដូចជាអ្នកប្រាថ្នានឹងចាប់ដុំភ្លើង ដ៏ក្រហមឆ្អៅ ជាដុំដែកក្តៅដែលប្រឡាក់ដោយលាមក ប្រហារអ្នកដទៃដូច្នោះ ឬ បើអ្នកដទៃក្រោធនឹងយើង គេនឹងធ្វើអ្វីយើងកើត គេអាចធ្វើសីលជាដើមរបស់យើងឱ្យវិនាសបានដែរឬ យើងមកដោយកម្មរបស់យើងទៅវិញក៏ដោយកម្មរបស់យើង ការក្រោធនោះ នឹងធ្លាក់ទៅលើគេវិញនោះឯង ដូចជាប្រហារអ្នកមិនប្រហារតប និងដូចជាផ្លុំធូលីបញ្ច្រាស់ខ្យល់ កាលពិចារណាកម្មស្សកតាទាំង ២ ចំណែក ធ្ងន់ដោយការពិចារណាក្តី សេពគប់កល្យាណមិត្តដែលជាអ្នករីករាយក្នុងការចម្រើនមេត្តា ដូចជាព្រះអស្សគុត្តត្ថេរក្តី រមែងលះបង់នូវព្យាបាទបាន ។ សូម្បីការនិយាយរឿងជាទីសប្បាយ អាស្រ័យមេត្តាក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះបង់ព្យាបាទបាន។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវព្យាបាទ ។ ភិក្ខុរមែងដឹងថា ព្យាបាទលះបង់បានដោយធម៌ ៦ ប្រការនេះ នឹងមិនកើតឡើងបានទៀត ដោយអនាគាមិមគ្គ ។**

## ហេតុកើតឡើងនៃថីនមិទ្ធៈ

**ថីនមិទ្ធៈ** រមែងកើតឡើងដោយអយោនិសោមនសិការ ក្នុងធម៌ទាំង-ឡាយ មានអរតិជាដើម ។ ការមិនរីករាយជាមួយអ្នកដទៃ( ឫស្សា ) ឈ្មោះថា **អរតិ** ។ សេចក្ដីទម្រន់កាយ ការពត់កាយ ការស្រវឹងអាហារ ការរសាប់រសល់ព្រោះអាហារ អាការ គឺ ការរួញចិត្ត កាលភិក្ខុធ្វើអយោនិសោមនសិការ ឱ្យប្រព្រឹត្តទៅច្រើន ក្នុងអរតិជាដើម **ថីនមិទ្ធៈ** រមែងកើតឡើង ។

ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ សេចក្ដីមិនត្រេកអរ ការទម្រន់កាយ ការពត់កាយ ការស្រវឹងអាហារ ការរួញចិត្តមានហើយ ការធ្វើឱ្យច្រើននូវអយោនិសោ-មនសិការក្នុងធម៌ទាំងឡាយនោះ នេះជាអាហារ ដើម្បីការកើតឡើងនៃថីនមិទ្ធៈដែលមិនទាន់កើតឡើង ឬ ដើម្បីធ្វើថីនមិទ្ធៈដែលកើតឡើងហើយ ឱ្យកាន់តែកម្រើកក្រៃលែងឡើង** ។

## ហេតុលះបង់នូវថីនមិទ្ធៈ

តែថីនមិទ្ធៈនោះ នឹងលះបង់បានដោយយោនិសោមនសិការ ក្នុងធម៌ទាំងឡាយ មានអារព្ភធាតុជាដើម , សេចក្ដីព្យាយាមជាខាងដើម ឈ្មោះថា **អារព្ភធាតុ** , សេចក្ដីព្យាយាមដែលមានកម្លាំងជាងអារព្ភធាតុនោះ ព្រោះកន្លងផុតនូវសេចក្ដីខ្ជិលច្រអូស ឈ្មោះថា **និក្កមធាតុ** , សេចក្ដីព្យាយាមដែលមានកម្លាំងជាងនិក្កមធាតុនោះ ព្រោះកន្លងឋានៈដទៃ ៗ ឈ្មោះថា **បរក្កមធាតុ** ការបោះពួយទៅមុខ , កាលភិក្ខុធ្វើយោនិសោមនសិការឱ្យប្រព្រឹត្តទៅច្រើន ៗ ក្នុង

សេចក្ដីព្យាយាម **៣** ប្រភេទនេះ រមែងលះបង់ថីនមិទ្ធៈបាន ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ **ធាតុ** គឺ ការផ្ដើមសេចក្ដីព្យាយាម , **ធាតុ** គឺ ការឈានកន្លងនូវសេចក្ដីខ្ជិលច្រអូស , **ធាតុ** គឺ ការបោះពួយទៅខាងមុខ មានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធាតុទាំងឡាយនោះ នេះជាអាហារ ដើម្បីការមិនកើតឡើងនូវថីនមិទ្ធៈ ដែលមិនទាន់កើតឡើង ឬ ដើម្បីលះបង់នូវថីនមិទ្ធៈដែលកើតឡើងហើយ ។

## ធម៌សម្រាប់លះបង់ថីនមិទ្ធៈ

ម្យ៉ាងទៀត ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់ថីនមិទ្ធៈ គឺ **១**-ការកំណត់និមិត្តក្នុងភោជនដែលលើស **២**-ការផ្លាស់ប្ដូរឥរិយាបថ **៣** - ការធ្វើទុកក្នុងចិត្តក្នុងអាលោកសញ្ញា **៤** - ការនៅក្នុងទីស្រឡះ **៥** - ការមានកល្យាណមិត្ត **៦** - ការនិយាយរឿងជាទីសប្បាយ ។

ព្រោះថា កាលភិក្ខុបរិភោគភោជន ដូចព្រាហ្មណ៍ដែល ឈ្មោះថា អាហារហត្ថកៈ តត្រវដ្ដកៈ អលង្សាដកៈ កាកមាសកៈ និង ឈ្មោះ ភុត្តវមិតកៈ អង្គុយក្នុងទីសម្រាកពេលយប់ និង ទីសម្រាកពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងមកគ្របសង្កត់បាន ដូចដំរីមកសង្កត់ តែថីនមិទ្ធៈនោះ នឹងមិនមានដល់ភិក្ខុដែលវៀរចាកឱកាសបរិភោគប្រមាណ ៤-៥ ដុំ ទៀតឆ្អែត ហើយក៏ផឹកទឹកញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅជាប្រក្រតី ព្រោះហេតុនោះ កាលភិក្ខុកំណត់និមិត្តក្នុងភោជនដែលលើស យ៉ាងនេះ រមែងលះថីនមិទ្ធៈបាន កាលភិក្ខុមានថីនមិទ្ធៈក្នុងឥរិយាបថណា ផ្លាស់ប្ដូរឥរិយាបថដទៃ ចាកពីឥរិយាបថនោះ ក៏អាចលះបង់

ថីនមិទ្ធៈបាន កាលភិក្ខុដាក់ចិត្តទៅក្នុងពន្លឺព្រះចន្ទ ពន្លឺប្រទីប ពន្លឺគប់ភ្លើង ក្នុងពេលយប់ ពន្លឺព្រះអាទិត្យក្នុងពេលថ្ងៃ នៅក្នុងទីវាលស្រឡះក្តី សេពគប់កល្យាណមិត្តដែលលះបង់ថីនមិទ្ធៈបាន ដូចព្រះមហាកស្សបត្ថេរក្តី រមែងលះថីនមិទ្ធៈបាន ។ សូម្បីការចរចាតែរឿងដែលជាទីសប្បាយ ដែលអាស្រ័យធុតង្គក្នុងឥរិយាបថទាំងឡាយ មានឈរ_អង្គុយជាដើម ក៏លះបង់ថីនមិទ្ធៈបាន ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ថា ធម៌ ៦ ប្រការ នេះ ប្រព្រឹត្តទៅដើម្បីលះបង់ថីនមិទ្ធៈ ។ ភិក្ខុរមែងដឹងច្បាស់ថា ថីនមិទ្ធៈរមែងលះបង់បានដោយធម៌ ៦ ប្រការ នឹងមិនកើតឡើងបានទៀតដោយអរហត្តមគ្គ ។

## ហេតុឱ្យកើតឧទ្ធច្ចកុក្កុច្ចៈ

**ឧទ្ធច្ចកុក្កុច្ចៈ** រមែងកើតឡើងដោយអយោនិសោមនសិការក្នុងសេចក្តីមិនស្ងប់នៃចិត្ត , អាការមិនស្ងប់ ឈ្មោះថា សេចក្តីមិនស្ងប់ ពាក្យនេះ ដោយអត្ថ គឺ ឧទ្ធច្ចកុក្កុច្ចៈនោះឯង ។

កាលភិក្ខុធ្វើអយោនិសោមនសិការ ឱ្យប្រព្រឹត្តទៅកាន់តែច្រើន ក្នុងសេចក្តីមិនស្ងប់នៃចិត្តនោះ ឧទ្ធច្ចកុក្កុច្ចៈរមែងកើតឡើង ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ សេចក្តីមិនស្ងប់នៃចិត្តមានហើយ ការធ្វើឱ្យច្រើននូវអយោនិសោមនសិការ ក្នុងសេចក្តីមិនស្ងប់នៃចិត្តនោះ នេះជាអាហារដើម្បីការកើតឡើងនៃឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ឬ ដើម្បីធ្វើឧទ្ធច្ច-កុក្កុច្ចៈដែលកើតឡើងហើយ ឱ្យកាន់តែកម្រើកខ្លាំងឡើង ។**

## ហេតុលះបង់ឧទ្ធច្ចកុក្កុច្ចៈ

តែឧទ្ធច្ចកុក្កុច្ចៈនោះ លះបង់បានដោយយោនិសោមនសិការក្នុងសេចក្តីស្ងប់នៃចិត្ត ពោលគឺ សមាធិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **ម្នាលភិក្ខុទាំងឡាយ សេចក្តីស្ងប់នៃចិត្តមានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងសេចក្តីស្ងប់នៃចិត្តនោះ នេះជាអាហារដើម្បីការមិនកើតឡើងនៃឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ដើម្បីលះបង់នូវឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ដូច្នេះ ។**

## ធម៌សម្រាប់លះឧទ្ធច្ចកុក្កុច្ចៈ

ម្យ៉ាងទៀត ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺ **១** - ការស្តាប់ច្រើន **២** - ការសាកសួរ **៣** - ការជំនាញក្នុងវិន័យ **៤**- សេពគប់អ្នកដែលមានការចម្រើន **៥**- មានកល្យាណមិត្ត **៦**- ការនិយាយតែរឿងជាទីសប្បាយ ។

ពិតហើយ កាលភិក្ខុសិក្សាទាំងព្រះបាលី ទាំងអដ្ឋកថា ១និកាយ ២និកាយ ៣និកាយ ៤និកាយ ឬ ៥និកាយ រមែងលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ ។ សូម្បីដោយភាពជាពហុស្សូត ( ភាពជាអ្នកស្តាប់ច្រើន ) ភិក្ខុដែលច្រើនដោយការសាកសួរក្នុងវត្ថុដែលគួរ និងមិនគួរក្តី អ្នកជំនាញ ព្រោះមានភាពជំនាញដែលបានសន្សំទុកក្នុងវិនយបញ្ញត្តិក្តី អ្នកចូលទៅរកព្រះថេរៈចាស់ៗក្តីព្រឹទ្ធាចារ្យក្តី សេពគប់កល្យាណមិត្តដែលទ្រទ្រង់ព្រះវិន័យ ដូចជាព្រះឧបាលីថេរៈក្តី រមែងលះបង់ឧទ្ធច្ចកុក្កុច្ចៈបាន ។ សូម្បីដោយការនិយាយតែរឿងដែលជាសប្បាយ

ដែលអាស្រ័យវត្ថុ ដែលគួរនិងមិនគួរ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ក៏លះបង់ឧទ្ធច្ចកុក្កុច្ចៈបានដែរ ។ ព្រោះដូចោះទើបទ្រង់ពោលថា ធម៌ ៦ ប្រការនេះ ប្រព្រឹត្តទៅដើម្បីលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ ។ ភិក្ខុដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈលះបង់បានដោយធម៌ ៦ ប្រការនេះ , **ឧទ្ធច្ចៈ** មិនកើតឡើងតទៅទៀតដោយអរហត្តមគ្គ , **កុក្កុច្ចៈ** មិនកើតឡើងទៀតដោយអនាគាមិមគ្គ ។

## ហេតុកើតឡើងនៃវិចិកិច្ឆា

**វិចិកិច្ឆា** រមែងកើតឡើងដោយអយោនិសោមនសិការ ក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃវិចិកិច្ឆា , ការងឿងឆ្ងល់ ជាហេតុនៃសេចក្ដីសង្ស័យរឿយ ៗ ឈ្មោះថា ធម៌ជាទីតាំងនៃវិចិកិច្ឆា , កាលភិក្ខុធ្វើអយោនិសោមនសិការឱ្យប្រព្រឹត្តទៅរឿយៗ ក្នុងធម៌ជាទីតាំងនៃវិចិកិច្ឆានោះ វិចិកិច្ឆារមែងកើតឡើង ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃវិចិកិច្ឆាមានហើយ ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងធម៌ ជាទីតាំងនៃវិចិកិច្ឆានោះ នេះជាអាហារដើម្បីការកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើង ឬ ដើម្បីធ្វើឱ្យវិចិកិច្ឆាដែលកើតឡើងហើយ ឱ្យកម្រើកកាន់តែខ្លាំងឡើង ។**

## ហេតុលះបង់វិចិកិច្ឆា

តែវិចិកិច្ឆានោះ លះបង់បានដោយយោនិសោមនសិការក្នុងធម៌ មានកុសលជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាកុសល អកុសល ធម៌ដែលមានទោស ធម៌មិនមានទោស ធម៌គួរសេព ធម៌មិនគួរសេព ធម៌ថោកទាប-ប្រណីត ធម៌ស ធម៌ខ្មៅ មានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងអស់នោះ នេះជាអាហារដើម្បីការមិនកើតឡើងនៃវិចិកិច្ឆាដែលមិនទាន់កើតឡើង ឬ ដើម្បីលះបង់វិចិកិច្ឆាដែលកើតឡើងហើយ ។**

## ធម៌សម្រាប់លះបង់វិចិកិច្ឆា

ម្យ៉ាងទៀត ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់វិចិកិច្ឆា គឺ **១**-ការស្តាប់ច្រើន **២**-ការសាកសួរ **៣**-ការជំនាញក្នុងវិន័យ **៤**-ការសម្បូរណ៍ដោយសទ្ធា **៥**- ការមាននូវកល្យាណមិត្ត **៦**- ការនិយាយរឿងជាទីសប្បាយ ។

ពិតហើយ កាលបុគ្គលសិក្សាទាំងព្រះបាលី ទាំងអដ្ឋកថា ១និកាយ ២និកាយ ៣និកាយ ៤និកាយ ៥និកាយ រមែងលះបង់វិចិកិច្ឆាបាន ដោយភាពជាពហុស្សូត ។ កាលភិក្ខុច្រើនដោយការប្រារព្ធព្រះរតនត្រៃ សួរបញ្ហាក្តី មានភាពជំនាញក្នុងវិន័យក្តី ច្រើនទៅដោយការជឿក្តី ពោលគឺ មានសទ្ធាមិនកម្រើកក្នុងព្រះរតនត្រៃក្តី សេពគប់កល្យាណមិត្ត ដូចជាព្រះវក្កលិដែលសម្បូរដោយសទ្ធាក្តី រមែងលះបង់វិចិកិច្ឆាបាន ។ សូម្បីដោយការនិយាយរឿងជាទីសប្បាយ ដែលអាស្រ័យគុណព្រះរតនត្រៃ ក្នុងឥរិយាបថទាំងឡាយ មានឈរ-អង្គុយជាដើម ក៏លះបង់វិចិកិច្ឆាបាន ។ ព្រោះហេតុនោះ ធម៌ **៦** ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះបង់វិចិកិច្ឆា ភិក្ខុរមែងដឹងច្បាស់ថា វិចិកិច្ឆា លះបង់បានដោយធម៌ទាំងនេះ រមែងមិនកើតតទៅទៀតដោយសោតាបត្តិមគ្គ ។

ពាក្យថា **ឥតិ អជ្ឈត្តំ វា** - ឬខាងក្នុង មានន័យថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ឬ ក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់នីវរណធម៌ទាំង ៥ នេះ ។ ការកើតឡើង និង ការរលត់ទៅ ក្នុងពាក្យថា **ពិចារណាឃើញ ធម៌** គឺ ការកើតឡើង និងការរលត់ទៅ នេះពោលហើយក្នុងនីវរណធម៌ **៥** ដោយអំណាចអយោនិសោមនសិការ និង យោនិសោមនសិការ ក្នុងសុភនិមិត្ត និងអសុភនិមិត្តជាដើម បណ្ឌិតគប្បីនាំមកប្រៀបធៀបចុះ ។

( ចប់ នីវរណបព្វៈ )

# ២ - ខន្ធបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំង-ឡាយ គឺ ឧបាទានក្ខន្ធ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ( ពិចារណាឃើញដូច្នេះថា ) រូបមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាទីកើតឡើងនៃរូប មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃរូប មានប្រមាណប៉ុណ្ណេះ វេទនាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនា មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃវេទនា មានប្រមាណប៉ុណ្ណេះ សញ្ញាមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញា មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃសញ្ញា មានប្រមាណប៉ុណ្ណេះ សង្ខារទាំងឡាយមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃសង្ខារទាំងឡាយ មានប្រមាណប៉ុណ្ណេះ វិញ្ញាណមានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ ធម៌ដែលជាដែនវិនាសទៅនៃវិញ្ញាណ មានប្រមាណប៉ុណ្ណេះ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយទាំងខាងក្នុងទាំងខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណា

ឃើញនូវធម៌ គឺ ការកើតឡើងនៃធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញនូវធម៌ គឺ ការរលត់ទៅនៃធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការកើតឡើង និងធម៌ គឺ ការរលត់ទៅនៃធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី ( ជាគ្រឿងកំណត់ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌មានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យដោយ ( តណ្ហា-ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធទាំង **៥** ជាប្រក្រតី គ្រប់ឥរិយាបថទាំង **៤** យ៉ាងនេះឯង ។

## អដ្ឋកថា

ព្រះមានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនា ដោយនីវរណធម៌ ៥ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់ចែកដោយខន្ធ **៥** ទើបត្រាស់ **បុន ចបរំ** សេចក្តីដទៃ នៅមានទៀត ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ ពាក្យថា **ក្នុងឧបាទានក្ខន្ធ ៥** គឺ គំនរឧបាទានឈ្មោះថា **ឧបាទានក្ខន្ធ** អធិប្បាយថា គំនរធម៌ គឺ ប្រជុំធម៌ដែលជាបច្ច័យនៃឧបាទាន ។ សេចក្តីសង្ខេបក្នុងទីនេះមានប៉ុណ្ណោះ ចំណែកសេចក្តីពិស្តារ លោកពោលទុកក្នុងគម្ពីរវិសុទ្ធិមគ្គខន្ធកថាហើយ ។ បទថា **ឥតិ រូបំ** ដូច្នេះ **រូប** មានន័យថា នេះរូប រូបមានប៉ុណ្ណោះ ភិក្ខុរមែងដឹងច្បាស់ដោយសភាវៈថា រូបដទៃ

ក្រៅពីនោះ មិនមាន ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យដូចគ្នា ។ បទថា **ឥតិ រូបស្ស សមុទយោ**-នេះការកើតឡើងនៃរូប មានន័យថា ការកើតឡើងនៃរូបប្រកបដោយអាការ **៥** ដោយការកើតឡើងនៃ **អវិជ្ជា** ជាដើម រមែងមានដោយអាការនេះ ។ ពាក្យថា **ឥតិ រូបស្ស អត្ថង្គមោ**-នេះការរលត់ទៅនៃរូប មានន័យថា ការរលត់ទៅនៃរូបប្រកបដោយអាការ ៥ ដោយការរលត់ទៅនៃអវិជ្ជាជាដើម រមែងមានដោយអាការយ៉ាងនេះ ។ សូម្បីក្នុងវេទនាជាដើម ក៏មានន័យដូចគ្នា ។ សេចក្តីសង្ខេបមានត្រឹមប៉ុណ្ណេះ ឯសេចក្តីពិស្តារ លោកពោលទុកក្នុងឧទយព្វយញ្ញាណ ក្នុងវិសុទ្ធមគ្គហើយ ។

វិសុទ្ធិមគ្គ : **ឧទយព្វយានុបស្សនា** - ព្រះយោគី ជាអ្នកមានញាណបរិសុទ្ធ ព្រោះលះបង់នូវនិច្ចសញ្ញាជាដើម ដែលជាបដិបក្ខធម៌នៃវិបស្សនាមានអនិច្ចានុបស្សនាជាដើម ដល់ត្រើយនៃសម្មសនញ្ញាណយ៉ាងនេះហើយ ក៏ផ្តើមឡើងនូវសេចក្តីព្យាយាម ដើម្បីសម្រេចនូវឧទយព្វយានុបស្សនញ្ញាណដែលលោកពោលទុកក្នុងលំដាប់នៃសម្មសនញ្ញាណថា បញ្ញាក្នុងការពិចារណាឃើញការប្រែប្រួលនៃធម៌ទាំងឡាយ ដែលកំពុងកើតឡើងប្រាកដ ឈ្មោះថា **ឧទយព្វយានុបស្សនញ្ញាណ ញាណក្នុងការពិចារណាឃើញការកើតឡើង និងការរលត់ទៅ** កាលផ្តើមធ្វើ រមែងផ្តើមដោយការសង្ខេបមុន នេះជាព្រះបាលីក្នុងការផ្តើមធ្វើដោយសង្ខេបនោះ :

**សួរថា** បញ្ញា ក្នុងការពិចារណាឃើញការប្រែប្រួលនៃធម៌ទាំងឡាយដែលកំពុងកើតឡើងប្រាកដ ឈ្មោះថា **ឧទយព្វយានុបស្សនញ្ញាណ** តើដូចម្តេច?

**ឆ្លើយថា** រូបកើតឡើងជាបច្ចុប្បន្ន លក្ខណៈនៃការកើតឡើងរបស់រូប

នោះជា **ឧទយ** , លក្ខណៈនៃការប្រែប្រួលនៃរូបនោះជា **វយ** បញ្ញាពិចារណាឃើញ " **ឧទយ** និង **វយ** នោះ " ជាញាណ , វេទនា សញ្ញា សង្ខារ វិញ្ញាណកំពុងកើតឡើងជាបច្ចុប្បន្ន លក្ខណៈដែលកើតឡើងនៃ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះជា **ឧទយ** និងលក្ខណៈនៃការប្រែប្រួលនៃ វេទនា សញ្ញា សង្ខារ វិញ្ញាណនោះជា **វយ** បញ្ញាពិចារណាឃើញនូវ " **ឧទយ** និង **វយ** នោះ " ជា **ញាណ** , **ចក្ខុ** កើតឡើងជាបច្ចុប្បន្ន ។ ល ។ **ភព** កើតឡើងជាបច្ចុប្បន្ន ។ ល ។ លក្ខណៈដែលកើតឡើងនៃ **ចក្ខុ** ។ ល ។ **ភព** នោះជា **ឧទយ** លក្ខណៈដែលប្រែប្រួលនៃ **ចក្ខុ** ។ ល ។ **ភព** នោះជា **វយ** បញ្ញាពិចារណាឃើញ "**ឧទយ** និង **វយ** នោះ" ជា **ញាណ** ។

ព្រះយោគាវចរនោះ ពិចារណាឃើញនិព្វត្តិលក្ខណៈ គឺ ការកើតឡើង អាការដែលកើតថ្មីនៃនាមរូបដែលកើតឡើងថាជា **ឧទយ** , ពិចារណាឃើញ វិបរិណាមលក្ខណៈ គឺ ការប្រែប្រួលទៅនៃនាមរូបដែលកើតហើយថាជា **វយ** តាមន័យបាលីនេះ លោករមែងដឹងទូទៅយ៉ាងនេះថា " ក្នុងកាលមុននៃការកើតឡើងរបស់នាមរូបនេះ ឬ គំនរនៃនាមរូបនេះ មិនទាន់មាននៅឡើយទេ ហើយនាមរូបនេះ កើតចាកពីនាមរូបដែលកំពុងតែកើត ក៏មិនមែន ឯការរលត់ហើយ ទៅរួមគ្នាជាគំនរ ជាពួក ជាសំណុំ ក្នុងទីណាមួយនៃនាមរូបនោះ ក៏មិនមែន ដូចជាពិណដែលបុគ្គលដេញហើយ សំឡេងដែលកើតឡើងនោះ មិនមែនមានស្រាប់ហើយនោះទេ ពេលកំពុងកើត វាក៏មិនបានមកពីទីណា ការទៅកាន់ទិសធំទិសតូចនៃសំឡេងដែលកំពុងរលត់ ក៏មិនមាន វារលត់ហើយ ក៏មិនបានទៅប្រជុំគ្នានៅទីណា ការពិតសំឡេងពិណនោះ មិនមាន ក៏មានឡើង

ព្រោះអាស្រ័យតូពិណ កពិណ និង សេចក្ដីព្យាយាម ដែលសមគួរដល់ការនោះៗរបស់មនុស្ស កាលមានហើយ ក៏រលត់ទៅវិញយ៉ាងណា ធម៌ទាំងឡាយទាំងដែលមានរូប ទាំងដែលមិនមានរូបទាំងពួង មិនមាន ក៏មានឡើង កាលមានហើយ ក៏រលត់ទៅវិញដូច្នោះឯង ។

ព្រះយោគី កាលធ្វើឧទយព្វយមនសិការដោយសង្ខេប ដូច្នេះហើយ ទើបធ្វើមនសិការយ៉ាងពិស្ដារដោយបច្ច័យ និង ដោយខណៈទៀត ជាដើមថា ការកើតឡើងនៃរូប រមែងមាន " ព្រោះការកើតឡើងនៃបច្ច័យ " យ៉ាងនេះខ្លះ ការរលត់ទៅនៃរូប " ព្រោះការរលត់ទៅនៃបច្ច័យ " យ៉ាងនេះខ្លះ រូបរមែងកើតឡើង ( ដោយខណៈ ) យ៉ាងនេះខ្លះ រូបរមែងរលត់ទៅ ( ដោយខណៈ ) យ៉ាងនេះខ្លះ តាមលក្ខណៈ **៥០** ដោយធ្វើជា ១០ ៗ ក្នុងការឃើញការកើតរលត់នៃខន្ធមួយ ៗ ទើបលោកពោលទុកក្នុងវិភង្គនៃឧទយព្វយញ្ញាណនោះដូច្នេះថា " ភិក្ខុ រមែងឃើញការកើតឡើងនៃរូបក្ខន្ធ ដោយអត្ថ គឺ ការកើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូប រមែងមានព្រោះការកើតឡើងនៃអវិជ្ជា, រមែងឃើញការកើតឡើងនៃរូបក្ខន្ធ ដោយអត្ថ គឺ ការកើតឡើងនៃបច្ច័យថា ការកើតឡើងនៃរូបរមែងមាន ព្រោះការកើតឡើងនៃតណ្ហា ព្រោះការកើតឡើងនៃកម្ម ព្រោះការកើតឡើងនៃអាហារ សូម្បីឃើញនិព្វត្តិលក្ខណៈ ( លក្ខណៈដែលកើតឡើងនៃរូប ) ក៏ឈ្មោះថា ឃើញការកើតឡើងនៃរូបក្ខន្ធ កាលឃើញការកើតឡើងនៃរូបក្ខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ , ភិក្ខុរមែងឃើញការរលត់ទៅនៃរូបក្ខន្ធដោយអត្ថ គឺ ការរលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូបរមែងមាន ព្រោះការរលត់ទៅនៃអវិជ្ជា ឃើញការរលត់ទៅនៃរូប ដោយអត្ថ

គឺ ការរលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃរូបរមែងមាន ព្រោះការរលត់ទៅនៃតណ្ហា ព្រោះការរលត់ទៅនៃកម្ម ព្រោះការរលត់ទៅនៃអាហារ សូម្បីឃើញវិបរិណាមលក្ខណៈ ក៏ឈ្មោះថា ឃើញការរលត់ទៅនៃរូបក្ខន្ធ កាលឃើញការរលត់ទៅនៃរូបក្ខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ **៥** នេះ ” ។

ន័យដូចគ្នានេះដែរ ភិក្ខុ រមែងពិចារណាឃើញវេទនាខន្ធ ដោយអត្ថ គឺ ការកើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនា រមែងមានព្រោះការកើតឡើងនៃអវិជ្ជា រមែងឃើញការកើតឡើងនៃវេទនាខន្ធ ដោយអត្ថ គឺ ការកើតឡើងនៃបច្ច័យថា ការកើតឡើងនៃវេទនារមែងមាន ព្រោះការកើតឡើងនៃតណ្ហា ព្រោះការកើតឡើងនៃកម្ម ព្រោះការកើតឡើងនៃផស្សៈ សូម្បីឃើញនិព្វត្តិលក្ខណៈ ក៏ឈ្មោះថា ឃើញការកើតឡើងនៃវេទនាខន្ធ សូម្បីឃើញការកើតឡើងនៃវេទនាខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ **៥** នេះ , ភិក្ខុ រមែងឃើញការរលត់នៃវេទនាខន្ធ ដោយអត្ថ គឺ ការរលត់ទៅនៃបច្ច័យថា ការរលត់ទៅនៃវេទនាខន្ធ រមែងមានព្រោះការរលត់ទៅនៃអវិជ្ជា ព្រោះការរលត់ទៅនៃតណ្ហា ព្រោះការរលត់ទៅនៃកម្ម ព្រោះការរលត់ទៅនៃផស្សៈ សូម្បីឃើញវិបរិណាមលក្ខណៈ ( នៃវេទនា ) ក៏ឈ្មោះថា ឃើញការរលត់ទៅនៃវេទនាខន្ធ សូម្បីឃើញការរលត់ទៅនៃវេទនាខន្ធ ក៏ឈ្មោះថា ឃើញលក្ខណៈ ៥ នេះ ។

រីឯ សញ្ញាខន្ធ សង្ខារក្ខន្ធ និង វិញ្ញាណក្ខន្ធ ក៏ដូចនឹងវេទនាខន្ធដែរ តែមានសេចក្ដីខុសគ្នា សម្រាប់វិញ្ញាណក្ខន្ធ គឺ ប្រកបពាក្យថា **នាមរូបសមុទយា** - ព្រោះការកើតឡើងនៃនាមរូប **នាមរូបនិរោធា** - ព្រោះការរលត់ទៅនៃនាមរូប ជំនួសត្រង់កន្លែង **ផស្សៈ** ។

កាលព្រះយោគាវចរនោះ មនសិការយ៉ាងនេះ **ញាណ** ដឹងថា " **ធម៌ទាំងនេះ មិនមានក៏មានឡើង កាលមានហើយក៏វិនាសទៅវិញ** " កាន់តែមុតខ្លាំងឡើង។

កាលព្រះយោគាវចរនោះ ឃើញការកើតឡើង និង ការរលត់ទៅ ដោយចំណែកទាំង **២** គឺ :

ដោយបច្ច័យ ១ ដោយខណៈ ១ យ៉ាងនេះហើយ ភាពផ្សេងគ្នានៃសច្ចៈ បដិច្ចសមុប្បាទន័យហើយ លក្ខណៈរមែងប្រាកដ ។

ព្រះយោគាវចរនោះ ឃើញការកើតឡើងនៃខន្ធទាំងឡាយ ព្រោះការកើតឡើងនៃបច្ច័យ មានអវិជ្ជាជាដើម ឃើញការរលត់នៃខន្ធទាំងឡាយ ព្រោះការរលត់នៃបច្ច័យ មានអវិជ្ជាជាដើម យ៉ាងណា ការនេះ ជាការឃើញការកើតឡើង និង ការរលត់ទៅដោយបច្ច័យរបស់ខ្លួន រីឯ កាលឃើញលក្ខណៈដែលកើត និងលក្ខណៈដែលប្រែប្រួលទៅ ទើបឃើញការកើត និង ការវិនាសទៅនៃខន្ធទាំងឡាយ យ៉ាងណា ការនេះ ជាការឃើញការកើត និង ការរលត់ទៅដោយខណៈរបស់ខ្លួន ព្រោះថា លក្ខណៈដែលកើតឡើង រមែងមានតែក្នុងឧប្បាទខណៈប៉ុណ្ណោះ ហើយលក្ខណៈដែលប្រែប្រួល រមែងមានក្នុងភង្គខណៈ ។

## សច្ចៈប្រាកដ

ហេតុនេះ កាលព្រះយោគាវចរនោះឃើញការកើតឡើង និងការរលត់ទៅទាំង **២** ចំណែក គឺ ដោយបច្ច័យ ១ ដោយខណៈ ១ ដូចដែលពោលមកដូច្នេះហើយ ការឃើញការកើតឡើងដោយបច្ច័យ **សមុទយសច្ច** ក៏ប្រាកដ ព្រោះដឹងបច្ច័យដែលឱ្យកើតឡើង , ដោយការឃើញការកើតឡើងដោយខណៈ

**ទុក្ខសច្ច** ក៏ប្រាកដ ព្រោះដឹងជាតិទុក្ខ , ដោយការឃើញការរលត់ទៅដោយបច្ច័យ **និរោធសច្ច** ក៏ប្រាកដ ព្រោះដឹងនូវការមិនកើតឡើងនៃវត្ថុដែលមានបច្ច័យតាក់តែងទាំងឡាយ ដោយការមិនកើតឡើងនៃបច្ច័យ , ការឃើញការវិនាសទៅដោយខណៈ **ទុក្ខសច្ច** ក៏ប្រាកដទៀត ព្រោះដឹងមរណទុក្ខ ចំណែកការឃើញការកើតឡើង និង ការវិនាសទៅ ( ទាំងដោយបច្ច័យ និង ដោយខណៈ ) នៃព្រះយោគាវចរនោះ យ៉ាងណា ការនេះ ជាលោកិយមគ្គ ព្រោះហេតុនោះ **មគ្គសច្ច** ក៏ប្រាកដ ព្រោះតែកម្ចាត់នូវ **សម្មោហ** - សេចក្ដីវង្វេងក្នុងមគ្គនោះបានហើយ ។

ពាក្យថា **ឥតិ អជ្ឈត្តំវា** - ឬខាងក្នុង មានន័យថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយរបស់ខ្លួន ក្នុងធម៌ទាំងឡាយរបស់អ្នកដទៃ ឬ ក្នុងធម៌ទាំង-ឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាល ដោយការកំណត់ខន្ធ **៥** យ៉ាងនេះ ។

**ការកើតឡើង** និង **ការរលត់ទៅ** ក្នុងពាក្យថា ពិចារណាឃើញធម៌ គឺការកើតឡើង និងការរលត់ទៅ បណ្ឌិត គប្បីនាំមកប្រៀបធៀបដោយលក្ខណៈ **៥០** ដែលពោលទុកក្នុងខន្ធ **៥** ព្រោះអវិជ្ជាកើត រូបទើបកើតឡើងដូច្នេះជាដើម ។ ( ការកើតដោយលក្ខណៈ ៥ មានការកើតនៃអវិជ្ជាជាដើម និងការរលត់ដោយលក្ខណៈ ៥ មានការរលត់នៃអវិជ្ជាជាដើម ។ ការកើត ៥ ការរលត់ ៥ បានលក្ខណៈ ១០ គុណក្នុងខន្ធ ៥ បានទៅជាលក្ខណៈ **៥០** ។ នេះជាផ្លូវបដិបត្តិចេញចាកទុក្ខរបស់ភិក្ខុដែលកំណត់ខន្ធជាអារម្មណ៍ ) ។

( ចប់ ខន្ធបព្វៈ )

# ៣-អាយតនបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវភ្នែកផង ដឹងច្បាស់នូវរូបទាំងឡាយផង មួយទៀតសញ្ញោជនៈណា អាស្រ័យនូវភ្នែក និងរូបទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតទៅទៀត ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុដឹងច្បាស់នូវត្រចៀកផង ដឹងច្បាស់នូវសំឡេងទាំងឡាយផង ។ ដឹងច្បាស់នូវច្រមុះផង ដឹងច្បាស់នូវក្លិនទាំងឡាយផង ។ ដឹងច្បាស់នូវអណ្តាតផង ដឹងច្បាស់នូវរសទាំងឡាយផង ។ ដឹងច្បាស់នូងកាយផង ដឹងច្បាស់នូវផោដ្ឋព្វៈទាំងឡាយផង ។ ដឹងច្បាស់នូវចិត្តផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង ។ សញ្ញោជនៈណា អាស្រ័យនូវចិត្ត និងធម្មារម្មណ៍ទាំងពីរនោះ ហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង សញ្ញោជនៈដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់បាននូវសញ្ញោជនៈដែលកើតឡើងហើយ ដោយហេតុ

ណា ក៏ដឹងច្បាស់នូវហេតុនោះផង សញ្ញោជនៈដែលលះបង់បានហើយ មិនកើតតទៅទៀតបាន ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ ក្នុងធម៌ទាំងឡាយខាងក្រៅ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញធម៌ គឺការរលត់ទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។

មួយទៀត ស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យដោយ ( តណ្ហា-ទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

ព្រះដ៏មានព្រះភាគ កាលទ្រង់ចែកធម្មានុបស្សនា ដោយអំណាចខន្ធ ៥ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់ចែកដោយអាយតនៈ ទើបត្រាស់ថា **បុន ចបរំ** សេចក្ដីដទៃនៅមានទៀត ដូច្នេះជាដើម ។

បណ្ដាបទទាំងឡាយនោះ បទថា **ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ** ក្នុងអាយតនៈខាងក្នុង និង ខាងក្រៅ ៦ មានន័យថា ក្នុងអាយតនៈខាង

ក្នុង **៦** នេះគឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ។ ក្នុងអាយតនៈខាងក្រៅ **៦** គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ បទថា **ចក្ខុញ្ច បជានាតិ - ដឹងច្បាស់នូវចក្ខុ** មានន័យថា រមែងដឹងនូវចក្ខុបសាទ ដោយលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្តីពិត ។ បទថា ***រូបេ ច បជានាតិ*** - ដឹងច្បាស់នូវរូប មានន័យថា រមែងដឹងច្បាស់នូវរូបដែលកើតពីសមុដ្ឋាន **៤** ( មាន កម្ម ចិត្ត ឧតុ អាហារ ) ក្នុងខាងក្រៅដោយលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្តីពិត។ ពាក្យថា **យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សំយោជនំ** - សំយោជនៈរមែងអាស្រ័យអាយតនៈទាំង២ កើតឡើង មានន័យថា សំយោជនៈ **១០** យ៉ាង គឺ ***កាមរាគ បដិឃ មាន ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ភវរាគ ឥស្សា មច្ឆរិយ*** និង ***អវិជ្ជា*** សំយោជនៈកើតឡើង ព្រោះអាស្រ័យអាយតនៈទាំង ២ គឺ ចក្ខុ និង រូប ។ និងរមែងដឹងច្បាស់នូវសំយោជនៈ **១០** នោះ ដោយលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្តីពិត ។

**១- កាមរាគសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលជាប់ជំពាក់នៅក្នុងកាមគុណារម្មណ៍ អង្គធម៌បានដល់ លោភចេតសិកដែលប្រកបក្នុងលោភមូលចិត្ត ៨ ។

**២- *ភវរាគសំយោជនៈ*** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលជាប់ជំពាក់នៅក្នុងរូបភព អរូបភព ឬ រូបឈាន អរូបឈាន អង្គធម៌បានដល់ លោភចេតសិក ដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៣- បដិឃសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលក្រោធខឹង អង្គធម៌បានដល់ ទោសចេតសិកដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៤- មានះសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលក្រអើត លើកកម្ពស់ វាយឫក អង្គធម៌បានដល់ មានះចេតសិក ដែលប្រកបក្នុងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ ។

**៥- ទិដ្ឋិសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលយល់ឃើញខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៦- សីលព្វតបរាមាសសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលស្ទាបអង្អែលក្នុងវត្តប្រតិបត្តិខុស អង្គធម៌បានដល់ ទិដ្ឋិចេតសិក ដែលប្រកបក្នុងទិដ្ឋិគតសម្បយុត្តចិត្ត ៤ ។

**៧- វិចិកិច្ឆាសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលសង្ស័យ ស្ទាក់ស្ទើរចិត្តក្នុងវត្ថុដែលគួរជឿ អង្គធម៌បានដល់ វិចិកិច្ឆាចេតសិក ដែលប្រកបក្នុងវិចិកិច្ឆាសម្បយុត្តចិត្ត ១ ។

**៨- ឥស្សាសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលច្រណែនក្នុងសម្បត្តិ ឬ គុណសេចក្ដីល្អរបស់អ្នកដទៃ អង្គធម៌បានដល់ ឥស្សា-ចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**៩- មច្ឆរិយសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលកំណាញ់ហួងហែងក្នុងសម្បត្តិ ឬ គុណសេចក្ដីល្អរបស់ខ្លួនឯង អង្គធម៌បានដល់ មច្ឆរិយចេតសិក ដែលប្រកបក្នុងទោសមូលចិត្ត ២ ។

**១០- អវិជ្ជាសំយោជនៈ** ធម្មជាតិដែលចងសត្វទុក ដោយអាការដែលវង្វេង ល្ងង់ខ្លៅ មិនដឹងសភាវធម៌តាមសេចក្ដីពិត អង្គធម៌បានដល់ មោហ-

ចេតសិក ដែលប្រកបក្នុងអកុសលចិត្ត ១២ ។

## ហេតុកើតឡើងនៃសំយោជនៈ

***សួរថា*** សំយោជនៈនោះ កើតឡើងបានយ៉ាងណា ?

**ឆ្លើយថា** កើតឡើងបានយ៉ាងនេះ សូមពោលក្នុងចក្ខុមុន កាលបុគ្គលត្រេកអររីករាយ ក្នុងឥដ្ឋារម្មណ៍ដែលប្រាកដតាមចក្ខុទ្វារ ដោយសេចក្តីត្រេកអរក្នុងកាមសំយោជនៈ គឺ **កាមរាគៈ** ក៏កើតឡើង , កាលបុគ្គលទាស់ចិត្តក្នុងអនិដ្ឋារម្មណ៍ សំយោជនៈ គឺ **បដិឃៈ** ក៏កើតឡើង ។ កាលសម្គាល់ថា វៀរយើងចេញហើយ នរណាដែលអាចសោយអារម្មណ៍នោះបាន មិនមាន ដូច្នេះ សំយោជនៈ គឺ **មានះ** ក៏កើតឡើង ។ កាលប្រកាន់រូបារម្មណ៍នោះថា ទៀងឋិតថេរ សំយោជនៈ គឺ **ទិដ្ឋិ** ក៏កើតឡើង ។ កាលសង្ស័យក្នុងរូបារម្មណ៍នោះថា សត្វ ឬហ្ន៎ ! របស់សត្វឬហ្ន៎ សំយោជនៈ គឺ **វិចិកិច្ឆា** ក៏កើតឡើង ។ កាលប្រាថ្នាភពថា អារម្មណ៍នេះ យើងបានដោយងាយក្នុងសម្បត្តិភពនោះ សំយោ-ជនៈ គឺ ***ភវរាគៈ*** ក៏កើតឡើង ។ កាលប្រកាន់មាំនូវសីលនិងវត្តថា យើងប្រកាន់មាំនូវសីលនិងវត្ត អាចបានអារម្មណ៍បែបនេះតទៅទៀត សំយោជនៈ គឺ **សីលព្វតបរាមាសៈ** ក៏កើតឡើង ។ កាលច្រណែនថា បុគ្គលដទៃមិនគប្បីបានអារម្មណ៍បែបនេះ សំយោជនៈ គឺ ***ឥស្សា*** ក៏កើតឡើង ។ កាលហួងហែងរូបារម្មណ៍ដែលខ្លួនបានហើយ មិនឱ្យដល់អ្នកដទៃ សំយោជនៈ គឺ **មច្ឆរិយៈ** ក៏កើតឡើង ។ កាលមិនដឹងច្បាស់ ដោយអំណាចនៃការមិនដឹងនូវវត្ថុដែលកើតព្រមជាមួយចក្ខុនិងរូបទាំងមូល សំយោជនៈ គឺ **អវិជ្ជា** ក៏កើតឡើង ។

# ការដឹងហេតុលះបង់សំយោជនៈ

ពាក្យថា **យថា អនុប្បន្នស្ស** ដែលមិនទាន់កើតឡើងដោយហេតុណា មានន័យថា សំយោជនៈ **១០** នោះ ដែលមិនទាន់កើតឡើង ដោយការមិនប្រាកដឡើង រមែងកើតព្រោះហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ពាក្យថា **យថា ច ឧប្បន្នស្ស** ដែលកើតឡើងហើយព្រោះហេតុណា មានន័យថា សំយោជនៈ **១០** យ៉ាងនោះ ដែលកើតឡើងហើយ ព្រោះអត្ថថា លះបង់មិនទាន់បាន ឬ ព្រោះប្រាកដឡើង ក៏លះបង់បានដោយហេតុណា រមែងដឹងច្បាស់នូវហេតុនោះផង ។ ពាក្យថា **យថា ច បហីនស្ស** ដែលលះបង់បានហើយព្រោះហេតុណា មានន័យថា សំយោជនៈ **១០** យ៉ាងនោះ លះបង់បានហើយដោយ តទង្គប្បហាន និង វិក្ខម្ភនប្បហាន រមែងមិនកើតទៀត ព្រោះហេតុណា រមែងដឹងច្បាស់នូវហេតុនោះផង ។

**សួរថា** សំយោជនៈ ១០ នោះ មិនកើតឡើងតទៅទៀត ព្រោះហេតុណា ?

**ឆ្លើយថា** កាលសំយោជនៈ **៥** គឺ ទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ឥស្សា និងមច្ឆរិយៈមិនកើតឡើងបានទៀតដោយសោតាបត្តិមគ្គ ។ សំយោជនៈ **២** គឺ កាមរាគៈ បដិឃៈ ដែលគ្រោតគ្រាត ក៏មិនកើតឡើងបានដោយសកទាគាមិមគ្គ ។ ( កាមរាគៈ និង បដិឃៈ ) ដែលល្អិត មិនកើតឡើងទៀតដោយអនាគាមិមគ្គ ។ សំយោជនៈ **៣** គឺ មានះ ភវរាគៈ អវិជ្ជា មិនកើតឡើងទៀតដោយអរហត្តមគ្គ ។

សូម្បីក្នុងពាក្យថា **សោតញ្ច បជានាតិ សទ្ទេ ច** រមែងដឹងច្បាស់សោតៈ

ផង សំឡេងផង ក៏មានន័យដូចគ្នា ។

ម្យ៉ាងទៀត អាយតនកថាក្នុងទីនេះ គប្បីជ្រាបដោយពិស្តារ តាមន័យដែលលោកពោលទុកហើយ ក្នុងអាយតននិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គចុះ ។

វិសុទ្ធិមគ្គ អាយតននិទ្ទេស : អាយតនៈ **១២** គឺ ចក្ខាយតនៈ - រូបាយតនៈ , សោតាយតនៈ - សទ្ទាយតនៈ , ឃានាយតនៈ - គន្ធាយតនៈ ជីវ្ហាយតនៈ - រសាយតនៈ , កាយាយតនៈ - ផោដ្ឋព្វាយតនៈ , មនាយតនៈ - ធម្មាយតនៈ ឈ្មោះថា អាយតនៈទាំងឡាយ ។

វិនិច្ឆ័យក្នុងអាយតនៈទាំងនោះ បណ្ឌិតគប្បីជ្រាប ដោយអត្ថ និងដោយលក្ខណៈ ដោយការមានត្រឹមនោះ ដោយលំដាប់ ដោយសង្ខេប ដោយពិស្តារ និង ជាវត្ថុគប្បីឃើញ ផង ។

## ដោយអត្ថ

ក្នុងបទទាំងឡាយនោះ ពោលដោយ **អត្ថ** ដែលខុសគ្នាមុន ធម្មជាតិណារមែងឃើញ ហេតុនេះ ធម្មជាតិនោះ ឈ្មោះថា **ចក្ខុ** , សេចក្តីនៃស័ព្ទ **ចក្ខតិ** - ឃើញ គឺ រមែងរីករាយនឹងរសរបស់រូប និងរមែងប្រាប់នូវរូប វត្ថុណារមែងសម្តែងពណ៌ ហេតុនេះ ទើបវត្ថុនោះ ឈ្មោះថា **រូប** សេចក្តីនៃស័ព្ទ **រូបយតិ** - សម្តែងពណ៌ រូប កាលដល់នូវការផ្លាស់ប្តូរពណ៌ រមែងប្រកាសសេចក្តីក្នុងចិត្ត ។

ធម្មជាតិណារមែងឮ ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា **សោតៈ** វត្ថុណាត្រូវបច្ច័យរបស់ខ្លួនបញ្ជូនចេញទៅ ហេតុនេះ វត្ថុនោះ ទើបបានឈ្មោះ

ឈ្មោះថា **សទ្ទៈ** សេចក្ដីនៃស័ព្ទ **សប្បតិ** - ត្រូវប្រកាសចេញ ត្រូវបន្លឺឡើង ( ឱ្យជាវត្ថុដែលដឹងតាមសោតទ្វារ ) ។

ធម្មជាតិណា រមែងស្រូប ( យកក្លិន ) បាន ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះថា **ឃានៈ** វត្ថុណារមែងភាយចេញទៅបាន ហេតុនេះ វត្ថុនោះ ទើបឈ្មោះថា **គន្ធៈ** សេចក្ដីនៃស័ព្ទ **គន្ធយតិ** - ភាយចេញ បង្ហាញទីអាស្រ័យ របស់ខ្លួន ។

ធម្មជាតិណា រមែងហៅរកជីវិត ហេតុនេះ ធម្មជាតិនោះ ទើបឈ្មោះ ថា **ជីវ្ហា** សត្វទាំងឡាយរមែងពេញចិត្តក្នុងវិស័យនោះ ហេតុនេះ វិស័យនោះ ទើបឈ្មោះថា **រស** ( វិស័យជា ទីពេញចិត្តនៃសត្វទាំងឡាយ ) សេចក្ដីនៃស័ព្ទ **រសន្តិ** - ពេញចិត្ត គឺ រីករាយ ដឹងថាឆ្ងាញ់ ។

ធម៌ដែលឈ្មោះថា **កាយ** ព្រោះជាអាយៈ ការមកនៃកុច្ឆិតធម៌ គឺ **សាសវធម៌** - ធម៌ដែលប្រព្រឹត្តទៅជាមួយនឹងអាសវធម៌ទាំងឡាយ ពាក្យថា **អាយៈ** បានដល់ ទីកើត ។

( **ដីកា** : សាសវធម៌ទីនេះ សំដៅយកកាមរាគៈប៉ុណ្ណោះ លោកថា បណ្ដា ឃានៈ ជីវ្ហា កាយ ដែលជាបច្ច័យពិសេស នៃកាមរាគៈនោះ កាយជា បច្ច័យពិសេសជាង ព្រោះដូច្នោះ សត្វទាំងឡាយ កាលត្រេកអរនឹងសេចក្ដីសុខ ក្នុងផោដ្ឋព្វៈ ទើបសេពមេថុនដែលជាកុច្ឆិតធម៌ ) ។

វត្ថុណាពាល់ត្រូវបានដោយកាយ ហេតុនេះ វត្ថុនោះ ទើបឈ្មោះថា **ផោដ្ឋព្វៈ** ។

សភាវៈណារមែងដឹង ហេតុនេះ សភាវៈនោះ ទើបឈ្មោះថា **មនៈ**

សភាវៈទាំងឡាយណា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ហេតុនេះ សភាវៈទាំងឡាយនោះ ទើបឈ្មោះថា **ធម៌** ។

## អធិប្បាយ អាយតនៈ ស័ព្ទ

តែកាលពោលដោយភាពដូចគ្នា គប្បីជ្រាបថា ទ្វារ និង អារម្មណ៍ មានចក្ខុនិងរូបជាដើម បានឈ្មោះថា អាយតនៈ ព្រោះជាទីបន្តគ្នា ១ ព្រោះពង្រីកអាយៈទាំងឡាយ ១ ព្រោះនាំអាយតៈទៅ ១ ។

- **អត្ថ ទី ១ គឺ អាយតនតោ** - ព្រោះជាទីបន្តគ្នា មានអធិប្បាយថា ចិត្ត និងចេតសិកធម៌ទាំងឡាយ រមែងបន្តគ្នា គឺ តែងតែព្យាយាមទៅតាមកិច្ចរបស់ខ្លួន មានការសោយ ( រសអារម្មណ៍ ) ជាដើម ក្នុងទ្វារ និងអារម្មណ៍នោះៗ មានចក្ខុនិងរូបជាដើម ( ព្រោះហេតុនោះ ទ្វារនិងអារម្មណ៍នោះៗ ទើបឈ្មោះថា អាយតនៈ ) ប្រែថា ជាទីបន្តនៃចិត្ត និងចេតសិកធម៌ទាំងឡាយ ។

- **អត្ថ ទី ២ គឺ អាយានំ តននតោ** - ព្រោះពង្រីកអាយៈ ទាំងឡាយ មានអធិប្បាយថា ទ្វារនិងអារម្មណ៍ទាំងឡាយនោះ រមែងផ្សាយ គឺ ពង្រីកធម៌ទាំងឡាយនោះដែលជា **អាយៈ** - អ្នកមក ( គឺ ចិត្ត - ចេតសិក ) ព្រោះហេតុនោះ ទ្វារនិងអារម្មណ៍ទាំងឡាយនោះ ទើបឈ្មោះថា **អាយតនៈ** ប្រែថា ផ្សាយពង្រីកអាយៈ គឺ ចិត្ត-ចេតសិកធម៌ ។

- **អត្ថ ទី ៣ គឺ អាយតស្ស នយនតោ** - ព្រោះនាំអាយតៈទៅ មានអធិប្បាយថា ទ្វារ និងអារម្មណ៍ទាំងឡាយនោះ មិនទាន់ត្រឡប់ ( គឺ មិនទាន់រលត់ ) ត្រឹមណា ក៏រមែងនាំទៅ គឺ ញុំាងសង្សារទុក្ខដែលប្រព្រឹត្តទៅក្នុងសង្សារ

ដែលមានទីបំផុតខាងដើម និងខាងចុងមិនប្រាកដជា **អាយត** គឺ អូសបន្លាយដ៏វែងឆ្ងាយ ឱ្យប្រព្រឹត្តទៅជាដរាប ព្រោះហេតុនោះ ទ្វារ និងអារម្មណ៍ទាំង-ឡាយនោះ ទើបឈ្មោះថា **អាយតន** ប្រែថា នាំអាយតៈ គឺ សង្សារទុក្ខឱ្យអូសបន្លាយទៅ ។

ធម៌ទាំងពួងនេះ បានឈ្មោះថា **អាយតនៈ** ព្រោះជាទីបន្ត ( នៃចិត្ត-ចេតសិក ) ១ ព្រោះផ្សាយអាយៈ ( គឺ ចិត្ត-ចេតសិកដែលមកក្នុងទ្វារ និងអារម្មណ៍ ) ១ ព្រោះនាំអាយតៈ ( គឺ សង្សារទុក្ខឱ្យអូសបន្លាយទៅ ) ១ មានន័យដូច្នេះឯង ។

## អធិប្បាយ អាយតនៈ ស័ព្ទ
## ដោយបរិយាយ

ន័យម៉្យាងទៀត **អាយតនៈ** គប្បីជ្រាបដោយអត្ថថា ជាទីអាស្រ័យ១ ជាអណ្តូងកើត១ ជាទីប្រជុំចុះ១ ជាទីឱ្យកំណើត១ ជាហេតុ១ ។

ពិតហើយ **ទីអាស្រ័យ** ហៅថា អាយតនៈ ក្នុងពាក្យថា **ឥស្សរាយតនំ**-សាលព្រះឥស្វរៈ **វាសុទេវាយតនៈ** - សាលព្រះវាសុទេពជាដើម ។ **អណ្តូងកើត** ក៏ហៅថា អាយតនៈ ក្នុងពាក្យថា **សុវណ្ណាយតនំ** - អណ្តូងមាស **រតនាយតនំ**-អណ្តូងកែវ ( ពេជ្រ ) ជាដើម រីឯក្នុងព្រះសាសនា ស្ថានជាទីប្រជុំគ្នា ក៏ហៅថា អាយតនៈ ក្នុងពាក្យថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** - ហ្វូងបក្សាបក្សីក្នុងព្រៃមកប្រជុំគ្នាគួរជាទីរីករាយ នៅក្នុងម្លប់ឈើធំជាដើម ។ ទីឱ្យកំណើត ក៏ហៅថា អាយតនៈ ក្នុងពាក្យថា **ទក្ខិណាបថោ គុន្នំ អាយតនំ** -

ដែនទក្ខិណាបថជាទីឱ្យកំណើតសត្វគោទាំងឡាយជាដើម ។ **ហេតុ** ក៏ហៅថា អាយតនៈ ក្នុងពាក្យថា **តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ** - កាលហេតុមានហើយ កើតហើយ ភិក្ខុនោះ ក៏ដល់នូវភាពជាអ្នកអាចធ្វើឱ្យជាក់ច្បាស់ក្នុងធម៌នោះ ៗ ជាដើម ។

បរិយាយមួយទៀត ចិត្ត និង ចេតសិកធម៌ ក៏អាស្រ័យទ្វារនិងអារម្មណ៍ទាំងឡាយ មានចក្ខុជាដើម និងព្រោះមានការប្រព្រឹត្តទៅទាក់ទងនឹងចក្ខុជាដើមនោះ ហេតុនោះទ្វារនិងអារម្មណ៍ មានចក្ខុជាដើម ទើបបានឈ្មោះថា ទីអាស្រ័យនៃចិត្តនិងចេតសិក ទាំងឡាយនោះ ប្រការ ១ ។

ម្យ៉ាងទៀត ចិត្ត និងចេតសិកទាំងឡាយនោះ នៅពេញក្នុងចក្ខុជាដើម ព្រោះអាស្រ័យចក្ខុជាដើមនោះ ( ជាទ្វារ ) និង ព្រោះមានរូបជាដើមនោះ ជាអារម្មណ៍ ព្រោះហេតុនោះ ទ្វារនិងអារម្មណ៍ មានចក្ខុជាដើម ទើបបានឈ្មោះថា ជាអណ្ដូងកើតនៃចិត្ត និងចេតសិកនោះ ប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាទីប្រជុំចុះនៃចិត្ត និងចេតសិកទាំងឡាយនោះ ព្រោះ ( ចិត្តចេតសិកទាំងនោះ ) ប្រជុំគ្នាក្នុងទ្វារ និងអារម្មណ៍នោះៗ ដោយជាវត្ថុជាទ្វារ និងជាអារម្មណ៍ ប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាទីឱ្យកំណើតនៃចិត្តនិងចេតសិកទាំងនោះ ព្រោះ ( ចិត្ត និង ចេតសិកទាំងនោះ ) កើតឡើងតែក្នុងចក្ខុជាដើមនោះតែប៉ុណ្ណោះ ដោយមានចក្ខុជាដើមនោះ ជាទីអាស្រ័យ និង មានរូបជាដើមជាអារម្មណ៍ ប្រការ ១ ។

ទ្វារ និងអារម្មណ៍ មានចក្ខុជាដើម បានឈ្មោះថា ជាហេតុនៃចិត្ត និង

ចេតសិកទាំងឡាយនោះ ព្រោះ កាលទ្វារ និងអារម្មណ៍ទាំងឡាយនោះ មិនមាន ( ចិត្តចេតសិក ) ក៏មិនមាន ប្រការ ១ ។

ធម៌ទាំងឡាយ ( មានចក្ខុនិងរូបជាដើម ) នោះ បានឈ្មោះថា អាយតនៈ ដោយហេតុទាំងឡាយនេះ គឺ ដោយអត្ថថា ជាទីអាស្រ័យ ១ ជាអណ្ដូងកើត ១ ជាទីប្រជុំចុះ ១ ជាទីឱ្យកំណើត ១ ជាហេតុ ១ មានន័យដូច្នេះឯង ។

ព្រោះហេតុនោះ ការវិនិច្ឆ័យក្នុងអាយតនៈទាំងឡាយនេះ គប្បីជ្រាប ដោយអត្ថយ៉ាងនេះជាមុនសិន ចក្ខុផង ចក្ខុនោះជាអាយតនៈផង ដោយអត្ថតាមដែលពោលហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ចក្ខាយតនៈ** ។ ល ។ ធម៌ទាំងឡាយផង ធម៌ទាំងនោះជាអាយតនៈផង ដោយអត្ថតាមដែលពោលហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មាយតនៈ** ។

## ដោយសភាវលក្ខណៈ

ពាក្យថា **លក្ខណៈ** គឺ វិនិច្ឆ័យក្នុងអាយតនៈទាំងនេះ គប្បីជ្រាបដោយលក្ខណៈនៃចក្ខុជាដើម ឯលក្ខណៈទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបក្នុងគម្ពីរវិសុទ្ធិមគ្គ - ខន្ធនិទ្ទេស បន្ថែមចុះ ។

*អភិធម្មត្ថសង្គហៈ* = ក្នុងអាយតនៈ **១២** នេះ ( ផ្នែកខាងរូប ) ដែលជាឱឡារិករូប **១២** គឺ រូបដែលងាយដល់ការកំណត់ដឹងដោយបញ្ញា នូវលក្ខណៈនៃអាយតនៈទាំងនោះ គឺ :

**១- ចក្ខុបសាទ** មានសភាពថ្លានៃមហាភូតរូបដែលសមគួរដល់ការប៉ះខ្ទប់

នឹងរូបារម្មណ៍ ជាលក្ខណៈ , មានការទាញស្រូបយកនូវរូបារម្មណ៍ ជាកិច្ច , ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃចក្ខុវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូបដែលកើតពីកម្មដោយភាវៈជាអ្នកចង់ប្រាថ្នាដើម្បីនឹងឃើញជាហេតុ ជាហេតុជិត ។

**២. សោតបសាទ** មានភាពថ្លានៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងសទ្ទារម្មណ៍ ជាលក្ខណៈ , មានការទាញស្រូបយកនូវសទ្ទារម្មណ៍ ជាកិច្ច , ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃសោតវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូបដែលកើតពីកម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នាដើម្បីនឹងឮសំឡេងជាហេតុ ជាហេតុជិត ។

**៣. ឃានបសាទ** មានសភាពថ្លានៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងក្លិន ជាលក្ខណៈ , មានការទាញស្រូបយកគន្ធារម្មណ៍ ជាកិច្ច , ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃឃានវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូបដែលកើតពីកម្មដោយភាវៈ ជាអ្នកចង់ប្រាថ្នាដើម្បីនឹងធុំក្លិនជាហេតុ ជាហេតុជិត ។

**៤. ជីវ្ហាបសាទ** មានសភាពថ្លានៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងរសជាលក្ខណៈ , មានការទាញស្រូបយកនូវរសារម្មណ៍ ជាកិច្ច , ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃជីវ្ហាវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូបដែលកើតពីកម្មដោយភាវៈជាអ្នកចង់ប្រាថ្នាដើម្បីនឹងលិតភ្លក្សនូវរសជាហេតុ ជាហេតុជិត ។

**៥. កាយបសាទ** មានភាពថ្លានៃមហាភូតរូប ដែលសមគួរប៉ះខ្ទប់នឹងផោដ្ឋព្វៈ ជាលក្ខណៈ , មានការទាញស្រូបយកនូវផោដ្ឋព្វារម្មណ៍ ជាកិច្ច , ជាទីទ្រទ្រង់ ជាទីអាស្រ័យនៃកាយវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូបដែលកើតពីកម្ម ដោយភាវៈជាអ្នកចង់ប្រាថ្នាដើម្បីនឹងប៉ះពាល់ជាហេតុ ជាហេតុជិត ។

**៦- រូបារម្មណ៍** មានការប៉ះខ្ទប់នឹងចក្ខុបសាទ ជាលក្ខណៈ , ធ្វើជាអារម្មណ៍របស់ចក្ខុវិញ្ញាណ ជាកិច្ច , មានភាពជាទីគោចររបស់ចក្ខុវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូប៤ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត ។

**៧- សទ្ទារម្មណ៍** មានការប៉ះខ្ទប់នឹងសោតបសាទ ជាលក្ខណៈ , ធ្វើជាអារម្មណ៍នៃសោតវិញ្ញាណ ជាកិច្ច , មានភាពជាទីគោចរនៃសោតវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋាន ២ គឺ ចិត្តនិងឧតុ ជាហេតុជិត ។

**៨- គន្ធារម្មណ៍** មានការប៉ះខ្ទប់នឹងឃានបសាទ ជាលក្ខណៈ , ធ្វើជាអារម្មណ៍នៃឃានវិញ្ញាណ ជាកិច្ច , មានភាពជាគោចរនៃឃានវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត ។

**៩- រសារម្មណ៍** មានការប៉ះខ្ទប់នឹងជិវ្ហាបសាទ ជាលក្ខណៈ , ធ្វើជាអារម្មណ៍នៃជិវ្ហាវិញ្ញាណ ជាកិច្ច , មានភាពជាទីគោចរនៃជិវ្ហាវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត ។

**១០- ផោដ្ឋព្វារម្មណ៍** មាន ៣ យ៉ាង គឺ **បឋវីផោដ្ឋព្វារម្មណ៍** បានដល់ រឹង ទន់ , **តេជោផោដ្ឋព្វារម្មណ៍** បានដល់ ក្តៅ ត្រជាក់ , **វាយោផោដ្ឋព្វារម្មណ៍** បានដល់ កម្រើក តឹង ញ័រ មានការប៉ះខ្ទប់នឹងកាយបសាទ ជាលក្ខណៈ , ធ្វើជាអារម្មណ៍នៃកាយវិញ្ញាណ ជាកិច្ច , មានភាពជាគោចរនៃកាយវិញ្ញាណ ជាអាការប្រាកដ , មានមហាភូតរូប ៤ ដែលកើតពីសមុដ្ឋានទាំង ៤ ជាហេតុជិត ( ចប់អភិធម្មត្ថសង្គហៈ ) ។

ពាក្យថា **តាវត្វតោ** គឺ **តាវភាវតោ** - ដោយការមានត្រឹមនោះ ព្រះ

ពុទ្ធាធិប្បាយនេះ មានន័យថា បើមានពាក្យសួរថា ធម៌ទាំងឡាយ មានចក្ខុជាដើម គឺ ធម៌នោះឯង បើដូច្នោះ ហេតុអ្វី ទ្រង់មិនត្រាស់ថា **ធម្មាយតនះ** តែម្យ៉ាង ទៅជាត្រាស់អាយតនៈដល់ទៅ **១២** ទៅវិញ ពាក្យឆ្លើយមានថា ព្រោះទីនេះ ចែកជាទ្វារ ១ ផ្នែក ជាអារម្មណ៍ ១ ផ្នែក នៃវិញ្ញាណ ៦ ដែលទ្រង់កំណត់ ( ចក្ខុនិងរូបជាដើម ) ជាឧប្បត្តិទ្វារ និងជាអារម្មណ៍នៃវិញ្ញាណ ៦ នេះឯងជាភាពផ្សេងគ្នានៃធម៌ទាំងឡាយនោះឯង ព្រោះហេតុនេះ ទើបទ្រង់ត្រាស់នូវអាយតនៈរហូតដល់ ១២ , ពិតហើយ ចក្ខាយតនៈប៉ុណ្ណោះជាឧប្បត្តិទ្វារ និងរូបាយតនៈប៉ុណ្ណោះដែលជាអារម្មណ៍នៃវិញ្ញាណដែលទាក់ទងក្នុងវិថីនៃចក្ខុវិញ្ញាណ ន័យនោះ ក៏ដូចគ្នា អាយតនៈដទៃក៏ជាឧប្បត្តិទ្វារ និង ជាអារម្មណ៍នៃវិញ្ញាណ ដែលទាក់ទងក្នុងវិថីនៃវិញ្ញាណនោះ ៗ ។

 រីឯ **មនាយតនៈ** ដែលជាឯកទេស បានដល់ **ភវង្គមន** ប៉ុណ្ណោះ ជាឧប្បត្តិទ្វារ ។ ( **ដីកា = ភវង្គមន** ការញ័រភវង្គ ២ ខណៈ ដែលជាឧប្បត្តិទ្វារហើយទើបឱ្យកើត **អាវជ្ជនៈ** បាន ) ព្រមទាំងធម្មាយតនៈជាអារម្មណ៍នៃវិញ្ញាណទី ៦ មិនទូទៅដល់វិញ្ញាណដទៃ ( មានចក្ខុវិញ្ញាណជាដើមឡើយ ) ។

វិសុទ្ធិមគ្គ : **អហេតុកកិរិយាមនោវិញ្ញាណធាតុ ប្រកបដោយឧបេក្ខាវេទនា** មានការដឹងច្បាស់នូវអារម្មណ៍ ៦ ជាលក្ខណៈ , មានវោដ្ឋព្វនៈនិងអាវជ្ជនៈក្នុងបញ្ចទ្វារនិងមនោទ្វារ ដោយអំណាចនៃកិច្ច " វោដ្ឋព្វនៈធ្វើកិច្ចក្នុងបញ្ចទ្វារ រីឯអាវជ្ជនៈ ធ្វើកិច្ចក្នុងមនោទ្វារ " ជាកិច្ច , មានភាពជាដូច្នោះ ( ជាវោដ្ឋវនៈ និងអាវជ្ជនៈ ) ជាអាការប្រាកដ , មានការប្រាសទៅនៃអហេតុកវិបាកមនោវិញ្ញាណ-ធាតុ ( ក្នុងវោដ្ឋវនកាល ) និង ការប្រាសទៅនៃភវង្គ ( ក្នុងអាវជ្ជនកាល ) យ៉ាង

ណាមួយ ជាហេតុជិត ។

អាយតនៈ **១២** ព្រះមានព្រះភាគទ្រង់ត្រាស់ ដោយទ្រង់កំណត់ទុកជាឧប្បត្តិទ្វារ និង ជាអារម្មណ៍នៃវិញ្ញាណ ៦ យ៉ាង នេះឯង ។

វិនិច្ឆ័យក្នុងការមានត្រឹមនោះ ក្នុងអាយតនៈទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបដូច្នេះចុះ ។

## ដោយលំដាប់

ន័យតាមលំដាប់ មានន័យថា បណ្ដាលំដាប់ទាំងឡាយ មានលំដាប់នៃការកើតជាដើម ដែលពោលក្នុងនិទ្ទេសខាងដើមហើយ ក្នុងទីនេះគ្រាន់តែជាលំដាប់នៃការសម្ដែងប៉ុណ្ណោះ ក៏អាចប្រើបាន ពិតហើយក្នុងអាយតនៈខាងក្នុងទាំងឡាយ ចក្ខាយតនៈជាអាយតនៈដែលប្រាកដ ព្រោះជាវិស័យដែលឃើញបាន និង ប៉ះពាល់បាន ព្រោះហេតុនោះ ទើបទ្រង់សម្ដែងមុនគេ បន្ទាប់មកទើបទ្រង់សម្ដែងអាយតនៈដ៏សេស មានសោតាយតនៈជាដើម ជាវិស័យដែលឃើញមិនបាន តែប៉ះពាល់បាន , ម្យ៉ាងទៀត បណ្ដាអាយតនៈខាងក្នុង ចក្ខាយតនៈ និងសោតាយតនៈ ទ្រង់សម្ដែងមុន ព្រោះជាវត្ថុមានឧបការច្រើន ដោយជាហេតុនៃទស្សនានុត្តរិយៈ និងសវនានុត្តរិយៈ បន្ទាប់ពីនោះ ទើបទ្រង់សម្ដែងអាយតនៈ ៣ ទៀត មានឃានាយតនៈជាដើម , មនាយតនៈ ទ្រង់សម្ដែងក្រោយគេ ព្រោះជាគោចរវិស័យនៃអាយតនៈ ៥ មានចក្ខាយតនៈជាដើម រីឯក្នុងអាយតនៈទាំងឡាយខាងក្រៅអាយតនៈ ៦ មានរូបជាដើម ទ្រង់សម្ដែងទុករៀងជាលំដាប់ ៗ នៃអាយតនៈខាងក្នុងនោះ ៗ ព្រោះជាគោចរនៃអាយតនៈខាងក្នុង មានចក្ខាយតនៈ

ជាដើម ។

ម្យ៉ាងទៀត លំដាប់នៃអាយតនៈទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបដោយការកំណត់ ( ការចែកតាមលំដាប់ ) ហេតុកើតឡើងនៃវិញ្ញាណក៏បាន ពិតហើយពាក្យនេះព្រះមានព្រះភាគ ក៏ទ្រង់បានត្រាស់ទុកថា :

" **អាស្រ័យចក្ខុនិងរូប ចក្ខុវិញ្ញាណក៏កើតឡើង ។ ល ។ អាស្រ័យមនៈនិងធម៌ទាំងឡាយ មនោវិញ្ញាណ ក៏កើតឡើង** " ។

ការវិនិច្ឆ័យក្នុងអាយតនៈដោយលំដាប់នេះ បណ្ឌិតគប្បីជ្រាបដូច្នេះចុះ ។

## ដោយសង្ខេប និង ពិស្ដារ

សេចក្ដីថា **ដោយសង្ខេប** និង **ពិស្ដារ** មានន័យថា កាលពោលដោយសង្ខេប អាយតនៈទាំង ១២ ត្រឹមតែជានាមរូបប៉ុណ្ណោះ ព្រោះមនាយតនៈ និងធម្មាយតនៈជាចំណែក១ សង្គ្រោះចូលជាមួយនាម ហើយអាយតនៈដ៏សេសនោះសង្គ្រោះចូលជាមួយរូប តែកាលពោលដោយពិស្ដារ ពោលនូវអាយតនៈខាងក្នុងមុនចក្ខាយតនៈ ដោយជាតិ ជាចក្ខុបសាទប៉ុណ្ណោះ តែចែកចេញជា បច្ច័យ គតិនិកាយ និង បុគ្គល ក៏មានប្រភេទជា អនន្ត អាយតនៈ ៤ មានសោតាយតនៈជាដើម ក៏យ៉ាងនោះ មនាយតនៈមាន ៨៩ ប្រភេទ ចែកជាកុសលវិញ្ញាណ អកុសលវិញ្ញាណ វិបាកវិញ្ញាណ និង កិរិយាវិញ្ញាណ និង មានដល់ទៅ ១២១ ប្រភេទ តែកាលចែកជាវត្ថុ និង បដិបទាជាដើម ក៏មានប្រភេទជាអនន្ត ។

រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ និង រសាយតនៈ ក៏មានប្រភេទជាអនន្ត ដោយចែកជាវិសភាគ និង បច្ច័យជាដើម ផោដ្ឋព្វាយតនៈមាន ៣ ប្រភទ

ដោយអំណាចនៃ បឋវីធាតុ តេជោធាតុ វាយោធាតុ បើដោយភាពផ្សេងគ្នានៃបច្ច័យជាដើម ក៏មានប្រភេទជាអនេក ធម្មាយតនៈក៏មានប្រភេទជាអនេក ដោយភាពផ្សេងគ្នានៃសភាវៈ និង ភាពផ្សេងគ្នានៃ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ សុខុមរូប និង និព្វាន ។

ការវិនិច្ឆ័យដោយ សង្ខេប និង ពិស្តារ បណ្ឌិតគប្បីជ្រាប ដូចពោលមកដូច្នេះចុះ ។

## ជាវត្ថុគប្បីឃើញ

ក្នុងសេចក្តីថា **ដោយជាវត្ថុគប្បីឃើញនេះ** មានវិនិច្ឆ័យថា អាយតនៈទាំងឡាយដែលជាសង្ខតៈទាំងអស់ គប្បីឃើញដោយការមិនមក និង ដោយការមិនទៅ , ពិតហើយ អាយតនៈទាំងឡាយនោះ កាលកើតឡើងក៏មិនបានមកពីទីណា បន្ទាប់ពីរលត់ទៅហើយ ក៏មិនទៅកាន់ទីណា សេចក្តីពិត មុននឹងកើតឡើងក៏មិនមានជាសភាវៈ បន្ទាប់ពីរលត់ហើយ ក៏ជាវត្ថុមានសភាវៈបែកធ្លាយទៅហើយ នៅត្រង់កណ្តាល រវាងខាងចុងនិងខាងដើម ក៏ជាវត្ថុប្រព្រឹត្តទៅដោយគ្មានអំណាច ព្រោះប្រព្រឹត្តទៅបាន ក៏ទាក់ទងដោយបច្ច័យ ព្រោះហេតុនោះ អាយតនៈទាំងឡាយនោះ បណ្ឌិតគប្បីឃើញដោយការមិនមានការមក និង មិនមានការទៅ ។

ន័យម្យ៉ាងទៀត គប្បីឃើញដោយការមិនមានការត្រិះរិះ និង ដោយការមិនមានសេចក្តីខ្វល់ខ្វាយ , ពិតហើយ ការគិតយ៉ាងនេះ រមែងមិនមានដល់ចក្ខុ និង រូបជាដើមថា " ឱ វិញ្ញាណកើតឡើង ព្រោះការព្រមព្រៀងរបស់ពួកយើង "

ទាំងចក្ខុ និងរូបជាដើមទាំងឡាយនោះ មិនគិត មិនខ្វល់ខ្វាយ ដោយភាពជាទ្វារក្តី ដោយភាពជាវត្ថុក្តី ដោយភាពជាអារម្មណ៍ក្តី ដើម្បីឱ្យវិញ្ញាណកើតឡើងសេចក្តីពិត វាជាធម្មតានោះឯង វិញ្ញាណទាំងឡាយ មានចក្ខុវិញ្ញាណជាដើមកើតឡើង ព្រោះការព្រមព្រៀងគ្នានៃចក្ខុនិងរូបជាដើមនោះ ព្រោះហេតុនោះ អាយតនៈ ទាំងឡាយនោះ បណ្ឌិតគប្បីឃើញដោយការមិនមានការគិត និងដោយការមិនមានសេចក្តីខ្វល់ខ្វាយ ដូច្នេះចុះ ។

ម្យ៉ាងទៀត អាយតនៈខាងក្នុង គប្បីឃើញដូចជាស្រុកស្ងាត់ ព្រោះប្រាសចាកភាពឋិតថេរ ភាពស្អាត ភាពសុខ និង ភាពជាអត្តា អាយតនៈខាងក្រៅ គប្បីឃើញដូចជាចោរប្លន់អ្នកស្រុក ព្រោះអាយតនៈខាងក្រៅនោះ ជាផ្នែកអភិឃាត ( បៀតបៀន ) នូវអាយតនៈខាងក្នុង សមដូចព្រះបាលីថា " **ម្នាលភិក្ខុទាំងឡាយ ចក្ខុត្រូវរូបទាំងឡាយដែលជាទីពេញចិត្ត និង មិនជាទីពេញចិត្ត បៀតបៀនហើយ** " ដូច្នេះជាដើម សេចក្តីពិស្តារ បណ្ឌិតគប្បីជ្រាបតាមន័យនៃព្រះបាលីនោះចុះ ។

ម្យ៉ាងទៀត អាយតនៈខាងក្នុង គប្បីឃើញដូចជាសត្វ ៦ ជំពូក អាយតនៈខាងក្រៅ គប្បីឃើញដូចជាទីគោចរនៃសត្វទាំង ៦ ជំពូកនោះ ។

សេចក្តីវិនិច្ឆ័យ ជាវត្ថុគប្បីឃើញ បណ្ឌិតគប្បីជ្រាបយ៉ាងនេះចុះ ។ នេះជាកថាយ៉ាងពិស្តារនៃអាយតនៈទាំងឡាយ ។

សម្មោហវិនោទនី អដ្ឋកថា ព្រះវិភង្គ :

**១- ចក្ខតីតិ ចក្ខុំ** ឈ្មោះថា **ចក្ខុ** ព្រោះអត្ថថា រមែងឃើញ អធិប្បាយថា

គឺ ធ្វើរូបឱ្យប្រាកដ ។

**២. រូបយតីតិ រូបំ** ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងឱ្យប្រាកដ អធិប្បាយថា **រូប** កាលដល់វិការនៃវណ្ណៈ ( ពណ៌ ) រមែងសម្ដែងភាវៈរបស់ខ្លួនទៅកាន់ហទយៈ ។

**៣. សុណាតីតិ សោតំ** ឈ្មោះថា **សោតៈ** ព្រោះអត្ថថា បានឮ ។

**៤. សប្បតីតិ សទ្ទោ** ឈ្មោះថា **សទ្ទៈ** ព្រោះអត្ថថា ចេញទៅ គឺ បន្លឺឡើង ។

**៥. ឃាយតីតិ ឃានំ** ឈ្មោះថា **ឃានៈ** ព្រោះអត្ថថា ស្រូបយកក្លិន ។

**៦. គន្ធយតីតិ គន្ធោ** ឈ្មោះថា **គន្ធៈ** ព្រោះអត្ថថា ភាយក្លិន គឺ រមែងសម្ដែងទីអាស្រ័យរបស់ខ្លួនឱ្យប្រាកដ ។

**៧. ជីវិតំ អាហាយតីតិ ជិវ្ហា** ឈ្មោះថា **ជិវ្ហា** ព្រោះអត្ថថា នាំមកនូវជីវិត ។

**៨. រសន្តិ តំ សត្តាតិ រសោ** ឈ្មោះថា **រស** ព្រោះអត្ថថា ជាទីរីករាយ គឺ ជាទីពេញចិត្តរបស់សត្វទាំងឡាយ ។

**៩. កុច្ឆិតានំ សាសវធម្មានំ អាយោតិ កាយោ** ឈ្មោះថា **កាយ** ព្រោះអត្ថថា ជាអណ្ដូងកើតនៃធម៌ មានអាសវៈដែលបណ្ឌិតខ្ពើមរអើម , ពាក្យថា **អាយោ** គឺ ទីកើត ។

**១០. ផុស្សិយតីតិ ផោដ្ឋព្វំ** ឈ្មោះថា **ផោដ្ឋព្វៈ** ព្រោះអត្ថថា ដែលកាយរមែងប៉ះពាល់ ។

**១១. មនុយតីតិ មនោ** ឈ្មោះថា **មនៈ** ព្រោះអត្ថថា ដឹង ។

**១២. អត្តនោ លក្ខណំ ធារយតីតិ ធម្មា** ឈ្មោះថា **ធម្មៈ** ព្រោះអត្ថថា

ទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ។

## អធិប្បាយ អាយតនៈ ដោយត្រៃលក្ខណ៍

ឥឡូវនេះ ព្រះមានព្រះភាគ មានព្រះបំណងសម្ដែងអាការនូវអាយតនៈទាំងឡាយនោះ ដែលបណ្ឌិតគប្បីឃើញច្បាស់តាមសេចក្ដីពិត ទើបផ្ដើមពាក្យថា **ចក្ខុំ អនិច្ចំ - ចក្ខុមិនទៀង** ដូច្នេះ ។

បណ្ដាអាយតនៈទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបថា **ចក្ខុ** ឈ្មោះថា មិនទៀង ដោយអត្ថថា មានហើយក៏មិនមានវិញ ដូច្នេះសិន ។

**ចក្ខុនោះ** ឈ្មោះថា **ការមិនទៀង** ប្រកបដោយហេតុ ៤ យ៉ាង ទៀត គឺ :

- មានការកើតឡើង និងវិនាសទៅវិញក្នុងទីបំផុត ១ - ដោយការប្រែប្រួលទៅ ១
- ដោយការកើតឡើងជាខណៈៗ ១ - ដោយបដិសេធនូវការទៀង ១

**ចក្ខុនោះ** ឈ្មោះថា **ជាទុក្ខ** ដោយអត្ថថា បៀតបៀន , ម្យ៉ាងទៀត ចក្ខុនេះកាលកើតឡើងហើយ រមែងដល់នូវការតាំងនៅ កាលតាំងនៅ រមែងលំបាកដោយជរា ដល់ជរាហើយ រមែងបែកធ្លាយទៅជាប្រាកដ ព្រោះដូច្នោះ ទើបឈ្មោះថា **ជាទុក្ខ** ដោយហេតុ ៤ ប្រការ នេះគឺ :

- ព្រោះជារបស់បៀតបៀនរឿយៗ ១ - ព្រោះជារបស់ទ្រាំបានដោយលំបាក ១
- ជាវត្ថុដែលជាទីតាំងនៃទុក្ខ ១ - ព្រោះបដិសេធនឹងសេចក្ដីសុខ ១

ម្យ៉ាងទៀត **ចក្ខុនោះ** ឈ្មោះថា **ជាអនត្តា** ដោយអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច , ន័យម្យ៉ាងទៀត ការដែលចក្ខុនោះ ប្រព្រឹត្តទៅក្នុងអំណាចរបស់នរណាមួយ ក្នុងឋានៈទាំង ៣ នេះ គឺ ចក្ខុនេះកើតឡើងហើយ សូមឱ្យដល់នូវភាព

តាំងនៅ ដល់នូវការតាំងនៅហើយ សូមកុំជរា ជរាហើយ សូមកុំបែកធ្លាយ ដូច្នេះ មិនបានឡើយ ជារបស់សូន្យចាកអាការដែលប្រព្រឹត្តទៅក្នុងអំណាចនោះ ព្រោះដូច្នោះ ចក្ខុនោះ ទើបឈ្មោះថា **ជាអនត្តា** ព្រោះហេតុទាំង ៤ នេះ គឺ :

- ជារបស់សូន្យ ១
- ជារបស់មិនមានម្ចាស់ ១
- ជាវត្ថុដែលធ្វើតាមការពេញចិត្តមិនបាន ១
- បដិសេធចំពោះអត្តា ១

ដែលឈ្មោះថា មានការប្រែប្រួលទៅជាធម្មតា ព្រោះមានភព និងគតិផ្សេងៗ ព្រោះមានការប្រែប្រួលទៅនៃភពមុន និងភពក្រោយ ព្រោះវៀរចាកភាពជាប្រក្រតី , ពាក្យថា **មានការប្រែប្រួលទៅជាធម្មតានេះ** ជាពាក្យវេវចនៈនៃពាក្យថា មិនទៀង នោះឯង ។ សូម្បីក្នុងអាយតនៈទាំងឡាយ មានពាក្យថា រូបមិនទៀង ក៏មានន័យដូច្នេះដែរ ។

ម្យ៉ាងទៀត ក្នុងអាយតនៈទាំងឡាយនេះ លើកលែងចក្ខុចេញហើយ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនមែនជាចក្ខុ តែចក្ខុនេះជាចក្ខុផង ជាសភាវៈមិនទៀងផង ធម៌ដ៏សេសក៏ដូចគ្នា តែមិនមែនចក្ខុ ចក្ខុនេះជាចក្ខុផងជាទុក្ខផង ធម៌ដ៏សេសជាអនត្តា តែមិនមែនជាចក្ខុ ចក្ខុនេះជាចក្ខុផងជាអនត្តាផង ដូច្នេះឯង ។ សូម្បីក្នុងរូបជាដើមក៏មានន័យដូចគ្នាដែរ ។

សួរថា ក្នុងសុតន្តភាជនីនេះ ព្រះតថាគតសម្តែងលក្ខណៈអ្វី ?

ឆ្លើយថា ទ្រង់សម្តែងអនត្តលក្ខណៈនៃអាយតនៈ ១២ យ៉ាង ។

ពិតហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ កាលទ្រង់សម្តែងអនត្តលក្ខណៈ ទ្រង់សម្តែងដោយភាពមិនទៀងខ្លះ ដោយភាពជាទុក្ខខ្លះ ដោយទាំងការមិនទៀងទាំងទុក្ខខ្លះ ក្នុងលក្ខណៈទាំង ៣ នោះ ព្រះអង្គទ្រង់សម្តែងអនត្តលក្ខណៈ ដោយភាព

មិនទៀងក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលណាពោលថា ចក្ខុជាអត្តា ពាក្យរបស់អ្នកនោះមិនសមគួរទេ ចក្ខុរមែងប្រាកដដោយការកើតឡើង និងការវិនាសទៅ វត្ថុណាប្រាកដការកើតឡើង និងការវិនាសទៅ វត្ថុនោះរបស់បុគ្គលនោះ ដែលពោលយ៉ាងនេះថា អត្តារបស់យើងកើតឡើង និងវិនាសទៅ ដូច្នោះ ពាក្យរបស់អ្នកដែលពោលថា ចក្ខុជាអត្តានោះ មិនសមគួរទេ ដូច្នេះ ចក្ខុជាអនត្តា ។

ព្រះអង្គទ្រង់សម្ដែងអនត្តលក្ខណៈដោយភាពជាទុក្ខ ក្នុងព្រះសូត្រនេះថា ម្នាលភិក្ខុទាំងឡាយ រូបជាអនត្តា ម្នាលភិក្ខុទាំងឡាយ បើរូបនេះជាអត្តា រូបនេះក៏មិនប្រព្រឹត្តទៅដើម្បីអាពាធ ព្រមទាំងនរណា១ ក៏អាចបាន ( តាមតម្រូវការ ) ក្នុងរូបថា សូមរូបរបស់យើងចូរជាយ៉ាងនេះ សូមរូបរបស់យើងកុំជាយ៉ាងនេះឡើយ , ម្នាលភិក្ខុទាំងឡាយ ព្រោះរូបជាអនត្តា ដូច្នោះ រូបទើបប្រព្រឹត្តទៅដើម្បីអាពាធ និងនរណា១ ក៏មិនអាចបាន ( តាមតម្រូវការ ) ក្នុងរូបថា សូមរូបរបស់យើងជាយ៉ាងនេះ សូមកុំឱ្យរូបរបស់យើងជាយ៉ាងនេះឡើយ ។

ទ្រង់សម្ដែងអនត្តលក្ខណៈ ទាំងមិនទៀងទាំងជាទុក្ខ ក្នុងព្រះសូត្រទាំង-ឡាយ មានជាដើមថា ម្នាលភិក្ខុទាំងឡាយ រូបមិនទៀង របស់ណាមិនទៀង របស់នោះជាទុក្ខ របស់ណាជាទុក្ខរបស់នោះជាអនត្តា របស់ណាជាអនត្តាគប្បីឃើញដោយសម្មប្បញ្ញា តាមសេចក្ដីពិតយ៉ាងនេះថា នោះមិនមែនជារបស់យើង នោះមិនជាយើង នោះមិនមែនជាខ្លួនយើង ។

សួរថា ទ្រង់សម្ដែងយ៉ាងនេះ ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាពមិនទៀង និងភាពជាទុក្ខប្រាកដ ។

ពិតហើយ កាលពែង ឬ ផ្តិល ឬ វត្ថុណាមួយ របូតពីដៃបែកហើយ ជនទាំងឡាយ រមែងពោលថា ឱ ! នោះមិនទៀង ការមិនទៀង ឈ្មោះថា រមែងប្រាកដហើយយ៉ាងនេះ , ពេលដែលបូសជាដើម កើតឡើងក្នុងអត្តភាពហើយ ឬថា ត្រូវដង្គត់ឈើ ឬ បន្លាមុតហើយ ក៏រមែងនិយាយថា ឱ ! ជាទុក្ខ ទុក្ខឈ្មោះថាប្រាកដហើយយ៉ាងនេះ ។

អនត្តលក្ខណៈមិនប្រាកដ ងងឹតឈឹង មិនបង្ហាញច្បាស់ ចាក់ធ្លុះបានដោយកម្រ សម្តែងបានដោយលំបាក ធ្វើឱ្យយល់បានដោយលំបាក ។ អនិច្ចលក្ខណៈ និងទុក្ខលក្ខណៈ ព្រះតថាគតទាំងឡាយទ្រង់ឧប្បត្តិឡើងក៏ដោយ ទ្រង់មិនឧប្បត្តិឡើងក៏ដោយ រមែងប្រាកដ ។ អនត្តលក្ខណៈ វៀរចាកការកើតឡើងនៃព្រះសម្ពុទ្ធទាំងឡាយហើយ រមែងមិនប្រាកដឡើយ រមែងប្រាកដតែក្នុងពុទ្ធុប្បាទប៉ុណ្ណោះ ។

ពិតហើយ តាបស និង បរិព្វាជកទាំងឡាយដែលមានឫទ្ធិច្រើន មានអានុភាពច្រើន មានសរភង្គសាស្តាជាដើម អាចពោលបានថា **អនិច្ចំ ទុក្ខំ** តែមិនអាចពោលបានថា **អនត្តា** បើពួកតាបសទាំងឡាយនោះ អាចពោលពាក្យថា **អនត្តា** បាន ក្នុងបរិស័ទដែលប្រជុំគ្នាហើយ បរិស័ទដែលប្រជុំគ្នានោះ ក៏អាចសម្រេចមគ្គផលបាន , ព្រោះការប្រកាសឱ្យដឹងអនត្តលក្ខណៈ មិនមែនជាវិស័យនរណាដទៃឡើយ ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ប៉ុណ្ណោះ អនត្តលក្ខណៈនេះ ទើបមិនប្រាកដដោយប្រការដូច្នេះ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងអនត្តលក្ខណៈ ទើបទ្រង់សម្តែងដោយការមិនទៀងខ្លះ ដោយភាពជាទុក្ខខ្លះ ដោយភាពទាំងមិនទៀងទាំងជាទុក្ខខ្លះ តែក្នុងអាយតនវិភង្គនេះ គប្បីជ្រាប

ថា ទ្រង់សម្តែងអាយតនៈនោះ ទាំងមិនទៀងទាំងជាទុក្ខ ដូច្នេះ ។

សួរថា លក្ខណៈទាំងឡាយនេះ រមែងមិនប្រាកដ ព្រោះមិនមនសិការអ្វី មិនចាក់ធ្លុះអ្វី និង មានអ្វីបិតបាំង ?

ឆ្លើយថា **អនិច្ចលក្ខណៈ** មិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការកើតឡើង និង ការរលត់ទៅ និងព្រោះសន្តតិបិទបាំង ។

**ទុក្ខលក្ខណៈ** មិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការបៀតបៀនរឿយៗ និងព្រោះឥរិយាបថទាំងឡាយបិទបាំង ។

**អនត្តលក្ខណៈ** មិនប្រាកដ ព្រោះមិនមនសិការ មិនចាក់ធ្លុះនូវការចែកធាតុផ្សេងៗ និងព្រោះឃនសញ្ញាបិទបាំង ។

ព្រះយោគាវចរកំណត់ការកើតឡើង និងការរលត់ទៅ បើកសន្តតិបានហើយ **អនិច្ចលក្ខណៈ** រមែងប្រាកដដោយកិច្ចទៅតាមសេចក្តីពិត , មនសិការនូវការបៀតបៀនរឿយៗ ការផ្លាស់ប្តូរឥរិយាបថ បានហើយ **ទុក្ខលក្ខណៈ** រមែងប្រាកដដោយកិច្ចទៅតាមសេចក្តីពិត , កាលចែកនូវធាតុផ្សេងៗ ហើយធ្វើការបំបែកនូវភាពជាដុំ ( ឃនៈ ) **អនត្តលក្ខណៈ** រមែងប្រាកដដោយកិច្ចទៅតាមសេចក្តីពិត ។

ម្យ៉ាងទៀត ក្នុងអធិការនេះ គប្បីជ្រាបវិភាគ ( ការចែក ) នេះ គឺ :

- **អនិច្ចំ** ការមិនទៀង ។
- **អនិច្ចលក្ខណំ** លក្ខណៈនៃការមិនទៀង ។
- **ទុក្ខំ** សេចក្តីទុក្ខ ។
- **ទុក្ខលក្ខណំ** លក្ខណៈនៃសេចក្តីទុក្ខ ។

**- អនត្តា** មិនមែនអត្តា ។

**- អនត្តលក្ខណំ** លក្ខណៈនៃអនត្តា ។

បណ្ដាវិភាគទាំង ៦ នោះ ពាក្យថា **អនិច្ចំ** បានដល់ ខន្ធ ៥ , ព្រោះហេតុអ្វី ? ព្រោះខន្ធ ៥ មានការប្រែប្រួលទៅដោយការកើតឡើង និងការរលត់ទៅ ឬថា មានហើយត្រឡប់មិនមានវិញ ។ ការដែលខន្ធ ៥ មានការប្រែប្រួលទៅដោយការកើតឡើង និងការរលត់ទៅ ឬថា ការប្រែប្រួលនៃអាការ ( លក្ខណៈ ) ពោលគឺ មានហើយត្រឡប់មិនមានវិញ ឈ្មោះថា **អនិច្ចលក្ខណៈ** ។

បញ្ចក្ខន្ធនោះឯង ឈ្មោះថា **ទុក្ខ** ព្រោះព្រះបាលីថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ , ព្រោះហេតអ្វី ? ព្រោះមានការបៀតបៀនរឿយ ៗ , អាការ ( គឺ លក្ខណៈ ) ដែលបៀតបៀនរឿយៗ នោះ ឈ្មោះថា **ទុក្ខលក្ខណៈ** ។

បញ្ចក្ខន្ធនោះឯង ឈ្មោះថា **អនត្តា** ព្រោះព្រះបាលីថា វត្ថុណាជាទុក្ខ វត្ថុនោះជា អនត្តា , ព្រោះហេតុអ្វី ព្រោះមិនប្រព្រឹត្តទៅក្នុងអំណាច , អាការ ( គឺ លក្ខណៈ ) ដែលមិនប្រព្រឹត្តទៅក្នុងអំណាចនោះ ឈ្មោះថា **អនត្តលក្ខណៈ** ព្រោះដូច្នោះ អនិច្ចំ ទុក្ខំ និង អនត្តា ផ្សេង , អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ និង អនត្តលក្ខណៈផ្សេង ។

ពិតហើយ ខន្ធ៥ អាយតនៈ១២ ធាតុ១៨ ទាំងអស់ ឈ្មោះថា មិនទៀង ជាទុក្ខ និងជាអនត្តា តែវិការ ( ការប្រែប្រួល ) នៃអាការ ( លក្ខណៈ ) មានប្រការតាមដែលពោលហើយ ឈ្មោះថា អនិច្ចលក្ខណៈ ទុក្ខលក្ខណៈ និង អនត្តលក្ខណៈដូច្នេះឯង ។

ពាក្យថា **ឥតិ អជ្ឈត្តំ វា** - ឬខាងក្នុង មានន័យថា ពិចារណាឃើញធម៌

ក្នុងធម៌ទាំងឡាយរបស់ខ្លួន ដោយការកំណត់អាយតនៈខាងក្នុង ក្នុងធម៌ទាំង-ឡាយរបស់អ្នកដទៃ ដោយការកំណត់អាយតនៈខាងក្រៅ ឬ ក្នុងធម៌ទាំងឡាយរបស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាលយ៉ាងនេះ ។ ការកើតឡើង និងការសូន្យទៅក្នុងអាយតនបព្វៈនេះ គប្បីនាំមកប្រៀបធៀបនឹងរូបាយតនៈក្នុងរូបក្ខន្ធ មនាយតនៈក្នុងអរូបាយតនៈទាំងឡាយចុះក្នុងវិញ្ញាណក្ខន្ធ ធម្មាយតនៈចុះក្នុងខន្ធដ៏សេស មិនគប្បីកាន់យកលោកុត្តរធម៌ឡើយ ។

( ចប់ អាយតនបព្វៈ )

# ៤ – ពោជ្ឈង្គបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ ពោជ្ឈង្គ **៧** ប្រការ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ ពោជ្ឈង្គ **៧** ប្រការ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ? , ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះសតិសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា សតិសម្ពោជ្ឈង្គ មិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះសតិ-សម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូណ៌ នៃសតិសម្ពោជ្ឈង្គដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

ទោះធម្មវិចយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ ។ ទោះវីរិយសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ ។ ទោះបីតិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ ។ ទោះបស្សទ្ធិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ ។ ទោះសមាធិសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ។ បេ ។ ទោះឧបេក្ខាសម្ពោជ្ឈង្គ មាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមាននៅក្នុងចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានចិត្តនៃខ្លួន ក៏ដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គមិនមាននៅក្នុងសន្តានចិត្តរបស់អាត្មាអញ ទោះឧបេក្ខាសម្ពោជ្ឈង្គ ដែលមិនទាន់កើត

ឡើង ហើយកើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាចម្រើនពេញបរិបូរណ៍នៃឧបេក្ខាសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្នុងនិងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលជាទីប្រជុំកើតឡើងក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលសូន្យទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ ដែលទាំងជាទីប្រជុំកើតឡើង ទាំងសូន្យទៅក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ។ មួយទៀត ស្មារតី ( ជាគ្រឿងកំណត់ ) របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ ( ដោយតណ្ហានិងទិដ្ឋិ ) គ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ ពោជ្ឈង្គទាំង ៧ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ចែកធម្មានុបស្សនាដោយអាយតនៈ

ខាងក្នុង ៦ ខាងក្រៅ ៦ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកដោយពោជ្ឈង្គ ទើបត្រាស់ថា **បុន ចបរំ** សេចក្ដីដទៃនៅមានទៀត ដូច្នេះជាដើម ។

បណ្ដាបទទាំងឡាយនោះ បទថា **ពោជ្ឈង្គទាំងឡាយ** គឺ ក្នុងអង្គនៃសត្វអ្នកត្រាស់ដឹង ។ បទថា **មានហើយ** គឺ ដល់ព្រមដោយការបានមក ។

## ១-សតិសម្ពោជ្ឈង្គ

បទថា **សតិសម្ពោជ្ឈង្គ** បានដល់ សម្ពោជ្ឈង្គ ពោលគឺ សតិ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា សម្ពោជ្ឈង្គនេះដូច្នេះ ព្រះយោគាវចរត្រាស់ដឹងតាំងពីការផ្ដើមវិបស្សនា ឬក៏ ព្រះយោគាវចរនោះ ភ្ញាក់ឡើងចាកកិលេសនិទ្រា ឬ ចាក់ធ្លុះសច្ចៈទាំងឡាយ ដោយធម្មសាមគ្គី **៧** មានសតិជាដើម យ៉ាងណា ធម្មសាមគ្គីនោះ ឈ្មោះថា **សម្ពោធិ** , **អង្គ** របស់អ្នកភ្ញាក់នោះ ឬ ធម្មសាមគ្គីដែលជាគ្រឿងភ្ញាក់នោះ ហេតុនោះ ទើបឈ្មោះថា **សម្ពោជ្ឈង្គ** ។ ព្រោះដូច្នោះ ទ្រង់ទើបពោលថា សម្ពោជ្ឈង្គ ពោលគឺ **សតិ** ។ សូម្បីនៅក្នុងសម្ពោជ្ឈង្គដ៏សេស គប្បីជ្រាបតាមន័យនេះចុះ ។ បទថា **មិនមានហើយ** គឺ មិនមាន ព្រោះមិនបានមក ។

វិនិច្ឆ័យក្នុងពាក្យថា **យថា ច អនុប្បន្នស្ស** ដែលមិនទាន់កើតឡើង ព្រោះហេតុណាជាដើម ដូចតទៅនេះ ជាបឋម សតិសម្ពោជ្ឈង្គ រមែងកើតឡើងតាមន័យដែលមកក្នុងព្រះបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃសតិសម្ពោជ្ឈង្គមានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងសតិសម្ពោជ្ឈង្គនោះ នេះជាអាហារដើម្បីការ

កើតឡើងនៃសតិសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើតឡើង ឬ ដើម្បីភិយ្យោភាព ចម្រើនពេញលេញក្រៃលែងឡើង នៃសតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ ក្នុងធម៌ទាំងឡាយនោះ **សតិ** នោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃសតិសម្ពោ-ជ្ឈង្គ ។ យោនិសោមនសិការ មានលក្ខណៈដូចដែលបានពោលមកហើយនោះ កាលភិក្ខុធ្វើយោនិសោមនសិការនោះ ឱ្យប្រព្រឹត្តទៅរឿយ ៗ ក្នុងអារម្មណ៍ ហើយ សតិសម្ពោជ្ឈង្គក៏កើតឡើង ។

## ហេតុនៃសតិសម្ពោជ្ឈង្គ

ន័យម្យ៉ាងទៀត ធម៌ ៤ ប្រការ ជាហេតុកើតឡើងនៃសតិសម្ពោជ្ឈង្គ គឺ **១**-សតិសម្បជញ្ញៈ **២**-ការវៀរចាកបុគ្គលដែលគ្មានសតិ **៣**-ការគប់រកបុគ្គលអ្នកមានសតិតាំងមាំ ៤-ការបង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ ។

សតិសម្ពោជ្ឈង្គ រមែងកើតឡើងដោយសតិសម្បជញ្ញៈ ក្នុងឋានៈទាំង **៧** មានការឈានទៅមុខជាដើម ដោយការវៀរចាកបុគ្គលដែលគ្មានសតិ ប្រៀបដូចជាសត្វក្អែកដែលស្វែងរកអាហារ ហើយសេពគប់រកបុគ្គលដែលមានសតិតាំងមាំ ដូចជាព្រះតិស្សទត្តត្ថេរ និងព្រះអភ័យត្ថេរជាដើម និងជាអ្នកមានចិត្តបង្អោនទៅ ដើម្បីសតិក្នុងឥរិយាបថទាំងឡាយមាន ឈរ អង្គុយ ជាដើម ។ ភិក្ខុរមែងដឹងច្បាស់ថា សតិសម្ពោជ្ឈង្គនោះ កើតឡើងដោយហេតុ ៤ ប្រការយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ២ - ធម្មវិចយសម្ពោជ្ឈង្គ

ធម្មវិចយសម្ពោជ្ឈង្គ រមែងកើតឡើងតាមន័យដែលបានពោលមកក្នុង

ព្រះបាលីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាកុសល និង អកុសល ធម៌ដែលប្រៀបដោយចំណែក ធម៌ខ្មៅ និង ធម៌ស ការធ្វើឱ្យច្រើននូវយោនិ-សោមនសិការ ក្នុងធម៌ទាំងឡាយនោះ នេះជាអាហារដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឬ ជាហេតុធ្វើនូវភិយ្យោភាព ការចម្រើនបរិបូរណ៍ពេញលេញនៃធម្មវិចយសម្ពោជ្ឈង្គ ដែលកើតឡើងហើយដូច្នេះ ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ គឺ ១. ការសាកសួរ ២. ការធ្វើវត្ថុឱ្យបរិសុទ្ធ ៣.ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា ៤. វៀរចាកបុគ្គលដែលគ្មានបញ្ញា ៥. គប់រកបុគ្គលដែលមានបញ្ញា ៦. ពិចារណាដោយបញ្ញាដ៏ជ្រាលជ្រៅ ៧. ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។

បណ្តាធម៌ ៧ ប្រការ នោះ ភាពជាអ្នកច្រើនដោយការសាកសួរដែលអាស្រ័យអត្ថនៃ ខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គ អង្គមគ្គ អង្គឈាន សមថៈ និង វិបស្សនា ឈ្មោះថា ការសាកសួរ ។

ការធ្វើវត្ថុខាងក្នុងខាងក្រៅឱ្យស្អាត ឈ្មោះថា ការធ្វើវត្ថុឱ្យបរិសុទ្ធ , ពេលណាភិក្ខុមាន សក់ ក្រចក និង សក់វែងពេកទៅ ឬ រាងកាយកខ្វក់ប្រឡាក់ដោយញើស និង ក្អែល វេលានោះ វត្ថុខាងក្នុង ( គឺ រាងកាយ ) មិនបរិសុទ្ធ មិនស្អាត ។ តែក្នុងវេលាណា ចីវរចាស់ទ្រុឌទ្រោម កខ្វក់ ក្លិនអាក្រក់ ឬ សេនាសនៈរខេករខាក ក្នុងវេលានោះ វត្ថុខាងក្រៅមិនបរិសុទ្ធ មិនស្អាត ។ ព្រោះដូច្នោះ ទើបគួរធ្វើវត្ថុខាងក្នុងឱ្យបរិសុទ្ធ ដោយកិច្ច មានការកោរសក់

ជាដើម ដោយការធ្វើរាងកាយឱ្យស្រាល ដោយកិច្ចមានការជម្រះមន្ទិលទូទៅ ទាំងខាងលើ ទាំងខាងក្រោមជាដើម និងដោយការដុសខាត់ ងូតទឹកជម្រះក្លិនស្អុយ ។ គប្បីធ្វើវត្ថុខាងក្រៅឱ្យបរិសុទ្ធ ដោយកិច្ច មានការដេរប៉ាក់ ជ្រលក់ បោកគក់ចីវរ និង ធ្វើការដុតបាត្រជាដើម ។ ព្រោះបើវត្ថុខាងក្នុងនិងខាងក្រៅមិនបរិសុទ្ធ កាលចិត្តនិងចេតសិកកើតឡើង សូម្បីបញ្ញាក៏មិនផូរផង់ ដូចជាពន្លឺប្រទីបដែលភ្លឺឡើង ព្រោះអាស្រ័យចង្កៀង ប្រឆេះ និងប្រេង ដែលមិនស្អាតបរិសុទ្ធដូច្នោះ តែកាលបើវត្ថុខាងក្នុងនិងខាងក្រៅបរិសុទ្ធ ពេលចិត្តនិងចេតសិកកើតឡើង សូម្បីបញ្ញាក៏ផូរផង់ ដូចពន្លឺប្រទីបភ្លឺឡើង ព្រោះអាស្រ័យចង្កៀង ប្រឆេះ និងប្រេងដែលបរិសុទ្ធដូច្នោះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ការធ្វើវត្ថុឱ្យបរិសុទ្ធ រមែងជាហេតុឱ្យកើតឡើងនូវ **ធម្មវិចយ-សម្ពោជ្ឈង្គ** ។

ការធ្វើឥន្ទ្រិយ មានសទ្ធាជាដើម ឱ្យស្មើគ្នា ឈ្មោះថា ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា ។ បើឥន្ទ្រិយ គឺ **សទ្ធា** របស់លោកមានកម្លាំងខ្លាំង ឥន្ទ្រិយក្រៅពីនេះខ្សោយ ដំណើរនោះ ឥន្ទ្រិយ គឺ **វីរិយៈ** មិនអាចធ្វើកិច្ច គឺ ការផ្គងចិត្តបានឡើយ , ឥន្ទ្រិយ គឺ **សតិ** ក៏មិនអាចធ្វើកិច្ច គឺ ការប្រាកដ , ឥន្ទ្រិយ គឺ **សមាធិ** ក៏មិនអាចធ្វើកិច្ច គឺ ការមិនរាយមាយ , ឥន្ទ្រិយ គឺ **បញ្ញា** ក៏មិនអាចធ្វើកិច្ច គឺ ការដឹង , ព្រោះដូច្នោះ កាលមនសិការដល់ ឥន្ទ្រិយ គឺ សទ្ធានោះ ដោយការពិចារណាសភាវធម៌ ឬដោយប្រការណា ឥន្ទ្រិយ គឺ សទ្ធាមានកម្លាំងខ្លាំង គប្បីធ្វើឱ្យថយចុះ ដោយការមិនមនសិការយ៉ាងនោះ ក្នុងរឿងនេះ មានរឿងព្រះវក្កលិត្ថេរ ជាឧទាហរណ៍ ។

បើឥន្ទ្រិយ គឺ វីរិយៈមានកម្លាំងខ្លាំង កាលបើដូច្នោះ ឥន្ទ្រិយ គឺ សទ្ធា ក៏មិនអាចធ្វើកិច្ច គឺ ការជឿបាន , ឥន្ទ្រិយក្រៅពីនេះ ក៏មិនអាចធ្វើកិច្ចផ្សេង ៗ របស់ខ្លួនបានដែរ ព្រោះដូច្នោះ គួរធ្វើឱ្យថយចុះនូវឥន្ទ្រិយ គឺ វីរិយៈនោះឯង ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ សូម្បីក្នុងខនោះ គប្បីសម្ដែងរឿងព្រះសោណត្ថេរជាឧទាហរណ៍ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេសក៏ដូចគ្នា កាលឥន្ទ្រិយប្រភេទណាមួយ មានកម្លាំងខ្លាំង គប្បីជ្រាបថា ឥន្ទ្រិយក្រៅពីនេះ ក៏មិនអាចធ្វើកិច្ច គឺ នាទីរបស់ខ្លួនបាន ។ តែដោយចំពោះយ៉ាងពិសេស ក្នុងរឿងនេះ ទ្រង់សរសើរសទ្ធានិងបញ្ញា សមាធិនិងវីរិយៈ ត្រូវស្មើគ្នា ។ ព្រោះអ្នកមានសទ្ធាខ្លាំងក្លា តែបញ្ញាទន់ខ្សោយក៏មាន សទ្ធាខ្លាំងក្លារមែងជ្រះថ្លាខុសរឿង ។ មានបញ្ញាខ្លាំងក្លា តែមានសទ្ធាខ្សោយ រមែងចូលចិត្តបង្កើតបញ្ហា ដូចរោគកើត ព្រោះការប្រើថ្នាំខុស កែខៃមិនបាន ។ អ្នកមានបញ្ញាខ្លាំងក្លា ក៏ស្ទុះទៅខុសផ្លូវ ដោយថា កុសលមានបានត្រឹមចិត្តុប្បាទក្នុងខណៈនឹកគិតប៉ុណ្ណោះ ដូច្នេះហើយ ក៏មិនធ្វើបុណ្យ មានទានជាដើម រមែងកើតក្នុងនរក ។ ព្រោះឥន្ទ្រិយ គឺ សទ្ធានិងបញ្ញាទាំងពីរស្មើគ្នា ទើបជ្រះថ្លាក្នុងវត្ថុ គឺ ព្រះរតនត្រៃតែម្យ៉ាង ។ តែបើសមាធិខ្លាំងក្លា វីរិយៈទន់ខ្សោយ កោសជ្ជៈ គឺ សេចក្ដីខ្ជិលច្រអូស រមែងគ្របសង្កត់បាន ព្រោះសមាធិជាបក្ខពួកកោសជ្ជៈ ។ បើវីរិយៈខ្លាំងក្លា សមាធិទន់ខ្សោយ ឧទ្ធច្ចៈរមែងគ្របសង្កត់បាន ព្រោះវីរិយៈជាបក្ខពួកឧទ្ធច្ចៈ ។ តែសមាធិដែលវីរិយៈចូលទៅប្រកបទុកហើយ រមែងមិនធ្លាក់ទៅក្នុងកោសជ្ជៈ វីរិយៈដែលសមាធិចូលទៅប្រកបទុកហើយ ក៏មិនធ្លាក់ទៅក្នុងឧទ្ធច្ចៈ ព្រោះដូច្នោះ ទើបគួរធ្វើឥន្ទ្រិយទាំង ២ គូ នោះឱ្យស្មើគ្នា ព្រោះថា អប្បនានឹង

មានបាន ព្រោះឥន្ទ្រិយទាំងគូស្មើគ្នា ។ ម្យ៉ាងទៀត សទ្ធាមានកម្លាំងខ្លាំងក្លា គួរដល់អ្នកចម្រើនសមាធិ ព្រោះថា អ្នកចម្រើនសមាធិ ជឿមាំយ៉ាងនេះថា នឹងសម្រេចអប្បនាបាន , រីឯ សមាធិ និងបញ្ញា - ឯកគ្គតា( កាលដែលចិត្តមានអារម្មណ៍តែមួយ )មានកម្លាំងខ្លាំងក្លា រមែងគួរដល់អ្នកដែលចម្រើនសមាធិ ព្រោះថា អ្នកចម្រើនសមាធិនោះ រមែងសម្រេចអប្បនាបាន ដោយឯកគ្គតាយ៉ាងនេះ , បញ្ញាមានកម្លាំងខ្លាំង រមែងគួរដល់អ្នកចម្រើនវិបស្សនា , ព្រោះអ្នកចម្រើនវិបស្សនានោះ រមែងដល់នូវការចាក់ធ្លុះត្រៃលក្ខណ៍ ដោយបញ្ញាយ៉ាងនេះ ។ តែអប្បនានឹងមានបាន ក៏ព្រោះសទ្ធានិងបញ្ញា ទាំងពីរស្មើគ្នាដោយពិត ។ រីឯសតិមានកម្លាំងវិញ រមែងគួរក្នុងទីទាំងពួង ព្រោះថា សតិរមែងរក្សាចិត្តមិនឱ្យធ្លាក់ទៅក្នុងឧទ្ធច្ចៈ ដោយអំណាចសទ្ធា វីរិយៈ បញ្ញា ដែលជាបក្ខពួកឧទ្ធច្ចៈ , និងមិនឱ្យធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាបក្ខពួកកោសជ្ជៈ ។ ព្រោះហេតុដូច្នោះ សតិនោះ ទើបចាំបាច់ត្រូវការក្នុងទីទាំងពួង ដូចរសជាតិអំបិល ចាំបាច់ត្រូវមានក្នុងការធ្វើម្ហូបគ្រប់យ៉ាង និង ដូចអមាត្យដែលជាអ្នកជំនាញក្នុងរាជកិច្ចគ្រប់យ៉ាង ចាំបាច់ត្រូវមានក្នុងរាជកិច្ចគ្រប់យ៉ាង ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា សតិត្រូវមានក្នុងទីទាំងពួង ព្រោះហេតុអ្វី ព្រោះចិត្តមានសតិជាទីអាស្រ័យ និង សតិមានការរក្សា ជាការប្រាកដ វៀរសតិចេញហើយ នឹងផ្គង នឹងរក្សាចិត្ត មិនបានឡើយ ។

ការវៀរចាកបុគ្គលដែលមានបញ្ញាទុព្វល មិនមានបញ្ញាចុះកាន់ប្រភេទនៃធម៌ មានខន្ធជាដើម ឱ្យឆ្ងាយ ឈ្មោះថា ការវៀរចាកបុគ្គលដែលមានបញ្ញាទុព្វល , ការគប់រកបុគ្គលអ្នកមានបញ្ញាដឹងនូវការកើត និង ការរលត់នៃ

សភាវធម៌ ដែលមានការកំណត់ដោយលក្ខណៈ ៥០ ឈ្មោះថា សេពគប់អ្នកមានបញ្ញា ។ ការពិចារណាដោយបញ្ញាដ៏មានជម្រៅ ដែលប្រព្រឹត្តទៅក្នុងសភាវធម៌ទាំងឡាយ មានខន្ធជាដើម ឈ្មោះថា ការពិចារណាដោយបញ្ញាដ៏មានជម្រៅ ភាពជាអ្នកមានចិត្តបង្អោនទៅដើម្បីធម្មវិចយសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។ ភិក្ខុរមែងដឹងច្បាស់ថា ធម្មវិចយសម្ពោជ្ឈង្គនោះ រមែងកើតឡើងដោយអាការយ៉ាងនេះ ហើយចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ៣-វីរិយសម្ពោជ្ឈង្គ

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងតាមន័យនៃព្រះបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អារព្ភធាតុ ( ធាតុ គឺ សេចក្ដីព្យាយាម ) និក្កមធាតុ បរក្កមធាតុ ( ធាតុ គឺ សេចក្ដីព្យាយាមឆ្ពោះទៅមុខ ) មានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធាតុទាំង ៣ នោះ នេះជាអាហារដើម្បីការកើតឡើងនៃវីរិយសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬប្រព្រឹត្តទៅដើម្បីភិយ្យោភាព ការចម្រើនបរិបូរណ៍ពេញលេញនៃវីរិយសម្ពោ-ជ្ឈង្គ ដែលកើតឡើងហើយ ។

## ហេតុកើតនៃវីរិយសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃ

វីរិយសម្ពោជ្ឈង្គ គឺ :

១- ការពិចារណាឃើញភ័យក្នុងអបាយ ២- ការឃើញអានិសង្ស ៣- ការពិចារណាដល់បដិបទា ៤- ការគោរពកោតក្រែងក្នុងបិណ្ឌបាត ៥- ការពិចារណាឃើញភាពជាធំ ក្នុងការទទួលមរតក ៦- ការពិចារណាចំពោះព្រះសាស្តាជាធំ ៧- ការពិចារណាដល់ជាតិជាធំ ៨- ការពិចារណាដល់ស-ព្រហ្មចារីជាធំ ៩- ការវៀរចាកបុគ្គលខ្ជិលច្រអូស ១០- ការគប់រកបុគ្គលដែលមានសេចក្តីព្យាយាម ១១- ការបង្អោនចិត្តទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ ។

## ពិចារណាភ័យក្នុងអបាយ

ធម្មតាធម៌ ១១ ប្រការ នោះ កាលភិក្ខុចម្រើនវីរិយសម្ពោជ្ឈង្គ ក៏ពិចារណាឃើញភ័យយ៉ាងនេះថា នរណាៗ ក៏មិនអាចញ៉ាំងវីរិយសម្ពោជ្ឈង្គឱ្យកើតឡើងបាន ក្នុងវេលាដែលរងទុក្ខធំ កាលដែលត្រូវទទួលទោសដោយគ្រឿងចង ៥ ប្រការ ក្នុងនរកក្តី ក្នុងកាលដែលត្រូវគេចាប់ដោយគ្រឿងចាប់ មានសំណាញ់ មង និង អួន ជាដើមខ្លះ ក្នុងពេលដែលដេញកាប់ចាក់ដោយគ្រឿងប្រហារ ឱ្យអូសរទេះខ្លះ ក្នុងកំណើតតិរច្ឆានក្តី ក្នុងពេលទុរន់ទុរាដោយការស្រេកឃ្លាន ជាច្រើនពាន់ឆ្នាំខ្លះ ១ ពុទ្ធន្តរខ្លះ ក្នុងបេតិវិស័យក្តី ក្នុងពេលដែលត្រូវសោយទុក្ខដែលកើតពីខ្យល់ និងកម្តៅថ្ងៃជាដើម ដោយរូបរាងកម្ពស់ ៦០ ហត្ថ ៨០ ហត្ថ សល់តែស្បែកដណ្តប់ឆ្អឹង ក្នុងជំពូកកាលកញ្ជិកអសុរក្តី ម្នាលភិក្ខុ វេលានេះប៉ុណ្ណោះ ជាវេលាដែលសមគួរដល់សេចក្តីព្យាយាមរបស់អ្នកវីរិយសម្ពោជ្ឈង្គ រមែងកើតឡើង ។

## ការឃើញអានិសង្ស

ពេលឃើញអានិសង្សយ៉ាងនេះថា បុគ្គលខ្ជិលច្រអូស មិនអាចបាន លោកុត្តរធម៌ ៩ ទេ បុគ្គលព្យាយាមប៉ុណ្ណោះ ទើបអាច នេះជាអានិសង្សនៃ សេចក្តីព្យាយាម ដូច្នេះវីរិយសម្ពោជ្ឈង្គ ក៏កើតឡើង ។

## ពិចារណាដល់បដិបទា

កាលពិចារណាដល់បដិបទា យ៉ាងនេះថា គួរធ្វើដំណើរតាមផ្លូវដែល ព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធជាម្ចាស់ ព្រះមហាសាវ័កគ្រប់ព្រះអង្គ ធ្វើ ដំណើរទៅហើយ ផ្លូវនោះ មនុស្សខ្ជិល មិនអាចធ្វើដំណើរទៅបានទេ វីរិយ-សម្ពោជ្ឈង្គ ក៏កើតឡើង ។

## គោរពចំពោះបិណ្ឌបាត

កាលពិចារណាដល់ការគោរពចំពោះបិណ្ឌបាត យ៉ាងនេះថា មនុស្ស ទាំងឡាយណា កាលចិញ្ចឹមយើងដោយបច្ច័យ មានបិណ្ឌបាតជាដើម មនុស្ស ទាំងឡាយនោះ មិនមែនជាញាតិ មិនមែនជាទាស: មិនមែនជាកម្មកររបស់ យើងឡើយ ទាំងមនុស្សទាំងឡាយនោះ មិនមែនថ្វាយបច្ច័យ មានចីវរជាដើម ដែល ប្រណីតដល់យើង ដោយគិតថា នឹងអាស្រ័យយើងចិញ្ចឹមគេវិញនោះទេ ដែលពិត គេសង្ឃឹមឱ្យឧបការដែលខ្លួនធ្វើហើយ មានផលច្រើន ទើបថ្វាយ , សូម្បីព្រះសាស្តា ក៏ទ្រង់មិនបានពិចារណាឃើញយ៉ាងនេះថា ភិក្ខុនេះបរិភោគ បច្ច័យយ៉ាងនេះហើយ នឹងមានរាងកាយមាំមួន រស់នៅជាសុខ ដូច្នេះឡើយ

ទ្រង់អនុញ្ញាតបច្ច័យដល់យើង ដែលពិតនោះ ព្រះអង្គពិចារណាឃើញថា ភិក្ខុបរិភោគបច្ច័យទាំងឡាយនេះហើយ បំពេញសមណធម៌ នឹងផុតចាកទុក្ខក្នុងវដ្តៈបាន ទើបទ្រង់អនុញ្ញាតបច្ច័យ , គួរឬ យើងខ្ជិល មិនគោរពក្នុងបិណ្ឌបាតនោះ ព្រោះថា ការគោរពក្នុងបិណ្ឌបាត រមែងមានចំពោះអ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ។ ដូច្នេះ វីរិយសម្ពោជ្ឈង្គ ក៏កើតឡើងបាន ដូចវីរិយសម្ពោជ្ឈង្គ ដែលកើតដល់ព្រះមហាមិត្តត្ថេរដូច្នោះ ។

## ពិចារណាចំពោះមរតក

កាលពិចារណាឃើញភាពជាធំក្នុងការទទួលមរតកយ៉ាងនេះថា មរតករបស់ព្រះសាស្តាមានច្រើន គឺ អរិយទ្រព្យ ៧ ប្រការ ( បានដល់ សទ្ធា សីល ហិរិ ឱត្តប្បៈ សុតៈ ចាគៈ បញ្ញា ) មរតកនោះ បុគ្គលខ្ជិលមិនអាចទទួលបានទេ ដូចមាតាបិតា រមែងកាត់បុត្តដែលប្រព្រឹត្តខុសចេញ ធ្វើឱ្យជាបុគ្គលខាងក្រៅថា បុគ្គលនេះមិនមែនជាកូនរបស់យើង កាលមាតាបិតាកន្លងទៅ គេក៏មិនបានទទួលទ្រព្យមរតកយ៉ាងណា សូម្បីបុគ្គលដែលខ្ជិលច្រអូសក៏ដូច្នោះ រមែងមិនបានមរតកគឺអរិយទ្រព្យនេះទេ មានតែអ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះរមែងបានទទួល ដូច្នេះ វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។

## ពិចារណាព្រះសាស្តាជាធំ

កាលពិចារណាចំពោះព្រះសាស្តាជាធំ យ៉ាងនេះថា ព្រះសាស្តារបស់យើងជាធំ ក្នុងវេលាដែលព្រះសាស្តារបស់យើង ទ្រង់ចុះចាប់បដិសន្ធិ ក្នុងព្រះ

គភ៌របស់ព្រះមាតាក្តី វេលាស្តេចចេញមហាភិនេស្ក្រមណ៍ក្តី វេលាត្រាស់ដឹងព្រះអនុត្តរសម្មាសម្ពោធិញ្ញាណក្តី វេលាប្រកាសព្រះធម្មចក្រ សម្តែងយមកប្បាដិហារយ៍ ស្តេចចុះចាកទេវលោក ទ្រង់ដាក់អាយុសង្ខារក្តី វេលាស្តេចរំលត់ខន្ធបរិនិព្វានក្តី ម៉ឺនលោកធាតុ ក៏កម្រើកញាប់ញ័រ យើងបួសក្នុងព្រះសាសនារបស់ព្រះសាស្តាបែបនេះ នឹងជាបុគ្គលខ្ជិល គួរដែរឬ វីរិយសម្ពោជ្ឈង្គ ក៏កើតឡើង ។

## ពិចារណាជាតិជាធំ

កាលពិចារណាការមានជាតិជាធំយ៉ាងនេះថា ដោយជាតិ ឥឡូវនេះ យើងមិនមែនជាមនុស្សមានជាតិអន់ថយឡើយ យើងឈ្មោះថា ជាអ្នកកើតហើយក្នុងវង្សរបស់ព្រះបាទឧក្កាករាជ ជាប់បន្តមកដោយមហាសម្មតប្រវេណីមិនលាយដោយជនជាតិដទៃ ជាព្រះនត្តារបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមហាមាយាទេវី ជាព្រះអនុជរបស់ព្រះរាហុលពុទ្ធជិនោរស ឈ្មោះថា យើងជាពុទ្ធជិនបុត្ត បែបនេះហើយ នៅជាបុគ្គលខ្ជិល មិនសមគួរឡើយ វីរិយសម្ពោជ្ឈង្គ រមែងកើតឡើង ។

## ពិចារណាសព្រហ្មចារីជាធំ

កាលពិចារណាដល់សព្រហ្មចារីជាធំ យ៉ាងនេះថា ព្រះសារីបុត្ត ព្រះមោគ្គល្លាន ព្រះសាវ័កធំ ៗ ៨០ រូប ចាក់ធ្លុះនូវលោកុត្តធម៌ ដោយសេចក្តីព្យាយាមទាំងនោះ យើងនឹងធ្វើដំណើរតាមផ្លូវរបស់សព្រហ្មចារីទាំងឡាយនោះ

ឬ ក៏មិនធ្វើដំណើរតាម វីរិយសម្ពោជ្ឈង្គ រមែងកើតឡើង ។

## ការវៀរចាកបុគ្គលខ្ជិលច្រអូស
## ការគប់រកបុគ្គលមានការព្យាយាម - ការបង្អោនចិត្ត
## ទៅក្នុងវីរិយសម្ពោជ្ឈង្គនោះ

ការវៀរចាកបុគ្គលខ្ជិល ជាអ្នកលះបង់សេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ដែលដូចជាសត្វពស់ ស៊ីអាហារពេញពោះ ហើយក៏នៅមួយកន្លែងក្ដី សេពគប់រកបុគ្គលដែលមានសេចក្ដីព្យាយាម ជាអ្នកឧទ្ទិសខ្លួនដើម្បីបដិបត្តិធម៌ក្ដី មានចិត្តបង្អោនទៅដើម្បីឱ្យសេចក្ដីព្យាយាមកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានឈរអង្គុយជាដើមក្ដី វីរិយសម្ពោជ្ឈង្គរមែងកើតឡើង និងរមែងបរិបូរណ៍ដោយអរហត្តមគ្គ ។

## ៤ - បីតិសម្ពោជ្ឈង្គ

បីតិសម្ពោជ្ឈង្គ រមែងកើតឡើងតាមន័យមកហើយក្នុងព្រះបាលី ( សំ-យុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា :

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គ មានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការ ក្នុងធម៌ដែលជាទីតាំងនៃបីតិសម្ពោ-ជ្ឈង្គ នេះជាអាហារដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញនៃបីតិសម្ពោជ្ឈង្គ

ដែលកើតឡើងហើយ ។ បីតិនោះ ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ ក្នុងបាលីនោះ ។ មនសិការញ៉ាំងបីតិនោះ ឱ្យកើតឡើង ឈ្មោះថា យោនិសោ-មនសិការ ។

## ធម៌ជាហេតុកើតបីតិសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ ជាហេតុឱ្យកើតនូវបីតិសម្ពោជ្ឈង្គ គឺ ១- ពុទ្ធានុស្សតិ ២- ធម្មានុស្សតិ ៣- សង្ឃានុស្សតិ ៤- សីលានុស្សតិ ៥- ចាគានុស្សតិ ៦- ទេវតានុស្សតិ ៧- ឧបសមានុស្សតិ ៨- វៀរចាកបុគ្គលសៅហ្មង ៩- គប់រកបុគ្គលបរិសុទ្ធ ១០- ពិចារណាន័យក្នុងព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ១១- បង្អោនចិត្តទៅក្នុងបីតិសម្ពោជ្ឈង្គនោះ ។

ពិតហើយ អ្នកចម្រើនបីតិសម្ពោជ្ឈង្គ កាលរលឹកដល់ ព្រះពុទ្ធគុណ បីតិសម្ពោជ្ឈង្គក៏ផ្សាយទូទៅទាំងសរីរៈ រហូតបានសម្រេចនូវឧបចារសមាធិ ។ កាលរលឹកដល់គុណព្រះធម៌ និងព្រះសង្ឃក្តី ពិចារណាបារិសុទ្ធិសីល ៤ ដែលខ្លួនរក្សា មិនឱ្យដាច់អស់កាលជាយូរក្តី សូម្បីគ្រហស្ថពិចារណាសីល ១០ សីល ៥ ក្តី ពិចារណាចាគៈ ការបរិច្ចាគថា ក្នុងកាលជួបទុព្ភិក្ខភ័យជាដើម យើងថ្វាយភោជនដ៏ប្រណីតដល់សព្រហ្មចារីទាំងឡាយ ហើយថ្វាយភោជន ឈ្មោះយ៉ាងនេះ ដូច្នេះក្តី សូម្បីគ្រហស្ថពិចារណាដល់ទាន ដែលថ្វាយដល់លោកអ្នកមានសីល ក្នុងវេលាបែបនោះក្តី ពិចារណាដល់គុណដូចនឹងគុណដែលទេវតាប្រកបហើយ ក៏ដល់នូវភាពជាទេវតាថា មាននៅក្នុងខ្លួននេះក្តី ពិចារណាឃើញថា កិលេសដែលគ្របសង្កត់បានហើយ ដោយសមាបត្តិរហូតដល់ ៦០ ឆ្នាំខ្លះ ៧០

ឆ្នាំខ្លះ មិនកម្រើកឡើងដូច្នេះក្តី វៀរចាកបុគ្គលសៅហ្មងដែលប្រៀបដូចនឹងល្អងធូលី ព្រោះមិនមានសេចក្តីជ្រះថ្លាចំពោះព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើម មានភាពងឹតឈឹងសាងទុកហើយ ព្រោះមិនធ្វើដោយគោរព ក្នុងពេលឃើញព្រះចេតិយ ឃើញព្រះពោធិព្រឹក្ស និងឃើញព្រះថេរៈ សេពគប់បុគ្គលដែលបរិសុទ្ធ ច្រើនដោយសេចក្តីជ្រះថ្លា មានចិត្តទន់ភ្លន់ក្នុងព្រះរតនត្រៃ មានព្រះពុទ្ធជាម្ចាស់ជាដើម ពិចារណាសេចក្តីក្នុងព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ដែលសម្តែងនូវគុណរបស់ព្រះរតនត្រៃក្តី មានចិត្តទោទន់ទៅដើម្បីឱ្យកើតបីតិ ក្នុងឥរិយាបថទាំងឡាយ មានឈរ អង្គុយជាដើមក្តី បីតិ-សម្ពោជ្ឈង្គ រមែងកើតឡើង ។ ភិក្ខុរមែងដឹងច្បាស់ថា បីតិសម្ពោជ្ឈង្គនោះកើតឡើងដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ៥ – បស្សទ្ធិសម្ពោជ្ឈង្គ

បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតដោយន័យដែលមកហើយ ក្នុងព្រះបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា :

ម្នាលភិក្ខុទាំងឡាយ **កាយបស្សទ្ធិ** សេចក្តីស្ងប់កាយ **ចិត្តបស្សទ្ធិ** សេចក្តីស្ងប់ចិត្ត ការធ្វើឱ្យច្រើននូវយោនិសោមនសិការ ក្នុងការស្ងប់កាយ និងការស្ងប់ចិត្តនោះ នេះជាអាហារដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើតឡើង ឬ ជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញ នៃបស្សទ្ធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ។

## ធម៌ជាហេតុឱ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ **៧** ប្រការ ជាហេតុឱ្យកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គ គឺ **១**. សេពភោជនប្រណីត **២**. សេពរដូវជាទីសប្បាយ **៣**. សេពឥរិយាបថជាទីសប្បាយ **៤**. ប្រកបភាពជាកណ្ដាល **៥**. វៀរបុគ្គលដែលមិនស្ងប់កាយ **៦**. សេពបុគ្គលដែលស្ងប់កាយ **៧**.បង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គនោះ ។

ពិតហើយ អ្នកចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ កាលបរិភោគភោជនជាទីសប្បាយ ប្រណីតក្ដី សេពរដូវជាទីសប្បាយ មិនថា ជារដូវរងា រដូវក្ដៅ សេពឥរិយាបថជាទីសប្បាយ មិនថា ជាឥរិយាបថឈរជាដើមក្ដី រមែងកើតសេចក្ដីស្ងប់បាន ។ តែពាក្យនោះ ទ្រង់មិនបានពោលសំដៅដល់បុគ្គលដែលជាមហាបុរស ដែលអត់ធន់ចំពោះរដូវ និងឥរិយាបថជាទីសប្បាយទេ ។ កាលអ្នកដែលមានរដូវ និងឥរិយាបថដែលត្រូវគ្នានិងមិនត្រូវគ្នា វៀររដូវនិងឥរិយាបថដែលមិនត្រូវគ្នាចេញ ហើយសេពរដូវ និងឥរិយាបថដែលត្រូវគ្នា បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតឡើង ។ ការពិចារណាដល់ខ្លួននិងអ្នកដទៃ មានកម្មជារបស់ចំពោះខ្លួន ឈ្មោះថា ប្រកបភាពជាកណ្ដាល បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើងបានផងដែរ ដោយការប្រកបភាពជាកណ្ដាលនេះ ។ កាលវៀរចាកបុគ្គលដែលមានកាយមិនស្ងប់ ដូចជាទៅបៀតបៀនសត្វដទៃដោយគ្រឿងប្រហារ មានដុំដីនិងដំបងជាដើមក្ដី សេពរកបុគ្គលដែលមានកាយស្ងប់ សង្រួមដៃជើងក្ដី មានចិត្តបង្អោនទៅដើម្បីឱ្យកើតបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងឥរិយាបថ មានឈរអង្គុយជាដើមក្ដី បស្សទ្ធិសម្ពោជ្ឈង្គ រមែងកើតឡើងបាន ។ ភិក្ខុរមែងដឹងច្បាស់ថា បស្សទ្ធិសម្ពោជ្ឈង្គនោះ កើតឡើងហើយដោយអាការយ៉ាងនេះ រមែងចម្រើន

បរិបូរណ៍ដោយអរហត្តមគ្គ ។

## ៦-សមាធិសម្ពោជ្ឈង្គ

សមាធិសម្ពោជ្ឈង្គ រមែងកើតឡើងតាមន័យមកហើយ ក្នុងព្រះបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា :

ម្នាលភិក្ខុទាំងឡាយ **សមថនិមិត្ត** ( បាលីថា សមាធិនិមិត្ត ) **អព្យគ្គនិមិត្ត** មានហើយ ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងនិមិត្តទាំង ២ នោះ នេះជាអាហារដើម្បីការកើតឡើងនៃសមាធិសម្ពោជ្ឈង្គ ដែលមិនទាន់កើតឡើង ឬជាផ្លូវដើម្បីភិយ្យោភាព ចម្រើនបរិបូរណ៍ពេញលេញ នៃសមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ ។

ក្នុងនិមិត្តទាំងឡាយនោះ សមថៈនោះឯង ឈ្មោះថា **សមថនិមិត្ត** , **អព្យគ្គនិមិត្ត** មានអត្ថថា ការមិនរាយមាយ ។

## ធម៌ជាហេតុឱ្យកើតសមាធិសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ១១ ប្រការ ជាផ្លូវកើតនៃសមាធិសម្ពោជ្ឈង្គ គឺ ១-ធ្វើវត្ថុឱ្យស្អាត ២-ធ្វើឥន្ទ្រិយឱ្យស្មើគ្នា ៣-ឆ្លាតក្នុងនិមិត្ត ៤-ផ្គងចិត្តក្នុងសម័យដែលគួរ ៥-គ្របសង្កត់ចិត្តក្នុងសម័យដែលគួរ ៦-ធ្វើចិត្តឱ្យរីករាយក្នុងសម័យដែលគួរ ៧-ព្រងើយក្នុងសម័យដែលគួរ ៨-វៀរចាកបុគ្គលដែលមានចិត្តមិនជាសមាធិ ៩-គប់រកបុគ្គលដែលមានចិត្តជាសមាធិ ១០-ពិចារណាឈាន និងវិមោក្ខ ១១-បង្អោនចិត្តទៅក្នុងសមាធិសម្ពោជ្ឈង្គនោះ ។

ក្នុងធម៌ **១១** ប្រការ ចំពោះការធ្វើវត្ថុឱ្យស្អាត និងការធ្វើឥន្ទ្រិយឱ្យស្មើគ្នា គប្បីជ្រាបតាមន័យដូចពោលមកហើយនោះចុះ ។

ភាពឆ្លាតក្នុងការកំណត់កសិណនិមិត្តជាអារម្មណ៍ ឈ្មោះថា ឆ្លាតក្នុងនិមិត្ត ។ ការផ្គងចិត្តទុកដោយការតាំងធម្មវិចយសម្ពោជ្ឈង្គ វីរិយសម្ពោជ្ឈង្គ និងបីតិសម្ពោជ្ឈង្គក្នុងសម័យដែលចិត្តរួញរា ព្រោះមានសេចក្ដីព្យាយាមខ្សោយទៅៗ ជាដើម ឈ្មោះថា **ការផ្គងចិត្តក្នុងសម័យដែលគួរ** ។

ការគ្របសង្កត់ចិត្តដោយការតាំងបស្សទ្ធិសម្ពោជ្ឈង្គ សមាធិសម្ពោជ្ឈង្គ និង ឧបេក្ខាសម្ពោជ្ឈង្គក្នុងសម័យដែលចិត្តរាយមាយ ព្រោះប្រារព្ធសេចក្ដីព្យាយាមហួសកម្រិតជាដើម ឈ្មោះថា **គ្របសង្កត់ចិត្តក្នុងសម័យដែលគួរ** ។

ពាក្យថា **ធ្វើចិត្តឱ្យរីករាយក្នុងសម័យដែលគួរ** អធិប្បាយថា សម័យណាចិត្តមិនរីករាយ ព្រោះមានបញ្ញា និង សេចក្ដីព្យាយាមទន់ខ្សោយ ឬ ព្រោះមិនសម្រេចនូវសេចក្ដីសុខដែលកើតចាកសេចក្ដីស្ងប់ សម័យនោះ គប្បីធ្វើចិត្តឱ្យស្លុត ដោយពិចារណាសង្វេគវត្ថុ រឿងដែលជាទីតាំងនៃសេចក្ដីតក់ស្លុត ៨ ប្រការ ។

រឿងដែលជាទីតាំងនៃសេចក្ដីតក់ស្លុត ៨ ប្រការ នោះគឺ :

**១**-ជាតិ **២**-ជរា **៣**-ព្យាធិ **៤**-មរណៈ **៥**-ទុក្ខក្នុងអបាយ **៦**-ទុក្ខក្នុងអតីតមានវដ្តៈជាមូល **៧**-ទុក្ខក្នុងអនាគតមានវដ្តៈជាមូល **៨**-ទុក្ខក្នុងបច្ចុប្បន្នមានការស្វែងរកអាហារជាមូល ។ ម្យ៉ាងទៀត ការធ្វើសេចក្ដីជ្រះថ្លាឱ្យកើតដោយការរលឹកដល់គុណព្រះរតនត្រៃ នេះក៏ហៅថា **ការធ្វើចិត្តឱ្យរីករាយ ក្នុងសម័យដែលគួរ** ។

ឈ្មោះថា **ព្រងើយៗក្នុងសម័យដែលគួរ** អធិប្បាយថា សម័យណាចិត្ត អាស្រ័យការបដិបត្តិត្រូវ មិនរួញរា មិនរាយមាយ រីករាយ ប្រព្រឹត្តទៅស្មើក្នុង អារម្មណ៍ ដំណើរទៅក្នុងសមថវិថី សម័យនោះ មិនត្រូវខ្វល់ខ្វាយ ក្នុងការផ្គង ការគ្របសង្កត់ និងការធ្វើចិត្តឱ្យរីករាយ ដូចសារថីមិនខ្វល់ខ្វាយក្នុងពេលដែល សេះរត់ទៅស្មើល្អហើយដូច្នោះ នេះឈ្មោះថា **ព្រងើយក្នុងសម័យដែលគួរ** ។

ការវៀរចាកបុគ្គលដែលមានចិត្តរាយមាយ មិនសម្រេចឧបចារ ឬ អប្បនា ឱ្យឆ្ងាយ ឈ្មោះថា **វៀរចាកបុគ្គលដែលមានចិត្តមិនជាសមាធិ** ។

ការសេព ការគប់រកការចូលទៅអង្គុយជិតអ្នកដែលមានចិត្តជាសមាធិ ដោយឧបចារភាវនា ឬ អប្បនាភាវនា ឈ្មោះថា **គប់រកបុគ្គលអ្នកមានចិត្តជា សមាធិ** ។

ភាពជាអ្នកមានចិត្តបង្អោនទៅដើម្បីឱ្យកើតសមាធិ ក្នុងឥរិយាបថ ទាំងឡាយ មានឈរអង្គុយជាដើម ឈ្មោះថា **បង្អោនចិត្តទៅក្នុងសមាធិ-សម្ពោជ្ឈង្គ** ។ ព្រោះថា កាលបដិបត្តិយ៉ាងនេះ សមាធិសម្ពោជ្ឈង្គនោះ រមែង កើតឡើងបាន ។ កាលភិក្ខុដឹងច្បាស់ថា សមាធិសម្ពោជ្ឈង្គនោះ កើតហើយ ដោយអាការយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

## ៧ - ឧបេក្ខាសម្ពោជ្ឈង្គ

ឧបេក្ខាសម្ពោជ្ឈង្គ រមែងកើតឡើងបានតាមន័យដែលបានមកហើយ ក្នុងបាលី ( សំយុត្តនិកាយ មហាវារវគ្គ ) យ៉ាងនេះថា :

ម្នាលភិក្ខុទាំងឡាយ ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គមានហើយ ការ

ធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ នោះនេះជាអាហារ ដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គដែលមិនទាន់កើតឡើង ឬ ជាផ្លូវដើម្បីភិយ្យោភាពបរិបូរណ៍ពេញលេញ នៃឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ។ ឯក្នុងធម៌ទាំងឡាយនេះ ឧបេក្ខានោះឯង ឈ្មោះថាធម៌ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

## ធម៌ជាហេតុឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គ

ម្យ៉ាងទៀត ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ គឺ ១-ដាក់ខ្លួនជាកណ្ដាលក្នុងសត្វ ២-ដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ ៣-វៀរចាកបុគ្គលដែលប្រកាន់សត្វនិងសង្ខារ ៤-សេពគប់រកបុគ្គលដែលដាក់ខ្លួនជាកណ្ដាលក្នុង សត្វ និង សង្ខារ ៥-បង្អោនចិត្តទៅក្នុងឧបេក្ខា-សម្ពោជ្ឈង្គនោះ ។

ក្នុងធម៌ ៥ ប្រការនោះ អ្នកចម្រើនឧបេក្ខាសម្ពោជ្ឈង្គ រមែងដាក់ខ្លួនជាកណ្ដាលក្នុងសត្វដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាដល់ខ្លួន និងអ្នកដទៃ មានកម្មជារបស់ខ្លួន យ៉ាងនេះថា យើងមកដោយកម្មរបស់យើង ហើយក៏ទៅ ដោយកម្មរបស់យើង គេក៏មកដោយកម្មរបស់គេ ហើយក៏ទៅដោយកម្មរបស់គេ ដូចគ្នា យើងនឹងប្រកាន់អ្វីបាន និងពិចារណាដល់ការមិនមានសត្វ យ៉ាងនេះថា ដោយបរមត្ថ ដែលថាសត្វ ៗ នោះ មិនមាន នឹងប្រកាន់អ្វីទៅ ។

ដាក់ខ្លួនជាកណ្ដាលក្នុងសង្ខារ ដោយអាការ ២ យ៉ាង ដោយការ

ពិចារណា ជារបស់មិនមានម្ចាស់ យ៉ាងនេះថា ចីវរនេះនឹងចូលដល់ការប្រែប្រួលពណ៌ និងចាស់គ្រាំគ្រា ជាសំពត់ជូតជើង ត្រូវឆ្កឹះចោលដោយចុងឈើច្រត់ ប្រសិនបើចីវរនោះ មានម្ចាស់សោត គេក៏មិនឱ្យវាវិនាសយ៉ាងនេះឡើយ និងដោយការពិចារណា ជារបស់បណ្តោះអាសន្ន យ៉ាងនេះថា ចីវរនេះនៅមិនបានយូរទេ ជារបស់បណ្តោះអាសន្នប៉ុណ្ណោះ ។ សូម្បីក្នុងបរិក្ខារមានបាត្រជាដើម គប្បីប្រកបសេចក្តីដូចក្នុងចីវរចុះ ។

ក្នុងន័យថា វៀរចាកបុគ្គលដែលប្រកាន់សត្វ និង សង្ខារមានវិនិច្ឆ័យដូច្នេះ :

បុគ្គលណាជាគ្រហស្ថ ក៏ប្រកាន់បិយជន មានបុត្ត ធីតា ជាដើមរបស់ខ្លួន ឬ បើជាបព្វជិត ក៏ប្រកាន់បព្វជិត មានអន្តេវាសិក និង អ្នករួមឧបជ្ឈាយ៍ជាដើមរបស់ខ្លួន រវល់ធ្វើកិច្ចកម្ម មានកោសក់ ដេរចីវរ ជ្រលក់ចីវរ រុំបាត្រជាដើម របស់ជនទាំងឡាយនោះ ដោយដៃរបស់ខ្លួនផ្ទាល់ កាលមិនបានឃើញតែមួយពេល ក៏គិតថា សាមណេររូបនោះទៅណា ភិក្ខុរូបនោះទៅណាសម្លឹងរកមើល ដូចជាម្រឹគភ្ញាក់ផ្អើលដូច្នោះ សូម្បីអ្នកដទៃអង្វរថា សូមបញ្ជូនសាមណេរឈ្មោះនោះ ទៅជួយកោសក់ជាដើម ត្រឹមតែមួយសន្ទុះ ក៏មិនព្រមឱ្យ ពួកយើងក៏នឹងត្រូវឱ្យធ្វើការងាររបស់យើងដែរ ពួកអ្នកនាំគេទៅនឹងលំបាកបុគ្គលនេះ ឈ្មោះថា ប្រកាន់សត្វ ។

ចំណែកបុគ្គលណា ប្រកាន់បរិក្ខារ មាន ចីវរ បាត្រ ស្រោមបាត្រ ឈើច្រត់ជាដើម សូម្បីអ្នកដទៃប៉ះ ក៏មិនឱ្យប៉ះ សូម្បីខ្ចី ក៏ឆ្លើយជំទាស់ថា យើងត្រូវការប្រើទ្រព្យនោះ ក៏មិនទាន់បានប្រើ នឹងឱ្យពួកអ្នកបានដូចម្តេចទៅ បុគ្គលនេះ

ឈ្មោះថា ប្រកាន់សង្ខារ ។

ចំណែកបុគ្គលណាដាក់ខ្លួនជាកណ្តាល ស្មោះត្រង់ក្នុងវត្ថុទាំង ២ នោះ បុគ្គលនេះ ឈ្មោះថា ដាក់ខ្លួនជាកណ្តាល ក្នុងសត្វ និងសង្ខារ ។

កាលវៀរចាកបុគ្គល ដែលប្រកាន់សត្វ និងសង្ខារយ៉ាងនេះក្តី សេពគប់បុគ្គលអ្នកដាក់ខ្លួនជាកណ្តាល ក្នុងសត្វនិងសង្ខារក្តី មានចិត្តបង្អោនទៅដើម្បីឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ក្នុងឥរិយាបថទាំងឡាយ មាន ឈរ អង្គុយ ជាដើម ឧបេក្ខាសម្ពោជ្ឈង្គនេះ រមែងកើតឡើងដោយប្រការដូច្នេះ ។ ភិក្ខុរមែងដឹងច្បាស់ថា ឧបេក្ខាសម្ពោជ្ឈង្គនោះ កើតឡើងហើយ ដោយប្រការយ៉ាងនេះ រមែងចម្រើនបរិបូរណ៍ដោយអរហត្តមគ្គ ។

ពាក្យថា **ឥតិ អជ្ឈត្តំវា**-ឬខាងក្នុងជាដើម មានន័យថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ព្រោះកំណត់សម្ពោជ្ឈង្គ ៧ របស់ខ្លួនតាមកាល ឬ របស់អ្នកដទៃតាមកាល ។ ឯការកើត និងការរលត់ ( នៃឧបេក្ខាសម្ពោជ្ឈង្គ ) គប្បីជ្រាបដោយអំណាចការកើត និង ការរលត់ទៅនៃសម្ពោជ្ឈង្គទាំងឡាយ ក្នុងពោជ្ឈង្គបព្វៈនេះ ។ សេចក្តីបន្ទាប់ពីនេះ ក៏មានន័យដូចដែលពោលមកហើយនោះឯង ។

( ចប់ ពោជ្ឈង្គបព្វៈ )

## ៥ – សច្ចបព្វៈ

ម្នាលភិក្ខុទាំងឡាយ ពាក្យខាងមុខនៅមានទៀត ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ គឺ អរិយសច្ចទាំង ៤ គ្រប់ឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ចទាំង ៤ គ្រប់ ឥរិយាបថទាំង ៤ តើដោយវិធីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឱ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសភាវៈរំលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាបដិបទាឱ្យបានដល់នូវទីរំលត់ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ **ចុះទុក្ខអរិយសច្ច** តើដូចម្តេច ?
**ជាតិ** គឺ កំណើតដែលកើតជាដំបូង ក៏ជាទុក្ខ , **ជរា** គឺ សេចក្តីចាស់គ្រាំគ្រា ក៏ជាទុក្ខ , **មរណៈ** គឺ សេចក្តីស្លាប់ក៏ជាទុក្ខ , **សោកៈ** គឺ សេចក្តីស្តាយស្រណោះ , **បរិទេវៈ** គឺ សេចក្តីខ្សឹកខ្សួល , **ទុក្ខ** គឺ សេចក្តីលំបាកកាយ , **ទោមនស្ស** គឺ សេចក្តីអាក់អន់តូចចិត្ត , **ឧបាយាសៈ** គឺ សេចក្តីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ , **អប្បិយេហិសម្បយោគ** គឺ ដំណើរជួបប្រសព្វដោយសត្វ និងសង្ខារទាំងឡាយដែលមិនជាទីស្រឡាញ់ក៏ជាទុក្ខ , **បិយេហិវិប្បយោគ** គឺ សេចក្តីព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយដែលជាទីស្រឡាញ់ ក៏ជាទុក្ខ , **យម្បិច្ឆំនលភតិតម្បិ** គឺ បុគ្គលកាលចង់បាននូវរបស់ណា តែមិនបាន ឯការមិនបានរបស់នោះក៏ជាទុក្ខ បើដោយសេចក្តីបំប្រួញ **ឧបាទានក្ខន្ធទាំង ៥** មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **ជាតិ** ?

កិរិយាកើតជាដំបូង កិរិយាកើតព្រម ការចុះចាប់ផ្ទៃ ការវិលត្រឡប់មកកើត ការកើតប្រាកដនៃខន្ធ ការបាននូវអាយតនៈណារបស់សត្វនោះ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ជាតិ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ជរា** ?

**ជរា** គឺ សេចក្តីចាស់គ្រាំគ្រា ឬ ការប្រែប្រួល ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវ យុរយារ ការរួញថយនៃអាយុ ការទ្រុឌទ្រោមនៃឥន្ទ្រិយទាំងឡាយណា របស់សត្វទាំងឡាយនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ជរា** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **មរណៈ** ?

ភាវៈនៃចិត្តដែលឃ្លាតចាក អាការនៃចិត្តដែលឃ្លាតទៅ ការបែកធ្លាយទៅ ការបាត់បង់ទៅ សេចក្តីវិនាសជីវិត សេចក្តីស្លាប់ កាលកិរិយា ការបែកធ្លាយនៃខន្ធទាំងឡាយ ការដាក់ចុះនូវសាកសព ការផ្តាច់ផ្តិលនូវជីវិតិន្ទ្រិយណារបស់សត្វទាំងឡាយនោះៗ ចាកសត្តនិកាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតថា **មរណៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **សោកៈ** ?

ម្នាលភិក្ខុទាំងឡាយ **សោកៈ** គឺ សេចក្តីស្តាយស្រណោះ សេចក្តីស្រងេះស្រងោច សេចក្តីសោកសៅ សេចក្តីរីងស្ងួតក្នុងចិត្ត សេចក្តីក្រៀមក្រំក្នុងចិត្តណា របស់សត្វ ដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ ឬដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សោកៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **បរិទេវ:** ?

ម្នាលភិក្ខុទាំងឡាយ សភាវ:ទូញរក ( បិយជន មានកូនជាដើម ) សភាវ:ទូញរៀបរាប់ ( សរសើរគុណ ) កិរិយាយំអណ្តឺតអណ្តក់ កិរិយាយំបម្រះនរៀល ភាវ:នៃការយំអណ្តឺតអណ្តក់ ភាវ:នៃការយំបម្រះនរៀល ណារបស់សត្វដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ ឬ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា **បរិទេវ:** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **ទុក្ខ:** ?

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាក សេចក្តីមិនសប្បាយ សេចក្តីលំបាកដែលកើតពីកាយសម្ផស្ស ការទទួលរងសេចក្តីមិនស្រួលណា ម្នាលភិក្ខុទាំង-ឡាយ នេះតថាគតហៅថា **ទុក្ខ:** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **ទោមនស្ស** ?

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកក្នុងចិត្ត សេចក្តីមិនសប្បាយក្នុងចិត្ត សេចក្តីលំបាកដែលកើតពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនស្រួលណា ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា **ទោមនស្ស** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **ឧបាយាស:** ?

ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត ភាវ:នៃសេចក្តីតានតឹងក្នុងចិត្ត ភាវ:នៃសេចក្តីចង្អៀតចង្អល់ចិត្តណា របស់សត្វដែលប្រកបហើយ ដោយសេចក្តីវិនាសណាមួយ ឬ ដែលសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ឧបាយាស:** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **អប្បិយេហិសម្បយោគទុក្ខ** ?

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយណា ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ប្រាថ្នានូវសេចក្តីមិនចម្រើន ប្រាថ្នានូវអំពើឥតប្រយោជន៍ ប្រាថ្នានូវសេចក្តីមិនសប្បាយ ប្រាថ្នានូវអំពើដែលមិនក្សេមចាកយោគៈ ចំពោះបុគ្គលនោះ កិរិយាបានជួបគ្នា កិរិយាជួបជុំគ្នា កិរិយាប្រជុំគ្នា ការនៅច្រឡូកច្រឡំគ្នា នឹងអារម្មណ៍ទាំងឡាយនោះៗ នឹងជនទាំងឡាយនោះ ៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **អប្បិយេហិសម្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **បិយេហិវិប្បយោគទុក្ខ** ?

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានដល់បុគ្គលណាក្នុងលោកនេះ ពុំនោះសោត ជនទាំងឡាយណា ទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្រក្តី អមាត្យក្តី ញាតិសាលោហិតក្តី ដែលជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសប្បាយ ប្រាថ្នានូវសេចក្តីក្សេមចាកយោគៈ ចំពោះបុគ្គលនោះ ការមិនបានជួបគ្នា ការមិនបានជួបជុំគ្នា កិរិយាមិនបានប្រជុំគ្នា ការមិននៅច្រឡូកច្រឡំ នឹងអារម្មណ៍ទាំងឡាយនោះ ៗ នឹងជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **បិយេហិវិប្បយោគទុក្ខ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **យម្បិច្ឆំនលភតិតម្បិទុក្ខ** ?

ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា តែងមានសេចក្តី

ប្រាថ្នាកើតឡើង យ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ឱ្យយើងទាំងឡាយ កុំគប្បីមានជាតិជាធម្មតា ពុំនោះសោត ជាតិកុំគប្បីមកដល់យើងទាំងឡាយ សេចក្ដីនេះ ពួកសត្វក៏មិនបានសម្រេចតាមប្រាថ្នាសោះឡើយ នេះឯង ឈ្មោះថា **យម្បិច្ឆំន-លភតិតម្បិទុក្ខ** ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីគ្រាំគ្រា ឬប្រែប្រួលជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីឈឺថ្កាត់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ... ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីស្លាប់ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលមានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីអាក់អន់តួចចិត្ត សេចក្ដីខ្លោចផ្សាចិត្តជាធម្មតា តែងមានសេចក្ដីប្រាថ្នាកើតឡើង យ៉ាងនេះថា ធ្វើម្ដេចហ្ន៎ ឱ្យយើងទាំងឡាយកុំគប្បីមានសេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីអាក់អន់តួចចិត្ត សេចក្ដីខ្លោចផ្សាចិត្ត កុំគប្បីមានដល់យើងទាំង-ឡាយឡើយ សេចក្ដីនេះ ពួកសត្វក៏មិនបានសម្រេច តាមសេចក្ដីប្រាថ្នាឡើយ នេះឯង ក៏ឈ្មោះថា **យម្បិច្ឆំនលភតិតម្បិទុក្ខ** ដែរ ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច **ឧបាទានក្ខន្ធទាំង ៥** ដោយបំព្រួញដែលថាជាទុក្ខ ?

ឧបាទានក្ខន្ធទាំង ៥ នោះ គឺ អ្វីខ្លះ គឺ រូប ជាឧបាទានក្ខន្ធ១ វេទនាជាឧបាទានក្ខន្ធ១ សញ្ញាជាឧបាទានក្ខន្ធ១ សង្ខារជាឧបាទានក្ខន្ធ១ វិញ្ញាណជាឧបាទានក្ខន្ធ១ ម្នាលភិក្ខុទាំងឡាយ ទាំងនេះតថាគតហៅថា ឧបាទានក្ខន្ធ ៥ ដោយសេចក្ដីបំព្រួញ ថាជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **ទុក្ខសមុទយអរិយសច្ច** ។ តណ្ហាណា ជាធម្មជាតិនាំសត្វឱ្យកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វឱ្យត្រេកត្រអាលនៅក្នុងភពនោះៗ ឬក្នុងអារម្មណ៍នោះៗ តណ្ហានោះ គឺ អ្វីខ្លះ គឺ កាមតណ្ហា ( សេចក្ដីប្រាថ្នាក្នុងកាម ) ១ ភវតណ្ហា ( សេចក្ដីប្រាថ្នាក្នុងរូបភព និងអរូបភព ) ១ វិភវតណ្ហា ( សេចក្ដីប្រាថ្នាក្នុងភពសូន្យ ) ។

ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះ កាលដែលកើតឡើង តើកើតឡើងក្នុងទីណា កាលដែលជាប់នៅ តើជាប់នៅក្នុងទីណា អារម្មណ៍ណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលកើតឡើង ក៏កើតឡើងក្នុងចក្ខុនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងចក្ខុនោះ ។ សោតៈក្នុងលោក ។ ឃានៈក្នុងលោក ។ ជីវ្ហាក្នុងលោក ។ កាយក្នុងលោក ។ មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោនោះ។ រូបារម្មណ៍ទាំងឡាយក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយក្នុងលោក ។ រសារម្មណ៍ទាំងឡាយក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក ។ ធម្មារម្មណ៍ទាំងឡាយក្នុងលោក ។ ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងធម្មារម្មណ៍នុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍នុ៎ះ ។ ចក្ខុវិញ្ញាណក្នុងលោក ។ សោតវិញ្ញាណក្នុងលោក ។ ឃានវិញ្ញាណក្នុងលោក ។ ជីវ្ហាវិញ្ញាណក្នុងលោក ។ កាយវិញ្ញាណក្នុងលោក ។

មនោវិញ្ញាណក្នុងលោក ។ ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោវិញ្ញាណនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុសម្ផស្សក្នុងលោក ។ សោតសម្ផស្សក្នុងលោក ។ ឃានសម្ផស្សក្នុងលោក ។ ជិវ្ហាសម្ផស្សក្នុងលោក ។ កាយសម្ផស្សក្នុងលោក ។ មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងមនោសម្ផស្សនុ៎ះ ។ វេទនាកើតពីចក្ខុសម្ផស្សក្នុងលោក ។ វេទនាកើតពីសោតសម្ផស្សក្នុងលោក ។ វេទនាកើតពីឃានសម្ផស្សក្នុងលោក ។ វេទនាកើតពីជិវ្ហាសម្ផស្សក្នុងលោក ។ វេទនាកើតពីកាយសម្ផស្សក្នុងលោក ។ វេទនាកើតពីមនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងវេទនាដែលកើតពីមនោសម្ផស្សនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងវេទនាដែលកើតពីមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ក្នុងលោក ។ ការគិតសន្សំ

នូវគន្ធារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលកើតឡើង ក៏កើតឡើងក្នុងការគិតសន្សំនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងធម្មារម្មណ៍ ។ សេចក្តីប្រាថ្នានូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវរសារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីត្រិះរិះនូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវរសារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។ ការពិចារណានូវរូបារម្មណ៍ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាព

គួរត្រេកអរ តណ្ហានុ៎ះ កាលដែលកើតឡើង ក៏កើតឡើងក្នុងការពិចារណា នូវធម្មារម្មណ៍នុ៎ះ កាលជាប់នៅ ក៏ជាប់នៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខសមុទយអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **ទុក្ខនិរោធអរិយសច្ច** ?

ការអស់ទៅ និងការរលត់ទៅ ដោយមិនមានសេសសល់ ការលះបង់ ការរលាស់ចោល ការជម្រុះចោល ការមិនមានអាល័យ ចំពោះតណ្ហានោះឯង ( ហៅថា ទុក្ខនិរោធអរិយសច្ច ) ។ ម្នាលភិក្ខុទាំងឡាយ ចុះតណ្ហានោះឯង កាលដែលបុគ្គលលះបង់ តើលះបង់ក្នុងទីណា កាលដែលរលត់ទៅ តើរលត់ទៅក្នុងទីណា ។ អារម្មណ៍ណាក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ តែងលះបង់ក្នុងអារម្មណ៍នុ៎ះ កាលដែលរលត់ទៅ តែងរលត់ទៅក្នុងអារម្មណ៍នុ៎ះ ។ ចុះអារម្មណ៍អ្វី ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ។ ចក្ខុក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងចក្ខុនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងចក្ខុនុ៎ះ ។ សោតៈក្នុងលោក ឃានៈក្នុងលោក ។ ជីវ្ហាក្នុងលោក ។ កាយក្នុងលោក ។ មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាវៈគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោនោះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោនោះ ។ រូបារម្មណ៍ទាំងឡាយក្នុងលោក ។ សទ្ទារម្មណ៍ទាំងឡាយក្នុងលោក ។ គន្ធារម្មណ៍ទាំងឡាយក្នុងលោក ។ រសារម្មណ៍ទាំងឡាយក្នុងលោក ។ ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក ។

ធម្មារម្មណ៍ទាំងឡាយ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងធម្មារម្មណ៍នុ៎ះ ។ ចក្ខុវិញ្ញាណក្នុងលោក ។ សោតវិញ្ញាណក្នុងលោក ។ ឃានវិញ្ញាណក្នុងលោក ។ ជិវ្ហាវិញ្ញាណក្នុងលោក ។ កាយវិញ្ញាណក្នុងលោក ។ មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោវិញ្ញាណនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោវិញ្ញាណនុ៎ះ ។ ចក្ខុសម្ផស្សក្នុងលោក ។ សោតសម្ផស្សក្នុងលោក ។ ឃានសម្ផស្សក្នុងលោក ។ ជិវ្ហាសម្ផស្សក្នុងលោក ។ កាយសម្ផស្សក្នុងលោក ។ មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ។ វេទនាដែលកើតឡើងពីចក្ខុសម្ផស្សក្នុងលោក ។ វេទនាដែលកើតឡើងពីសោតសម្ផស្សក្នុងលោក ។ វេទនាដែលកើតឡើងពីឃានសម្ផស្សក្នុងលោក ។ វេទនាដែលកើតឡើងពីជិវ្ហាសម្ផស្សក្នុងលោក ។ វេទនាដែលកើតឡើងពីកាយសម្ផស្សក្នុងលោក ។ វេទនាដែលកើតឡើងពីមនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងមនោសម្ផស្សនុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងមនោសម្ផស្សនុ៎ះ ។ សេចក្តីសម្គាល់នូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវរសារម្មណ៍ ក្នុងលោក ។ សេចក្តី

សម្គាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីសម្គាល់នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីសម្គាល់នូវធម្មារម្មណ៍នុ៎ះ ។ ការគិតសន្សំនូវរូបារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវសទ្ទារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវគន្ធារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវរសារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការគិតសន្សំនូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការសន្សំនូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីប្រាថ្នានូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវសទ្ទារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវរសារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីប្រាថ្នានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងសេចក្តីប្រាថ្នានូវធម្មារម្មណ៍នុ៎ះ ។ សេចក្តីត្រិះរិះនូវរូបារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក ។ សេចក្តីត្រិះរិះនូវគន្ធារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវរសារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ សេចក្តីត្រិះរិះនូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងសេចក្តីត្រិះរិះនូវធម្មារម្មណ៍នុ៎ះ ។ ការពិចារណានូវ

រូបារម្មណ៍ ក្នុងលោក ។ ការពិចារណានូវសទ្ទារម្មណ៍ ក្នុងលោក ។ ការពិចារណានូវគន្ធារម្មណ៍ ក្នុងលោក ។ ការពិចារណានូវរសារម្មណ៍ក្នុងលោក ។ ការពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក ។ ការពិចារណានូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានុ៎ះ កាលដែលបុគ្គលលះបង់ ក៏លះបង់ក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ កាលដែលរលត់ទៅ ក៏រលត់ទៅក្នុងការពិចារណានូវធម្មារម្មណ៍នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខនិរោធអរិយសច្ច** ។

ម្នាលភិក្ខុទាំងឡាយ ដូចម្តេច ហៅថា **ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច** ?

អរិយមគ្គ ដែលប្រកបដោយអង្គ ៨ ប្រការ នេះឯង ( ហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ) អរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ តើដូចម្តេច គឺ :

| | | | |
|---|---|---|---|
| ១- | **សម្មាទិដ្ឋិ** | សេចក្តីយល់ឃើញត្រូវ | ។ |
| ២- | **សម្មាសង្កប្បៈ** | សេចក្តីត្រិះរិះត្រូវ | ។ |
| ៣- | **សម្មាវាចា** | ការនិយាយត្រូវ | ។ |
| ៤- | **សម្មាកម្មន្តៈ** | ការងារត្រូវ | ។ |
| ៥- | **សម្មាអាជីវៈ** | ការចិញ្ចឹមជីវិតត្រូវ | ។ |
| ៦- | **សម្មាវាយាមៈ** | សេចក្តីព្យាយាមត្រូវ | ។ |
| ៧- | **សម្មាសតិ** | សេចក្តីនឹករលឹកត្រូវ | ។ |
| ៨- | **សម្មាសមាធិ** | ការតម្កល់ចិត្តឱ្យនឹងត្រូវ | ។ |

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា **សម្មាទិដ្ឋិ** ?

ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដឹងច្បាស់ក្នុងកងទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងធម៌ដែលជាទីប្រជុំឱ្យកើតទុក្ខ ប្រាជ្ញាដឹងច្បាស់ ក្នុងធម៌ដែលជាទីរលត់ទៅនៃទុក្ខ ប្រាជ្ញាដឹងច្បាស់ក្នុងបដិបទា ទៅកាន់ធម៌ជាទីរលត់នៃទុក្ខណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាទិដ្ឋិ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា **សម្មាសង្កប្បៈ** ?

សេចក្ដីត្រិះរិះ ដើម្បីចេញចាកកាម សេចក្ដីត្រិះរិះដើម្បីការមិនព្យាបាទ សេចក្ដីត្រិះរិះដើម្បីការមិនបៀតបៀន ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាសង្កប្បៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា **សម្មាវាចា** ?

ចេតនាវៀរចាកកិរិយានិយាយពាក្យមិនពិត ១ ចេតនាវៀរចាកសម្ដីញុះញង់ស៊កសៀត ១ ចេតនាវៀរចាកសម្ដីត្រគោះបោះបោក ១ ចេតនាវៀរចាកពាក្យពោលរោយរាយឥតប្រយោជន៍ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាវាចា** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេច ហៅថា **សម្មាកម្មន្តៈ** ?

ចេតនាវៀរចាកកិរិយាញ៉ាំងសត្វមានជីវិត ឱ្យធ្លាក់ចុះកន្លង ( សម្លាប់សត្វ ) ១ ចេតនាវៀរចាកកិរិយាកាន់យករបស់ដែលគេមិនបានឱ្យ ១ ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ម្នាលភិក្ខុទាំងឡាយ នេះតថាគត ហៅថា **សម្មាកម្មន្តៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្ដេចហៅថា **សម្មាអាជីវៈ** ?

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយរស់នៅដោយការចិញ្ចឹមជីវិតត្រូវ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាអាជីវៈ** ?

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **សម្មាវាយាមៈ** ?

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញ៉ាំងឆន្ទៈឱ្យកើតឡើង ប្រឹងប្រែងប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឱ្យកើតឡើងបាន ញ៉ាំងឆន្ទៈឱ្យកើត ប្រឹងប្រែងប្រារព្ធនូវការព្យាយាម ផ្គងចិត្តទុក តាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយ ជាអកុសលដ៏លាមក ដែលកើតឡើងហើយ ញ៉ាំងឆន្ទៈឱ្យកើត ប្រឹងប្រែងប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាម ដើម្បីញ៉ាំងធម៌ទាំងឡាយ ជាកុសលដែលមិនទាន់កើតឡើងហើយឱ្យកើតឡើងបាន ញ៉ាំងឆន្ទៈឱ្យកើតឡើង ប្រឹងប្រែងប្រារព្ធនូវការព្យាយាម ផ្គងនូវចិត្តទុក តាំងព្យាយាមមាំ ដើម្បីញ៉ាំងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយ ឱ្យឋិតថេរ មិនឱ្យវិនាស ឱ្យចម្រើនធំទូលាយ ពេញបរិបូរណ៍ ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាវាយាមៈ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេច ហៅថា **សម្មាសតិ** ?

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានការព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោក ពិចារណាឃើញនូវវេទនាក្នុងវេទនាទាំងឡាយ ជា

ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ។ បេ ។ ក្នុងចិត្ត ។ បេ ។ ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតីជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាសតិ** ។

ម្នាលភិក្ខុទាំងឡាយ ចុះដូចម្តេចហៅថា **សម្មាសមាធិ** ?

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសល ក៏ចូលកាន់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ និង វិចារៈ មានបីតិ និង សុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ លុះភិក្ខុចូលទៅជិតរម្ងាប់វិតក្កៈ និងវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈាន ដែលកើតមានក្នុងសន្តាន ជាទីផូរផង់ មានសភាពជាចិត្តខ្ពស់ឯក គ្មានវិតក្កៈគ្មានវិចារៈ មានតែបីតិនិងសុខ ដែលកើតអំពីសមាធិ ។ បេ ។ ចូលកាន់តតិយជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ចូលកាន់ចតុត្ថជ្ឈាន មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ឥតទុក្ខ ឥតសុខ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរលត់ទៅនៃសោមនស្ស និង ទោមនស្សអំពីមុនផង ក៏សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **សម្មាសមាធិ** ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា **ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច** ។

ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយខាងក្នុង ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ខាងក្រៅ ជា

ប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើង ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការរលត់ទៅ ក្នុងធម៌ទាំងឡាយ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ពិចារណាឃើញនូវធម៌ គឺ ការកើតឡើង និងធម៌ គឺ ការរលត់ទៅ ក្នុងធម៌ទាំងឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ផង ដោយប្រការដូច្នេះឯង ។ម្យ៉ាងទៀត ស្មារតីជាគ្រឿងកំណត់នូវសច្ចៈ ៤ របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា ធម៌ទាំងឡាយមានមែន ក៏គ្រាន់តែជាទីកំណត់ ដើម្បីឱ្យចម្រើនប្រាជ្ញា ដើម្បីឱ្យចម្រើនស្មារតីប៉ុណ្ណោះ ។ ភិក្ខុមានចិត្តមិនអាស្រ័យនៅ ( ដោយតណ្ហា និង ទិដ្ឋិ ) ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញនូវធម៌ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ចទាំង ៤ ជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

## អដ្ឋកថា

កាលព្រះមានព្រះភាគ ទ្រង់ចែកធម្មានុបស្សនា ដោយពោជ្ឈង្គ ៧ ប្រការ យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់ចែកសច្ចៈ ៤ ប្រការ ទើបត្រាស់ថា **បុន ចបរំ** ន័យដទៃនៅមានទៀត ដូច្នេះ ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ដឹងច្បាស់តាមសេចក្តីពិតថា នេះទុក្ខជាដើម** មានន័យថា ដឹងច្បាស់តាមសភាវៈពិត នូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ

៣ , វៀរតណ្ហា , ថានេះជា **ទុក្ខ** , ដឹងច្បាស់តាមសភាវៈពិតនូវតណ្ហាដែលជាហេតុធ្វើទុក្ខនោះឱ្យកើតឡើង ឱ្យប្រាកដឡើងថា នេះជា **ទុក្ខសមុទយៈ** , ដឹងច្បាស់តាមសភាវៈពិតនូវការរលត់ គឺ កម្ចាត់នូវទុក្ខនិងទុក្ខសមុទយៈទាំង ២ ថានេះជា **ទុក្ខនិរោធ** , ដឹងច្បាស់តាមសេចក្ដីពិតនូវអរិយមគ្គ ដែលជាហេតុកំណត់ដឹងទុក្ខ ជាហេតុលះបង់សមុទយៈ ជាហេតុធ្វើឱ្យជាក់ច្បាស់និរោធថា នេះជា **ទុក្ខនិរោធគាមិនីបដិបទា** ។

វិសុទ្ធិមគ្គៈ ក្នុងពាក្យថា **ទុក្ខំ** នេះ ស័ព្ទថា **ទុ** សំដៅយកក្នុងអត្ថ គឺ គួរស្អប់ បានដល់ អាក្រក់ ពិតហើយ ជនទាំងឡាយ រមែងហៅបុត្តដែលគួរស្អប់ថា **ទុបុត្ត** , ចំណែក ស័ព្ទថា **ខំ** កាន់យកក្នុងអត្ថ គឺ សូន្យ , ពិតហើយ ទីទទេ គឺ អាកាស គេក៏ហៅថា **ខំ** ។

**ឯសច្ចៈទី ១** នេះ គឺ គួរស្អប់ ព្រោះជាទីតាំងនៃវត្ថុថោកទាប មានឧបទ្ទវៈជាដើមដ៏ច្រើន ចាត់ថា សូន្យ ព្រោះវៀរចាកភាពឋិតថេរ ភាពស្អាត សេចក្ដីសុខ និង ភាពជាអត្តា ដែលជនពាលប្រកាន់ហើយ ព្រោះហេតុនោះ ទើបហៅថា **ទុក្ខ** ព្រោះគួរស្អប់ និង ព្រោះជារបស់សូន្យ ។

ចំណែក ( ទុក្ខសមុទយៈ ) ស័ព្ទថា **សំ** សំដៅដល់ការប្រកបចូលគ្នា , ដូចក្នុងពាក្យថា **សមាគម សមេត** - ប្រជុំគ្នាជាដើម , ស័ព្ទថា **ឧ** សំដៅដល់ការកើត ដូចក្នុងពាក្យថា **ឧប្បន្ន ឧទិត** - កើតឡើង ឧទ័យឡើង , ស័ព្ទថា **អយ** សំដៅដល់ ហេតុ ។

**ឯសច្ចៈទី ២** នេះ កាលប្រកបគ្នាជាមួយបច្ច័យដ៏សេស ក៏ជាហេតុកើតឡើងនៃទុក្ខ ព្រោះហេតុនោះ ទើបហៅថា **ទុក្ខសមុទយ** ព្រោះបើ ( បច្ច័យ )

ប្រកបគ្នាហើយ ក៏ជាហេតុឱ្យកើតទុក្ខ ។

**ឯសច្ចៈទី ៣** ( ទុក្ខនិរោធ ) ព្រោះហេតុដែល **និ** ស័ព្ទ សំដៅដល់ការមិនមាន , និង **រោធ** ស័ព្ទ សំដៅដល់ **គុក** ហេតុនោះ ការមិនមានទីឃុំឃាំងដែលហៅថា គុកសង្សារ , ក្នុងសច្ចៈនេះ ទើបហៅថា **ទុក្ខនិរោធ** ព្រោះថាប្រាសចាកគតិទាំងពួង ឬថា កាលសច្ចៈនេះ បើព្រះយោគាវចរបានសម្រេចហើយ ក៏មិនមានទីឃុំឃាំងនូវទុក្ខ ដែលហៅថា គុកសង្សារ ព្រោះសច្ចៈនេះជាបដិបក្ខនឹងទុក្ខនោះ ហេតុនេះ ជាប្រការ ១ ដែលហៅថា **ទុក្ខនិរោធ** , ឬមិនដូច្នោះ ដែលហៅថា **ទុក្ខនិរោធ** ព្រោះជាបច្ច័យនៃការរលត់ គឺ ការមិនកើតឡើងនៃទុក្ខ ( **អនុប្បាទនិរោធ** ការរលត់ គឺ ការមិនកើតឡើង ) ។

**ឯសច្ចៈទី ៤** ( ទុក្ខនិរោធគាមិនីបដិបទា ) ហៅថា **ទុក្ខនិរោធគាមិនី-បដិបទា** ហេតុដែលសច្ចៈនេះ ហៅថា ដំណើរទៅកាន់ទុក្ខនិរោធ ព្រោះជាធម៌មានមុខឆ្ពោះទៅកាន់ទុក្ខនិរោធនោះ និង មានទុក្ខនិរោធនោះ ជាអារម្មណ៍ព្រមទាំងជាបដិបទានៃការសម្រេចទុក្ខនិរោធនោះផងដែរ ។

សច្ចៈទាំងឡាយនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅថា **អរិយសច្ច** ព្រោះជាធម៌ដែលព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់សម្រេចហើយ ដូចបាលីថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ចមាន ៤ , អរិយសច្ច ៤ គឺ អ្វីខ្លះ ។ ល ។ នេះឯងអរិយសច្ច ៤ ព្រះអរិយៈទាំងឡាយ រមែងសម្រេចនូវសច្ចៈទាំងឡាយនេះ ហេតុនោះ សច្ចៈទាំងឡាយនេះ ទើបឈ្មោះថា **អរិយសច្ច** ។

ន័យម្យ៉ាងទៀត ហៅថា **អរិយសច្ច** ព្រោះជាសច្ចៈរបស់ព្រះអរិយៈក៏បាន ដូចបាលីថា តថាគតជាព្រះអរិយៈក្នុងលោក ព្រមទាំងទេវលោក ។ ល ។

ក្នុងពពួកសត្វទាំងសមណៈ ព្រាហ្មណ៍ ទាំងដែលជាទេវតា និង មនុស្ស ព្រោះហេតុនោះ សច្ចៈទាំងឡាយនេះ ទើបហៅថា **អរិយសច្ច** ។

ន័យម្យ៉ាងទៀត ហៅថា **អរិយសច្ច** ព្រោះការបានសម្រេចជាព្រះអរិយៈ ក៏ដោយសារការបានត្រាស់ដឹងសច្ចៈទាំងឡាយនោះក៏បាន ដូចបាលីថា ម្នាលភិក្ខុទាំងឡាយ ព្រោះការបានត្រាស់ដឹងអរិយសច្ចទាំង ៤ តាមសេចក្ដីពិត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទើបបានព្រះនាមថា ព្រះអរិយៈ ។

ម្យ៉ាងទៀត **សោត** ហៅថា អរិយសច្ច ព្រោះជាសច្ចៈបែបអរិយៈ ក៏បាន , ពាក្យថា **អរិយ** មានន័យថា ពិត មិនមុសា ដូចបាលីថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ ជារបស់ពិត មិនមែនជារបស់មុសា ព្រោះហេតុនោះ សច្ចៈទាំងឡាយនេះ ទើបហៅថា **អរិយសច្ច** ។

## លក្ខណៈនៃសច្ចៈទាំង ៤

សួរថា វិនិច្ឆ័យដោយលក្ខណៈ តើដូចម្ដេច ? ឆ្លើយថា ក្នុងសច្ចៈ ៤ នេះ គឺ :

**១ - ទុក្ខសច្ច** មានការបៀតបៀន ជាលក្ខណៈ , មានការធ្វើឱ្យក្ដៅក្រហាយ ជាកិច្ច , មានបវត្តិ ( ការប្រព្រឹត្តទៅ មិនឈប់ ) ជាអាការប្រាកដ ។

**២ - សមុទយសច្ច** មានភាពជាហេតុឱ្យកើត ជាលក្ខណៈ , មានការធ្វើមិនឱ្យដាច់ខ្សែ ជាកិច្ច , មានការហួងហែង ជាអាការប្រាកដ ។

**៣ - និរោធសច្ច** មានការស្ងប់ ជាលក្ខណៈ , មានការមិនប្រែប្រួល ជាកិច្ច , មានការមិនមាននិមិត្ត ( គ្រឿងសម្គាល់នៃទុក្ខ ) ជាអាការប្រាកដ ។

**៤ - មគ្គសច្ច** មានការនាំចេញ ( ចាកគុកសង្សារ ) ជាលក្ខណៈ , មានការលះបង់កិលេស ជាកិច្ច , មានការចេញចាក ( និមិត្ត និង បវត្តិ ) ជាអាការប្រាកដ ។

ម្យ៉ាងទៀត **សច្ចៈ ៤** មាន **បវត្តិ** - ការប្រព្រឹត្តទៅ , **បវត្តន** - ហេតុឱ្យប្រព្រឹត្តទៅ , **និវត្តិ** - ការមិនប្រព្រឹត្តទៅ , **និវត្តន** - ហេតុមិនឱ្យប្រព្រឹត្តទៅ ជាលក្ខណៈ តាមលំដាប់ ។

ម្យ៉ាងទៀត មានភាពជាសង្ខតៈ , ជាសេចក្តីប្រាថ្នា , ជាអសង្ខតៈ , ជាការឃើញតាមសេចក្តីពិត ជាលក្ខណៈ តាមលំដាប់ ។

## អត្ថរបស់សច្ចៈ

ក្នុង ២ ប្រការ គឺ **អត្ថត្ថុទ្ធារតោ ចេវ** - ដោយ **អត្ថ** និងដោយ **អត្ថុទ្ធារ** នេះ គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដូចតទៅ :

បើមានពាក្យសួរថា **អ្វីជាអត្ថនៃសច្ចៈ** ដូច្នេះ ពាក្យឆ្លើយ គប្បីមានថា សភាវៈណា កាលព្រះយោគាវចរទាំងឡាយ ចូលទៅសម្លឹងមើល ដោយបញ្ញាចក្ខុ ក៏មិនជាសភាវៈដែលវិបរិត ( ខុសចាកការពិត ) ដោយកលមាយា មិនជាសភាវៈ ដែលបោកបញ្ឆោតដូចថ្ងៃបណ្តើរកូន និង មិនជាសភាវៈដែលនរណាៗ រកមិនបាន ដូចជាអត្តារបស់ពួកតិរ្ថិយ តែជាគោចរ ( គឺជាអារម្មណ៍ )

នៃអរិយញ្ញាណ ជាសភាវៈដែលពិត មិនវិបរិត និង ពិតដោយការបៀតបៀន ជាហេតុ ស្ងប់ និង នាំចេញ ជាសភាវៈដែលពិត មិនវិបរិត ដូចលក្ខណៈរបស់ភ្លើង និង ដូចប្រក្រតីរបស់លោក ( **ដីកា** : ប្រក្រតីរបស់លោក គឺ កើត ចាស់ ស្លាប់ ជាធម្មតា ) បណ្ឌិតគប្បីជ្រាបថា ជាអត្ថនៃសច្ចៈ ដូចព្រះបាលីថា **ម្នាលភិក្ខុទាំងឡាយ ពាក្យថា នេះទុក្ខ នោះជាពាក្យពិត នោះជាពាក្យមិនមុសា នោះជាពាក្យមិន ( ប្រែប្រួល ) ជាដទៃ** ដូច្នេះជាដើម សេចក្តីពិស្តារ បណ្ឌិតនាំមកពោលចុះ ។

ម្យ៉ាងទៀត ហេតុណា ទុក្ខមិនបៀតបៀនមិនមាន វត្ថុដទៃក្រៅពីទុក្ខអាចបៀតបៀនមិនមាន ព្រោះហេតុនោះ **ទុក្ខនេះ** ទើបជាសច្ចៈ ព្រោះទៀងតែជាធម្មជាតិដែលបៀតបៀន ។

ហេតុណា វៀរតណ្ហាចេញ ទុក្ខកើតចាកហេតុដទៃមិនមាន តណ្ហាមិនមាន ទុក្ខក៏កើតមិនបាន ព្រោះហេតុនោះ **វិសត្តិកា** គឺ តណ្ហា ទើបជាសច្ចៈ ព្រោះទៀងតែជាហេតុនៃទុក្ខ ។

ហេតុណា សេចក្តីស្ងប់ដទៃពីព្រះនិព្វានមិនមាន និង **សន្ត** គឺ និព្វានមិនមាន សេចក្តីស្ងប់នោះក៏មិនមាន ព្រោះហេតុនោះ និព្វាន ទើបជាសច្ចៈ ព្រោះទៀងតែជាធម៌ស្ងប់ ។

ហេតុណា គ្រឿងនាំចេញក្រៅពីមគ្គមិនមាន បើនិយ្យានៈមិនមាន ធម៌ជាគ្រឿងនាំចេញនោះ ក៏មិនមាន ព្រោះហេតុនោះ **មគ្គនោះ** ទើបជាសច្ចៈ ព្រោះទៀងតែជាធម៌នាំចេញ ។

បណ្ឌិតទាំងឡាយ ពោលនូវសេចក្តីពិត សេចក្តីមិនឃ្លៀងឃ្លាត និង

សេចក្ដីពិត ក្នុងអរិយសច្ចទាំង ៤ មានទុក្ខ ជាដើម ផ្សេងពីគ្នាថា ជាអត្ថនៃ **សច្ច** ស័ព្ទ ដោយប្រការដូច្នេះឯង ។

វិនិច្ឆ័យក្នុង **អត្ថុទ្ធារ** តើដូចម្ដេច ក្នុងន័យនេះ **សច្ច** ស័ព្ទ សំដៅយកអត្ថ បានច្រើនយ៉ាង គឺ យ៉ាងណាខ្លះ ?

- **សច្ច** ស័ព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **សច្ចំ ភណេ ន កុជ្ឈេយ្យ** - បុគ្គលគប្បីនិយាយពាក្យពិត មិនគប្បីក្រោធជាដើម សំដៅយក **វាចាសច្ច** ។
- **សច្ច** ស័ព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **សច្ចេ ឋិតា សមណ-ព្រាហ្មណា វា** - សមណព្រាហ្មណ៍ទាំងឡាយ តាំងនៅក្នុងសច្ចៈជាដើម សំដៅយក **វិរតិសច្ច** ។
- **សច្ច** ស័ព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **កស្មា នុ សច្ចានិ វទន្តិ នានា បវាទិយាសេ កុសលាវទានា** - ហេតុអ្វី ម្ចាស់លទ្ធិទាំងឡាយសម្គាល់ថា ខ្លួនជាអ្នកមានវាទៈជាកុសល ( ត្រឹមត្រូវ ) ពោលនូវសច្ចៈច្រើនយ៉ាង ផ្សេងគ្នាជាដើម នេះសំដៅយក **ទិដ្ឋិសច្ច** ។
- **សច្ច** ស័ព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **ឯកំ ហិ សច្ចំ ន ទុតិយំ** - សច្ចៈមានតែ១ មិនមាន២ ជាដើម សំដៅយកនិព្វាន និង មគ្គដែលជា **បរមត្ថសច្ច** ។
- **សច្ច** ស័ព្ទ ក្នុងពាក្យទាំងឡាយ មានពាក្យថា **ចតុន្នំ សច្ចានំ កតី កុសលា** ក្នុងសច្ចៈ៤ សច្ចៈប៉ុន្មានជាកុសលជាដើម បានដល់ **អរិយសច្ច** ។

មហាដីកា : លោកអាចារ្យកាលនឹងសម្ដែងថា **សច្ច** ដែលលើកឡើងសម្ដែងដោយ **សច្ច** ស័ព្ទ តែម្យ៉ាង គឺ អរិយសច្ចនោះឯង មិនបានធ្វើពាក្យផ្សេងទុក ដោយ **អរិយ** ស័ព្ទ ទើបពោលថា **សច្ច** បានដល់ អរិយសច្ច ៤ ។ ពិតហើយ ការបំភ្លឺសេចក្ដីដែលស្មើគ្នា រមែងប្រើបានក្នុងភាពផ្សេងគ្នា ហើយអ្នកដែលត្រូវការភាពផ្សេងគ្នា គប្បីប្រកបសេចក្ដីផ្សេងគ្នាចុះ ។

ន័យម្យ៉ាងទៀត កាលបានពិចារណាអរិយសច្ចហើយ សូម្បីសច្ចៈក្រៅពីនេះ ក៏បានពិចារណាហើយដូចគ្នាដោយអត្ថដែរ ព្រោះដូច្នោះ លោកអាចារ្យសូម្បីលើកពាក្យថា **សច្ច** ឡើងមកហើយ ពោលថា បានដល់ **អរិយសច្ច ៤** ព្រោះធ្វើពាក្យអធិប្បាយថា **សច្ច** ជាភូមិរបស់វិបស្សនាផង និងថា **សច្ច** គឺ អរិយសច្ចនោះផង ។

អរិយសច្ច ឬ ការសម្ដែងអរិយសច្ច លោកហៅថា **សាសនក្កមោ** ប្រែថា លំដាប់នៃពាក្យប្រៀនប្រដៅ ពិតហើយ ពាក្យប្រៀនប្រដៅ គឺ ព្រះតម្រាស់របស់ព្រះមានព្រះភាគទាំងអស់ នឹងផុតទៅអំពីសច្ចៈមិនមាន ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការបង្ហាញនូវ ការកើត ការរលត់ និង ហេតុនៃការកើត ការរលត់ ២ នោះ ។

ព្រោះដូច្នោះ ពាក្យប្រៀនប្រដៅ ទើបឈានចុះកាន់សច្ចៈ ទាំងឡាយ , ម្យ៉ាងទៀត ពាក្យប្រៀនប្រដៅ ពោលគឺ សីល សមាធិ និង បញ្ញា រមែងឈានចុះកាន់សច្ចៈទាំងឡាយនេះ គឺ រមែងប្រព្រឹត្តទៅដោយអំណាចការធ្វើកិច្ច មានបរិញ្ញាកិច្ច ជាដើមឱ្យសម្រេច ព្រោះដូច្នោះ ទើបឈ្មោះថា **កម** ព្រោះអត្ថថា ជាទីឈានចុះ អ្វីឈានចុះ ? ពាក្យប្រៀនប្រដៅឈានចុះ ។ លំដាប់នៃពាក្យ

ប្រៀនប្រដៅ ឈ្មោះថា **សាសនក្កមោ** ព្រោះដូច្នោះ **សច្ចៈ** ដែលជាទីតាំងនៃការប្រព្រឹត្តទៅនៃពាក្យប្រៀនប្រដៅ ទើបហៅថា **សាសនក្កមោ** និង ការសម្តែងសច្ចៈនោះ ក៏ហៅដោយវោហារដែរ ។

បទថា **តថា** គឺ មានសភាវៈដូច្នោះ បានដល់ មានសភាវៈជាទុក្ខជាដើម ។ បទថា **អវិតថា** មានសេចក្តីថា មានសភាវៈមិនជាមុសា គឺ មានសភាវៈពិត ព្រោះមានភាវៈដែលបៀតបៀនជាដើម ។ បទថា **អនញ្ញថា** វៀរចាកអាការជាយ៉ាងដទៃ បានដល់ វៀរចាកអាការដែលមិនបៀតបៀនជាដើម ។

ភាពជាអារម្មណ៍ដែលមិនគួរប្រាថ្នា ព្រោះជាទុក្ខពិត និង មានទុក្ខពិតជានិមិត្ត ឈ្មោះថា **អត្ថ** គឺ ការបៀតបៀន ។

ភាវៈដែលត្រូវបច្ច័យប្រជុំតាក់តែង គឺ រួមគ្នាធ្វើ ឈ្មោះថា **អត្ថ** គឺ សង្ខតៈ ។

ការដុតរោល ព្រោះភាពជាទុក្ខពិត១ និង មានទុក្ខពិត១ នោះជានិមិត្ត ឬ ការប្រកបដោយកម្តៅ គឺ កិលេស ឈ្មោះថា **អត្ថ** គឺ ការដុតរោល ។

ភាពជាវត្ថុដែលត្រូវប្រែប្រួលទៅដោយហេតុ ២ ប្រការ គឺ ជរា និង មរណៈ ឈ្មោះថា **អត្ថ** គឺ ការប្រែប្រួល ។

ក្នុងអធិការនេះ អត្ថទាំង ៤ យ៉ាង មានភាពផ្សេងគ្នា យ៉ាងនេះ គឺ **អត្ថ** គឺ ការបៀតបៀន ជាអាការដែលធ្វើទុក្ខឱ្យប្រាកដច្បាស់ តាមសភាវៈនោះឯងអត្ថក្រៅពីនោះជាការធ្វើទុក្ខឱ្យប្រាកដច្បាស់ ក៏ធ្វើឱ្យប្រាកដនូវ សមុទយៈ មគ្គ និង និរោធ តាមលំដាប់ ។

សេចក្តីអន្ទះសាដែលផ្សាយទៅ ដោយអំណាចសេចក្តីត្រេកអរក្នុង

អារម្មណ៍នោះៗ គឺ ធ្វើឱ្យជាគំនរ បានដល់ ការសាងឡើងនូវទុក្ខ ឈ្មោះថា **អាយូហនំ** ប្រែថា ប្រមូល ព្រោះអត្ថថា ធ្វើអាការឱ្យផ្សាយទៅ ,ម្យ៉ាងវិញទៀត **ទុក្ខ** ឈ្មោះថា **អាយ** ព្រោះអត្ថថា មកពីសមុទយៈ , ការកើត គឺ ការប្រព្រឹត្តទៅនៃទុក្ខនោះ ឈ្មោះថា **អាយូហនំ** ប្រែថា ការកើតឡើងនៃទុក្ខ , នេះឯង ជាអាការដែលធ្វើសមុទយៈឱ្យប្រាកដច្បាស់ ដោយសភាវៈនោះឯង ។ ឈ្មោះថា **និទានំ** ព្រោះអត្ថថា បង្កឡើងនូវទុក្ខ អធិប្បាយថា ធ្វើទុក្ខឱ្យកើតឡើង ដូចធ្វើឱ្យព្រមទទួលថា " នេះ គឺ ទុក្ខនោះ " ។

អត្ថថា **និទាន** គឺ បង្កហេតុ នេះជាអាការធ្វើសមុទយៈឱ្យប្រាកដច្បាស់ ដោយការប្រកាសនូវទុក្ខ ។ ការចងទុកនូវ ទុក្ខ គឺ សង្សារ , ឈ្មោះថា **អត្ថ** គឺ ការចងទុក ។ ការហាមនូវការសម្រេចមគ្គ ឈ្មោះថា អត្ថថា រូបរឹត ។ អត្ថថា ចង និង រូបរឹត នេះឈ្មោះថា ជាអាការធ្វើសមុទយៈឱ្យប្រាកដច្បាស់ ក៏ធ្វើឱ្យប្រាកដច្បាស់នូវ និរោធ និង មគ្គ ។

ឈ្មោះថា **និស្សរណំ** ព្រោះអត្ថថា រលាស់ចេញចាកសត្វទាំងឡាយ , ម្យ៉ាងទៀត ព្រោះអត្ថថា ខ្លួនឯងនោះឯង រលាស់ចេញទៅ គឺ មិនជាប់ជំពាក់ក្នុងសង្ខារទាំងពួង ព្រោះជាធម៌ចេញចាកឧបធិទាំងពួង ។ នេះឯង ជាអាការធ្វើនិរោធឱ្យជាក់ច្បាស់ ដោយសភាវៈ , អត្ថថា **ស្ងប់** អត្ថថា **អសង្ខត** និង អត្ថថា **អមត** គឺ ការអស់ទៅនៃសមុទយៈ ការមិនមានបច្ច័យ សេចក្ដីមិនវិនាស ជាការធ្វើនិរោធឱ្យជាក់ច្បាស់ ក៏ធ្វើឱ្យប្រាកដនូវ សមុទយៈ មគ្គ និង ទុក្ខ ។

ការចេញទៅចាកសង្សារ ឈ្មោះថា **និយ្យានំ** ប្រែថា នាំចេញ។ អាការនេះ ជាអាការធ្វើមគ្គឱ្យប្រាកដច្បាស់ដោយសភាវៈ , ការសម្រេចព្រះនិព្វាន

នោះឯង ជានាទីនៃមគ្គ ជាហេតុនៃព្រះនិព្វាន ជាអត្ថដែលមានមគ្គជាហេតុ ដោយការចូលទៅកាត់សេចក្ដីកង្វល់ ។

ការឃើញនូវព្រះនិព្វាន ឬ ការឃើញនូវសច្ចៈ ៤ ជាអត្ថនៃការឃើញ ព្រោះនាទីនៃមគ្គមានបញ្ញាជាអធិបតី ។ ក្នុងបណ្ដាសម្បយុត្តធម៌ទាំងឡាយ ធម៌ គឺ មគ្គរមែងធ្វើភាពជាអធិបតី ក្នុងការឃើញសច្ចៈ ៤ និងក្នុងការចូលទៅស្ងប់រម្ងាប់ សេចក្ដីក្ដៅក្រហាយ គឺ ទុក្ខដែលកើតចាកកិលេស ព្រោះដូច្នោះ ការនោះ ទើបឈ្មោះថា ជាអត្ថ គឺ ភាពជាអធិបតីនៃមគ្គ ។ ន័យមួយទៀត ពោលដោយពិសេស ធម៌ គឺ មគ្គ ដែលជាអារម្មណាធិបតី មានដោយព្រះបាលីថា **មគ្គាធិបតិនោ** ប្រែថា ធម៌មានមគ្គជាអធិបតី ព្រោះដូច្នោះ អាការនៃធម៌ គឺ មគ្គនោះ ទើបឈ្មោះថា មានអត្ថ គឺ ភាពជាអធិបតី ។

អត្ថ គឺ ភាពជាហេតុ , អត្ថ គឺ ការឃើញ , អត្ថ គឺ ភាពជាអធិបតី ទាំងនេះ ជាអាការធ្វើមគ្គឱ្យប្រាកដច្បាស់ ក៏ឱ្យប្រាកដនូវ សមុទយៈ និរោធ និង ទុក្ខ ។ ភ្ជាប់សេចក្ដីព្រះ បាលីថា **ឯវមាទិ អាហ** ។ បទថា **អភិសមយដ្ឋោ** ប្រែថា អត្ថ គឺ ជាវត្ថុគប្បីត្រាស់ដឹង , ន័យមួយទៀត អត្ថ ជាវិស័យនៃការត្រាស់ដឹង ឈ្មោះថា **អភិសមយដ្ឋោ** ប្រែថា អត្ថជា វិស័យនៃការត្រាស់ដឹង ។ មួយទៀត អាការប្រព្រឹត្តទៅនៃការត្រាស់ដឹង ឈ្មោះថា **អភិសមយដ្ឋោ** ប្រែថា អត្ថ ជាអាការប្រព្រឹត្តទៅនៃការត្រាស់ដឹង ។ ក្នុងអធិការនេះ អត្ថ គឺ ការត្រាស់ដឹងនោះ បណ្ឌិតគប្បីឃើញថា លោកសម្ដែងដោយអត្ថ មានការបៀតបៀនជាដើម ដែលគប្បីត្រាស់ដឹង ។

វិគ្រោះ **ទុក្ខ** ថា **កុច្ឆិតំ ខំ ទុក្ខំ** ប្រែថា ភាពសោះសូន្យ គួរស្អប់ខ្ពើម

ឈ្មោះថា **ទុក្ខ** មានន័យថា ដែលបណ្ឌិតគប្បីតិះដៀល មិនមានសារៈ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **សមាគមោ សមេតំ** ដូច្នេះជាដើម លោកអាចារ្យពោលថា **សំយោគំ ទីបេតិ** លោកសម្ដែងសេចក្ដីប្រកបចូលគ្នា ព្រោះកាលប្រើ **អាគម** ស័ព្ទ និង **ឯត** ស័ព្ទ សុទ្ធៗ នឹងមិនបានន័យថា **សំយោគ** និង ព្រោះកាលប្រកប **សំ** ស័ព្ទ ចូល ទើបមានន័យ ព្រោះសម្រេចភាពជាធមី ២ ន័យ នៃពាក្យនោះ ដោយន័យដែលស្របតាម និង ន័យដែលជាពាក្យមានខ្លឹមសារដទៃ ។ សូម្បី ក្នុងពាក្យថា **ឧប្បន្នំ ឧទិតំ** ក៏មានន័យដូចគ្នា ។

**អយ** ស័ព្ទ ប្រើក្នុងអត្ថនៃ **គតិ** ស័ព្ទ សំដៅដល់ហេតុ ដូច **ហេតុ** ស័ព្ទ ។ ឈ្មោះថា **អយ** ព្រោះអត្ថថា កើត គឺ ប្រព្រឹត្តទៅ ដោយការញុំាងផលរបស់ខ្លួនឱ្យសម្រេច ។ មួយទៀត ឈ្មោះថា **អយ** ព្រោះអត្ថថា ជាដែនកើតនៃផល ព្រោះដូច្នោះ ហេតុដែលកើតឡើងក្នុងកាលមានការប្រកបគ្នា ឈ្មោះថា **សមុទយ** ។ ស័ព្ទ **ឧបសគ្គ** សូម្បីប្រកបបែកគ្នា ក្នុងបទថា **សមុទយោ** នេះ បណ្ឌិតគប្បីជ្រាបថា រមែងសម្ដែងអត្ថថា ប្រកប និង អត្ថថា កើតឡើងព្រមទាំងធាតុ ព្រោះជាកិរិយាវិសេស ។

ពាក្យថា **ឈ្មោះថា និរោធ ព្រោះអត្ថថា មិនមានគុកក្នុងសច្ចៈ** នេះ លោកអាចារ្យសម្ដែងដល់និព្វាន ជាធម្មជាតិសូន្យចាកទុក្ខ ។ កាលសម្រេចសច្ចៈនោះហើយ បុគ្គលដែលសម្រេចសច្ចៈនោះ ក៏មិនមានគុក ព្រោះបានសម្រេចការរលត់ដែលជាបដិបក្ខ នឹងការកើត ។ ក្នុងអត្ថនេះ មានការសង្ខេបបទថា **និរោធ** ព្រោះអត្ថថា ការមិនមានគុកក្នុងសច្ចៈនេះ ។

ក្នុងពាក្យថា ការមិនមានទុក្ខ ជារបស់បុគ្គល មិនមែនជារបស់និព្វាន

ឡើយ ។ **ការរលត់** គឺ ការមិនកើតឡើងនោះឯង ឈ្មោះថា **អនុប្បាទនិរោធ** ប្រែថា ការរលត់ គឺ ការមិនកើតឡើង បានដល់ ការមិនកើតឡើងក្នុងភពតទៅ តែមិនមែនជាភង្គៈ ព្រោះដូច្នោះ លោកអាចារ្យទើបហាម **និរោធ** ស័ព្ទ ដែលប្រាប់សេចក្តីថា **ភង្គៈ** កាន់យក **និរោធ** ស័ព្ទ ដែលប្រាប់ដល់ **អនុប្បាទ** ។ ក្នុងអត្ថនេះ បច្ច័យនៃនិរោធ ទ្រង់ហៅថា **និរោធ** ពោលដោយអាស្រ័យផលព្រោះហេតុ ព្រមទាំងបដិបទានៃការសម្រេចទុក្ខនិរោធរបស់បុគ្គលផង ។ សួរថា បដិបទានោះឯង ជាហេតុឱ្យសម្រេចទុក្ខនិរោធ ព្រោះដូច្នោះ ទើបមិនគួរពោលថា បដិបទានោះ ជាបដិបទានៃការសម្រេចទុក្ខនិរោធនោះ មិនមែនឬ ? ឆ្លើយថា មិនត្រូវ ព្រោះបដិបទានោះ ទ្រង់ពោលទុក ជាហេតុឱ្យសម្រេចនៃការសម្រេចរបស់បុគ្គល និងជាបដិបទានៃធម៌ ដែលជាហេតុឱ្យបុគ្គលនោះសម្រេច ។

សួម្បីការធ្វើឱ្យជាក់ច្បាស់ និងធម៌ដែលត្រូវធ្វើឱ្យជាក់ច្បាស់ មិនមានភាពជាយ៉ាងដទៃ ទ្រង់ទើបធ្វើនិទ្ទេសឱ្យមានការផ្សេងគ្នា ដោយការធ្វើឱ្យជាក់ច្បាស់របស់បុគ្គល និងធម៌ដែលត្រូវធ្វើឱ្យជាក់ច្បាស់។ ម្យ៉ាងទៀត ធម្មជាតិណាជាផលសម្រេចនៃការសម្រេចទុក្ខនិរោធ និង ជាតួសម្រេចទុក្ខនិរោធខ្លួនឯងផង បណ្ឌិតគប្បីជ្រាបសេចក្តីនៃធម្មជាតិនោះ ជាបដិបទានៃការសម្រេចទុក្ខនិ-រោធ ដែលជាការត្រាស់ដឹង ។

ក្នុងពាក្យថា **ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងចាក់ធ្លុះ** នេះលោកអាចារ្យពោលថា មានព្រះពុទ្ធជាម្ចាស់ជាដើម ដោយលើកយកវោហារ មានព្រះពុទ្ធជាម្ចាស់ជាដើម ដែលប្រើក្នុងកាលបានត្រាស់ដឹង

ទាំងក្នុងកាលមុនត្រាស់ដឹង ព្រោះជាឧបចារវោហារ ហៅលោកអ្នកដែលនឹងបានជាព្រះពុទ្ធ ដូចជាក្នុងអ្នកដែលកើតហើយ ដូចក្នុងពាក្យថា **អគមា រាជគហំ ពុទ្ធោ** ប្រែថា ព្រះពុទ្ធជាម្ចាស់ ស្តេចយាងមកកាន់ក្រុងរាជគ្រឹះ ។ ពិតហើយ ព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងចាក់ធ្លុះដោយមគ្គទាំង ៤ ។

ក្នុងពាក្យថា **តស្មា អរិយសច្ចានីតិ វុច្ចន្តិ** នេះ បណ្ឌិតគប្បីឃើញការលុបបទចុង ព្រោះបទដើមថា **អរិយបដិវិជ្ឈិតព្វានិ សច្ចានិ អរិយសច្ចានិ** ប្រែថា សច្ចៈទាំងឡាយ ដែលព្រះអរិយៈគប្បីចាក់ធ្លុះ ឈ្មោះថា **អរិយសច្ចានិ** ។ បទថា **តស្មា** ប្រែថា ព្រោះព្រះតថាគតជាព្រះអរិយៈ លោកទើបហៅថា **អរិយសច្ច** ព្រោះជាសច្ចៈរបស់ព្រះតថាគតនោះ ។ ពិតហើយ សច្ចៈទាំងឡាយនោះ ជារបស់ព្រះតថាគតនោះ ព្រោះជាសច្ចៈដែលព្រះតថាគត បានសម្រេចដោយព្រះអង្គឯង ព្រោះជាសច្ចៈដែលព្រះតថាគតបានប្រកាសហើយ ព្រោះហេតុនោះឯង ទើបបុគ្គលដទៃអាចសម្រេចបាន ។

ក្នុងបទថា **អរិយភាវសិទ្ធិតោបិ** នេះ ប្រែថា ព្រោះសម្រេចភាពជាអរិយៈនេះ បណ្ឌិតគប្បីឃើញការលុបបទចុង ដូចក្នុងបទមុនថា **អរិយសាធកានិ សច្ចានិ អរិយសច្ចានិ** ប្រែថា សច្ចៈទាំងឡាយ ដែលញុំាងភាពជាអរិយៈឱ្យសម្រេចឈ្មោះថា **អរិយសច្ចានិ** ។ ក្នុង ២ បទថា **អរិយានិ សច្ចានីតិបិ** នេះ ឈ្មោះថា **អរិយានិ** ព្រោះបុគ្គលគប្បីដល់ គឺ គប្បីសម្រេចតាមសេចក្តីពិត , ម្យ៉ាងទៀត ឈ្មោះថា **អរិយ** គប្បីយល់ថា ជាពាក្យដែលប្រើជាប់មាត់ ក្នុងសេចក្តីមិនវិបរិត គឺ ក្នុងសេចក្តីពិត ។

ក្នុងពាក្យថា **មានការបៀតបៀន ជាលក្ខណៈ** នេះ ភាពជាទុក្ខពិត និង ជានិមិត្តនៃទុក្ខពិត ៗ នោះគ្គី ការដែលត្រូវការកើតឡើង និង ការវិនាសទៅបៀតបៀនដោយចំពោះគ្គី ឈ្មោះថា ការបៀតបៀន ។ ការកើតឡើងនៃទុក្ខដ៏ច្រើនប្រការនោះឯង ដោយអំណាចនៃទុក្ខ មានជាតិជាដើម ក្នុងភពជាដើម និង ដោយអំណាចរោគ មានរោគភ្នែកជាដើម ឈ្មោះថា ធ្វើបុគ្គលឱ្យក្តៅក្រហាយ ការធ្វើឱ្យក្តៅក្រហាយនោះឯង ជាកិច្ច គឺជា រស នៃទុក្ខសច្ចនោះ ព្រោះហេតុនោះ ទុក្ខសច្ចនោះ ឈ្មោះថា មានការដុតរោល ជាកិច្ច ។

ទុក្ខសច្ច បណ្ឌិតរមែងកាន់យកបាន ដោយជាធម្មជាតិដែលប្រព្រឹត្តទៅក្នុងការកើត និងការរលត់ គឺ ក្នុងសង្សារវដ្ត និង វិមោក្ខ គឺ និព្វាន ព្រោះហេតុនោះ ទុក្ខសច្ចនោះ ទើបឈ្មោះថា មានការប្រព្រឹត្តទៅ ជាអាការប្រាកដ ។

**ទុក្ខ** ឈ្មោះថា មានហេតុឱ្យកើតឡើង ព្រោះអត្ថថា ទុក្ខរមែងកើតឡើង គឺ កើតចាកពីសមុទយៈ គឺ ទាក់ទងនឹងភពក្រោយ និងភពមុន ប្រព្រឹត្តទៅ ។ ការកើតឡើងរឿយៗ យ៉ាងនេះ គឺ កាលតណ្ហានុស័យ មិនទាន់ដកឡើង ទុក្ខក៏រមែងកើតឡើងរឿយ ៗ សូម្បីដូច្នោះ នេះឈ្មោះថា ការធ្វើមិនឱ្យដាច់ខ្សែ ។ ការរារាំងនូវការចេញចាកភព ឈ្មោះថា ការរួបរឹត ។

ភាពជាធម្មជាតិស្ងប់ចាកភពទាំងពួង ដោយភាវៈជាធម៌អស់ទៅនៃតណ្ហា ឈ្មោះថា សេចក្តីស្ងប់ ។ បទថា **អច្ចុតិរសំ** ប្រែថា មានការមិនចុតិជាសម្បត្តិ ឬ ប្រែថា មានការមិនឃ្លាតចាក ជាកិច្ចក៏បាន ។ ពាក្យថា **កិច្ច** គឺ លោកពោលទុក ជាពាក្យបរិយាយ និង ការមិនឃ្លាតចាកនៃនិរោធសច្ចនោះ គឺ ការមិនលះបង់សភាវៈ គប្បីឃើញថា ជាការមិនឃ្លាតចាក ។

និរោធសច្ចនោះ បណ្ឌិតគប្បីកាន់យកជាធម្មជាតិមិនមានរូបរាង ព្រោះជាធម្មជាតិសូន្យចាកនិមិត្ត គឺ ខន្ធ ៥ ព្រោះដូច្នោះ ទើបឈ្មោះថា **អនិមិត្ត-បច្ចុប្បដ្ឋានំ** ប្រែថា ជាធម្មជាតិមិនមាននិមិត្ត ជាអាការប្រាកដ ។

ភាវៈដែលជាឧបាយនាំចេញចាកគុក គឺ សង្សារវដ្ត ដោយការលះបង់អនុស័យដាច់ជាសមុច្ឆេទ ឈ្មោះថា **និយ្យានំ** ប្រែថា ការនាំចេញ ។ ការរលត់កិលេសទាំងពួង មិនឱ្យកើតឡើង ឈ្មោះថា **កិលេសប្បហាករណំ** ប្រែថា ការធ្វើការលះបង់នូវកិលេស ។ **មគ្គសច្ច** បណ្ឌិតគប្បីកាន់យកភាពជាធម្មជាតិ នាំចេញទៅនៃចិត្ត ចាកនិមិត្ត និង ចាកបវត្តិ ព្រោះដូច្នោះ **មគ្គសច្ច** ឈ្មោះថា **វុដ្ឋានប្បច្ចុប្បដ្ឋានំ** ប្រែថា មានការនាំចេញ ជាអាការប្រាកដ ។

លោកពោលថា **តថ** នោះ ជាភាពវិបរិត ដែលមានសភាវៈជាវត្ថុថា វត្ថុ របស់ដែលមិនមែនជាដុំមាសជាដើម រឺឯ ថ្ងៃបណ្តើរកូន មើលឃើញដូចទឹក តែកាលគេចូលទៅជិត ក៏ជារបស់សូន្យទទេ សូម្បីត្រឹមតែវត្ថុ គឺ ទីតាំងនៃថ្ងៃបណ្តើរកូននោះ ក៏មើលមិនឃើញ ព្រោះដូច្នោះ លោកទើបពោលដល់ថ្ងៃបណ្តើរកូនថា ជារបស់បញ្ឆោត ។ ភាវៈដែលផ្ទុយគ្នាពីថ្ងៃបណ្តើរកូន **តថ អត្ថា** ឈ្មោះថា ភាវៈដែលពិត មិនវិបរិត និង មានតាមសេចក្តីពិត ។

ពាក្យថា **នៃអរិយញ្ញាណ** គឺ នៃញាណដែលជាអរិយៈ បានដល់ ការកាន់យកសភាវៈដែលមានពិត , ដោយពាក្យនោះ គឺ កាន់យកដោយបច្ចវេក្ខ-ណញ្ញាណ ដូចនឹងបដិវេធញ្ញាណ ព្រោះបណ្ឌិតគប្បីឃើញនូវសច្ចៈទាំងនោះជាគោចរ និង ជាអារម្មណ៍ថា ជាធម្មជាតិដែលគប្បីចាក់ធ្លុះ ។ លក្ខណៈរបស់ភ្លើង គឺ ក្តៅ ។ ពិតហើយ លក្ខណៈរបស់ភ្លើងនោះ ទោះនៅក្នុងទីណា កាល

មានឈ្មោះដូចនឹងអុសជាដើមផ្សេងគ្នា ក៏មិនជាវត្ថុបញ្ឆោត មិនជាវត្ថុដែលវិបរិត ឬ មិនជាវត្ថុដែលមិនពិត ទោះបីនៅក្នុងកាលណាមួយឡើយ ។

ធម្មជាតិ មានការកើតជាដើម ដែលទ្រង់ត្រាស់ទុកដូច្នេះថា **សត្វទាំងឡាយមានការកើតជាធម្មតា មានជរាជាធម្មតា ឬ មានមរណៈជាធម្មតា** ដូច្នេះ ឈ្មោះថា ប្រក្រតីរបស់លោក ។ អាចារ្យទាំងឡាយពោលថា សត្វតិរច្ឆានពួកខ្លះ វែងទៅទទឹង , សត្វទាំងឡាយ មានមនុស្សជាដើម ខ្ពស់ទៅលើកាលបើចម្រើនបរិបូរណ៌ហើយ ក៏មិនធំតទៅទៀតទេ ឈ្មោះថា ប្រក្រតីរបស់លោក ។ ក្នុងបណ្ដាភាវៈដែលពិត មិនវិបរិត មានពិត ភាវៈក្រោយបំផុតជា **តថតា** ប្រែថា ជាភាវៈដែលពិត ។ ភាវៈដំបូងជា **អវិតថតា** ប្រែថា ការមិនពិត , ភាវៈកណ្ដាលជា **អនញ្ញថតា** ប្រែថា ភាពមិនជាដទៃ ព្រោះដូច្នោះ នេះជាភាពផ្សេងគ្នានៃពាក្យទាំងឡាយនេះ ។

មានពាក្យសួរសៀតចូលមកថា ព្រោះហេតុអ្វី លោកអាចារ្យពោលដល់វត្ថុដទៃក្រៅពីទុក្ខ អាចនឹងបៀតបៀន មិនមាន , សូម្បីតណ្ហាក៏ជាតួបៀតបៀនព្រោះជាហេតុនៃទុក្ខ ដូចជាជាតិដែរ មិនមែនឬ ? ឆ្លើយថា មិនមែនទេ ព្រោះតណ្ហាកាន់យកទុកក្នុងផ្នែកមួយ គឺ ជាដែនកើតនៃទុក្ខ ដែលជាតួបៀតបៀន ។ ការប្រព្រឹត្តទៅ និង ហេតុនៃការប្រព្រឹត្តទៅ គឺ លោកធ្វើឱ្យយល់ដោយការមិនច្រឡូកគ្នា ដោយអាការយ៉ាងនេះ ។ម្យ៉ាងទៀត ភាពជាទីតាំងនៃទុក្ខ ដូចជាជាតិជាដើម និងជាទុក្ខពិត ដោយការបៀតបៀន មិនមែនជាដែនកើតនៃទុក្ខ ព្រោះដូច្នោះ កាលតណ្ហា ត្រូវកាន់យកក្នុងផ្នែកមួយ ព្រោះជាដែនកើត ក៏មិនទាក់ទងនឹងការបៀតបៀនទេ ។

ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **វត្ថុដែលបៀតបៀនក្រៅអំពីទុក្ខ មិនមាន** ។ បទថា **ពាធកត្តនិយាមេន** មានន័យថា ដោយការហាមនូវធម្មជាតិដែលបៀតបៀន ដោយអាការទាំង ២ យ៉ាង គឺ ទុក្ខដែលជាតួបៀតបៀន , មានតែទុក្ខប៉ុណ្ណោះដែលជាតួបៀតបៀន ។ បទថា **ពាធកត្ត-និយាមេន** ប្រែថា តាមសេចក្តីពិតនៃទុក្ខដែលជាតួបៀតបៀន និង ដោយភាពប្រាកដប្រជាក្នុងការដែលទុក្ខ ជាតួបៀតបៀន ។ ទុក្ខជាធម្មជាតិដែលកំណត់ពិតប្រាកដ ក្នុងភាពជាធម្មជាតិបៀតបៀន ដូចគ្នានឹងភាពជាធម្មជាតិដែលបៀតបៀន ជាធម្មជាតិដែលទៀងតែជាទុក្ខ ។

ពាក្យថា **វៀរតណ្ហានោះ ទុក្ខកើតពីធម្មជាតិដទៃ មិនមាន** មានន័យថា សូម្បីកិលេសដ៏សេស អកុសលធម៌ និង កុសលមូលដែលមានអាសវៈដ៏សេស កុសលធម៌ដែលមានអាសវៈដ៏សេស ជាហេតុនៃទុក្ខ មានហើយ វៀរចាកតណ្ហាចេញ ធម្មជាតិទាំងឡាយនោះ នឹងជាហេតុនៃទុក្ខមិនបាន តែបើវៀរចាកធម៌ទាំងឡាយនោះ តណ្ហាជាហេតុនៃទុក្ខ ក៏សម្រេចបាន ព្រោះវៀរចាកកុសល វៀរចាកអកុសល វៀរចាកកុសល មានរូបាវចរជាដើម និង វៀរចាកធម៌ដែលជាកាមាវចរជាដើម តណ្ហាក៏នៅញុំាងទុក្ខឱ្យកើតឡើងបាន ។

ភាពពិតប្រាកដ នៃធម្មជាតិដែលស្ងប់ ឬ ក្នុងភាពជាធម្មជាតិស្ងប់ ឈ្មោះថា ភាពពិតប្រាកដនៃធម្មជាតិស្ងប់ , ដោយការពិតប្រាកដថា ជាធម្មជាតិដែលស្ងប់នោះ ។ ពាក្យថា **ព្រោះជាធម៌នាំចេញយ៉ាងប្រាកដ** មានន័យថា មគ្គនេះជាធម៌នាំចេញ យ៉ាងពិតប្រាកដ ដោយភាពពិតប្រាកដ ២ ប្រការ មិនមែនមិនពិតព្រោះការវិបរិត ដូចជាផ្លូវខុស ឬ មិនមែនមិនពិត ព្រោះមិនបានជា

ធម្មជាតិដែលប្រព្រឹត្តទៅ ដូចជាផ្លូវនៃលោកិយនោះទេ ព្រោះដូច្នោះឯង ធម៌ដែលជាគ្រឿងនាំចេញ យ៉ាងពិតប្រាកដនោះ បានដល់ **មគ្គ** , ភាវៈនៃមគ្គនោះ ឈ្មោះថា ធម្មជាតិជាគ្រឿងនាំចេញ យ៉ាងពិតប្រាកដ ព្រោះជាធម្មជាតិនាំចេញតាមសេចក្តីពិតនោះឯង ។ ក្នុងសច្ចៈគ្រប់ប្រការ លោកពោលថា ជាធម្មជាតិពិត មិនវិបល្លាស ជាសេចក្តីពិត ដោយកំណត់ទាំង ២ ប្រការ ព្រោះដូច្នោះ លោកអាចារ្យ ទើបពោលថា **ព្រោះពិត មិនវិបល្លាស** ដោយប្រការដូច្នេះ ។

ការលើកឡើងនូវសេចក្តីដែលមាន នៃ **សច្ច** ស័ព្ទ ឬ ការពោលនូវខ្លឹមសារដែលមានឡើង គឺ អធិប្បាយសេចក្តីដែលបំណងចេញទៅ ឈ្មោះថា **អត្ថុទ្ធារោ** ប្រែថា ការលើកខ្លឹមសារឡើង ឬ ការអធិប្បាយសេចក្តី ។ ពាក្យថា **ក្នុងវិរតិសច្ចៈ** បានដល់ ក្នុងការវៀរចាកការពោលកុហក ។ ព្រោះថា **សច្ច** ស័ព្ទ ជាពាក្យជាប់មាត់ក្នុងវិរតិដទៃ មិនមាន ។ រីឯអាចារ្យទាំងឡាយណា ពោលថា **វិរតិសច្ចៈ** បានដល់ **សមាទានវិរតិ** , វិរតិសច្ចៈនៃលោកអាចារ្យទាំងឡាយនោះ ប្រើត្រឹមតែសមាទានមិនបានឡើយ ការពិតជាសច្ចៈដែលសមាទានមិនឱ្យឃ្លៀងឃ្លាត ។

ម្យ៉ាងទៀត វិរតិសច្ចៈនោះ បានដល់ សច្ចៈតាមបដិញ្ញា ជាការវៀរចាកការពោលពាក្យកុហកនោះឯង ។

ទិដ្ឋិដែលប្រកាន់ថា **នេះប៉ុណ្ណោះពិត ដទៃមិនពិត** ឈ្មោះថា ទិដ្ឋិសច្ចៈ ព្រោះប្រព្រឹត្តទៅដោយការប្រកាន់ថា **ពិត** ។ **និព្វាន** ឈ្មោះថា **បរមត្ថសច្ចៈ** ព្រោះជាធម៌ដែលមិនមុសា ប្រការនេះ សមដូចព្រះតម្រាស់ថា **អមោសធម្មំ**

**និព្វានំ តំ អរិយា សច្ចតោ វិទូ** ប្រែថា និព្វានជាធម៌ដែលមិនមុសា ព្រះអរិយៈទាំងឡាយដឹងព្រះនិព្វាននោះ ថាជារបស់ពិត ។ ម្យ៉ាងទៀត ការដឹងច្បាស់ គឺការចាក់ធ្លុះនូវនិព្វាននោះ និង មគ្គដែលញ៉ាំងនិព្វាននោះឱ្យដល់ព្រម ជាហេតុនៃការមិនប្រកែកគ្នា ព្រោះដូច្នោះ និព្វាន និង មគ្គទាំង ២ ព្រះមានព្រះភាគត្រាស់ថាជា **សច្ចៈ** ដោយព្រះគាថានេះថា **ឯកំ ហិ សច្ចំ ន ទុតិយមត្ថិ យស្មឹ បជា នោ វិវទេ បជានំ** ប្រែថា សច្ចៈមានតែម្យ៉ាងប៉ុណ្ណោះ មិនមាន ២ យ៉ាងឡើយ ដែលបុគ្គលដឹងច្បាស់ មិនប្រកែកគ្នា ។

ដោយពាក្យថា បើមានសមណៈ ឬ ព្រាហ្មណ៍មក ពោលថា **នេះមិនមែនទុក្ខអរិយសច្ច នេះមិនមែនឋានៈដែលគប្បីមានបាន** នេះ ព្រះមានព្រះភាគត្រាស់ថា ទុក្ខ មានជាតិជាដើម ជារបស់ពិត មិនខុស ក្នុងប្រការដែលចាត់ថាជាទុក្ខអរិយសច្ច ព្រោះមានប្រការបៀតបៀន តែម្យ៉ាងប៉ុណ្ណោះ ។ ដោយពាក្យថា សមណៈ ឬ ព្រាហ្មណ៍ គប្បីមកពោលថា " **ទុក្ខអរិយសច្ចដទៃ គប្បីមាន នេះមិនមែនជាឋានៈដែលគប្បីមានបានឡើយ** " ព្រះមានព្រះភាគ សម្តែងថា ទុក្ខអរិយសច្ច ជារបស់មានពិតប្រាកដ ក្នុងកាលមានជាតិជាដើម ព្រោះជាតិជាដើម មិនមានក្នុងធម៌ដទៃ គឺ សមុទយៈ និរោធ មគ្គ ព្រោះចាត់ចូលក្នុងទុក្ខអរិយសច្ចប៉ុណ្ណោះ ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បើមានសមណៈ ឬ ព្រាហ្មណ៍ មកពោលថា យើងនឹងលើកយកទុក្ខអរិយសច្ចនេះចេញ ហើយបញ្ញត្តទុក្ខសច្ចប្រការទី ១ ផ្សេងវិញ នេះក៏មិនមែនឋានៈដែលគប្បីមានបានឡើយ , កាលទ្រង់សម្តែងថា បើនរណាមានការគិតយ៉ាងនេះ ក៏ជាអ្នកមិនអាចក្នុងការបញ្ញត្តិ

គឺ ឱ្យគេរួមទទួល គឺ ឱ្យទទួលនូវវាទៈរបស់ខ្លួន មិនបានឡើយ ។

ការដែលធម៌ មានជាតិជាដើម មិនជាយ៉ាងដទៃ និង អរិយសច្ចប្រការដទៃ នឹងជាយ៉ាងនោះ ក៏មិនបាន ( ប្រការដែលថា នឹងបញ្ញត្តអរិយសច្ចប្រការទី ១ ក្រៅពីទុក្ខអរិយសច្ចនេះ ) គឺ ប្រព្រឹត្តទៅមិនបានឡើយ ។ ខ្លឹមសារក្នុងព្រះសូត្រប្រការនេះថា បើប្រាថ្នានឹងមកពោល ចូរពោលមកចុះ , ក៏មិនមានឋានៈដែលនឹងមានបាន ។ សូម្បីក្នុងសូត្រទី ២ ក៏មានន័យនេះដូចគ្នា ។ ក្នុងសូត្រទី ២ នោះ មានអធិប្បាយថា កាលសត្វទាំងឡាយ បានដល់ ធម៌ មានជាតិជាដើម និងការមានព្រមចំពោះមុខ រមែងមានដោយការបានអត្តភាពនោះឯង ព្រោះដូច្នោះ គប្បីឃើញថា ការដល់ព្រម និងការប្រចក្ស ជាអរិយសច្ចប្រការទី ១ ព្រោះអរិយសច្ចនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងជាប្រការដំបូង , ភាពជាហេតុនៃធម៌ មានជាតិជាដើម ជាអរិយសច្ចប្រការទី ២ , ការចូលទៅស្ងប់ធម៌ មានជាតិជាដើមនោះ ជាអរិយសច្ចប្រការទី ៣ , ធម៌ដែលធ្វើឱ្យដល់នូវសេចក្តីស្ងប់ធម៌ មានជាតិជាដើម ជាអរិយសច្ចប្រការ ទី ៤ ។

ដោយបទថា **ឯតបរមតោ** ដែលប្រែថា មានប្រការនេះ ដ៏ប្រសើរ លោកអាចារ្យពោលដល់ការកំណត់យកដោយមិនមានចំណែកសល់ នៃបវត្តិជាដើម ដោយអរិយសច្ចទាំង ៤ ។ ព្រះមានព្រះភាគ ត្រាស់នូវអរិយសច្ចទុក ៤ ប្រការប៉ុណ្ណោះ ព្រោះកិច្ចផ្សេងក្រៅពីកិច្ច មានការកំណត់ដឹងជាដើម ដែលបុគ្គលអ្នកប្រាថ្នានូវព្រះនិព្វាន គប្បីធ្វើ មិនមាន ។ម្យ៉ាងទៀត កិច្ច គឺ ការដឹងធម៌ យ៉ាងដទៃក្រៅពីកិច្ច មានការកំណត់ដឹងជាដើម ក៏មិនមាន និង អរិយសច្ចមានទុក្ខដែលគប្បីកំណត់ដឹងជាដើម ក៏មានកិច្ច គឺ ការកំណត់ដឹងជាដើមនេះ

ដ៏យ៉ាងក្រៃលែងនោះឯង ។ លោកអាចារ្យពោលថា ព្រោះវត្ថុនៃតណ្ហាជាដើម មានប្រការនេះដ៏យ៉ាងក្រៃលែង ដោយអំណាចនៃបុគ្គលដែលឃើញទោសរបស់តណ្ហា។ ម្យ៉ាងទៀត លោកអាចារ្យពោលថា ព្រោះសេចក្តីអាល័យជាដើម មានប្រការនេះ ដ៏យ៉ាងក្រៃលែង ដោយអំណាចនៃបុគ្គលអ្នកឃើញទោស ក្នុងសេចក្តីអាល័យ គឺ ក្នុងទុក្ខ ពោលគឺ កាមគុណ ៥ និង វត្ថុកាមទាំងអស់ ឬ ពោលគឺ វត្ថុកាមភពទាំង ៣ ។

ពាក្យថា **ព្រោះជារបស់គ្រោតគ្រាត** នេះ លោកអាចារ្យពោលសំដៅយកត្រឹមតែភារៈនៃធម៌ មានជាតិជាដើម ជាទុក្ខ ជាវត្ថុដែលប្រាកដដល់ពួកជនជាច្រើន មិនបានពោលសំដៅដល់អារម្មណ៍ដែលព្រះអរិយៈ គប្បីចាក់ធ្លុះដោយញាណទេ ។ បទថា **តំ យោគ ទុក្ខំ** ប្រែថា ទុក្ខនោះ , ពាក្យថា **តណ្ហាមិនបានតាក់តែងឡើង** គឺ មិនបានធ្វើឱ្យកើតឡើង អធិប្បាយថា មិនបានមានហេតុដែលតណ្ហាធ្វើឱ្យសម្រេចហើយ ។ ពិតហើយ កាលហេតុសម្រេចហើយ ផលក៏សម្រេចផងដែរ ។ ដោយពាក្យថា **ទុក្ខដែលតណ្ហាមិនបានតាក់តែងឡើងក៏មិនមក** នេះលោកអាចារ្យបដិសេធអហេតុកវាទៈ ( លទ្ធិថា មិនមានហេតុ )។ ដោយពាក្យថា **មានឡើងព្រោះហេតុខាងក្រៅ មានព្រះឥស្សរៈបណ្តាលជាដើមក៏មិនមែន** នេះ លោកអាចារ្យបដិសេធវាទៈ គឺ លទ្ធិមានលទ្ធិបជាបតី ម្ចាស់ជាធំលើពួកសត្វ លទ្ធិបុរស លទ្ធិប្រក្រតី និង លទ្ធិកាលៈជាដើម ។ ពាក្យណាដែលគប្បីពោលក្នុងអធិការនេះ ពាក្យនោះ នឹងមានច្បាស់នៅខាងមុខ ។ ដោយពាក្យថា **ត្រូវទុក្ខព្រមទាំងហេតុ** នេះលោកអាចារ្យពោលបន្ថែមឡើងនូវសេចក្តីតក់ស្លុត ដែលកើតឡើងព្រោះឃើញទុក្ខ ។

ពិតហើយ ការតក់ស្លុតយ៉ាងខ្លាំងក្លា រមែងកើតឡើង ព្រោះបានស្តាប់នូវសេចក្តីទុក្ខ ដែលប្រកបទៅដោយហេតុថា ហេតុនេះ នៅមានជរាបណា ទុក្ខក៏នៅប្រព្រឹត្តទៅមិនដាច់ខ្សែជរាបនោះ ។ ពាក្យថា **ទ្រង់ត្រាស់និរោធដើម្បីញុំាងចិត្តឱ្យស្រឡះឡើងវិញ** មានន័យថា ព្រះមានព្រះភាគ ត្រាស់និរោធសច្ចដើម្បីញុំាងចិត្តឱ្យស្រឡះឡើងវិញ ដល់បុគ្គលដែលមានការតក់ស្លុតហើយ។ ពិតហើយ **និរោធកថា** ដែលព្រះមានព្រះភាគត្រាស់ហើយ ដល់បុគ្គលដែលមានទុក្ខក្នុងសង្សារវដ្ត នឿយណាយហើយ រមែងញុំាងចិត្តឱ្យស្រឡះឡើងវិញ ដ៏ក្រៃលែង ហួសប្រមាណ ។

ភ្ជាប់សេចក្តីព្រះបាលីថា **យេ តេ ជាតិអាទយោ ធម្មា ភគវតា វុត្តា** ប្រែថា ធម៌មានជាតិជាដើមនោះ ព្រះមានព្រះភាគ បានត្រាស់ទុកហើយ ។ មានពាក្យសួរថា ក្នុងធម៌ទាំងឡាយនេះ ហេតុអ្វីទ្រង់មិនកាន់យកព្យាធិផង ? ឆ្លើយថា ព្រោះព្យាធិនោះ ជាឯកន្តធម៌ គឺ មិនទៀងទាត់ ។ ពិតហើយ ព្យាធិនោះគ្រាខ្លះក៏មិនមាន និងសម្រាប់បុគ្គលខ្លះក៏មិនមាន ។ ដូចទ្រង់ត្រាស់ទុកថា **រោគ ៣ យ៉ាង មានមកហើយ សេចក្តីលំបាក ១ ការស្រេកឃ្លាន ១ ជរា ១ ។**

បុគ្គល មានព្រះពាកុលត្ថេរៈជាដើម មិនបានមានអាពាធនោះឡើយ , ប្រការមួយទៀត គប្បីឃើញថា ទ្រង់កាន់យកព្យាធិទុកក្នុងទីនេះដូចគ្នា ដោយស័ព្ទថា ទុក្ខ ។ ពិតហើយ ពោលដោយបរមត្ថ ទុក្ខផ្លូវកាយ មានការកម្រើកនៃធាតុជាបច្ច័យ ឈ្មោះថា ព្យាធិ ។ លោកអាចារ្យពោលថា ធម៌ ១២ យ៉ាង ព្រោះចាត់ឧបាទានក្ខន្ធ ៥ ជាផ្នែកមួយ ។ **តណ្ហា** សូម្បីលោកកាន់យកដោយរូបមួយ ព្រោះរួមជាក្រុមមួយ ព្រោះភាពជាកាមតណ្ហាស្មើគ្នា មិនបានទាក់ទង

ទៅដល់ប្រភេទនៃធម៌ដែលជាខាងក្នុងផ្សេងទៀត ថា **ទុក្ខសមុទយអរិយសច្ចនេ** លោកក៏ពោលចែកទុកជា ៣ យ៉ាង គឺ តណ្ហាដែលសហគតៈដោយសស្សតទិដ្ឋិ ១ , សហគតៈដោយឧច្ឆេទិដ្ឋិ និង ដែលវៀរចាកទិដ្ឋិ ១ , ជាការពេញចិត្តក្នុងកាមសុទ្ធ ១ ។

លោកអាចារ្យពោលថា ធម៌ ៨ យ៉ាង ដូច្នេះ ព្រោះធម៌ទាំងឡាយនោះសូម្បីពោលរួមទុកក្នុងមគ្គសច្ចថា **នេះឯងអរិយមគ្គមានអង្គ ៨** ក៏ចែកដោយសភាវៈ ។

# ទុក្ខអរិយសច្ច

## ជាតិទុក្ខ

ក្នុងបទភាជនៈ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ពាក្យថា **កតមា ច ភិក្ខវេ ជាតិ** ម្នាលភិក្ខុទាំងឡាយ ជាតិ ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ជាតិណាដែលតថាគតពោលយ៉ាងនេះថា សូម្បីជាតិក៏ជាទុក្ខ ជាតិនោះ ដូចម្តេច គប្បីជ្រាបអត្ថក្នុងបុច្ឆា ទាំងពួងដូចតទៅនេះ :

ពាក្យថា **នៃសត្វទាំងឡាយនោះៗ យ៉ាងណា** ជាពាក្យកំណត់រួមសត្វទាំងអស់ ដោយមិនមានការកំណត់ថា នៃសត្វឈ្មោះនេះ ។ សូម្បីពាក្យថា ក្នុងពួកសត្វនោះៗ នេះជាពាក្យកំណត់រួមយកសត្វទាំងអស់ ។ ការកើត ឈ្មោះថា ជាតិ ។ ពាក្យថា **ជាតិ** នេះ ជាឈ្មោះនៃខន្ធដែលកើតជាគ្រាដំបូង ព្រមទាំងការប្រែប្រួលទៅ ។ ពាក្យថា **សញ្ជាតិ** នេះ ជាវេវចនៈនៃ **ជាតិ** នោះឯង តែប្រកបដោយឧបសគ្គ ។ ការកើតនោះឯង ឈ្មោះថា **ឱក្កន្តិ** - ចុះកាន់ ដោយអត្ថថា ចុះកាន់ក្នុងអាការដែលចូលទៅតាមលំដាប់ , ឈ្មោះថា **អភិនិព្វត្តិ** - កើតប្រាកដ ដោយអត្ថថា កើតចំពោះ ពោលគឺ កើតទាំង ៤ យ៉ាង នេះឈ្មោះថា ពោលដោយសម្មតិ ។ ចំណែកព្រះបាលី **ខន្ធានំ បាតុភាវោ** ការប្រាកដនៃខន្ធទាំងឡាយ នេះពោលដោយបរមត្ថ ។ ការប្រាកដនៃខន្ធទាំងឡាយនោះឯងដែលចែកជា ខន្ធ១ ខន្ធ៤ និង ខន្ធ៥ ក្នុងបណ្តាពួកសត្វដែលមានខន្ធ ១ នោះឯង មិនមែនការប្រាកដនៃបុគ្គលនោះទេ ។ តែកាលការប្រាកដនៃខន្ធនោះៗមានហើយ ក៏សន្មតហៅថា បុគ្គលប្រាកដ ។ ពាក្យថា **អាយតនានំ បដិលាភោ**

ការបានអាយតនៈទាំងឡាយ មានន័យថា អាយតនៈទាំងឡាយប្រាកដហើយ ឈ្មោះថា បានមក នោះឈ្មោះថា ការបានមក ដែលពោលបានថា ការប្រាកដនៃអាយតនៈទាំងនោះ ។

( ចប់ អដ្ឋកថា )

វិសុទ្ធិមគ្គ : ចិត្តដួងដំបូងកើតឡើង វិញ្ញាណដួងដំបូងប្រាកដឡើងក្នុងផ្ទៃរបស់មាតាណា ជាតិនោះឯង អាស្រ័យចិត្តដួងដំបូងនោះ ទើបមាន ។

**ជាតិ** មានការកើតឡើងក្នុងភពនោះ ៗ ជាគ្រាដំបូង ជាលក្ខណៈ , មានការប្រគល់ឱ្យ ជាកិច្ច , មានការប្រាកដឡើងក្នុងភពនេះ បន្ទាប់ពីភពមុន ជាអាការប្រាកដ ឬ មានការវិចិត្រទៅដោយទុក្ខ ជាអាការប្រាកដ ។

បើមានពាក្យសួរថា **ហេតុអ្វីជាតិជាទុក្ខ** ដូច្នេះសោត គួរឆ្លើយថា ព្រោះជាវត្ថុនៃទុក្ខច្រើនប្រការ ពិតហើយ ទុក្ខជាច្រើនដូចជា ទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អបដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ ។

ក្នុងទុក្ខទាំងឡាយនោះ **ទុក្ខវេទនា** ទាំងផ្លូវកាយ និងផ្លូវចិត្ត ហៅថា **ទុក្ខទុក្ខ** ព្រោះជាទុក្ខទាំងដោយសភាវៈ ទាំងឈ្មោះ ។

**សុខវេទនា** ហៅថា **វិបរិណាមទុក្ខ** ព្រោះជាហេតុឱ្យកើតទុក្ខ ដោយការប្រែប្រួល ។

**ឧបេក្ខាវេទនា** និង**សង្ខារទាំងឡាយ** ដែលប្រព្រឹត្តទៅក្នុងភូមិ៣ដ៏សេស

ហៅថា **សង្ខារទុក្ខ** ព្រោះត្រូវការកើត និង ការវិនាសបៀតបៀន ។

**ការឈឺចាប់តាមផ្លូវកាយ** និង **ផ្លូវចិត្ត** មានឈឺត្រចៀក ឈឺធ្មេញ និង ការរោលរាលកើតពីរាគៈ ការមួហ្មងកើតពីទោសៈជាដើម ហៅថា **បដិច្ឆន្នទុក្ខ** ព្រោះត្រូវសួរទើបដឹង និង ព្រោះមិនប្រាកដការធ្វើ ។

**ការឈឺចាប់** មានទ្វត្តឹង្សកម្មករណ៍ ( ការដាក់អាជ្ញា ៣២ ប្រការ ) ជាដើម ជាសមុដ្ឋាន ហៅថា **អបដិច្ឆន្នទុក្ខ** ព្រោះ បើមិនសួរ ក៏ដឹង និងព្រោះ ការប្រាកដដោយការធ្វើ ។

វៀរទុក្ខទុក្ខចេញ **ទុក្ខដ៏សេស មានជាតិជាដើម** ដែលមកក្នុងវិភង្គនៃ ទុក្ខសច្ចទាំងអស់ ហៅថា **បរិយាយទុក្ខ** ព្រោះជាវត្ថុនៃទុក្ខនោះៗ ។

**ទុក្ខទុក្ខ** ហៅថា **និប្បរិយាយទុក្ខ** ។

មហាដីកា : ពាក្យថា **ក្នុងភព** មានន័យថា ការបន្តគ្នានៃធម៌ដែល កំណត់ដោយការកើតជាដំបូង និង ការដាក់ចុះនៃសង្ខារ ឈ្មោះថា **ភព** , ក្នុង ភពនោះ ។ ពិតហើយ **ភព** នោះ ហៅថា **ជាតិ** ព្រោះជាទីកើតឡើងនៃការ ចែកកំណើត និង គតិជាដើម , **និកាយ** ក៏ឈ្មោះថា **ជាតិ** ព្រោះជាទីកើត របស់ពួកសត្វ ដែលមានការប្រព្រឹត្តស្រដៀង ៗ គ្នា ។ ពាក្យថា **ក្នុងសង្ខត-លក្ខណៈ** បានដល់ ក្នុងការកើតឡើងយ៉ាងណាមួយ ។ ពិតហើយ **ការកើតឡើងនោះ** ក៏ឈ្មោះថា ជាតិ ព្រោះអត្ថថា ជាការកើត ។ ពាក្យថា **ក្នុងបដិសន្ធិ** បានដល់ ក្នុងខណៈនៃបដិសន្ធិចិត្ត ។ ក្នុងបទថា **សម្បត្តិជាតោ** នេះ លោក អាចារ្យពោលថា **ក្នុងការប្រសូត្រ** សំដៅដល់ន័យថា កើត ពោលគឺ ការចេញ

ចាកគភ៌មាតា សម្រេចដោយ **ជាតិ** ស័ព្ទ អធិប្បាយថា ក្នុងការកើតចំពោះមុខ ។ **ត្រកូល** ក៏ឈ្មោះថា **ជាតិ** ព្រោះអត្ថថា ជាហេតុកើតឡើងនៃឈ្មោះ មានឈ្មោះថា ក្សត្រិយ៍ជាដើម ។

ឈ្មោះថា **សេយ្យា** ព្រោះអត្ថថា ជាទីដេក , **គភ៌** ពោលគឺ ផ្ទៃរបស់មាតា ជាទីដេករបស់សត្វទាំងឡាយនេះ ព្រោះហេតុនោះ សត្វទាំងឡាយនេះទើបឈ្មោះថា **គព្ភសេយ្យកា** ប្រែថា មានគភ៌ជាទីដេក បានដល់ សត្វជំពូកអណ្ឌជៈ ពួកដែលកើតក្នុងស៊ុត និង ពួកដែលកើតក្នុងស្បូន ។ បទថា **ឥតរេសំ យោគ សំសេទជានំ** និង **ឱបបាតិកានំ** ប្រែថា សម្រាប់សត្វពួកសំសេទជៈ ចំពូកដែលកើតក្នុងក្អែល និងចំពូកឱបបាតិកៈដែលកើតឡើងភ្លាម ក្រៅពីនេះ ។ បទថា **អយម្បិ ច** មានន័យថា សូម្បីកថាដែលពោលទុកក្នុងលំដាប់ ថា **ក្នុងបដិសន្ធិខន្ធនោះឯង** ក្នុងកថាដែលពោលថា បន្ទាប់ពីបដិសន្ធិទៅ មិនត្រូវនិយាយដល់ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ការប្រាកដជាដំបូងនៃខន្ធទាំងឡាយនោះ ឈ្មោះថា ជាតិ** ។

**ជាតិណា** ដែលបុគ្គលកាន់យកហើយ ដោយការកើតឡើង ព្រោះហេតុនោះ ជាតិនោះ ឈ្មោះថា **ឧម្មុជ្ជនបច្ចុប្បដ្ឋានា** មានការកើតឡើង ជាអាការប្រាកដ ។

**ជាតិណា** ញ៉ាំងភាពជាធម្មជាតិ មានការវិចិត្រទៅដោយទុក្ខ ដែលមានវិភាគគប្បីពោលដល់ ឱ្យចូលទៅតាំងទុក្ខដោយចំពោះ ព្រោះហេតុនោះ **ជាតិនោះ** ឈ្មោះថា **ទុក្ខវិចិត្តតាបច្ចុប្បដ្ឋានា** ប្រែថា មានភាពជាធម្មជាតិវិចិត្រទៅដោយទុក្ខ ជាអាការប្រាកដ ។

អាចារ្យអ្នកចោទពោលថា ព្រោះហេតុអ្វី ? មានសេចក្ដីដូច្នេះ :

**ជាតិ** គឺ ការកើតក្នុងនរកដែលជាទុក្ខតែម្យ៉ាង ឬ ក្នុងទុគ្គតិទាំងឡាយដទៃទៀត ព្រោះមានបាបកម្មជាសមុដ្ឋាន សូមលើកទុកសិន តែជាតិ មានការកើតក្នុងសុគតិទាំងឡាយ ដែលមានកម្ម គប្បីញ៉ាំងសេចក្ដីសុខឱ្យប្រព្រឹត្តទៅជាសមុដ្ឋាន ជាទុក្ខបានដូចម្ដេច ? លោកអាចារ្យផ្សេងទៀត កាលនឹងសម្ដែងថា ជាតិ មានការកើតនេះ លោកហៅថា ទុក្ខ ដោយអំណាចនៃសភាវទុក្ខ ក៏មិនបាន ព្រោះថា បដិសន្ធិណាៗ ដែលសម្បយុត្តដោយទុក្ខវេទនាក៏មិនមាន , ដោយពិត **ជាតិ** ឈ្មោះថា ជាទុក្ខ ព្រោះជាទីទទួលរងនូវទុក្ខ ទើបពោលពាក្យជាដើមថា **ជាតិ** ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំងឡាយច្រើនប្រការ ។ សភាវៈដែលជាទុក្ខ លោកអាចារ្យពោលឱ្យផ្សេងគ្នា ដោយ **ទុក្ខ** ស័ព្ទ ថា **ទុក្ខទុក្ខំ** ដែលប្រែថា ទុក្ខពិត ដូចពាក្យថា **រូបរូបំ** ដែលប្រែថា រូបដែលប្រែប្រួល ដូច្នេះ , ព្រោះ សូម្បីសភាវៈមិនមែនជាទុក្ខ លោកក៏ហៅថាជាទុក្ខ ដោយបរិយាយ ។

ពាក្យថា **ព្រោះជាហេតុកើតនៃទុក្ខ** បានដល់ ព្រោះជាហេតុកើតឡើងនៃទុក្ខតាមផ្លូវចិត្តថា មានដល់យើងប្រាកដហ្ន៎ ! ឬ វត្ថុនោះ មិនមែនទេឬហ្ន៎ ។

សង្ខារដែលអាចប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា សង្ខារទុក្ខ ព្រោះមានព្រះបាលីថា វត្ថុណាមិនទៀង វត្ថុនោះជាទុក្ខ លោកពោលនូវហេតុក្នុងសង្ខារទុក្ខនោះថា " ព្រោះត្រូវការកើតឡើង និង ការវិនាសទៅនោះ បៀតបៀន ដោយចំពោះរឿយ ៗ វត្ថុនោះ ក៏ឈ្មោះថា **ទុក្ខ** ព្រោះភាវៈ គឺ ការទ្រាំមិនបាន លោកប្រើស័ព្ទថា ប្រព្រឹត្តទៅក្នុងភូមិ ៣ ព្រោះបំណងយកការប្រព្រឹត្ត

នៃវិបស្សនា ។

លោកអាចារ្យពោលដល់ ទុក្ខ ទោមនស្ស និង ឧបាយាសៈថា **ទុក្ខទុក្ខ** , **ទុក្ខទុក្ខ** មកក្នុងវិភង្គនៃទុក្ខសច្ច ដោយន័យជាដើមថា **ជាតិបិ ទុក្ខា** សូម្បី **ជាតិ** ក៏ជាទុក្ខ ។

ពាក្យថា **សូម្បីព្រះមានព្រះភាគ** មានន័យថា សូម្បីព្រះមានព្រះភាគ ដែលទ្រង់មានព្រះអនាវរណញ្ញាណ ទ្រង់មានភាពជាអ្នកឆ្លាតក្នុងទេសនាដ៏អស្ចារ្យ និង រកប្រមាណមិនបាន ។ ពាក្យថា **ដោយអំណាចនៃឧបមា** គឺ ដោយអំណាចឧបមា មានឧបមាដោយគំនរភ្នក់ភ្លើងជាដើម ។

ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **បុណ្ឌរិកាទីសុ** គប្បីឃើញការរួមយកពាក្យទាំងឡាយ មានជាដើមយ៉ាងនេះថា មិនមែនកើតក្នុងទីសន្សំនៃរតនៈ មានកែវមណី មាស ប្រាក់ និង កែវប្រវាឡជាដើម , ទាំងមិនមែនកើតនៅលើទីដេកដ៏ស្អាត និង គួរជ្រើមចិត្តជាដើមថា ទីដេកធ្វើដោយស្លាបបក្សី រោមចៀម និង សំពត់ត្បាញជាដើម , ទាំងមិនមែនកើតនៅលើប្រាសាទ ដែលនាំមកនូវសេចក្តីត្រេកអរនៃចិត្ត ដែលទ្រាប់ដោយរតនៈ , ទាំងមិនកើតនៅត្រង់ទីឧបចារៈនៃប្រាសាទ ទីព្រោះទឹកដែលរាបស្មើ និង រោយដោយផ្កាឈើ ទាំងមិនមែនកើតក្នុងទីទួលាយល្អ ដែលដេរដាសទៅដោយគ្រាប់ខ្សាច់ ដែលដូចជាវិចិត្រទៅដោយកែវមុក្តា ទាំងមិនបានកើតនៅលើផែនដី ដែលរួមទុកទៅដោយស្បូវភ្លាំង ដែលទន់ល្មើយ ដូចសំពត់កម្ពល់ខៀវ ។

ពាក្យថា **ចង្អៀតក្រៃលែង** គឺ សែនចង្អៀត ។ ពាក្យថា **ងងឹតឈឹង** គឺ ងងឹតស្លប់ ។ ចង្អៀតទៅដោយរបស់មិនស្អាតផ្សេង ៗ មានប្រមាត់ ស្លេស្ម ខ្ទុះ

ឈាម លាមក និង អាហារថ្មីជាដើម ។ បើមាតាមានអាយុ ២០ ឆ្នាំ ឬ ៣០ ឆ្នាំ ៤០ ឆ្នាំ ជាដើម ក្នុងផ្ទៃគូរខ្ទើម ឈ្មោះថា គូរខ្ទើមដ៏ពន្លឹក ព្រោះដូចជាបង្គន់ដែលមិនបានជម្រះអស់កាលដ៏យូរហើយ មានប្រមាណប៉ុណ្ណោះ ។ ពាក្យទាំងអស់ មានពាក្យថា ត្រីស្អុយជាដើម មិនមែនជាពាក្យប្រៀបធៀបដូចគ្នាទេ ព្រោះពាក្យថា ត្រីស្អុយជាដើមនោះ គង់នឹងមានការប្រាសចាកខ្លិនស្អុយបានខ្លះដោយអំណាចនៃខ្យល់ជាដើម ។ បទថា **ទសមាសេ** ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគ , ពាក្យនោះ លោកពោលដោយចំណែកច្រើន ព្រោះនៅមានបុគ្គលពួកខ្លះ នៅក្នុងគភ៌នោះ បានជាង ១០ ខែ កាលខ្លួនដាក់ដៃទាំង ២ ក្តោបមុខ អង្គុយរាងជំទើតនោះឯង សត្វនេះ ក៏ឈ្មោះថា វៀរចាកអាការមានបត់ចូល និង លាចេញជាដើម ។

ការកន្ត្រាក់មកខាងមុខ ឈ្មោះថា **អាកឌ្ឍនំ** ប្រែថា ការទាញកន្ត្រាក់។ ការកន្ត្រាក់ទៅជុំវិញ គឺ ដោយជុំវិញ ឈ្មោះថា **បរិកឌ្ឍនំ** ប្រែថា ការបម្រាស់។ ការកន្ត្រាក់ចុះក្រោម ឈ្មោះថា **ឱធូននំ** ប្រែថា ការអុក ។ ការកន្ត្រាក់សន្ធឹងហើយ សន្ធឹងទៀត ឈ្មោះថា **និទ្ធូននំ** ប្រែថា ការច្រាន ។ ការធ្វើដែលដូចគ្នានឹងការទាញកន្ត្រាក់ជាដើម លោកក៏ហៅថា ការទាញកន្ត្រាក់ ក្នុងទីនេះ ។

សរីរៈដែលនៅក្នុងគភ៌ ទន់ខ្ចីក្រៃលែង ដូចដំបៅរលួយ រមែងទ្រាំមិនបាន សូម្បីរងាជាដើម ទោះជាមានប្រមាណបន្តិចបន្តួច ដូច្នោះ លោកទើបសម្តែងឧទាហរណ៍ មានភាពជាអ្នកឧប្បត្តិក្នុងនរកត្រជាក់ជាដើម ។ ពិតហើយ ភាពត្រជាក់ជាដើម រមែងប្រាកដនូវភាពត្រជាក់ដ៏ក្រៃលែងដល់សត្វនោះ និងការប្រាកដដ៏ក្តៅក្រៃលែង ។ ការដាក់ទោសដោយការស្តោះសរីរៈ ដោយកាំបិត

ជាដើម ហើយស្រោចដោយទឹកក្រុត ឈ្មោះថា **ការដាក់ទោស** គឺ ច្រៀករាងកាយហើយ ស្រោចដោយទឹកក្រុត ។ ពាក្យថា **ក្នុងទីដែលកើតទុក្ខ** លោកពោលសំដៅដល់ចំណែកទី ៣ ដែលដឹងគ្នាថា ស្បូន ។ ពាក្យថា **ផាត់ត្រឡប់** បានដល់ ការផាត់ត្រឡប់យកជើងឡើងលើ យកសីសៈចុះក្រោម ។ ទុក្ខស្មើតែនឹងស្លាប់ ដែលជាហេតុឱ្យសត្វទាំងឡាយអន្ទះអន្ទែង ដល់នូវវេទនា ទូញយំអស់កាលវេលាបច្ចុប្បន្ន សូម្បីកន្លងទៅ ២ - ៣ ខែ ក៏មាន ដូចជាការស្ទុះទៅកាន់ផ្លូវលំបាកដ៏ធំ ដែលងងឹតឈឹង នេះឈ្មោះថា ទុក្ខមានការប្រសូត្រ ជាមូល ។ ពាក្យថា **ប្រទូស្ត** បានដល់ បៀតបៀនដោយការសោយសោក ទូញយំជាដើម ។ ឈ្មោះថា **អាតាបន** ការធ្វើឱ្យក្តៅរោលរាល ដោយសេចក្តីស្រេកឃ្លាន និង ដោយការឈរហាលថ្ងៃជាដើម ។ ឈ្មោះថា **បរិតាបន** ការដុតកិលេសដោយជុំវិញ ដោយការធ្វើខ្លួនឱ្យក្តៅដោយភ្លើង ៥ កង ជាដើម ។

បទថា **ឥមស្ស** មានន័យថា ទាំង ៧ យ៉ាង តាមដែលពោលហើយ ។ បទថា **សព្វស្សាបិ** ប្រែថា ទាំងអស់ ដែលឱ្យកើតហើយដោយការច្របាច់ និងការរឹតជាដើម ក្នុងពេលនៅក្នុងគភ៌ជាដើម និង ដោយការដុតដោយភ្លើងនរកជាដើម ។ ឈ្មោះថា ជាទីតាំងតែមួយ ព្រោះបើជាតិនោះមិនមាន សេចក្តីទុក្ខក៏មិនមាន ។ ព្រោះហេតុនោះឯង លោកអាចារ្យ ទើបពោលពាក្យ មានជាអាទិ៍ថា " **បើសត្វមិនកើតនៅក្នុងនរកសោត** " ដូច្នេះ ។

បទថា **វិចិត្រ** ប្រែថា មានប្រភេទផ្សេង ៗ ឬថា គួរអស្ចារ្យ ។

( អធិប្បាយ **ជាតិ** ជាទុក្ខ ចប់ដោយប្រការដូច្នេះ )

# ជរាទុក្ខ

ស័ព្ទថា **ជរា** ជាស័ព្ទ សម្ដែងដល់សភាពនៃខ្លួនឯង ។ ស័ព្ទថា **ជីរណតា** សម្ដែងដល់ភាវៈ គឺ អាការៈ ។ ស័ព្ទថា **ខណ្ឌិច្ចំ** ជាដើម គឺ សម្ដែងដល់ការប្រែប្រួល ពិតហើយ កាលនៅកំលោះក្រមុំ ធ្មេញក៏រៀបស្មើ ស កាលចាស់ធ្មេញទាំងឡាយនោះ ប្រែពណ៌ទៅជាលំដាប់ ជ្រុះទៅក្នុងទីនោះៗ ។ ម្យ៉ាងទៀត ធ្មេញបាក់ សំដៅដល់ធ្មេញដែលជ្រុះ និង បើមិនទាន់ជ្រុះ ហៅថា **ខណ្ឌិតា** ។ ភាវៈនៃធ្មេញបាក់ ហៅថា **ខណ្ឌិច្ចំ** គឺ ធ្មេញបាក់ ។ សក់ និង រោមចាស់គ្រាំគ្រាទៅជាលំដាប់ ហៅថា សក់ស្កូវ ។ ភាវៈនៃបុគ្គលដែលមានសក់ស្កូវ ឈ្មោះថា **បាលិច្ចំ** គឺ សក់ស្កូវ ។ ភាពជ្រីវជ្រួញនៃស្បែករបស់បុគ្គលនោះមានហើយ ព្រោះមានសាច់ និង ឈាមហួតហែង ដោយត្រូវខ្យល់ គឺ ជរាប្រហារ ព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា មានស្បែកជ្រីវជ្រួញ ។ ភាវៈនៃបុគ្គលដែលមានស្បែកជ្រីវជ្រួញនោះ ឈ្មោះថា **វលិត្តចតា** គឺ ស្បែកជ្រីវជ្រួញ ។ ដោយពាក្យមានប្រមាណត្រឹមប៉ុណ្ណេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់ជរាដែលជាក់ស្ដែង ប្រាកដច្បាស់ ដោយការសម្ដែងដល់ ការប្រែប្រួលទៅនៃ ធ្មេញ សក់ រោម ស្បែក , ផ្លូវទៅនៃ ខ្យល់ ឬ ភ្លើង នឹងប្រាកដបាន ក៏ព្រោះខ្យល់បក់ត្រូវស្មៅ ឬ ដើមឈើជាដើម បាក់រាត់រាយ ឬ ឆេះព្រៃ តែផ្លូវទៅរបស់ខ្យល់ និង ភ្លើងនោះក៏នៅតែមិនប្រាកដ យ៉ាងណា ផ្លូវទៅនៃជរាក៏ដូច្នោះ ដូចគ្នានឹងប្រាកដបានក៏ព្រោះ ធ្មេញបាក់ជាដើមនៃអាការ ៣២ មានធ្មេញជាដើម សូម្បីបុគ្គលបើកភ្នែកមើល ក៏ចាប់មិនបាន ការចាស់គ្រាំគ្រានៃអាការ មានធ្មេញបាក់ជាដើម ថាជាតួជរាមិនបាន ព្រោះជរាដឹងតាមចក្ខុទ្វារមិនបាន ។ តែ

ព្រោះ កាលដល់ជរាហើយ អាយុក៏អស់ទៅ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដោយផលជិតថា ការវិនាសទៅនៃអាយុ ហៅថា **ជរា** ។ម្យ៉ាងទៀត ព្រោះវេលាជាកំលោះ ក្រមុំ ឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមនៅស្រស់ថ្លាល្អ អាចទទួលអារម្មណ៍របស់ខ្លួន សូម្បីតូចឆ្មាបានដោយស្រួល ដល់ពេលជរា ក៏រសេមរសាមស្រអាប់ មិនស្រស់ថ្លា មិនអាចទទួលអារម្មណ៍របស់ខ្លួន សូម្បីអារម្មណ៍ដ៏ឱឡារិក ដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ដល់ផលជិតថា ការទន់ខ្សោយនៃឥន្ទ្រិយទាំងឡាយ ឈ្មោះថា **ជរា** ។

វិសុទ្ធិមគ្គ: សេចក្ដីថា **ជរាជាទុក្ខ** មានវិនិច្ឆ័យថា **ជរា** មាន **២** យ៉ាង គឺ :

**១- សង្ខតលក្ខណៈ** សំដៅយកខណិកជរា ។

**២- ការចាស់នៃខន្ធនៅក្នុងភពមួយ** ក្នុងសន្តតិ ដែលដឹងដោយអាការមានធ្មេញបាក់ជាដើម ។

**ជរា** ( ដែលប្រាកដ ) គឺ ការចាស់នៃខន្ធនោះ សំដៅយកក្នុងទីនេះ ។

**ជរា** មានការចាស់នៃខន្ធ ជាលក្ខណៈ , មានការនាំចូលទៅរកសេចក្ដីស្លាប់ ជាកិច្ច , មានការវិនាសទៅនៃវ័យក្មេង ជាអាការប្រាកដ , ឈ្មោះថា **ជាទុក្ខ** ព្រោះជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃសេចក្ដីទុក្ខ , ពិតហើយ ទុក្ខដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្តមានបច្ច័យជាច្រើន ដូចជាការទន់ខ្សោយនៃអវយវៈតូចធំ ភាពពិការនៃឥន្ទ្រិយ ការមានរូបរាងវិកល ភាពជាយុវវ័យវិនាសទៅ សេចក្ដីព្យាយាមខ្សោយទៅ សតិ និងមតិប្រាសទៅ អ្នកដទៃមើលងាយជាដើមកើតឡើង ជរាជាទីតាំងនៃទុក្ខនោះ ព្រោះហេតុនោះ អ្នក

ប្រាជ្ញទើបពោលថា :

មច្ចុ: ( សត្វដែលត្រូវស្លាប់ ) បានទទួលទុក្ខផ្លូវកាយ និងផ្លូវចិត្ត ព្រោះការទ្រុឌទ្រោមទៅនៃអង្គាវយវ: ព្រោះភាពពិការទៅនៃឥន្ទ្រិយទាំងឡាយ និងព្រោះការវិនាសទៅនៃយុវវ័យ ព្រោះការខ្សោយទៅនៃកម្លាំង ព្រោះការប្រាសទៅនៃសតិជាដើម កូនប្រពន្ធរបស់ខ្លួនឯង ក៏ស្អប់ខ្ពើម ព្រោះមានតែការដល់នូវការទន់ខ្សោយទៅ ព្រោះហេតុដែលទុក្ខនោះ មានជរាជាហេតុ ព្រោះហេតុនោះ **ជរា** ទើបជាទុក្ខ ។

មហាដីកា : ពាក្យថា **សង្ខតលក្ខណ:** ពោលសំដៅដល់ជរាគ្រប់ខណ: ទ្រង់ត្រាស់ទុកថា **វត្ថុដែលតាំងនៅហើយ ក៏ប្រែប្រួលទៅជាយ៉ាងដទៃ**។ ពាក្យថា **ដែលដឹងថា ធ្មេញបាក់ សក់ស្កូវជាដើម** គឺ ដែលដឹងដោយអាការ មានធ្មេញបាក់ សក់ស្កូវ និង ស្បែកជ្រីវជ្រួញជាដើម ។ បទថា **សា យោគខន្ធបុរាណភាវសញ្ញិតា បាកដជរា** ប្រែថា ជរាប្រាកដ ដែលដឹងថា ភាពចាស់នៃខន្ធនោះ ។ **ភាពទុំជោរនៃខន្ធ** បានដល់ ភាពចាស់នៃខន្ធដែលទាក់ទងនៅក្នុងភពមួយ ។

( អធិប្បាយ **ជរាទុក្ខ** ចប់ដោយប្រការដូច្នេះ )

## មរណទុក្ខ

សព្ទថា **យំ** សំដៅដល់ ជាសព្ទសម្តែង នបុំសកលិង្គ ( មិនមែនភេទប្រុស ភេទស្រី តាមវេយ្យាករណ៍ ) ។ ក្នុងពាក្យថា **យំ** នោះ គប្បីប្រកបសេចក្តីដូច្នេះថា **មរណៈ** ទ្រង់ហៅថា **ចុតិ** ហៅថា **ចវនតា** ។ ក្នុងសព្ទទាំងឡាយនោះ សព្ទ ថា **ចុតិ** សម្តែងដល់សភាពនៃខ្លួនឯង ។ សព្ទថា **ចវនតា** សម្តែងដល់ភាវៈ គឺ អាការ ។ កាលបុគ្គលដល់នូវមរណៈហើយ ខន្ធទាំងឡាយ រមែងបែកធ្លាយ និងវិនាសទៅ ក៏លែងឃើញ ព្រោះដូច្នោះ មរណៈនោះ ទើបហៅថា ការបែកធ្លាយ ការវិនាស ការលាចាកលោក ។ បទថា **មច្ចុមរណ** គឺ មច្ចុមរណៈ មិនមែនខណិកមរណៈទេ ។ ការធ្វើកាលៈ គឺ ស្លាប់ ឈ្មោះថា កាលកិរិយា ។ ទាំងអស់នេះ ពោលដោយសម្មតិទាំងអស់ ។ ចំណែកព្រះបាលីថា **ខន្ធានំ ភេទោ** នេះ ជាការពោលដោយបរមត្ថ ។ ការបែកធ្លាយនៃខន្ធទាំងឡាយដែលចែកជាខន្ធ ១ ខន្ធ ៤ និង ខន្ធ ៥ ក្នុងបណ្តាពួកសត្វដែលមានខន្ធ ១ ជាដើម នោះឯងមិនមែនជាការបែកធ្លាយនៃបុគ្គលទេ ។ តែកាលបើការប្រជុំព្រមនៃខន្ធ មានហើយ ក៏សម្មតិ ហៅថា បុគ្គលស្លាប់ ។ ការដាក់ចុះនូវអត្តភាព ឈ្មោះថា ការដាក់ចុះនូវសាកសព ។ ពិតហើយ កាលបុគ្គលដល់នូវសេចក្តីស្លាប់ អត្តភាពក៏ធ្លាក់ចុះ ដូចជាអង្កត់ឧស រកប្រយោជន៍គ្មាន ដូច្នោះ ។ ព្រោះដូច្នោះ មរណៈនោះ ទើបទ្រង់ហៅថា ការដាក់ចុះនូវសាកសព ។ ចំណែកការដាច់នៃជីវិតិន្ទ្រិយ ពោលដោយបរមត្ថដោយអាការទាំងពួង គឺ មរណៈ ។ មរណៈនោះឯង ហៅថា សម្មតិមរណៈ ។ ពពួកជនកាន់យកនូវការដាច់ទៅនៃជីវិតិន្ទ្រិយប៉ុណ្ណោះ ទើបនិយាយថា តិស្សៈស្លាប់ បុស្សៈស្លាប់ ដូច្នេះ ។

វិសុទ្ធិមគ្គ: ក្នុងសេចក្តីថា សូម្បីមរណៈក៏ជាទុក្ខ នេះ មរណៈមាន **២** យ៉ាង គឺ :

១ - **សង្ខតលក្ខណៈ** លោកសំដៅយក ជរាមរណៈ សង្គ្រោះដោយខន្ធ ២ ដូច្នេះ ១ ។

**២ - ការដាច់នៃការបន្តគ្នាទៅនៃជីវិតិន្ទ្រិយ ដែលទាក់ទងនៅក្នុងភពមួយ** ដែលព្រះមានព្រះភាគទ្រង់ត្រាស់សំដៅដល់ការភ័យខ្លាចស្លាប់ មានជានិច្ច ដូច្នេះ ១ ។

**មរណៈ** គឺ ការដាច់ជីវិតិន្ទ្រិយនោះ បំណងយកក្នុងទីនេះ សូម្បីពាក្យថា **ជាតិប្បច្ចយាមរណ** - សេចក្តីស្លាប់មាន ព្រោះជាតិជាបច្ច័យ , **ឧបក្កមមរណ** - សេចក្តីស្លាប់ព្រោះមានគេព្យាយាម , **សរសមរណ** - សេចក្តីស្លាប់ដោយខ្លួនឯង , **អាយុខយមរណ** - សេចក្តីស្លាប់ព្រោះអស់អាយុ , **បុញ្ញខយមរណ** - សេចក្តីស្លាប់ព្រោះអស់បុណ្យ ក៏ជាឈ្មោះរបស់ **មរណៈ** គឺ ការដាច់ជីវិតិន្ទ្រិយនោះដែរ ។

**មរណៈ** នោះ មានចុតិ គឺ ការឃ្លាតចាកបច្ចុប្បន្នភព ជាលក្ខណៈ , មានការព្រាត់ទៅ ចាកសត្វ និង សង្ខារដែលខ្លួនបានរក្សា ជាកិច្ច , មានការព្រាត់ចាកគតិដែលខ្លួនបានចូលដល់ហើយ ជាអាការប្រាកដ ។

រីឯ ( **មរណៈ** ) **ជាទុក្ខ** គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ ហេតុនោះអ្នកប្រាជ្ញ ទើបពោលពាក្យប្រព័ន្ធទុកថា :

ទុក្ខផ្លូវចិត្តកើតឡើង មិនខុសគ្នាដល់បុគ្គលដែលកំពុងស្លាប់ ដែលជាមនុស្សអាក្រក់ ឃើញនិមិត្ត មានកម្មនិមិត្តផ្នែកខាងបាបជាដើម សូម្បីជាបុគ្គល

ល្អ ( តែ )អត់ធន់ចំពោះការវិនាសនូវរបស់ជាទីស្រឡាញ់ មិនបាន , ម្យ៉ាងទៀត ទុក្ខផ្លូវកាយ មានសន្ធាក់ និង សរសៃត្រូវដាច់ជាដើម ប្រាកដឡើងដល់បុគ្គលដែលមានកម្មដ្ឋាន ត្រូវខ្យល់ចាក់ទម្លុះ ទុក្ខនេះជាទុក្ខដែលបុគ្គលទ្រាំមិនបាន កែខៃមិនបាន ព្រោះមរណៈនេះជាទីតាំងនៃទុក្ខ ព្រោះហេតុនោះ **មរណៈនេះ** ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **ជាទុក្ខពិត** ។

មហាដីកា : ពាក្យថា **សង្ខតលក្ខណៈ** លោកអាចារ្យពោលដល់សេចក្តីស្លាប់គ្រប់ខណៈ ដែលដឹងគ្នាថា ជាសេចក្តីវិនាសទៅរបស់សង្ខារ ។ បទថា **សន្ធាយ** មានន័យស្មើនឹង **យំ ខណិកមរណំ សន្ធាយ** ប្រែថា ទ្រង់សំដៅដល់សេចក្តីស្លាប់គ្រប់ខណៈណា , ក្នុងពាក្យថា " **ជរា និងមរណៈសង្គ្រោះដោយខន្ធ ២** " នេះ មានន័យថា លោកពោលថា **សេចក្តីស្លាប់** ។ បទថា **តំ យោគ ជីវិតិន្ទ្រិយុបច្ឆេទសញ្ញិតំ បាកដមរណំ** ប្រែថា សេចក្តីស្លាប់ប្រាកដដែលដឹងគ្នាថា ការដាច់នៃជីវិតិន្ទ្រិយ ។ ឈ្មោះថា **មានចុតិ ជាលក្ខណៈ** ព្រោះគប្បីកំណត់ថា " ជាការឃ្លាតចាក " ។ ពាក្យថា **មានការព្រាត់ទៅ ជាកិច្ច** គឺមានការព្រាត់ទៅចាកសត្វ និង សង្ខារដែលខ្លួនព្រាត់ទៅ ជាកិច្ច ។ មរណៈណា ដែលបុគ្គលរមែងកាន់យក ដោយការព្រាត់ចាកគតិ តាមដែលខ្លួនបានចូលដល់ហើយ ព្រោះហេតុនោះ មរណៈនោះ ឈ្មោះថា **មានការព្រាត់ទៅ** ចាកគតិ ជាអាការប្រាកដ ។

ពាក្យថា **ជាបុគ្គលអាក្រក់** គឺ ជាមនុស្សអាក្រក់ ដោយការប្រកបបាប អធិប្បាយថា បានសន្សំបាបកម្មទុក ។ ពាក្យថា **ឃើញនិមិត្ត មានកម្មនិមិត្តផ្នែកខាងបាបកម្មជាដើម** មានន័យថា ឃើញអារម្មណ៍ដែលជាអកុសលវិបាកប្រាកដ

ក្នុងវេលាជិតស្លាប់ ពោលគឺ កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ និង គតិនិមិត្ត-អារម្មណ៍ ផ្នែកមិនល្អ ។ ពិតហើយ ទុក្ខធំ រមែងមានដល់បុគ្គលខ្លះដែលឃើញអារម្មណ៍ ដែលជាអកុសលវិបាកនោះឯង ដូចកំពុងសោយ ។ ពាក្យថា **ដែលជាមនុស្សល្អ** គឺ ដែលមានកម្មល្អ , អធិប្បាយថា ដែលបានធ្វើកុសលទុក ។ អារម្មណ៍ដែលគួរប្រាថ្នាយ៉ាងណាមួយ ប្រាកដដល់មនុស្សល្អនោះ ដោយពិតសូម្បីដូច្នោះ ក៏នៅតែជាទុក្ខធំ ដែលមានការប្រាសចាកសត្វ និង សង្ខារដែលជាទីស្រឡាញ់ជាទីតាំង ព្រោះដូច្នោះ លោកអាចារ្យទើបពោលថា ទ្រាំមិនបាននូវការព្រាត់ប្រាស ដែលមានរបស់ជាទីស្រឡាញ់ជាទីតាំង ។ ពាក្យថា **ដោយមិនផ្សេងគ្នា** បានដល់ ដោយការស្មើគ្នានៃមនុស្សអាក្រក់ និង មនុស្សល្អ ។ លោកអាចារ្យសូម្បីពោលថា ដោយមិនផ្សេងគ្នា ដូច្នេះហើយ ក៏នៅពោលថាដល់គ្រប់មនុស្ស ដើម្បីនឹងសម្តែងទុក្ខនោះ រមែងមានយ៉ាងប្រាកដ សូម្បីព្រះខីណាស្រពរូបខ្លះ ដែលញាំញីសង្ខារបានហើយ ។

( អធិប្បាយ **មរណៈជាទុក្ខ** ចប់ ដោយប្រការដូច្នេះ )

## សោកៈ

បទថា **ព្យសនេន - សេចក្តីវិបត្តិ** មានន័យថា ដោយសេចក្តីវិបត្តិយ៉ាងណាមួយ បណ្តាសេចក្តីវិបត្តិទាំងឡាយ មានសេចក្តីវិបត្តិចាកញាតិជាដើម ។ បទថា **ទុក្ខធម្មេន - ទុក្ខធម៌** មានន័យថា ហេតុនៃទុក្ខ មានការសម្លាប់ និង ការចាប់ចងជាដើម ។ បទថា **ផុដ្ឋស្ស - ពាល់ត្រូវហើយ** បានដល់ ខ្ទាំងខ្ទប់

ហើយ គ្របសង្កត់ហើយ ។ ពាក្យថា **សោក** បានដល់ សេចក្ដីសោកដែលមានការក្រៀមក្រំចិត្ត ជាលក្ខណៈ រមែងកើតឡើងដល់បុគ្គល ក្នុងកាលត្រូវសេចក្ដីវិបត្តិ មានការវិបត្តិញាតិជាដើម ឬ ហេតុនៃទុក្ខ មានការសម្លាប់ ការឃុំឃាំងជាដើម យ៉ាងណាមួយ គ្របសង្កត់ហើយ ។ ភាពជាអ្នកសោកសៅ បានដល់ សេចក្ដីសោកសៅ សេចក្ដីសោកសៅនោះ កើតឡើងធ្វើខាងក្នុងឱ្យក្រៀមក្រំ ឱ្យចំបែង ព្រោះដូច្នោះទើបហៅថា ការស្រងេះស្រងោចចិត្ត ការក្រៀមក្រំចិត្តខាងក្នុង ។

វិសុទ្ធិមគ្គៈ ក្នុងបកិណ្ណកទុក្ខ មានសោកៈជាដើម , សេចក្ដីរោលរាលចិត្តនៃបុគ្គលដែលត្រូវទុក្ខ មានការវិនាសញាតិជាដើមពាល់ត្រូវហើយ ឈ្មោះថា **សោក** សោកៈនោះ ដោយន័យ គឺ ទោមនស្សនោះឯង ក៏ពិត សូម្បីដូច្នោះ ( ក៏មានលក្ខណៈប្រចាំខ្លួន គឺ ) មានសេចក្ដីទុក្ខព្រួយខាងក្នុង ជាលក្ខណៈ , មានការធ្វើឱ្យក្រៀមក្រំចិត្តជាកិច្ច , មានកិរិយាសោយសោកជាអាការប្រាកដ។ រីឯ សោកៈជាទុក្ខគប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ ( តួទុក្ខ ) និងជាទីតាំងនៃទុក្ខផង ព្រោះហេតុនោះ អ្នកប្រាជ្ញ ទើបពោលពាក្យប្រព័ន្ធនេះទុកថា :

សេចក្ដីសោក រមែងចាក់ទម្លុះចិត្តរបស់សត្វទាំងឡាយ ដូចទម្លុះដោយព្រួញដែលលាបដោយថ្នាំពិស និង ដុតរោលចិត្តដ៏ពន្លឹក ដូចលំពែងដែកដុតដ៏ក្ដៅទម្លាយចូលទៅ នឹងដល់នូវសេចក្ដីទុក្ខច្រើនប្រការ ដោយការឈឺចាប់ , ជរា និង មរណៈ ក៏មកផងដែរ ដោយហេតុណា ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា **ជាទុក្ខ** ។

មហាដីកា : បទថា **សោ យោគ សោកោ** ប្រែថា សេចក្តីសោកនោះ ដោយន័យ គឺជា ទោមនស្សនោះឯង ព្រោះមិនមានចេតសិកដទៃ ។ តែសេចក្តីផ្សេងគ្នានៃទោមនស្ស ក៏ឈ្មោះថា មានហើយ ព្រោះមានភាពផ្សេងគ្នានៃអាការដែលប្រព្រឹត្តទៅ ក្នុងការផ្សេងគ្នានៃអារម្មណ៍ ព្រោះដូច្នោះ លោកអាចារ្យ កាលបំណងនឹងសម្តែងភាពផ្សេងគ្នានោះ ដោយប្រការបកិណ្ណកៈមានលក្ខណៈជាដើម ទើបពោលពាក្យ មានជាអាទិថា សូម្បីដូច្នេះ ។ ភាពទុក្ខព្រួយខាងក្នុង បានដល់ ការក្តៅក្រហាយចិត្ត ។ ភាពក្រៀមក្រំ បានដល់ ការដុតរោលដោយការផ្សេងគ្នានៃការដុតរោល គឺ រាគៈ និង ទោសៈ ។

វិប្បដិសារី ដែលប្រព្រឹត្តទៅដោយអាការ គឺ ការក្តៅក្រហាយចិត្ត ជាខាងក្រោយ ចំពោះអារម្មណ៍ គឺ កុសល និង អកុសល ដែលធ្វើហើយ និង មិនទាន់បានធ្វើ ឈ្មោះថា កុក្កុច្ចៈ , ការសោកស្តាយ ដែលជាការដុតរោលចិត្ត តែម្យ៉ាង ដែលមានការវិនាសញាតិជាដើម ជាអារម្មណ៍ ឈ្មោះថា សោកៈ , កុក្កុច្ចៈ និងសោកៈទាំងឡាយនេះ មានភាពផ្សេងគ្នា សូម្បីក្នុងន័យថា មានការស្តាយក្រោយ ជាអាការប្រាកដ ដូចពោលមកដូច្នេះឯង ។

កូនសរដែលជ្រលក់ថ្នាំពិស ឈ្មោះថា កូនសរលាបដោយថ្នាំពិស ។ សូម្បីការឈឺចាប់ មានជំងឺរាគមូលជាដើម ក៏មានដោយអំណាចនៃសេចក្តីសោក , សរីរៈរបស់បុគ្គលដែលច្រើនដោយសេចក្តីសោក រមែងទ្រុឌទ្រោមទៅមិនយូរឡើយ បុគ្គលដែលត្រូវសេចក្តីសោកគ្របសង្កត់ហើយ រមែងស្លាប់បាន ព្រោះដូច្នោះ លោកអាចារ្យទើបពោលថា នាំមកនូវទុក្ខផ្សេង ៗ មានជំងឺជរា និង សេចក្តីស្លាប់មកផង ។

( អធិប្បាយ **សោកៈជាទុក្ខ** ចប់ដោយប្រការដូច្នេះ )

## បរិទេវៈ

មនុស្សទាំងឡាយ ប្រកាន់យ៉ាងនេះថា កូនស្រីរបស់យើង កូនប្រុសរបស់យើង ដូច្នេះ រមែងយំរៀបរាប់ ដោយការប្រកាន់នោះ ព្រោះហេតុនោះ ការប្រកាន់នោះ ទើបឈ្មោះថា ជាហេតុនៃការយំរៀបរាប់។ មនុស្សទាំងឡាយ យំរៀបរាប់ដល់គុណនោះៗ ដោយហេតុនោះ ព្រោះដូច្នោះ ហេតុនោះ ទើបឈ្មោះថា ជាហេតុឱ្យយំរៀបរាប់ ។ ស័ព្ទទាំង ២ គឺ **អាទេវនា បរិទេវនា** ក្រៅពី **អាទេវនា បរិទេវនា** នោះជា ស័ព្ទសម្តែងដល់ភាវៈនៃការយំរៀបរាប់ ខ្សឹកខ្សួលនោះឯង ។

វិសុទ្ធិមគ្គ : ការយំរៀបរាប់នៃបុគ្គលដែលត្រូវសេចក្តីទុក្ខ មានការវិនាសញាតិជាដើម ពាល់ត្រូវ ឈ្មោះថា **បរិទេវ** , **បរិទេវៈនោះ** មានការយំរៀបរាប់ ជាលក្ខណៈ , មានការប្រកាសនូវសេចក្តីវិនាស ជាកិច្ច , មានការយំនៀល ជាអាការប្រាកដ , រីឯ បរិទេវៈនោះជាទុក្ខ គប្បីជ្រាបថា ព្រោះជាសង្ខារទុក្ខ និង ជាទីតាំងនៃទុក្ខផងដែរ ព្រោះហេតុនោះ អ្នកប្រាជ្ញពោលពាក្យប្រព័ន្ធថា :

បុគ្គលដែលត្រូវសរ គឺ សេចក្តីសោកប្រហារហើយ មកយំរៀបរាប់ រមែងទទួលនូវសេចក្តីទុក្ខកាន់តែខ្លាំងឡើង ដែលជាទុក្ខកើតពីការខ្សឹកខ្សួល ស្ងួតក បបូរមាត់ និង ពិតានមាត់ ហួសពីការទ្រាំ ដោយហេតុណា ហេតុនោះ

ព្រះមានព្រះភាគ ទើបត្រាស់ថា **បរិទេវៈជាទុក្ខ** ។ នេះជាវិនិច្ឆ័យក្នុង បរិទេវៈ ។

**មហាដីកា :** បទថា **វចីបលាបោ** ប្រែថា ការរៀបរាប់តាមផ្លូវវាចា ការរៀបរាប់តាមផ្លូវវាចានោះ ដោយអត្ថ គឺ សំឡេងនោះឯង ។ ពាក្យថា **ក្រៃលែងឡើង** គឺ ក្រៃលែងជាងសេចក្ដីទុក្ខ គឺ សោកៈ ។ ព្រោះ **បរិទេវៈ** មានសេចក្ដីសោកជាសមុដ្ឋាន ។

( អធិប្បាយ **បរិទេវៈជាទុក្ខ** ចប់ដោយប្រការដូច្នេះ )

# ទុក្ខទុក្ខ

សេចក្ដីទុក្ខដែលមានកាយបសាទជាទីតាំង ព្រោះអត្ថថា ទ្រាំបានដោយលំបាក ឈ្មោះថា **ទុក្ខផ្លូវកាយ** ។ ពាក្យថា **មិនស្រួលចិត្ត** គឺ មិនសុខចិត្ត ។ ពាក្យថា **ទុក្ខដែលកើតពីកាយសម្ផស្ស** គឺ ទុក្ខដែលកើតពីសម្ផស្សផ្លូវកាយ ។

វិសុទ្ធិមគ្គ: សេចក្ដីទុក្ខប្រព្រឹត្តទៅក្នុងកាយ ឈ្មោះថា ទុក្ខ , **ទុក្ខនោះ** មានការបៀតបៀនកាយ ជាលក្ខណៈ , មានការធ្វើឱ្យថ្នាំងថ្នាក់ចិត្តដល់បុគ្គលដែលគ្មានបញ្ញាទាំងឡាយជាកិច្ច , មានការឈឺចាប់ផ្លូវកាយ ជាអាការប្រាកដ , រីឯ ទុក្ខ ជាទុក្ខនោះ គប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ ព្រោះជាតួទុក្ខ និងជាហេតុនាំមកនូវសេចក្ដីទុក្ខផ្លូវចិត្ត ព្រោះហេតុនោះ អ្នកប្រាជ្ញ ទើបពោលពាក្យប្រព័ន្ធថា :

ទុក្ខផ្លូវកាយនេះ រមែងបៀតបៀននូវកាយ ធ្វើឱ្យកើតសេចក្តីទុក្ខតាមផ្លូវចិត្តផង ដោយហេតុណា ព្រោះហេតុនោះ ទុក្ខផ្លូវកាយនេះ ព្រះមានព្រះភាគ ទើបត្រាស់ថា **ជាទុក្ខ** ។

មហាដីកា: ធម៌ទាំងឡាយ មានជាតិជាដើម សូម្បីជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ និងជាសេចក្តីទុក្ខពិតៗ តាមគួរ , ទុក្ខផ្លូវកាយនេះ ក៏ឈ្មោះថា ទុក្ខមានភាពពិសេសទាក់ទងនឹងការបៀតបៀនកាយ ព្រោះដូច្នោះ លោកអាចារ្យទើបពោលថា ព្រះមានព្រះភាគត្រាស់ថា ជាទុក្ខយ៉ាងពិសេស ។

( អធិប្បាយ **ទុក្ខទុក្ខ** ចប់ដោយប្រការដូច្នេះ )

## ទោមនស្ស

ពាក្យថា **វេទនាដែលមិនសុខតាមផ្លូវចិត្ត** គឺ វេទនាដែលមិនសប្បាយចិត្ត។ ទោមនស្សសម្បយុត្តជាមួយចិត្ត ឈ្មោះថា ចេតសិក បានដល់ ទោមនស្សផ្លូវចិត្ត ។ ពាក្យដ៏សេស មានន័យដូចពោលហើយក្នុងទុក្ខនោះឯង ។

វិសុទ្ធិមគ្គ : សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ឈ្មោះថា **ទោមនស្ស** , ទោមនស្សនោះ មានការបៀតបៀនចិត្ត ជាលក្ខណៈ , មានការធ្វើឱ្យចង្អៀតចង្អល់ចិត្ត ជាកិច្ច , មានការឈឺផ្សាតាមផ្លូវចិត្ត ជាអាការប្រាកដ , រីឯទោមនស្សជាទុក្ខ គប្បីជ្រាបថា ព្រោះជាទុក្ខទុក្ខ និង ព្រោះនាំឱ្យកើតទុក្ខតាមផ្លូវកាយ , ពិតហើយ បុគ្គលទាំងឡាយដែលពេញដោយសេចក្តីទុក្ខតាមផ្លូវចិត្ត

ហើយ រមែងសោយទុក្ខ មានប្រការផ្សេងៗ ដូចជា វិលាយសក់យំ គក់ទ្រូង ននៀលខ្លួនទៅមក បោកកាយ លើកជើង ចាប់សស្ត្រា ( ប្រហារខ្លួនឯង ) លេបថ្នាំពិស ចងកដោយខ្សែ លោតចូលភ្លើង ព្រោះហេតុនោះ អ្នកប្រាជ្ញទើប ពោលពាក្យប្រព័ន្ធថា :

ទោមនស្ស រមែងបៀតបៀនចិត្ត និងនាំឱ្យមានការលំបាកតាមផ្លូវកាយ ដោយហេតុណា ព្រោះហេតុនោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់បានធ្វាយ ចាកពីទោមនស្ស ទើបទ្រង់ត្រាស់ថា **ទោមនស្សជាទុក្ខ** ។

មហាដីកា: ពាក្យថា **មានការធ្វើឱ្យចង្អៀតចង្អល់ចិត្ត ជាកិច្ច** គឺ មាន ការពិឃាតចិត្តដែលប្រកបដោយព្យាបាទ ជាកិច្ច ។ ពាក្យថា **បុគ្គលទាំងឡាយ ដែលពេញទៅដោយទុក្ខផ្លូវចិត្ត** គឺ អ្នកដែលមានសេចក្តីព្រមព្រៀងដោយទុក្ខ ដែលកើតតាមផ្លូវចិត្ត ។ បទថា **អាវដ្ដន្តិ** ប្រែថា ននៀលខ្លួន គឺ បង្វិលខ្លួនទៅ ទិសផ្សេង រមៀលមកពីទិសនោះៗ ។ បទថា **វិវដ្ដន្តិ** ប្រែថា រមៀលទៅ ដោយ ការបោកកាយ ។ ២ បទថា **ឧទ្ធំបាទំ បបតន្តិ** ប្រែថា ដួលផ្ងារពោះលើក ជើងឡើងលើ ។ ពាក្យថា **ចាប់សស្ត្រា** គឺ នាំសស្ត្រាចូលមកដើម្បីទម្លាយ សរីរៈខ្លួនឯង ។

( អធិប្បាយ **ទោមនស្សជាទុក្ខ** ចប់ )

## ឧបាយាសៈ

បទថា **អាយាសោ** បានដល់ ការលំបាកផ្លូវចិត្ត ដែលដល់នូវអាការ គឺការស្រងាកចិត្ត អស់កម្លាំងចិត្ត ។ ការតឹងចិត្ត ដោយភាវៈមានកម្លាំងខ្លាំងក្លា ឈ្មោះថា ការកន្ទក់កន្ទេញតាមផ្លូវចិត្ត ។ ស័ព្ទទាំង ២ **អាយាសិត្តកំ ឧបាយាសិត្តំ** ក្រៅពី **អាយាស** និង **ឧបាយាស** នោះ ជាធម៌ទាក់ទងនៅក្នុងខ្លួន ផ្ទុះបញ្ជាំងភាវៈ បង្ហាញភាវៈ ។

វិសុទ្ធិមគ្គ : ទោសៈ ដែលបណ្ដាលឱ្យដល់នូវសេចក្ដីទុក្ខតាមផ្លូវចិត្ត យ៉ាងធ្ងន់ធ្ងរនៃបុគ្គលដែលត្រូវទុក្ខ មានការវិនាសញាតិជាដើម ឈ្មោះថា **ឧបាយាស** អាចារ្យពួកមួយពោល **ឧបាយាស** ជា ( ចេតសិក ) ធម៌មួយ រាប់ចូលក្នុងសង្ខារក្ខន្ធ , ឧបាយាសៈនោះ មានការដុតរោលចិត្ត ជាលក្ខណៈ , មានការធ្វើឱ្យដកដង្ហើមធំជាកិច្ច , មានសេចក្ដីក្រំចិត្តជាអាការប្រាកដ , រីឯ ឧបាយាសៈជាទុក្ខ គប្បីជ្រាបថា ព្រោះជាសង្ខារទុក្ខ ព្រោះដុតរោលចិត្ត និង ព្រោះធ្វើរាងកាយឱ្យស្លេកស្លាំងផងដែរ ព្រោះហេតុនោះ អ្នកប្រាជ្ញ ទើបពោលពាក្យប្រព័ន្ធទុកថា :

ឧបាយាសៈ រមែងញ៉ាំងទុក្ខណាឱ្យកើត ទុក្ខនោះ គឺ មានប្រមាណក្រៃលែង ព្រោះទាំងដុតរោលចិត្ត ទាំងធ្វើកាយឱ្យស្លេកស្លាំង ព្រោះហេតុនោះ ឧបាយាសៈ ព្រះមានព្រះភាគ ទើបត្រាស់ថា **ជាទុក្ខ** ។

មហាដីកា : ពាក្យថា **ទោសៈនោះឯង** បានដល់ អាការនៃការប្រព្រឹត្តទៅរបស់ទោសៈនោះឯង ដោយអំណាចការចង្អៀតចង្អល់នៃកាយ និង

ចិត្ត , ព្រោះដែលលោកហៅថា **ឧបាយាស** ដោយសេចក្តីថា ជាការចង្អៀតចង្អល់ដ៏ខ្លាំង ដូចពាក្យថា **ភុសមាទានំ ឧបាទានំ** ការកាន់យកនោះ ឈ្មោះថា ឧបាទាន ។ ពាក្យថា **ធម៌ម្យ៉ាង** បានដល់ ចេតសិកធម៌ម្យ៉ាង ក្រៅពីអកុសលចេតសិក ១៤ ដែលលោកអាចារ្យទាំងឡាយហៅថា **ក្រំចិត្ត** ឈ្មោះថា មានការដកដង្ហើមធំ ជាកិច្ច ព្រោះការដល់ព្រមដោយអំណាចនៃការដកដង្ហើមធំ ឬ មានការធ្វើឱ្យដកដង្ហើមធំក្នុងកាយ ជាកិច្ច ។ លោកអាចារ្យ កាលពោលថា " ព្រោះភាពជាសង្ខារទុក្ខ " ដូច្នេះហើយ កាលនឹងសម្តែងថា ឧបាយាសៈនោះ មានប្រមាណក្រៃលែង ក្នុងបកិណ្ណកទុក្ខទាំងនេះ ទើបពោលថា **ព្រោះដុតរោលចិត្ត និង ព្រោះធ្វើរាងកាយឱ្យស្វេកស្វាំង ។**

## ការប្រៀបធៀប

## " សោកៈ បរិទេវៈ ឧបាយាសៈ "

ឯក្នុង **សោកៈ បរិទេវៈ** និង **ឧបាយាសៈ** នេះ :

- **សោកៈ** គប្បីឃើញ ដូចជាទឹកនៅក្នុងភាជនៈ ដោយភ្លើងដែលក្តៅឧណ្ហ ៗ ។
- **បរិទេវៈ** គប្បីឃើញ ដូចទឹកពុះហៀរចេញក្រៅភាជនៈដោយភ្លើងដែលក្តៅខ្លាំង ។
- **ឧបាយាសៈ** គប្បីឃើញ ដូចជាការក្តៅរហូតធ្វើឱ្យហួតទឹកនៅក្នុងភាជនៈនោះ ទឹកដែលនៅសល់ក្រៅពីទឹកដែលហូរចេញទៅក្រៅ ក៏មិនអាចហូរបានទៀត ។

មហាដីកា : លោកអាចារ្យពោលពាក្យមានជាអាទិថា ក្នុងបណ្ដា **សោកៈ បរិទេវៈ** និង **ឧបាយាសៈ** ទាំងនេះ ក៏ដើម្បីនឹងសម្ដែងនូវសោកៈ បរិទេវៈ និង ឧបាយាសៈ ទាំងនោះ ជាអាការពិសេសនៃការកើតឡើង របស់ទោមនស្សចិត្ត តាមបច្ច័យ ដោយវៀរចាកវិញ្ញត្តិ និង រួមជាមួយវិញ្ញត្តិ ។ ក្នុងបណ្ដាពាក្យទាំងនោះ ពាក្យថា ដូចទឹកក្ដៅឧណ្ហៗ នៃវត្ថុដែលគប្បីស្ងោរ មានគ្រឿងជ្រលក់ជាដើម ។

( អធិប្បាយ **ឧបាយាសៈ** ចប់ ដោយប្រការដូច្នេះ )

## អប្បិយសម្បយោគទុក្ខ

បទថា **ជាតិធម្មានំ** មានការកើតជាធម្មតា គឺ មានការកើតជាសភាវៈ។ ២បទថា **ឥច្ឆា ឧប្បជ្ជតិ** សេចក្ដីប្រាថ្នារមែងកើត គឺ តណ្ហារមែងកើត ។ ពាក្យថា **អហោ វត** បានដល់ សេចក្ដីប្រាថ្នា ។ បទថា **ន ខោ បនេតំ ឥច្ឆាយ** សេចក្ដីនោះ មិនបានតាមសេចក្ដីប្រាថ្នា មានន័យថា ប្រការនោះ គឺ ការមិនត្រូវមកកើត វៀរមគ្គភាវនាចេញ បុគ្គលមិនគប្បីសម្រេចបានតាមប្រាថ្នាទេ ។ ពាក្យថា **ឥទំបិ** គឺ សូម្បីការនេះ ។ **បិ** អក្សរ ក្នុងពាក្យថា **ឥទម្បិ** សំដៅដល់បទដ៏សេសខាងមុខ ។ បទថា **យម្បិច្ឆំ** ប្រាថ្នាវត្ថុណា មានន័យថា បុគ្គលប្រាថ្នាវត្ថុណាដែលមិនគួរបាន រមែងមិនបាន ព្រោះធម៌ណា សេចក្ដីប្រាថ្នាវត្ថុដែលមិនគួរបាននោះ ក៏ជាទុក្ខ ។ គ្រប់ៗបទក៏មានន័យដូចគ្នា ។ ក្នុងខន្ធនិទ្ទេសមានវិនិច្ឆ័យដូច្នេះឯង ។ រូបផង ឧបាទានក្ខន្ធផង ព្រោះហេតុនោះ ទើបឈ្មោះថា

រូបូបាទានក្ខន្ធ ។ គ្រប់ ៧ ខន្ធ ក៏គួរជ្រាបយ៉ាងនេះ ។

វិសុទ្ធិមគ្គ : ការជួបប្រសព្វសត្វនិងសង្ខារទាំងឡាយ មិនជាទីពេញចិត្ត ឈ្មោះថា **អប្បិយសម្បយោគ** អប្បិយសម្បយោគនោះ មានការជួបប្រសព្វសត្វនិងសង្ខារ មិនជាទីប្រាថ្នា ជាលក្ខណៈ , មានការធ្វើឱ្យចង្អៀតចង្អល់ចិត្ត ជាកិច្ច , មានសភាពមិនបានប្រយោជន៍ ជាអាការប្រាកដ , រីឯ **អប្បិយសម្បយោគជាទុក្ខ** គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ ព្រោះហេតុនោះ អ្នកប្រាជ្ញទើបពោលពាក្យប្រព័ន្ធថា :

ការជួបបុគ្គលដែលគួរស្អប់ ជាបឋម ទុក្ខក៏ប្រាកដឡើងក្នុងចិត្ត បន្ទាប់មកទុក្ខដែលកើតពីការប្រទូសរ៉ាយ ក៏កើតមានក្នុងកាយ ក្នុងលោកនេះ ដោយហេតុណា ព្រោះហេតុនោះ ការជួបវត្ថុដែលគួរស្អប់ គប្បីជ្រាបថា ព្រះមហាឥសី ទ្រង់ត្រាស់ថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខទាំង ២ ( គឺ ទុក្ខផ្លូវចិត្ត និងផ្លូវកាយ ) ។

មហាដីកា : **ការជួបប្រសព្វ** បានដល់ ការប្រាកដនៃអនត្ថៈ មានទុក្ខផ្លូវកាយ និង ការចង្អៀតចង្អល់ផ្លូវចិត្តជាដើម ឈ្មោះថា **អនត្ថភាវបច្ចុប្បដ្ឋានោ** ប្រែថា មានភាពជាអនត្ថៈ ជាអាការប្រាកដ ។

ការចូលទៅប្រទូសរ៉ាយ ពោលគឺ ប្រយោគផ្លូវកាយនិងផ្លូវវាចា ចំពោះសត្វ និងសង្ខារ ដែលមិនជាទីស្រឡាញ់ ទាំងនោះ ឈ្មោះថា **តទុបក្កមសម្ភូតោ** កើតពីការប្រទូសរ៉ាយ គេនោះ ។

( អធិប្បាយ **អប្បិយសម្បយោគ** ចប់ដោយប្រការដូច្នេះ )

## បិយវិប្បយោគទុក្ខ

ការព្រាត់ប្រាសចាកសត្វ និង សង្ខារទាំងឡាយ ដែលជាទីពេញចិត្ត ឈ្មោះថា **បិយវិប្បយោគ** បិយវិប្បយោគនោះ មានការព្រាត់ចាកវត្ថុដែលជាទីពេញចិត្ត ជាលក្ខណៈ , មានការញុំាងសេចក្ដីសោកឱ្យកើតឡើង ជាកិច្ច , មានសេចក្ដីវិនាស ជាអាការប្រាកដ , រីឯ **បិយវិប្បយោគ** ជាទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ គឺ សេចក្ដីសោក ព្រោះហេតុនោះ អ្នកប្រាជ្ញ ទើបពោលពាក្យប្រព័ន្ធថា :

បុគ្គលល្ងង់ខ្លៅទាំងឡាយ ដែលឆ្អែតដោយសរ គឺ សេចក្ដីសោក ព្រោះព្រាត់ប្រាសចាកសត្វ និង សង្ខារ ជាទីស្រឡាញ់ មានញាតិ និងទ្រព្យជាដើម រមែងឈឺចិត្ត ដោយហេតុណា ព្រោះហេតុនោះ បិយវិប្បយោគនេះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **ជាទុក្ខ** ។

( អធិប្បាយ **បិយវិប្បយោគទុក្ខ** ចប់ដោយប្រការដូច្នេះ )

## ឥច្ឆិតាលាភទុក្ខ

បទថា **ជាតិធម្មានំ** មានការកើតជាធម្មតា គឺ មានការកើតជាសភាវៈ។ ២ បទថា **ឥច្ឆា ឧប្បជ្ជតិ** សេចក្ដីប្រាថ្នារមែងមាន គឺ តណ្ហារមែងកើតឡើង ។ ពាក្យថា **អហោ វត** បានដល់ សេចក្ដីប្រាថ្នា ។ បទថា **ន ខោ បនេតំ ឥច្ឆាយ** ប្រការនោះ មិនគប្បីបានតាមសេចក្ដីប្រាថ្នា មានន័យថា ប្រការ គឺ ការមិនត្រូវមកកើត វៀរមគ្គភាវនាចេញ បុគ្គលមិនអាចនឹងសម្រេចបាន តាមសេចក្ដី

ប្រាថ្នាឡើយ ។ ពាក្យថា **ឥទំបិ** គឺ សូម្បីយ៉ាងនេះ ។ **បិ** អក្សរ ក្នុងពាក្យថា **ឥទម្បិ** សំដៅដល់បទដ៏សេសខាងមុខ ។ បទថា **យម្បិច្ឆំ** - ប្រាថ្នាវត្ថុណា មានន័យថា បុគ្គលប្រាថ្នាវត្ថុដែលមិនអាចបាន រមែងមិនបានព្រោះធម៌ណា សេចក្តីប្រាថ្នាវត្ថុដែលមិនអាចបាននោះ ក៏ជាទុក្ខ ។ គ្រប់ៗបទ មានន័យដូចគ្នា ។

វិសុទ្ធិមគ្គ : ក្នុងសេចក្តីថា **យម្បិច្ឆំ ន លភតិ...** នេះ មានវិនិច្ឆ័យថា សេចក្តីប្រាថ្នាក្នុងវត្ថុដែលមិនអាចបានទាំងឡាយ ដូចជា ប្រាថ្នាថា " ឱហ្ន៎ ! យើងទាំងឡាយ កុំមានការកើតឡើងជាធម្មតា " ជាដើមនោះឯង ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** - ប្រាថ្នាហើយតែមិនបាន ការប្រាថ្នានូវវត្ថុនោះ ក៏ជាទុក្ខ ។

**សេចក្តីប្រាថ្នានោះ** មានសេចក្តីត្រូវការវត្ថុដែលមិនអាចបាន ជាលក្ខណៈ , មានការស្វែងរកវត្ថុដែលមិនអាចនឹងបាន ជាកិច្ច , មានការមិនបានវត្ថុនោះ ជាអាការប្រាកដ , រីឯ សេចក្តីប្រាថ្នានោះជាទុក្ខ គប្បីជ្រាបថា ព្រោះជាទីតាំងនៃទុក្ខ ព្រោះហេតុនោះ អ្នកប្រាជ្ញទើបពោលពាក្យប្រព័ន្ធថា :

ទុក្ខដែលប្រកបដោយការតូចចិត្ត កើតឡើងដល់សត្វទាំងឡាយ ក្នុងលោកនេះ ព្រោះកាលគេទាំងឡាយប្រាថ្នាវត្ថុនោះ តែមិនបានវត្ថុនោះ សេចក្តីប្រាថ្នាវត្ថុដែលមិនអាចបានទាំងឡាយ គឺជាហេតុនៃទុក្ខនោះ ដោយហេតុណា ព្រោះហេតុនោះ ព្រះជិនជាម្ចាស់ ទើបត្រាស់ថា **ការមិនបានវត្ថុដែលប្រាថ្នាជាទុក្ខ** ។

មហាដីកា : ការមិនបានវត្ថុដែលខ្លួនប្រាថ្នា យ៉ាងណាមួយ ឈ្មោះថា

**ឥច្ឆិតាលាភ** ។ សេចក្តីនេះសមដូចព្រះបាលីត្រាស់ទុកថា " **យម្បិច្ឆំ ន លភតិ** " ប្រាថ្នាវត្ថុណា មិនបាន ។ តែដើម្បីនឹងសម្តែង **ឥច្ឆិតាលាភ** ដែលដល់កំពូល លោកមិនបានអធិប្បាយទុក ដោយពាក្យថា នៃសត្វទាំងឡាយដែលមានការកើតជាធម្មតា ដូច្នេះជាដើម ក្នុងព្រះបាលី ព្រោះហេតុនោះ លោកអាចារ្យពោលពាក្យថា **ឱហ្ន៎ !** ជាដើម ដើម្បីនឹងសម្តែងដល់ **ឥច្ឆិតាលាភ** ដ៏កំពូលនោះឯង ។ ក្នុងបទថា **ឥច្ឆាវ** ប្រែថា សេចក្តីប្រាថ្នានេះ លោកអាចារ្យទាំងឡាយពោលថា ការដែលមិនបានមកនូវវត្ថុតាមប្រាថ្នា ។ បទថា **តប្បរិយេសនរសា** មានការស្វែងរកវត្ថុដែលមិនសង្ឃឹមថាបាននោះ ជាកិច្ច ។ **អប្បត្តិ** ប្រែថា ការមិនបាន ។

( អធិប្បាយ **ឥច្ឆិតាលាភទុក្ខ** ចប់ដោយប្រការដូច្នេះ )

## បញ្ចុបាទានក្ខន្ធទុក្ខ

វីឯក្នុងសេចក្តីថា " **ដោយបំព្រួញ ឧបាទានក្ខន្ធ ៥ ជាទុក្ខ** " នេះ មានវិនិច្ឆ័យថា :

ទុក្ខចាប់តាំងពីជាតិទុក្ខមកយ៉ាងណា ដែលព្រះមានព្រះភាគ ទ្រទ្រង់នូវតាទិគុណ ត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះហើយក្តី ទុក្ខណាដែលទ្រង់មិនទាន់បានត្រាស់ទុកក្នុងទុក្ខនិទ្ទេសនេះក្តី ទុក្ខទាំងពួងនោះ វៀរឧបាទានក្ខន្ធនេះហើយមិនមាន ដោយហេតុណា ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយនេះ ព្រះមហាឥសីជាម្ចាស់ប្រកាសទីបំផុតនៃទុក្ខ ទើបត្រាស់ថា **ជាទុក្ខ ដោយបំព្រួញ** ។

ពិតហើយ ទុក្ខធម៌ទាំងឡាយ មានជាតិជាដើមដែលបៀតបៀនឧបា-ទានក្ខន្ធទាំង ៥ នេះ ដោយប្រការផ្សេងៗ ដូចភ្លើងបៀតបៀនកម្ទេចឈើ ដូចគ្រឿងប្រហារបៀតបៀនគោលដៅ ដូចសត្វល្អិតទាំងឡាយ មានរបោមនិងមូសជាដើម បៀតបៀនគោ ដូចមនុស្សច្រូតស្រូវទាំងឡាយបៀតបៀនស្រែ ដូចចោរប្លន់ស្រុក បៀតបៀនអ្នកស្រុក ការកើតឡើងនូវឧបាទានក្ខន្ធទាំង-ឡាយនេះឯង ដូចជាស្មៅនិងវល្លិជាដើមដែលកើតឡើងលើផែនដី ដូចជាផ្កាផ្លែនិងពន្លកដែលកើតលើដើមឈើទាំងឡាយ ដូច្នោះ , ម្យ៉ាងទៀត ទុក្ខក្នុងខាងដើមនៃឧបាទានក្ខន្ធទាំងឡាយ គឺ ជាតិទុក្ខត្រង់កណ្តាល គឺ ជរា ទុក្ខខាងចុង គឺ មរណៈ , ទុក្ខ គឺ ការអន្ទះអន្ទែង ព្រោះប្រទះនឹង **មរណន្តិកទុក្ខ** ( ទុក្ខពេលជិតស្លាប់ ) ជាសោកទុក្ខ គឺ សេចក្តីត្អូញត្អែរ ព្រោះអត់ទ្រាំនឹងទុក្ខនោះមិនបាន , ជាបរិទេវៈ ចំពោះទុក្ខ គឺ ការឈឺចាប់ផ្លូវកាយ ព្រោះប្រទះនឹងអនិដ្ឋផោដ្ឋព្វៈ គឺ ការកម្រើកនៃធាតុ ជាទុក្ខ , ទុក្ខ គឺ ការឈឺចិត្ត ព្រោះកើតបដិឃៈក្នុងទុក្ខកាយនោះ នៃបុថុជ្ជនទាំងឡាយដែលពាល់ត្រូវនូវការឈឺចាប់ផ្លូវកាយនោះ បៀតបៀន ជាទោមនស្ស , ទុក្ខ គឺ ការរួចល់ចិត្តនៃបុគ្គលទាំងឡាយ ដែលមានការតក់ស្លុត ព្រោះការចម្រើនឡើងនៃទុក្ខដែលបានពោលហើយ មានសោកៈជា-ដើម ធ្វើឱ្យកើតឡើង ជាឧបាយាសៈ , ទុក្ខ គឺ ការមិនសមតាមប្រាថ្នានៃបុគ្គលទាំងឡាយ ដែលបានទទួលនូវការអស់សង្ឃឹម ជាឥច្ឆិតាលាភៈ ព្រោះហេតុនោះ ឧបាទានក្ខន្ធទាំងឡាយនោះឯង កាលពិចារណាដោយប្រការផ្សេង ៗ ដូចពោលមកនេះ រមែងជាទុក្ខពិត ។

នរណាៗ ក៏មិនអាចរៀបរាប់នូវទុក្ខមួយនេះ ឱ្យអស់បាន ដែលព្រះមាន

ព្រះភាគទ្រង់សម្ដែងទុកមិនឱ្យសល់ ដោយកាល សូម្បីច្រើនកប្ប ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនូវទុក្ខទាំងពួងនោះ ដោយបំព្រួញ ទុក្ខទាំងពួងនោះ ប្រជុំចុះក្នុងឧបាទានក្ខន្ធ ៥ គ្រប់យ៉ាង ដូចបំព្រួញរសជាតិទឹកសមុទ្រទាំងអស់ ទុកក្នុងតំណក់ទឹកមួយដំណក់ ទើបទ្រង់ត្រាស់ថា **ដោយបំព្រួញ ឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ ។**

មហាដីកា: ពាក្យថា **យំ វុត្តមិធ** ប្រែថា ទុក្ខណា ព្រះមានព្រះភាគត្រាស់ទុកដោយសរុបក្នុងសច្ចនិទ្ទេសនេះ ។ បទថា **អវុត្តំ** មានន័យថា សូម្បីទ្រង់ត្រាស់ទុកក្នុងព្រះសូត្រទាំងឡាយ មានទុក្ខខន្ធសូត្រ និង ពាលបណ្ឌិតសូត្រជាដើម តែមិនបានត្រាស់ទុកដោយសរុបក្នុងសច្ចនិទ្ទេសនេះ , ទុក្ខនោះ ទាំងអស់ វៀរឧបាទានក្ខន្ធទាំងឡាយនេះចេញ រមែងមិនមាន ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា **ដូចភ្លើងបៀតបៀនកម្ទេចឈើ** ដើម្បីនឹងសម្ដែងថា ទុក្ខដែលមានខន្ធជាទីអាស្រ័យ ក្នុងឧបាទានក្ខន្ធនោះឯង រមែងបៀតបៀនខន្ធ។ ន័យមួយទៀត លោកអាចារ្យពោលថា ដូចគ្រឿងប្រហារបៀតបៀនគោលដៅជាដើម ដើម្បីនឹងសម្ដែងថា គោលដៅជាវត្ថុដែលត្រូវប្រហារ ដោយគ្រឿងប្រហារ យ៉ាងណា **ខន្ធ** ក៏ជាទីតាំងនៃសង្ខារទុក្ខ ក៏ដូច្នោះដែរ ។ម្យ៉ាងទៀត គោជាទីតាំងនៃការបៀតបៀនរបស់របោម និង មូស យ៉ាងណា **ខន្ធ** ក៏ជាទីតាំងនៃទុក្ខ មានជាតិជាដើម ក៏ដូច្នោះ ។ ម្យ៉ាងទៀត ស្រែជាទីតាំងនៃការច្រូតស្រូវដែលទុំហើយ យ៉ាងណា **ខន្ធ** ក៏ជាទីតាំងនៃទុក្ខ មានជាតិជាដើម ក៏ដូច្នោះ ។ ម្យ៉ាងទៀត ស្រុកជាទីតាំងនៃការបៀតបៀនរបស់ចោរប្លន់ស្រុក

យ៉ាងណា **ខន្ធ** ក៏ជាទីតាំងនៃទុក្ខ មានជាតិជាដើម ក៏ដូច្នោះ ។ លោកអាចារ្យពោលថា **ដូចជាស្មៅ និង វល្លិជាដើម** ក៏ដើម្បីសម្តែងថា ដោយច្រើន អ្នកបៀតបៀនក្នុងលោក វៀរវត្ថុដែលត្រូវបៀតបៀន មិនមាន , តែខន្ធទាំងនេះក៏អាស្រ័យវត្ថុដែលគប្បីបៀតបៀននោះឯង ។ ដែលឈ្មោះថា ខាងដើម ក្នុងសង្សារ ដែលមានខាងដើមមិនប្រាកដ គឺ មិនប្រាកដដល់អ្នកណាដោយពិត , សូម្បីដូច្នោះ លោកអាចារ្យពោលថា ទុក្ខក្នុងខាងដើម ( នៃឧបាទានក្ខន្ធទាំងឡាយ ) ក៏គឺ **ជាតិ** ដោយអំណាចនៃការបន្តគ្នានៃខន្ធ ដែលកំណត់ដោយភព ១ ។

ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា ទុក្ខក្នុងទីបំផុត គឺ មរណៈ , ក្នុងពាក្យនេះ លោកមិនបានបំណងយកសមុច្ឆេទមរណៈឡើយ ។ ទុក្ខដែលកើតក្នុងទីបំផុត គឺ ក្នុងវេលាជិតនឹងស្លាប់ ឈ្មោះថា ទុក្ខកាលជិតស្លាប់ ។ សេចក្តីអន្ទះអន្ទែង បានដល់ ការក្តៅក្រហាយចិត្ត ។ ការទួញសោក បានដល់ ការយំរៀបរាប់ខ្លាំងឡើង ។ ការឈឺចិត្ត បានដល់ ការក្រៀមក្រំក្នុងខាងក្នុង ។ ពាក្យថា **ទុក្ខម្យ៉ាង ៗ** បានដល់ បណ្តាទុក្ខ មានទុក្ខប្រភេទផ្សេងៗក្នុងរវាងនៃជាតិទុក្ខជាដើម ឬ ទុក្ខ គឺ ឧបាទានក្ខន្ធទាំង ៥ មានជាតិទុក្ខជាដើមនោះឯង ជាទុក្ខម្យ៉ាង ៗ ។ បទថា **សង្ខិបិត្វា** ប្រែថា ដោយសង្ខេប , ឬ ទ្រង់ធ្វើសេចក្តីសង្ខេបដោយសាមញ្ញនិទ្ទេស ។

( អធិប្បាយ **ទុក្ខសច្ច** ចប់ដោយប្រការដូច្នេះ )

# សមុទយអរិយសច្ច

បទថា **យាយំ តណ្ហា** កាត់ជា **យា អយំ តណ្ហា** ប្រែថា តណ្ហានេះ ។ ពាក្យថា **បោនោព្ភវិកា** មានវិគ្រោះថា ការធ្វើភពថ្មី ឈ្មោះថា ភពថ្មី ការបង្កភពថ្មី ជាប្រក្រតីនៃតណ្ហានោះ ព្រោះហេតុនោះ តណ្ហានោះ ទើបឈ្មោះថា **បោនោព្ភវិកា** មានការកើតទៀតជាប្រក្រតី ។ ពាក្យថា **នន្ទិរាគសហគតា** បានដល់ តណ្ហាដែលកើតរួមជាមួយតម្រេក ដោយអំណាចសេចក្ដីត្រេកត្រអាល ។ លោកអធិប្បាយថា ដោយអត្ថ តណ្ហានោះ គឺ នន្ទិរាគៈនោះឯង ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **តត្រតត្រាភិនន្ទិនី** ត្រេកត្រអាលក្នុងអារម្មណ៍នោះៗ មានន័យថា អត្តភាពកើតចំពោះក្នុងទីណា ៗ តណ្ហា ក៏ត្រេកត្រអាលក្នុងទីនោះ ៗ ។ម្យ៉ាងទៀត តណ្ហាត្រេកត្រអាលក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ក្នុងទីនោះៗ , អធិប្បាយថា ត្រេកត្រអាលក្នុងរូប ត្រេកត្រអាលក្នុងសំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ។ ស័ព្ទថា **សេយ្យថីទំ** នោះមានន័យថា បើមានពាក្យសួរថា តណ្ហានោះ ដូចម្ដេច ? សេចក្ដីប្រាថ្នាក្នុងកាម ឈ្មោះថា **កាមតណ្ហា** , ពាក្យថា **តណ្ហានោះ** ជាឈ្មោះនៃសេចក្ដីត្រេកអរ ក្នុងកាមគុណ **៥** ។ សេចក្ដីប្រាថ្នាក្នុងភព ឈ្មោះថា **ភវតណ្ហា** , ពាក្យថា **ភវតណ្ហានេះ** ជាឈ្មោះនៃសេចក្ដីត្រេកអរក្នុងរូបភព និងអរូបភព ដែលកើតរួមជាមួយនឹងសស្សតទិដ្ឋិ កើតដោយការប្រាថ្នាភព និងសេចក្ដីត្រេកអរក្នុងឈាន ។ សេចក្ដីប្រាថ្នាក្នុងវិភព ឈ្មោះថា **វិភវតណ្ហា** , ពាក្យថា **វិភវតណ្ហានេះ** ជាឈ្មោះនៃសេចក្ដីត្រេកអរដែលកើតរួមជាមួយនឹងឧច្ឆេទទិដ្ឋិ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងនូវវត្ថុដែលជាទីតាំង ទីកើតនៃតណ្ហានោះ

ដោយពិស្តារ ទើបត្រាស់ថា **សា ខោ បនេសា** តណ្ហានេះឯង ដូច្នេះ ជាដើម ។

បណ្តាពាក្យទាំងឡាយនោះ ពាក្យថា **ឧប្បជ្ជតិ** ប្រែថា កើត ។ ពាក្យថា **និវិសតិ** បានដល់ តាំងនៅដោយការប្រព្រឹត្តទៅរឿយ ៗ ។ ពាក្យថា **យំ លោកេ បិយរូបំ សាតរូបំ** មានន័យថា ជាសភាវៈគួរស្រឡាញ់ និង ជាសភាវៈគួរពេញចិត្តក្នុងលោក ។ ក្នុងពាក្យថា **ចក្ខុំ លោកេ** ជាដើម មានអធិប្បាយដូច្នេះ ពិតហើយ សត្វទាំងឡាយប្រកាន់មាំក្នុងចក្ខុជាដើម ក្នុងលោកថា ជារបស់យើង តាំងមាំនៅក្នុងសម្មតិ រមែងសម្គាល់ថា ចក្ខុជារបស់ខ្លួន ដែលមានបសាទទាំង ៥ ថ្លាយង់ដូចកែវមណី បើកឡើងក្នុងវិមានមាស តាមទំនងនៃការកាន់យកនិមិត្ត ក្នុងកញ្ចក់ជាដើម , រមែងសម្គាល់សោតៈ ដូចបំពង់ប្រាក់ និង ដូចកម្រងសង្វារ , រមែងសម្គាល់ឃានៈ ដែលបានវោហារ ហៅថា តុង្គនាសា ដូចកំពូលហរតាលដែលគេស្ងួនហើយតម្កក់ទុក , រមែងសម្គាល់ជីវ្ហាទន់ល្មើយ ចាំទទួលរសឆ្ងាញ់ ដូចផ្ទាំងសំពត់កម្ពល់ក្រហម , រមែងសម្គាល់កាយ ដូចដើមសាលៈក្រមុំ និង ដូចរបងមាស , រមែងសម្គាល់មនៈដ៏ឱឡារៈ មិនដូចនឹងចិត្តរបស់អ្នកដទៃៗ រមែងសម្គាល់រូបថា មានពណ៌សម្បុរដូចផ្កា កណិកាមាសជាដើម , រមែងសម្គាល់សំឡេង ដូចនឹងសំឡេងសត្វករវិក និង ពោលថា គួរឱ្យវង្វេងវង្វាន់ និង ដូចសំឡេងរំពងរបស់ប៉ីកែវដែលផ្លុំថ្នមៗ , រមែងសម្គាល់អារម្មណ៍ មានគន្ធារម្មណ៍ជាដើម ដែលមានសមុដ្ឋាន ៤ ដែលខ្លួនបានហើយថា អារម្មណ៍បែបនេះ បុគ្គលដទៃណាទៅ នឹងមាន ។ កាលសត្វទាំងឡាយនោះ សម្គាល់យ៉ាងនេះ ចក្ខុជាដើមទាំងឡាយនោះ ក៏រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត , កាលបើដូច្នោះ តណ្ហារបស់សត្វទាំងឡាយនោះ ដែលមិនទាន់

កើតឡើង ក៏កើតក្នុងចក្ខុជាដើមទាំងឡាយនោះ ឯតណ្ហាដែលកើតឡើងហើយ ក៏រមែងតាំងនៅ ដោយការប្រព្រឹត្តទៅរឿយៗ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ចក្ខុជាទីស្រឡាញ់ ជាទីពេញចិត្តក្នុងលោក តណ្ហានោះ កាលកើតឡើង ក៏កើតឡើងក្នុងចក្ខុនោះ ដូច្នេះជាដើម ។ ពាក្យថា **តត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ** មានន័យថា តណ្ហានោះ កាលកើតឡើងក្នុងពេលណា ក៏រមែងកើតឡើងក្នុងចក្ខុនេះ ក្នុងកាលនោះឯង ។ គ្រប់ៗបទ ក៏មានន័យដូច្នេះឯង ។

*វិសុទ្ធិមគ្គ:* តណ្ហា **៦** ដោយចែកជារូបតណ្ហាជាដើម ទ្រង់សម្តែងទុកក្នុងបទនេះ ក្នុងតណ្ហាទាំងឡាយនោះ តណ្ហាមួយ ៗ មាន ៣ យ៉ាង តាមអាការដូចតទៅ :

ពិតហើយ ក្នុងបទនេះ ក្នុងវិភង្គទ្រង់សម្តែងតណ្ហា ៦ មានឈ្មោះហៅតាមអារម្មណ៍ថា រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា ដូចបុត្តដែលត្រូវហៅឈ្មោះ តាមឈ្មោះបិតាថា សេដ្ឋីបុត្ត ព្រាហ្មណបុត្តជាដើមដូច្នោះ , ម្យ៉ាងទៀត តណ្ហាប្រការដទៃៗ មាន ៣ យ៉ាង តាមអាការដែលប្រព្រឹត្តទៅ ដូច្នេះ គឺ **កាមតណ្ហា ភវតណ្ហា វិភវតណ្ហា** ។

ក្នុងរូបតណ្ហានោះ កាលត្រេកអរក្នុងរូបារម្មណ៍ ដែលមកកាន់គន្លងចក្ខុ ដោយអំណាចការពេញចិត្តក្នុងកាមដែលប្រព្រឹត្តទៅ ដូច្នោះ ក៏បានឈ្មោះថា **កាមតណ្ហា** , កាលណាវាប្រព្រឹត្តទៅជាមួយសស្សតទិដ្ឋិ ដែលជាការប្រព្រឹត្តទៅ ព្រោះឃើញថា អារម្មណ៍នោះឯងជារបស់ទៀង ឋិតថេរ ពេលនោះ ក៏បានឈ្មោះថា **ភវតណ្ហា** ព្រោះថា រាគៈដែលសហគតៈជាមួយសស្សតទិដ្ឋិ ទ្រង់

ហៅថា **ភវតណ្ហា** , រីឯ កាលណាវានោះ ប្រព្រឹត្តទៅជាមួយឧច្ឆេទទិដ្ឋិ ដែលជាការឃើញថា អារម្មណ៍នោះឯងនឹងដាច់សូន្យ ពេលនោះ វាក៏បានឈ្មោះថា ជាវិភវតណ្ហា ព្រោះថា រាគៈដែលសហគតៈជាមួយឧច្ឆេទទិដ្ឋិ ទ្រង់ហៅថា **វិភវតណ្ហា** , សូម្បីតណ្ហាដ៏សេស មានសទ្ទតណ្ហាជាដើម ក៏មានន័យដូច្នេះ ព្រោះហេតុនោះ ទើបបានតណ្ហា ១៨ វាប្រព្រឹត្តទៅក្នុងរូបារម្មណ៍ជាដើម ជាខាងក្នុង ១៨ ជាខាងក្រៅ ១៨ ព្រោះដូច្នោះ ទើបបានជាតណ្ហា ៣៦ , ជាអតីត ៣៦ ជាអនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ ដូច្នោះ ទើបបានជាតណ្ហា **១០៨** , តណ្ហាទាំងឡាយនោះ បណ្ឌិតគប្បីជ្រាបថា កាលសង្ខេបក៏បានជាតណ្ហា ៦ ដោយអំណាចនៃអារម្មណ៍ មានរូបជាដើម ឬ ជាតណ្ហា ៣ មានប្រភេទនៃកាមតណ្ហាជាដើមនោះឯង ។

ព្រោះថា សត្វទាំងឡានោះ ពេញចិត្តក្នុងវេទនាដែលកើតឡើង ដោយអំណាចអារម្មណ៍ មានរូបជាដើម ទើបធ្វើសក្ការ ( ឱ្យរង្វាន់ ) ធំដល់វិចិត្រករ ( ជាងគំនូរ ) , គន្ធព ( អ្នកតន្ត្រី និង អ្នកចម្រៀង ) , គន្ធិក ( អ្នកតាក់តែងគ្រឿងក្រអូប ) , សូទ ( ចុងភៅ ) , តន្តាវាយ ( ជាងត្បាញ ) និង រសាយនវិធាយកពេទ្យ ( ពេទ្យដែលធ្វើថ្នាំតាមតម្រារសាយនវេទ ) ជាដើម ដែលជាអ្នកឱ្យអារម្មណ៍ មានរូបជាដើម ដោយការត្រេកអរក្នុងវេទនា ដូចបិតាពេញចិត្តក្នុងបុត្ត ហើយធ្វើការបូជាដល់ម៉ែដោះ ដោយការស្រឡាញ់បុត្តដូច្នោះ ព្រោះហេតុនោះ តណ្ហាទាំងពួងនោះ បណ្ឌិតគប្បីជ្រាបថា ជាតណ្ហាមានព្រោះបច្ច័យ គឺ វេទនា ។

សុខវេទនាជាវិបាកប៉ុណ្ណោះ ដែលទ្រង់បំណងយកក្នុងទីនេះ ព្រោះ

ហេតុនោះ សុខវេទនានោះ ទើបជាបច្ច័យដល់តណ្ហា ប្រការ ១ ។

ពាក្យថា **ជាបច្ច័យប្រការ ១** គឺជាបច្ច័យ ដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

ឬ ព្រោះថា អ្នកមានទុក្ខ រមែងប្រាថ្នាសេចក្ដីសុខ អ្នកមានសុខហើយក៏រមែងប្រាថ្នាសេចក្ដីសុខក្រៃលែងឡើងទៀត , រីឯ ឧបេក្ខាវេទនា ព្រោះជាវេទនាល្អិត ទ្រង់ក៏ពោលថា ជាសុខដូចគ្នា ព្រោះហេតុនោះ វេទនា ទើបជាបច្ច័យដល់តណ្ហាទាំង ៣ តែព្រោះថា តណ្ហា ព្រះមហាឥសីត្រាស់ទុកក្នុងបទថា **វេទនាបច្ចយា** , **តណ្ហា** នោះ សូម្បីមានវេទនាជាបច្ច័យ តែវៀរអនុស័យចេញ វាក៏មិនមាន ព្រោះដូច្នោះ ទើបមិនមានដល់ព្រាហ្មណ៍ ដែលនៅចប់ព្រហ្មចរិយៈហើយ ។

មហាដីកា : **បុនព្ភវករណំ** ជា **បុនព្ភវោ** ដែលប្រែថា ការបង្កភពថ្មីឈ្មោះថា **បុនព្ភវោ** ដោយការលុបបទខាងចុងចេញ , **តណ្ហា** ឈ្មោះថា **ពោនោព្ភវិកា** ព្រោះអត្ថថា មានការបង្កភពថ្មី ជាប្រក្រតី ដូចមនុស្សដែលមានការបរិភោគនំ ជាប្រក្រតី ឈ្មោះថា **អាបូបិកោ** ន័យម្យ៉ាង , **តណ្ហា** ឈ្មោះថា **ពោនោព្ភវិកា** ព្រោះអត្ថថា គួរដល់ផល មានការបង្កភពថ្មី ន័យម្យ៉ាង , **តណ្ហា** ឈ្មោះថា **ពោនោព្ភវិកា** ព្រោះអត្ថថា មានការបង្កភពថ្មីនោះ ជាប្រយោជន៍ ន័យម្យ៉ាង ។ **តណ្ហា** ឈ្មោះថា ប្រព្រឹត្តទៅដោយនន្ទិរាគៈ ព្រោះប្រព្រឹត្តទៅមិនលះបង់នូវនន្ទិរាគៈ ព្រោះថា ត្រេកអរ និង ព្រោះថា ត្រេកត្រអាល ក្នុងអាការដែលតាំងចុះក្នុងទីទាំងពួង ។

ព្រោះតណ្ហានោះ សត្វទាំងឡាយ រមែងត្រេកត្រអាលក្នុងភពជាដើម នោះៗ សូម្បីក្នុងអត្តភាព មានដង្កូវ សត្វល្អិត និង មេអំបៅជាដើម និងរមែងរីករាយដោយតណ្ហា ដែលជាតួត្រេកត្រអាលនៅក្នុងរូប ព្រោះដូច្នោះ **តណ្ហា** ទើបឈ្មោះថា **តត្រតត្រាភិនន្ទិនី** ប្រែថា មានការត្រេកអរនៅក្នុងភពនោះៗ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ពាក្យមានជាដើមថា ទៅជាមួយនឹងនន្ទិរាគៈ ។ គប្បីជ្រាបនូវ កាមតណ្ហា ភវតណ្ហា និង វិភវតណ្ហា ដោយការប្រព្រឹត្តទៅដោយអំណាចនៃកាមភព និង វិភព ។

តណ្ហាទាំង ៣ នេះ ឈ្មោះថា **ទុក្ខសមុទយអរិយសច្ច** ព្រោះជាហេតុនៃទុក្ខទាំងពួង ព្រោះមានសភាពវិចិត្រដ៏ក្រៃលែង ក្នុងការឱ្យសម្រេចកម្ម ដែលឱ្យកើតនូវភាពវិចិត្រនៃទុក្ខនោះ ៗ ព្រោះសត្វប្រភេទខ្លះ មានភាវៈដូចគ្នានឹងសត្វប្រភេទខ្លះ រាប់បញ្ចូលគ្នាតែមួយ ដោយការកាន់យកដូចគ្នាក្នុងភាពជាតណ្ហាតែម្យ៉ាង មិនបានសំដៅដល់ការផ្សេងគ្នានៃតណ្ហា មានកាមតណ្ហាជាដើម នោះទេ ។

សួរថា ព្រោះហេតុអ្វី ក្នុងអរិយសច្ចទាំង ៤ នេះ បានជាទ្រង់ពោលតណ្ហាតែម្យ៉ាងថាជា សមុទយៈ ទៅវិញ ? ឆ្លើយថា តណ្ហា ជាហេតុវិសេស ។ ពិតហើយ អវិជ្ជាបិទបាំងនៅក្នុងភពទាំងឡាយ និង ឧបាទាន មានទិដ្ឋិជាដើម ដែលប្រកាន់មាំនៅក្នុងភពនោះ ៗ ក៏ញុាំងតណ្ហាឱ្យចម្រើនក្រៃលែង សូម្បីកិលេស មានទោសៈជាដើម ក៏គង់ជាហេតុនៃកម្ម តែក៏សំដៅយកតណ្ហា ដែលជាធម្មជាតិវិចិត្រទៅដោយភពនោះ ៗ កំណើតនោះៗ គតិនោះ ៗ វិញ្ញាណដ្ឋិតិនោះ ៗ សត្តាវាសនោះ ៗ សត្វនិកាយនោះ ៗ ត្រកូលនោះ ៗ ភោគៈនោះ ៗ

និង ឥស្សរិយៈនោះ ៗ ជាដើម ចូលដល់ភាពជាឧបនិស្ស័យនៃភាពជាធម្មជាតិវិចិត្រដោយកម្ម និង ជាសំឡាញ់របស់កម្ម រមែងកំណត់ភាពវិចិត្រដោយភពជាដើម ព្រោះដូច្នោះ គប្បីជ្រាបថា កាលហេតុនៃទុក្ខទាំងពួងផ្សេងៗ មានដែរ ដែលទ្រង់ត្រាស់ទុកក្នុងព្រះសូត្រ មាន អវិជ្ជា ឧបាទាន និង កម្ម ជាដើម និង ដែលទ្រង់ត្រាស់ទុកក្នុងអភិធម្ម មានកិលេសដ៏សេស និង អកុសលមូលជាដើម ទ្រង់ក៏ពោលចំពោះតែតណ្ហាប៉ុណ្ណោះ ព្រោះជាហេតុពិសេសនៃទុក្ខ ។

( អធិប្បាយ **សមុទយសច្ច** ចប់ដោយប្រការដូច្នេះ )

# និរោធអរិយសច្ច

បទទាំងពួង មានបទថា **អសេសវិរាគនិរោធោ** ការរលត់ដោយការលះបង់មិនមានសេសសល់ជាដើមទាំងអស់ គឺជា វេវចនៈនៃព្រះនិព្វាននោះឯង ។ ពិតហើយ តណ្ហាមកដល់ព្រះនិព្វាន រមែងវិនាស រលត់មិនមានសេសសល់ ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបទ្រង់ត្រាស់ថា **និរោធ** ព្រោះរលត់មិនមានសេសសល់នៃតណ្ហានោះឯង ។ម្យ៉ាងទៀត តណ្ហាមកដល់ព្រះនិព្វាន រមែងលះបង់ លះបង់មិនឱ្យត្រឡប់វិញ រសាយទៅ មិនជាប់ស្អិត ព្រោះដូច្នោះ ព្រះនិព្វាន ទើបទ្រង់ត្រាស់ថា ជាទីលះបង់ លះដាច់ស្រឡះ ជាទីបន្សាត់ មិនជាប់ស្អិត ។ ពិតហើយ ព្រះនិព្វានមានមួយប៉ុណ្ណោះ តែឈ្មោះរបស់ព្រះនិព្វាននោះមានច្រើន ជាបដិបក្ខនឹងឈ្មោះរបស់សង្ខតធម៌ទាំងអស់ តើដូចម្តេច គឺធម៌ជាទីខ្ជាក់ចោល មិនមានសល់ ជាទីរលត់មិនមានសល់ ជាទីលះបង់ ជាទីរលត់ ជាទីបំផុត ជាទីមិនជាប់ស្អិត ជាទីអស់រាគៈ ជាទីអស់ទោសៈ ជាទីអស់មោហៈ ជាទីអស់តណ្ហា ជាទីមិនកើត ជាទីសម្រាក មិនមាននិមិត្ត មិនមានទីតាំង មិនមានទីអាស្រ័យ មិនមានបដិសន្ធិ មិនប្រព្រឹត្តទៅ មិនទៅ មិនកើត មិនចាស់ មិនឈឺ មិនស្លាប់ មិនសោក មិនក្រៀមក្រំ មិនចង្អៀតចង្អល់ មិនសៅហ្មង ដូច្នេះជាដើម ។ ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្តែងការមិនមាននៃតណ្ហាទាំងពួង ដែលមគ្គកាត់ផ្តាច់បានហើយ ដល់នូវការសម្រាក ( មិនប្រព្រឹត្តទៅ ) ព្រោះមកដល់ព្រះនិព្វាន ក្នុងវត្ថុដែលទ្រង់សម្តែងថា តណ្ហាកើតនោះឯង ទើបត្រាស់ថា **សា ខោ បនេសោ** គឺ តណ្ហានេះ ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដូចតទៅនេះ ប្រៀបដូចបុរសឃើញវល្លិដែលដុះក្នុងស្រែ ក៏ចាប់ពីចុងស្រាវទៅរកគល់ រួចហើយ ក៏ដកឡើង វល្លិនោះក៏ស្ងួតជាលំដាប់ ដល់នូវការមិនប្រាកដ , ទីនោះ គេក៏ហៅថា វល្លិក្នុងស្រែនោះ វិនាសហើយ អស់ហើយ , តណ្ហាក្នុងចក្ខុជាដើម ប្រៀបដូចជាវល្លិក្នុងស្រែ , តណ្ហានោះ ត្រូវកាត់ឫសបានហើយដោយអរហត្តមគ្គ ដល់នូវការសម្រាក ព្រោះមកដល់ព្រះនិព្វាន , ម្យ៉ាងទៀត តណ្ហាដែលដល់នូវការសម្រាកយ៉ាងនោះហើយ រមែងមិនប្រាកដក្នុងវត្ថុទាំងឡាយនោះ ដូចវល្លិមិនប្រាកដក្នុងស្រែដូច្នោះ។ ម្យ៉ាងទៀត ដូចពួកមនុស្សនាំចោរមកពីក្នុងព្រៃសម្លាប់ចោលនៅត្រង់ទ្វារទិសខាងត្បូងនៃព្រះនគរ បន្ទាប់ពីនោះទៅ មនុស្សទាំងឡាយនឹងនិយាយគ្នាថា ពួកចោរក្នុងព្រៃស្លាប់ហើយ ឬ ត្រូវសម្លាប់ហើយ ដូច្នេះយ៉ាងណា សេចក្តីនោះដូចគ្នា តណ្ហាក្នុងចក្ខុជាដើម ប្រៀបដូចចោរក្នុងព្រៃ តណ្ហានោះ ឈ្មោះថា រលត់ក្នុងព្រះនិព្វាននោះឯង ព្រោះមកដល់ព្រះនិព្វាននោះហើយ ទើបរលត់ទៅ ដូចចោរត្រូវសម្លាប់នៅត្រង់ទ្វារទិសខាងត្បូងដូច្នោះ , ម្យ៉ាងទៀត តណ្ហាដែលរលត់ហើយយ៉ាងនោះ រមែងមិនប្រាកដក្នុងវត្ថុទាំងឡាយនោះ ដូចចោរមិនប្រាកដក្នុងព្រៃដូច្នោះ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងការរលត់នៃតណ្ហានោះ ក្នុងចក្ខុជាដើមនោះ ទើបត្រាស់ថា ចក្ខុជាទីស្រឡាញ់ ជាទីពេញចិត្តក្នុងលោក តណ្ហានោះ កាលបុគ្គលលះបង់ ក៏លះបង់បានក្នុងចក្ខុនោះ កាលនឹងរលត់ក៏រលត់ក្នុងចក្ខុនោះជាដើម ។

វិសុទ្ធិមគ្គៈ ក្នុងទុក្ខនិរោធនិទ្ទេស មានវិនិច្ឆ័យថា **យោ តស្សាយេវ**

**តណ្ហាយ** ជាដើម គឺ ទ្រង់ត្រាស់ដល់ការរលត់នៃសមុទ័យ , សួរថា ហេតុអ្វីទើបទ្រង់ត្រាស់ដល់ការរលត់នៃ សមុទយៈ ? ចម្លើយមានថា ការរលត់នៃទុក្ខរមែងមានព្រោះការរលត់នៃសមុទ័យ , ពិតហើយ ទុក្ខរមែងរលត់ព្រោះការរលត់នៃសមុទ័យ មិនមែនដោយហេតុដទៃទេ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **ដើមឈើកាលគល់នៅមាំ មិនទាន់បានគាស់រំលើង សូម្បីត្រូវកាត់ហើយ ក៏អាចនៅដុះឡើងបានទៀត យ៉ាងណា សូម្បីទុក្ខក៏ដូច្នោះ កាលតណ្ហានុស័យមិនទាន់ត្រូវគាស់រំលើង ក៏នៅកើតបានជានិច្ច ។**

ព្រោះហេតុដែលទុក្ខ រមែងរលត់ ព្រោះការរលត់ទៅនៃសមុទ័យ ដូចពោលមកនោះឯង ព្រះមានព្រះភាគ កាលទ្រង់សម្តែងនូវការរលត់ទៅនៃទុក្ខទើបទ្រង់សម្តែងការរលត់ទៅនៃសមុទ័យនោះឯង ។

ព្រះតថាគតទាំងឡាយ ជាអ្នកមានការប្រព្រឹត្តស្មើដោយសីហៈ ទ្រង់រលត់ទុក្ខ ហើយទ្រង់សម្តែងទីរលត់ទុក្ខ រមែងបដិបត្តិក្នុងហេតុ មិនបានបដិបត្តិក្នុងផលទេ ចំណែកតិរ្ថិយទាំងឡាយ មានការប្រព្រឹត្តស្មើដោយសុនខ គេប្រាថ្នារលត់ទុក្ខ និង សម្តែងពីការរលត់ទុក្ខ រមែងបដិបត្តិក្នុងផល សម្តែងអត្តកិលមថានុយោគជាដើម មិនបានបដិបត្តិក្នុងហេតុ ដោយប្រការយ៉ាងនេះ ។

ប្រយោជន៍នៃការសម្តែងការរលត់ទុក្ខ ដោយអំណាចនៃការរលត់សមុទ័យ បណ្ឌិតគប្បីជ្រាបដូច្នេះសិន ។

សេចក្តីតទៅនេះ ជាអត្ថនៃបាលីទុក្ខនិរោធ , ពាក្យថា **តស្សាយេវ តណ្ហាយ** មានន័យថា នៃតណ្ហាដែលព្រះមានព្រះភាគត្រាស់ថា ( លក្ខណៈ ) ថា " **បោនោព្ភវិកា** - មានការសាងភពថ្មីទៀត ជាប្រក្រតី " ជាដើម ហើយ

ទ្រង់ចែកដោយប្រភេទ មានកាមតណ្ហាជាដើមនោះ ។

**មគ្គ** ឈ្មោះថា **វិរាគ** - ការនាំចេញ ព្រោះព្រះបាលីថា **វិរាគា វិមុច្ចតិ** - រមែងរួចផុតព្រោះវិរាគៈ , ការរលត់ដោយការនាំចេញ ឈ្មោះថា **វិរាគនិរោធ** , ការរលត់ដោយការនាំចេញមិនមានសល់ ព្រោះដកចេញនូវអនុស័យ ឈ្មោះថា **អសេសវិរាគនិរោធ** , ន័យម្យ៉ាងទៀត ការលះបង់ ក៏ហៅថា **វិរាគ** ព្រោះដូច្នោះ ក្នុងបទថា **អសេសវិរាគនិរោធោ** នេះ បណ្ឌិតគប្បីឃើញថា ប្រកបសេចក្តីថា " ការលះបង់មិនមានសេសសល់ ការរលត់មិនមានសល់ " ដូច្នេះក៏បាន , តែដោយខ្លឹមសារពិត បទទាំងពួងនោះ ជាវេវចនៈនៃនិព្វាននោះឯង ព្រោះព្រះនិព្វាន ព្រះមានព្រះភាគត្រាស់ហៅថា **ទុក្ខនិរោធអរិយសច្ច** , ដោយបរមត្ថ ហេតុណាដែលតណ្ហាត្រូវលះបង់បាន និងរលត់ទៅបាន ក៏ព្រោះអាស្រ័យព្រះនិព្វាននោះ ជាអារម្មណ៍ ព្រោះហេតុនោះ ព្រះនិព្វាននោះ ទើបទ្រង់ត្រាស់ ហៅថា **វិរាគ** និងថា **និរោធ** ផង , ម្យ៉ាងទៀត ហេតុណា ដែលធម៌ទាំងឡាយ មានការរលាស់ចោលនូវតណ្ហានោះជាដើម រមែងមានប្រាកដបានក៏ព្រោះអាស្រ័យព្រះនិព្វាននោះ ហើយពោលចំពោះបណ្តាអាល័យជាដើម មានកាមគុណាល័យជាដើម អាល័យសូម្បីតែមួយ ក៏មិនមានក្នុងព្រះនិព្វាននោះ ព្រោះហេតុនោះ ព្រះនិព្វាននោះ ទើបទ្រង់ត្រាស់ហៅថា **ចាគ បដិនិស្សគ្គ មុត្តិ អនាលយ** ។

ព្រះនិព្វាននោះ មានសេចក្តីស្ងប់ ជាលក្ខណៈ , មានការមិនប្រែប្រួលជាកិច្ច ឬថា មានការធ្វើឱ្យស្រឡះចិត្ត ជាកិច្ច , មានការមិនមាននិមិត្ត ( គឺមិនមានគ្រឿងសម្គាល់នៃទុក្ខ ) ជាអាការប្រាកដ ឬថា មានការមិនមានគ្រឿង

ស្អិត លាបលនចិត្ត ជាអាការប្រាកដ ។

មហាដីកា : បទថា **តស្សាយេវ** មានន័យថា តណ្ហា ទ្រង់ត្រាស់ហៅថា **សមុទយសច្ច** ដោយចំណែកណា ចុះអវធារណៈថា **តស្សេវ** ដោយចំណែកនោះ ។ កាលមានការរលត់ហេតុដែលជាប្រធាន ហេតុដទៃ ក្រៅពីហេតុដែលជាប្រធាននោះ ក៏ត្រូវរលត់ទៅផងដែរ ព្រោះដូច្នោះ ការរលត់ផលក៏ដោយការរលត់ហេតុ ដូចការចូលទៅរម្ងាប់រោគ គប្បីមានបាន ក៏ដោយការចូលទៅរម្ងាប់ហេតុនៃរោគ ព្រោះដូច្នោះ ទើបលោកអាចារ្យពោលថា " ការរលត់ទុក្ខទៅបាន ក៏ដោយការរលត់សមុទយៈ " ។ ពាក្យថា **មិនមែនដោយប្រការដទៃ** លោកអាចារ្យសម្ដែងដល់ផល តាមដែលបានពោលទុកហើយប្រព្រឹត្តទៅតែម្យ៉ាង ។

ពាក្យថា **មិនមានអន្តរាយ** គឺ វៀរចាកអន្តរាយ មានសត្វល្អិត ១ ចោះរន្ធ និង ការទម្លាយដោយសស្ត្រាជាដើម ។ ព្រោះហេតុនោះឯង ឈ្មោះថា **មាំទាំ** គឺ គ្មានទីបំផុត ។ សូម្បីត្រូវកាត់ដោយការលួសស្លឹកជាដើម ។ ពាក្យថា **កាលតណ្ហានុស័យ** បានដល់ កាមរាគានុស័យ និង ភវរាគានុស័យ ។ ពាក្យថា **នៅមិនទាន់ត្រូវដកឡើង** គឺ នៅមិនទាន់ភើចកន្ត្រាក់ឡើង ដោយដាច់ខាត ។

លោកអាចារ្យ ពោលពាក្យមានជាដើមថា " មានការប្រព្រឹត្តស្មើដោយសីហៈ " ដូច្នេះ កាលនឹងសម្ដែងសេចក្ដីប្រការនេះថា ឧបមាដូចសីហៈកាលបុគ្គលកាន់កូនសរចូលទៅកាន់ទីនៅរបស់ខ្លួន ក៏សម្ដែងកម្លាំងរបស់ខ្លួនក្នុងបុគ្គលនោះប៉ុណ្ណោះ មិនសម្ដែងកម្លាំងក្នុងកូនសរឡើយ , ព្រះពុទ្ធទាំង-

ឡាយ ក៏ទ្រង់បដិបត្តិក្នុងហេតុ មិនមែនបដិបត្តិក្នុងផល ក៏ដូច្នោះដែរ ។ រីឯពួកសុនខ កាលគេគប់ដោយដុំដី ក៏ព្រុសដុំដី មិនបានព្យាយាមទៅរកបុគ្គលអ្នកគប់ យ៉ាងណា ពួកអន្យតិរ្ថិយក៏ដូច្នោះ មានបំណងនឹងរំលត់សេចក្តីទុក្ខ ក៏ខ្វល់ខ្វាយក្នុងការធ្វើឱ្យលំបាកកាយ មិនខ្វល់ខ្វាយក្នុងការរំលត់កិលេស ។

**មគ្គ** ហៅថា **វិរាគ** ព្រោះអត្ថថា ជាហេតុឱ្យសម្រក គឺ ទម្លាយសមុទ័យ ។ ការសម្រក ការទម្លាយ ការលះបង់ដាច់ជាសមុច្ឆេទ ឈ្មោះថា **វិរាគ** , បហានៈ ឈ្មោះថា **វិរាគ** ។ ពាក្យថា **ព្រោះហេតុនោះ** មានន័យថា **វិរាគ** ស័ព្ទ និង **និរោធ** ស័ព្ទ ជាបរិយាយនៃ **បហានៈ** ព្រោះហេតុណា ព្រោះហេតុនោះ ពាក្យដែលគប្បីនឹងភ្ជាប់គ្នាថា ការសម្រកមិនឱ្យមានសល់ ការរំលត់មិនឱ្យមានសល់ ព្រោះការដកចេញនូវអនុស័យបានដោយដាច់ខាតហើយ ។ លោកអាចារ្យកាន់យកបទថា ចាគៈជាដើម ពោលថា ពាក្យទាំង-ឡាយនេះ ទាំងអស់ ។

ព្រោះលោកពោលដល់ **និព្វាន** មិនមែនពោលចំពោះតែការរលត់ទុក្ខនោះទេ ដូច្នោះ សូម្បីបទថា **ការរលត់** គឺ ការលះបង់មិនមានសល់នៃតណ្ហាក៏ជាវេវចនៈនៃ **ព្រះនិព្វាន** ។ បទថា **យស្មា បន** ជាដើម ជាពាក្យធ្វើខ្លឹមសារដែលបានពោលហើយនេះឯង ឱ្យជាក់ច្បាស់ , ជាពាក្យសម្តែងដល់ប្រការដែលបទថា **វិរាគ** ជាដើម ប្រើនៅក្នុងនិព្វាន ។ ពាក្យថា **ព្រោះអាស្រ័យនិព្វាននោះ** គឺ ព្រោះសម្រេចនិព្វាននោះ ដោយអំណាចការធ្វើឱ្យជាអារម្មណ៍។ ពាក្យថា **តណ្ហា រមែងវិនាសទៅ** មានន័យថា តណ្ហារមែងត្រូវអរិយមគ្គធ្វើឱ្យវិនាសទៅ ដោយអំណាចការកាត់ផ្តាច់ទៅ ជាសមុច្ឆេទ ។

ពាក្យថា **រមែងរលត់ទៅ** គឺ រមែងត្រូវអរិយមគ្គ ធ្វើឱ្យរលត់ទៅ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលនូវ **វិរាគ** ស័ព្ទ និង **និរោធ** ស័ព្ទ ជាអធិករណសាធនៈ ។ បទថា **តទេវ** ប្រែថា និព្វាននោះឯង ។ ពាក្យថា **ធម៌ទាំងឡាយ មានការលះជាដើម រមែងមាន** នេះលោកអាចារ្យពោលដល់ហេតុ មានការលះជាដើម ដោយវោហារថា ជាផល ។ ក្នុងគម្ពីរទាំងឡាយ ចារឹកទុកថា **កាមគុណាលយេសុ** តែបាឋៈថា **កាមគុណាលយាទីសុ** ។

ពាក្យថា **តយិទំ** ជាដើម មិនមែនបាឋៈចាស់ទេ តែបាននាំមកពីទីនោះ តាំងទុកជាខាងក្រោយ តាមទំនងដែលបានពោលទុក ក្នុងពេលដែលសម្តែងអត្ថន័យនៃសច្ចៈ ។ ពិតហើយ ប្រការផ្សេងៗ មានលក្ខណៈជាដើម សូម្បីបានពោលទុកជាខាងដើម លោកក៏បានពោលម្តងទៀត ។ ពាក្យថា **មានការធ្វើឱ្យស្រឡះចិត្ត** ជាកិច្ច ព្រោះដូចជាបុគ្គលធ្វើឱ្យស្រឡះចិត្ត ដល់បុគ្គលដែលមានចិត្តនឿយណាយចាកសង្សារទុក្ខ ។ ឈ្មោះថា **ជាធម្មជាតិមិនមានគ្រឿងស្អិតលាបលនចិត្ត ជាអាការប្រាកដ** ព្រោះញុំាងធម្មជាតិដែលមិនយឺតយូរឱ្យចូលទៅប្រាកដដោយចំពោះ ដោយភាវៈ ជាហេតុចូលទៅស្ងប់ធម៌ដែលជាហេតុឱ្យយឺតយូរទាំងពួង មានរាគៈជាដើម ។

ពាក្យថា **និព្វានមិនមាន** មានន័យថា ការដែលគ្រប់គ្នា ដឹងដោយសាមញ្ញ សូម្បីនិព្វានដែលខ្លួនប្រាថ្នា ក៏មិនមាន , បើដូច្នោះ ក៏ខុសពីការដែលត្រូវដឹង ។ បើសម្លឹងដល់និព្វាន ដែលអ្នកដទៃនាំគ្នាយល់នោះ , បើដូច្នោះ នឹងជាការដែលសម្រេចមិនត្រឹមត្រូវតាមធម៌ និង ព្រោះហេតុនោះ ក៏មិនបានសម្រេចនូវធម៌ដែលជាទីអាស្រ័យ។ ពាក្យថា **ព្រោះជាវត្ថុដែលរកមិនបាន** មាន

ន័យថា ជាវត្ថុដែលរកមិនបាន ដោយការប្រចក្ស ឬថា ដោយអនុមាន ? ជាខាងដើម ជាការមាន តែមិនមែនមានក្នុងផ្លូវចក្ខុទ្វារជាដើម , ផ្នែកទី ២ ជាហេតុ ដែលមិនអាចសម្រេចបានដោយសារអ្នកដទៃ ។

ព្រោះហេតុនោះ លោកអាចារ្យទើបពោលពាក្យ មានជាអាទិថា " **មិនមែនមិនមាន** " ព្រោះព្រះនិព្វាន គប្បីសម្រេចបានដោយឧបាយ ។ ក្នុងពាក្យនោះ មានឧបមាថា ព្រះអរិយបុគ្គលទាំងឡាយ ដែលមានចេតោបរិយញ្ញាណប៉ុណ្ណោះ រមែងដឹងលោកុត្តរចិត្តរបស់ព្រះអរិយៈដទៃ , សូម្បីក្នុងព្រះអរិយៈទាំងឡាយនោះ ព្រះអរហន្តប៉ុណ្ណោះ ទើបដឹងលោកុត្តរចិត្តរបស់ព្រះអរិយៈទាំងអស់ មិនមែនដឹងគ្រប់ព្រះអរិយៈទាំងអស់នោះទេ , សេចក្តីនេះ យ៉ាងណា សូម្បីព្រះនិព្វានក៏ដូច្នោះ រមែងសម្រេចបានដោយឧបាយដែលជាសម្មាបដិបត្តិ គឺ សីល សមាធិ បញ្ញា ព្រោះដូច្នោះ ប្រការនេះ គប្បីឃើញថា ជាពាក្យដែលសម្តែងដល់ន័យ មិនមែនជាពាក្យសម្តែងដល់ប្រយោគនោះទេ ។ ពាក្យនោះនឹងមានច្បាស់ខាងមុខ ។

ប្រការថា នរណា ៗ ក៏មិនអាចពោលថា **និព្វានមិនមាន** អធិប្បាយថា ព្រះនិព្វានដែលព្រះអរិយបុគ្គលគប្បីបាន ន័យនេះសម្រេចដោយសន្និទាំងអស់ថា បុគ្គលទាំងអស់ដែលមានចិត្តរួចស្រឡះហើយ ចាកសង្សារវដ្ត រមែងសម្រេចនិព្វានបាន ដោយសម្មាបដិបត្តិ ។ ក្នុងពាក្យឆ្លើយនោះ លោកអាចារ្យពោលថា ព្រោះការបដិបត្តិដទៃនឹងជាមោឃៈ , ត្រូវអាស្រ័យតែការបដិបត្តិនៅក្នុងព្រះសាសនានេះប៉ុណ្ណោះ , ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យមានជាអាទិថា **កាលនិព្វានមិនមាន** ដូច្នេះ ។

បទថា **សម្មាទិដ្ឋិបុរេជវាយ** ប្រែថា មានសម្មាទិដ្ឋិជាខាងដើម ។ ការដែលសម្មាទិដ្ឋិនោះ ជាខាងដើម ព្រោះសម្មាទិដ្ឋិនោះ ជាប្រធាន ។ ពិតហើយ សម្មាទិដ្ឋិនោះ ព្រះមានព្រះភាគ ទ្រង់លើកឡើងកាន់ទេសនាមុន , មិនមែនដោយសារកើតមុនធម៌ទាំងអស់ទេ ។ ម្យ៉ាងទៀត សម្មាបដិបត្តនឹងជាមោឃៈ មិនមាន ព្រោះធ្វើឱ្យដល់ព្រះនិព្វាន គឺ ព្រោះញ៉ាំងព្រះនិព្វានឱ្យដល់ព្រម ។ មានពាក្យប្រកបថា បើតាមមតិរបស់អ្នកនឹងត្រូវជាមោឃៈ ព្រោះព្រះនិព្វាននោះ មិនមាន ។

ពាក្យថា **ព្រោះធ្វើឱ្យដល់នូវការមិនមាន** អធិប្បាយថា លោកអាចារ្យអ្នកសួរ គប្បីពោលថា ព្រោះការដែលសម្មាបដិបត្តិ ជាកិរិយាឱ្យដល់ព្រមនូវការមិនមាននៃខន្ធទាំងឡាយ ដោយការលះបង់កិលេសបានជាសមុច្ឆេទជាសំខាន់ , មិនមែនជាមោឃៈនោះទេ ។ ស័ព្ទថា **ន** ប្រព្រឹត្តទៅក្នុងការបដិសេធ , គឺថាប្រការណាដែលលោកពោលថា ព្រោះការបដិបត្តិធ្វើឱ្យដល់នូវការមិនមាន ដូច្នេះ ក៏ព្រមទទួលថា ការមិនមានខន្ធ ឈ្មោះថា **និព្វាន** , សេចក្ដីនោះមិនមែនទេ ព្រោះការមិនមានខន្ធជាអតីត និង ខន្ធជាអនាគត ការសម្រេចនិព្វាន ក៏មិនមាន ។

ពិតហើយ ខន្ធដែលជាអតីត និង អនាគត រមែងមិនមាន ព្រោះដូច្នោះ **និព្វាន** ក៏គប្បីឈ្មោះថា បានសម្រេចហើយ ព្រោះការមិនមាននោះ តែការមិនមាននោះ ក៏រមែងមិនមាន ។ មិនមែនចំពោះតែខន្ធដែលជាអតីត និងអនាគតម្យ៉ាងប៉ុណ្ណោះទេ , ដោយពិត សូម្បីខន្ធជាបច្ចុប្បន្នផង ព្រោះដូច្នោះ ការមិនមានខន្ធទាំងអស់ មានក្នុងអទ្ធាទាំង ៣ ទើបឈ្មោះថា **និព្វាន** ។ ពិតហើយ

និព្វាននោះ សមគួរជាការមិនមាន គ្រាន់តែជាចំណែកខ្លះ ក៏មិនមែន ព្រោះដូច្នោះ បើមានបច្ចុប្បន្នខន្ធ នឹងមិនមាន ក៏មិនមែន , បើថា មិនមាន គឺ មិនមានបច្ចុប្បន្នខន្ធ ព្រោះដូច្នោះ ប្រការថា " បច្ចុប្បន្នខន្ធផង និងថា មិនមានផង " ទើបជាប្រការដែលខ្វែងគ្នា ព្រោះដូច្នោះ ទើបអាចារ្យអ្នកឆ្លើយ ពោលថា " មិនមែន ព្រោះបច្ចុប្បន្នខន្ធទាំងនោះ ក៏មិនមាន ការមិនមាន ហើយកាលមិនមាននឹងជាបច្ចុប្បន្នខន្ធមិនបាន " ។

នឹងពោលបន្ថែមបន្តិចទៀតថា បើការមិនមានបច្ចុប្បន្នខន្ធ ជានិព្វានសោត , ការមិនមាននិព្វាន ក៏នឹងគប្បីមានក្នុងកាលនោះ ព្រោះអធិប្បាយថា អរិយមគ្គប្រព្រឹត្តទៅក្នុងកាលណា ខន្ធដែលជាទីអាស្រ័យរបស់អរិយមគ្គនោះក្នុងកាលនោះ គឺ ជាខន្ធបច្ចុប្បន្ន , លោកអាចារ្យកាលនឹងសម្តែងថា កាលបើដូច្នោះ ការធ្វើឱ្យជាក់ច្បាស់នូវនិព្វានក្នុងខណៈនៃមគ្គ ក៏ត្រូវមិនមាន ទើបពោលថា " ព្រោះនឹងត្រូវមិនមានការសម្រេចសឧបាទិសេសនិព្វានធាតុ ក្នុងខណៈនៃមគ្គដែលអាស្រ័យបច្ចុប្បន្នខន្ធ " ។

ខ្ញុំម្ចាស់ទើបពោលចំពោះព្រះនិព្វាន ព្រោះខន្ធទាំងឡាយ មិនមានជាបច្ចុប្បន្ន ក៏មិនមែន , បើមានពាក្យសួរថា ព្រោះហេតុអ្វី ? ក៏មានពាក្យឆ្លើយថា ព្រោះកិលេសមិនកើតឡើងក្នុងពេលនោះ គឺ ក្នុងខណៈនៃមគ្គ , ទើបតទៅនឹងមិនទាស់គ្នា គឺ មិនមានការជំទាស់គ្នាក្នុងពាក្យតាមដែលពោលហើយ ។ ព្រោះហេតុដូច្នោះ ប្រការនេះ ឆ្លើយថា បើការមិនមាន ពោលគឺ ការដែលកិលេសមិនកើតឡើង ជានិព្វានសោត , កាលបើយ៉ាងនេះ អរិយមគ្គក៏ទៅជាគ្មានប្រយោជន៍ ព្រោះមុនខណៈនៃមគ្គ ក៏សម្រេច ក៏មិនមាននៃកិលេសនោះ

ដោយហេតុនោះ ទើបលោកអាចារ្យពោលថា " អរិយមគ្គ ក៏គ្មានប្រយោជន៍ " ដូច្នេះជាដើម ។

ពាក្យថា **ព្រោះហេតុនោះ ប្រការនេះ ទើបមិនមែនហេតុដែលគួរ** មានន័យថា ព្រោះនិព្វានជាវត្ថុដែលមិនមាន ក៏មិនមែន ព្រមទាំងការបដិបត្តិនឹងជាមោឃៈ ក៏មិនមែន និង កាលមិនមានខន្ធដែលជាអតីត និង អនាគតនឹងត្រូវសម្រេចនិព្វាន ក៏មិនមែន ទាំងការមិនមានខន្ធសូម្បីជាបច្ចុប្បន្ន ក៏មិនសម្រេច នឹងពោលទៅថ្វី ដល់ការដែលកិលេសមិនកើតឡើង ដូច្នោះ អរិយមគ្គនឹងត្រូវគ្មានប្រយោជន៍ , សេចក្តីនេះ យ៉ាងណា **ដែលលោកពោលថា ព្រោះនិព្វានជាវត្ថុដែលរកមិនបាន ព្រោះការបដិបត្តធ្វើឱ្យដល់នូវការមិនមាន និង ព្រោះកិលេសមិនកើតឡើងក្នុងពេលនោះ** ដើម្បីនឹងឱ្យសម្រេចនូវការមិនមាននៃនិព្វាន ព្រោះហេតុនេះ មិនមែនជាហេតុដែលសមគួរ អធិប្បាយថា ប្រការនេះមិនសមគួរ ។

ដោយ **អាទិ** សព្ទ ក្នុងពាក្យថា **អាទិវចនតោ** លោកអាចារ្យរួមយកនូវចំណែកខ្លះនៃជម្ពុខាទកសូត្រដ៏សេស , និងរួមយកទាំងព្រះបាលីដែលជានិទ្ទេសនៃអសង្ខតធាតុដទៃ ។ ពិតហើយ ព្រះធម្មសង្គាហកាចារ្យ ពោលទុកក្នុង **ជម្ពុខាទកសូត្រ** ថា ជម្ពុខាទកបរិព្វាជក សួរថា ម្នាកអាវុសោ សារីបុត្ត ពាក្យដែលលោកពោលថា **និព្វាន និព្វាន** ដូច្នេះ , ម្នាលអាវុសោ តើនិព្វាននោះដូចម្តេច ? ព្រះសារីបុត្តឆ្លើយថា ម្នាលអាវុសោ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ឯណា នេះហៅថា **និព្វាន** , ព្រះមានព្រះភាគ ក៏ត្រាស់ទុកក្នុងអាយតនវិភង្គថា ក្នុងប្រការនោះ អសង្ខតធាតុ តើដូចម្តេច ? គឺ ការអស់រាគៈ

ការអស់ទោសៈ ការអស់មោហៈ ។

ក្នុងព្រះបាលីនោះ មានខ្លឹមសារដូចតទៅនេះ គឺ **និព្វាន** បានដល់ អសង្ខតធាតុ គឺ ធម៌ដែលមានសភាវៈបច្ចុប្បន្ន តាក់តែងមិនបាន ។ ព្រោះ កិលេស មានរាគៈជាដើមត្រូវរលត់ទៅ កាលមកដល់ព្រះនិព្វាននោះ ព្រោះ ហេតុនោះ **និព្វាន** ហៅថា **រាគក្ខយោ** - ការអស់នូវរាគៈ , ថា **ទោសក្ខយោ** - ការអស់នូវទោសៈ និងថា **មោហក្ខយោ** - ការអស់នូវមោហៈ ។ ឯពាក្យថា **ព្រោះមកដល់** មានន័យថា ព្រោះធ្វើឱ្យជាក់ច្បាស់ដោយមគ្គ នូវអរហត្តផង ដែលគោត្រភូបើកឱ្យហើយ ក្នុងការនឿយណាយចាកសង្ខារទាំងពួង បង្អោន ទៅក្នុងវិសង្ខារ ។

ពិតហើយ **មគ្គ** ដែលហៅថា **ខយ** គឺ ការអស់ទៅ រមែងញ៉ាំងកិលេស មានរាគៈជាដើម ឱ្យវិនាសទៅ ព្រោះបានសម្រេចនូវព្រះនិព្វាននោះ ដែល ការកបុគ្គលធ្វើឱ្យជាក់ច្បាស់ គឺ ព្រោះអាស្រ័យនិព្វាននោះ ជាអារម្មណប្បច្ច័យ និង ព្រោះតាំងនៅដោយចំពោះ ក្នុងនិព្វាននោះ ដែលជាអធិបតិប្បច្ច័យ គឺ ជាទីអាស្រ័យ ដោយភាវៈជាការស្រឡះផ្លូវផង់នៃចិត្តដ៏កំពូល និង ជាបដិបទាដ៏ កំពូល របស់អ្នកដែលមានការរួចស្រឡះហើយចាកសង្ខារ ព្រោះហេតុនោះ កិលេស មានរាគៈជាដើម ទើបលោកពោលថា រមែងអស់ទៅ , ប្រសិនបើ មិនមានការធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាននោះ ការដល់នូវការរលត់ គឺការកើត ឡើងមិនបាននៃកិលេស មានរាគៈជាដើម ក៏មិនមាន ។

និព្វាននេះ បណ្ឌិតអះអាងយ៉ាងនេះ ដោយដាច់ខាត កាលកាន់យកខ្លឹម សារនៃព្រះបាលី ដោយប្រការផ្សេងនោះ ទាក់ទងនឹងពាក្យសួរដែលបានពោល

ហើយ គឺ មានប្រភេទច្រើនយ៉ាង ព្រោះដូច្នោះ លោកអាចារ្យបំណងសម្ដែងប្រការទាំងឡាយនោះ ទើបពោលពាក្យមានជាអាទិ៍ថា " មិនមែនព្រោះព្រះអរហត្ត ដែលគ្រាន់តែជាការអស់ទៅប៉ុណ្ណោះទេ " ពិតហើយ **អរហត្ត** បានដល់ខន្ធទាំង ៤ ដែលមានផលដ៏លើស ជាបរមសុខ ព្រោះដូច្នោះ ការដែលអរហត្តផលនោះ ត្រឹមតែជាការអស់ទៅនៃកិលេស មានរាគៈជាដើម នឹងសមគួរ ក៏មិនមែន ។

ពិតហើយ អរហត្តនោះ លោកបានសម្ដែងអធិប្បាយទុកក្នុងន័យ មានជាអាទិ៍ថា " ម្នាលអាវុសោ ការអស់រាគៈឯណា " ដូច្នេះ ។ ក្នុងពាក្យរបស់លោកអាចារ្យទាំងឡាយនោះ ការដែលព្រះសូត្រ មានអត្ថគប្បីដឹងថា **អរហត្ត** លោកសម្ដែងអធិប្បាយក្នុងន័យមានជាអាទិ៍ថា " **រាគក្ខយោ** " ព្រោះជាគុណ-ជាតិកើតឡើង ក្នុងទីបំផុតនៃកិលេស មានរាគៈជាដើម បានរលត់អស់ទៅហើយ , សេចក្ដីនេះយ៉ាងណា , គប្បីជ្រាប សេចក្ដីនៃព្រះសូត្រនេះ មានអត្ថគប្បីដឹងបានថា **និព្វាន** លោកសម្ដែងអធិប្បាយទុក ក្នុងន័យ មានជាដើមថា " **រាគក្ខយោ** " ព្រោះកិលេស មានរាគៈជាដើមរលត់ទៅ កាលដែលមកដល់ព្រះនិព្វាន ក៏ដូច្នោះ ។ លោកអាចារ្យបំណងនឹងសម្ដែងថា **និព្វាន** មានប្រការជាច្រើន ព្រោះត្រឹមតែការអស់កិលេស មានរាគៈជាដើម ទើបផ្ដើមពាក្យ មានជាអាទិ៍ថា " នៅមានពាក្យដែលគួរពោលឱ្យក្រៃលែងឡើងបន្តិចទៀត " ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ ពាក្យថា **ព្រោះនិព្វាន មានប្រការទាក់ទងដល់ភាពជាធម្មជាតិមានកាលខ្លី** មានអធិប្បាយថា ព្រោះនិព្វានត្រូវមានប្រការ ជាដើមយ៉ាងនេះថា គឺជាធម្មជាតិមានកាលខ្លី ១ ជាធម្មជាតិមាន

លក្ខណៈជាសង្ខត ១ ជាធម្មជាតិវៀរចាកសេចក្តីកង្វល់មួយ ក៏ត្រូវសម្រេចបាន ដោយសភាពត្រឹមប៉ុណ្ណោះ ១ ជាធម្មជាតិដែលមិនផុតចាកកិលេស មានរាគៈជាដើម ១ ជាធម្មជាតិត្រូវភ្លើង មានរាគៈជាដើម ជាប់តាមហើយ ១ ជាទុក្ខ ១ ជាធម្មជាតិមិនចូលទៅស្ងប់ ១ មានច្រើន ១ ជាធម្មជាតិគ្រោតគ្រាត ១ មិនជាអារម្មណ៍របស់គោត្រភូ និង មគ្គ ១ ព្រោះត្រឹមតែការអស់ទៅនៃកិលេស មានរាគៈជាដើមប៉ុណ្ណោះ , ការអស់ទៅនៃរាគៈតែម្យ៉ាង ឈ្មោះថា **រាគក្ខយោ** , មិនមែនជាការអស់ទៅនៃកិលេស មានទោសៈជាដើមនោះទេ ។ សូម្បីការអស់ទៅនៃទោសៈជាដើម ក៏ដូចគ្នា ព្រោះដូច្នោះ ការអស់ទៅនៃទោសៈម្យ៉ាង ការអស់ទៅនៃមោហៈ ក៏ម្យ៉ាង ព្រោះហេតុនោះ **និព្វាន** គប្បីមាន ៣ យ៉ាង ដែលជាការអស់ទៅនៃអកុសលមូលទាំង ៣ , មាន ៤ យ៉ាង ព្រោះការអស់ទៅនៃឧបាទាន ៤ , មាន ៥ យ៉ាង ព្រោះការអស់ទៅនៃនីវរណៈ ៥ , មាន ៦ យ៉ាង ព្រោះការអស់ទៅនៃកងតណ្ហាទាំង ៦ , មាន ៧ យ៉ាង ព្រោះការអស់ទៅនៃអនុស័យ ៧ , មាន ៨ យ៉ាង ព្រោះការអស់ទៅនៃមិច្ឆត្តៈ ៨ , មាន ៩ យ៉ាង ព្រោះការអស់ទៅនៃតណ្ហាមូលកៈ ៩ , មាន ១០ យ៉ាង ព្រោះការអស់ទៅនៃសំយោជនៈ ១០ , និព្វាននឹងមានតែម្យ៉ាង ៗ ព្រោះការអស់ទៅនៃកិលេស ១៥០០ ព្រោះដូច្នោះ និព្វាននឹងមានច្រើន ។

ធម្មតាថា ការអស់រាគៈជាដើម ប្រាកដច្បាស់សូម្បីដល់បុគ្គលល្ងង់ខ្លៅ , ដោយទីបំផុត សូម្បីសត្វតិរច្ឆាន មានខ្លា ម្រឹគ និង ស្វាជាដើម អាចដឹងច្បាស់បានងាយ ព្រោះដូច្នោះ ទើបជានិព្វានគ្រោតគ្រាត ។ ម្យ៉ាងទៀត ព្រោះការអស់កិលេស មិនមានក្នុងខណៈគោត្រភូ និង ព្រោះកិលេសមិនទាន់អស់

ទៅ សូម្បីក្នុងខណៈនៃមគ្គ ក៏មិនមានការធ្វើនិព្វានឱ្យជាអារម្មណ៍បាន ។

ពាក្យថា **ព្រោះការអស់ទៅនោះ នឹងជានិព្វានផង** មានន័យថា ព្រោះការអស់កិលេស មានរាគៈជាដើម ដែលជាទីបំផុតនៃធម៌ទាំងពួង នឹងជានិព្វានដែរ , ចាប់តាំងពីការអស់ទៅណា ការប្រព្រឹត្តទៅនៃកិលេស មានរាគៈជាដើម រមែងមិនមាន , ការអស់ទៅនោះ គួរនឹងកំណត់ឱ្យប្រាកដថា " ឈ្មោះនេះ " ជាអារម្មណ៍នៃមគ្គញ្ញាណ និង ផលញ្ញាណ , ក៏មិនមាន , ព្រោះដូច្នោះ លោកអាចារ្យទើបពោលថា " មិនមែន , ព្រោះការអស់ទៅដូច្នោះ មិនមាន " ។

បើមានពាក្យគួរនឹងពោល ឱ្យក្រៃលែងឡើងបន្តិចទៀតថា បុគ្គលណាឃើញទោសក្នុងកិលេស មានរាគៈជាដើម ក្នុងអត្តភាពទី ៣ តែភពចុងក្រោយនោះ គ្របសង្កត់កិលេសទាំងឡាយនោះ ដោយឈានភាវនាហើយ មានឈានមិនវិនាស ស្លាប់ទៅហើយចូលដល់ព្រហ្មលោក នៅក្នុងព្រហ្មលោកនោះ រហូតអស់អាយុ សូម្បីមកក្នុងលោកនេះ ក៏ជាអ្នកប្រាសចាករាគៈ ក្នុងកាមទាំង-ឡាយ បួសហើយសម្រេចអរហត្ត , ម្យ៉ាងទៀត បុគ្គលណា នឿយណាយចាករាគៈជាដើម ក្នុងបឋមវ័យ ហើយគ្របសង្កត់រាគៈជាដើមទាំងឡាយនោះ ដោយឈាន និងសម្រេចអរហត្តក្នុងបច្ឆិមវ័យ ព្រោះកិលេសមានរាគៈជាដើមទាំងឡាយនោះ មិនកើតឡើងចាប់តាំងពីការគ្របសង្កត់ហើយ ការមិនកើតឡើងនោះឯង ឈ្មោះថា ជាការរលត់ ព្រោះដូចគ្នានឹងនិរោធ ។ បុគ្គលទាំង-ឡាយនោះ ក៏គួរបានឈ្មោះថា សម្រេចព្រះនិព្វាន , តែមិនមែនដូច្នោះទេ , ព្រោះដូច្នោះ ការអស់ទៅរបៀបនោះ ជានិព្វាន ក៏មិនមែន ។

សូម្បីការអស់ទៅនោះ ក៏ប្រកបទៅដោយប្រការ ជានិព្វានមានកាល

ខ្វីនោះឯង ដូច្នោះ ទើបលោកអាចារ្យពោលថា " ព្រោះកាលមានការអស់ទៅនោះ " ដូច្នេះជាដើម ។ ប្រសិនបើ ការមិនប្រព្រឹត្តទៅនៃកិលេស មានរាគៈជាដើម ចាប់តាំងតែពីការអស់ទៅណា ដោយព្រះបាលីថា " **ខយោ** " លោកក៏គប្បីសម្គាល់ថា ត្រឹមការអស់ទៅនោះ ថាជា **និព្វាន** បើជាយ៉ាងនេះ ចាប់តាំងពីការអស់ទៅនោះ កើតឡើង កិលេសមានរាគៈជាដើម ក៏មិនកើតឡើង ព្រោះលោកពោលទុកថា " **ខយោ** " ដូចក្នុងពាក្យថា " **ខយោ ញាណំ** " ញាណ គឺ ការដឹងក្នុងការអស់ទៅជាដើម ព្រោះដូច្នោះ លោកអាចារ្យកាលនឹងសម្តែងថា សូម្បីមគ្គក៏ជានិព្វានដែរ ដូច្នេះ ទើបពោលពាក្យជាដើមថា " និង ព្រោះអរិយមគ្គ " ដូច្នេះ ។

វត្ថុដែលរលត់ទៅហើយ រមែងមិនមាន យ៉ាងណា , សូម្បីវត្ថុដែលមិនកើតឡើងក៏ដូច្នោះ ព្រោះហេតុនោះ ការដែលមិនកើតឡើងនោះឯង ក៏ជាការរលត់ ព្រោះដូចគ្នានឹងនិរោធ គឺ ជាការមិនមានដូចគ្នា ទើបឈ្មោះថា **អនុប្បាទនិរោធ** ប្រែថា ការរលត់ គឺ ការមិនកើតឡើង ។ ពិតហើយ **អនុប្បាទ-និរោធ** នេះ ជាអាការនៃធម៌ដែលមគ្គ គប្បីធ្វើឱ្យអស់ទៅ គឺជាការធ្វើវត្ថុដែលគួរធ្វើឱ្យកើតឡើង ឱ្យដល់នូវការកើតឡើងមិនបានជាធម្មតា ព្រោះដូច្នោះ ទើបលោកពោលថា " **ខយោ** " ផង ។ លោកអាចារ្យ កាលនឹងធ្វើ **អនុប្បត្តិនិរោធ** នោះ ឱ្យផ្សេងពី " **ខយ** " នេះ ទើបពោលថា "ម្យ៉ាងទៀត ព្រះនិព្វាននេះ ជាឧបនិស្ស័យនៃ **ខយ** ដែលហៅថា **អនុប្បត្តិនិរោធ** " ។

លោកពោលថា និព្វាននេះ ជាអនិប្ផន្នធម៌ ព្រោះជាឧបនិស្ស័យដោយបរិយាយនៃ " **ខយ** " នោះ ។ ពិតហើយ និព្វានជាអារម្មណ៍នៃមគ្គ ដែលធ្វើនូវ

ការអស់ទៅ គឺ **អនុប្បត្តិនិរោធ** ដោយសេចក្តីថា រមែងបានភាវៈដែលគួរពោល ថា ដូចជាឧបនិស្ស័យនៃមគ្គនោះ ។ បទថា **តទុបចារេន** ប្រែថា ដោយការពោលដល់ " **ខយ** " ដែលជាផល ដោយអត្ថន័យ ។ ពិតហើយ **ហេតុ** លោកហៅដោយឧបចារវោហារដល់ **ផល** ។

បទថា **អស្ស យោគ និព្វានស្ស** ។ ព្រោះនាំមកនូវភាពខ្វាយខ្វល់តិចដល់ព្រះមានព្រះភាគ ដែលទ្រង់ពិចារណាឃើញថា ដោយន័យ មានជាអាទិ៍ថា " ឋានៈនេះឃើញបានដោយកម្រ " ។ ឈ្មោះថា គប្បីឃើញបានដោយចក្ខុដែលជាអរិយៈ ដូចមានព្រះបាលីថា ម្នាលមាគណ្ឌិយ អ្នកមិនមានចក្ខុជាអរិយៈ ដែលជាហេតុឱ្យអ្នកបានដឹង ភាពជាអ្នកមិនមានរោគ ឱ្យអ្នកបានឃើញនូវព្រះនិព្វាននោះ ។

លោកអាចារ្យពោលថា " និព្វានជាធម្មជាតិមិនទូទៅ ព្រោះអ្នកដែលមានការព្រមព្រៀងដោយមគ្គ ទើបសម្រេចបាន " កាលនឹងចិញ្ចឹមពាក្យសួរថា ប្រសិនបើ មានសភាវធម៌ និង ធម៌ដែលទាក់ទងនៅក្នុងសន្តានរបស់សត្វ ឈ្មោះថា និព្វានសោត , កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនមែនជាធម៌ដែលជាទូទៅ ដល់វត្ថុគ្រប់យ៉ាង ដូចជាទីប្រជុំ ក្នុងផ្លូវបែកជា ៤ ។ **និព្វាន** ឈ្មោះថា មិនមានដែនកើត ព្រោះមិនមានទីបំផុតខាងដើមយ៉ាងនេះថា **និព្វាន** កើតក្នុងកាលនៃព្រះសម្មាសម្ពុទ្ធ អង្គនោះ ។ ពាក្យថា **កាលមានមគ្គ** គឺ កាលមានអរិយមគ្គ ។ ព្រោះមាន គឺ ព្រោះមានប្រាកដ ព្រោះគប្បីបាន ។

ពាក្យថា **សភាវៈមានអណ្វជាដើម** បានដល់ សភាវៈ មានអណ្វ ប្រក្រតី កាល និង បុរស ជាដើម ។ ពាក្យថា **ត្រូវជាសេចក្តីទៀង** គឺ សម្រេចភាវៈដែល

ទៀង ។ ភាពជាសភាវៈទៀង ដែលជារបស់មុសា លោកសំដៅយកក្នុងទីនេះ ។ ពាក្យថា **ព្រោះមិនមានហេតុ** គឺ ព្រោះមិនមានហេតុដែលជាតួឱ្យសម្រេច នៃការចូលដល់ ។ **តេ យោគ អណុអាទយោ** ប្រែថា ភាវៈ មានអណូជាដើមទាំងនោះ ទៀង ។ ពាក្យថា **ព្រះនិព្វានជាធម្មជាតិទៀង** មានន័យថា មិនចូលដល់លក្ខណៈនៃហេតុ មានភាពជាធម៌ដែលមិនត្រូវមើលដោយភ្នែកជាដើម ។

ដោយពាក្យថា **ដោយសភាវៈ មានអណូជាដើម មិនសម្រិតផល** នេះ លោកអាចារ្យសម្តែងថា ប្រការដែលអះអាងថា សភាវៈមានអណូជាដើមទៀង មិនមានភាពសម្រិតដែលត្រឹមត្រូវ ព្រោះហេតុនោះឯង ទើបមិនជាហេតុដែលសម្រិតផល ដោយធម៌ដែលជាទីអាស្រ័យ ។

ពាក្យថា **ព្រោះមានភាពពាល់ត្រូវ តាមដែលបានពោលទុកហើយ** លោកអាចារ្យពោលដល់ហេតុដែលខ្លួនបានពោលទុកហើយ ព្រោះមិនមានដែនកើត ។ ភាពដែលព្រះនិព្វាននោះ មិនមានដែនកើត បណ្ឌិតគប្បីឃើញបាន ដោយភាវៈដែលនិព្វាននោះ មិនមានបច្ច័យ , ព្រោះភាវៈដែលនិព្វាននោះ មិនមានបច្ច័យ និព្វាននោះ ទើបមិនមានទីបំផុតខាងដើម ។ ពាក្យថា **ព្រោះឈានកន្លងនូវភាវៈនៃរូប** នេះលោកអាចារ្យសម្តែងថា រូបធម៌ទាំងឡាយ មានសភាវៈប្រែប្រួល និង មានសភាវៈដែលសម្ពន្ធជាមួយទីឋាន ព្រោះមានការប្រព្រឹត្តទៅជាកលាបៈ ព្រោះហេតុដែលអាចប៉ះខ្ទប់បាន សេចក្តីនេះយ៉ាងណា និព្វានមិនមានការប៉ះខ្ទប់ក្នុងទីណា ៗ និង ជាធម្មជាតិដែលមិនមានទីឋាន ក៏យ៉ាងនោះ។ ព្រោះថា **និព្វាន** ឈ្មោះថា នៅក្នុងទិសនោះ ឬថា នៅក្នុងទីឋាននោះ ដូច្នេះ មិនមាន ព្រោះនិព្វាននោះ មិនមានទីអាស្រ័យ នោះឯង ។

ដោយពាក្យថា **ព្រោះនិព្វាន គប្បីជាក់ច្បាស់បានដោយញាណពិសេសដែលសម្រេចដោយសេចក្ដីព្យាយាម មិនមែនតិចតួចឡើយ** នេះលោកអាចារ្យសម្ដែងដល់និព្វានជាធម្មជាតិដែលព្រះអរិយៈទាំងឡាយដឹងបានដោយប្រចក្ស ។

ពាក្យថា **ព្រោះព្រះតម្រាស់របស់ព្រះសព្វញ្ញូ** នេះលោកសម្ដែងដល់បុគ្គលដទៃ ក្រៅពីព្រះសព្វញ្ញូនោះ ដឹងបានដោយអនុមាន ( គឺ គិតដៅយក ) , ដោយពាក្យទាំង ២ នោះ លោកសម្ដែងដល់បទថា ព្រោះព្រះនិព្វានជាធម្មជាតិដែលរកមិនបាន ជាវត្ថុដែលដឹងមិនបានដោយហេតុ ។ **និព្វាន** មិនមានការកើតដោយបរមត្ថ តែមានដោយពិត ព្រោះដូច្នោះ លោកអាចារ្យទើបបញ្ជាក់សេចក្ដីតាមដែលបានផ្ដើមទុក ហើយសម្ដែងព្រះបាលីដែលជាទីមក ជាឧទាហរណ៍នៃសេចក្ដីប្រការនោះ ទើបពោលពាក្យមានជាដើមថា **វុត្តំហេតំ** ដូច្នេះ ។

ក្នុងបណ្ដាពាក្យទាំងឡាយនោះ បទទាំង ៤ គឺ **អជាតំ អភូតំ អកតំ អសង្ខតំ** ជាវេវចនៈនៃគ្នានិងគ្នា ។ ប្រការមួយទៀត **និព្វាន** ឈ្មោះថា **អជាតំ** ព្រោះមិនកើតទៀត គឺ មិនកើតឡើងព្រោះការដល់ព្រមនៃហេតុ ពោលគឺ ការព្រមព្រៀងនៃហេតុបច្ច័យ ដូចជាវេទនាជាដើម ។

និព្វានវៀរចាកហេតុ ក៏មិនមាន គឺ មិនប្រាកដ មិនមានដោយឯកឯងដូចគ្នា ព្រោះដូច្នោះ ទើបឈ្មោះថា **អភូតំ** ប្រែថា មិនកើតទៀត ។ ព្រោះមិនកើតយ៉ាងនេះ និង ព្រោះមិនមានយ៉ាងនេះ និព្វានទើបមិនមានហេតុណាមួយធ្វើឱ្យកើតឡើង ព្រោះដូច្នោះ ទើបឈ្មោះថា **អកតំ** ប្រែថា មិនមានហេតុណាមួយ ធ្វើឱ្យកើតឡើង ។ លោកពោលថា **អសង្ខតំ** ដើម្បីនឹងសម្ដែងថា ដែលឈ្មោះថា ភាពជាធម្មជាតិកើត ( មានជីវិត ) រស់នៅ និង ហេតុណាមួយធ្វើ

ឡើង រមែងមានបានចំពោះសង្ខតធម៌ទាំងឡាយ មានរូបជាដើម , តែមិនមែនមានចំពោះនិព្វានដែលមានសភាវៈជាអសង្ខតនោះទេ ។

ម្យ៉ាងទៀត ពោលដោយបដិលោម គឺ បញ្ច្រាស់លំដាប់ , ធម្មជាតិឈ្មោះថា **សង្ខតំ** ព្រោះបច្ច័យទាំងឡាយមកប្រជុំ គឺ រួមគ្នាធ្វើឡើង , តែនិព្វានឈ្មោះថា **អសង្ខតំ** ដែលបច្ច័យទាំងឡាយមិនបានធ្វើឡើង ព្រោះអត្ថថា មិនត្រូវបច្ច័យណាមួយ ធ្វើឡើងយ៉ាងនោះ និង ព្រោះអត្ថថា វៀរចាកសង្ខតលក្ខណៈ ព្រោះហេតុនោះ កាលនឹងយល់ថា **និព្វាន** ជាធម្មជាតិដែលហេតុជាច្រើនធ្វើឱ្យកើតឡើងយ៉ាងនេះ ទើបព្រះសព្វញ្ញូត្រាស់ថា **អកតំ** ដើម្បីនឹងសម្ដែងថា មិនត្រូវហេតុណាមួយធ្វើឡើង , កាលមានសេចក្ដីសង្ស័យថា " និព្វាននេះ គង់មានហេតុណាមួយធ្វើឡើង ដូចជាប្រក្រតី របស់ពួកលទ្ធិប្រក្រតីទាំងឡាយ ឬហ្ន៎ " ។

និព្វាន សូម្បីជាធម្មជាតិមិនមានបច្ច័យ យ៉ាងនេះ ព្រះសព្វញ្ញូ ក៏ត្រាស់ថា **អភូតំ** ដើម្បីនឹងទ្រង់បដិសេធនិព្វាននោះ ក្នុងកាលមានសេចក្ដីសង្ស័យថា " និព្វាននេះកើតហើយ ប្រាកដហើយឯកឯង ឬហ្ន៎ " ។ នៅត្រាស់ថា **អជាតំ** មិនកើត ដើម្បីនឹងទ្រង់សម្ដែងថា ភាវៈនៃនិព្វាននេះ មិនត្រូវបច្ច័យណាមួយតាក់តែងឡើង មិនត្រូវហេតុណាមួយធ្វើឡើង និង ការមិនកើតនេះ ក៏ព្រោះ **និព្វាន** មានការមិនកើតឡើងនៃវត្ថុគ្រប់យ៉ាងជាធម្មតា ។

ព្រះសាសស្ដា ទ្រង់ប្រកាសចំពោះព្រះនិព្វាន មានដោយបរមត្ថ ក្នុងអធិការនេះ យ៉ាងនេះ ។ កាលនឹងទ្រង់ប្រកាស ទ្រង់មិនបានប្រកាស ដើម្បីនឹងទ្រង់ប្រើអំណាច របស់ព្រះអង្គថា " តថាគត ជាធំក្នុងធម៌ ជាម្ចាស់នៃធម៌នោះ

ទេ ” តែដើម្បីទ្រង់អនុគ្រោះពួកសត្វដែលជាបទបរមៈ ទើបទ្រង់ប្រកាសតាមសេចក្ដីដែលសមគួរ ។ ដូចដែលទ្រង់ត្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ បើធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយមិនបានធ្វើឡើង ដែលបច្ច័យណាមួយមិនបានតាក់តែងឡើង នេះ មិនមានសោត ការរលាស់ចេញនូវធម្មជាតិដែលកើត ដែលឧប្បត្តិ ដែលហេតុយ៉ាងណាមួយធ្វើឡើង ដែលបច្ច័យតាក់តែងឡើង ក៏មិនប្រាកដក្នុងលោកនេះឡើយ, ម្នាលភិក្ខុទាំងឡាយ តែព្រោះធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាមួយមិនបានធ្វើឡើង ដែលបច្ច័យណាមួយមិនបានតាក់តែងឡើង មានប្រាកដ , ដូច្នោះ ទើបការរលាស់ចេញនូវធម្មជាតិដែលកើត ដែលឧប្បត្តិ ដែលហេតុណាមួយធ្វើឡើង ដែលបច្ច័យតាក់តែងឡើង មានប្រាកដបាន ។

សេចក្ដីនៃព្រះបាលីនោះថា ម្នាលភិក្ខុទាំងឡាយ បើអសង្ខតធាតុ ដែលមានសភាវៈមិនកើតជាដើម មិនមានទេ ឬ មិនគប្បីមានសោត , ការរលាស់ចេញ គឺ ការចូលទៅស្ងប់ ជាឯក នូវធម្មជាតិដែលបច្ច័យទាំងឡាយតាក់តែងឡើង ពោលគឺ ខន្ធ ៥ មានរូបក្ខន្ធជាដើម ដែលមានសភាវៈកើតហើយជាដើម ក៏មិនប្រាកដ គឺ រកមិនបាន បានដល់ មិនគប្បីមាននៅក្នុងលោកនេះឡើយ ។

ពិតហើយ ធម្មជាតិ គឺ អរិយមគ្គ មានសម្មាទិដ្ឋិជាដើម ដែលធ្វើនិព្វានឱ្យជាអារម្មណ៍ កើតឡើង រមែងលះបង់នូវសង្កិលេសបានជាសមុច្ឆេទ មិនមានសល់ , ដោយហេតុនោះ ក្នុងអធិការនេះ ការបម្រាស់ គឺ ការរលាស់ចេញនូវវដ្តទុក្ខទាំងឡាយ ទើបប្រាកដ ។ ព្រះសាស្ដាកាលទ្រង់សម្ដែងនូវព្រះនិព្វានមានដោយភាពពិសេសយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់បំណងសម្ដែងបញ្ជាក់នូវ

និព្វាននោះ ដោយទ្រង់អនុលោមតាម ទើបទ្រង់ត្រាស់ថា " **យស្មា ច ខោ** " ជាដើម ។ ខ្លឹមសារនៃព្រះពុទ្ធវចនៈនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលហើយនោះឯង ។

ក្នុងអធិការនេះ ព្រោះហេតុដែលព្រះសម្មាសម្ពុទ្ធ ទ្រង់អនុគ្រោះលោកទាំងពួង ទ្រង់ប្រកាសការមានប្រាកដដោយបរមត្ថនៃនិព្វានធាតុទុក ដោយបទព្រះសូត្រជាច្រើន មានជាអាទិ៍ថា " **អបច្ចយា ធម្មា អសង្ខតា ធម្មា** " ... ធម្មជាតិដែលមិនមានបច្ច័យ ធម្មជាតិដែលបច្ច័យទាំងឡាយ មិនបានតាក់តែងឡើង ... ថា " **អត្ថិ ភិក្ខវេ តទាយតនំ , យត្ថ នេវ បឋវី** ... ម្នាលភិក្ខុទាំងឡាយ អាយតនៈនោះមាន តែមិនមែនដី , ថា " **ឥទម្បិ ខោ ឋានំ សុទុទ្ទសំ , យទិទំ សព្វសង្ខារសមថោ សព្វូបធិបដិនិស្សគ្គោ** ... " ឋានៈដែលបុគ្គលឃើញបានដោយលំបាកនេះ គឺ សេចក្តីស្ងប់នូវសង្ខារទាំងពួង ការលះ-បង់នូវឧបធិទាំងពួង ... , ថា " **អសង្ខតញ្ច វោ ភិក្ខវេ ធម្មំ ទេសេស្សាមិ អសង្ខតគាមិញ្ច បដិបទំ** ... " ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងអសង្ខតធម៌ និង បដិបទាដែលឱ្យដល់អសង្ខតធម៌ ... , និង ដោយបទព្រះសូត្រនេះថា " **អត្ថិ ភិក្ខវេ អជាតំ** " ម្នាលភិក្ខុទាំងឡាយ ធម្មជាតិនោះ មិនមានការកើតមានហើយ ..., ដូច្នោះ វិញ្ញូជនដែលជ្រះថ្លាដ៏ក្រៃលែងក្នុងព្រះសាសនា សូម្បីមិនទាន់បានធ្វើឱ្យប្រចក្សក្នុងនិព្វាននោះ មិនមានសេចក្តីសង្ស័យ ជាប្រាកដ ។ សូម្បីដូច្នោះ ដើម្បីបន្ទោបង់សេចក្តីសង្ស័យរបស់បុគ្គល ដែលមានការយល់ដឹងដែលបុគ្គលដទៃគប្បីណែនាំបាន ទើបមានសេចក្តីវិចារដែលសមគួរ ដោយពាក្យអធិប្បាយចេញមកពង្រីកក្នុងនិព្វាននោះ ដូចតទៅ :

ព្រោះកាម និង រូបព្រមទាំងវត្ថុដែលក្រៃលែងឡើង ជាធម្មជាតិដែលគប្បីកំណត់ដឹងបាន ទើបប្រាកដនូវការលះបង់ចេញនូវធម៌ជាបដិបក្ខ ចំពោះកាមនិងរូប ដែលមានសភាពផ្សេងចាកកាមនិងរូបនោះ យ៉ាងណា សង្ខតធម៌ទាំងអស់ ដែលមានសភាពដូច្នោះ ចាំបាច់ត្រូវមានការលះបង់ដែលមានការជាប់ទាក់ទងនឹងសង្ខតធម៌នោះ ដែលជាបដិបក្ខគ្នា , ការចេញចាកនោះយ៉ាងណា គឺ អសង្ខតធាតុ នោះឯង ។

នឹងពោលឱ្យក្រៃលែងបន្តិចទៀត វិបស្សនាញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និង អនុលោមញ្ញាណរមែងលះកិលេសបាន ដោយជាតទង្គប្បហាន មិនអាចលះបានដោយសមុច្ឆេទប្បហានទេ ។ ម្យ៉ាងទៀត ញាណក្នុងបឋមជ្ឈានជាដើម រមែងលះបង់កិលេសដោយវិក្ខម្ភនប្បហានប៉ុណ្ណោះ មិនអាចលះបង់បានជាសមុច្ឆេទទេ ។

ដោយប្រការដូចពោលមកនេះ ព្រោះញាណដែលមានសង្ខតធម៌ជាអារម្មណ៍ និង មានសម្មតិសច្ចៈជាអារម្មណ៍ មិនអាចលះបង់កិលេសបានជាសមុច្ឆេទឡើយ ទើបត្រូវមានអារម្មណ៍ ដែលមានសភាពខុសគ្នាជាមួយនឹងញាណទាំង ២ នោះ គឺ អសង្ខតធាតុនោះឯង ។

ម្យ៉ាងទៀត មានពាក្យជាដើមថា " ម្នាលភិក្ខុទាំងឡាយ ធម្មជាតិដែលមិនកើត មិនឧប្បត្តិ ដែលហេតុណាៗ តាក់តែងមិនបាន ដែលបច្ច័យណាៗ តាក់តែងឡើងមិនបាន មានហើយ " ជាពាក្យបង្ហាញសេចក្តី ដែលនិព្វានមានដោយបរមត្ថ ឈ្មោះថា មានអត្ថដែលមិនវិបរិត ព្រោះជាពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។ ពិតហើយ ក្នុងពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ពាក្យនោះ

មានអត្ថមិនខុស ដូចដែលទ្រង់ត្រាស់ទុកថា សង្ខារទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ សង្ខារទាំងពួងជាអនត្តា ។

ម្យ៉ាងទៀត **និព្វាន** ស័ព្ទ ជាអារម្មណ៍របស់បរមត្ថ តាមសេចក្ដីពិត ក្នុងអារម្មណ៍ប្រភេទខ្លះ ព្រោះមានការប្រព្រឹត្តទៅជាឧបចារវោហារ ។ បណ្ឌិតគប្បីជ្រាបតាមដែលអសង្ខតធាតុ មានដោយបរមត្ថ ។

ន័យម្យ៉ាងទៀត ប្រសិនបើ និព្វានត្រឹមតែការមិនមានប៉ុណ្ណោះសោត និព្វាននោះ ក៏មិនត្រូវពោលថា ជាធម៌ដែលមានជម្រៅ ជាដើមថា " ធម៌ដែលមានជម្រៅ ឃើញបានដោយលំបាក ដឹងបានដោយលំបាក ស្ងប់ ប្រណីត មិនមែនវិស័យដែលនឹកដៅយក ជាធម៌ល្អិត បណ្ឌិតទើបដឹងបាន " , មិនត្រូវពោលថា ជាអសង្ខតធម៌ជាដើមដោយន័យជាដើមថា " ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងអសង្ខតធម៌ ដល់អ្នកទាំងឡាយ " , និងមិនត្រូវពោលថា ជាអព្យាកតធម៌ ជាដើម ក្នុងន័យមានជាដើមថា " ធម៌ដែលជាអព្យាកតៈ ធម៌ដែលមិនមានបច្ច័យតាក់តែង " តើការមិនមាន នឹងមានដូចម្ដេច ដើម្បីឱ្យបានដឹងនូវការមិនមាននោះ ដោយអាការជាធម៌ដែលមានជម្រៅ និងជាអសង្ខតធម៌ គឺ មិនអាចទៅរួចឡើយ , ព្រោះថា ការមិនមាន ក៏ជាការមិនមាននោះឯង , ការមិនមាននោះ នឹងមានទំនាក់ទំនងជាភាវៈ ជាធម៌មានជម្រៅ និងជាអសង្ខតធម៌ជាដើម មកពីណា ? , កិលេសទាំងពួងដែលមាននៅក្នុងសន្តានរបស់សត្វទាំងឡាយ គួរនឹងមាន ការមិនមាននេះតែម្យ៉ាងបាន ឬ ច្រើនយ៉ាងក៏បាន , ប្រសិនបើមានតែម្យ៉ាង ក៏ប្រើមគ្គតែមួយប៉ុណ្ណោះ នឹងធ្វើកិលេសទាំងពួងឱ្យមិនមាន និង ធ្វើឱ្យជាក់ច្បាស់បាន ព្រោះដូច្នោះមគ្គទាំងឡាយដទៃ នឹង

ជាវត្ថុគ្មានប្រយោជន៍ ព្រោះដូច្នោះ មិនចាំបាច់មានមគ្គច្រើន ហើយសត្វទាំងពួង ក៏នឹងដល់នូវការសម្រេចនិព្វានរួមគ្នាបាន ។

ប្រសិនបើជាយ៉ាងនេះ ការមិនមានកិលេសដែលដឹងគ្នាថា និព្វាននោះ ក៏មិនមានតែម្យ៉ាងប៉ុណ្ណោះ , ការមិនមានកិលេសនោះ មិនត្រូវប្រើមគ្គសាងឡើង ក៏អាចធ្វើឱ្យជាក់ច្បាស់បាន , ប្រសិនបើដូច្នេះ ពោលដោយពិសេស មគ្គក៏មិនមែនជារបស់ដែលគ្មានប្រយោជន៍ ព្រោះមិនបានលះបង់កិលេសទាំងឡាយ ព្រោះដូច្នោះ សូម្បីមគ្គតែមួយក៏មិនត្រូវមាន ។ ប្រសិនបើ មិនមានការលះបង់នូវកិលេស ក៏លះបង់ទុក្ខមិនបាន ដូច្នោះ ការដែលធ្វើឱ្យជាក់ច្បាស់នូវការមិនមានកិលេស នឹងមានប្រយោជន៍អ្វីទៅ ? , ម្យ៉ាងទៀត កាលបើដូច្នោះ មគ្គទាំងឡាយ មាននាទីប្រាកដប្រជា ក្នុងការលះបង់សំយោជនៈទាំង ៣ ជាដើម ដែលនៅក្នុងសន្តាន, ដូច្នោះ ក្នុងមគ្គទាំង ៤ នីមួយៗ មិនមានកិលេសឡើយ ។ កាលបើដូច្នេះ វៀរចាកការចែកសភាវៈ ក៏មិនមានមគ្គច្រើនយ៉ាង ព្រោះដូច្នោះ ការមិនមាននោះ គួរជាសភាវធម៌ដែលកំពុងពោលដល់ ដោយបរិយាយ ដល់នូវការអស់ទៅនូវកិលេសនោះឯង ។

ម្យ៉ាងទៀត និព្វាននេះ ទ្រង់ហៅថា " **ខយោ** " ការអស់ទៅ ព្រោះជាធម្មជាតិដែលគប្បីសម្រេចបាន ដោយការអស់ទៅ ។ ព្រោះថា អរិយមគ្គឈ្មោះថា " **ខយោ** " ការអស់ទៅ ដូចមានព្រះបាលីថា " **ខយេ ញាណំ** " ការដឹងក្នុងការអស់ទៅ ។ ព្រោះហេតុនោះ និព្វាននេះ ទើបជាធម្មជាតិដែលគប្បីធ្វើឱ្យសម្រេចជាក់ច្បាស់បាន , ព្រោះដូច្នោះ ទ្រង់ទើបហៅថា " **ខយោ** " ការអស់ទៅ ។

# បញ្ហាកម្ម
## ដំរិញរឿងព្រះនិព្វាន

បើមានពាក្យអះអាងថា " មិនមានទេ ព្រះនិព្វាននោះ ព្រោះមិនមែនវត្ថុដែលគប្បីរកបាន ដូចស្នែងទន្សាយដូច្នោះ " យ៉ាងនេះ ចម្លើយគប្បីមានថា " ព្រះនិព្វានមិនមាន ក៏មិនមែន ព្រោះព្រះនិព្វាននោះ ជាធម្មជាតិដែលគប្បីរកបានដោយឧបាយ ពិតហើយ ព្រះនិព្វាននោះ រមែងរកបានដោយឧបាយ ពោលគឺ ការបដិបត្តិដែលសមគួរដល់ព្រះនិព្វាននោះ ដូចលោកុត្តរចិត្តរបស់បុគ្គលដទៃ ៗ , ព្រះអរិយៈ រមែងដឹងបានដោយចេតោបរិយញ្ញាណដូច្នោះ ព្រោះហេតុនោះ " មិនគួរពោលថា ព្រះនិព្វានមិនមាន ព្រោះមិនមែនវត្ថុដែលគប្បីបាន " ដែលថា បុថុជ្ជនល្ងង់ខ្លៅ " មិនបានប្រសព្វវត្ថុណា ក៏ថា វត្ថុនោះមិនមាន " ដូច្នេះ មិនគួរ , ព្រោះអ្នកបានប្រសព្វមានហើយ ។

ម្យ៉ាងទៀត មិនគួរពោលថា ព្រះនិព្វានមិនមាន ព្រោះហេតុអ្វី ព្រោះមិនជាមោឃៈនៃការបដិបត្តិ ពិតហើយ បើព្រះនិព្វានមិនមាន ការបដិបត្តិត្រូវដែលសង្គ្រោះក្នុងខន្ធ ៣ មាន សីលក្ខន្ធជាដើម ដែលមានសម្មាទិដ្ឋិជាប្រមុខក៏ត្រូវជាមោឃៈ តែថា ការបដិបត្តិត្រូវនេះ មិនជាមោឃៈ ព្រោះជាហេតុឱ្យដល់ព្រះនិព្វានបាន ។

បើមានពាក្យជំទាស់ថា " ការមិនជាមោឃៈ នៃការបដិបត្តិនោះ មិនមានទេ ព្រោះការបដិបត្តិនោះ ជាហេតុឱ្យដល់ការមិនមាន ដូច្នេះសោត , ពាក្យឆ្លើយគប្បីមានថា " ការមិនមាន ជាព្រះនិព្វានក៏មិនមែន " ព្រោះមិនមាន

ការសម្រេចព្រះនិព្វានណា ដោយសារមិនមានខន្ធអតីត និងអនាគត ( ទោះមិនមានខន្ធអតីត-អនាគត ក៏គង់សម្រេចព្រះនិព្វានបានដែរ )។

បើជំទាស់ទៀតថា " មិនមែនតែខន្ធអតីត-អនាគតនោះ ប៉ុណ្ណោះទេ សូម្បីការមិនមានវត្តមានខន្ធ គឺ ខន្ធបច្ចុប្បន្នទាំងឡាយ ក៏ជានិព្វានដែរ " ដូច្នេះសោត , គប្បីឆ្លើយថា " មិនត្រូវ ព្រោះព្រះនិព្វានមាន មិនមែនដោយសារការមិនមានខន្ធទាំងឡាយនោះទេ " , ម្យ៉ាងទៀត ព្រោះកាលវត្តមានខន្ធមិនមានព្រះនិព្វានក៏ដល់នូវការមិនមានដែរឬ " មិនមែនមិនមានវត្តមានខន្ធ ហើយព្រះនិព្វានមិនមាននោះទេ " និងទោស គឺ ការមិនសម្រេចសឧបាទិសេសនិព្វានធាតុ ក្នុងខណៈនៃមគ្គចិត្ត ក៏អាស្រ័យវត្តមានខន្ធដែរ ( គឺថា ក្នុងខណៈនៃមគ្គនឹងសម្រេចនិព្វានមិនបាន ) ។

បើជំទាស់ទៀតថា " ទោសមិនមាន ព្រោះក្នុងខណៈនៃមគ្គនោះ កិលេសទាំងឡាយក៏មិនប្រព្រឹត្តទៅ " ដូច្នេះសោត , គប្បីឆ្លើយថា " មិនបាន ព្រោះ បើក្នុងខណៈនៃមគ្គ កិលេសមិនប្រព្រឹត្តទៅ អរិយមគ្គក៏គ្មានប្រយោជន៍ពិតហើយ កាលបើយ៉ាងនោះ កិលេសទាំងឡាយ មិនមានមកតាំងពីមុនខណៈនៃអរិយមគ្គ ព្រោះដូច្នោះ អរិយមគ្គក៏គ្មានប្រយោជន៍ ។

ព្រោះហេតុដូចដែលពោលមកនោះ ប្រការ " ដែលថា ព្រះនិព្វានមិនមាន ព្រោះជាវត្ថុដែលគ្មានដូចស្នែងទន្សាយ និងថា ការបដិបត្តិមិនជាមោឃៈ ព្រោះការបដិបត្តិនោះ ជាហេតុ ឱ្យដល់នូវការមិនមាន និងថា ទោស គឺ ការសម្រេចព្រះនិព្វាន ក្នុងខណៈនៃមគ្គមិនបាននោះ មិនមាន ព្រោះក្នុងខណៈនៃមគ្គ កិលេសមិនប្រព្រឹត្តទៅហើយ " នោះ ទើបមិនមែនជាហេតុ គឺ មិនត្រូវ

តាមហេតុ ។

បើមានពាក្យជំទាស់ទៀតថា " **ខយោ** - ការអស់ទៅ ជានិព្វាន ដោយបាលីថា **យោ ខោ អាវុសោ រាគក្ខយោ - ម្នាលអាវុសោ ការអស់ទៅនៃរាគៈណា ជាដើម** " ដូច្នេះ សោត , គប្បីឆ្លើយថា " មិនបាន ព្រោះត្រឹមតែការអស់រាគៈសំដៅដល់ព្រះអរហត្តក៏បាន " ព្រោះព្រះអរហត្តនោះ ទ្រង់សម្តែងទុកដោយន័យថា **យោ ខោ អាវុសោ រាគក្ខយោ** ជាដើម ដូចគ្នា នៅមានអ្វីខុសទៀត , គឺ ការពោលត្រឹមតែថា ការអស់កិលេសជានិព្វាននោះ មិនត្រូវ , ព្រោះទោស គឺ ព្រះនិព្វាន ក្លាយជាធម្មជាតិមានកាលវេលាដែលខ្លីជាដើម ពិតហើយ កាលបើយ៉ាងនោះ ព្រះនិព្វានក៏ដល់នូវភាពជាធម្មជាតិមានកាលវេលាខ្លី ជាធម្មជាតិមានលក្ខណៈនៃសង្ខតធម៌ ព្រោះជាធម្មជាតិដែលគប្បីសម្រេចបាន ដែលមិនគិតដល់សម្មាវាយាមៈ ទៅហើយឬ ម្យ៉ាងទៀត ព្រោះជាធម្មជាតិដែលមានលក្ខណៈ ជាសង្ខតធម៌នោះ ព្រះនិព្វានក៏ដល់នូវភាវៈជាធម្មជាតិ រាប់បញ្ចូលក្នុងសង្ខតធម៌នោះឯង ក៏ដល់នូវភាវៈជាធម្មជាតិដែលត្រូវភ្លើងមានរាគៈជាដើមដុតរោលបាន កាលបើជាធម្មជាតិត្រូវដុត ក៏ដល់នូវភាវៈជាទុក្ខទៅហើយ ។

បើមានពាក្យជំទាស់ទៀតថា " ទោសមិនមាន ព្រោះការប្រព្រឹត្តទៅ ( នៃកិលេស ) ឈ្មោះថា មិនមានតទៅទៀត ចាប់តាំងពីការអស់ ( គ្រាចុងក្រោយ ) ការអស់នោះជានិព្វាន " ដូច្នេះសោត គប្បីឆ្លើយថា " មិនត្រូវ ព្រោះមិនមានការអស់ ដូច្នោះ ប្រការ ១ ទៀត ព្រោះសូម្បីមានការអស់នោះក៏មិន កន្លងទោសមានប្រការដូចដែលពោលហើយ និងព្រោះអរិយមគ្គក្លាយជាព្រះនិព្វានទៅហើយ " ពិតហើយ អរិយមគ្គ រមែងញុំាងទោសទាំងឡាយឱ្យ

អស់ទៅ ព្រោះដូច្នោះ ទ្រង់ទើបហៅថា **ខយោ** ហើយបន្ទាប់ពីនោះទៅ ការប្រព្រឹត្តទៅ ( នៃទោស ) មិនមានទៀតឡើយ តែថា ព្រោះព្រះនិព្វាននោះជាឧបនិស្ស័យ ( ជាទីអាស្រ័យ ) ដោយបរិយាយនៃ **ខយ** គឺ មគ្គ បានដល់ **អនុប្បត្តិនិរោធ** " និរោធ គឺ ការមិនកើតឡើង " ព្រះនិព្វាននោះ ទើបទ្រង់ហៅថា **ខយោ** គឺជាឧបចារវោហារ ( ទាក់ទងគ្នា ) នឹងវត្ថុដែលមានព្រះនិព្វានជាឧបនិស្ស័យ ។

បើមានពាក្យសួរថា " ព្រោះហេតុអ្វី ព្រះនិព្វាននោះ ព្រះមានព្រះភាគត្រាស់ទុកដោយសរុបតែមួយ ? ដូច្នេះនោះ គប្បីឆ្លើយថា ព្រះនិព្វានជាធម៌ល្អិតសុខុម ការដែលព្រះនិព្វាននោះជាធម៌ល្អិតសុខុម ជាការសម្រេចទូទៅ (ប្រាកដទូទៅ ) ហើយ ព្រោះជាហេតុនាំមកនូវភាពជាអ្នកខ្វល់ខ្វាយតិច នៃព្រះមានព្រះភាគជាម្ចាស់ និងព្រោះជាធម៌ដែលត្រូវឃើញដោយ អរិយចក្ខុ ព្រោះហេតុនោះ ព្រះនិព្វាននោះ ជាធម៌មិនទូទៅ ព្រោះជាធម៌ដែលបុគ្គលព្រមព្រៀងដោយមគ្គ ទើបបានដល់ , ជាធម៌មិនមានដែនកើត ព្រោះមិនមានខាងដើមខាងចុង។

បើមានពាក្យជំទាស់ថា " ព្រះនិព្វាន មិនមែនជាធម៌មិនមានដែនកើត ព្រោះលុះត្រាតែមានមគ្គ ទើបសម្រេចបាន " ដូច្នេះសោត , គប្បីឆ្លើយថា " មិនត្រូវ ព្រោះនិព្វានមិនមែនជាធម៌ដែលមគ្គគប្បីឱ្យកើតឡើងនោះឡើយ " ការពិត ព្រះនិព្វាននោះ ជាធម៌ដែលបុគ្គលអាចបានដោយមគ្គប៉ុណ្ណោះ មិនមែនមគ្គឱ្យកើតឡើងនោះទេ ព្រោះដូច្នោះ ព្រះនិព្វាននោះ ទើបឈ្មោះថា មិនមានដែនកើត ដោយសារមិនមានដែនកើត ទើបមិនមានជរាមរណ ព្រោះមិនមានដែនកើត និង ជរាមរណៈ ទើបទៀង ។

បើមានពាក្យសួរទៀតថា " កាលបើអណ្ឌជាដើម ដល់នូវភាវៈទៀង ដូចព្រះនិព្វាន " ដូច្នេះសោត , គប្បីឆ្លើយថា អណ្ឌជាដើមនោះ ឈ្មោះថាទៀង មិនបាន ព្រោះមិនមានហេតុ ( ឱ្យចូលដល់ ) ។ បើមានពាក្យសួរទៀតថា " ព្រះនិព្វានទៀង វត្ថុទាំងនោះក៏ទៀង " ដូច្នេះសោត , គប្បីឆ្លើយថា មិនបាន ព្រោះវត្ថុទាំងអស់នោះ មិនចូលក្នុងលក្ខណៈនៃហេតុ ( ដែលជាធម៌គួរប្រាថ្នាបានជាដើម ) ។ បើមានពាក្យសួរថា " វត្ថុទាំងឡាយនោះ ចាត់ថាទៀង ព្រោះមិនមានហេតុឱ្យកើតឡើងជាដើម ដូចព្រះនិព្វាន " ដូច្នេះសោត , គប្បីឆ្លើយថា " មិនបាន ព្រោះអណ្ឌជាដើមមិនសម្រិតផល ( មិនបរិសុទ្ធ ) "។

ព្រះនិព្វាននោះប៉ុណ្ណោះ ទៀងពិត ព្រោះមានសភាវៈ គឺ ការពាល់ត្រូវ ( ដោយហេតុផល ) ដូចពោលមកហើយ ជាអរូប ព្រោះកន្លងនូវសភាវៈនៃរូប ( មានការវិនាសជាដើម ) មិនមែនជាវត្ថុដែលមិនមានដោយបរមត្ថ ព្រោះជាវត្ថុដែលគប្បីសម្រេចបានដោយញាណពិសេស សម្រេចដោយការព្យាយាមដែលមិនធូរថយ ព្រោះជាព្រះតម្រាស់របស់ព្រះសព្វញ្ញូជាម្ចាស់ ពិតហើយ ព្រះសព្វញ្ញូជាម្ចាស់បានត្រាស់ពាក្យនេះទុកថា **ម្នាលភិក្ខុទាំងឡាយ ធម្មជាតិដែលមិនកើត មិនមានហេតុណាៗ ធ្វើឱ្យកើតឡើង ដែលបច្ច័យទាំងឡាយមិនបានតាក់តែងឡើង** នេះជាពាក្យវិនិច្ឆ័យយ៉ាងសំខាន់ក្នុងទុក្ខនិរោធនិទ្ទេស ។

អភិធម្មាវតារ : ខ្ញុំម្ចាស់នឹងសម្តែងព្រះនិព្វានបន្ទាប់ពីរូប ក្នុងឧទ្ទេសកថា ឥឡូវនេះ ដល់លំដាប់ន័យក្នុងការអធិប្បាយ ព្រះនិព្វានហើយ ។ ដូច្នោះបន្ទាប់ពីនេះទៅខ្ញុំម្ចាស់នឹងពោល អធិប្បាយអំពីព្រះនិព្វាន ដែលគប្បីសម្រេច និង ត្រាស់ដឹងបានដោយកម្រ ។

ពាក្យថា **និព្វាន** មានន័យថា តណ្ហា ឈ្មោះថា **វាន** ព្រោះជាគ្រឿងបន្តភពតូច - ភពធំ , រឺឯ បរមសុខដែលមិនស្លាប់ មិនមានបច្ច័យតាក់តែង ព្រះពុទ្ធជាម្ចាស់ត្រាស់ហៅថា **និព្វាន** ព្រោះប្រាសចាកតណ្ហា សមពិតដូចដែលទ្រង់ត្រាស់ថា :

**យោ សោ សព្វសង្ខារាសមថោ សព្វូបធិបដិនិស្សគ្គោ តណ្ហក្ខយោ វិរាគោ និព្វានន្តិ** ។

សភាពស្ងប់នៃសង្ខារទាំងពួង ការលះបង់នូវឧបធិទាំងពួង ការអស់ទៅនៃតណ្ហា ការប្រាសចាកតម្រេក គឺជា ព្រះនិព្វាន ។

ពាក្យថា **ឧបធិ** ប្រែតាមស័ព្ទថា ទីតាំង សំដៅដល់ ទីតាំងនៃទុក្ខ សុខ និង សោមនស្ស អង្គធម៌ បានដល់ កាមគុណ ៥ ខន្ធ ៥ កិលេស ១០ លោកិយកុសលកម្ម និង អកុសលកម្ម ចែកចេញជា ៥ ប្រភេទ គឺ :

**១**- កាមូបធិ — កាមគុណ ៥ ជាទីតាំងនៃសុខ និង សោមនស្ស ។

**២**- ខន្ធូបធិ — ជាទីតាំងនៃទុក្ខទាំងអស់ ដែលមានខន្ធជាហេតុ ។

**៣**- កិលេសូបធិ — កិលេស ១០ ជាទីតាំងនៃទុក្ខ ក្នុងអបាយ ( កិលេស ១០ មាន លោភៈ ទោសៈ មោហៈ មានៈ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ) ។

៤- អភិសង្ខារូបធិ កម្ម ដែលជាលោកិយកុសលកម្ម និងអកុសលកម្ម ជាទីតាំងនៃទុក្ខក្នុងភព ។

ការអស់ទៅនៃកិលេសទាំងពួង គប្បីមានបាន ព្រោះការសម្រេចនូវធម៌ណា ព្រះសាស្តា ទ្រង់ជាអ្នកឆ្លាតក្នុងសភាវៈនោះ បានត្រាស់សម្តែងនូវធម៌នោះ ថាជា ព្រះនិព្វាន ។

## ការអស់កិលេសមិនមែនជាព្រះនិព្វាន

សួរថា ក្នុងសេចក្តីនេះ ព្រះសារីបុត្តត្ថេរ ជាធម្មសេនាបតី កាលមានគេសួរដល់ព្រះនិព្វានថា " លោកដ៏មានអាយុ ព្រះនិព្វាន ដូចម្តេច ? ក៏បានសម្តែងនូវការប្រាសចាករាគៈជាដើម ដោយពោលថា អ្នកមានអាយុ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ សភាវៈនេះ ហៅថា ព្រះនិព្វាន យ៉ាងនេះ បើដូច្នោះ ព្រះនិព្វាន ត្រឹមតែជាការអស់ទៅនៃរាគៈជាដើមឬ ? សួរថា សេចក្តីនោះ ដូចម្តេចទៅ ?

ឆ្លើយថា ព្រះសារីបុត្តកាលត្រូវសួរថា អ្នកមានអាយុ អរហត្តផលដូចម្តេច ? បានសម្តែងដល់ការអស់ទៅនៃរាគៈ ជាដើមថា " អ្នកមានអាយុ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ហៅថា អរហត្តផល " ដូច្នោះ សូម្បីអរហត្តផល ក៏មានការអស់ទៅនូវរាគៈជាដើម តាមការយល់ឃើញរបស់អ្នកសួរ និងការដែលលោកុត្តរផលចិត្ត មិនមានចិត្តដទៃក្រៃលែងជាង មានសភាពត្រឹមតែជាការអស់ទៅនៃរាគៈជាដើម ក៏សមគួរ , ព្រោះហេតុនោះ សូមអ្នកកុំពោលដល់ ឆាយារបស់រូបស័ព្ទ ចូរពិចារណាអត្ថរបស់ព្រះសូត្រទាំង

ពីរ ដែលពោលដល់ ព្រះនិព្វាន និង អរហត្តផល ។

ប្រសិនបើ ព្រះនិព្វាន ត្រឹមតែជាការអស់កិលេសនោះ មិនមានសភាវៈយ៉ាងដទៃ អរហត្តផលចិត្ត ក៏គួរបានឈ្មោះថា ជាព្រះនិព្វាន ព្រោះជាការអស់កិលេសដូចគ្នា ព្រោះហេតុនោះ មិនគប្បីយល់ថា ត្រឹមតែការអស់កិលេសជាព្រះនិព្វាន ។

## ព្រះនិព្វាន
## ជាការអស់កិលេសដោយបរិយាយ

ការអស់ទៅនៃរាគៈជាដើម រមែងមានព្រោះការសម្រេច នូវធម៌ណា ធម៌នោះ សូម្បីមានសភាពមិនវិនាសទៅ ក៏ពោលថា ការអស់ទៅនៃរាគៈជាដើម ឈ្មោះថា ព្រះនិព្វាន បានដោយឈ្មោះ នៃការអស់ទៅ ( ដែលជាផល ) ។

ព្រះនិព្វានជាហេតុឱ្យសម្រេចផល គឺ ការអស់ទៅនៃរាគៈជាដើម ព្រោះព្រះអរិយបុគ្គលដែលបានសម្រេចនូវព្រះនិព្វាន រមែងកម្ចាត់បង់កិលេសនៅក្នុងខណៈនោះ , ការពោលថា ការអស់ទៅនៃរាគៈជាដើម ឈ្មោះថា ព្រះនិព្វាន គ្រាន់តែសំនួនវោហារដែលពោលដោយអម គឺ ការពោលដល់ផលដែលប្រើហេតុជាឈ្មោះរបស់ផល ដូចពោលថា **តិបុសំ ជរោ** " ជំងឺទទឹម " , **គុឡោ សេម្ហោ** " ស្លេស្មទឹកអំពៅ " សំដៅដល់ ជំងឺដែលកើតពីការបរិភោគផ្លែទទឹម និង ស្លេស្ម ដែលកើតឡើងពីការផឹកទឹកអំពៅ , ការប្រើពាក្យក្នុងលក្ខណៈ នេះហៅថា **ផលូបចារ** គឺ ការពោលដល់ផលដោយប្រើ ហេតុជាឈ្មោះរបស់ផល ។

## អរហត្តផល
## ជាការអស់កិលេសដោយអម

វីឯ **អរហត្តផល** ក៏ហៅថា ការអស់កិលេស ( ដោយអម ដូចព្រះនិព្វាន ) ព្រោះកើតឡើងក្នុងទីបំផុតនៃការអស់កិលេស ។ សូម្បីការពោលថា ការអស់កិលេសជាអរហត្តផល គ្រាន់តែជាសំនួនវោហារដូចគ្នា ។

## ការអស់កិលេស
## ជាខណៈៗ មិនមែនព្រះនិព្វាន

សេចក្ដីពិត បើការអស់ទៅនៃរាគៈជាដើម ជាខណៈៗ ជាព្រះនិព្វាន បើតាមសេចក្ដីនេះ សូម្បីបុថុជ្ជនល្ងង់ខ្លៅគ្រប់គ្នា ក៏បានឈ្មោះថា ដឹងច្បាស់នូវព្រះនិព្វានដែរ ( គឺ បុថុជ្ជនល្ងង់ខ្លៅ សូម្បីសត្វតិរច្ឆាន កាលសេពកាមហើយ រាគៈរមែងអស់ទៅជាខណៈ ដូច្នោះ ការអស់កិលេសជាខណៈ ទើបមិនមែនជាព្រះនិព្វាន ព្រោះព្រះនិព្វាន គឺ ការអស់កិលេសជាសមុច្ឆេទ ) ។

ម្យ៉ាងទៀត ការយល់នោះ មិនសមគួរ ព្រោះព្រះនិព្វានមានច្រើនទាក់ទងនឹងការអស់ទៅនៃរាគៈជាដើម ហើយព្រះនិព្វាន ក៏មានលក្ខណៈជាសង្ខតធម៌បាន ទាំងរាប់ចូលនៅក្នុងសង្ខតធម៌ ព្រោះមានលក្ខណៈនៃសង្ខតធម៌ ហើយព្រះនិព្វាន ក៏មិនទៀង ជាទុក្ខ ព្រោះរាប់ចូលក្នុងសង្ខតធម៌ ។

បើសម្គាល់ថា ការអស់កិលេសជាខណៈ ៗ ជាព្រះនិព្វាន ក៏ខុសចាកសេចក្ដីសមគួរ ២ ប្រការ គឺ :

**១**- និព្វាន មានច្រើនតាមកិលេសដែលអស់ទៅ ក្នុងខណៈមួយ ៗ ពោលគឺ ការអស់រាគៈ ការអស់ទោសៈ ការអស់មោហៈ ជានិព្វានម្យ៉ាង ៗ ជាដើម ។

**២**- ការអស់កិលេសជាខណៈៗ គឺជា ភង្គៈក្នុងឧប្បាទខណៈ ( ខណៈកើតឡើង ) , ឋិតិខណៈ ( ខណៈតាំងនៅ ) , ភង្គខណៈ ( ខណៈរលត់ទៅ ) ដែលជាលក្ខណៈនៃសង្ខតធម៌ បើតាមសេចក្ដីនេះ ព្រះនិព្វានក៏រាប់ចូលនៅក្នុងសង្ខតធម៌ ដូចរូបធម៌ និង នាមធម៌ដទៃៗ ក៏មានសភាពមិនទៀង ជាទុក្ខដូចគ្នា តែព្រះនិព្វានមានសភាពទៀង និង ជាសុខ ជានិរន្តរ ។

## ការអស់កិលេស
## ដែលមិនទាន់កើតឡើងមិនមែនព្រះនិព្វាន

**សួរថា** បើការអស់កិលេសប៉ុណ្ណោះជាព្រះនិព្វាន អារម្មណ៍របស់ចិត្ត គឺ គោត្រភូ វោទាន មគ្គ និង ផល គឺអ្វី , អ្នកដ៏ចម្រើនសូមឆ្លើយមក ( **គោត្រភូ** គឺ ញាណដែលជាអនន្តរប្បច្ច័យដល់សោតាបត្តិមគ្គ , **វោទាន** គឺ ជាញាណ ដែលកើតមុនមគ្គជាន់លើ ៣ ) ?

**ឆ្លើយថា** អារម្មណ៍របស់ចិត្តដូចពោល គឺ ការអស់ទៅនៃរាគៈជាដើម ។

**សួរថា** រាគៈជាដើមកំពុងអស់ទៅ នឹងអស់ទៅ ឬ បានអស់ទៅហើយ ក្នុងខណៈនៃគោត្រភូជាដើម ?

**ឆ្លើយថា** យើងពោលនូវការអស់ទៅ កាលកិលេសរលត់ទៅហើយ អ្នកដ៏ចម្រើន លោកពិចារណាឱ្យល្អហើយ សូមសួរចុះ ?

ប្រសិនបើ រាគៈជាដើមអស់ទៅក្នុងខណៈរលត់កិលេស ហើយបើដូច្នេះ គោត្រភូចិត្តជាដើម ក៏ដឹងព្រះនិព្វានជាអារម្មណ៍ មិនបាន ព្រោះរាគៈជាដើមនឹងអស់ទៅក្នុងខណៈជា គោត្រភូ និង វេទាន , តែកំពុងអស់ទៅក្នុងខណៈមគ្គចិត្ត មិនមែនអស់ទៅហើយ ទាំងមានសភាពអស់ទៅហើយក្នុងខណៈផលចិត្ត , កាលបើដូច្នោះ តាមមតិរបស់លោក ផលចិត្តដែលកើតឡើងក្នុងខណៈអស់កិលេសហើយ ក៏មានអារម្មណ៍ គឺ **ការអស់ទៅ** , ចិត្តដទៃ មានគោត្រភូ និង វោទាន មគ្គចិត្ត មានអារម្មណ៍ គឺ **ការអស់ទៅ** មិនបានអារម្មណ៍របស់ចិត្តទាំងនោះ គឺអ្វី អ្នកបរវាទី " អ្នកយល់បែកគ្នា " នោះ មិនអាចនឹងរកអារម្មណ៍នៃគោត្រភូចិត្តជាដើមបាន នឹងឆ្លើយមិនបានជាប្រាកដ ។

ម្យ៉ាងទៀត ការអស់ទៅនៃកិលេស សប្បុរសទាំងឡាយ រមែងធ្វើ គឺរមែងធ្វើឱ្យកើតឡើង ដោយការបដិបត្តិតាមសមគួរចំពោះវិសុទ្ធិទាំង ៧ តែព្រះនិព្វានមិនត្រូវធ្វើ ធ្វើឱ្យកើតឡើងមិនបានដោយបច្ច័យយ៉ាងណាមួយឡើយ ដូច្នេះ ព្រះនិព្វាន ទើបឈ្មោះថា **អមតៈ - មិនស្លាប់ , អសង្ខត - មិនមានបច្ច័យតាក់តែង** ព្រះអរិយសាវ័ករមែងដឹងថា ព្រះនិព្វាននោះ មិនមានបច្ច័យតាក់តែង ទើបហៅថា **អកតញ្ញូ - អ្នកដឹងនូវព្រះនិព្វានដែលមិនមានបច្ច័យតាក់តែង** ដូចព្រះពុទ្ធវចនៈត្រាស់ទុកថា " អ្នកមិនជឿងាយតាមពាក្យរបស់អ្នកដទៃ ដឹងច្បាស់នូវព្រះនិព្វានដែលមិនមានបច្ច័យតាក់តែង អស់នូវការវិលវល់ស្លាប់កើត អស់ឱកាសនឹងត្រូវកើតឡើងថ្មីទៀត និង អស់កិលេសដែលធ្វើឱ្យប្រាថ្នា បុគ្គលនោះ ហៅថា អ្នកដ៏ប្រសើរ ។

# ព្រះនិព្វាន ជានិស្សរណៈ

ម្យ៉ាងទៀត ព្រះនិព្វានមានពិត ព្រោះព្រះមានព្រះភាគ ត្រាស់ថា **និស្សរណ - ការរួចផុត** , តាមពិត ពាក្យថា **និស្សរណ** ជាឈ្មោះនៃ **ព្រះនិព្វាន** សមដូចព្រះពុទ្ធតម្រាស់ថា :

ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង នេះ ចាក់ធ្លុះបានដោយកម្រ , ធម៌ ៣ យ៉ាង ដែលចាក់ធ្លុះបានដោយកម្រ ដូចម្តេច ? គឺ ការរួចផុត ៣ យ៉ាង បានដល់ បឋមជ្ឈានដែលរួចផុតចាកកាមគុណ , អាកាសានញ្ចាយតនជ្ឈាន ដែលរួចផុតចាករូប និង ព្រះនិព្វានជាសភាវៈរួចផុតចាកខន្ធទាំងពួង ដែលខន្ធនោះជាធម៌មានការកើតឡើង មានបច្ច័យតាក់តែង កើតឡើងដោយបច្ច័យ ។

សូមជ្រាបសេចក្តីសរុបក្នុងទីនេះថា សភាវធម៌ម្យ៉ាង ដែលឈ្មោះថា ព្រះនិព្វានមានពិត ដូចព្រះអាឡវកៈពោលថា :

**ធម៌រួចផុតចាកកិលេស ដែលយើងបានសម្លឹងស្បហើយ ដោយបញ្ញាមានប្រាកដ ។**

ព្រះសម្មាសម្ពុទ្ធជាព្រះធម្មរាជា ស្តេចយាងទៅដោយល្អ ត្រាស់ទុកដោយបរមត្ថក្នុងព្រះសូត្រជាច្រើនថា :

**ម្នាលភិក្ខុទាំងឡាយ សភាវៈមិនកើត មិនឧប្បត្តិ មិនមានការធ្វើឱ្យកើត មិនមានបច្ច័យតាក់តែង តែសភាវៈនោះជាធម៌ឯក មានប្រាកដ ឈ្មោះថា និព្វាន ។**

# ព្រះនិព្វានមានដោយសភាវៈ

ម្យ៉ាងទៀត ក្នុងគម្ពីរធម្មសង្គណី បរិត្តត្តិកៈ ( ធម៌ពួក ៣ គឺ ធម៌ដែលមានអានុភាពតិច ធម៌ដែលចូលដល់ភាពប្រសើរ ធម៌ដែលជាបដិបក្ខចំពោះកិលេស មានរាគៈជាដើមដែលធ្វើឱ្យមានប្រមាណ ) ព្រះមានព្រះភាគ ទ្រង់សម្តែងបទ មាតិកាថា ធម៌មិនមានប្រមាណ គឺអ្វី ? ហើយត្រាស់ឆ្លើយថា មគ្គចិត្ត ៤ ដែលជាលោកុត្តរ ផលនៃភាពជាសមណៈ ( ចិត្ត និង ចេតសិកដែលប្រកបជាមួយផលចិត្ត ) ៤ និង ព្រះនិព្វាន ធម៌ទាំងឡាយនេះ មិនមានប្រមាណ ការមិនមានប្រមាណនៃការអស់រាគៈជាដើម ទើបមិនសមគួរ ព្រោះហេតុនេះ សភាវធម៌ម្យ៉ាង ឈ្មោះថា **ព្រះនិព្វាន** ទើបមានពិតដោយបរមត្ថ មិនមែនមិនមានតាមពិត ដូចប្រក្រតីរបស់ប្រក្រតីវាទី ដូចអត្តារបស់ពួកអន្យតិរ្ថិយ និង ដូចស្នែងទន្សាយនោះទេ ។

# ទុក្ខនិរោធគាមិនីបដិបទា

## សម្មាទិដ្ឋិ

ពាក្យថា **អយមេវ** ជាពាក្យកំណត់ប្រាកដប្រជា ដើម្បីបដិសេធមគ្គដទៃ ។ ពាក្យថា **អរិយោ** មានន័យថា **មគ្គ** ឈ្មោះថា **អរិយៈ** ព្រោះឆ្ងាយចាក កិលេសទាំងឡាយ ដែលមគ្គនោះៗ គប្បីសម្លាប់ និង ព្រោះធ្វើឱ្យសម្រេចភាព ជាព្រះអរិយៈ ។ ទ្រង់សម្តែងកម្មដ្ឋានពោលដោយសច្ចៈ ៤ ក្នុងពាក្យថា ដឹងក្នុង ទុក្ខជាដើម ។ ក្នុងសច្ចៈ ៤ នោះ សច្ចៈ ២ ខាងដើម ( ទុក្ខ និង សមុទយៈ ) ជាវដ្តសច្ចៈ , សច្ចៈ ២ ខាងចុង ( និរោធ និង មគ្គ ) ជាវិវដ្តសច្ចៈ ។ ក្នុង វដ្តសច្ចៈ និង វិវដ្តសច្ចៈនោះ ការតាំងមាំនៃកម្មដ្ឋានរបស់ភិក្ខុ រមែងមានក្នុង វដ្តសច្ចៈ មិនមានក្នុងវិវដ្តសច្ចៈឡើយ ។ ព្រះយោគាវចរកំណត់សច្ចៈ ២ ខាង ដើម ក្នុងសម្នាក់អាចារ្យដោយសង្ខេប យ៉ាងនេះថា បញ្ចក្ខន្ធជាទុក្ខ តណ្ហាជា សមុទយៈ និងពិស្តារ ក្នុងន័យជាដើមថា បញ្ចក្ខន្ធ តើដូចម្តេច ? គឺ រូបក្ខន្ធ ដូច្នេះជាដើម សាចុះឡើង ឈ្មោះថា ធ្វើកម្មក្នុងសច្ចៈទាំង ២ នោះ ។ រីឯ ក្នុង សច្ចៈ ២ ក្រៅពីនេះ ព្រះយោគាវចររមែងធ្វើកម្មដោយការស្តាប់តែម្យ៉ាង យ៉ាង នេះថា **និរោធសច្ច** គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត **មគ្គសច្ច** គួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ។ ព្រះយោគាវចរនោះ មានការធ្វើយ៉ាងនេះ រមែង ចាក់ធ្លុះសច្ចៈទាំង ៤ ដោយបដិវេធញ្ញាណ , រមែងត្រាស់ដឹងដោយអភិសមយ ញ្ញាណ គឺ ចាក់ធ្លុះទុក្ខសច្ចដោយបដិវេធ គឺ បរិញ្ញាកិច្ច ចាក់ធ្លុះសមុទយសច្ច ដោយបហានកិច្ច ចាក់ធ្លុះនិរោធដោយសច្ឆិកិរិយាកិច្ច ចាក់ធ្លុះមគ្គសច្ចដោយ

ភាវនាកិច្ច ។ ជាខាងដើម ព្រះយោគាវចរនោះ មានបដិវេធញ្ញាណក្នុងសច្ចៈ ២ ខាងដើម ដោយការកំណត់ ការសាកសួរ ការស្តាប់ ការចងចាំ និង ការពិចារណា , រីឯ ក្នុងសច្ចៈ ២ ខាងចុង ព្រះយោគាវចរ មានបដិវេធញ្ញាណដោយអំណាចការស្តាប់តែម្យ៉ាង , បន្ទាប់មក ទើបមានបដិវេធញ្ញាណក្នុងសច្ចៈ ៣ ដោយកិច្ច មានបដិវេធញ្ញាណក្នុងនិរោធសច្ចដោយអារម្មណ៍ ។ រីឯ បច្ចវេក្ខណញ្ញាណ មានចំពោះព្រះយោគាវចរដែលសម្រេចនូវសច្ចៈហើយ ។ និងព្រះយោគាវចរនេះ ជាអ្នកផ្តើមបំពេញកម្មដ្ឋាន ព្រោះដូច្នោះ ទើបទ្រង់មិនត្រាស់បច្ចវេក្ខណញ្ញាណទុកក្នុងទីនេះ ។ ម្យ៉ាងទៀត កាលភិក្ខុកំណត់ដឹងជាខាងដើម តាមពិចារណា រូបរួមចិត្ត ដាក់ចិត្ត និង ពិចារណាថា យើងកំណត់ដឹងទុក្ខ យើងលះបង់សមុទយៈ យើងធ្វើឱ្យជាក់ច្បាស់និរោធ យើងចម្រើនមគ្គដូច្នេះ មិនទាន់មាន នឹងមានបានតាំងពីការកំណត់ទៅ ។ ឯក្នុងពេលបន្ទាប់ទុក្ខ ក៏ឈ្មោះថា បានកំណត់ដឹងហើយ សមុទយៈក៏លះបង់បានហើយ និរោធបានធ្វើឱ្យជាក់ច្បាស់ហើយ មគ្គបានធ្វើឱ្យកើតឡើងហើយ ។

ក្នុងសច្ចៈទាំងឡាយនោះ សច្ចៈ ២ ខាងដើម ឈ្មោះថា មានជម្រៅ ព្រោះឃើញបានដោយកម្រ , សច្ចៈ ២ ខាងចុង ឈ្មោះថា ឃើញបានដោយកម្រ ព្រោះមានជម្រៅ ។ ការពិតទុក្ខសច្ចប្រាកដតាំងពីកើតមក រហូតដល់ពោលថា ទុក្ខហ្ន៎ ក្នុងពេលដែលជល់ដង្គត់ឈើ ឬ បន្លាមុតជាដើម តែសច្ចៈទាំង ២ នោះ ឈ្មោះថា មានជម្រៅដោយលក្ខណៈ និងការចាក់ធ្លុះសច្ចៈ ២ នោះ ឈ្មោះថា ជ្រៅ ព្រោះឃើញបានដោយកម្រ យ៉ាងនេះ ។ រីឯ សេចក្តីព្យាយាមដើម្បីឃើញសច្ចៈ ២ ក្រៅពីនេះ ដូចគ្នានឹងការលូកដៃចាប់ភវគ្គព្រហ្ម

ឈានដើងចុះទៅក្នុងអវីចីនរក និងដូចជាការយកចុងរោម តភ្ជាប់នឹងចុងរោម ដែលបំបែកជា ៧ ចម្រៀក ឱ្យជាប់គ្នា សច្ចៈ ២ ខាងចុងនេះ ឈ្មោះថា ឃើញដោយលំបាក ព្រោះមានជម្រៅដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ការដឹងក្នុងទុក្ខដូច្នេះជាដើម ទ្រង់សំដៅដល់ការកើតឡើងនៃញាណដែលជាចំណែកខាងដើម , ក្នុងសច្ចៈ ៤ ឈ្មោះថា មានជម្រៅ ព្រោះឃើញបានដោយកម្រ និង ឈ្មោះថា ឃើញបានដោយកម្រ ព្រោះមានជម្រៅដោយអំណាចនៃការកំណត់ដឹងជាដើម ដោយប្រការដូច្នេះ , រីឯ ក្នុងខណៈនៃការចាក់ធ្លុះ , ញាណ ( បដិវេធញ្ញាណ ) នោះ ក៏មានតែម្យ៉ាងប៉ុណ្ណោះ ។

បញ្ញាចក្ខុ មានព្រះនិព្វានជាអារម្មណ៍ នោះឈ្មោះថា សម្មាទិដ្ឋិ , **សម្មាទិដ្ឋិ** មានការឃើញត្រូវជាលក្ខណៈ , មានការប្រកាសសេចក្តីពិត ជាកិច្ច , មានការកម្ចាត់នូវភាពងងឹត គឺ អវិជ្ជា ជាអាការប្រាកដ ។

ពាក្យថា **មានការប្រកាសសេចក្តីពិត ជាកិច្ច** គឺ មានការប្រកាសបរមត្ថ ជាកិច្ច អធិប្បាយថា មានការធ្វើសច្ចៈ ៤ ឱ្យប្រាកដច្បាស់ ជាកិច្ច ។

## សម្មាសង្កប្បៈ

ការត្រិះរិះ មានការត្រិះរិះចេញចាកកាមជាដើម ព្រោះសញ្ញាក្នុងការវៀរចាក កាម ព្យាបាទ និងវិហឹង្សា ផ្សេងគ្នា , តែក្នុខណៈនៃមគ្គ ការត្រិះរិះក្នុងផ្នែកខាងកុសលតែម្យ៉ាងប៉ុណ្ណោះ កើតឡើងក្នុងអង្គមគ្គបរិបូរណ៍ ព្រោះឱ្យសម្រេចនូវការមិនកើតឡើងនៃការត្រិះរិះផ្នែកអកុសល ដែលកើតហើយ ក្នុងឋានទាំង ៣ នេះ ព្រោះកាត់ផ្លូវនៃការត្រិះរិះផ្នែកអកុសលនោះ ដាច់ខាតហើយ

នេះឈ្មោះថា **សម្មាសង្កប្បៈ** ។

**សម្មាសង្កប្បៈ** មានការលើកចិត្តឡើងដោយត្រូវផ្លូវ ជាលក្ខណៈ , មានការត្រិះរិះយ៉ាងមាំទាំនៅក្នុងផ្លូវ ជាកិច្ច , មានការលះបង់នូវមិច្ឆាសង្កប្បៈ ជាអាការប្រាកដ ។

## សម្មាវាចា

សូម្បីកុសលធម៌ មានចេតនាវៀរចាកមុសាវាទជាដើម ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកមុសាវាទជាដើមផ្សេងគ្នា , តែក្នុងខណៈនៃមគ្គ ចេតនាវៀរចាកផ្នែកកុសលតែមួយប៉ុណ្ណោះ កើតឡើងឱ្យអង្គមគ្គបរិបូរណ៍ ព្រោះឱ្យសម្រេចការមិនកើតឡើងនៃចេតនាជាហេតុទ្រុស្តសីលផ្នែកអកុសលដែលកើតហើយ ក្នុងឋានទាំង ៤ នេះ ព្រោះកាត់ផ្លូវនៃចេតនាជាហេតុទ្រុស្តសីល ផ្នែកខាងអកុសលបានដាច់ខាតហើយ នេះឈ្មោះថា **សម្មាវាចា** ។

**សម្មាវាចា** មានការកំណត់កាន់យក ( គឺប្រមូលសម្បយុត្តធម៌ទុក ) ជាលក្ខណៈ , មានការវៀរចាក ជាកិច្ច , មានការលះបង់នូវមិច្ឆាវាចា ជាអាការប្រាកដ ។

## សម្មាកម្មន្តៈ

សូម្បីកុសលធម៌ មានចេតនាវៀរចាកបាណាតិបាតជាដើម ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញាក្នុងការវៀរចាកបាណាតិបាតជាដើមផ្សេងគ្នា , តែ

ក្នុងខណៈមគ្គ ចេតនាវៀរចាកផ្នែកខាងកុសលតែមួយប៉ុណ្ណោះកើតឡើងឱ្យអង្គនៃមគ្គបរិបូរណ៍ ព្រោះឱ្យសម្រេចការមិនកើតនៃចេតនាជាហេតុទ្រុស្តសីល ផ្នែកអកុសលក្នុងឋានទាំង ៣ នេះ ព្រោះលះបង់បានដាច់ខាតហើយ នេះឈ្មោះថា **សម្មាកម្មន្ត** ។

**សម្មាកម្មន្តៈ** មានការត្រកង ( សម្បយុត្តធម៌ ) ជាលក្ខណៈ , មានការវៀរចាក ជាកិច្ច , មានការលះបង់នូវមិច្ឆាកម្មន្តៈ ជាអាការប្រាកដ ។

## សម្មាអាជីវៈ

ពាក្យថា **មិច្ឆាអាជីវ** បានដល់ កាយទុច្ចរិត និង វចីទុច្ចរិតដែលប្រព្រឹត្តទៅដើម្បីត្រូវការ របស់ទំពា របស់ស៊ី ជាដើម ។ ពាក្យថា **លះ** គឺ វៀរ ។ ពាក្យថា **ដោយសម្មាអាជីវៈ** គឺ ដោយអាជីពដែលព្រះមានព្រះភាគ ទ្រង់សរសើរ។ ពាក្យថា **សម្រេចជីវិត** គឺ ដំណើរការចិញ្ចឹមជីវិត។ ដែលឈ្មោះថា សម្មាអាជីវៈផ្សេងគ្នាក្នុងខាងដើម ព្រោះសញ្ញា ក្នុងការវៀរចាកទុច្ចរិត មានមុសាវាទជាដើមផ្សេងគ្នា , តែក្នុងខណៈនៃមគ្គ ចេតនាវៀរចាកផ្នែកខាងកុសលតែមួយប៉ុណ្ណោះ កើតឡើងឱ្យអង្គមគ្គបរិបូរណ៍ ព្រោះឱ្យសម្រេចការមិនកើតឡើងនៃចេតនាជាហេតុទ្រុស្តសីល ដែលជាមិច្ឆាអាជីវៈ ដែលកើតឡើងក្នុងឋានទាំង ៧ ( កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ) នេះ ព្រោះលះបង់បានដាច់ខាតហើយ នេះឈ្មោះថា **សម្មាអាជីវៈ** ។

**សម្មាអាជីវៈ** មានការស្អាតនៃអាជីពជាលក្ខណៈ , មានការញ៉ាំងអាជីព

ដែលប្រកបដោយធម៌ឱ្យប្រព្រឹត្តទៅ ជាកិច្ច , មានការលះមិច្ឆាអាជីវៈចេញបាន ជាអាការប្រាកដ ។

## សម្មាវាយាមៈ

ពាក្យថា **ដែលមិនទាន់កើតឡើង** គឺ ដែលមិនទាន់កើតឡើងដល់ខ្លួន ក្នុងភពមួយ ឬ ក្នុងអារម្មណ៍បែបនោះ , តែព្រះយោគាវចរឃើញបាបអកុសលធម៌ ដែលកំពុងកើតឡើងដល់អ្នកដទៃ រមែងញ៉ាំងឆន្ទៈឱ្យកើត ប្រារព្ធសេចក្តីព្យាយាម ផ្គងចិត្តទុក ដើម្បីមិនឱ្យកើតបាបអកុសលដែលមិនទាន់កើតឡើង ដោយគិតយ៉ាងនេះថា ឱហ្ន៎ ! បាបអកុសលធម៌បែបនោះ កុំគប្បីកើតដល់យើងឡើយ ។ ពាក្យថា **ឆន្ទំ ជនេតិ** រមែងញ៉ាំងឆន្ទៈឱ្យកើត គឺ ឱ្យកើតការពេញចិត្តក្នុងសេចក្តីព្យាយាម ដែលឱ្យសម្រេចនូវការបដិបត្តិ មិនឱ្យកើតអកុសលធម៌ទាំងឡាយនោះ ។ ពាក្យថា **វាយមតិ - ព្យាយាម** គឺ ធ្វើសេចក្តីព្យាយាម ។ ពាក្យថា **ចិត្តំ បគ្គណ្ហាតិ - ផ្គងចិត្ត** គឺ ធ្វើការផ្គងចិត្តដោយសេចក្តីព្យាយាម ។ ពាក្យថា **បទហតិ - តម្កល់** គឺ ដំណើរការតាំងសេចក្តីព្យាយាម សូម្បីសល់តែ ស្បែក សរសៃ ឆ្អឹង ក៏ដោយចុះ ។ ពាក្យថា **ឧប្បន្នានំ - ដែលកើតហើយ** គឺ ដែលធ្លាប់កើតហើយចំពោះខ្លួន ដោយការកម្រើកឡើង ។ រមែងឱ្យកើតឆន្ទៈ ដើម្បីលះបាបអកុសលទាំងឡាយនោះថា ឥឡូវនេះ យើងនឹងមិនឱ្យបាបអកុសលបែបនោះ កើតឡើងឡើយ ។ ពាក្យថា **អនុប្បន្នានំ កុសលានំ - កុសលដែលមិនទាន់កើត** គឺ កុសលធម៌ មានបឋមជ្ឈានជាដើម ដែលខ្លួនមិនទាន់បាន ។ ពាក្យថា **ឧប្បន្នានំ - ដែលកើតហើយ** គឺ កុសលធម៌

ទាំងឡាយនោះឯង ដែលខ្លួនបានហើយ ។ ពាក្យថា **ឋិតិយា - ដើម្បីតាំងមាំ** គឺ ដើម្បីតាំងនៅដោយការកើតបន្តរឿយៗ ។ ពាក្យថា **អសម្មោសាយ - ដើម្បីមិនដាច់ខ្សែ** គឺ ដើម្បីមិនឱ្យវិនាសវិញ ។ ពាក្យថា **ភិយ្យោភាវាយ - ដើម្បីចម្រើនឡើង** គឺ ដើម្បីចម្រើនក្រៃលែងឡើង ។ ពាក្យថា **វេបុល្លាយ** គឺ ដើម្បីភាពបរិបូរណ៍ ។ ពាក្យថា **ភាវនាយ ពារិបូរិយា** គឺ ដើម្បីការសម្រេចបរិបូរណ៍ ។ សូម្បីសម្មាវាយាមៈ ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលគិតមិនឱ្យកើតអកុសលដែលមិនទាន់កើតជាដើមផ្សេងគ្នា ។ តែក្នុងខណៈមគ្គ វីរិយៈផ្ទេកខាងកុសលមានតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឱ្យអង្គមគ្គបរិបូរណ៍ ព្រោះឱ្យសម្រេចកិច្ច ក្នុងឋានទាំង ៤ នេះ ដូចគ្នា នេះឈ្មោះថា **សម្មាវាយាមៈ** ។

**សម្មាវាយាមៈ** មានការផ្គងចិត្តឡើង ជាលក្ខណៈ , មានសម្មប្បធាន ៤ ដែលញ៉ាំងអកុសលធម៌មិនទាន់កើតឡើង មិនឱ្យកើតឡើងជាដើម ជាកិច្ច , មានការលះបង់មិច្ឆាវាយាមៈ ជាអាការប្រាកដ ។

## សម្មាសតិ

សូម្បី **សម្មាសតិ** ក៏ផ្សេងគ្នាក្នុងខាងដើម ព្រោះចិត្តដែលកំណត់អារម្មណ៍ មានកាយជាដើមផ្សេងគ្នា តែក្នុងខណៈនៃមគ្គ សតិតែម្យ៉ាងប៉ុណ្ណោះ កើតឡើងឱ្យអង្គមគ្គបរិបូរណ៍ ឱ្យសម្រេចកិច្ចក្នុងឋានទាំង ៤ នេះឈ្មោះថា **សម្មាសតិ** ។

**សម្មាសតិ** មានការតាំងសតិទុកមាំទាំ ជាលក្ខណៈ , មានការមិនភ្លេចជាកិច្ច , មានការលះបង់មិច្ឆាសតិ ជាអាការប្រាកដ ។

អកុសលខន្ធទាំងឡាយ មានសុភសញ្ញាជាដើម ជាប្រធាន ប្រព្រឹត្តទៅដោយអំណាចនៃការចូលទៅទ្រទ្រង់ទុកនូវអាការថា ស្អាតជាដើម ក្នុងកាយជាដើម ឈ្មោះថា **មិច្ឆាសតិ** ។

ការកំណត់សភាវធម៌តាមសេចក្តីពិត ដែលជាអារម្មណ៍ ឈ្មោះថា **ឧបដ្ឋាន** ប្រែថា ទីតាំងមាំ ។ សតិ ជាគ្រឿងរក្សាកុសលចិត្តយ៉ាងពិសេស ព្រោះមានព្រះបាលីថា **អារក្ខបច្ចុប្បដ្ឋានា** ប្រែថា មានការរក្សាជាអាការប្រាកដ និងថា **សតារក្ខេន ចេតសា** ប្រែថា មានចិត្តត្រូវបានរក្សាដោយសតិ ។

## សម្មាសមាធិ

**ឈាន** ទាំងឡាយផ្សេងគ្នា ទាំងក្នុងខាងដើម ទាំងក្នុងខណៈនៃមគ្គ ។ ក្នុងខាងដើមផ្សេងគ្នាដោយសមាបត្តិ ។ ក្នុងខណៈនៃមគ្គផ្សេងគ្នាដោយមគ្គ ។ ពិតហើយ មគ្គទី ១ នៃមគ្គ ១ ខណៈ មានបឋមជ្ឈានជាបាទ , មគ្គទី ២ មានបឋមជ្ឈានជាបាទខ្លះ មានឈានណាមួយក្នុងទុតិយជ្ឈានជាដើម ជាបាទខ្លះ ។ មគ្គទី១ នៃមគ្គសូម្បី ១ ខណៈ មានឈានយ៉ាងណាមួយ មានទុតិយជ្ឈានជាដើម ជាបាទ , សូម្បីមគ្គទី ២ ជាដើម ក៏មានឈានយ៉ាងណាមួយ មានទុតិយជ្ឈានជាដើម ជាបាទខ្លះ មានបឋមជ្ឈានជាបាទខ្លះ ។ មគ្គទាំង ៤ ពោលដោយឈានដូចគ្នាក៏មាន ផ្សេងគ្នាក៏មាន ដូចគ្នាខ្លះក៏មាន ដោយប្រការដូច្នេះ។ នេះឯង ជាភាពផ្សេងគ្នានៃមគ្គនោះ ដោយការកំណត់ឈានជាបាទ ។ គប្បីជ្រាបអធិប្បាយដោយការកំណត់ឈានជាបាទ មុនមគ្គដែលកើត ព្រោះព្រះយោគាវចរបានបឋមជ្ឈាន ចេញចាកបឋមជ្ឈាន ចម្រើនវិបស្សនា ឈ្មោះថា

មានបឋមជ្ឈានជាបាទ , អង្គនៃ មគ្គ និង ពោជ្ឈង្គ រមែងមានគ្រប់ក្នុង បឋមជ្ឈាននេះដោយពិត ។ មគ្គដែលកើត ព្រោះព្រះយោគី បានទុតិយជ្ឈាន ចេញចាកទុតិយជ្ឈានហើយ ចម្រើនវិបស្សនា ឈ្មោះថា មានទុតិយជ្ឈានជាបាទ , ឯអង្គមគ្គក្នុងទុតិយជ្ឈាននេះ មាន ៧ ប្រការ ។ មគ្គដែលកើតដល់ព្រះយោគាវចរ ចេញចាកតតិយជ្ឈាន ហើយចម្រើនវិបស្សនា ឈ្មោះថា មានតតិយជ្ឈានជាបាទ , អង្គមគ្គក្នុងតតិយជ្ឈាននេះ មាន ៧ តែពោជ្ឈង្គមាន ៦ ប្រការ ។ សម្រាប់ព្រះយោគាវចរចេញចាកចតុត្ថជ្ឈាន រហូតដល់នេវសញ្ញា-នាសញ្ញាយតនៈ ក៏មានន័យដូចគ្នានឹងឈានពួក ៤ និងពួក ៥ រមែងកើតឡើងក្នុងអរូប , និងឈាននោះ ទ្រង់ពោលថា ជាលោកុត្តរ មិនមែនជាលោកិយ ។ សួរថា ក្នុងឈាន មានបឋមជ្ឈានជាដើមនេះ យ៉ាងណា ? ឆ្លើយថា ក្នុងឈានមានបឋមជ្ឈានជាដើមនេះ ព្រះយោគាវចរនោះ ចេញចាកឈានណាហើយ បានសោតាបត្តិមគ្គ ចម្រើនអរូបសមាបត្តិហើយកើតក្នុងអរូបភព មគ្គទាំង ៣ មានឈាននោះជាបាទ កើតឡើងដល់ព្រះយោគាវចរនោះ ក្នុងអរូបនោះ , ទ្រង់កំណត់មគ្គដែលមានឈានជាបាទតែម្យ៉ាង ដោយប្រការដូច្នេះ ។ តែព្រះថេរៈរូបខ្លះពោលថា កំណត់ខន្ធជាអារម្មណ៍នៃវិបស្សនា ។ រូបខ្លះពោលថា កំណត់អជ្ឈាស្រ័យបុគ្គល ។ រូបខ្លះពោលថា កំណត់វិបស្សនាជាវុដ្ឋានគាមិនី ។ វិនិច្ឆ័យវាទៈនៃព្រះថេរៈទាំងឡាយនោះ គប្បីជ្រាបតាមន័យ ដែលលោកពោលទុកក្នុងអធិការពោលដោយវុដ្ឋានគាមិនីវិបស្សនា " គម្ពីរវិសុទ្ធិមគ្គ " ។ ពាក្យថា **អយំ វុច្ចតិ ភិក្ខវេ** សម្មាសមាធិ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សម្មាសមាធិ មានន័យថា ធម៌នេះ ខាងដើមជាលោកិយ ខាងក្រោយជាលោកុត្តរសម្មា-

សមាធិ ។

**សម្មាសមាធិ** មានការមិនរាយមាយនៃចិត្ត ជាលក្ខណៈ , មានការតាំងចិត្តទុកយ៉ាងមាំ ជាកិច្ច , មានការលះបង់មិច្ឆាសមាធិ ជាអាការប្រាកដ ។

## សម្មោហវិនោទនី អដ្ឋកថា ព្រះវិភង្គ
## " លោកិយមគ្គ និងលោកុត្តរមគ្គ "

បណ្តាមគ្គដែលជាលោកិយ និងលោកកុត្តរពួកណា ក្នុងលោកិយមគ្គទាំងអស់ រមែងមានអារម្មណ៍យ៉ាងណាមួយ ក្នុងអារម្មណ៍ ៦ តាមសមគួរ តែក្នុងលោកុត្តរមគ្គ បញ្ញាចក្ខុ ( ចក្ខុ គឺ បញ្ញា ) មាននិព្វានជាអារម្មណ៍ ដកចេញនូវអវិជ្ជានុស័យ របស់ព្រះអរិយសាវ័កអ្នកប្រព្រឹត្តដើម្បីចាក់ធ្លុះសច្ចៈ ៤ ជា **សម្មាទិដ្ឋិ** ។

ម្យ៉ាងទៀត ការលើកចិត្តឡើងកាន់ផ្លូវព្រះនិព្វាន ដែលសម្បយុត្តដោយសម្មាទិដ្ឋិនោះ ហើយដកនូវមិច្ឆាសង្កប្បៈ ៣ យ៉ាង របស់បុគ្គលអ្នកដល់ព្រមដោយទិដ្ឋិនោះ ជា **សម្មាសង្កប្បៈ** ។

**ធម្មជាតិ** ដែលជាគ្រឿងវៀរចាកមិច្ឆាវាចា ដែលសម្បយុត្តដោយសម្មាសង្កប្បៈ ដកចេញនូវវចីទុច្ចរិត ៤ យ៉ាង របស់បុគ្គលអ្នកដល់ព្រមដោយសម្មាទិដ្ឋិ និង សម្មាសង្កប្បៈនោះ ជា **សម្មាវាចា** ។

**ធម្មជាតិ** ដែលជាគ្រឿងវៀរចាកកាយទុច្ចរិត ៣ យ៉ាង ដែលសម្បយុត្តដោយសម្មាវាចានោះ កាត់ផ្តាច់នូវមិច្ឆាកម្មន្តៈ របស់បុគ្គលអ្នកវៀរចាកហើយ

ជា **សម្មាកម្មន្ត** ។

**ធម្មជាតិ** ដែលជាគ្រឿងវៀរចាកមិច្ឆាអាជីវៈ ដែលជាធម្មជាតិបរិសុទ្ធនៃសម្មាវាចា និងសម្មាកម្មន្តៈពួកនោះ ជាធម៌សម្បយុត្តដោយសម្មាវាចា និងសម្មាកម្មន្តៈនោះៗ ព្រមទាំងកាត់ផ្តាច់នូវអនុស័យ ដែលមានការលលួងជាដើម ជា **សម្មាអាជីវៈ** ។

ម្យ៉ាងទៀត វីរិយារម្ភៈ ( ការប្រារព្ធព្យាយាម ) របស់បុគ្គលអ្នកតាំងនៅក្នុងសីល ពោលគឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ ដែលសមគួរដល់សីលនោះៗ សម្បយុត្តដោយសីលនោះ កាត់ផ្តាច់នូវការរួញរា ឱ្យសម្រេចនូវការមិនកើតឡើងនូវអកុសលដែលមិនទាន់កើតឡើង លះបង់អកុសលដែលកើតឡើងហើយ ញុំាងកុសលដែលមិនកើតឡើងឱ្យកើតឡើង ដែលកើតឡើងហើយ ឱ្យតាំងនៅ ជា **សម្មាវាយាមៈ** ។

ការដែលចិត្តមិនវង្វេងភ្លេចនៃអ្នកព្យាយាមយ៉ាងនោះ សម្បយុត្តដោយសម្មាវាយាមៈ ដកចេញនូវមិច្ឆាសតិ ឱ្យសម្រេចជាកាយានុបស្សនាជាដើម ក្នុងអារម្មណ៍ មានកាយជាដើម ជា **សម្មាសតិ** ។

ការដែលចិត្តមានអារម្មណ៍តែមួយ របស់អ្នករក្សាចិត្ត ដែលអនុត្តរសតិចាត់ចែងល្អហើយ សម្បយុត្តដោយសម្មាសតិ និងដកចេញនូវមិច្ឆាសមាធិ ជា **សម្មាសមាធិ** ដោយប្រការដូច្នេះ ។

## មគ្គជា វិជ្ជា និង ចរណៈ

ម្យ៉ាងទៀត លោកុត្តរមគ្គណា និង លោកិយមគ្គដែលដល់នូវការរាប់ថា

ជាទុក្ខនិរោធគាមិនីបដិបទា ( បដិបទាទៅកាន់ទីរលត់ទុក្ខ ) មគ្គនោះឯង ទាំងជាវិជ្ជា និងចរណៈ ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ទ្រង់សង្គ្រោះដោយ **វិជ្ជា** ធម៌ដ៏សេស ទ្រង់សង្គ្រោះដោយ **ចរណៈ** ។

ម្យ៉ាងទៀត មគ្គនោះ ទាំងជាសមថៈ និង វិបស្សនា ព្រោះសម្មាទិដ្ឋិ និង សម្មាសង្កប្បៈ ទាំង ២ នោះ ទ្រង់សង្គ្រោះដោយ **វិបស្សនាញាណ** ធម៌ក្រៅពីនេះទ្រង់សង្គ្រោះដោយ **សមថញាណ** ។

ម្យ៉ាងទៀត មគ្គនោះ ទាំងជាខន្ធ ៣ និង សិក្ខា ៣ ព្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ទាំង ២ នោះ ទ្រង់សង្គ្រោះដោយបញ្ញាខន្ធ ធម៌ ៣ ក្នុងលំដាប់នៃសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ទ្រង់សង្គ្រោះជាសីលក្ខន្ធ ( ធម៌ )ដ៏សេសទ្រង់សង្គ្រោះជាសមាធិខន្ធ ព្រមទាំងធម៌ពួកនោះឯង សង្គ្រោះដោយអធិប្បញ្ញា-សិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា ។

ព្រះអរិយៈប្រកបដោយមគ្គណា ជាអ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ដូចបុគ្គលដើរផ្លូវឆ្ងាយ ប្រកបដោយចក្ខុទាំង ២ ដែលអាចក្នុងការឃើញ និងជើងទាំង ២ ដែលអាចក្នុងការដើរ វៀរចាកទីបំផុត ២ យ៉ាង គឺ :

កាមសុខល្លិកានុយោគ ដោយវិបស្សនាញាណ និងអត្តកិលមថានុយោគ ដោយសមថញាណ ធ្វើដំណើរឡើងកាន់មជ្ឈិមាបដិបទា ទម្លាយនូវកងមោហៈ ដោយបញ្ញាខន្ធ កងទោសៈដោយសីលក្ខន្ធ កងលោភៈដោយសមាធិខន្ធ សម្រេចបាននូវសម្បត្តិ ៣ ប្រការ គឺ បញ្ញាសម្បទាដោយអធិប្បញ្ញាសិក្ខា សីលសម្បទាដោយអធិសីលសិក្ខា សមាធិសម្បទាដោយអធិចិត្តសិក្ខា រមែងធ្វើឱ្យជាក់ច្បាស់នូវអមតៈ គឺ ព្រះនិព្វាន ឈ្មោះថា ចុះកាន់អរិយភូមិ ពោលគឺ

សម្មត្តនិយាម ( និយាមដ៏ប្រពៃ ) ដែលវិចិត្រដោយរតនៈ គឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ ប្រកបដោយ លំអបទដើម បទកណ្ដាល បទចុង ដោយប្រការដូច្នេះឯង ។

ពាក្យថា **ឥតិ អជ្ឈត្តំ វា** ឬ **ក្នុងខាងក្នុង** មានន័យថា ពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ព្រោះកំណត់សច្ចៈ ៤ របស់ខ្លួន របស់អ្នកដទៃ ឬ ព្រោះកំណត់សច្ចៈ ៤ របស់ខ្លួនតាមកាល របស់អ្នកដទៃតាមកាលយ៉ាងនេះ ។ រីឯការកើតឡើង និងការវិនាសទៅ ក្នុងសច្ចបព្វៈនេះ គប្បីជ្រាបតាមន័យនៃការកើតឡើង និងការអស់ទៅនៃសច្ចៈ ៤ តាមសេចក្ដីពិត ។ ពាក្យដទៃក្រៅពីនេះមានន័យដូចដែលពោលហើយនោះឯង ។

## សរុបសេចក្ដី

លំដាប់ពាក្យ មានប្រមាណត្រឹមប៉ុណ្ណេះ កម្មដ្ឋាន ២១ គឺ អានាបានស្សតិ ១ , ចតុឥរិយាបថបព្វៈ ១ , ចតុសម្បជញ្ញបព្វៈ ១ , ទ្វត្តឹង្សាការ ១ ចតុធាតុវវដ្ឋាន ១ , សីវថិកា ៩ , វេទនានុបស្សនា ១ , ចិត្តានុបស្សនា ១ , នីវរណបរិគ្គហៈ ១ , ខន្ធបរិគ្គហៈ ១ , អាយតនបរិគ្គហៈ ១ , ពោជ្ឈង្គបរិគ្គហៈ ១ , សច្ចបរិគ្គហៈ ១ ។

ក្នុងបណ្ដាកម្មដ្ឋាន ២១ នោះ កម្មដ្ឋាន ១១ គឺ អានាបាន ១ , ទ្វត្តឹង្សាការ ១ , សីវថិការ ៩ ជាអប្បនាកម្មដ្ឋាន ។ តែព្រះមហាសីវត្ថេរ អ្នករចនាគម្ពីរទីឃនិកាយ ពោលថា ព្រះមានព្រះភាគ ត្រាស់សីវថិកាបព្វៈ ៩ ដោយអាទីនវា-

នុបស្សនា ។ ព្រោះដូច្នោះ តាមមតិរបស់លោក អានាបាន និង ទ្វត្តឹង្សាការ ២ ប៉ុណ្ណោះ ជាអប្បនាកម្មដ្ឋាន ដ៏សេសជាឧបចារកម្មដ្ឋាន , សួរថា ការតាំងមាំកើតក្នុងកម្មដ្ឋាននោះ ទាំងអស់ ឬ មិនកើត ? ឆ្លើយថា មិនមែនមិនកើតទេ , ការតាំងមាំមិនកើតក្នុងឥរិយាបថ សម្បជញ្ញៈ នីវរណៈ និងពោជ្ឈង្គៈ តែងកើតក្នុងកម្មដ្ឋានដ៏សេស ។ ចំណែកព្រះមហាសិវត្ថេរ ពោលថា ការតាំងមាំរមែងកើតក្នុងកម្មដ្ឋានទាំងនោះ ( ទាំងអស់ ) ព្រោះព្រះយោគីនេះ រមែងកំណត់យ៉ាងនេះថា ឥរិយាបថ ៤ មានដល់យើង ឬ មិនមានហ្ន៎ ! សម្បជញ្ញៈ ៤ , នីវរណៈ ៥ , ពោជ្ឈង្គ ៧ , មានដល់យើង ឬ មិនមានហ្ន៎ ! ព្រោះដូច្នោះ ការតាំងមាំនោះ រមែងមានក្នុងកម្មដ្ឋានទាំងអស់ ។

( ចប់ ធម្មានុបស្សនាសតិប្បដ្ឋានភាវនា )

# មិច្ឆាទិដ្ឋិ

## " សេចក្តីប្រកាន់ស្អិត និង ស្ទាបអង្អែល "

## ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ )

ពាក្យថា **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ស្អិត និង ស្ទាបអង្អែល តើដូចម្តេច ?

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែលនូវរូបថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវវេទនា សញ្ញា សង្ខារ វិញ្ញាណថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែលនូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែលនូវចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជីវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវវេទនា កើតពីចក្ខុសម្ផស្ស វេទនាកើតពីសោតសម្ផស្ស វេទនាកើតពីឃានសម្ផស្ស

វេទនាកើតជីវ្ហាសម្ផស្ស វេទនាកើតពីកាយសម្ផស្ស វេទនាកើតពីមនោសម្ផស្ស ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា ធម្មសញ្ញាថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ រូបសញ្ចេតនា សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនាថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហាថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ រូបវិតក្កៈ សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែលនូវរូបវិចារៈ សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ ថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវ បឋវីកសិណ អាបោកសិណ តេជោកសិណ វាយោកសិណ នីលកសិណ បីតកសិណ លោហិតកសិណ ឱទាតកសិណ អាកាសកសិណ វិញ្ញាណកសិណថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែលនូវ សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ ។ ល ។ ទឹកមាត់ ទឹកសំបោរ ទឹករំអិល ទឹកមូត្រ ខួរក្នុងក្បាលថា នោះជាអញ នោះជា របស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺសេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជីវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ ចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជីវ្ហាធាតុ រសធាតុ ជីវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុសនិងស្ទាបអង្អែលនូវចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជីវ្ហិន្ទ្រិយ កាយិន្ទ្រិយ មនិន្ទ្រិយ ជីវិតិន្ទ្រិយ សោមនស្សិន្ទ្រិយ ទោមនស្សិន្ទ្រិយ ឧបេក្ខិន្ទ្រិយ សទ្ធិន្ទ្រិយ វិរិយិន្ទ្រិយ សតិន្ទ្រិយ សមាធិន្ទ្រិយ បញ្ញិន្ទ្រិយថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និងស្ទាបអង្អែលនូវកាមធាតុ រូបធាតុ អរូបធាតុ កាមភព រូបភព សញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព បញ្ចវោការភព បឋមជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន មេត្តាចេតោវិមុត្តិ ករុណាចេតោវិមុត្តិ មុទិតាចេតោ-វិមុត្តិ ឧបេក្ខាចេតោវិមុត្តិ អាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណញ្ចាយតន-

សមាបត្តិ អាកិញ្ចញ្ញាយតនសមាបត្តិ នេវសញ្ញានាសញ្ញាយតនសមាបត្តិថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ ។

- **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុសនិងស្ទាបអង្អែលនូវ អវិជ្ជា សង្ខារ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា តណ្ហា ឧបាទាន ភព ជាតិ ជរា និង មរណៈថា នោះជាអញ នោះជារបស់អញ នោះជាខ្លួនរបស់អញ , **ទិដ្ឋិ** គឺ សេចក្តីប្រកាន់ខុស និង ស្ទាបអង្អែល មានដូច្នេះឯង ។

- **ឯតំ មម** " នោះជារបស់អញ " ជាទិដ្ឋិដែលមានការប្រកាន់ ព្រោះ **តណ្ហា** ជាមូល ។

- **ឯសោហមស្មិ** " នោះជាអញ " ជាទិដ្ឋិដែលមានការប្រកាន់ ព្រោះ **មានះ** ជាមូល ។

- **ឯសោ មេ អត្តា** " នោះជាខ្លួនរបស់អញ " ជាការប្រកាន់ដោយ **ទិដ្ឋិ** នោះឯង ។

## ហេតុនៃទិដ្ឋិ ៨ យ៉ាង

ខន្ធទាំងឡាយ១ អវិជ្ជា១ ផស្សៈ១ សញ្ញា១ វិតក្កៈ១ អយោនិសោមនសិការ១ បាបមិត្ត១ បរតោឃោសៈ១ ជាហេតុនៃទិដ្ឋិ ព្រោះអត្ថថា ជាទីតាំងកើតឡើងព្រមនៃទិដ្ឋិ ។

## ការរួបរឹតនៃទិដ្ឋិ ១៨ យ៉ាង

**១**- ដំណើរ គឺ ទិដ្ឋិ **២**- ការប្រកាន់ គឺ ទិដ្ឋិ

| | | | |
|---|---|---|---|
| ៣. ផ្លូវកន្តារ | គឺ ទិដ្ឋិ | ៤. ចម្រូង | គឺ ទិដ្ឋិ |
| ៥. ការវិបត្តិ | គឺ ទិដ្ឋិ | ៦. សំយោជនៈ | គឺ ទិដ្ឋិ |
| ៧. សរ | គឺ ទិដ្ឋិ | ៨. ការចង្អៀតចិត្ត | គឺ ទិដ្ឋិ |
| ៩. កង្វល់ | គឺ ទិដ្ឋិ | ១០. ចំណង | គឺ ទិដ្ឋិ |
| ១១. ជ្រោះ | គឺ ទិដ្ឋិ | ១២. អនុស័យ | គឺ ទិដ្ឋិ |
| ១៣. កម្តៅ | គឺ ទិដ្ឋិ | ១៤. ក្រហល់ក្រហាយ | គឺ ទិដ្ឋិ |
| ១៥. គ្រឿងចាក់ស្រែះ | គឺ ទិដ្ឋិ | ១៦. គ្រឿងប្រកាន់ | គឺ ទិដ្ឋិ |
| ១៧. ការប្រកាន់ស្អិត | គឺ ទិដ្ឋិ | ១៨. ការស្ទាបអង្អែល | គឺ ទិដ្ឋិ |

នេះ សេចក្តីរួបរឹត គឺ ទិដ្ឋិ ១៨ យ៉ាង ។

## ទិដ្ឋិ មាន ១៦ យ៉ាង

១. អស្សាទទិដ្ឋិ ២. អត្តានុទិដ្ឋិ ៣. មិច្ឆាទិដ្ឋិ ៤. សក្កាយទិដ្ឋិ ៥. សកាយវត្ថុកសស្សតទិដ្ឋិ ៦. សក្កាយវត្ថុកឧច្ឆេទទិដ្ឋិ ៧. អន្តគ្គាហិកទិដ្ឋិ ៨. បុព្វន្តានុទិដ្ឋិ ៩. អបរន្តានុទិដ្ឋិ ១០. សញ្ញោជនិកទិដ្ឋិ ១១.ទិដ្ឋិដែលជាប់ដោយមានៈថាអញ ១២. ទិដ្ឋិដែលជាប់ដោយមានៈថា របស់អញ ១៣. អត្តវាទប្បដិសំយុត្តទិដ្ឋិ ១៤. លោកវាទប្បដិសំយុត្តទិដ្ឋិ ១៥. ភវទិដ្ឋិ ១៦. វិភវទិដ្ឋិ នេះទិដ្ឋិ ១៦ យ៉ាង ។

## អធិប្បាយ ទិដ្ឋិ ពីមួយ ៗ

១. **អស្សាទទិដ្ឋិ** គឺ ការប្រកាន់ស្អិត និង ការស្ទាបអង្អែលថា សុខ និង

សោមនស្សកើតឡើង ព្រោះអាស្រ័យរូប នេះឈ្មោះថា អស្សាទៈចំពោះរូបនោះ ។

**២. អត្តានុទិដ្ឋិ** គឺ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានជួបប្រទះនឹងពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ចិត្តក្នុងធម៌របស់ព្រះអរិយៈ មិនឈ្លាសវៃចំពោះធម៌របស់សប្បុរស មិនបានហាត់ចិត្តក្នុងធម៌របស់សប្បុរស តែងពិចារណាឃើញថា :

១. រូបជាខ្លួន ២. ខ្លួនមានរូប ៣. រូបមានក្នុងខ្លួន ៤. ខ្លួនមានក្នុងរូប , ក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏មានទំនងដូចគ្នានេះឯង ទើបបានជាអត្តានុទិដ្ឋិ ដោយអាការ **២០** យ៉ាង ។

## អដ្ឋកថា

- ការប្រកាន់ **រូបថាជាខ្លួន** គឺ ប្រកាន់រូបខន្ធ និង កសិណរូប ។
- ការប្រកាន់ **រូបសុទ្ធ** ថាជាខ្លួន មាន ១ ។
- ការប្រកាន់ **អរូប** ថាជាខ្លួន មាន **៧** គឺ :

ខ្លួនមានរូប១ រូបមានក្នុងខ្លួន១ ខ្លួនមានក្នុងរូប១ វេទនាជាខ្លួន១ សញ្ញាជាខ្លួន១ សង្ខារជាខ្លួន១ វិញ្ញាណជាខ្លួន១ ។

- ការប្រកាន់ **រូប** និង **អរូប** លាយគ្នាថាជាខ្លួនមាន **១២** ដោយវេទនា **៣** ជាដើម , ក្នុង ( អរូប ) ខន្ធ **៤** យ៉ាង នេះគឺ ខ្លួនមានវេទនា វេទនាមានក្នុងខ្លួន ខ្លួនមានក្នុងវេទនា ។

បុថុជ្ជនប្រកាន់ថា សញ្ញា សង្ខារ វិញ្ញាណ រូប ថាជាខ្លួន មានន័យថា ធ្វើអរូប មានសញ្ញាជាដើម លាយគ្នានឹងរូប ហើយប្រកាន់ថាជាខ្លួន , បថុជ្ជន តែងប្រកាន់តាមការប្រាកដ ដូចបុគ្គលឆ្កួត ។ សញ្ញា សង្ខារ វិញ្ញាណ ក៏មាន ន័យដូចគ្នា ។

ទិដ្ឋិទាំង **២០** នេះ ហាមមគ្គ តែមិនហាមសួគ៌ លះបង់ដាច់ជាសមុច្ឆេទ ដោយសោតាបត្តិមគ្គ ។

**៣- មិច្ឆាទិដ្ឋិ** គឺ ការប្រកាន់ពោលយ៉ាងនេះ ចំពោះវត្ថុថា ទានដែល បុគ្គលឱ្យហើយ មិនមានផល , ការបូជាតូច បូជាធំមិនមានផល , ផលវិបាកនៃ កម្មដែលបុគ្គលធ្វើល្អ និង អាក្រក់មិនមាន , លោកនេះមិនមាន លោកខាង មុខមិនមាន , មាតាបិតាមិនមានគុណ , សត្វជាឱបបាតិកៈកំណើតមិនមាន , សមណៈព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រព្រឹត្តត្រឹមត្រូវ ធ្វើឱ្យជាក់ ច្បាស់ដោយបញ្ញារបស់ខ្លួន នូវលោកនេះ និងលោកខាងមុខ ហើយប្រកាស បាន មិនមាន នេះឈ្មោះថា **ទិដ្ឋិ** គឺ ការប្រកាន់ស្អិត និង ការស្ទាបអង្អែលនៃ មិច្ឆាទិដ្ឋិ ។ ទិដ្ឋិមិនមែនវត្ថុ វត្ថុមិនមែនទិដ្ឋិ ទិដ្ឋិដោយឡែក វត្ថុដោយឡែក ។

**៤- សក្កាយទិដ្ឋិ** គឺ អត្តានុទិដ្ឋិនោះឯង តែលោកពោលទុក ដើម្បី សម្តែងពាក្យបរិយាយក្នុងទីដទៃ នេះឯង ការប្រកាន់ស្អិតនៃសក្កាយទិដ្ឋិ មាន អាការ **២០** យ៉ាង គឺ :

- បុគ្គលពិចារណាឃើញ **រូបថាជាខ្លួន** គឺ ប្រកាន់ រូបក្ខន្ធ និង កសិណ-

រូបថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **ខ្លួនមានរូប រូបមានក្នុងខ្លួន ខ្លួនមានក្នុងរូប** គឺ ប្រកាន់ វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញ **វេទនាថាជាខ្លួន** គឺ ប្រកាន់វេទនាដែលកើតពីចក្ខុសម្ផស្សជាដើម ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញ **ខ្លួនមានវេទនា វេទនាមានក្នុងខ្លួន ខ្លួនមានក្នុងវេទនា** គឺ ប្រកាន់ សញ្ញា សង្ខារ វិញ្ញាណ រូប ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **សញ្ញាជាខ្លួន** គឺ ប្រកាន់សញ្ញាដែលកើតពីចក្ខុសម្ផស្សជាដើម ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **ខ្លួនមានសញ្ញា សញ្ញាមានក្នុងខ្លួន ខ្លួនមានក្នុងសញ្ញា** គឺ ប្រកាន់ រូប វេទនា សង្ខារ វិញ្ញាណ ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **សង្ខារជាខ្លួន** គឺ ប្រកាន់ចេតនាដែលកើតពីចក្ខុសម្ផស្សជាដើម ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **ខ្លួនមានសង្ខារ សង្ខារមានក្នុងខ្លួន ខ្លួនមានក្នុងសង្ខារ** គឺ ប្រកាន់ រូប វេទនា សញ្ញា វិញ្ញាណ ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **វិញ្ញាណជាខ្លួន** គឺ ប្រកាន់ចក្ខុវិញ្ញាណជាដើម ថាជាខ្លួន ។

- បុគ្គលពិចារណាឃើញថា **ខ្លួនមានវិញ្ញាណ វិញ្ញាណមានក្នុងខ្លួន ខ្លួនមានក្នុងវិញ្ញាណ** គឺ ប្រកាន់ រូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន ។

**៥- សកាយវត្ថុកសស្សតទិដ្ឋិ** គឺ សស្សតទិដ្ឋិ ដែលមានការប្រកាន់ស្អិតនូវសក្កាយវត្ថុកៈ ដោយអាការ **១៥** យ៉ាង , បថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះមិនដឹង មិនបានឃើញពួក ព្រះអរិយៈ...... តែងប្រកាន់ថា :

**១**-ខ្លួនមានរូប **២**-រូបមានក្នុងខ្លួន **៣**-ខ្លួនមានក្នុងរូប ក្នុងទីនេះប្រកាន់វេទនា សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ។

**៤**-ខ្លួនមានវេទនា **៥**-វេទនាមានក្នុងខ្លួន **៦**-ខ្លួនមានក្នុងវេទនា ក្នុងទីនេះប្រកាន់ រូប សញ្ញា សង្ខារ វិញ្ញាណ ថាជាខ្លួន ។

**៧**-ខ្លួនមានសញ្ញា **៨**-សញ្ញាមានក្នុងខ្លួន **៩**-ខ្លួនមានក្នុងសញ្ញា ក្នុងទីនេះប្រកាន់ រូប វេទនា សង្ខារ វិញ្ញាណ ថាជាខ្លួន ។

**១០**-ខ្លួនមានសង្ខារ **១១**-សង្ខារមានក្នុងខ្លួន **១២**-ខ្លួនមានក្នុងសង្ខារ ក្នុងទីនេះការប្រកាន់ថា រូប វេទនា សញ្ញា វិញ្ញាណ ថាជាខ្លួន ។

**១៣**-ខ្លួនមានវិញ្ញាណ **១៤**-វិញ្ញាណមានក្នុងខ្លួន **១៥**-ខ្លួនមានក្នុងវិញ្ញាណក្នុងទីនេះប្រកាន់ រូប វេទនា សញ្ញា សង្ខារ ថាជាខ្លួន ។ សស្សតទិដ្ឋិនេះ មានសក្កាយៈជាវត្ថុ ។

**៦-សក្កាយវត្ថុកឧច្ឆេទទិដ្ឋិ** គឺ ការប្រកាន់ស្អិតនៃឧច្ឆេទទិដ្ឋិ ជាសក្កាយវត្ថុកៈ ដោយអាការ **៥** យ៉ាង គឺ :

**១**- ពិចារណាឃើញថា រូបជាខ្លួន **២**- វេទនាជាខ្លួន **៣**- សញ្ញាជាខ្លួន **៤**- សង្ខារជាខ្លួន **៥**- ពិចារណាឃើញថា វិញ្ញាណជាខ្លួន ។ ឧច្ឆេទទិដ្ឋិនេះ មានសក្កាយៈជាវត្ថុ ។

**៧- អន្តគ្គាហិកទិដ្ឋិ** គឺ ជាការប្រកាន់ស្អិតថា លោកទៀង លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះសរីរៈនោះ ជីវិតដទៃ សរីរៈដទៃ សត្វខាងមុខអំពីសេចក្តីស្លាប់ កើតទៀត , មិនកើតទៀត , កើតទៀតក៏មានមិនកើតទៀតក៏មាន , កើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមែន ។

**អន្តគ្គាហិកទិដ្ឋិ** គឺ ប្រកាន់ស្អិតនូវ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងន័យខាងលើនេះ ។

បទថា **លោក** បានដល់ តួខ្លួន ។

បទថា **សរីរៈ ឬ ជីវិត** បានដល់ ខន្ធ ៥ ។

បទថា **ខាងមុខអំពីសេចក្តីស្លាប់** គឺ បន្ទាប់ពីខន្ធបែកធ្លាយ ។

**៨- បុព្វន្តានុទិដ្ឋិ** គឺ ទិដ្ឋិដែលតាមឃើញខន្ធជាអតីត ប្រកាន់ខុសដោយអាការ **១៨** យ៉ាង គឺ **សស្សតវាទ ៤** ជាទិដ្ឋិដែលពោលថា ខ្លួន និង លោក ទៀង , **ឯកច្ចសស្សតវាទ ៤** ជាទិដ្ឋិដែលប្រកាន់ថា ខ្លួន និង លោក ទៀងខ្លះ , **អន្តានន្តវាទ ៤** ជាទិដ្ឋិប្រកាន់ថា លោកមានទីបំផុត និង មិនមានទីបំផុត , **អមរាវិក្ខេបវាទ ៤** ជាទិដ្ឋិដែលប្រកាន់ក្នុងការបោះពាក្យ បោះសំដីមិនឱ្យស្លាប់ពាក្យ , **អធិច្ចសមុប្បន្នវាទ ២** ជាទិដ្ឋិដែលប្រកាន់ថា ខ្លួន និង លោកកើតឡើងរឿយ ៗ ។

**៩- អបរន្តានុទិដ្ឋិ** គឺ ការតាមឃើញក្នុងខន្ធជាអនាគត រមែងប្រកាន់ខុសដោយអាការ **៤៤** យ៉ាង មាន **សញ្ញីវាទ** ជាទិដ្ឋិប្រកាន់ថា ខ្លួនស្លាប់ហើយ

មានសញ្ញា **១៦** យ៉ាង , **អសញ្ញីវាទ** ប្រកាន់ថា ខ្លួនស្លាប់ហើយ មិនមានសញ្ញា **៨** , **នេវសញ្ញិនាសញ្ញិវាទ** ប្រកាន់ថា ខ្លួនស្លាប់ហើយ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន **៨** , **ឧច្ឆេទវាទ** ប្រកាន់ថា ខ្លួនស្លាប់ហើយសូន្យ **៧** , **ទិដ្ឋធម្មនិព្វានវាទ** ប្រកាន់ថា និព្វានជាបច្ចុប្បន្ន ជាធម៌ដ៏ក្រៃលែងរបស់សត្វ **៥**។

**១០. សំញោជនិកទិដ្ឋិ** គឺ ការប្រកាន់ស្អិតនៃទិដ្ឋិ ប្រកបដោយសញ្ញោជនៈ ដោយអាការ ១៨ យ៉ាង ( ន័យ គឺ ដូចការរូបរឹតនៃទិដ្ឋិទាំង ១៨ យ៉ាង ) ។

**១១. វិនិពន្ធទិដ្ឋិ** គឺ ការប្រកាន់ថា **អញ** ដោយអាការ ១៨ យ៉ាង មានមានះជាមូល គឺ ប្រកាន់អាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ និង វិញ្ញាណ ៦ ។

**១២. វិនិពន្ធទិដ្ឋិ** គឺ មានះប្រកាន់ថា **របស់អញ** , ប្រកាន់អាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ វិញ្ញាណ ៦ ។

**១៣. អត្តវាទប្បដិសំយុត្តទិដ្ឋិ** គឺ ការប្រកាន់ថា រូបជាខ្លួន ខ្លួនមានរូប រូបនៅក្នុងខ្លួន ខ្លួននៅក្នុងរូប , រីឯ វេទនា សញ្ញា សង្ខារ វិញ្ញាណ ក៏រាប់ដូចគ្នាដូច្នេះ ប្រកាន់ដោយអាការ ២០ ។

**១៤- លោកវាទប្បដិសំយុត្តទិដ្ឋិ** គឺ ការប្រកាន់ ដោយអាការ ៨ យ៉ាង គឺ ប្រកាន់ថា ខ្លួននិងលោក ទៀង , មិនទៀង , ទៀងក៏មានមិនទៀងក៏មាន , ទៀងក៏មិនមែនមិនទៀងក៏មិនមែន និងប្រកាន់ថា មានទីបំផុត , មិនមានទីបំផុត , មានទីបំផុតក៏មានមិនមានទីបំផុតក៏មាន , មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ។

**១៥- ភវទិដ្ឋិ** គឺ ការប្រកាន់ស្អិត ដោយការក្រាញនៅ ប្រកាន់ថា ទៀង ដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា ទេវតា និងមនុស្សពួកមួយ កាលតថាគតសម្តែងធម៌ដើម្បីរំលត់ភព ចិត្តរបស់គេ រមែងមិនស្ទុះទៅ មិនត្រេកអរក្នុងព្រះនិព្វាន ។

**១៦- វិភវទិដ្ឋិ** គឺ ការប្រកាន់ស្អិត ដោយការស្ទុះទៅ ប្រកាន់ថា ដាច់សូន្យ ដូចព្រះមានព្រះភាគទ្រង់ត្រាស់ថា ទេវតា និង មនុស្សពួកមួយ មានសេចក្តីរង្កៀសក្នុងភព ក៏ត្រេកអរក្នុងការដាច់សូន្យ វង្វេងក្នុងបដិបទានាំទៅកាន់ការរលត់ទុក្ខ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលវិបត្តិព្រោះទិដ្ឋិ គេមិនត្រូវសេពគប់ គេមិនត្រូវចូលទៅអង្គុយជិតទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិលាមក ទិដ្ឋិណា រាគៈណា រាគៈនោះមិនមែនទិដ្ឋិ ទិដ្ឋិក៏មិនមែនរាគៈ ទិដ្ឋិដោយឡែក រាគៈដោយឡែក ទិដ្ឋិណា រាគៈណា នេះលោកហៅថា **ទិដ្ឋិរាគៈ** បុគ្គលប្រកបដោយ ទិដ្ឋិនោះផង រាគៈនោះផង ឈ្មោះថា ជា

អ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ទានដែលទាយកឱ្យហើយ ដល់បុគ្គលអ្នកត្រេកអរក្នុង ទិដ្ឋិរាគៈ ជាទានមិនមានអានិសង្សច្រើនទេ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះជាធម្មជាតិលាមក ជាអស្សាទទិដ្ឋិ ជាមិច្ឆាទិដ្ឋិ បុរស បុគ្គលប្រកបដោយមិច្ឆាទិដ្ឋិ មានគតិ ២ គឺ នរក ១ កំណើតតិរច្ឆាន ១ កាយ កម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គល ប្រកបដោយមិច្ឆាទិដ្ឋិ កាន់យក ហើយក្តី វចីកម្មណា មនោកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គល កាន់យកហើយក្តី ចេតនាក្តី សេចក្តីប្រាថ្នាក្តី ការតម្កល់ទុកណាក្តី សង្ខារ ទាំងឡាយណាក្តី ( ដែលបុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយ ) ធម៌ទាំងអស់នោះ ប្រព្រឹត្តទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទី ពេញចិត្ត មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ប្រៀបដូចពូជស្តៅក្តី ពូជ ននោងព្រៃក្តី ពូជឃ្លោកល្វីងក្តី ដែលគេដាំក្នុងផែនដីសើម រមែងជញ្ជក់យក រសផែនដីណាក្តី ជញ្ជក់យករសទឹកណាក្តី ពូជទាំងអស់នោះ រមែងប្រព្រឹត្ត ទៅដើម្បីល្វីង ដើម្បីក្រពុល ដើម្បីមិនឆ្ងាញ់ពិសារ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ពូជឈើនោះ ជាវត្ថុដ៏អាក្រក់ មានឧបមាដូចម្តេចមិញ មានឧបមេយ្យ ដូចជា កាយកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែលបុរសបុគ្គលប្រកបដោយ មិច្ឆាទិដ្ឋិកាន់យកហើយក្តី វចីកម្មណា មនោកម្មណា បរិបូណ៌ដោយទិដ្ឋិ ដែល បុរសបុគ្គលប្រកបដោយមិច្ឆាទិដ្ឋិកាន់យកហើយក្តី ចេតនាក្តី សេចក្តីប្រាថ្នាក្តី ការតម្កល់ទុកណាក្តី សង្ខារទាំងឡាយណាក្តី ធម៌ទាំងអស់នោះ រមែងប្រព្រឹត្ត ទៅ ដើម្បីមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីពេញចិត្ត មិនជាប្រយោជន៍

ដើម្បីសេចក្ដីទុក្ខ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះថា ទិដ្ឋិ របស់បុគ្គលនោះ ជាធម្មជាតិដ៏លាមក ។

**បាសាទិកសូត្រ ( បិ.១៨ ) :** ម្នាលចុន្ទ **សតិប្បដ្ឋានទាំង ៤** ដែលតថាគតសម្ដែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីលះបង់ ដើម្បីឈានកន្លងនូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើមនេះផង នូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងមុខនេះផង យ៉ាងនេះឯង ។

( ចប់ ទិដ្ឋិកថា )

( សេចក្ដីពិស្ដារនៃទិដ្ឋិកថា មានក្នុងព្រហ្មជាលសូត្រ បិ.១៤ )

# ទិដ្ឋិវិសុទ្ធិ

វិសុទ្ធិទាំងឡាយដែលខ្ញុំម្ចាស់បានពោលមកហើយថា វិសុទ្ធិជាមូល ២ យ៉ាង គឺ **សីលវិសុទ្ធិ ១ ចិត្តវិសុទ្ធិ ១** ដែលព្រះយោគាវចរ ផ្ដើមចម្រើននូវការយល់ដឹង តាមរយៈការសិក្សារៀនសូត្រ និង ការសាកសួរ ក្នុងធម៌ទាំងឡាយដែលជា ( ភូមិ គឺ អារម្មណ៍នៃវិបស្សនា មានខន្ធជាដើម ) ទាំងឡាយនេះហើយ គប្បីធ្វើឱ្យដល់ព្រមចុះ ។ ក្នុងវិសុទ្ធិ ២ នោះ សីល ៤ យ៉ាង មានបាតិមោក្ខសំវរសីលជាដើម ដែលបរិសុទ្ធល្អ ឈ្មោះថា **សីលវិសុទ្ធិ** , សីល ៤ យ៉ាងនោះ ខ្ញុំម្ចាស់បានពោលឱ្យពិស្ដារក្នុងសីលនិទ្ទេសហើយ , ឯសមាបត្តិ ៨ ព្រមទាំងឧបចារៈ ឈ្មោះថា **ចិត្តវិសុទ្ធិ** , សូម្បីសមាបត្តិទាំងនោះ ខ្ញុំម្ចាស់ក៏បានពោលដោយអាការទាំងពួង ក្នុងសមាធិនិទ្ទេស ដែលពោលដោយមាតិកា គឺ **ចិត្ត** ហើយដូចគ្នា ព្រោះហេតុនោះ វិសុទ្ធិទាំង ២ នោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលខ្ញុំម្ចាស់ ( ព្រះពុទ្ធឃោសាចារ្យ ) បានពោលឱ្យពិស្ដារហើយក្នុងនិទ្ទេសទាំង ២ នោះចុះ ។ ចំណែកពាក្យណាដែលខ្ញុំម្ចាស់នឹងពោលទៅថា វិសុទ្ធិ ៥ ទៀត គឺ ទិដ្ឋិវិសុទ្ធិ កង្ខាវិតរណវិសុទ្ធិ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ បដិបទាញាណទស្សនវិសុទ្ធិ ញាណទស្សនវិសុទ្ធិ ទាំងនេះជាតួបញ្ញា ។

ការឃើញនូវនាមរូបទៅតាមសេចក្ដីពិត ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ក្នុងពាក្យនោះ ។

ក្នុងអភិធម្មាវតារសំដែងនូវសេចក្តីពិតនៃនាមរូប គឺ :

នាមតោ រូបតោ អញ្ញោ  សត្តោ វា បុគ្គលោបិ វា

អត្តា វា កោចិ នត្ថីតិ  និដ្ឋំ គច្ឆតិ សព្វទា ។

មិនមានវត្ថុដទៃដែលជា សត្វ បុគ្គល ឬ អត្តា គឺ មានតែនាមរូប ។

. ខន្ធាទីសុ ហិ ធម្មេសុ  ភូមិភូតេសុ យោគិនា

ឧគ្គហាទិវសេនេត្ថ  កត្វា បរិចយំ បន ។

. សីលំ ចិត្តវិសុទ្ធិញ្ច  សម្បាទេត្វា តតោ បរំ

ទិដ្ឋិសុទ្ធាទយោ បញ្ច  សម្បាទេន្តេន សុទ្ធិយោ ។

. តាយ បញ្ញាយ យុត្តេន ភីតេន  ជននាទិតោ

ភាវេតព្វា ភវាភាវំ  បត្ថយន្តេន ភិក្ខុនា ។

ប្រែថា : ភិក្ខុដែលប្រកបដោយសេចក្តីព្យាយាមបដិបត្តិ គប្បីធ្វើការសន្សំ ( នូវការយល់ឱ្យបានត្រឹមត្រូវ ) តាមរយៈការសិក្សាជាខាងដើម ក្នុងធម៌មានខន្ធជាដើម ញុំាងសីលវិសុទ្ធិ និង ចិត្តវិសុទ្ធិ ឱ្យដល់ព្រម ព្រះយោគាវចរជាអ្នកប្រកបដោយបញ្ញា ឃើញភ័យក្នុងជាតិ ប្រាថ្នានូវការផុតចាកការកើត គប្បីចម្រើនបញ្ញា ដើម្បីការបានសម្រេចនូវវិសុទ្ធិទាំង ៥ ចុះ ។

មហាដីកា : ខន្ធជាដើម ហៅថា **ភូមិ** គឺ អារម្មណ៍របស់វិបស្សនា , សីលវិសុទ្ធិ និងចិត្តវិសុទ្ធិ ជាមូល គឺជាឫសគល់នៃវិបស្សនា ចំណែកវិសុទ្ធិទាំង ៥ ជាសរីរៈ គឺជាតួវិបស្សនា ។

## លក្ខណៈរបស់នាមរូប

រុប្បនលក្ខណំ រូបំ នាមំ នមនលក្ខណំ
ឥតិ សង្ខេបតោ នាម- រូបំ សោ បរិគណ្ហាតិ

ព្រះយោគាវចរ រមែងកំណត់ចែក រូប និង នាម ដោយសង្ខេបថា **រូប** មានលក្ខណៈបែកធ្លាយ , **នាម** មានលក្ខណៈបង្អោនទៅកាន់ ( អារម្មណ៍ ) ។

# វិសុទ្ធិមគ្គ
# វិបស្សនានៃសមថយានិក

ព្រះយោគាវចរ ដែលមានបំណងធ្វើនូវទិដ្ឋិវិសុទ្ធិនោះ ឱ្យដល់ព្រម , ចំពោះអ្នកដែលជាសមថយានិក ចេញចាករូបាវចរឈាន ឬ អរូបាវចរឈាន យ៉ាងណាមួយ លើកលែងតែនេវសញ្ញានាសញ្ញាយតនៈ ហើយគប្បីកំណត់ដឹង អង្គឈានទាំងឡាយ មានវិតក្កៈជាដើម និងធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយអង្គឈាននោះ នូវលក្ខណៈ និងកិច្ចជាដើម កាលដែលកំណត់ដឹង( សភាវៈលក្ខណៈ ) បានហើយ ក៏ជាហេតុឱ្យមានការកំណត់ដឹងជាទូទៅនូវ **នាមធម៌** ដោយអត្ថថា មានការបង្អោនទៅ ព្រោះនាមធម៌ មានលក្ខណៈបង្អោនទៅកាន់អារម្មណ៍ បន្ទាប់មក ក៏មានឧបមាដូចបុរសឃើញពស់នៅក្នុងផ្ទះហើយតាមវាទៅ ក៏បានឃើញទីអាស្រ័យរបស់វា យ៉ាងណា សូម្បីព្រះយោគាវចរ ក៏ដូច្នោះដូចគ្នា កាលកំណត់ដឹងនូវនាមធម៌នោះហើយ ក៏ជាហេតុឱ្យមានការសង្កេតតទៅទៀតថា នាមនេះអាស្រ័យអ្វី ទើបប្រព្រឹត្តទៅបាន ក៏ឃើញថាហទយរូប គឺជាទីអាស្រ័យរបស់នាមនោះ ជាហេតុឱ្យមានការកំណត់ដឹងនូវរូប គឺ ភូតរូបទាំងឡាយដែលជាទីអាស្រ័យនៃហទយរូប និង ឧបាទាយរូបដ៏សេសដែលអាស្រ័យមហាភូតរូបនោះ លោកក៏មានការកំណត់ដឹងជាទូទៅថា ទាំងអស់នេះជារូប ព្រោះមានការបែកធ្លាយ បន្ទាប់មក ក៏អាចនឹងកំណត់ដឹងនូវ **នាមរូប** ដោយសង្ខេបថា សភាវៈដែលមានការបង្អោនទៅ ជាលក្ខណៈ **ជានាមធម៌** , សភាវៈដែលមានការបែកធ្លាយ ជាលក្ខណៈ **ជារូបធម៌** ។

# មហាដីកា

## អធិប្បាយ ការកំណត់នាមរូប

ភ្ជាប់សេចក្តីបាលីថា យា វិសុទ្ធិយោ សម្បាទេតព្វា វិសុទ្ធិទាំងឡាយណា ព្រះយោគាវចរគប្បីធ្វើឱ្យដល់ព្រម ក្នុងធម៌ទាំងឡាយដែលជាភូមិរបស់វិបស្សនា មានខន្ធជាដើម តាមដែលបានវិចារណ៍ទុកហើយទាំងអស់នេះ ។ ការរៀននូវគន្ថៈ ( ព្រះបរិយត្តិ ) គឺ ការធ្វើឱ្យរត់មាត់ , ឈ្មោះថា **ឧគ្គហ** ការរៀន សេចក្តីប្រាថ្នាឱ្យបានយល់ដឹងច្បាស់ដោយជុំវិញ គ្រប់ប្រការទាំងពួង ។ ឈ្មោះថា **បរិបុច្ឆា** ការសាកសួរ បានដល់ វិធីមនសិការនូវខ្លឹមសារនោះៗ ដោយអំណាចការស្តាប់ និងការពិចារណាជាដើម ព្រោះញាណក្នុងធម៌ដែលជាភូមិទាំងឡាយនោះ បានសេពស្ពាត់ជំនាញហើយ ដោយអំណាចការរៀន និង ការសាកសួរទាំង ២ នោះ ដូច្នោះ លោកអាចារ្យទើបពោលថា " ផ្តើមធ្វើឱ្យមានការយល់ដឹងដោយញាណ ដោយអំណាចការរៀនសូត្រ និងការសាកសួរ " ដូច្នេះ , អធិប្បាយថា ធ្វើញាណដែលសម្រេចដោយការស្តាប់ឱ្យកើតក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ។

អធិប្បាយថា ខ្ញុំម្ចាស់បានសម្តែងដោយពិស្តារហើយ ព្រោះហេតុនោះ យោគាវចរ គប្បីញុាំងសីលវិសុទ្ធិឱ្យដល់ព្រម តាមទំនងដែលខ្ញុំម្ចាស់បានសម្តែងដោយពិស្តារហើយ ក្នុងសីលនិទ្ទេសនោះ ។

សូម្បី **ឧបចារសមាធិ** ក៏ឈ្មោះថា **ចិត្តវិសុទ្ធិ** ដូចគ្នា ព្រោះជាទីតាំងនៃវិបស្សនា ដូចនឹងអប្បនាសមាធិដែរ ព្រោះហេតុនោះ លោកអាចារ្យទើបពោល

ថា " **ព្រមទាំងឧបចារសមាធិ** " ។

ពាក្យថា **គប្បីដឹង** គឺបណ្ឌិតគប្បីឃើញច្បាស់ ទាក់ទងនឹងការកើតឡើងក្នុងសន្តានរបស់ខ្លួននោះឯង ។ មានអធិប្បាយថា វិសុទ្ធិទាំង ២ នោះ ឈ្មោះថា បណ្ឌិតបានឃើញច្បាស់ហើយ ដោយប្រចក្សយ៉ាងនេះ ព្រោះហេតុនោះទើបគប្បីដឹង គឺ គប្បីធ្វើឱ្យដល់ព្រម ។

ម្យ៉ាងទៀត ពាក្យថា **គប្បីដឹងច្បាស់** មានន័យថា គប្បីសោយទាក់ទងនឹងការសម្រេចសុខក្នុងសមាបត្តិ ព្រោះថា **សមថយានិក** ដែលឈ្មោះថាតាំងនៅក្នុងចិត្តវិសុទ្ធិ ដោយហេតុគ្រាន់តែដើម្បីដឹងតែម្យ៉ាង ក៏ទេ តែថា បើមិនបានតាំងនៅក្នុងចិត្តវិសុទ្ធិនោះ ក៏មិនអាចញុំាងវិសុទ្ធិជាន់លើៗ ឱ្យដល់ព្រមបានឡើយ ។

ពាក្យថា **ការឃើញនាមរូបតាមសេចក្តីពិត** គឺ ការឃើញនាមរូប ចែកដាច់ពីគ្នាតាមសេចក្តីពិត ។ បណ្ឌិតគប្បីឃើញថា ក្នុងទីនេះ លោកកាន់យកខន្ធទាំង ៤ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មានវេទនាជាដើម ដោយស័ព្ទថា **នាម** មិនមែនវៀរវិញ្ញាណ ដូចក្នុងពាក្យថា " ព្រោះវិញ្ញាណជាបច្ច័យ ទើបមាននាមរូប " ទាំងមិនមែនរួមជាមួយលោកុត្តរខន្ធ និង និព្វាន ផងដែរ ។

ឈ្មោះថា **យាន** ព្រោះមានសេចក្តីថា ជាគ្រឿងទៅ គឺ ដល់ , **យាន** គឺ សមថៈ ឈ្មោះថា **សមថយាន** , សមថយាននោះ មានដល់យោគាវចរនេះ ព្រោះហេតុនោះ យោគាវចរនេះ ឈ្មោះថា **សមថយានិកោ** អ្នកមានយាន គឺ សមថៈ ។ ពាក្យថា **សមថយានិក** នេះ ជាឈ្មោះរបស់យោគាវចរដែលតាំងនៅក្នុងឈាន ឬ ក្នុងឧបចារៈនៃឈាន ប្រកបវិបស្សនា នេះព្រះយោគាវចរ

ដែលជាសមថយានិកនោះ ។

ពាក្យថា **វៀរនេវសញ្ញានាសញ្ញាយតនៈ** នេះ លោកអាចារ្យពោល ព្រោះការដែលភវគ្គធម៌ ( ធម៌នៃភពជាន់ខ្ពស់ ) កំណត់បានដោយលំបាក សម្រាប់យោគាវចរដែលជាអាទិកម្មិកៈ ។ អធិប្បាយថា គប្បីកំណត់នូវលក្ខណៈ និង កិច្ចជាដើម គឺ គប្បីកំណត់ដោយញាណ ក៏វិធីកំណត់ខ្ញុំម្ចាស់បានពោលទុកហើយ ក្នុងខន្ធនិទ្ទេសនោះឯង ។

ការបង្អោនទៅកាន់អារម្មណ៍ គឺ បើវៀរចាកអារម្មណ៍ ក៏មិនប្រព្រឹត្តទៅដោយអត្ថ គឺ ការបង្អោនទៅ ឬ ដោយអត្ថ គឺ ការតាំងឈ្មោះទុកនោះ ។

ពិតហើយ អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា **នាម** ដោយអត្ថ គឺ ការតាំងឈ្មោះទុក ព្រោះការដែលមានឈ្មោះ ត្រូវខ្លួននោះឯងបានតាំងទុក ដោយមិនមែនជាឈ្មោះយ៉ាងដទៃ មានសក់ជាដើម ដូចជារូបធម៌ទាំងឡាយ មានបឋវីជាដើម ព្រោះមានឈ្មោះថា ផស្សៈជាដើម សូម្បីក្នុងកាលទាំងពួង ។

ន័យម្យ៉ាងទៀត អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា **នាម** ដោយមានការកាន់យកទាក់ទងនឹងឈ្មោះ ព្រោះមិនដល់នូវភាពជាឈ្មោះ គឺ ការកាន់យកនូវអង្គប្រកប ដែលឈ្មោះដទៃមិនបានចូលទៅសន្សំទុក ដូចជាសម្ព័ស្ស ដោយការហៅ ក៏មិនដល់នូវការហៅ ដូច្នោះ , ចំណែករូប សូម្បីវៀរចាកការស្តាប់ឈ្មោះ ក៏រមែងកាន់យកបានដោយសភាព គឺ ការបែកធ្លាយនោះឯង ។ ពាក្យថា **គប្បីកំណត់** មានន័យថា គប្បីតាំងទុកឱ្យដាច់ពីគ្នា អធិប្បាយថា គប្បីតាំងគ្នានិងគ្នាទុកក្នុងចិត្ត ធ្វើមិនឱ្យលាយជាមួយរូប ។

ឈ្មោះថា **ការកំណត់នាមនិងរូប** ក៏ដើម្បីការលះបង់ នាមនិងរូបនោះ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្តែងរូប ដែលសមគួរដល់នាមនិងរូបនោះប៉ុណ្ណោះ ជាតួយ៉ាង ទើបពោលពាក្យមានជាអាទិ៍ថា " ឧបមាដូចជា ", អត្ថថា ប្រែប្រួល ក្នុងពាក្យថា ដោយការប្រែប្រួល នេះខ្ញុំម្ចាស់បានពោលទុកហើយ ក្នុងវណ្ណនានៃខន្ធនិទ្ទេស ដោយពាក្យមានជាអាទិ៍ថា **ការដល់នូវភាពមិនដូចគ្នា ក្នុងពេលវិរោធិប្បច្ច័យ មានភាពត្រជាក់ជាដើម ប្រជុំគ្នា ដូច្នេះ** ។ លោកអាចារ្យ កាលសម្តែងនូវការកំណត់នាម និង ការកំណត់រូបមួយៗ ដោយឡែកដូច្នេះហើយ ឥឡូវនេះបំណងនឹងសម្តែងការកំណត់ នាម និង រូប រួមគ្នា ទើបពោលពាក្យមានជាអាទិ៍ថា " បន្ទាប់មក ទើបកំណត់នាម និង រូប ដោយសង្ខេបថា វត្ថុដែលមានការបង្អោនទៅ ជាលក្ខណៈ ជានាម ដូច្នេះ ។

( ចប់ មហាដីកា )

# វិសុទ្ធិមគ្គ
# វិបស្សនានៃវិបស្សនាយានិក

## ការកំណត់នាមរូបតាមរយៈចតុធាតុវវដ្ឋាន

ចំណែកព្រះយោគាវចរ ដែលជាវិបស្សនាយានិកសុទ្ធ ឬ សូម្បីព្រះយោគាវចរដែលជាសមថយានិកនោះក៏ដោយ កំណត់ធាតុ ៤ ដោយសង្ខេប ឬ ដោយពិស្តារ ដោយធាតុបរិគហមុខ ( កំណត់ធាតុ ) ដែលបានពោលហើយក្នុងចតុធាតុវវដ្ឋាន ដោយធាតុណាមួយ ( គឺ ការកំណត់ទៅលើវិសេសលក្ខណៈ ដូចជា វត្ថុណាមានលក្ខណៈរឹង-ទន់ វត្ថុនោះជា បឋវីធាតុជាដើម ) បន្ទាប់មកក្នុងធាតុទាំងឡាយ ដែលប្រាកដច្បាស់ដោយ កិច្ច និង លក្ខណៈ របស់ខ្លួនទៅតាមសេចក្ដីពិត គឺថា ក្នុងសក់ដែលមានកម្មជាសមុដ្ឋាននោះ :

រូប ១០ ដោយក្រិដ្ឋក្រមនៃ **កាយទសកៈ** បានដល់ ធាតុ ៤ និង ពណ៌ ក្លិន រស ឱជា ជីវិត កាយបសាទ , រូប ១០ ដោយក្រិដ្ឋក្រមនៃ **ភាវទសកៈ** ( គឺ សំណុំរូប ១០ រាប់ទាំងភាវៈ គឺ ភេទ ) ព្រោះក្នុងសក់ដែលមានកម្មជាសមុដ្ឋាននោះ ក៏មានភាវរូបផងដែរ ( រួមទាំងអស់ ២០ ) ។

រូប ២៤ ដទៃទៀត ក្នុងសំណុំរូបដែលឈ្មោះថា សក់នោះ ដូចគ្នា គឺ ឱជដ្ឋមករូប ( សំណុំរូបដែលមានឱជា ជាគម្រប់ ៨ ) ដែលមានអាហារជាសមុដ្ឋាន , ឱជដ្ឋមករូប ដែលមានឧតុជាសមុដ្ឋាន , ឱជដ្ឋមករូបដែលមានចិត្ត

ជាសមុដ្ឋាន ( រួមទាំងអស់ ២៤ ) ។ រួមទាំងរូបមុន ក៏បានរូប ៤៤ ។ រមែង ប្រាកដដល់ព្រះយោគាវចរនោះឯង ។

មហាដីកាពោលថា គល់សក់ដែលដុះជាប់នៅក្នុងស្បែកក្បាល គឺ មាន កម្មជាសមុដ្ឋាន ។

( ក្នុងសក់ មានរូប ៤៤ យ៉ាងណា ) ក្នុងកោដ្ឋាស ២៤ ដែលជា ចតុសមុដ្ឋាន ( លើកលែងកោដ្ឋាសដែលនឹងពោលតទៅ ៨ ចេញ ) មួយៗ ក៏មានរូប ៤៤ ។

ចំណែកកោដ្ឋាសដែលមានតែ រដូវ និង ចិត្ត ជាសមុដ្ឋាន មាន ៤ គឺ ញើស ទឹកភ្នែក ទឹកមាត់ ទឹកសំបោរ មួយៗ មានរូប ១៦ ដោយក្រិដ្ឋក្រមនៃ ឱជដ្ឋមករូប ២ សំណុំ ។

ក្នុងកោដ្ឋាស ដែលមានតែរដូវជាសមុដ្ឋាន មាន ៤ គឺ អាហារថ្មី អាហារចាស់ ខ្ទុះ ទឹកមូត្រ មួយ ៗ មានរូប ៨ ដោយក្រិដ្ឋក្រមនៃឱជដ្ឋមករូប មានរដូវជាសមុដ្ឋានតែម្យ៉ាង នេះជាន័យក្នុងអាការ ៣២ ក្នុងលំដាប់ដំបូង ។

( ឱជដ្ឋមករូប រូបដែលមានឱជា ជាគម្រប់ ៨ បានដល់ មហាភូតរូប ៤ ពណ៌ ក្លិន រស ឱជា ឬ ហៅថា អវិនិព្ភោគរូប ៨ គឺ រូបដែលមិនបែកគ្នា ) ។

ម្យ៉ាងទៀត កាលអាការ ៣២ នេះប្រាកដច្បាស់ហើយ អាការ ១០ ផ្សេងទៀត ( មានតេជោកោដ្ឋាស ៤ និង វាយោកោដ្ឋាស ៦ ) ក៏នឹងប្រាកដ ច្បាស់ក្នុងអាការទាំងពួងនោះដែរ , ម្យ៉ាងទៀត ក្នុងតេជោកោដ្ឋាសដែលកើត ពីកម្ម មាននាទីញ៉ាំងអាហារដែលបរិភោគចូលទៅឱ្យរលាយ មាន រូប ៩ គឺ ឱជដ្ឋមករូប ៨ និង ជីវិតរូប ១ ។

ន័យដូចគ្នាដែរ ក្នុងកោដ្ឋាស គឺ ខ្យល់ដង្ហើមដែលកើតពីចិត្ត មានរូប ៩ គឺ ឱជដ្ឋមករូប ៨ និង សទ្ទរូប ១ ។

ក្នុងកោដ្ឋាសដ៏សេស ៨ ( គឺ តេជោ ៣ វាយោ ៥ ) ជាចតុសមុដ្ឋាន , មួយ ១ មានរូប ៣៣ គឺ ជីវិតនវករូប ៩ និង ឱជដ្ឋមករូប ៣ ( សមុដ្ឋាន ) = ២៤ ប្រាកដ ( ដល់យោគាវចរនោះ ) ។

កាលភូតរូប និង ឧបាទាយរូបទាំងឡាយនេះ ប្រាកដដល់ព្រះយោគាវចរនោះ ដោយអាការ ៤២ ដោយពិស្តារ , ដូច្នេះហើយ សូម្បីរូបដទៃទៀត ៦០ គឺ រូបកលាបៈ ៥ មានចក្ខុទសកៈជាដើម និង ហទយវត្ថុទសកៈ ដែលជាវត្ថុ និង ទ្វារ ក៏រមែងប្រាកដដែរ ។

ព្រះយោគាវចរនោះ រួមរូបទាំងពួងនោះចូលគ្នា ដោយលក្ខណៈ គឺ ការបែកធ្លាយ ក៏ជាក់ច្បាស់ថា នោះជា **រូបធម៌** ។

អរូបធម៌ ( នាមធម៌ ) ទាំងឡាយក៏រមែងប្រាកដដោយភាពជាទ្វារ ដល់ព្រះយោគាវចរនោះ ដែលជាអ្នកកំណត់រូបបានហើយ អរូបធម៌នេះ បានដល់អ្វីខ្លះ គឺ បានដល់ លោកិយចិត្ត ៨១ ដួង មាន :

- ទ្វិបញ្ចវិញ្ញាណ ១០
- មនោធាតុ ៣
- មនោវិញ្ញាណធាតុ ៦៨

ព្រមទាំងដោយសេចក្តីដូចគ្នា ( ជាសាធារណៈ ) បានដល់ ចេតសិក ៧ មាន ផស្ស វេទនា សញ្ញា ចេតនា ជីវិត ចិត្តដ្ឋិតិ ( ឯកគ្គតា ) មនសិការ ដែលកើតរួមជាមួយចិត្តទាំងឡាយនោះ ។

ចំណែកលោកុត្តរចិត្តទាំងឡាយ នឹងជាអារម្មណ៍នៃការកំណត់របស់ព្រះយោគាវចរសុទ្ធវិបស្សកៈក៏មិនបាន នៃព្រះយោគាវចរដែលជាសមថយានិកក៏មិនបាន ព្រោះមិនទាន់បានសម្រេច ។

បរមត្ថទីបនីដីកា អធិប្បាយទុកថា លោកុត្តរធម៌ សូម្បីជាសង្ខតធម៌ ក៏ជាអារម្មណ៍នៃការពិចារណាមិនបាន ព្រោះការពិចារណា រមែងមានដើម្បីលះបង់អនុស័យកិលេស , អនុស័យ មានកាមរាគៈជាដើម ដេកត្រាំនៅក្នុងសង្ខតធម៌ទាំងឡាយណា សង្ខតធម៌ទាំងឡាយនោះ រមែងគួរដល់ការពិចារណា ព្រោះដូច្នោះ ទើបលោកពោលថា **តេភូមកសង្ខារេសុ** សង្ខារទាំងពួងក្នុងភូមិ ៣ ។

ព្រះយោគាវចរនោះ រួមអរូបធម៌ ( នាមធម៌ ) ទាំងពួងនោះចូលគ្នាដោយលក្ខណៈ គឺ ការបង្អោនទៅ ( ដឹងអារម្មណ៍ ) ក៏ឃើញច្បាស់ថា នោះជានាមធម៌ ។

## ការកំណត់នាមរូបតាមរយៈធាតុ ១៨

ព្រះយោគាវចរមួយអង្គ បានកំណត់នាមរូបតាមរយៈធាតុ ១៨ តើកំណត់ដូចម្តេច គឺ ភិក្ខុក្នុងព្រះសាសនានេះ ពិចារណាដល់ធាតុទាំងឡាយថា " មាននៅក្នុងអត្តភាពនេះ គឺ ចក្ខុធាតុ-រូបធាតុ-ចក្ខុវិញ្ញាណធាតុ , សោតធាតុ-សទ្ទធាតុ-សោតវិញ្ញាណធាតុ , ឃានធាតុ-គន្ធធាតុ-ឃានវិញ្ញាណធាតុ , ជិវ្ហាធាតុ-រសធាតុ-ជិវ្ហាវិញ្ញាណធាតុ , កាយធាតុ-ផោដ្ឋព្វធាតុ-កាយវិញ្ញាណធាតុ , មនោធាតុ-ធម្មធាតុ-មនោវិញ្ញាណធាតុ " ដូច្នេះហើយ មិន

ប្រកាន់ដុំសាច់ ដែលមានសរសៃចងទុកក្នុងរណ្តៅភ្នែក មានសណ្ឋានពងក្រពើ មានសភាពវិចិត្រផ្សេងៗ ដោយពណ៌ប្រផេះផ្លេកៗក៏មាន ពណ៌ខ្មៅស្រិល ក៏មាន ដែលមហាជនស្គាល់ថាជា ចក្ខុ ព្រះយោគីគប្បីកំណត់នូវចក្ខុបសាទ មានប្រការដូចដែលពោលមក ទុកក្នុងពួកឧបាទាយរូប ក្នុងខន្ធនិទ្ទេស ថាជា ចក្ខុធាតុចុះ ។

ម្យ៉ាងទៀត រូបដ៏សេស ៥៣ គឺ :

សហជាតរូប ( នៃចក្ខុបសាទ ) ៩ បានដល់ ធាតុ ៤ ដែលជាទីអាស្រ័យ នៃចក្ខុបសាទនោះ និងរូប ៤ ទៀត គឺ ពណ៌ ក្លិន រស ឱជា ដែលជារូប មិនបែកគ្នា ។

ជីវិតិន្ទ្រិយ ដែលជារូបអនុបាលកម្មជរូប ២០ គឺជា កាយទសកៈរូប ១០ និង ភាវទសកៈរូប ១០ ដែលតាំងនៅរួមនឹងចក្ខុបសាទនោះឯង ។

អនុបាទិន្នករូប ( គឺ អកម្មជរូប ) ២៤ ជាឱជដ្ឋមករូប ៣ ( សមុដ្ឋាន ) គឺ រូបដែលមានអាហារជាសមុដ្ឋានជាដើម ( បានជា ៩ + ២០ + ២៤ = ៥៣ ) ក៏មិនកំណត់នូវរូប ៥៣ នោះថា ជាចក្ខុធាតុ សូម្បីធាតុទាំងឡាយ មានសោត ធាតុជាដើម ក៏មានន័យដូច្នេះ តែក្នុងកាយធាតុ រូបដ៏សេសមាន ៤៣ អាចារ្យ ពួកខ្លះពោលថាមាន ៤៥ ដោយរួមយករូប ដែលមានឧតុជាសមុដ្ឋាន និង រូបដែលមានចិត្តជាសមុដ្ឋាន ក្នុង ១ សំណុំមាន ៩ ទាំងសទ្ទរូប ។

ព្រះយោគាវចរនោះ កំណត់ថា " រូប ១០ គឺ បសាទរូប ៥ ដូច ពោលមកនេះ និង វិស័យនៃបសាទទាំងឡាយនោះ ៥ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ បានជា **ធាតុ ១០** ឯរូបដ៏សេស ( ដីកា : អនិប្ផន្នរូប ៦ ) រាប់ថាជា

**ធម្មធាតុ ១** , ចំណែកទ្វិបញ្ចវិញ្ញាណ ដោយន័យថា " ចិត្តអាស្រ័យចក្ខុប្រសាទរូបកើតឡើង ឈ្មោះថា ចក្ខុវិញ្ញាណធាតុ " ដូច្នេះ ជាដើម បានជា **វិញ្ញាណធាតុ ៥** , ចិត្តមនោធាតុ ៣ ដួង រាប់ជា **មនោធាតុ ១** , ចិត្តមនោ-វិញ្ញាណធាតុ ៦៨ ដួង រាប់ជា **មនោវិញ្ញាណធាតុ ១** រួមជា **ធាតុ ១៨** ។

កំណត់ថា " លោកិយចិត្តទាំងអស់ ៨១ ដួង , វិញ្ញាណធាតុ ៧ , ធម៌ទាំងឡាយ មានផស្សៈជាដើម ដែលសម្បយុត្តជាមួយវិញ្ញាណធាតុនោះ ក៏ជាធម្មធាតុ " ។

ក្នុងធាតុ ១៨ នេះ ធាតុ ១០កន្លះ ជារូប , ធាតុ ៧កន្លះ ជានាមដូច្នេះឯង ។

ព្រះយោគាវចរអង្គ ១ កំណត់នាមរូបតាមរយៈធាតុ ១៨ តាមន័យដូចដែលបានពោលមកដូច្នេះឯង ។

## ការកំណត់នាមរូបតាមរយៈអាយតនៈ១២

ព្រះយោគាវចរអង្គ ១ កំណត់នាមរូប តាមរយៈអាយតនៈ ១២ តើកំណត់ដូចម្តេច ? គឺ កំណត់តែចក្ខុបសាទ វៀររូប ៥៣ តាមន័យដែលបានពោលខាងដើមហើយ ក្នុងចក្ខុធាតុចុះ ថាជា ចក្ខាយតនៈ និង កំណត់សោតធាតុ ឃានធាតុ ជីវ្ហាធាតុ កាយធាតុ តាមន័យដែលបានពោលក្នុងចក្ខុធាតុនោះដូចគ្នា ថាជា សោតាយតនៈ ឃានាយតនៈ ជីវ្ហាយតនៈ កាយាយតនៈ , កំណត់ធាតុ ៥ ជាវិស័យនៃអាយតនៈ ៥ នោះ ថាជា រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ , កំណត់លោកិយចិត្តនិងវិញ្ញាណធាតុ

៧ ថាជា មនាយតនៈ , កំណត់ធម៌ទាំងឡាយ មានផស្សៈជាដើម ដែលសម្បយុត្តជាមួយវិញ្ញាណធាតុនោះ និង រូបដ៏សេស ថាជា ធម្មាយតនៈ ។

ក្នុងអាយតនៈ ១២ នេះ អាយតនៈ ១០កន្លះ ជារូប , អាយតនៈ ១ កន្លះ ជានាម ដូច្នេះឯង ។

ព្រះយោគាវចរអង្គ ១ កំណត់នូវនាមរូបតាមរយៈអាយតនៈ ១២ តាមន័យដូច្នេះឯង ។

## ការកំណត់នាមរូបតាមរយៈខន្ធ

ព្រះយោគាវចរអង្គ ១ កំណត់ដោយសង្ខេបជាងនោះ តាមរយៈខន្ធ ៥ តើកំណត់ដូចម្តេច ? ភិក្ខុក្នុងព្រះសាសនានេះ កំណត់ថារូប ១៧ ក្នុងសរីរៈនេះ គឺ :

- ធាតុ ៤ ទាំង ៤ សមុដ្ឋាន
- ពណ៌ ក្លិន រស ឱជា ដែលអាស្រ័យធាតុ ៤ នោះ
- បសាទរូប ៥ មានចក្ខុបសាទជាដើម
- វត្ថុរូប ភាវរូប ជីវិតិន្ទ្រីយ៍
- សំឡេង ទាំង ២ សមុដ្ឋាន

ទាំងអស់នេះជារូប សម្រេចហើយជារូបពិត គួរដល់ការពិចារណា ។

ចំណែករូប ១០ គឺ : កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា ឧបចយរូប សន្តតិរូប ជរតារូប អនិច្ចតារូប មិនមែនជារូបដែលសម្រេចជារូបពិតទេ គ្រាន់តែជាអាការ និងវិការនៃរូប និងជាគ្រឿង

កំណត់នូវចន្លោះនៃរូប មិនមែនជារូបដែលគួរដល់ការពិចារណា តែថា វាក៏ដល់នូវការដែលរាប់ថា រូប ដោយត្រឹមតែជាអាការ ជាវិការ ជាគ្រឿងកំណត់នូវចន្លោះនៃរូបទាំងឡាយ រូបទាំងអស់នោះ រួមជា ២៧ ជារូបក្ខន្ធ ។

វេទនា ដែលកើតឡើងរួមជាមួយចិត្ត ៨១ ជាវេទនាខន្ធ សញ្ញាដែលសម្បយុត្តជាមួយលោកិយចិត្ត ជាសញ្ញាខន្ធ សង្ខារទាំងឡាយ... ជាសង្ខារក្ខន្ធ វិញ្ញាណ... ជាវិញ្ញាណក្ខន្ធ ។ រូបក្ខន្ធជារូបធម៌ , អរូបខន្ធជានាមធម៌ ដូច្នេះឯង ។

ព្រះយោគីកំណត់នាមរូបតាមរយៈខន្ធ ៥ ដូច្នេះឯង ។

## ការកំណត់នាមរូបដោយសង្ខេប

ព្រះយោគាវចរអង្គ ១ កំណត់រូបក្នុងអត្តភាពនេះ តែម្យ៉ាងថា " រូបគ្រប់យ៉ាង រូបទាំងអស់ គឺ មហាភូតរូប ៤ និង រូបអាស្រ័យមហាភូតរូប ៤ ជារូប " ដូច្នេះហើយ កំណត់មនាយតនៈ និង ចំណែកមួយនៃធម្មាយតនៈ ថាជានាម ដោយសង្ខេបដូចគ្នាហើយ ក៏កំណត់នាមរូបដោយសង្ខេបថា " នាមនេះផង រូបនេះផង ដូចដែលពោលមក នេះហៅថា **នាមរូប** " ។

# ការកំណត់រូប
# ជាឧបាយជួយដល់ការកំណត់នាម

ប្រសិនបើ ព្រះយោគាវចរកំណត់រូបដោយមុខនោះៗ ហើយកំណត់អរូប ( គឺ នាម ) តទៅ អរូបនៅមិនទាន់ប្រាកដ ព្រោះជាធម៌ល្អិត ចូរកុំដាក់ធុរៈចុះឡើយ គប្បីពិចារណា ធ្វើទុកក្នុងចិត្តដោយការចែកជាគូរៗ និងរឿយៗទៅចុះ កាលណារូបប្រាកដជាវត្ថុបរិសុទ្ធ មិនមានអ្វីលាយឡំ ដោយប្រការណាៗ អរូបធម៌ទាំងឡាយដែលមានរូបធម៌នោះជាអារម្មណ៍ ក៏រមែងប្រាកដឡើងឯង ដោយប្រការនោះ ៗ ប្រៀបដូចបុរសមានភ្នែកល្អ ប្រាថ្នាចង់ឆ្លុះមើលស្រមោលមុខ ក្នុងកញ្ចក់ដែលស្រអាប់ ស្រមោលក៏មិនប្រាកដ គេគិតថាស្រមោលមិនប្រាកដ តែមិនលះបង់កញ្ចក់ចោល គេក៏ជូតកញ្ចក់នោះរឿយៗពេលកញ្ចក់នោះថ្លាហើយ ស្រមោលមុខរបស់គេក៏ប្រាកដឯង យ៉ាងណា , ម្យ៉ាងទៀត កាលបុគ្គលត្រូវការប្រេង ចាក់ម្សៅល្ងចូលទៅក្នុងស្នូកដែលមានទឹក កាលបើច្របាច់ ២ - ៣ គ្រាហើយ នៅមិនទាន់បានប្រេង គេក៏មិនបោះម្សៅល្ងនោះចោល តែគេប្រោះទឹកក្តៅបន្ថែម ហើយច្របាច់តទៅរឿយ ៗ ពេលគេធ្វើយ៉ាងនោះ ប្រេងល្អយ៉ាងថ្លាក៏ចេញមក យ៉ាងណា ឬ ដូចជាបុគ្គលត្រូវការនឹងធ្វើទឹកឱ្យថ្លា យកផ្លែតុម្ពកា កាន់ត្រដុសក្នុងក្អមទឹក កាលបើត្រដុស ១លើក ២លើក ទឹកមិនទាន់ថ្លា គេក៏មិនបោះផ្លែតុម្ពកាចោល តែគេត្រដុសវាយូរៗទៅ ពេលគេធ្វើយ៉ាងនោះ កករមែងធ្លាក់ចុះ ទឹករមែងថ្លាស្អាត យ៉ាងណា , ភិក្ខុនោះ ក៏ដូច្នោះដូចគ្នា មិនគប្បីដាក់ចុះនូវធុរៈ ពិចារណាធ្វើទុកក្នុង

ចិត្តចែកនូវរូបនោះរឿយៗ កាលរូបប្រាកដជាវត្ថុដែលបរិសុទ្ធ មិនមានអ្វីលាយឡំ ដោយប្រការណាៗ កិលេសទាំងឡាយដែលជាសត្រូវដល់ញាណ ក្នុងការកំណត់អរូបធម៌នោះ ក៏ស្រាលស្តើងទៅ ចិត្តរមែងថ្លាដូចទឹកនៅលើៗ អរូបធម៌ទាំងឡាយ ដែលមានរូបធម៌នោះជាអារម្មណ៍ ក៏រមែងប្រាកដដោយប្រការនោះៗ សេចក្តីនេះ បណ្ឌិតគប្បីប្រកាសដោយឧបមាដទៃ ដូចជាអំពៅ ចោរ គោ ទឹកដោះជូរ និងត្រី ក៏បាន តាមន័យដូចដែលពោលមកដូច្នេះ ។

## មហាដីកា

ពិតហើយ អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា **នាម** ដោយអត្ថ គឺ ការតាំងឈ្មោះទុក ព្រោះមានឈ្មោះដែលខ្លួននោះឯងបានតាំងទុក ដោយមិនត្រូវជាឈ្មោះយ៉ាងដទៃ មានសក់ និង ធ្មេញជាដើម ដូចជារូបធម៌ទាំងឡាយ មានបឋវីជាដើម ព្រោះមានឈ្មោះថា ផស្សជាដើម គ្រប់កាលទាំងពួង ។

ម្យ៉ាងទៀត អរូបធម៌ទាំងឡាយ មានវេទនាជាដើម លោកហៅថា **នាម** ព្រោះមានការប្រកាន់យកទាក់ទងនឹងឈ្មោះ ព្រោះមិនដល់ភាពជាឈ្មោះ គឺ ការប្រកាន់យកអង្គប្រកបដែលឈ្មោះដទៃ មិនបានចូលទៅសន្សំទុក ដូចជាផស្ស ដោយការហៅ ក៏មិនដល់នូវការហៅដូច្នោះ ។

ចំណែក រូប សូម្បីវៀរការស្តាប់ឈ្មោះ ក៏រមែងកាន់យកបានដោយសភាព គឺ ការបែកធ្លាយខ្លួនឯងនោះឯង ។

ពាក្យថា **គប្បីកំណត់** មានន័យថា គប្បីតាំងទុក ដោយមិនលាយគ្នា

អធិប្បាយថា គប្បីតាំងគ្នានិងគ្នាទុកក្នុងចិត្ត ធ្វើមិនឱ្យលាយជាមួយនឹងរូប ។

ដែលឈ្មោះថា ការកំណត់នាម និងរូប ក៏ដើម្បីការលះបង់នាម និងរូបនោះ ព្រោះហេតុនោះ លោកអាចារ្យកាលនឹងសម្ដែងរូប ដែលសមគួរដល់នាមនិងរូបនោះប៉ុណ្ណោះ ជាតួយ៉ាង ទើបពោលពាក្យ មានជាអាទិថា " ឧបមាយ៉ាងណា " ។ អត្ថថា **ប្រែប្រួល** ក្នុងពាក្យថា **ដោយការប្រែប្រួល** គឺខ្ញុំម្ចាស់បានពោលទុកហើយ ក្នុងវណ្ណនានៃខន្ធនិទ្ទេស ពាក្យមានជាអាទិថា " ការដល់នូវភាពមិនដូចគ្នា ក្នុងពេលវិរោធប្បច្ចយ មានភាពត្រជាក់ជាដើមប្រជុំគ្នា " ដូច្នេះនេះឯង ។ លោកអាចារ្យកាលសំដែងការកំណត់នូវនាម និង ការកំណត់នូវរូបជាផ្នែក២ ដាច់ពីគ្នាយ៉ាងនេះហើយ ឥឡូវនេះ បំណងសម្ដែងការកំណត់នាមនិងរូបរួមគ្នា ទើបពោលពាក្យមានជាអាទិ៍ថា " បន្ទាប់ពីនោះ ទើបកំណត់នាមរូបដោយសង្ខេបថា វត្ថុដែលមានការបង្អោនទៅ ជាលក្ខណៈ **ជានាម** " ដូច្នេះ ។

លោកអាចារ្យ កាលសម្ដែងការប្រារព្ធវិបស្សនា តាមរយៈអរូប ដូច្នេះហើយ ឥឡូវនេះ កាលនឹងសម្ដែងការប្រារព្ធវិបស្សនា តាមរយៈរូប ទើបពោលពាក្យ មានជាដើមថា" **ចំណែកព្រះយោគាវចរដែលជាវិបស្សនាយានិកសុទ្ធ** " ក្នុងពាក្យនោះ ព្រះយោគាវចរដែលជាសមថយានិក មានការប្រារព្ធវិបស្សនាតាមរយៈសមថៈ ចំណែកព្រះយោគាវចរដែលជាវិបស្សនាយានិក មិនអាស្រ័យសមថៈ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " **ព្រះយោគាវចរ ដែលជាវិបស្សនាយានិកសុទ្ធ** " ដូច្នេះ អធិប្បាយថា មានវិបស្សនាយាន ដែលមិនលាយដោយសមថភាវនានោះ ។

២ បទថា **អយមេវ វា សមថយានិកោ** ប្រែថា ឬ ជាសមថយានិក តាមដែលពោលហើយនេះ ក៏ដោយ ។ ដោយពាក្យនោះ លោកអាចារ្យសម្តែងថា ការប្រារព្ធវិបស្សនា តាមរយៈរូប រមែងសម្រេចដល់ព្រះយោគាវចរដែលជាសមថយានិកផងដែរ មិនមែនសម្រេចបានតែតាមរយៈអរូប តែម្យ៉ាងនោះទេ ។ ពាក្យថា **តាមរយៈនៃការកំណត់ធាតុនោះៗ** មានន័យថា បណ្តាការកំណត់ធាតុ ១៣ ប្រការ ដែលបានពោលទុកហើយទាក់ទងនឹងមនសិការដោយសង្ខេបជាដើម ដោយពាក្យមានជាអាទិ៍ថា " វត្ថុណា មានលក្ខណៈរឹង វត្ថុនោះជាបឋវីធាតុ " ។ សក់ដែលដុះជាប់ស្បែក ឈ្មោះថា មានកម្មជាសមុដ្ឋាន ។

បទថា **តត្ថេវ** ស្មើគ្នានឹង **តស្មឹយេវ យោគ កម្មសមុដ្ឋានេ កេសេ** ប្រែថា ក្នុងសក់ដែលមានកម្មជាសមុដ្ឋាននោះឯង ។ លោកអាចារ្យពោលទុកថា " ព្រោះមានភាវៈប្រាកដ " ដូច្នេះ ព្រោះសូម្បីភាវៈដែលផ្សាយទូទៅទាំងសរីរៈ ដូចជាកាយបសាទ ។ បទថា **តត្ថេវ** តទៅ មានន័យស្មើគ្នានឹង **តស្មឹយេវ យោគ កេសេសញ្ញិតេ រូបសមុទាយេ** ប្រែថា ក្នុងសំណុំរូបដែលមានឈ្មោះថាសក់នោះ ដូចគ្នា ។ ពាក្យថា **សូម្បីរូបដទៃទៀត** បានដល់ រូប ២០ ដែលមានកម្មជាសមុដ្ឋាន ដែលបានពោលទុកខាងដើមហើយ , រូប ២៤ មានរូបដែលមានអាហារជាសមុដ្ឋានជាដើម ទាំងឡាយនេះ រួមជារូប ៤៤ ហើយរូបនោះឯង គប្បីជ្រាបដោយភាពជាសីសៈនៃសន្តតិរូប ដែលមាននៅក្នុងរូបទាំងឡាយនោះជានិច្ច ។

ពាក្យថា **រូប ៤៤** នេះ លោកពោលទុក ព្រោះសំឡេងជារូបមិនប្រាកដប្រជា ព្រោះថា សំឡេងនោះឯង ជារូបកើតឡើងពីឧតុ និងចិត្ត រមែងមិនអាច

កើតឡើងអស់កាលទាំងពួងបានឡើយ ។ ពាក្យថា **ដូច្នោះ** មានន័យថា ក្នុងសក់ យ៉ាងណា ក្នុងកោដ្ឋាសៈ ២៤ ដែលជាចតុសមុដ្ឋាន មានរោមជាដើម ក៏ដូច្នោះដូចគ្នា ។ ពាក្យថា **ក្នុងកោដ្ឋាសៈ** ២៤ បានដល់ ចែកកោដ្ឋាសៈទាំង ៨ ដែលនឹងពោលដល់ ក្នុងកោដ្ឋាសៈ ៣២ ចេញទៅ ក៏បានកោដ្ឋាសៈ ២៤ ។ កោដ្ឋាសៈទាំងឡាយនោះ លោកពោលថា មានឧតុ និងចិត្តជាសមុដ្ឋាន ព្រោះកោដ្ឋាសៈ មានញើសជាដើម កើតឡើងដោយកម្តៅ និង ការធ្វើទារុណកម្មជាដើម និងដោយការប្រែប្រួលនៃចិត្ត ។

កាលរូបនៅក្នុងកោដ្ឋាសៈ ៣២ កើតប្រាកដហើយ សូម្បីរូបដទៃក្រៅពីកោដ្ឋាសៈ ៣២ នោះ ក៏រមែងប្រាកដ ព្រោះហេតុនោះ កាលនឹងសម្តែងរូប សូម្បីរូបទាំងឡាយនោះ លោកអាចារ្យទើបពោលពាក្យមានជាអាទិ៍ថា **អាការដទៃទៀត** ដូច្នេះ ។ ក្នុងពាក្យនោះ ពាក្យថា **អាការ ១០ ដទៃទៀត** បានដល់ អាការ ១០ ដទៃទៀត គឺ តេជោកោដ្ឋាសៈ ៤ វាយោកោដ្ឋាសៈ ៦ ។ បទថា **កម្មជេ** លោកពោលដល់ ភូតរូប មិនមែនជាពាក្យធ្វើឱ្យផ្សេងនោះទេ ព្រោះតេជោដែលញ៉ាំងអាហារ ដែលបរិភោគចូលទៅជាដើមឱ្យរលាយ ដែលមិនកើតពីកម្ម មិនមាន ។

លោកអាចារ្យពួកខ្លះពោលថា ក៏បទថា **តថា ចិត្តជេ** លោកពោលទុកព្រោះខ្យល់ដង្ហើមចេញចូល មានចិត្តជាសមុដ្ឋានតែម្យ៉ាង ប្រការនោះ លោកពោល ព្រោះខ្យល់ដង្ហើមចេញចូល ដែលប្រព្រឹត្តទៅក្នុងសន្តានដែលមិនមែនកើតពីចិត្ត និងជាវត្ថុដែលកើតពីឧតុ មិនមាន ។

ក៏ខ្យល់ដង្ហើមចេញចូលនោះ ស្ថិតនៅខាងក្នុងប៉ុណ្ណោះ ឈ្មោះថា កើត

ពីចិត្ត មិនមែនខ្យល់ដង្ហើមចេញ-ចូល ដែលនៅខាងក្រៅនោះទេ ព្រោះហេតុនោះ ពាក្យថា **កើតពីចិត្ត** នេះ ក្នុងពាក្យនោះ ទើបជាពាក្យដែលធ្វើឱ្យផ្សេងគ្នា និងសេចក្តីនេះ ខ្ញុំម្ចាស់បានពោលទុកហើយ ក្នុងអានាបានកថា ក្នុងខាងដើមរូចហើយ ។ ពាក្យថា **ក្នុងកោដ្ឋាសៈដ៏សេស** បានដល់ ក្នុងតេជោកោដ្ឋាសៈ ៣ និង វាយោកោដ្ឋាសៈ ៥ , ដែលប្រព្រឹត្តទៅក្នុងភាពជាភ្លើង ក្នុងការធ្វើឱ្យក្តៅជាដើម និងខ្យល់ដែលបក់ផាត់ចុះឡើងជាដើម ។

ក្នុងបណ្តារូបកលាបៈ មានចក្ខុទសកៈជាដើម រូបដែលជាប្រធាន បានដល់ ចក្ខុជាដើម ព្រោះហេតុនោះ ទើបលោកអាចារ្យ លើកកិច្ចដែលជាផ្នែកតូចៗ មានភាពជាវត្ថុ និងជាទ្វារ ដែលមានក្នុងរូប មានចក្ខុទាំងឡាយនោះឡើង ទុកក្នុងសេចក្តីរួម ហើយពោលថា **រូបកលាបៈ ៥ មានចក្ខុទសកៈជាដើម ដោយជាវត្ថុ និងទ្វារ** ដូច្នេះ ។ គប្បីប្រកបពាក្យថា និងហទយវត្ថុទសកៈ ដោយជាវត្ថុ **ឯកទស** រមែងស្របតាម សូម្បីពាក្យដែលបានអធិប្បាយទុក ដោយការប្រកបទុកក្នុងពាក្យមួយ ដូច្នេះ ។ ពាក្យថា **រូបទាំងពួង** បានដល់ រូបរូបចំនួន ១៤៩៤ រូប ក្នុងការរាប់រូបតាមដែលពោលហើយ ។

តែកាលកាន់យកប្រភេទនៃចំណែកតូចៗ នៃកោដ្ឋាសៈ និងរូបកលាបៈ ដែលជាចំណែកតូចៗនៃកោដ្ឋាសៈទាំងឡាយនោះ នឹងមានប្រភេទនៃរូបច្រើនក្រៃលែងជាងនោះ តែប្រភេទនោះ មិនគួរកាន់យក ព្រោះកំណត់បានដោយលំបាកសម្រាប់យោគាវចរដែលជាអាទិកម្មិកៈក្នុងទីនេះ ។

លោកអាចារ្យពោលថា **អរូបធម៌ទាំងឡាយ រមែងប្រាកដដោយភាពជាទ្វារ** ដូច្នេះ ព្រោះធ្វើអធិប្បាយថា អរូបធម៌ទាំងឡាយ រមែងប្រាកដ សូម្បី

ដោយភាពជាវត្ថុ ក៏ពិត សូម្បីយ៉ាងនោះ ការកំណត់ដោយភាពជាទ្វារ ក៏មិនច្រឡំគ្នា លោកពោលថា **លោកិយចិត្ត ៨១** ដូច្នេះ ទាក់ទងដោយចិត្តដែលរួបរួមទុកតាំងអស់ តែមហគ្គតចិត្ត រមែងប្រាកដដល់យោគាវចរដែលបានសម្រេចប៉ុណ្ណោះ ។ ពាក្យថា **ដោយសេចក្ដីដូចគ្នា** គឺដោយទូទៅ ពិតហើយ ចេតសិក ៧ ដួង មានផស្សជាដើម ជាសាធារណៈដល់ចិត្តុប្បាទគ្រប់ដួង ព្រោះកើតឡើងបាន សូម្បីប្រកបជាមួយចក្ខុវិញ្ញាណជាដើម ។ ពាក្យថា **ទាំងពួងនោះ** បានដល់ អរូបធម៌ទាំងពួងនោះ គឺ លោកិយចិត្ត ៨១ ចេតសិក មានផស្សជាដើម ដែលសម្បយុត្តជាមួយនឹងលោកិយចិត្តនោះ ។ កាលកំណត់ប្រភេទនៃចិត្តុប្បាទដោយវិភាគ មានអារម្មណ៍ជាដើម ខ្លឹមសាររមែងមានច្រើន តែខ្លឹមសារនោះ លោកមិនបានបំណងយកក្នុងទីនេះទេ ។

ភ្ជាប់សេចក្ដីថា ធាតុទាំង ៤ ជាទីអាស្រ័យនៃចក្ខុបសាទនោះ ។ ភ្ជាប់សេចក្ដីថា សហជាតរូបនៃចក្ខុបសាទនោះ ដូច្នេះដូចគ្នា ។ បទថា **តត្ថេវ** មានន័យស្មើនឹង **តស្មឹយេវ យោគ សសម្ភារចក្ខុបទេសេ** ប្រែថា ក្នុងចំណែកនៃសសម្ភារចក្ខុនោះ ។ ពាក្យថា **អនុបាទិន្នរូប** លោកពោលទុក ព្រោះរូបដែលបានពោលហើយក្នុងកាលមុន ជាឧបាទិន្នរូប មានន័យថា បានដល់ អកម្មជរូប។

ពាក្យថា **រូបដ៏សេស** បានដល់ រូបដ៏សេសក្រៅពីចក្ខុនោះ ព្រោះចក្ខុបានពោលទុករួចហើយ រួមជាមួយចក្ខុនោះ ក៏មានរូប ៥៤ ។

ពាក្យថា **រូប ៤៣ ដ៏សេស** លោកពោលទុកព្រោះ មិនត្រូវកាន់យកសូម្បីតែ ១ ទសកៈ ក្នុងបណ្ដាទសកៈទាំងឡាយ មានចក្ខុទសកៈជាដើម ។ លោកអាចារ្យពោលថា រូប ៤៣ ដូច្នេះ ព្រោះមិនកាន់យកសទ្ទរូបនោះ ព្រោះ

សទ្ទរូបនោះជាអនិយតៈ ហើយសម្ដែងវាទៈនៃកេចិអាចារ្យ តទៅថា រូប ៤៥ ព្រោះកាន់យកសទ្ទរូបទាំង ២ ដែលមាន ឧតុ និង ចិត្ត ជាសមុដ្ឋាន ។

ពាក្យថា **រូបដ៏សេស** បានដល់ និប្ផន្នរូប ៦ ដ៏សេស វៀររូបធម៌ ១២ ដែលលោកពោលថា " ធាតុ ១០ " ក្នុងទីនេះ លោកកំណត់យករូបរូបប៉ុណ្ណោះ មិនមែនកំណត់បរិច្ឆេទនៃរូប វិការនៃរូប និងលក្ខណៈនៃរូប ។ ចក្ខុវិញ្ញាណទាំង ២ ផ្នែក លោកពោលថា ចិត្តនោះឯង ព្រោះជាកុសលវិបាក និងអកុសលវិបាក ដោយដឹងរូបារម្មណ៍ និងមានចក្ខុជាទីអាស្រ័យដូចគ្នា ព្រោះជាចិត្តស្មើគ្នា ។ ដោយពាក្យថា **យ៉ាងនេះ** នេះលោកអាចារ្យរួមយកពាក្យដែលពោលទុក ដោយន័យ ជាដើមថា " អាស្រ័យចក្ខុ " ដូច្នេះ និងពាក្យជាដើមថា " អាស្រ័យសោតៈ " ដែលមិនបានពោលទុក ។

សូម្បីក្នុងពាក្យថា **មនោវិញ្ញាណធាតុ** នេះ គប្បីនាំ យកបទថា **ឯកោ** មកភ្ជាប់ថា មនោវិញ្ញាណធាតុ ១ ដូច្នេះ , ធាតុ ១១ ដកកន្លះ ឈ្មោះថា **អឌ្ឍេកាទស** ប្រែថា ១០ កន្លះ ។ម្យ៉ាងទៀត ធាតុ ១១ ដកកន្លះ នៃធាតុទាំង-ឡាយនោះ ហេតុនោះ ធាតុនោះ ឈ្មោះថា **អឌ្ឍេកាទស** ប្រែថា មាន ១១ ដកកន្លះ គឺ ១០ កន្លះ ។ សូម្បីក្នុងបទថា **អឌ្ឍដ្ឋមា** ប្រែថា ៨ ដកកន្លះ គឺ ធាតុ ៧ កន្លះ ក៏មានន័យដូចគ្នា ។

ពាក្យថា **តាមន័យដែលពោលហើយក្នុងចក្ខុធាតុនោះឯង** គឺ តាមន័យដែលពោលហើយដោយពាក្យមានជាអាទិ៍ថា ស្អាតដោយពន្លឺភ្នែកសខ្មៅ ដែលពពួកជនស្គាល់ថាជា ចក្ខុ ។

ពាក្យថា **ភិក្ខុក្នុងសាសនានេះ កំណត់ថា រូប ១៧ ក្នុងសរីរៈនេះ** លោក

ពោលទុក ដោយអំណាចការសម្តែងដល់ការប្រារព្ធវិបស្សនាក្នុងខាងក្នុង ។ ដោយហេតុនោះឯង លោកអាចារ្យ ទើបពោលថា រូប ១៧ គួរដល់ការពិចារណា រមែងចូលដល់ការពិចារណា ព្រោះហេតុនោះ ទើបឈ្មោះថា **សម្មសនុបគានិ** ប្រែថា ចូលដល់ការពិចារណា មានន័យថា គួរដល់ការពិចារណា ។

អាចារ្យទាំងឡាយពោលថា វិញ្ញត្តិទាំង ២ លោកពោលទុកដោយសព្ទថា **អាការ** , រូប ៣ មានលហុតារូប ជាដើម លោកពោលទុកដោយសព្ទថា **វិការ** , អាកាសធាតុ លោកពោលដោយសព្ទថា **បរិច្ឆេទ** ។ ម្យ៉ាងទៀត លោកអាចារ្យ ពោលលក្ខណៈរូប ជាមួយវិញ្ញត្តិរូបទាំង ២ ដោយសព្ទថា **អាការ** ។ ក៏លក្ខណៈរូបនោះ គ្រាន់តែជា អាការនៃការកើតឡើងជាដើម នៃរូបទាំងឡាយ ។

ពាក្យថា **អនន្តរបរិច្ឆេទ** បានដល់ គ្រឿងកំណត់ចន្លោះ ប្រហោង ព្រោះជាហេតុ មិនឱ្យកលាបៈទាំងនោះជាប់គ្នា ។ លោកអាចារ្យពោលពាក្យជាដើមថា " តែថា "ដូច្នេះ ដើម្បីនឹងចិញ្ចឹមពាក្យសួរថា ប្រសិនបើថា រូប ១០ មិនមែនជារូបដែលគួរដល់ការពិចារណា និងត្រឹមតែជាអាការជាដើម នឹងជារូបបានដូចម្តេច ?

លោកអាចារ្យកាលធ្វើការកំណត់រូប ឱ្យប្រាកដច្បាស់ ដោយពិស្តារ ទាក់ទងនឹងការកំណត់កោដ្ឋាសៈ ៤២ ញុំាងការកំណត់នាម ឱ្យប្រាកដច្បាស់ ដោយពិស្តារដូចគ្នា តាមទំនងនៃការកំណត់រូបនោះ បន្ទាប់ពីនោះ សម្តែងនូវការកំណត់រូប និងអរូប ដោយសង្ខេប យ៉ាងសង្ខេបជាងថា ដោយជាធាតុ ១៨

ដោយជាអាយតនៈ ១២ និង ដោយជា ខន្ធ ៥ យ៉ាងនេះហើយ បំណងនឹងសម្ដែងរូបនោះ ដោយន័យយ៉ាងសង្ខេបបំផុត ទើបពោលពាក្យជាដើមថា រូបយ៉ាងណាមួយ ។

បណ្ឌិតគប្បីជ្រាបការកំណត់រូប និងអរូប ដោយភាពជាឥន្ទ្រីយ៍ សច្ចៈ និង បដិច្ចសមុប្បាទ ដូចការកំណត់ធាតុដែរ ជាដើម ។ កំណត់យ៉ាងណា ? កំណត់ដោយជាឥន្ទ្រីយ៍មុន ៖ ឥន្ទ្រីយ៍ ៧ គឺ ឥន្ទ្រីយ៍ ៥ មានចក្ខុជាដើម និង ឥត្ថិន្ទ្រីយ៍ បុរិសិន្ទ្រីយ៍ ជារូប , ឥន្ទ្រីយ៍ ១១ គឺ មនិន្ទ្រីយ៍ ១ វេទនិន្ទ្រីយ៍ ៥ និង ឥន្ទ្រីយ៍ ៥ មានសទ្ធិន្ទ្រីយ៍ជាដើម ( សទ្ធិន្ទ្រីយ៍ សតិន្ទ្រីយ៍ វិរិយិន្ទ្រីយ៍ សមាធិន្ទ្រីយ៍ បញ្ញិន្ទ្រីយ៍ ) ចាត់ជានាម , ជីវិតិន្ទ្រីយ៍ ចាត់ជារូបផង ចាត់ជានាមផង , ឥន្ទ្រីយ៍ ៣ ខាងក្រោយ លោកមិនបំណងយកក្នុងទីនេះទេ ព្រោះជាលោកុត្តរ ។

ទុក្ខសច្ចៈ ជានាមផង ជារូបផង , សុមទយសច្ចៈជា នាម , សច្ចៈក្រៅពីនេះ លោកមិនបំណងយកក្នុងទីនេះទេ ព្រោះជាលោកុត្តរ ។

អង្គ ៣ ខាងដើមក្នុងបច្ចយាការ ជានាម , អង្គ ទី ៤ ទី ៥ ជានាមផង ជារូបផង , អង្គ ទី ៦-៧-៨-៩ ជានាម , អង្គ ទី ១០ ជានាមផង ជារូបផង , ២ អង្គចុងក្រោយ  អង្គ ១ ១ ចាត់ជានាមផង ចាត់ជារូបផង ។ បណ្ឌិតគប្បីធ្វើការកំណត់នាមរូបតាមរយៈ ឥន្ទ្រីយ៍ សច្ចៈ និង បច្ចយាការ តាមទំនងដែលបានពោលហើយ ក្នុងទីនោះ ។ ដោយប្រការដូចពោលមកដូច្នេះចុះ ។ ប្រយោជន៍នៃការពោលដោយវិភាគនៃការកំណត់នាមរូប  យ៉ាងនេះ  បានពោលទុកក្នុងបទមុននោះហើយ ។

បណ្ដាអរូបធម៌ទាំងឡាយ  មានវេទនាជាដើម អរូបធម៌ដែលកើតឡើង

មុន ៗ មានសភាពជាអរូបធម៌ដែលល្អិតសុខុម ក្រៃលែងឡើង ៗ នោះក៏ទេ , ពិតហើយ អរូបធម៌ទាំងអស់ បើប្រៀបជាមួយរូបធម៌ទាំងឡាយ ដែលដល់នូវភាពប្រែប្រួល ដោយអាការដែលប៉ះខ្ទប់ ក៏ជាធម៌ដែលល្អិត តែម្យ៉ាង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **អរូបធម៌មិនទាន់ប្រាកដ ព្រោះជាធម៌ល្អិត** ។

ពាក្យថា **គប្បីពិចារណា** គឺ គប្បីសង្កេតដោយលក្ខណៈជាដើម ឱ្យបានប្រាកដត្រឹមត្រូវ ។ ពាក្យថា **គប្បីធ្វើទុកក្នុងចិត្ត** គឺ គប្បីតម្កល់ទុកក្នុងចិត្តយ៉ាងនោះ ។ ពាក្យថា **គប្បីកំណត់** គឺ គប្បីកំណត់ដោយបញ្ញាដែលធ្វើការកំណត់ហើយ ជាក់ច្បាស់ ។ ពាក្យថា **គប្បីចែក** គឺ គប្បីបែងចែកមិនឱ្យលាយឡំគ្នា ។ បទថា **អស្ស យោគ យោគិនោ** ។

បទថា **សុវិក្ខាលិតំ** ប្រែថា ជាវត្ថុដែលបរិសុទ្ធល្អ ។

កាលយោគាវចរ ដែលជាអាទិកម្មិកៈ កំណត់កម្មដ្ឋាន ធម៌ទាំងឡាយដែលនៅមិនទាន់ប្រាកដច្បាស់ល្អ ដរាបណា ធម៌ទាំងឡាយនោះនៅត្រូវកំលាំងគឺ សម្មោហៈ បិទបាំងធម៌នោះ នៅគ្របសង្កត់ រមែងជាធម្មជាតិមិនបរិសុទ្ធនៅលាយឡំគ្នានិងគ្នា ព្រោះមិនមានការប្រាកដ ដោយការដាច់ពីគ្នា ។ តែពេលណាប្រាកដច្បាស់ ដោយវិធី មានការពិចារណាជាដើម ពេលធម៌ទាំងឡាយនោះ បរិសុទ្ធល្អហើយ រមែងជាសភាវៈ ឈ្មោះថា មិនមានអ្វីលាយឡំ ។ ដោយហេតុនោះ លោកអាចារ្យទើបពោលពាក្យជាដើមថា **រូបជាវត្ថុបរិសុទ្ធមិនមានអ្វីលាយឡំ ដោយប្រការណា ៗ** ។

លោកអាចារ្យពោលថា **អរូបធម៌ទាំងឡាយ ដែលមានរូបធម៌នោះ ជា**

**អារម្មណ៍** ដូច្នេះ ព្រោះធ្វើអធិប្បាយថា អរូបធម៌ទាំងឡាយ រមែងប្រាកដដោយអាការដែលប្រព្រឹត្តទៅ ប្រារព្ធយករូបធម៌ទាំងឡាយដោយច្រើន ដល់ព្រះយោគាវចរ ដែលជាអាទិកម្មិកៈ ។ ដោយហេតុនោះឯង ក្នុងខាងដើម លោកអាចារ្យទើបពោលថា **អរូបធម៌ទាំងឡាយ រមែងប្រាកដដោយភាពជាទ្វារ ដល់ព្រះយោគាវចរនោះ ដែលមានរូបបានកំណត់ហើយ យ៉ាងនេះ** មិនមែនប្រាកដដោយជាវត្ថុទេ ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងប្រកាសសេចក្តី តាមដែលបានពោលហើយថា ការកំណត់រូបជាឧបាយ និង ជាការឧបត្ថម្ភនៃការកំណត់អរូបដោយឧបមាទាំងឡាយ ទើបពោលពាក្យមានជាអាទិថា **ដូចជា.... មានឧបមាយ៉ាងណា** ។ ពាក្យថា **ស្រមោលមុខ** បានដល់ រូបដូចមុខ ។

ក្នុងពាក្យនោះ មានការប្រៀបឧបមាដូច្នេះ :

ព្រះយោគាវចរប្រៀបដូចបុរសមានភ្នែកល្អ ញាណកំណត់កម្មដ្ឋានរបស់យោគី ប្រៀបដូចជាភ្នែករបស់បុរសនោះ ការកំណត់រូប ប្រៀបដូចជាកញ្ចក់ ការកំណត់អរូប ប្រៀបដូចជាស្រមោលមុខ កាលកំណត់រូបមិនបរិសុទ្ធ ប្រៀបដូចកញ្ចក់ដែលស្រអាប់ ការដែលអរូបទាំងឡាយមិនប្រាកដ ព្រោះការដែលកំណត់រូបនៅមិនទាន់បរិសុទ្ធ ប្រៀបដូចជាការមិនប្រាកដនៃស្រមោលមុខក្នុងវេលានោះ ការកំណត់រូបឱ្យបរិសុទ្ធ បន្តិចម្តង ៗ ប្រៀបដូចជាការជូតកញ្ចក់រឿយៗ ការប្រាកដច្បាស់នៃអរូបធម៌ទាំងឡាយ ក្នុងការកំណត់រូបបរិសុទ្ធល្អមិនមានអ្វីលាយឡំ ប្រៀបដូចជាការប្រាកដច្បាស់នៃស្រមោលមុខ ក្នុងកញ្ចក់ដែលជូតថ្លាល្អ ហើយដូច្នោះ ។

គប្បីជ្រាបការប្រៀបធៀប ពាក្យឧបមាតាមសមគួរ ស្វម្បីក្នុងពាក្យឧបមាទាំងឡាយ មានពាក្យឧបមាដោយបុគ្គលដែលត្រូវការប្រេងជាដើម តាមន័យនេះ ។ ពាក្យថា **ម្សៅល្ង** បានដល់ លម្អិតល្ង ។ ពាក្យថា **គ្រាប់តុម្ពកា** បានដល់ផ្លែឈើតុម្ពកា ។ ពាក្យថា **កករ១** បានដល់ លំអងដីតូច ១ ។

ពាក្យថា **ជាសត្រូវដល់ញាណដែលកំណត់អរូបធម៌នោះ** បានដល់កិលេស មានសម្មោហៈជាដើម ដែលជាបដិបក្ខ ដោយភាពជាធម្មជាតិរារាំងនូវញាណដែលកំណត់អរូបធម៌នោះ ។

ក្នុងពាក្យឧបមា មានអំពៅជាដើម មានពាក្យសម្ដែងនូវគន្លងផ្លូវដូចតទៅនេះ :

បុគ្គលដែលត្រូវការទឹកអំពៅ បានដាក់អំពៅចូលទៅក្នុងឧបករណ៍គាបអំពៅ ពេលដែលទឹកអំពៅមិនបានចេញដោយគ្រឿងគាប ដំណើរទៅ ១ លើក ២លើក ក៏មិនបានលះបង់អំពៅចោល យ៉ាងណា អ្នកមានអំណាចចាប់ចោរបានហើយ ត្រូវការនឹងដឹងកំហុសដែលពួកវាបានធ្វើ កាលបើចោរមិនទាន់បានប្រាប់សេចក្ដីនោះ ដោយគ្រាន់តែដាក់ទណ្ឌកម្ម ១លើក ២លើក ក៏មិនដោះលែងពួកចោរទៅ យ៉ាងណា , ន័យម្យ៉ាងទៀត អ្នកហ្វឹកគោត្រូវការនឹងហ្វឹកគោ ទើបចាប់គោទឹម កាលវាមិនព្រមដើរទៅតាមផ្លូវ ១លើក ២លើក ក៏មិនព្រមលែងវា , ម្យ៉ាងទៀត បុគ្គលត្រូវការកូរទឹកដោះជូរ ដើម្បីឱ្យបានទឹកដោះខាប់ ក៏ដាក់ម្សៅចូលទៅក្នុងទឹកដោះជូរនោះ គ្រាន់តែកូរ ១លើក ២លើក ពេលដែលវាមិនទាន់កើតជាទឹកដោះខាប់ ក៏មិនបោះចោលនូវទឹកដោះជូរនោះ យ៉ាងណា , ន័យម្យ៉ាងទៀត បុគ្គលត្រូវការនឹងអាំងត្រីបរិភោគ ត្រឹមតែអាំង

ភ្លើងត្រឡប់ ២ត្រឡប់ កាលបើត្រីមិនទាន់ឆ្អិន ក៏មិនបោះត្រីនោះចោល យ៉ាងណា បណ្ឌិតគប្បីប្រកបខ្លឹមសារឧបមា ក្នុងទីគ្រប់កន្លែង ដោយពាក្យជាដើមថា " **គ្រានោះឯង គេរមែងគាបអំពៅនោះរឿយៗ ក្នុងឧបករណ៍គាបអំពៅ** " តាមទំនងនៃពាក្យដែលបានពោលហើយ ក្នុងពាក្យនេះថា " **គ្រានោះឯង គេក៏ផ្ទួតកញ្ចក់នោះរឿយៗ** " ដូច្នេះ ។

( ចប់មហាដីកា )

## អរូបធម៌ប្រាកដដោយអាការ ៣ យ៉ាង

ឯអរូបធម៌ទាំងឡាយ រមែងប្រាកដដល់ភិក្ខុអ្នកមានការកំណត់រូបដែលបរិសុទ្ធល្អ បានយ៉ាងនេះហើយ ដោយអាការ ៣ គឺ **ដោយអំណាចផស្សខ្លះ ដោយអំណាចវេទនាខ្លះ ដោយអំណាចវិញ្ញាណខ្លះ** តើប្រាកដយ៉ាងណា ?

## អរូបធម៌ប្រាកដតាមរយៈផស្ស

លំដាប់ដំបូង កាលព្រះយោគាវចរ ១ រូប កំណត់ធាតុទាំងឡាយដោយន័យថា " **បឋវីធាតុ មានភាពរឹង ជាលក្ខណៈ** " ដូច្នេះជាដើម អរូបធម៌ដែលប្រាកដមកចំពោះមុខ ជាដំបូង ឈ្មោះថា **ផស្ស** រមែងប្រាកដ បន្ទាប់ពីនោះ **វេទនា** ដែលសម្បយុត្តជាមួយផស្សនោះ ឈ្មោះថា វេទនាខន្ធក៏ប្រាកដ , **សញ្ញា** ដែលសម្បយុត្តជាមួយផស្សនោះ ឈ្មោះថា សញ្ញាខន្ធក៏ប្រាកដ , **ចេតនា**

ដែលកើតរួមជាមួយផស្សនោះ ឈ្មោះថា សង្ខារក្ខន្ធ ក៏ប្រាកដ , **ចិត្ត** ឈ្មោះថា វិញ្ញាណក្ខន្ធក៏ប្រាកដ តាមន័យដែលទាក់ទងគ្នានោះ កាលព្រះយោគាវចរភិក្ខុ កំណត់ធាតុទាំងឡាយ ( ដោយពិស្តារ ) តាមន័យថា " បឋវីធាតុក្នុងសក់មាន ភាពរឹង ជាលក្ខណៈ ។ល។ " បឋវីធាតុក្នុងខ្យល់ដង្ហើមចេញ-ចូល មានភាព រឹង ជាលក្ខណៈ " ដូច្នេះជាដើម អរូបធម៌ដែលព្រមព្រៀងចំពោះមុខ ដំបូង ឈ្មោះថា **ផស្ស** រមែងប្រាកដ , **វេទនា** ដែលសម្បយុត្តជាមួយផស្សនោះ ឈ្មោះថា វេទនាខន្ធក៏ប្រាកដ ។ ល ។ **ចិត្ត** ឈ្មោះថា វិញ្ញាណក្ខន្ធក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ ប្រាកដដោយអំណាចផស្ស មានប្រការដូចដែល ពោលមកដូច្នេះឯង ។

## អរូបធម៌ប្រាកដតាមរយៈវេទនា

កាលព្រះយោគាវចរ ១ រូប កំណត់ធាតុទាំងឡាយ ដោយន័យថា " **បឋវីធាតុ មានភាពរឹង ជាលក្ខណៈ**" ដូច្នេះជាដើម **វេទនា** ដែលសោយ រសនៃសភាវៈ គឺ ភាពរឹងនោះ ឈ្មោះថា វេទនាខន្ធប្រាកដ , **សញ្ញា** ដែល សម្បយុត្តជាមួយវេទនានោះ ឈ្មោះថា សញ្ញាខន្ធក៏ប្រាកដ , **ផស្ស** និង **ចេតនា** ដែលសម្បយុត្តជាមួយវេទនាខន្ធនោះ ឈ្មោះថា សង្ខារក្ខន្ធក៏ប្រាកដ , **ចិត្ត** ដែលសម្បយុត្តជាមួយវេទនាខន្ធនោះ ឈ្មោះថា វិញ្ញាណក្ខន្ធក៏ប្រាកដ តាមន័យដូចគ្នានោះ កាលព្រះយោគាវចរភិក្ខុកំណត់ធាតុទាំងឡាយ ( យ៉ាង ពិស្តារ ) ដោយន័យថា " **បឋវីធាតុក្នុងសក់ មានភាពរឹង ជាលក្ខណៈ** ។ល។ បឋវីធាតុក្នុងខ្យល់ដង្ហើមចេញចូល មានភាពរឹង ជាលក្ខណៈ " ដូច្នេះជាដើម

វេទនាដែលសោយរសនៃសភាវៈ គឺ ភាពរឹងនោះ ឈ្មោះថា វេទនាខន្ធ រមែងប្រាកដ ។ ល ។ **ចិត្ត** ដែលសម្បយុត្តជាមួយវេទនានោះ ឈ្មោះថា វិញ្ញាណក្ខន្ធ ក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ រមែងប្រាកដ ដោយអំណាចនៃវេទនា ដូចពោលមក ដូច្នេះឯង ។

## អរូបធម៌ប្រាកដតាមរយៈវិញ្ញាណ

កាលព្រះយោគាវចរ ១ រូប កំណត់ធាតុទាំងឡាយ ដោយន័យថា " **បឋវីធាតុ មានភាពរឹង ជាលក្ខណៈ** " ដូច្នេះជាដើម **វិញ្ញាណ** ដែលដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា វិញ្ញាណក្ខន្ធ ក៏ប្រាកដ , **វេទនា** ដែលសម្បយុត្តជាមួយវិញ្ញាណនោះ ឈ្មោះថា វេទនាខន្ធក៏ប្រាកដ , **សញ្ញា** ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ ឈ្មោះថា សញ្ញាខន្ធ ក៏ប្រាកដ , **ផស្ស** និង **ចេតនា** ឈ្មោះថា សង្ខារក្ខន្ធ ក៏ប្រាកដ ដោយន័យដូចគ្នានោះ កាលព្រះយោគាវចរ កំណត់ធាតុទាំងឡាយ ដោយន័យថា " **បឋវីធាតុក្នុងសក់ មានភាពរឹង ជាលក្ខណៈ** ។ ល ។ **បឋវីធាតុក្នុងខ្យល់ដង្ហើមចេញ-ចូល មានភាពរឹង ជាលក្ខណៈ** " ដូច្នេះជាដើម **វិញ្ញាណ** ដែលដឹងច្បាស់នូវអារម្មណ៍ ឈ្មោះថា វិញ្ញាណក្ខន្ធ ក៏ប្រាកដ , **វេទនា** ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ ឈ្មោះថា វេទនាខន្ធ ក៏ប្រាកដ , **សញ្ញា** ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ ឈ្មោះថា សញ្ញាខន្ធ ក៏ប្រាកដ , **ផស្ស** និង **ចេតនា** ដែលសម្បយុត្តជាមួយនឹងវិញ្ញាណនោះ ឈ្មោះថា សង្ខារក្ខន្ធ ក៏ប្រាកដ ។

អរូបធម៌ទាំងឡាយ ប្រាកដដោយអំណាចនៃវិញ្ញាណ មានដូចពោលមក ដូច្នេះឯង ។

ដោយឧបាយនេះឯង បណ្ឌិតគប្បីធ្វើយោជនា ( ការប្រកបសេចក្ដី ) ក្នុងកោដ្ឋាសៈនៃធាតុ ៤២ ដោយន័យថា " បឋវីធាតុក្នុងសក់ ដែលមានកម្មជាសមុដ្ឋាន មានភាពរឹង ជាលក្ខណៈ " ដូច្នេះជាដើម និងក្នុងធាតុដ៏សេសមានចក្ខុធាតុជាដើម ដោយអំណាចនៃធាតុ ៤ ។ ទៅតាមប្រភេទនៃន័យទាំងពួង ក្នុងមាតិកានៃការកំណត់រូបនោះចុះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលអរូបធម៌ទាំងឡាយ រមែងប្រាកដដោយអាការ ៣ យ៉ាង ដល់ភិក្ខុដែលមានការកំណត់រូបបានបរិសុទ្ធល្អ យ៉ាងនេះប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគាវចរ គប្បីធ្វើយោគៈ ដើម្បីកំណត់អរូបធម៌ តាមរយៈការកំណត់រូបឱ្យបរិសុទ្ធល្អនោះឯង មិនគប្បីធ្វើដោយការកំណត់យ៉ាងដទៃទេ ព្រោះប្រសិនបើ រូបធម៌ ១ ឬ ២ យ៉ាង ប្រាកដ ( មិនទាន់បរិសុទ្ធល្អ ) លោកលះបង់រូបចោល ផ្ដើមកំណត់អរូប លោកនឹងវិនាសចាកកម្មដ្ឋានក៏បាន ដូចគោដែលរកស៊ីនៅលើភ្នំ ( មិនស្គាល់ភូមិសាស្ត្រ ដើរទៅភ្លាត់ធ្លាក់រណ្ដៅ ) មានប្រការដូចពោលហើយនៅក្នុងការបំពេញបឋវីកសិណ តែកាលបើលោកធ្វើយោគៈ តាមការកំណត់រូបដែលបរិសុទ្ធល្អហើយ កម្មដ្ឋានទើបនឹងដល់នូវភាពចម្រើនរុងរឿងទៅបាន ។

ព្រះយោគាវចរនោះ កំណត់អរូបខន្ធ ៤ ដែលប្រាកដដោយអំណាចនៃផស្សជាដើមថា ជានាម , កំណត់មហាភូតរូប ៤ ដែលជាអារម្មណ៍នៃអរូបក្ខន្ធនោះ និង រូបដែលអាស្រ័យនឹងមហាភូតរូប ៤ ថា ជារូប ដោយប្រការ

ដូច្នេះ ។

ព្រះយោគាវចរ រមែងកំណត់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ គឺ ធាតុ ១៨ អាយតនៈ ១២ ខន្ធ ៥ ចែកជា ២ ចំណែក គឺ នាម ១ រូប ១ ដូចបុគ្គលបើកស្មុគដោយកាំបិត និង ដូចពុះបំបែកគ្រាប់ត្នោត ដូច្នោះ លោករមែងដល់នូវភាពខកចិត្តថា " **ក្រៅពីនាមរូបហើយ វត្ថុដទៃដែលជា សត្វក្តី បុគ្គលក្តី ទេពក្តី ព្រហ្មក្តី មិនមាន** " ។

## មហាដីកា

## អាការប្រាកដនៃអរូបធម៌

ធម៌ទាំងឡាយ រមែងប្រាកដទូទៅ គឺ រមែងជួបប្រទះដោយសភាវៈទាំងឡាយនេះ ព្រោះហេតុនោះ សភាវៈទាំងឡាយនោះ ឈ្មោះថា **អាការ** ប្រែថា ជាគ្រឿងប្រាកដទូទៅ បានដល់ **អាការ** គឺ ការប៉ះខ្ទប់ ការសោយអារម្មណ៍ និង ការដឹងច្បាស់ ដែលជាគន្លងនៃការប្រាកដនៃអរូបធម៌ទាំងឡាយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលពាក្យមានជាអាទិ៍ថា " **អរូបធម៌ទាំងឡាយ រមែងប្រាកដដោយអាការ ៣ យ៉ាង** " ។

សូម្បីកាលមិនទាន់មានចិត្ត និងចេតសិក ប្រព្រឹត្តទៅក្នុងអារម្មណ៍ , ផស្ស ដែលមានការប៉ះខ្ទប់ក្នុងអារម្មណ៍ ទាំងខាងដើមនិងខាងចុង ជាលក្ខណៈ ក៏រមែងដូចជាប្រាកដចំពោះមុខ មុនអរូបធម៌ទាំងអស់ ក្នុងបណ្តាចិត្ត និង ចេតសិកទាំងអស់នោះ ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា " **ការ**

**ដែលអរូបធម៌ប្រាកដចំពោះដំបូង ឈ្មោះថា ផស្ស** ” ។ ដោយហេតុនោះ លោកអាចារ្យទើប សម្តែងសេចក្តីប្រាកដ ដោយអាការប៉ះខ្ទប់នៃផស្សនោះ ដោយភាវៈដែលប្រាកដច្បាស់ល្អ ។

ពេលផស្សប្រាកដហើយ ផស្សនោះនៅក្នុងអារម្មណ៍ណា វេទនា ក៏មានការសោយអារម្មណ៍នោះ ជាលក្ខណៈ , សញ្ញា ក៏មានការចាំអារម្មណ៍នោះ ជាលក្ខណៈ , ចេតនា មានការតាំងចិត្ត ជាលក្ខណៈ , វិញ្ញាណ មានការដឹងច្បាស់នូវអារម្មណ៍នោះ ជាលក្ខណៈ ព្រោះហេតុនោះ សូម្បីធម៌ទាំងឡាយនេះ ក៏ជាធម៌ប្រាកដដូច្នេះ , លោកអាចារ្យ ទើបពោលពាក្យមានជាអាទិ៍ថា “ **វេទនាដែលសម្បយុត្តជាមួយផស្សនោះ** ” ដូច្នេះ ។

លោកអាចារ្យកាលសម្តែងការកំណត់អរូប តាមរយៈផស្ស ទាក់ទងនឹងការកំណត់ធាតុ ៤ ដោយសង្ខេបលក្ខណៈរបស់ខ្លួនយ៉ាងនេះហើយ ឥឡូវនេះ បំណងនឹងសម្តែងការកំណត់អរូបនោះ ទាក់ទងនឹងការកំណត់ធាតុ ៤ ដោយពិស្តារ ទើបពោលពាក្យជាដើមថា “ ដោយន័យដូចគ្នា ” កាលព្រះយោគាវចរកំណត់ធាតុដោយពិស្តារថា “ **បឋវីធាតុក្នុងសក់ មានលក្ខណៈរឹង** ” ។ ក្នុងពាក្យនោះ ពាក្យថា **បឋវីធាតុ ក្នុងសក់** បានដល់ បឋវីធាតុក្នុងចំណែកនៃបឋវី-ធាតុដែលហៅថា សក់ ។ ក្នុងប្រការនេះ ជាពាក្យសំដែងនូវការកំណត់ធាតុដោយការចែកលក្ខណៈរបស់ខ្លួន ។

លោកអាចារ្យ បំណងនឹងសម្តែងការកំណត់អរូប តាមរយៈវេទនា ទាក់ទងនឹងការកំណត់ធាតុទាំង ២ យ៉ាង តទៅ ទើបពោលពាក្យ មានជាអាទិ៍ថា “ **កាលព្រះយោគាវចរ ១ អង្គ** ” ដូច្នេះ ។ ក្នុងបណ្តាពាក្យទាំងឡាយ

នោះ ពាក្យថា **វេទនាដែលសោយរសនៃសភាវៈ គឺ ភាពរឹងនោះ** បានដល់ វេទនាដែលប្រព្រឹត្តទៅ ទាក់ទងនឹងការសោយសភាវៈនៃផោដ្ឋព្វៈ ពោលគឺ ភាពរឹង ។

សូម្បីក្នុងពាក្យថា កាលយោគាវចរ ១ រូប ទៀត គប្បីជ្រាបការភ្ជាប់សេចក្តី តាមន័យដែលពោលហើយនោះចុះ ។ ក្នុងពាក្យនោះ ពាក្យថា **ទទួលដឹងអារម្មណ៍** បានដល់ ទទួលដឹងអារម្មណ៍ គឺ ផោដ្ឋព្វៈ ពោលគឺ ភាពរឹង ។ លោកអាចារ្យពោលដល់ ការប្រាកដតាមកាយទ្វារ ឬ ពោលដល់ ជវនវិញ្ញាណ ( ជវនចិត្ត ) តាមមនោទ្វារតែម្យ៉ាង ។ ក៏ជវនវិញ្ញាណតាមមនោទ្វារនោះ រមែងដឹងថា " បឋវីធាតុ មានលក្ខណៈរឹង " ចំណែកការប្រាកដចំពោះមុខតាមរយៈកាយទ្វារក្រៅពីនេះ គ្រាន់តែដឹងលក្ខណៈរឹងប៉ុណ្ណោះ ។

ពាក្យថា **ដោយឧបាយនេះចុះ** មានន័យថា លោកអាចារ្យកាលសំដែងការកំណត់រូប ទាក់ទងនឹងការកំណត់ធាតុ ៤ ដោយសង្ខេបលក្ខណៈនៃធាតុ ដោយការចែកលក្ខណៈរបស់ធាតុ ហើយបានសម្តែងឧបាយនៃការកំណត់អរូបតាមរយៈអរូបធម៌មានផស្សជាដើម ដល់ព្រះយោគាវចរដែលតាំងនៅក្នុងការកំណត់រូបនោះ ដោយឧបាយនេះចុះ ។ ពាក្យថា **ក្នុងសក់ដែលមានកម្មជាសមុដ្ឋាន** គឺ ក្នុងសក់ដែលមានកម្មជាសមុដ្ឋាន ដែលបានអធិប្បាយសេចក្តីក្នុងសក់ដែលមានកម្មជាសមុដ្ឋាន ៤ ។

ដោយ **អាទិ** ស័ព្ទ ក្នុងពាក្យថា ដោយន័យជាដើមថា បឋវីធាតុមានភាពរឹង ជាលក្ខណៈ ។ បណ្ឌិតគប្បីឃើញថា ព្រមទាំងធាតុដទៃដែលមានលក្ខណៈផ្សេងគ្នាថា " អាបោធាតុ មានលក្ខណៈសើមជ្រួតជ្រាប " ដូច្នេះ តែ

ម្យ៉ាង ប៉ុណ្ណោះ ក៏មិនបាន , ដោយពិត រួមយកកោដ្ឋាសៈដទៃ ដែលចែកជាកោដ្ឋាសៈនៃធាតុដែលមានសមុដ្ឋាន ១ ជាដើម ក្នុងបណ្តាកោដ្ឋាសៈនៃធាតុ ៤២ នោះ បណ្ឌិតគប្បីធ្វើពាក្យប្រកបទាក់ទងនឹងការសម្តែងការកំណត់អរូបតាមរយៈការកំណត់រូប មានចក្ខុធាតុជាដើម ទៅតាមប្រភេទនៃន័យ គឺសេចក្តីផ្សេងៗ នៃន័យទាំងពួងនោះ ។

ការសម្តែងគន្លងពាក្យប្រកប ក្នុងពាក្យនោះមានដូច្នេះ : ជាដំបូងកាលព្រះយោគាវចរអង្គ ១ កំណត់ធាតុទាំងឡាយ ដោយន័យមានជាអាទិថា " ចក្ខុធាតុ មានលក្ខណៈថ្លានៃមហាភូតរូប ដែលគួរដល់ការប៉ះខ្ទប់នឹងរូបខ្លះ ឬមានលក្ខណៈថ្លានៃមហាភូតរូប ដែលមានកម្មជាសមុដ្ឋាន មានការប្រាថ្នាចង់ឃើញជាហេតុខ្លះ " ដូច្នេះ គប្បីប្រកបពាក្យទាំងអស់ថា ការដែលអរូបធម៌ប្រាកដមក ចំពោះមុខដំបូងប្រាកដ ឈ្មោះថា **ផស្ស** , តទៅវេទនាដែលសម្បយុត្តជាមួយផស្សនោះប្រាកដ ឈ្មោះថា **វេទនា** ដូច្នេះ ។

គប្បីប្រកបពាក្យមានជាអាទិថា " វេទនាដែលសោយរសនៃចក្ខុធាតុដែលមានលក្ខណៈ តាមដែលពោលហើយ ប្រាកដឈ្មោះថា វេទនាខន្ធ " ។ ម្យ៉ាងទៀត បណ្ឌិតគប្បីប្រកបពាក្យទាំងពួង ដោយន័យមានជាអាទិ៍ថា " ចក្ខុធាតុ មានលក្ខណៈតាមដែលពោលហើយ " វិញ្ញាណដែលដឹងអារម្មណ៍ជាវិញ្ញាណក្ខន្ធ " សូម្បីក្នុងគន្លងនៃការកំណត់រូប ទាក់ទងនឹងអាយតនៈជាដើម ក៏មានន័យដូច្នេះ ។

លោកអាចារ្យ កាលនឹងសម្តែងថា ឈានជាន់ទាបដែលចម្រើនល្អហើយ ធ្វើឱ្យដល់ភាពជាវសីនោះឯង រមែងជាបទដ្ឋាននៃឈានជាន់លើ ឈាន

ដែលទើបតែបានមក ជាបទដ្ឋានមិនបានឡើយ យ៉ាងណា ការកំណត់រូបដែលបរិសុទ្ធល្អ មិនមានអ្វីលាយឡំ មិនមានអ្វីបិទបាំង រមែងជាបទដ្ឋាននៃការកំណត់អរូប ការកំណត់រូបដែលមិនបរិសុទ្ធ ជាបទដ្ឋានមិនបានឡើយ ក៏ដូច្នោះដែរ ព្រោះហេតុនោះ កាលចំណែកមួយនៃរូប និងអរូបមិនប្រាកដ ការកំណត់រូបនោះ ឈ្មោះថា នៅមិនទាន់បរិសុទ្ធ នឹងចាំបាច់ពោលថ្វី ដល់ទៅភាគច្រើននោះ ដូច្នេះ ទើបពោលពាក្យមានជាអាទិ៍ថា " ប្រសិនបើ " ។ ដូចគោដែលរកស៊ីលើភ្នំ តែល្ងង់ មិនឆ្លាត មិនស្គាល់ភូមិសាស្ត្រ ។

ពាក្យថា **ដោយកាំបិត** គឺ ដោយចុងកាំបិត ។ ពាក្យថា **ប្រអប់** គឺ ប្រអប់ធំស្រដៀងហិប ។ លោកអាចារ្យ ពោលការបើកប្រអប់ និងការពុះផ្លែត្នោត ដោយភាវៈជាតួយ៉ាង ដើម្បីសម្តែងថា **នាមរូប** សូម្បីប្រាកដហាក់ដូចមិនបែកគ្នា ដល់បុគ្គលដែលមិនបានកំណត់កម្មដ្ឋាន ក៏នៅតែជាសភាវៈបែកពីគ្នា ព្រោះថា ភាពបែកពីគ្នានោះ រមែងប្រាកដក្នុងការកំណត់កម្មដ្ឋាន ។ ដូចគ្រាប់ត្នោត ដែលមានស្នាមតដាច់ពីគ្នា ក៏ប្រាកដដូចជាមិនបែកគ្នា រូបធម៌ និង នាមធម៌ ក៏ដូច្នោះដែរ ។

ក្នុងពាក្យថា ព្រះយោគាវចរ រមែងកំណត់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ចែកជា ២ ចំណែក គឺ រូប ១ នាម ១ នេះ ស័ព្ទថាទាំងអស់ ជាពាក្យកំណត់យកដែលមិនមានចំណែកសល់ ក៏ពិត សូម្បីយ៉ាងនោះ ភាពជានាម និងរូបបែកពីគ្នា ក៏ព្រោះហេតុ នាម និងរូប ទាំង ២ មិនគប្បីឱ្យសម្រេចចុះ ដោយការរួមគ្នា ព្រោះហេតុនោះ ទើបមានសេចក្តីថា រមែងកំណត់ចែកជា ២ ចំណែកយ៉ាងនេះ " ក្នុង នាម និងរូប ទាំង ២ នេះ

វត្ថុណា មានការបង្អោនទៅ ជាលក្ខណៈ វត្ថុនោះជា **នាម** , វត្ថុណា មានការបែកធ្លាយ ជាលក្ខណៈ វត្ថុនោះជា **រូប** " ដូច្នេះ ។

ព្រះយោគាវចរដែលកំណត់ចែកយ៉ាងនេះឯង លោកហៅថា " កំណត់ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ ចែកជា ២ ចំណែក គឺ នាម១ រូប១ " ព្រោះក្នុងបណ្តាធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មិនមានអ្វីៗដែលផុតទៅអំពីនាម និងរូប ទាំង ២ នោះឡើយ ។

សេចក្តីដែល នាម និងរូបនោះ សម្រេចជា ២ យ៉ាង ដោយពាក្យថា " នាម១ រូប១ " នោះ , ពាក្យថា " រមែងកំណត់ចែកជា ២ ចំណែក " ដើម្បីនឹងសម្តែងនូវការដែលមិនមានធម៌ដទៃក្រៅពី **នាម** និង **រូប** ។

ព្រោះហេតុនោះ លោកអាចារ្យទើបពោលពាក្យមានជាអាទិ៍ថា " **ក្រៅពីនាមរូបហើយ** " ដូច្នេះ ។ ចំណែក ស័ព្ទថា " ធម៌ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងអស់ " ក្នុងទីនេះ លោកពោលទុក ព្រោះជាធម៌ដែលគួរដល់ការពិចារណា ជាសភាវៈដែលមិនគប្បីឱ្យមានចំណែកសល់ ។ ពិតហើយ ធម្មជាតិនោះ គួរកំណត់ដឹងគ្រប់ប្រការទាំងពួង គួរលះបង់នូវសេចក្តីត្រេកត្រអាល ព្រោះហេតុនោះ **ចិត្ត** ក៏ភិក្ខុគួរលះបង់ការជាប់ជំពាក់ចោលដែរ ។

ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា :

**ម្នាលភិក្ខុទាំងឡាយ អ្នកដែលមិនដឹង មិនកំណត់ដឹងវត្ថុទាំងពួង មិនលះបង់តម្រេក មិនទាន់លះបង់ការជាប់ចិត្តក្នុងវត្ថុទាំងពួង នឹងជាអ្នកមិនគួរអស់ទុក្ខបានឡើយ , ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកដែលដឹង កំណត់ដឹងវត្ថុទាំងពួង លះបង់តម្រេក លះបង់ការជាប់ចិត្តក្នុងវត្ថុទាំងពួង ជាអ្នកគួរនឹងអស់**

**ទុក្ខបាន ។**

សួរថា ប្រសិនបើធម្មជាតិដែលប្រព្រឹត្តទៅក្នុងភូមិ ៣ លោកកាន់យក ដោយមិនមានចំណែកសល់ថា " **នាមរូប** " ដូច្នេះសោត លទ្ធិណា ដែលបុគ្គល ក្រៅពីព្រះសាសនានេះ កំណត់ដោយការសម្គាល់ចំពោះបទ ដូចជា បកតិ ជាដើម ទ្រព្យជាដើម ជីវៈជាដើម កាយជាដើម ក្នុងលទ្ធិនោះ គួរបដិបត្តិ យ៉ាងណា ?

សេចក្ដីនេះ ឆ្លើយថា ក្នុងលទ្ធិនោះ ព្រះសម្មាសម្ពុទ្ធ មិនបានប្រកាស ទុកឡើយ ប្រព្រឹត្តទៅជាភាពរវើរវាយ ដូចបុគ្គលឆ្កួតប៉ុណ្ណោះ នឹងមានឧបដិបត្តិ យ៉ាងណាទៅ ក្រៅពីការព្រងើយ ៗ ។

## ការប្រៀបធៀប
## ដោយព្រះសូត្រច្រើនសូត្រ

ព្រះយោគាវចរនោះ កាលកំណត់ចែកនាមរូប តាមសេចក្ដីពិត បាន យ៉ាងនេះហើយ ដើម្បីជាប្រយោជន៍ក្នុងការលះបង់នូវលោកសមញ្ញា " ដែល មហាជនដឹងគ្នា " ថានេះជា " សត្វ " វា " បុគ្គល " ដើម្បីជាប្រយោជន៍ដល់ ការឈានកន្លងនូវសេចក្ដីវង្វេង ថាជាសត្វ ដើម្បីប្រយោជន៍ដល់ការតម្កល់ចិត្ត ទុកនៅក្នុងអសម្មោហភូមិឱ្យប្រពៃឡើងទៅ រមែងកំណត់ដោយប្រៀបធៀប សេចក្ដីនោះថា **នេះមានត្រឹមតែនាមរូបប៉ុណ្ណោះ សត្វមិនមាន បុគ្គលមិនមាន** បានតាមព្រះសូត្រច្រើនសូត្រ , ពិតហើយ ក្នុងវជិរាសូត្រ ព្រះនាងវជិរាភិក្ខុនី

បានពោលពាក្យនេះទុកថា :

ព្រោះមានអង្គសម្ភារៈប្រកប ពាក្យហៅថា " រថ " ទើបមានបាន យ៉ាងណា កាលខន្ធទាំងឡាយមានហើយ សេចក្ដីសន្មតថា " សត្វ " ទើបមាន ដូច្នេះ ។

ព្រះសូត្រមួយទៀត ព្រះសារីបុត្តពោលទុកថា :

អាវុសោ អាកាសអាស្រ័យគ្រឿងឈើផង អាស្រ័យវល្លិផង អាស្រ័យ ដីឥដ្ឋផង អាស្រ័យស្មៅផង ព័ទ្ធជុំវិញ រមែងបានឈ្មោះថា " ផ្ទះ " ប៉ុណ្ណោះ ឯង យ៉ាងណាក្ដី អាវុសោ អាកាសអាស្រ័យឆ្អឹងផង អាស្រ័យសរសៃផង អាស្រ័យសាច់ផង អាស្រ័យស្បែកផង ព័ទ្ធជុំវិញ រមែងបានឈ្មោះថា " រូប " ប៉ុណ្ណោះឯង ដូច្នោះដូចគ្នា ។

ព្រះនាងវជិរាភិក្ខុនីបានពោលទុកទៀតថា :

សេចក្ដីពិត មានតែទុក្ខទេកើតឡើង មានតែទុក្ខទេតាំងនៅ មានតែទុក្ខ ទេរលត់ទៅ ក្រៅពីទុក្ខមិនមានវត្ថុដទៃកើត ក្រៅពីទុក្ខមិនមានវត្ថុដទៃរលត់ ទៅឡើយ ។

នាមរូបនោះឯង ដែលព្រះសូត្ររាប់រយសូត្រសម្ដែង ទុកដោយន័យដូច ពោលមកនេះ មិនមែនជាសត្វ មិនមែនជាបុគ្គល ព្រោះហេតុនោះ កាលអង្គ សម្ភារៈ មានភ្លៅ កង់ ទ្រុង និងចន្ទោលជាដើម ដែលតាំងនៅរៀបរយដោយ អាការមួយ វោហារថា " **រថ** " ក៏មានឡើងប៉ុណ្ណោះឯង តែបើពិនិត្យមើលអង្គ មួយចំណែកៗ ដោយបរមត្ថ ឈ្មោះថា **រថ** មិនមានយ៉ាងណា , ម្យ៉ាងទៀត ពេលដែលគ្រឿងផ្ទះ មានឈើជាដើម ព័ទ្ធជុំវិញអាកាស តាំងនៅដោយអាការ

មួយហើយ វោហារថា " ផ្ទះ " ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **ផ្ទះ** មិនមាន យ៉ាងណា , មយ៉ាងទៀត ពេលម្រាមដៃទាំងឡាយមាន មេដៃទាំងឡាយមានជាដើម តាំងនៅដោយអាការមួយហើយ វោហារថា " កណ្តាប់ដៃ " ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **កណ្តាប់ដៃ** មិនមាន , ពេលដែលចំណែកនៃពិណ មានរាងជាដើម តាំងនៅដោយអាការមួយហើយ វោហារ ថា " **ពិណ** "ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **ពិណ** មិនមាន , ពេលដែលអង្គនៃកងទ័ព មានពលដំរី ពលសេះជាដើម តាំងនៅដោយអាការមួយហើយ វោហារថា " កងទ័ព " ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **កងទ័ព** មិនមាន , ពេលអង្គនៃក្រុង មានកំពែងនិងទ្វារជាដើម តាំងនៅដោយអាការមួយហើយ វោហារថា " ក្រុង " ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **ក្រុង** មិនមាន , ពេលអវយវៈ មានដើម មែក ស្លឹក ជាដើម តាំងនៅដោយអាការមួយហើយ វោហារថា " ដើមឈើ " ក៏មានឡើងប៉ុណ្ណោះឯង ដោយបរមត្ថ ឈ្មោះថា **ដើមឈើ** មិនមាន យ៉ាងណា កាលឧបាទានក្ខន្ធ ៥ មានហើយ វោហារថា " សត្វ " ថា " បុគ្គល " ក៏មានឡើងប៉ុណ្ណោះឯង កាលបើពិនិត្យមើលធម៌មួយចំណែក១ ហើយ ដោយបរមត្ថ ឈ្មោះថា **សត្វ** ដែលជាវត្ថុនៃសេចក្តីប្រកាន់ថា " **ជាយើង** " ឬថា " **ជារបស់យើង** " មិនមាន ដោយបរមត្ថពិតនោះ មានតែនាមរូបប៉ុណ្ណោះ ។

ទស្សនៈនៃព្រះយោគាវចរដែលឃើញយ៉ាងនេះ ឈ្មោះថា **យថាភូតទស្សនៈ** ( ការឃើញតាមសេចក្តីពិត ) ។

ចំណែកបុគ្គលណា លះបង់នូវយថាភូតទស្សនៈចេញ ប្រកាន់ថា " សត្វ

មាន " បុគ្គលនោះឯង គប្បីឈ្មោះថា ចម្រើនដោយយល់ថា ដាច់សូន្យ ឬ ការមិនដាច់សូន្យ បានដល់ ខ្លួនឯង ពេលដែលប្រកាន់ថា មិនដាច់សូន្យ រមែងធ្លាក់ទៅក្នុង **សស្សតៈ** ពេលដែលប្រកាន់ថា ដាច់សូន្យ រមែងធ្លាក់ទៅក្នុង **ឧច្ឆេទៈ** ព្រោះហេតុអ្វី ព្រោះមិនមានវត្ថុដទៃដែលជាវត្ថុជាប់តាមទៅ ដូចទឹកដោះជូរជាប់តាមទឹកដោះស្រស់ បុគ្គលនោះពេលប្រកាន់ថា " សត្វទៀង " ឈ្មោះថា ធ្លាក់ចុះ , ពេលដែលប្រកាន់ថា " សត្វដាច់សូន្យ " រមែងស្ទុះទៅ ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សទាំងឡាយដែលត្រូវទិដ្ឋិគតៈ ២ យ៉ាង រួបរឹត គ្របសង្កត់ហើយ ពួកមួយក៏ធ្លាក់ចុះ ពួកមួយទៀតក៏ស្ទុះទៅ , ចំណែកអ្នកមានចក្ខុ ( គឺ បញ្ញា ) ទាំងឡាយរមែងឃើញ ( តាមសេចក្ដីពិត ) ។

ម្នាលភិក្ខុទាំងឡាយ ទេវតា និង មនុស្សពួកមួយធ្លាក់ចុះ តើដូចម្ដេច ? ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សពួកមួយ មានភពជាទីរីករាយ ពេញចិត្តក្នុងភព សប្បាយចិត្តក្នុងភព កាលធម៌ដើម្បីសេចក្ដីរលត់នៃភព ដែលតថាគតសម្ដែងហើយ ចិត្តរបស់ទេវតា និងមនុស្សពួកនោះ មិនស្ទុះទៅតាមក្រសែធម៌ មិនជ្រះថ្លា មិនចុះស៊ប់ មិនបង្អោនចិត្តជឿ យ៉ាងនេះឯង ភិក្ខុទាំងឡាយ ដែលថា ទេវតា និង មនុស្សទាំងឡាយពួកមួយធ្លាក់ចុះ ។

ម្នាលភិក្ខុទាំងឡាយ ទេវតា និងមនុស្សពួកមួយ ស្ទុះទៅ តើដូចម្ដេច ? ទេវតា និងមនុស្សពួកមួយនោះ ធុញទ្រាន់ មិនត្រេកអរ រង្កៀសក្នុងភពរីករាយក្នុងវិភព ជាហេតុឱ្យពោលថា " អ្នកទាំងឡាយ អត្តានេះ កាលខាងមុខសេចក្ដីស្លាប់ ព្រោះកាយបែកធ្លាយទៅ រមែងដាច់ រមែងសូន្យ រមែងមិនមាន

ទៀត បន្ទាប់ពីស្លាប់ទៅ ភាពដាច់សូន្យនោះឯង ជាធម្មជាតិល្អិត ភាពដាច់សូន្យនោះឯង ជាធម្មជាតិប្រណីត ភាពដាច់សូន្យនោះឯង ជាធម្មជាតិពិត យ៉ាងនេះឯង ភិក្ខុទាំងឡាយ ដែលថា ទេវតា និងមនុស្សទាំងឡាយស្ទុះទៅ ។

ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកមានចក្ខុរមែងឃើញ យ៉ាងណា ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ រមែងឃើញ ភូត ( គឺ បញ្ចក្ខន្ធ ឬ នាមរូប ) ដោយភាពជា ភូត ( គឺ មិនឃើញជាសត្វបុគ្គល ) កាលឃើញភូតដោយភាពជាភូតហើយ រមែងជាអ្នកបដិបត្តិដើម្បីសេចក្តីនឿយណាយ ដើម្បីលះបង់នូវតម្រេក ដើម្បីរំលត់ភូត យ៉ាងនេះឯង ភិក្ខុទាំងឡាយ ដែលថា អ្នកមានចក្ខុរមែងឃើញ ។

ព្រោះហេតុនោះ ឈើយន្តជារបស់សូន្យ ( ចាកតួខ្លួន ) មិនមានជីវៈ មិនមានការត្រិះរិះ តែថា វាដើរក៏បាន ឈប់ក៏បាន ប្រាកដដូចរបស់មានការត្រិះរិះ មានការព្យាយាម ដោយអំណាចការប្រកបគ្នានៃឈើ ជាមួយខ្សែ យ៉ាងណា សូម្បីនាមនិងរូបនេះ បណ្ឌិតគប្បីឃើញថា ជាវត្ថុសូន្យ មិនមានជីវៈ មិនមានការត្រិះរិះ តែថា វាដើរក៏បាន ឈប់ក៏បាន ប្រាកដដូចវត្ថុមានការត្រិះរិះ មានការព្យាយាម ដោយអំណាចការប្រកបគ្នានិងគ្នាក៏ដូច្នោះ ព្រោះហេតុនោះ ព្រះបុរាណាចារ្យទាំងឡាយ ទើបពោលទុកថា :

មានតែ នាម និងរូបប៉ុណ្ណោះ មាននៅក្នុងលោកនេះ ដោយសច្ចៈ ក្នុងនាម និងរូបនោះ មិនមានសត្វបុគ្គលឡើយ នាម និងរូបនោះជារបស់សូន្យទទេ ដែលបច្ច័យតាក់តែងឡើង ដូចរូបយន្ត នោះជាកងទុក្ខ ដូចជាស្មៅ និងកំណាត់ឈើ ។

ម្យ៉ាងទៀត នាមរូបនោះ គួរអធិប្បាយ ឱ្យប្រាកដច្បាស់ដោយឧបមា ត្រឹមឈើយន្តប៉ុណ្ណោះក៏ទេ បណ្ឌិតគួរធ្វើឱ្យប្រាកដច្បាស់ដោយឧបមាដទៃ មាន កំណាត់ឈើជាដើម ពិតហើយ ពេលកំណាត់ឈើ ២ កំណាត់ តាំងឡើង ទល់គ្នា វាទប់គ្នាទុក ពេលកំណាត់ឈើ១រលំ កំណាត់ឈើ ១ ទៀត ក៏រលំដែរ យ៉ាងណា នាមរូបក្នុងបញ្ចវោការភព ក៏អាស្រ័យគ្នានិងគ្នា ប្រព្រឹត្តទៅគាំទ្រ គ្នាទុក ពេលមួយណា រលំដោយអំណាចមរណៈ មួយទៀតក៏រលំដែរ ដូច្នោះ ដូចគ្នា ព្រោះហេតុនោះ បុរាណាចារ្យទាំងឡាយ ទើបពោលថា :

នាមនិងរូបជាគូគ្នា ទាំងគូអាស្រ័យគ្នានិងគ្នា ពេលមួយណា បែកធ្លាយ ហើយ ក៏បែកធ្លាយទាំងគូ តាមបច្ច័យ ។

ម្យ៉ាងទៀត ពេលសំឡេងកើតឡើងដោយការវាយស្គរ មានហើយ ស្គរ ផ្សេង សំឡេងផ្សេង សំឡេងនិងស្គរ មិនបានលាយគ្នា ស្គរសូន្យចាកសំឡេង សំឡេងសូន្យចាកស្គរ យ៉ាងណា ពេលនាមអាស្រ័យរូប ពោលគឺ វត្ថុ ទ្វារ និង អារម្មណ៍ នាមទទេចាករូប រូបក៏ទទេចាកនាមក៏ដូច្នោះដូចគ្នា ប៉ុន្តែថា នាម អាស្រ័យរូបទើបប្រព្រឹត្តទៅបាន ដូចសំឡេងអាស្រ័យស្គរ ប្រព្រឹត្តទៅដូច្នោះ ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលទុកថា :

ធម៌ទាំងឡាយ មានផស្សជាទី ៥ មិនបានកើតពីភ្នែក មិនបានកើតពីរូប និងមិនបានកើតក្នុងរវាងភ្នែកនិងរូបទាំង ២ វាជាសង្ខតៈ អាស្រ័យហេតុកើត ឡើង ដូចជាការវាយស្គរ សំឡេងក៏កើតឡើងដូច្នោះ ។

ធម៌ទាំងឡាយ មានផស្សជាទី ៥ មិនបានកើតពីត្រចៀក មិនបានកើត ពីសំឡេង មិនបានកើតក្នុងរវាងត្រចៀក និងសំឡេងទាំង ២ ។ ល ។

ធម៌ទាំងឡាយ មានផស្សជាទី ៥ មិនបានកើតពីច្រមុះ មិនបានកើតពីក្លិន និងមិនបានកើតក្នុងរវាងច្រមុះ និងក្លិនទាំង ២ ។ ល ។

ធម៌ទាំងឡាយ មានផស្សជាទី ៥ មិនបានកើតពីអណ្ដាត មិនបានកើតពីរស និងមិនបានកើតក្នុងរវាង អណ្ដាត និងរស ទាំង ២ ។ ល ។

ធម៌ទាំងឡាយ មានផស្សជាទី ៥ មិនបានកើតពីកាយ មិនបានកើតពីផោដ្ឋព្វៈ និងមិនបានកើតក្នុងរវាងកាយ និងផោដ្ឋព្វៈ ទាំង ២ ។ ល ។

សង្ខតធម៌ទាំងឡាយ មិនបានកើតពីវត្ថុរូប និង ទាំងមិនបានកើតពីធម្មាយតនៈទាំងឡាយ វាជាសង្ខត អាស្រ័យហេតុកើតឡើង ប្រៀបដូចជាពេលដែលវាយស្គរ សំឡេងក៏កើតឡើងដូច្នោះ ។

ម្យ៉ាងទៀត ក្នុងនាម និងរូបនេះ នាមមិនមានតេជះ មិនអាចប្រព្រឹត្តទៅដោយអំណាចរបស់ខ្លួនបាន ទំពាមិនបាន ផឹកមិនបាន និយាយមិនបាន សម្រេចឥរិយាបថមិនបាន សូម្បីរូបក៏មិនមានតេជះ មិនអាចប្រព្រឹត្តទៅដោយអំណាចរបស់ខ្លួនបាន ទាំងសេចក្ដីប្រាថ្នានឹងទំពារបស់វាក៏មិនមាន សេចក្ដីប្រាថ្នានឹងផឹកក៏មិនមាន សេចក្ដីប្រាថ្នានឹងនិយាយក៏មិនមាន សេចក្ដីប្រាថ្នាថានឹងសម្រេចឥរិយាបថ ក៏មិនមាន សេចក្ដីពិតនោះ រូបអាស្រ័យនាមប្រព្រឹត្តទៅ នាមក៏អាស្រ័យរូបប្រព្រឹត្តទៅ តែពេលសេចក្ដីប្រាថ្នានឹងទំពា ពេលសេចក្ដីប្រាថ្នានឹងផឹក ពេលសេចក្ដីប្រាថ្នានឹងនិយាយ ពេលសេចក្ដីប្រាថ្នានឹងសម្រេចឥរិយាបថ របស់នាមមានហើយ រូបក៏ទំពា ក៏ផឹង ក៏និយាយ ក៏សម្រេចឥរិយាបថ ។

ម្យ៉ាងទៀត អាចារ្យទាំងឡាយនាំឧបមាមកអាងថា ដើម្បីញុំាងសេចក្ដី

នេះឱ្យប្រាកដច្បាស់ឡើង ប្រៀបដូចបុគ្គល ២ នាក់ , ម្នាក់ខ្វាក់ពីកំណើត ម្នាក់ទៀតខ្វិន មានបំណងដើម្បីធ្វើដំណើរទៅកាន់ទីដទៃ បុគ្គលខ្វាក់ក៏និយាយទៅកាន់អ្នកខ្វិនថា " នែសំឡាញ់ ខ្ញុំអាចប្រើជើង តែមិនអាចមើលទីរាបស្មើមិនស្មើ " ឯបុគ្គលខ្វិន ក៏និយាយនឹងអ្នកខ្វាក់ថា " នែសំឡាញ់ ខ្ញុំអាចមើលបាន តែប្រើជើងឈានទៅមុខ ឬ ថយក្រោយមិនបាន " បុគ្គលភ្នែកខ្វាក់នោះសប្បាយចិត្ត ក៏លើកនាយខ្វិនឱ្យជិះលើស្មា នាយខ្វិនអង្គុយលើស្មានាយខ្វាក់ប្រាប់ដូច្នេះថា " ងាកស្តាំ ងាកឆ្វេង ងាកឆ្វេង ងាកស្តាំ " ( ពួកគេក៏អាចធ្វើដំណើរទៅបាន ) ក្នុងអ្នកទាំង ២ នោះ នាយខ្វាក់ក៏មិនមានតេជះ នាយខ្វិនក៏មិនមានតេជះ មានភាពទុព្វល ទៅដោយអំណាចរបស់ខ្លួនមិនបាន ទៅដោយកំលាំងរបស់ខ្លួនក៏មិនបាន តែការអាស្រ័យគ្នានិងគ្នានៃគេទាំងពីរនោះនឹងប្រព្រឹត្តទៅមិនបានក៏ទេ យ៉ាងណា សូម្បីនាមក៏មិនមានតេជះ កើតឡើងដោយអំណាចតេជះរបស់ខ្លួនមិនបាន ប្រព្រឹត្តទៅក្នុងកិរិយានោះៗ ក៏មិនបាន , រូបទាំងឡាយ ក៏មិនមានតេជះ កើតឡើងដោយអំណាចរបស់ខ្លួនមិនបាន ប្រព្រឹត្តទៅក្នុងកិរិយានោះៗ ក៏មិនបាន តែការអាស្រ័យគ្នានិងគ្នាកើតឡើង ឬប្រព្រឹត្តទៅនៃនាម និងរូបនោះ មិនមានក៏ទេ ព្រោះហេតុនោះ ព្រះអាចារ្យទាំងឡាយ ទើបពោលពាក្យប្រព័ន្ធនេះទុកថា :

ធម៌ទាំងឡាយជាសង្ខតៈ មិនរឹងមាំដោយកំលាំងរបស់ខ្លួន កើតដោយកំលាំងរបស់ខ្លួនមិនបាន តាំងនៅដោយកំលាំងរបស់ខ្លួនមិនបាន វាមានប្រក្រតីប្រព្រឹត្តទៅតាមអំណាចនៃធម៌ដទៃ កើតឡើង , ធម៌ទាំងឡាយនោះកើតឡើងព្រោះមានធម៌ដទៃជាបច្ច័យ តាំងឡើងព្រម ព្រោះមានធម៌ដទៃជាអារម្មណ៍

ហើយអារម្មណ៍ និងបច្ច័យទាំងឡាយ ក៏មានធម៌ដទៃឱ្យកើតឡើង ។

បុគ្គលទាំងឡាយអាស្រ័យទូក ទើបធ្វើដំណើរតាមទន្លេបាន យ៉ាងណាក្តី នាមកាយអាស្រ័យរូប ទើបប្រព្រឹត្តទៅបាន ក៏ដូច្នោះ , មនុស្សទាំងឡាយនិងទូកអាស្រ័យគ្នា ទើបទៅក្នុងទន្លេបាន យ៉ាងណា នាម និងរូប ទាំង ២ ក៏ជាធម៌អាស្រ័យគ្នានិងគ្នា ដូច្នោះដែរ ។

ការឃើញនាមរូបតាមសេចក្តីពិត រមែងគ្របសង្កត់នូវសត្តសញ្ញា តាំងនៅក្នុងអសម្មោហភូមិ នៃព្រះយោគាវចរ ដែលកំណត់នាមរូបដោយន័យផ្សេងៗ ដូចពណ៌នាមកដូច្នេះ បណ្ឌិតគប្បីជ្រាបថា **ទិដ្ឋិវិសុទ្ធិ** ។

ពាក្យថា **នាមរូបវវត្ថាន** - ការកំណត់នាមរូបក្តី , **សង្ខារបរិច្ឆេទ** - ការកំណត់សង្ខារក្តី ជាពាក្យហៅ **នាមរូបយថាវទស្សន** - ការឃើញនាមរូបតាមសេចក្តីពិតនោះឯង ។

## មហាដីកា

" ការប្រៀបធៀបដោយព្រះសូត្រច្រើនសូត្រ "

បទថា **សោ** មានន័យថា **សោ យោគ វិបស្សនាកម្មិកោ យោគាវចរោ** ប្រែថា ព្រះយោគាវចរ អ្នកប្រកបកម្ម គឺ វិបស្សនានោះ ។ ពាក្យថា **យ៉ាងនេះ** ជាពាក្យរំលឹកដល់ប្រការដែលបានពោលហើយ ។ បទថា **យថាវសរសតោ** ប្រែថា តាមសេចក្តីពិត ។ ភ្ជាប់សេចក្តីបាលីថា **នាមរូបំ វវត្ថបេត្វា ឯតមត្ថំ សំសន្ទេត្វា វវត្ថបេតិ** ប្រែថា កាលកំណត់នាមរូប រមែងកំណត់ដោយសេចក្តីប្រៀបធៀបសេចក្តីនេះ ។ ដើម្បីប្រយោជន៍លះបង់នូវលោកសមញ្ញា អធិប្បាយ

ថា នឹងចាំបាច់ពោលថ្វីដល់ការប្រកាន់ខុសយ៉ាងមាំ ដែលប្រព្រឹត្តទៅថា " សត្វ , ជីវៈ " នោះ ។

សេចក្ដីវង្វេងដែលប្រព្រឹត្តទៅថា " សត្វ " ដោយអំណាចសេចក្ដីប្រកាន់ថា ជាវត្ថុមួយ ដោយការប្រជុំរួមគ្នា វៀរចាកសេចក្ដីប្រកាន់នោះ ព្រោះការដែលមិនបានវិនិច្ឆ័យដោយត្រឹមតែ នាម និង រូប និងព្រោះមិនបានធ្វើការចែកនូវភាពជាដុំ មានការបន្តគ្នាជាដើម ឈ្មោះថា វង្វេង ថាជាសត្វ ។ ការគ្របសង្កត់ទុកនូវសេចក្ដីវង្វេងថាជាសត្វនោះ ឈ្មោះថា **អសម្មោហភូមិ** ។ ពាក្យថា **ដោយអំណាច ព្រះសូត្រច្រើនសូត្រ** មានន័យថា ដោយអំណាចនៃព្រះសូត្រច្រើនសូត្រដែលពោលទុកក្នុងទីនេះថា ដោយពាក្យ មានជាអាទិ៍ថា **យថាបិ** និងដែលមិនបានពោលទុកដោយពាក្យមានជាអាទិ៍យ៉ាងនេះថា " ម្នាលមហាលិ ប្រសិនបើរូបនេះ នឹងជាអត្តាពិត រូបនេះក៏មិនប្រព្រឹត្តទៅដើម្បីអាពាធ " ។

លោកអាចារ្យពោលថា សេចក្ដីនេះ សំដៅយកពាក្យដែលលោកពោលទុកជាដើមថា **ត្រឹមតែនាមរូបប៉ុណ្ណោះ** ។

ព្រោះមានអង្គសម្ភារៈ គឺ ព្រោះមានអង្គសម្ភារៈជាហេតុ ។ ព្រោះអង្គសម្ភារៈនោះជានិមិត្ត មិនលះអង្គសម្ភារៈនោះ គឺ ពេលមានអង្គសម្ភារៈនោះទើបមានវោហារថា " សត្វ " ។

ពាក្យថា **បានឈ្មោះថា ផ្ទះ** មានពាក្យប្រកបថា អាកាសអាស្រ័យវត្ថុមានឈើជាដើម លះឈ្មោះនៃឈើជាដើម ទាំងឡាយនោះ ក៏បានឈ្មោះ គឺ ហៅថា ផ្ទះ យ៉ាងណា អាកាសអាស្រ័យចំណែកនៃរាងកាយ មានឆ្អឹងជាដើម

លះឈ្មោះរបស់ឆ្អឹង ជាដើមទាំងឡាយនោះ បានឈ្មោះថា រូប ( សត្វ ) សរីរៈ នោះឯង ជាដើម ។

ពាក្យថា **មានតែទុក្ខដែលកើត** មានន័យថា ទុក្ខ ៣ យ៉ាង ផ្សេង ៗ មានទុក្ខទុក្ខជាដើមនេះឯងកើត គឺ កើតឡើងតាមបច្ច័យ ទុក្ខនោះឯងតាំងនៅជាខណៈៗ និងតាំងនៅបន្តគ្នាទៅ និងរលត់ទៅដោយខណៈៗ និងរលត់ទៅដោយការអស់អាយុជាដើម ។

ឥឡូវនេះ លោកអាចារ្យបំណងសម្តែងនូវខ្លឹមសារ ដែលលោកហាមទុកដោយ **ឯវ** អក្សរ ថា **ទុក្ខមេវ** ទើបពោលពាក្យជាដើមថា **នាញ្ញត្រ** សេចក្តីនៃពាក្យនោះថា វៀរទុក្ខតាមដែលពោលហើយ ធម្មជាតិអ្វីៗដទៃ ក្រៅពីទុក្ខនោះ មិនមានអ្វីកើត សភាវៈណាដែលគប្បីពោលថា " សត្វ " ក្តី " ជីវៈ " ក្តី ការរលត់នៃសភាវៈនោះនឹងមានមកពីណា ព្រោះមិនមានដោយប្រការទាំងពួង ( អធិប្បាយថា មិនមានដោយបរមត្ថ ) ។

ពាក្យថា **តាំងនៅដោយល្អ ដោយអាការមួយ** មានន័យថា ពេលដែលអង្គសម្ភារៈ មានភ្លៅជាដើម តាំងនៅដោយល្អ ដោយអាការណា ឈ្មោះថា រថទើបមាន ពេលអង្គសម្ភារៈតាំងចុះរៀបរយ គឺ ធ្វើឱ្យជាអង្គប្រកបរួមគ្នាដោយអាការមួយនោះ ។ ពាក្យថា **ដូច្នោះដូចគ្នា** មានន័យថា ពេលធម៌មួយចំណែកៗ និងធម៌ជាចំណែករួម ដែលផ្សេងគ្នា ប្រជុំគ្នា ប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា វោហារថា " រថ ផ្ទះ កណ្តាប់ដៃ ពិណ កងទ័ព ក្រុង ដើមឈើ " ក៏មានប៉ុណ្ណោះឯង តែថា ដោយបរមត្ថ រមែងមិនមានអ្វីៗដែលឈ្មោះថា **រថ** ជាដើមឡើយ សេចក្តីនេះ យ៉ាងណា ឧបមេយ្យ ក៏ដូច្នោះដូចគ្នា ។

ពាក្យថា **ពេលឧបាទានក្ខន្ធ** មានន័យថា ការដឹងតាមសេចក្ដីពិតថា ពេលរូបធម៌ និងអរូបធម៌ ដែលគេដឹងថា ឧបាទានក្ខន្ធប្រជុំគ្នា គឺ ប្រព្រឹត្តទៅដោយអំណាចការបន្តគ្នា វោហារថា " សត្វ ជីវៈ " ក៏មានឡើងប៉ុណ្ណោះឯង តែថា ដោយបរមត្ថ មិនមានសត្វ ឬ ជីវៈឡើយ ។ ការឃើញតាមសេចក្ដីពិតនេះ លោកហៅថា **ទិដ្ឋិវិសុទ្ធិ** ។

បទថា **តស្ស យោគ សត្តោតិ គហិតស្ស អត្តនោ** ដល់បុគ្គលដែលប្រកាន់ថា សត្វមាន ។ ពាក្យថា **ការដាច់សូន្យ** បានដល់ ភាពដាច់សូន្យនៃអត្តាដែលរលត់ទៅ ។ ពាក្យថា **ការមិនដាច់សូន្យ** គឺ ការមិនវិនាសទៅ អធិប្បាយថា ជាវត្តទៀង ។ ក៏បុគ្គលដែលជាអត្តវាទីទាំងឡាយ តាំងនៅហើយ ដោយអំណាចនៃការឃើញទាំងឡាយ ២ យ៉ាង នោះឯង គឺ ឃើញថា អត្តាទៀងខ្លះ ឃើញថា អត្តាដាច់សូន្យខ្លះ សូម្បីវាទៈថា ទៀងចំណែកខ្លះ ក៏រួមនៅក្នុងទីនេះដូចគ្នា ។

ពាក្យថា **ប្រកបដោយការដាច់សូន្យ** បុគ្គលនោះពេលប្រាថ្នា ការដាច់សូន្យនៃធម៌ទាំងឡាយ មានពុទ្ធិជាដើម ក៏ប្រកបដោយភាពមិនមាន ការដាច់សូន្យនៃអត្តាថា **សភាវៈមានធម៌ទៀង តាំងនៅដូចជាកំពូលភ្នំ** ។ ពាក្យថា **ក្នុងសស្សតៈ** គឺ ក្នុងសេចក្ដីប្រកាន់ថាទៀង , អធិប្បាយថា នឹងធ្លាក់ទៅ ព្រោះការទាក់ទងនឹងទោស មានការដាច់សូន្យនៃសង្ខតធម៌ និងការប្រាកដចំពោះមុខនៃអសង្ខតធម៌ ។

បទថា **ឱរន្ទយស្ស** ប្រែថា ជាប់តាមទឹកដោះគោស្រស់ អធិប្បាយថា ដែលជាផល ។ ពាក្យថា **នឹងជាវត្ត ជាប់តាមទៅ** គឺ ព្រោះមិនមានអ្វីៗ ដទៃ

ដែលជាវត្ថុជាប់តាមអត្តានោះ ។

ពាក្យថា **ធ្លាក់ចុះ** មានន័យថា បុគ្គលដែលជាអ្នក ត្រេកអរក្នុងភព ដោយសេចក្តីប្រកាន់ថា " អត្តាទៀង " នឹងងាកចេញពីការរំលត់ភព ឈ្មោះថា ធ្លាក់ចុះក្នុងភពនោះឯង ។ ពាក្យថា ឈ្មោះថា **ស្ទុះទៅ** អាចារ្យទាំងឡាយ រមែងពោលថា អ្នកមានលទ្ធិថា **ដាច់សូន្យ** គឺ អត្តាក្នុងភពនោះៗ ឯង រមែង ដាច់សូន្យប្រកាន់ថា **អត្តារមែងដាច់** សូន្យ បន្ទាប់ពីភពដែលមាននេះ ក្រោយពី ស្លាប់ទៅថា **មិនមាន** ដូច្នេះ ឈ្មោះថា ស្ទុះទៅ ។

កាលនឹងប្រាថ្នាការរំលត់ភពព្រោះកម្មមិនឱ្យផល ក្នុងការរំលត់កិលេស បុគ្គលមិនបានកាន់យកយ៉ាងនោះ តែកាន់យកថា ការរំលត់ភព រមែងមានយ៉ាង នេះ គឺ **អត្តាអាស្រ័យភពពិសេសនោះ ៗ រមែងដាច់សូន្យ** ដូច្នេះឈ្មោះថា រមែងស្ទុះទៅកាន់ភពនោះ ។ ពាក្យថា **រួបរឹត** គឺ គ្របសង្កត់ហើយ ។ ពាក្យថា **អ្នកមានចក្ខុ** គឺ អ្នកមានចក្ខុ ដោយញាណចក្ខុ ពោលគឺ ការឃើញតាមសេចក្តី ពិត ។

ភពផ្សេងៗ មានកាមភពជាដើម ជាទីរីករាយ ដោយសំគាល់ថា គួរ រីករាយដល់ទេវតា និងមនុស្សទាំងឡាយ ព្រោះហេតុនោះ ទេវតា និងមនុស្ស ទាំងឡាយនេះ ឈ្មោះថា **ភវារាមា** មានភពជាទីរីករាយ ។ ទេវតា និង មនុស្សទាំងឡាយណា រីករាយហើយ គឺ ត្រេកត្រអាលហើយក្នុងភព ព្រោះ ហេតុនោះ ទេវតា និងមនុស្សទាំងឡាយនោះ ឈ្មោះថា **ភវសម្មុទិតា** ដល់នូវ សេចក្តីត្រេកត្រអាលក្នុងភព ។

ពាក្យថា **ចិត្តមិនស្ទុះទៅ** មានន័យថា ចិត្តមិនស្ទុះទៅតាមក្នុងធម៌ដែល

នាំមកនូវសេចក្ដីរំលត់ភព ព្រោះទេវតា និងមនុស្សនោះ ជាអ្នកជាប់ជំពាក់ដោយសេចក្ដីរីករាយក្នុងភព ។ ពាក្យថា **មិនជ្រះថ្លា** គឺ មិនដាក់ចិត្តជឿ ។ ពាក្យថា **មិនចុះចិត្តស៊ប់** គឺ មិនតាំងមាំ ។ ពាក្យថា **មិនបង្អោនចិត្ត** គឺ មិនបង្អោនចិត្តជឿ ។

ពាក្យថា **រអា** គឺ ធ្វើឱ្យជាទុក្ខ ។ ពាក្យថា **ចង់ក្អួត** គឺ ខ្ពើម ។ ពាក្យថា **រង្កៀស** គឺ មើលងាយ ។ ពាក្យថា **វិភព** គឺ ភាពខាច់សូន្យ ។ ប្រការថា **យតោ កិរ ភោ** ជាដើម ជាពាក្យសំដែងដល់អាការរីករាយ ដូចបានពោលហើយថា សេចក្ដីត្រេកត្រអាល ។

ពាក្យថា **ភូត** បានដល់ ខន្ធ ៥ ។ ខន្ធ ៥ នោះ ហៅថា **ភូត** ព្រោះជាវត្ថុដែលកើតដោយបច្ច័យទាំងឡាយតាមគួរដល់ខ្លួន និងព្រោះជាវត្ថុមានដោយបរមត្ថ ។ ពាក្យថា **ដោយភាពជាភូត** បានដល់ ដោយសភាពតាមពិត ដោយលក្ខណៈរបស់ខ្លួន ( វិសេសលក្ខណៈ ) និងដោយសាមញ្ញលក្ខណៈ ។

លោកអាចារ្យ កាលសម្ដែងទោសនៃការធ្លាក់ចុះ និង ការស្ទុះទៅដោយការប្រកាន់ថា ជាសត្វ និងគុណ មាននិព្វិទាជាដើម ព្រោះឃើញតាមសេចក្ដីពិត ដោយអំណាចព្រះសូត្រនោះឯង យ៉ាងនេះហើយ ឥឡូវនេះបំណងនឹងសម្ដែងការសម្រេចកិច្ចនៃអត្ថា មានការដើរបានជាដើម សូម្បីក្នុងវត្ថុដែលត្រឹមតែជានាមរូប ប៉ុណ្ណោះ ទើបពោលពាក្យថា **ព្រោះហេតុនោះ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ពាក្យថា **ព្រោះហេតុនោះ** មានន័យថា ឈ្មោះថា សត្វដែលជាវត្ថុនៃសេចក្ដីប្រកាន់ថា " ជាយើង " ឬថា " ជារបស់យើង " មិនមាន ពោលដោយបរមត្ថ នឹងមានត្រឹមតែនាម និងរូបប៉ុណ្ណោះ ព្រោះហេតុ

ណា ព្រោះហេតុនោះ ។

លោកអាចារ្យពោលពាក្យថា " ឈើយន្ត " ជាដើម សំដៅដល់ការបំណងថា សូម្បីតែអត្តា ក៏មិនមានផង នៅក្នុងសភាវៈត្រឹមតែនាមរូបក្នុងទីនេះ នឹងមានការសម្រេចកិច្ចនៃអត្តា មានការដើរជាដើម បានដូចម្ដេចទៅ ។

ដោយពាក្យថា **ប្រាកដ** នេះ លោកអាចារ្យសំដែងថា ក្នុងគ្រឿងយន្តដែលធ្វើដោយឈើ មិនមានជីវៈ ក៏នៅមានការប្រាកដបាន ហាក់ដូចជារបស់ដែលមានការត្រិះរិះ មានសេចក្ដីព្យាយាម ដោយអំណាចជីវៈ ដែលមាននៅខាងក្នុង ព្រោះភាពផ្សេងគ្នានៃបច្ច័យ យ៉ាងណា ក្នុងសភាវៈដែលត្រឹមតែជានាមរូប ដែលមិនមានជីវៈ ក៏មានការសម្រេចនាទីរបស់អត្តា មានការដើរជាដើម ព្រោះភាពផ្សេងគ្នានៃបច្ច័យ ក៏ដូច្នោះ ។

ពាក្យថា **ដោយសច្ចៈ** ប្រែថា ដោយសេចក្ដីពិត អធិប្បាយថា ដោយបរមត្ថ ។ សេចក្ដីបំណងថា នាមរូបត្រូវបច្ច័យតាក់តែងឡើង ដូចជាគ្រឿងយន្តទទេចាកជីវៈ រមែងប្រព្រឹត្តទៅដោយអំណាចបច្ច័យ ។ ឈ្មោះថា **ជាកងទុក្ខ** ព្រោះវារសាប់រសល់ជានិច្ច ។ ឈ្មោះថា **ដូចជាស្មៅ និងកំណាត់ឈើ** ព្រោះវាសូន្យចាកអត្តា ។ បទថា **ឯតំ** បានដល់ នាមរូប ។

បទថា **យមកំ** ប្រែថា ទាំងគូ ។ សេចក្ដីដែលនាមរូប ជារបស់គូគ្នានោះឯង ដោយសភាវៈជាវត្ថុអាស្រ័យគ្នានិងគ្នា ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ទាំងគូ អាស្រ័យគ្នានិងគ្នា** ដូច្នេះ ។ ព្រោះហេតុនោះឯងពេលមួយណាវិនាស ក៏ត្រូវរលត់ទាំងគូ ។ ក្នុងបញ្ចវោការភព ពេលរូបរលត់ អរូបមិនរលត់ ឬ ពេលអរូបរលត់ រូបមិនរលត់ នឹងមានក្នុងកាលណា ៗ មិន

ដែលមាន ។ សេចក្ដីរលត់នេះ ទៅតាមបច្ច័យ គឺ ដោយការរលត់នៃបច្ច័យនោះឯង អធិប្បាយថា ជាការរលត់នៃនាមរូប ។ ន័យម្យ៉ាងទៀត បទថា **បច្ចយា** ប្រែថា បច្ច័យ អធិប្បាយថា ទាំងគូ សូម្បីជាបច្ច័យដល់គ្នានិងគ្នា ក៏គង់រលត់ ។

ពាក្យថា **ដែលមនុស្សវាយដោយឈើ** លោកអាចារ្យសំដែលដល់ឈើ ដោយពាក្យធ្វើឱ្យពិសេសឡើង និងការព្យាយាមរបស់មនុស្សជាបច្ច័យនៃការវាយដោយឈើ ចំណែកស្គរជាវត្ថុដែលគប្បីធ្វើឱ្យពិសេសឡើង ព្រោះជាហេតុដែលមិនទូទៅនៃសំឡេង ព្រោះហេតុនោះ លោកទើបកាន់យក " ស្គរម្យ៉ាង " មិនបានកាន់យកវត្ថុ មានឈើជាដើមនោះទេ ។ លោកអាចារ្យធ្វើការប្រៀបធៀបពាក្យឧបមា ដោយពាក្យថា " ដូច្នោះដូចគ្នា " ជាដើម ធ្វើសំឡេងឱ្យស្ថិតនៅក្នុងឋានៈជានាម ព្រោះសំឡេងជារូប ដែលមើលមិនឃើញ ។

ពាក្យថា **មិនបានកើតពីភ្នែក** មានន័យថា មិនបានកើតចេញចាកចក្ខាយតនៈ ។ ពិតហើយ មុននឹងចូលដល់ភាពជាបច្ច័យនៃចក្ខាយតនៈ នឹងរកធម៌ទាំងឡាយដែលមានផស្សៈជាទី ៥ មិនបាន ព្រមទាំងរកធម៌ទាំងឡាយដែលជាទីអាង ដែលជាហេតុគប្បីចេញចាកចក្ខាយតនៈនោះ ក៏មិនបានឡើយ ។ ដោយហេតុនោះលោកអាចារ្យទើបពោលថា " គំនរខន្ធមិនមានក្នុងអនាគត " ដូច្នេះ ។ សូម្បីក្នុងពាក្យថា " មិនបានកើតពីរូប " ក៏មានន័យដូចគ្នា ។

ចំណែកពាក្យថា " មិនបានកើតក្នុងរវាងភ្នែក និងរូបទាំងពីរ " នេះ លោកពោលទុក ព្រោះជាធម៌មិនមានទីអាង ព្រោះធម៌ទាំងឡាយមានផស្សជាទី ៥ នេះ ជាអរូបធម៌ តែការរួមនៃបច្ច័យមានក្នុងខណៈណា ក៏នឹងមានត្រឹមការកើតឡើងប៉ុណ្ណោះឯងក្នុងខណៈនោះ តែម្យ៉ាង ព្រោះហេតុនោះ លោក

អាចារ្យទើបពោលថា " វាជាសង្ខតៈ អាស្រ័យហេតុកើតឡើង " អធិប្បាយថា ធម៌ទាំងឡាយ មានផស្សៈជាដើម ឈ្មោះថា **សង្ខតៈ** ព្រោះធម៌ទាំងឡាយនោះប្រជុំគ្នា គឺ កើតរួមគ្នាតាក់តែងឡើង អាស្រ័យធម្មជាតិផ្សេង ៗ មានចក្ខុរូប ពន្លឺ និងមនសិការជាដើម គឺ បានហេតុជាបច្ច័យហើយ ទើបកើតឡើង ។

លោកអាចារ្យកាលនឹងសម្ដែងការប្រព្រឹត្តទៅនៃរូបធម៌ ដែលប្រាកដដោយការកើតឡើងនៃធម៌ទាំងឡាយនោះ ទើបពោលថា " ប្រៀបដូចជាស្គរត្រូវគេវាយ សំឡេងក៏កើតឡើង ដូច្នោះ " ក្នុងទីនេះ លោកកាន់យកធម៌មានផស្សៈជាទី ៥ ជាការសម្ដែងអរូបធម៌ដែលប្រាកដ ។ សូម្បីក្នុងកថាដ៏សេសក៏មានន័យដូច្នេះ ។

ពាក្យថា **ពីវត្ថុរូប** គឺ ពីហទយវត្ថុ ។ លោកអាចារ្យ ពោលពាក្យថា " **សង្ខតធម៌ទាំងឡាយ** " ដើម្បីសម្ដែងអរូបធម៌ទាំងឡាយនោះ ដោយសាមញ្ញវោហារ ព្រោះអរូបធម៌ទាំងឡាយ ដែលមានប្រភេទជាច្រើន មានហទយវត្ថុនោះជាទីអាស្រ័យ ។

ពាក្យថា **មិនមានតេជះ** មានន័យថា ប្រាសចាកតេជះ គឺ វៀរចាកអានុភាព ។ លោកអាចារ្យពោលពាក្យថា **ទំពាមិនបាន** ជាដើម ដើម្បីសម្ដែងប្រការដែលនាមនោះមិនមានតេជះ។ ក៏នាមណាៗ អាចពោលថា " មិនមានតេជះ " ក្នុងអាការទាំងឡាយ មានការជឿ និងភាពឧស្សាហ៍ជាដើម ដោយអាការដទៃ ក៏ទេ , ទាំងរូបណាៗ នឹងអាចពោលថា មិនមានតេជះក្នុងការទ្រទ្រង់ និងការកកពូនផ្ដុំជាដើម ក៏ទេ ។

ដោយហេតុនោះឯង លោកអាចារ្យទើបពោលថា **រូបមិនមានតេជះ**

ដូច្នេះហើយ បានពោលពាក្យជាដើមថា **ទាំងសេចក្តីប្រាថ្នានឹងទំពារបស់វាក៏មិនមាន** ។ លោកអាចារ្យញ៉ាំងសេចក្តីដែលនាមនិងរូប ជាធម្មជាតិដែលមិនមានតេជះនេះឯងឱ្យជាក់ច្បាស់ សូម្បីទាក់ទងនឹងសេចក្តីពិសេស ដោយពាក្យថា " ដោយពិត " ដូច្នេះជាដើម ។

សូម្បីការសម្រេចនាទីនៃអត្តា នៃនាម និងរូប ដោយជាទីអាស្រ័យគ្នានិងគ្នា ជាការប្រកាសនូវធម្មជាតិមួយៗ មិនមានអំណាចឱ្យប្រាកដច្បាស់ ។ ពិតហើយ កាលដែលនាម និងរូបសូន្យចាកអត្តា ភាពជាវត្ថុដែលមិនមានការត្រិះរិះ និង ជាវត្ថុដែលមិនមានសេចក្តីខ្វល់ខ្វាយ រមែងជាភាវៈដែលប្រាកដច្បាស់ក្រៃលែងហើយ ។

លោកអាចារ្យពោលពាក្យ មានជាអាទិ៍ថា " ដើម្បីនឹងញ៉ាំងប្រការនេះឱ្យប្រាកដច្បាស់ " ដូច្នេះ សំដៅដល់ពាក្យថា ព្រោះសេចក្តីដែលសភាវធម៌គ្មានអំណាចដោយឯកឯង មកប្រជុំគ្នាហើយ នឹងមានអំណាចបានយ៉ាងណាទៅ ? ព្រោះកាលបើសភាវធម៌មិនមានហេតុ ក្នុងពេលដែលមិនទាន់ព្រមព្រៀងគ្នា កាលមកព្រមព្រៀងគ្នា ក៏ជាសភាវធម៌ដែលមិនមានហេតុដដែល ព្រោះដូចជាបុគ្គលខ្វាក់មិនអាចមើលឃើញ ម្នាក់ ។ សូម្បីមកប្រជុំគ្នារាប់រយនាក់ រាប់ពាន់នាក់ ក៏នៅតែមិនអាចមើលឃើញ ។

ព្រះអដ្ឋកថាចារ្យទាំងឡាយ ឈ្មោះថា រមែងនាំយកពាក្យឧបមានេះមកអាង ព្រោះត្រូវញ៉ាំងខ្លឹមសារដែលមិនទាន់សម្រេចដោយឧបមា ដើម្បីឱ្យសម្រេច ។ ដោយហេតុនោះឯង ព្រះសារីបុត្តទើបពោលថា " ខ្ញុំនឹងធ្វើឧបមាឱ្យលោកស្តាប់ ក្នុងលោកនេះ បុរសអ្នកឆ្លាតពួកខ្លះ រមែងយល់សេចក្តី

នៃភាសិតបាន សូម្បីដោយពាក្យឧបមា ” ។

ពាក្យថា **សប្បាយចិត្ត** មានន័យថា បុគ្គលភ្នែកខ្វាក់ពីកំណើត សប្បាយចិត្តថា យើងមិនអាចនឹងធ្វើកិច្ចដែលគប្បីធ្វើដោយភ្នែកបាន ក៏ពិត សូម្បីដូច្នោះ យើងក៏អាចធ្វើកិច្ចដែលគប្បីធ្វើបានដោយជើង ហើយលោកក៏អាចធ្វើកិច្ចដែលគប្បីធ្វើបានដោយភ្នែក ព្រោះដូច្នោះ ការដល់តំបន់ដែលបំណង ក៏សម្រេចបានដោយអំណាចយើងទាំង ២ នោះឯងរួមគ្នា ។

ក្នុងបណ្តាពាក្យទាំងឡាយនោះ ពាក្យថា **បុគ្គលខ្វាក់ពីកំណើតជាដើម** ជាពាក្យប្រៀបធៀប ពាក្យឧបមា និងឧបមេយ្យ ។ ពាក្យថា **កើតឡើងដោយតេជៈនៃខ្លួនមិនបាន ប្រព្រឹត្តទៅក្នុងកិរិយានោះ ក៏មិនបាន** លោកអាចារ្យពោលទុកដើម្បីសម្តែងថា ពាក្យដែលគួរនឹងពោលថា ការបានខ្លួននៃសភាវធម៌ទាំងឡាយ ទាក់ទងដោយធម៌ដទៃ ដូច្នេះតែម្យ៉ាង មិនមាន ព្រោះមុននោះ ក៏មិនមាន សូម្បីការបានខ្លួនដែលបានហើយ ក៏មានកិច្ច នឹងត្រូវការទាក់ទងនឹងធម៌ដទៃដែរ ។

លោកអាចារ្យ កាលនឹងញ៉ាំងខ្លឹមសារ ដែលឱ្យសម្រេចហើយ ដោយឧបមានៃមនុស្សខ្វាក់ពីកំណើត និងមនុស្សខ្វិនថា តែការអាស្រ័យគ្នានិងគ្នាកើតឡើង ឬប្រព្រឹត្តទៅនៃនាមនិងរូបនោះ មិនមានក៏ទេ ទើបអធិប្បាយហេតុដែលពោលហើយ ជាហេតុដែលមិនមែនប្រព្រឹត្តទៅតែមួយចំណែកថា “ ព្រោះកាលដែលសភាវធម៌មិនមានហេតុ ក្នុងពេលដែលមិនទាន់ព្រមព្រៀងគ្នា មកព្រមព្រៀងគ្នា ក៏នៅជាសភាវធម៌មិនមានហេតុដដែល ” ។ ពាក្យថា **វាមានប្រក្រតីប្រព្រឹត្តទៅដោយអំណាចនៃធម៌ដទៃ** គឺ មានប្រក្រតីប្រព្រឹត្តទៅដោយ

អំណាចនៃធម៌ដទៃ បានដល់ ធម៌ ពោលគឺ ហេតុបច្ច័យក្រៅពីខ្លួន ។ ពាក្យថា **ខ្លួនឯងគ្មានកំលាំង** មានន័យថា ខ្សោយ គឺ មិនអាចដោយខ្លួនឯង ។ ពាក្យថា **ព្រោះមានធម៌ដទៃជាបច្ច័យ** មានន័យថា ព្រោះធម៌ទាំងឡាយដទៃជាបច្ច័យ ។ ដោយពាក្យថា លោកអាចារ្យពោលដល់បច្ច័យដែលធ្វើឱ្យកើត ។ ដោយសព្ទនោះឯង ទើបលោកពោលថា **កើត** ។

ពាក្យថា **ព្រោះមានធម៌ដទៃជាអារម្មណ៍** មានន័យថា ព្រោះធម៌ទាំងឡាយដទៃជាអារម្មណ៍ ។ ពាក្យថា លោកអាចារ្យពោលដល់បច្ច័យដែលជាតួឧបត្ថម្ភ , ន័យម្យ៉ាងទៀត ស័ព្ទថា **បច្ច័យ** សំដៅយករូប អារម្មណ៍សំដៅយកនាម ។ ពាក្យថា **ដែលធម៌ដទៃ** នេះជាវិសេសនៈនៃបច្ច័យ និងអារម្មណ៍ លោកអាចារ្យធ្វើខ្លឹមសារដែលពោលទុក ក្នុងអត្ថមុខឱ្យប្រាកដ ដោយអត្ថក្រោយ ។ បទថា **បភាវិតា** ប្រែថា ធ្វើឱ្យកើតឡើង ។

លោកអាចារ្យពោលគាថាទាំង ៣ ដោយពាក្យថា **សូម្បីយ៉ាងណា** ជាដើម ដើម្បីនឹងអធិប្បាយនូវនាម និងរូបជាធម្មជាតិ មិនប្រព្រឹត្តទៅក្នុងអំណាច សូម្បីដោយឧបមា មានទូកជាទីបំផុត ។ ពាក្យថា **អាស្រ័យ** គឺ ពឹង ។ ពាក្យថា **យន្តិ** គឺ ទៅ ។ ពាក្យថា **អាស្រ័យមនុស្ស** មានន័យថា ពឹងមនុស្សមានអ្នកនាំផ្លូវ និងមនុស្សធ្វើការងារជាដើម ដែលជាអ្នកនាំទៅ ។ ព្រោះទូកវៀរចាកកិរិយា មានការចែវ និងការធ្វើសំពត់ក្តោងឱ្យតាំងល្អ ព្រមទាំងការកាយទឹកជាដើម នៃមនុស្សទាំងឡាយនោះ នឹងទៅដល់កន្លែងដែលបំណងក៏មិនបាន ។ ពាក្យថា **ទាំង ២ ផ្នែក** មានន័យថា នូវគ្នានិងគ្នា បានដល់ មនុស្សអាស្រ័យទូក ទូកក៏អាស្រ័យមនុស្ស ។

ពាក្យថា **ដូច្នោះ** គឺ ដូចប្រការដែលពោលហើយ ។ ពាក្យថា **ដោយន័យផ្សេងៗ** បានដល់ ដោយន័យនៃការកំណត់នាមរូប ៧៤ ន័យ គឺ :

តាមរយៈការកំណត់អរូប **១៤** ប្រការ ទាក់ទងនឹងឈាន ៧ មានបឋមជ្ឈានជាដើម និងឧបចារៈនៃឈាន ៧ នោះ , តាមរយៈការកំណត់រូប **២០** ទាក់ទងនឹងធាតុ អាយតនៈ ខន្ធ និងមហាភូត តាមរយៈការកំណត់ធាតុ ១៣ ប្រការ ដែលពោលទុកក្នុងចតុធាតុវវដ្ឋានៈ ទាក់ទងនឹង ឥន្ទ្រិយ សច្ចៈ បដិច្ចសមុប្បន្នធម៌ ដែលបានពោលទុកក្នុងទីនេះ និងមិនបានពោលទុក , តាមរយៈការកំណត់រូប ៦០ ចំនួនទាំងឡាយនោះ គុណមួយៗមាន ៣ ទាក់ទងនឹងអរូបធម៌ទាំង ៣ ដែលប្រាកដដោយសភាវៈនេះគឺ **ផស្ស វេទនា ចិត្ត** និងតាមរយៈការកំណត់អរូបទាំង ១៤ នោះផង តាមន័យនៃការចែកសេចក្តី ត្រឹមតែនាមរូបដោយព្រះសូត្រច្រើនសូត្រ និងពាក្យឧបមាដោយរថ ផ្ទះ កណ្តាប់ដៃ ពិណ កងទ័ព ដើមឈើ ឈើយន្ត ស្នុក ស្គរ មនុស្សខ្វាក់ពីកំណើត មនុស្សខ្វិន ទូក និងអ្នកចែវទូក ។

ពាក្យថា **ដែលគ្របសង្កត់នូវសត្តសញ្ញា** គឺ ដែលគ្របសង្កត់ការប្រកាន់ថា ជាអត្តាក្នុងខន្ធ ៥ ដែលមានមកអស់កាលរកទីបំផុតមិនបាន ។ ពាក្យថា **ការឃើញនាម និងរូបតាមសេចក្តីពិត** មានន័យថា ការឃើញភាវៈត្រឹមតែជាធម៌ ដោយសេចក្តី គឺ ការកំណត់លក្ខណៈនៃនាម និងរូបទាំងឡាយនោះ គឺ **នេះនាម** នាមត្រឹមប៉ុណ្ណេះ មិនក្រៃលែងជាងនេះ , **នេះរូប** រូបត្រឹមប៉ុណ្ណេះ មិនក្រៃលែងជាងនេះ ។ គប្បីជ្រាបថា ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ព្រោះជម្រះមន្ទិល គឺ ការឃើញថាជាអត្តា ។ បទថា **ឯតស្សេវ យោគ នាមរូបស្ស យាថាវ-**

**ទស្សនស្ស** នោះឯង ប្រែថា នៃការឃើញនាមរូប តាមសេចក្ដីពិតនោះឯង ។

## អភិធម្មាវតា
## ការដល់ព្រមនៃទិដ្ឋិវិសុទ្ធិ

**សត្តសញ្ញំ វិនោទេត្វា នាមរូបស្ស សព្វថា**
**យថាវទស្សនំ ឯតំ " ទិដ្ឋិសុទ្ធិ " តិ វុច្ចតិ**

ការឃើញនាមរូបតាមសេចក្ដីពិត រមែងបន្ទោបង់នូវការសម្គាល់ថា ជាសត្វ បុគ្គល នេះហៅថា **ទិដ្ឋិវិសុទ្ធិ** ។

**បរិមុច្ចិតុកាមោ ច ទុក្ខតោ ជាតិអាទិតោ**
**អន្តទ្វយំ វិវជ្ជេត្វា ភាវយេ បន បណ្ឌិតោ**

បណ្ឌិត ប្រាថ្នាការរួចផុតចាកទុក្ខ មានជាតិជាដើម គប្បីវៀរចាកធម៌ថោកទាប ២ ប្រការ ( សស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិ ) ហើយចម្រើន **ទិដ្ឋិវិសុទ្ធិ** នេះចុះ ។

# មហាវិបស្សនា ១៨

១ – អនិច្ចានុបស្សនំ ភាវេន្តោ និច្ចសញ្ញំ បជហតិ បុគ្គលចម្រើនបញ្ញា ឃើញថា មិនទៀង រមែងលះសេចក្តីសម្គាល់ថា ទៀង ( លះនិច្ចសញ្ញា ) ។

អធិប្បាយ : បុគ្គលប្រារព្ធសេចក្តីព្យាយាម កំណត់ដឹងនូវនាមរូប ដោយលក្ខណៈពិសេសតាមសមគួរ រមែងឃើញការកើតឡើង និងការរលត់ទៅ ។ បញ្ញាដែលឃើញថា មិនទៀងនេះ ឈ្មោះថា **អនិច្ចានុបស្សនា** ។ ក្នុងធម៌នេះ មានចំណុច ៣ ប្រការ ក្នុងអដ្ឋកថា ចូឡតណ្ហាសង្ខយសូត្រ :

| | |
|---|---|
| –អនិច្ចំ | សភាវៈមិនទៀង បានដល់ នាមរូប ឬ ខន្ធ ៥ ដែលកើតរលត់តាមទ្វារទាំង ៦ គឺជាសភាវៈកើតឡើង និងរលត់ទៅភ្លាមៗ ។ |
| –អនិច្ចានុបស្សនា | បញ្ញាឃើញថា មិនទៀង ដោយឃើញច្បាស់សភាពមិនទៀងនៃនាមរូបបច្ចុប្បន្ន ។ |
| –អនិច្ចានុបស្សី | បុគ្គលប្រកបដោយញាណ ឃើញថាមិនទៀងក្នុងនាមរូបនោះ ។ |

២ – ទុក្ខានុបស្សនំ ភាវេន្តោ សុខសញ្ញំ បជហតិ បុគ្គលចម្រើនបញ្ញាឃើញថា ជាទុក្ខ រមែងលះសេចក្តីសម្គាល់ថា សុខ ( លះសុខសញ្ញា ) ។

អធិប្បាយ : ក្នុងគម្ពីរវិសុទ្ធិមគ្គលោកបានពោលទុកថា ខន្ធ ៥ នោះឯង ដែលមានសភាពជាទុក្ខ ដូចព្រះពុទ្ធតម្រាស់ត្រាស់ថា **យទនិច្ចំ តំ ទុក្ខំ** សភាវៈណាដែលមិនទៀង សភាវៈនោះជាទុក្ខ ព្រោះត្រូវបៀតបៀនជានិច្ច , លក្ខណៈដែលត្រូវបៀតបៀនជានិច្ចនោះ ឈ្មោះថា **ទុក្ខលក្ខណៈ** ។

**ទុក្ខលក្ខណៈ** ចែកចេញជា ៣ ប្រការ គឺ

- ទុក្ខទុក្ខ — ទុក្ខព្រោះទ្រាំមិនបាន គឺជាទុក្ខវេទនាផ្លូវកាយ និង ផ្លូវចិត្តក្នុងពេលដែលសោយអារម្មណ៍ ។
- វិបរិណាមទុក្ខ — ទុក្ខព្រោះប្រែប្រួល គឺជាសុខវេទនាផ្លូវកាយនិងផ្លូវចិត្តជាសភាវៈប្រែប្រួល មិនស្ថិតនៅជានិច្ច ។
- សង្ខារទុក្ខ — ទុក្ខប្រចាំសង្ខារ គឺ នាមរូប ដែលមានការកើតរលត់ជានិច្ច ។

៣ - អនត្តានុបស្សនំ ភាវេន្តោ អត្តសញ្ញំ បជហាតិ បុគ្គលចម្រើនបញ្ញា ឃើញថា ជាអនត្តា រមែងលះសេចក្តីសម្គាល់ថា ជាតួខ្លួន ( លះអត្តសញ្ញា ) ។

អធិប្បាយ : បុគ្គលអ្នកបដិបត្តិធម៌ កំណត់ដឹងនាមរូបដោយសភាវៈលក្ខណៈ បញ្ញាក៏ឃើញច្បាស់នូវនាមរូបនោះ មិនមានអំណាចក្នុងខ្លួនឯងគ្រាន់តែជាសភាវធម៌ដែលកើតរលត់ទៅតាមហេតុ តាមបច្ច័យប៉ុណ្ណោះ ឈ្មោះថា **អនត្តានុបស្សនា** ។

ក្នុងគម្ពីរវិសុទ្ធិមគ្គលោកបានពោលទុកថា ខន្ធ ៥ នោះជាអនត្តា ដូចព្រះពុទ្ធតម្រាស់ត្រាស់ថា **យំ ទុក្ខំ អនត្តា** សភាវៈណាជាទុក្ខ សភាវៈនោះមិនមែនជាតួខ្លួន ។ **អវស វត្តនាការោ អនត្តលក្ខណំ** លក្ខណៈដែលប្រព្រឹត្តទៅ មិននៅក្នុងអំណាច ឬ មិនប្រព្រឹត្តទៅតាមដែលត្រូវការ ជាលក្ខណៈនៃអនត្តា ។

មហាដីកាវិសុទ្ធិមគ្គពោលថា **ឃនៈ** ដែលបិទបាំងអនត្តលក្ខណៈចែកជា ៤ ប្រភេទ :

-សន្តតិឃនៈ: **ឃនៈ** គឺ ដុំដែលតគ្នា បានដល់ នាមរូបដែលកើតឡើងបន្តជាប់គ្នា ។

-សមូហឃនៈ: **ឃនៈ** គឺ ដុំដោយកងនាមរូប បានដល់ នាមរូបដែលបុគ្គលសម្គាល់ថាតែមួយ ព្រោះប្រជុំគ្នាក្នុងទីតែ ១ ។

-កិច្ចឃនៈ: **ឃនៈ** គឺ ដុំដោយនាទី បានដល់ នាមរូបដែលមាននាទីផ្សេងៗគ្នា តាមសភាវៈនោះៗ ប៉ុន្តែបុគ្គលមានសេចក្តីសម្គាល់ថា នាមរូបតែមួយដែលធ្វើកិច្ចទាំងនោះ ។

-អារម្មណឃនៈ: **ឃនៈ** គឺ ដុំដោយអារម្មណ៍ បានដល់ នាមធម៌មួយៗមានអារម្មណ៍ផ្សេងៗគ្នា តាមសភាវៈនោះៗ ប៉ុន្តែបុគ្គលដោយច្រើន មានសេចក្តីសម្គាល់ថា នាមធម៌ គឺតួខ្លួនតែមួយ ដែលដឹងអារម្មណ៍នោះៗ ។

**ឃនៈ** គឺ ដុំទាំង ៤ នេះឯង ដែលធ្វើឱ្យមានការយល់ខុសថា ជាតួខ្លួន ហើយបិទបាំងនូវអនត្តលក្ខណៈនៃសង្ខារធម៌ ។

ដោយសេចក្ដីពិត បញ្ញត្តិដែលជាដុំដោយកងនាមរូប ដែលបុគ្គលមិនបានដឹងច្បាស់នូវសង្ខារធម៌ ក៏មានការយល់ថាតែមួយ ក្នុងនាមធម៌ និងរូបធម៌នោះ ដែលកើតរួមគ្នា បន្តគ្នា និងឧបត្ថម្ភដល់គ្នា ។ ភាពជាដុំដោយនាទីដែលបុគ្គលថាតែមួយ ក្នុងសភាវធម៌នោះ ដែលសភាវធម៌នោះៗមាននាទីផ្សេងគ្នាពិតប្រាកដ និងភាពជាដុំដោយអារម្មណ៍ ដែលបុគ្គលយល់ថា ជាសភាវធម៌តែមួយ សូម្បីសភាវធម៌ដែលទទួលអារម្មណ៍នោះៗ មានការដឹងអារម្មណ៍ផ្សេងគ្នាយ៉ាងណាក៏ដោយ ។

**បញ្ញត្តិទាំងនោះ** រមែងសាបសូន្យទៅ កាលបុគ្គលបានឃើញធាតុផ្សេងៗគ្នាដោយបញ្ញា ដូចពពុះទឹកដែលប៉ះខ្ទប់នឹងបាតដៃ ។

**អនត្តលក្ខណៈ** រមែងប្រាកដច្បាស់ថា ធម៌ គឺ នាមរូបទាំងអស់នេះគ្រាន់តែជាសភាវធម៌ដែលសូន្យទទេចាកតួខ្លួន ប្រព្រឹត្តទៅតាមបច្ច័យ ។

៤ - និព្វិទានុបស្សនំ ភាវេន្តោ នន្ទិំ បជហតិ បុគ្គលចម្រើនបញ្ញា ឃើញសង្ខារទាំងឡាយតាមសេចក្ដីពិត ក៏នឿយណាយ រមែងលះបង់នូវនន្ទិ គឺ ការភ្លើតភ្លើន ។

អធិប្បាយ : **និព្វិទានុបស្សនា** បានដល់ និព្វិទាញាណ រមែងមានប្រាកដដល់បុគ្គលដែលឃើញការរលត់ទៅនៃនាមរូបបច្ចុប្បន្នខណៈនោះៗ ក៏បានដឹងថា នាមរូបមានទោសគួរឱ្យខ្លាច ទើបបានជាបច្ច័យឱ្យកើតការនឿយ-ណាយ ក្នុងនាមរូបដែលបានឃើញដោយបញ្ញាថា មានការរលត់ទៅនោះឯង។

បុគ្គលដែលមិនបានឃើញតាមសេចក្ដីពិតដោយអនុបស្សនានេះ រមែង

សម្គាល់ថា នាមរូបគួរឱ្យភ្លើតភ្លើន ទើបរីករាយភ្លើតភ្លើន ដែលជាតណ្ហាប្រកប ជាមួយបីតិ នាំឱ្យកិលេស កម្ម និង វិបាកជាផលរបស់កម្មប្រព្រឹត្តទៅដោយ អាស្រ័យការភ្លើតភ្លើនជាហេតុ ។ ការភ្លើតភ្លើនជាដើមនោះ ត្រូវកម្ចាត់បង់ ដោយនិព្វិទានុបស្សនានេះ ក្នុងខណៈដែលឃើញសង្ខារថាគួរនឿយណាយ ។

៥ – វិរាគានុបស្សនំ ភាវេន្តោ រាគំ បជហាតិ បុគ្គល ចម្រើនបញ្ញា ឃើញសង្ខារទាំងឡាយតាមពិតហើយ ក៏ប្រាសចាកតម្រេករមែង លះនូវរាគៈ ។

អធិប្បាយ : បុគ្គលចម្រើនវិបស្សនា កាលដែលនឿយណាយនឹង នាមរូបដោយនិព្វិទាញាណ រមែងប្រាសចាកនូវតម្រេកក្នុងនាមរូប ដែលឃើញ ការរលត់ទៅនោះ ។ ចិត្តនៃព្រះយោគាវចរ រមែងបង្អោនទៅកាន់ព្រះនិព្វាន ដែលជាទុក្ខនិរោធ ។

ក្នុងអដ្ឋកថា ចូឡតណ្ហាសង្ខយសូត្រ បានសម្តែងថា វិរាគៈ ២ យ៉ាង គឺ **ខយវិរាគៈ** ១ និង **អច្ចន្តវិរាគៈ** ១ ទាំងពីរបទនោះ វិបស្សនាដែលឃើញសង្ខារ ទាំងឡាយ មានការអស់ទៅ សូន្យទៅ ឈ្មោះថា **ខយវិរាគៈ** ។

ចំណែកមគ្គញ្ញាណ ដែលឃើញព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគៈ** , បុគ្គលដែលព្រមព្រៀងដោយវិរាគៈទាំងពីរនោះ ឈ្មោះថា **វិរាគានុបស្សី** ។ ក្នុងទីនេះសំដៅយក **មុញ្ចិតុកាម្យតាញាណ** ( បញ្ញាប្រាថ្នាឱ្យបានរួចផុត ) ដែល ជាវិរាគានុបស្សនា ព្រោះនៅក្នុងចំណែកនៃវិបស្សនាដែលជាលោកិយ ។

៦ – និរោធានុបស្សនំ ភាវេន្តោ សមុទយំ បជហាតិ

បុគ្គលចម្រើនបញ្ញា ឃើញសង្ខារធម៌ទាំងឡាយរលត់តាមសេចក្តីពិត ហើយ រមែងលះនូវសមុទយៈ ។

អធិប្បាយ : **និរោធានុបស្សនា** គឺ បញ្ញាឃើញការរលត់ទៅនៃសង្ខារធម៌ ជាមុញ្ចិតុកាម្យតាញាណដែលមានកម្លាំងចាស់ក្លា ត្រូវការនឹងលែងចោលនូវសង្ខារដែលបានប្រចក្សការរលត់ទៅនោះ ។

មហាដីកាវិសុទ្ធិមគ្គសម្តែងថា ពាក្យថា **និរោធានុបស្សនា** គឺ បញ្ញាឃើញការរលត់ទៅនៃសង្ខារទាំងឡាយ ។ ន័យម្យ៉ាងទៀត គឺ បញ្ញាឃើញសង្ខារធម៌ទាំងឡាយរលត់ទៅ មិនកើតឡើងជាភពថ្មីទៀត ។

តាមពិត អនុបស្សនានេះ គឺ មុញ្ចិតុកាម្យតាញាណដែលសម្រេចនូវភាពចាស់ក្លា ។

វិសុទ្ធិមគ្គសម្តែងថា កាលអ្នកបដិបត្តិធម៌នោះ មិនមានតម្រេកយ៉ាងនេះ ក៏ធ្វើភាគៈក្នុងសង្ខារឱ្យរលត់ទៅដោយញាណថ្នាក់លោកិយជាមុន ដោយសេចក្តីថា ធ្វើមិនឱ្យកើតឡើង ។

ន័យម្យ៉ាងទៀត ព្រះយោគាវចរជាអ្នកប្រាសចាកតម្រេក យ៉ាងនេះ ហើយ រមែងកំណត់ដឹងយ៉ាងប្រចក្សនូវសង្ខារក្នុងបច្ចុប្បន្ន មានការរលត់ទៅមិនកើតទៀត យ៉ាងណា បញ្ញាបានកំណត់ដឹងថា សង្ខារមានការរលត់ទៅក្នុងអតីត និងក្នុងអនាគត មិនកើតឡើងទៀត ក៏យ៉ាងនោះ សូម្បីមិនបានប្រចក្សប៉ុន្តែឃើញដោយញាណទៅតាមបញ្ញាដែលបានប្រចក្សសង្ខារជាបច្ចុប្បន្ននេះ ។ ដូច្នោះ **និរោធានុបស្សនា** គឺ ការកំណត់ដឹងថា មានការរលត់ទៅនៃសង្ខារ មិនឃើញមានការកើត ក៏ត្រូវការនឹងរួចផុតពីសង្ខារធម៌ទាំងឡាយនោះ ។

៧- បដិនិស្សគ្គានុបស្សនំ ភាវេន្តោ អាទានំ បជហតិ បុគ្គលចម្រើនបញ្ញា ឃើញសង្ខារធម៌ទាំងឡាយថា ត្រូវលះបង់តាមពិតហើយ រមែងលះនូវ **អាទាន** គឺ សេចក្ដីប្រកាន់ ។

អធិប្បាយ : មហាដីកាវិសុទ្ធិមគ្គសម្ដែងថា តាមពិត បដិនិស្សគ្គា-នុបស្សនា គឺ បដិសង្ខាញាណ និង សង្ខារុបេក្ខាញាណ នោះឯង ។

អដ្ឋកថា ចូឡតណ្ហាសង្ខយសូត្របានសម្ដែងថា **វោស្សគ្គ** គឺ ការលះបង់ក្នុងបទថា បដិនិស្សគ្គានុបស្សនានេះ ។

**វោស្សគ្គ** មាន ២ យ៉ាង គឺបរិច្ចាគវោស្សគ្គ ១ និងបក្ខន្ទនវោស្សគ្គ ១ ។ ទាំង ២ យ៉ាងនេះ **វិបស្សនា** ឈ្មោះថា **បរិច្ចាគវោស្សគ្គ** ព្រោះថា វិបស្សនានោះ រមែងលះកិលេស និងខន្ធទាំងឡាយ ដោយអំណាចនៃតទង្គប្បហាន ចំណែក **មគ្គ** ឈ្មោះថា **បក្ខន្ទនវោស្សគ្គ** ព្រោះមគ្គនោះរមែងស្ទុះទៅកាន់ព្រះនិព្វានដោយអារម្មណ៍ ។

ម្យ៉ាងទៀត **បរិច្ចាគវោស្សគ្គ** រមែងលះកិលេស និងខន្ធទាំងឡាយដោយសមុច្ឆេទប្បហាន និងស្ទុះទៅកាន់ព្រះនិព្វាន , រីឯ **និរោធ** ឈ្មោះថា **បក្ខន្ទនវោស្សគ្គ** ព្រោះអត្ថថា ចិត្តរមែងស្ទុះទៅកាន់និព្វានធាតុ ។

៨ - ខយានុបស្សនំ ភាវេន្តោ ឃនសញ្ញំ បជហតិ បុគ្គលចម្រើនបញ្ញា ឃើញការអស់ទៅ រមែងលះសេចក្ដីសម្គាល់ថាជាដុំ ( ឃនសញ្ញា ) ។

អធិប្បាយ : គឺ បញ្ញាឃើញនូវការអស់ទៅនៃបច្ចុប្បន្នខណៈ បាន

ដល់ ការឃើញនាមរូបដែលរលត់ទៅនោះ ។ **ខយានុបស្សនា** គឺ ភង្គញាណ ដែលឃើញការរលត់ទៅនៃអារម្មណ៍ ដែលខ្លួនបានកំណត់ដឹង និងឃើញការ រលត់ទៅនៃវិបស្សនាចិត្តក្នុងខណៈនោះ ។ បញ្ញត្តិ ដែលជារូបរាងសណ្ឋាន រមែងអន្តរធានអស់ទៅ មានត្រឹមតែការរលត់ទៅនៃនាមរូប ដែលជាសភាវធម៌ ប៉ុណ្ណោះ ។ **ខយានុបស្សនា** ឃើញការអស់ទៅនៃខន្ធជាបច្ចុប្បន្នដូច្នេះ រមែង បំបែកដុំ ( ឃនៈ ) ដែលជារូបរាងផ្សេងៗ ដូចជាបត់ លាត សណ្តូកដៃជើង ជាដើម រមែងឃើញការរលត់ទៅជាខណៈៗយ៉ាងល្អិតនៃសភាវនោះៗ ទើប ដឹងថា សភាវៈនោះអស់ទៅជានិច្ច ។ ក្រៅពីនេះ ក៏បានឃើញវិបស្សនាចិត្ត រលត់ទៅទៀត ។ ព្រះយោគាវចរ មិនបានជួបនូវរូបរាងទ្រង់ទ្រាយសណ្ឋាននៃ ដៃ ឬ ជើងដែលបត់ ឬ លា ឬ ឈានជាដើមនោះឡើយ ហើយក៏មិនបានជួប នូវចិត្តដែលស្ថិតនៅនោះដែរ ។ ដូច្នេះ **ខយានុបស្សនា** នេះ ទើបអាចលះនូវ **ឃនសញ្ញា** បាន ។

៩ - វយានុបស្សនំ ភាវេន្តោ អាយូហានំ បជហតិ

បុគ្គលចម្រើនបញ្ញា ឃើញការសូន្យទៅនៃសង្ខារទាំងឡាយដែលជាអតីត និង ភាពសូន្យនៃសង្ខារទាំងឡាយក្នុងអនាគត ស្មើដោយការអស់ទៅ សូន្យទៅនៃ សង្ខារទាំងឡាយជាបច្ចុប្បន្ន រមែងលះនូវការខ្វាយខ្វល់ក្នុងរឿងរស់នៅជាសុខ ស្រួល ។

អធិប្បាយ : **វយានុបស្សនា** គឺ បញ្ញាឃើញនូវការសូន្យទៅ ពោល គឺ បុគ្គលដែលឃើញការរលត់ទៅគ្រប់ខណៈនៃរូបធម៌ នាមធម៌ ដែលកំណត់

ដឹងក្នុងខណៈបច្ចុប្បន្ន ដូច្នេះហើយ រមែងអនុមានដឹងថា នាមរូបក្នុងអតីត និងក្នុងអនាគត ក៏មានសភាពសូន្យដូចនាមរូបក្នុងបច្ចុប្បន្នដែរ ។ **អនុបស្សនា** នេះ រមែងលះការខ្វាយខ្វល់អំពីការរស់នៅ ដើម្បីបរិភោគឆ្ងាញ់ ទីកន្លែងនៅស្រួល មានឋានៈកិត្តិយស ។ល។... បុគ្គលដែលមិនបានឃើញនាមរូបអស់ទៅ សូន្យទៅ ក៏សម្គាល់ខុសថា ជាតួខ្លួនឯង និងអ្នកដទៃមាននៅ ទើបខ្វាយខ្វល់ដើម្បីឱ្យសង្ខារទាំងឡាយដែលសម្គាល់ខុសថា ជាតួខ្លួនឯង និងអ្នកដទៃនេះរស់នៅជាសុខ ទាំងក្នុងភពនេះ និងទាំងក្នុងភពខាងមុខ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គសម្តែងថា ការលះនូវ **អាយូហន** ( ការខ្វាយខ្វល់ប្រមូលមកនូវកម្ម ) ដោយវយានុបស្សនានោះ ព្រោះកាលដែលព្រះយោគាវចរបដិបត្តិឃើញថា បុគ្គលគប្បីខ្វាយខ្វល់ដើម្បីប្រយោជន៍ដល់សង្ខារទាំងឡាយណា សង្ខារទាំងឡាយនោះ មានការសូន្យទៅជាធម្មតា ដូច្នោះឯង ។

១០ - វិបរិណាមានុបស្សនំ ភាវេន្តោ ធុវសញ្ញំ បជហាតិ បុគ្គលចម្រើនបញ្ញាឃើញការប្រែប្រួលនៃសង្ខារទាំងឡាយ រមែងលះនូវសេចក្តីសម្គាល់ថា ទៀង ។

អធិប្បាយ : **វិបរិណាមានុបស្សនា** គឺ បញ្ញាឃើញការប្រែប្រួលទៅ ដូចក្នុងគម្ពីរវិសុទ្ធិមគ្គសម្តែងថា :

**១ - វិបរិណាមានុបស្សនា** ឃើញការប្រព្រឹត្តទៅយ៉ាងដទៃកន្លងផុតព្រំដែននោះៗ ដោយចែកជាចំណែកៗ ដូចជា រូបក្នុងបឋមវ័យមិនទាន់ដល់មជ្ឈិមវ័យក៏រលត់ទៅក្នុងបឋមវ័យនោះ ដូច្នេះ រូបក្នុងបឋមវ័យទើបផ្សេងគ្នាពីរូបក្នុង

មជ្ឈិមវ័យ ។ ល ។ ពិចារណាយ៉ាងល្អិតដល់រូបដែលប្រព្រឹត្តទៅក្នុងខណៈដើរទៅខាងមុខ មិនទាន់ត្រឡប់មកវិញផង ក៏រលត់ទៅក្នុងខណៈដែលដើរទៅខាងមុខនោះ ដូច្នេះ រូបក្នុងខណៈដើរទៅខាងមុខ ទើបផ្សេងពីរូបក្នុងខណៈដើរត្រឡប់មកវិញ ។

**២ - វិបរិណាមានុបស្សនា** ឃើញការប្រែប្រួលទៅនៃនាមរូបដែលកើតឡើងហើយ ដោយលក្ខណៈទាំងពីរ គឺ ចាស់ និង ស្លាប់ ។ ការពិចារណាយ៉ាងគ្រោតគ្រាត គឺ នាមរូបប្រែប្រួលដោយចាស់ និង ដោយស្លាប់ ដូច្នេះនាមរូបគ្រប់យ៉ាង ទើបប្រែប្រួលមិនតាំងនៅជានិច្ច ដោយលក្ខណៈទាំងពីរ ។ ការពិចារណាយ៉ាងល្អិត គឺ នាមរូបប្រែប្រួលចាកខណៈកើត ទៅកាន់ខណៈតាំងនៅ និងប្រែប្រួលពីខណៈតាំងនៅ ទៅកាន់ខណៈរលត់ ដូច្នេះនាមរូបគ្រប់យ៉ាង ទើបប្រែប្រួលជានិច្ច ។ បញ្ញាដូចអធិប្បាយមកនេះ ទើបលះនូវធុវសញ្ញា ( ការសម្គាល់ថា ទៀង ) បាន ។

ក្នុងគម្ពីរបដិសម្ភិទាមគ្គសម្តែងថា **វយានុបស្សនា** គឺ បញ្ញាឃើញការសូន្យទៅនៃខន្ធអតីត និងអនាគត តាមបច្ចក្ខវិបស្សនា ( ការឃើញខន្ធក្នុងបច្ចុប្បន្នរលត់ ) ។ **វិបរិណាមានុបស្សនា** គឺ បញ្ញាឃើញការប្រែប្រួលនៃខន្ធទាំងពួងថា ខន្ធទាំងអតីត អនាគត និងបច្ចុប្បន្ន មានការប្រែប្រួលទៅ ព្រោះបង្អោនទៅក្នុងនិរោធដែលជាការរលត់នោះឯង ។

១១ - អនិមិត្តានុបស្សនំ ភាវេន្តោ និមិត្តំ បជហតិ

បុគ្គលចម្រើនបញ្ញាឃើញថា មិនមាននិមិត្តរូបរាង រមែងលះបង់នូវនិមិត្តទាំង-ឡាយ ។

អធិប្បាយ : **អនិមិត្តានុបស្សនា** គឺ អនិច្ចានុបស្សនានោះឯង សំដៅដល់បញ្ញាដែលឃើញថា មិនមាននិមិត្ត ។

គម្ពីរវិសុទ្ធិមគ្គសម្តែងថា **និមិត្តន្តិ សង្ខារនិមិត្តំ** " ពាក្យថា **និមិត្ត** គឺ របស់ប្រាកដដូចជាមានពិត " សំដៅដល់ និមិត្ត គឺ សង្ខារ ។

ដីកាវិសុទ្ធិមគ្គសម្តែងថា **សង្ខារនិមិត្តន្តិ សង្ខារានំ សមូហាទិ ឃន-វសេន សកិច្ចបរិច្ឆេទ តាយ ច សវិគ្គហានំ វិយ ឧបដ្ឋានំ** ពាក្យពោលថា **សង្ខារនិមិត្ត** គឺ ការប្រាកដឱ្យកាន់យកខុសនៃសង្ខារ ដោយភាពជាកង ជាដុំ នៃនាមរូបជាដើម និងការប្រាកដនៃសង្ខារដោយចំណែករូបរាង មុខមាត់របស់ខ្លួន ( សង្ខារមានត្រឹមតែការកើត និងការលត់ទៅវិញប៉ុណ្ណោះ ) ។

បុគ្គលទូទៅ ដែលមិនបានចម្រើនវិបស្សនា រមែងសម្គាល់ថា មានរូបរាង សណ្ឋាន ដែលស្ថិតនៅស្មើក្នុងអាកប្បកិរិយានៃរាងកាយ ។

រីឯបុគ្គលដែលចម្រើនវិបស្សនារហូតដល់ **អនិមិត្តានុបស្សនា** ថ្នាក់ **ភង្គញ្ញាណ** រមែងឃើញសភាវធម៌ដែលប្រាកដតាមទ្វារទាំង ៦ មានការកើត និងរលត់ទៅទាន់ពេល មិនប្រាកដនូវរូបរាងសណ្ឋានឡើយ ។

គម្ពីរវិសុទ្ធិមគ្គសម្តែងថា មគ្គនេះលះនូវនិមិត្ត ថាទៀង ថាយឺនយូរ ថាមាំទាំ ឋិតថេរ មានការបំបែកក្រុមរបស់សង្ខារដោយ **អនិច្ចានុបស្សនា** ដូច្នេះទើបឈ្មោះថា **អនិមិត្តានុបស្សនា** ។

គម្ពីរបដិសម្ភិទាមគ្គសម្តែងថា សង្ខារទាំងឡាយ រមែងប្រាកដនូវការអស់ទៅ ដល់បុគ្គលដែលឃើញថា មិនទៀង ។ បុគ្គលដែលឃើញថាមិនទៀង រមែងឃើញសង្ខារតាមសេចក្តីពិត ។

១២ – អប្បណិហិតានុបស្សនំ ភាវេន្តោ បណីធិបជហាតិ បុគ្គលចម្រើនបញ្ញាឃើញថា មិនគួរប្រាថ្នា រមែងលះនូវសេចក្ដីប្រាថ្នា ។

អធិប្បាយ : តណ្ហាដែលរីករាយត្រេកអរក្នុង បិយរូប សាតរូប ព្រោះសម្គាល់ខុសថា នាមរូបដែលប្រាកដក្នុងខណៈឃើញ ខណៈឮជាដើម ជារបស់ដែលគួរឱ្យពេញចិត្ត នេះហៅថា **បណីធិ** ឬ **បណិហិត** ។

បុគ្គលដែលឃើញដោយបញ្ញា ចំពោះនាមរូបមានការកើតហើយ ក៏រលត់ទៅវិញដូច្នេះ រមែងជ្រួតជ្រាបថា នាមរូបជាទុក្ខ មិនមែនជាសភាវៈគួរឱ្យរីករាយឡើយ ។ ការឃើញដូច្នេះ ឈ្មោះថា **អប្បណិហិតានុបស្សនា** គឺ បញ្ញាឃើញថា លោកនេះមិនគួរឱ្យត្រេកអរ មិនគប្បីប្រាថ្នា រមែងលះនូវការប្រាថ្នារកសុខក្នុងសង្ខារ ។

ការឃើញតាមសេចក្ដីពិតដូច្នេះ ក៏បានឈ្មោះថាជា **ទុក្ខានុបស្សនា** នេះឯង គ្រាន់តែផ្លាស់ឈ្មោះមកជា **អប្បណិហិតានុបស្សនា** ព្រោះថា បញ្ញានេះ បានលះការតម្កល់ទុកនូវបំណងប្រាថ្នាក្នុងលោក ។

១៣–សុញ្ញតានុបស្សនំ ភាវេន្តោ អភិនិវេសំ បជហាតិ បុគ្គលចម្រើនបញ្ញាឃើញថា សូន្យទទេ ( សូន្យចាកខ្លួន និងចាកវត្ថុជារបស់ខ្លួន ) រមែងលះនូវការប្រកាន់មាំ ។

អធិប្បាយ : បុគ្គលទូទៅរមែងសម្គាល់ខុសថា មានខ្លួន ដែលធ្វើ

កាយវិការ និងដែលមានឥរិយាបថផ្សេងៗ ។ បុគ្គលចម្រើនវិបស្សនារហូតដល់សម្រេចភង្គញ្ញាណ ដែលជាការចាស់ក្លានៃ **អនត្តានុបស្សនា** ហើយរមែងឃើញត្រឹមតែសភាវធម៌ដែលកើតឡើង និងរលត់ទៅវិញ មិនមានបុគ្គលយើងរបស់យើងអ្វីឡើយ ជាការដែលមិននៅក្នុងអំណាចខ្លួនឯង ទើបជា **សុញ្ញតា-នុបស្សនា** ហើយរមែងលះបង់នូវការប្រកាន់ថាជាតួខ្លួន ។ មិនចេះតែតាមរករបស់ដែលពេញចិត្ត រំលងចោលសភាវធម៌ពិតដែលកំពុងប្រាកដឡើយ ។

១៨ - អធិប្បញ្ញា ធម្មវិបស្សនំ ភាវេន្តោ សារាទា-នាភិនិវេសំ បជហាតិ បុគ្គលចម្រើនបញ្ញាដ៏ក្រៃលែង ឃើញនូវសភាវធម៌ ( ឃើញការរលត់ទៅនៃសង្ខារដែលជាអារម្មណ៍ និង វិបស្សនាចិត្តដែលដឹងអារម្មណ៍នោះ ) រមែងលះនូវអភិនិវេសៈ គឺ ការប្រកាន់ថាមានខ្លឹមសារក្នុងសង្ខារទាំងឡាយ ។

អធិប្បាយ : អធិប្បញ្ញាធម្មវិបស្សនា គឺ បញ្ញាដ៏ក្រៃលែងដែលដឹងនូវសភាវធម៌ថា សង្ខារធម៌ពិតជារលត់ទៅ ព្រោះឃើញនូវការរលត់ទៅនៃសង្ខារ ដែលជាអារម្មណ៍ និង វិបស្សនាចិត្តដែលដឹងអារម្មណ៍ នេះគឺជា **ភង្គញ្ញាណ** ក្នុងលំដាប់ចាស់ក្លា មានការដឹងនាមរូប មួយខណៈៗ រលត់ទៅយ៉ាងរហ័ស ទាំងដែលឃើញវិបស្សនាចិត្តរលត់ទៅទៀត ជាការឃើញច្បាស់ថា ក្នុងជីវិតនេះត្រឹមតែជាសង្ខារធម៌ប៉ុណ្ណោះ មានការលះនូវសេចក្ដីប្រកាន់ថាមានខ្លឹមសារក្នុងសង្ខារ ដោយឃើញប្រចក្សថា មិនមានអត្តា និងឃើញសង្ខារធម៌ផ្សេងៗ មិនមែនខ្លួន ។

ក្នុងបដិសម្ភិទាមគ្គ ភង្គានុបស្សនាញាណនិទ្ទេស សម្ដែងថា អារម្មណំ បដិសង្ខា ភង្គញ្ច អនុបស្សតិ សុញ្ញតោ ច ឧបដ្ឋានំ អធិប្បញ្ញា វិបស្សនា ការពិចារណានូវអារម្មណ៍ក្ដី បុគ្គលឃើញនូវការបែកធ្លាយក្ដី ការប្រាកដឡើងថាសូន្យក្ដី ឈ្មោះថា ការពិចារណាឃើញដោយបញ្ញាដ៏ក្រៃលែង ។

អដ្ឋកថា : បទថា **អារម្មណញ្ច បដិសង្ខា** បានដល់ ការពិចារណាអារម្មណ៍ គឺ ដឹងអារម្មណ៍ មានរូបជាដើមមុន ។ បទថា **ភង្គញ្ច អនុបស្សតិ** បានដល់ ការពិចារណាឃើញការរលត់ ដោយសេចក្ដីថា ឃើញការរលត់ទៅនៃអារម្មណ៍នោះហើយ ពោលគឺ ពិចារណាឃើញការរលត់ទៅនៃអារម្មណ៍នោះ និងការរលត់ទៅនៃចិត្ត ( វិបស្សនាចិត្ត ) ។ បទថា **សុញ្ញតោ ច ឧបដ្ឋានំ** បានដល់ ការប្រាកដដោយភាពជារបស់សូន្យ គឺ ការប្រាកដដោយភាពជារបស់សូន្យថា សង្ខារទាំងឡាយរមែងបែកធ្លាយ ការបែកធ្លាយទៅនៃសង្ខារទាំងនោះ គឺ សេចក្ដីស្លាប់មិនមានអ្វីៗដទៃ ។ បទថា **អធិប្បញ្ញា វិបស្សនា** គឺ លោកពោលអធិប្បាយទុកថា ការពិចារណាអារម្មណ៍ ការឃើញច្បាស់នូវការរលត់ និងកាប្រាកដដោយសភាពជារបស់សូន្យ ឈ្មោះថា **អធិប្បញ្ញា វិបស្សនា** គឺការឃើញច្បាស់ដោយអធិប្បញ្ញា ។

ព្រះបោរាណាចារ្យ បានសម្ដែងគាថាបញ្ជាក់ក្នុងបទ **សុញ្ញតោ ច ឧបដ្ឋានំ** នេះថា **ខន្ធានិរុជ្ឈន្តិ ន ចត្ថិ អញ្ញោ ខន្ធា ន ភេទូ មរណន្តិ វុច្ចតិ តេសំ ខយំ បស្សតិ អប្បមត្តោ មណីវវិជ្ឈំវជិរេន យោនិសោ** ប្រែថា ខន្ធទាំងឡាយ

រមែងរលត់ មិនមានអ្វីៗដទៃ គឺ មិនមានសត្វបុគ្គល ការបែកធ្លាយនៃខន្ធ លោកហៅថា " **មរណៈ** " ។ បុគ្គលមិនប្រមាទឃើញការអស់ទៅនៃខន្ធទាំងនោះ ដោយឧបាយត្រូវទំនង ដូចជាងកែងមណី ធ្វើការចោះនូវកែវមណីដោយពេជ្រ ដូច្នោះឯង ។

## អានិសង្សនៃអធិប្បញ្ញាវិបស្សនា

| | |
|---|---|
| **១ - ភវទិដ្ឋិប្បហានំ** | លះនូវភវទិដ្ឋិ ( សស្សតទិដ្ឋិ ) ។ |
| **២ - ជីវិតនិកន្តិ បរិច្ចាគោ** | លះបង់សេចក្តីប្រាថ្នាក្នុងជីវិត ។ |
| **៣ - សទា បយុត្តោ** | ព្យាយាមក្នុងបុណ្យកុសលសព្វកាល ។ |
| **៤ - វិសុទ្ធា ជីវិតា** | ចិញ្ចឹមជីវិតដោយការងារបរិសុទ្ធ ។ |
| **៥ - ឧស្សុកប្បហានំ** | លះបង់នូវការខ្វាយខ្វល់ក្នុងបាបអកុសល ក្នុងការស្វែងរកខុស ជាអ្នកមានសេចក្តីសន្តោស ។ |
| **៦ - វិគត ភយតា ច** | ប្រាសចាកភ័យ ។ |
| **៧ - ខន្តិ សោរច្ចប្បដិលាភោ** | បាននូវខន្តី និងសេចក្តីស្ងប់ស្ងៀម ។ |
| **៨ - អរតិរតិសហនតោ** | គ្របសង្កត់នូវការមិនត្រេកអរ ក្នុងព្រហ្មចរិយធម៌ជាដើម និងគ្របសង្កត់នូវសេចក្តីត្រេកអរក្នុងកាមជាដើម ។ |

១៩ - យថាភូតញ្ញាណទស្សនំ ភាវេន្តោ សម្មោហាភិនិវេសំ បជហាតិ បុគ្គលចម្រើនបញ្ញាឃើញតាមសេចក្តីពិតនៃនាមរូបព្រមទាំងបច្ច័យ រមែងលះបង់នូវការប្រកាន់ គឺ សម្មោហៈ ។

អធិប្បាយ : **យថាភូតញ្ញាណទស្សនៈ** គឺ បញ្ញាឃើញតាមសេចក្ដីពិតនៃនាមរូប ព្រមទាំងបច្ច័យ ។

គម្ពីរវិសុទ្ធិមគ្គសម្ដែងថា **យថាភូតញ្ញាណទស្សនៈ** គឺ ការកំណត់ដឹងនាមរូបព្រមទាំងហេតុ-បច្ច័យ លះបង់នូវការប្រកាន់ខុស ដែលប្រព្រឹត្តទៅដោយន័យជាដើមថា យើងធ្លាប់កើតពីមុន ហើយបន្តមកដល់ភពនេះឬទេហ្ន៎ ! និងដោយន័យជាដើមថា សត្វលោកកើតមកពីព្រះជាម្ចាស់ ។

បុគ្គលដែលចម្រើនវិបស្សនា រហូតបានសម្រេចនូវញាណនេះ រមែងដឹងថា មានត្រឹមតែនាមរូបកើតឡើង ជាហេតុ ជាផល គឺ ដឹងច្បាស់ថា នាមរូបក្នុងបច្ចុប្បន្នអាស្រ័យអវិជ្ជា តណ្ហា ឧបាទាន និង កម្ម ក្នុងភពមុន ទោះបីនាមរូបក្នុងអតីត និងអនាគត ក៏កើតចាកហេតុដូចគ្នាដែរ ។ ក្នុងកាលទាំង ៣ មានត្រឹមតែនាមរូប ជាហេតុ ជាផលនឹងគ្នា ។ អនុបស្សនានេះ រមែងលះបង់នូវសេចក្ដីប្រកាន់មាំ គឺ ការវង្វេងដោយទិដ្ឋិដែលប្រកាន់ថា មានអ្នកនិម្មិតនូវលោក និងសេចក្ដីសង្ស័យថា យើងធ្លាប់កើតពីមុនឬទេហ្ន៎ ! ។

១៦-អាទីនវានុបស្សនំ ភាវេន្តោ អាលយាភិនិវេសំ បជហាតិ បុគ្គលចម្រើនបញ្ញា ឃើញទោសក្នុងសង្ខារ រមែងលះបង់នូវអភិនិវេសៈ គឺ អាល័យ ( ការជាប់ជំពាក់ ) ។

អធិប្បាយ : **អាទីនវានុបស្សនា** គឺ បញ្ញាឃើញទោសក្នុងសង្ខាររមែងលះបង់ការប្រកាន់មាំដោយការជាប់ជំពាក់ ដូចក្នុងគម្ពីរវិសុទ្ធិមគ្គសម្ដែងថា :

**អាទីនវានុបស្សនា** គឺ បញ្ញាដែលឃើញទោសក្នុងភពទាំងអស់ជាដើម ដែលកើតឡើង មានសភាពប្រាកដថា គួរខ្លាច ហើយមានការលះនូវសេចក្តីប្រកាន់មាំដោយការជាប់ជំពាក់ ព្រោះឃើញថា របស់ណាមួយដែលគប្បីពឹងពាក់អាស្រ័យបាននោះ មិនមានឡើយ ។

បុគ្គលទូទៅ ទោះបីលំបាកលំបិនយ៉ាងណា ក៏មិនអាចលះភពជាតិបានឡើយ ទើបត្រូវការស្វែងរកសេចក្តីសុខដោយវិធីផ្សេងៗ ដូចជាអ្នកឈឺត្រូវការឱ្យជាសះស្បើយនូវរោគ អ្នកក្រនូវសម្បត្តិត្រូវការឱ្យមានទ្រព្យសម្បត្តិ ។ ល ។ សូម្បីមិនបាននូវរបស់តាមតម្រូវការនៅក្នុងជាតិនេះ ក៏រមែងត្រូវការឱ្យបានក្នុងជាតិតទៅ ឬក៏គិតថា ជីវិតមនុស្សមានទុក្ខ ក៏ត្រូវការឱ្យខ្លួនទៅកើតជាទេវតា ឬព្រហ្ម , ទាំងអស់នេះមិនត្រូវការរលត់ទុក្ខ បានដល់នាមរូបនោះឡើយ នេះដោយអំណាចនៃការជាប់ជំពាក់ គឺ តណ្ហា ។

បុគ្គលដែលសម្រេចនូវភង្គញ្ញាណ លំដាប់ថ្នាក់ចាស់ក្លាហើយ រមែងឃើញសង្ខារទាំងឡាយថា ជាទីពឹងអាស្រ័យមិនបាន គឺ មិនឃើញទីពឹងយ៉ាងណាមួយក្នុងនាមរូបដែលប្រព្រឹត្តទៅក្នុងភពទាំង ៣ ដូច្នេះ **អាទីនវញ្ញាណ** ទើបលះបង់នូវអាល័យក្នុងភព ។

១៧ - បដិសង្ខានុបស្សនំ ភាវេន្តោ អប្បដិសង្ខំ បជហាតិ បុគ្គលចម្រើនបញ្ញាកំណត់ដឹងទៀតនូវលក្ខណៈរបស់សង្ខារ ( ក្នុងការលះបង់ភព ) រមែងលះបង់នូវការមិនកំណត់ដឹងទៀត ។

អធិប្បាយ : បដិសង្ខានុបស្សនា គឺ បញ្ញាកំណត់ដឹងទៀត ដើម្បី

លែងចោលនូវសង្ខារ ចាត់ជាបដិសង្ខាញាណ ប្រាកដដល់បុគ្គលដែលបាន សម្រេចនូវ មុញ្ចិតុកាម្យតាញាណហើយ ។

បុគ្គលទូទៅ ដែលមិនឃើញនូវត្រៃលក្ខណ៍ រមែងកើតឆន្ទរាគៈក្នុង សង្ខារ កាលដែលបានជួបប្រសព្វនូវទុក្ខ ដែលជាទុក្ខវេទនាក្តី ការប្រែប្រួលនៃ សុខវេទនាក្តី ឬ ការបែកធ្លាយទៅនៃសង្ខារយ៉ាងណាក្តី ក៏រមែងភ័យខ្លាច ទោមនស្ស តក់ស្លុត ញាប់ញ័រ រវើរវាយជាដើម ដោយមិនអាចលែងចោលនូវ សង្ខារទៅបានឡើយ គឺ នៅមានការប្រកាន់ដោយសេចក្តីជាប់ជំពាក់ ។

បុគ្គលដែលឃើញនូវសង្ខារដោយអំណាចនៃត្រៃលក្ខណ៍ រមែងមិន សម្គាល់ថា សង្ខារគួរឱ្យរីករាយភ្លើតភ្លើនឡើយ មិនសម្គាល់ថា ជាយើង មិន សម្គាល់ថា ជារបស់យើង ហើយក៏មិនសង្ឃឹមឱ្យសង្ខារនោះជាសុខ មិនប្រាថ្នា ឱ្យសង្ខារសាបសូន្យ និងមិនកង្វល់ថាសង្ខារនឹងជាទុក្ខ ដូចជាភាពព្រងើយ គឺ មិនសង្ឃឹម មិនប្រាថ្នា មិនកង្វល់ជាមួយនឹងដុំក្រួស ដុំថ្មផ្សេងៗ ដែលមិនជាប់ ទាក់ទងនឹងខ្លួនដូច្នោះដែរ ។

តាមពិត បុគ្គលដែលផុតចាកអំពីសង្ខារ ដោយពិតប្រាកដ គឺ ព្រះ អរហន្តតែប៉ុណ្ណោះ ។ ប៉ុន្តែបុគ្គលចម្រើនវិបស្សនាសម្រេចនូវ **សង្ខារុបេក្ខា ញាណ** ក៏ត្រូវផុតចាកនូវសង្ខារក្នុងខណៈនៃវិបស្សនាញាណកើតឡើងដែរ ។ ការលែងចោលនូវសង្ខារដោយ **មុញ្ចិតុកាម្យតាញាណ** គឺ នៅមិនទាន់គ្រប់ គ្រាន់ទេ ទើបព្យាយាមកំណត់ដឹងតទៅទៀតដោយ **បដិសង្ខាញាណ** ទើបបាន ផុតអំពីសង្ខារដោយ **សង្ខារុបេក្ខាញាណ** នោះឯង ។

អនុបស្សនានេះ រមែងលះបង់នូវការមិនកំណត់ដឹងទៀត ពោលគឺ លះ

បង់អវិជ្ជាដែលបិទបាំងត្រៃលក្ខណ៍ក្នុងបដិបទា លែងចោលនូវសង្ខារទាំងពួង ។

១៨ – វិវដ្ដានុបស្សនំ ភាវេន្តោ សំយោគាភិនិវេសំ បជហាតិ បុគ្គលចម្រើនបញ្ញា វិលត្រឡប់ចាកសង្ខារទាំងអស់ រមែងលះបង់នូវសេចក្ដីប្រកាន់ក្នុងការប្រកបជាមួយសង្ខារ ។

អធិប្បាយ : **វិវដ្ដានុបស្សនា** បានដល់ សង្ខារុបេក្ខាញាណ និង អនុលោមញ្ញាណ ប្រៀបដូចតំណក់ទឹកនៅលើស្លឹកឈូក ដែលគេផ្អៀងស្លឹកឈូកដូច្នោះឯង ។

កាលដែល **សង្ខារុបេក្ខាញាណ** ចាស់ក្លាហើយ ក៏កើតអនុលោម-ញ្ញាណ បន្តទៅ គោត្រភូញាណ មគ្គញ្ញាណ និង ផលញ្ញាណ រមែងប្រាកដឡើង លែងចោលនូវសង្ខារទាំងអស់ ស្ទុះទៅកាន់ទុក្ខនិរោធ គឺ **ព្រះនិព្វាន** ។

**វិវដ្ដានុបស្សនា** រមែងលះបង់នូវការប្រកាន់ដែលប្រកបដោយសង្ខារ មានកាមរាគសំយោជនៈ និង បដិឃសំយោជនៈជាដើម ។

មហាវិបស្សនា ១៨ នេះ បង្រៀន

ដោយលោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស**